# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៦១

បាលីប្រែ ៧៤ - ៧៥ - ៧៦

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# វិសុទ្ធជនវិលាសិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ អបទាន

# ចតុត្ថភាគ

# ៦១

# បាលីប្រែ ៧៤-៧៥-៧៦



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

*ក្បាលនេះបាត់អបទានមួយវគ្គគឺ យសវគ្គទី ៥៦*

# ក្បាលទី ៦១
# ខុទ្ទកនិកាយ អបទាន
# តតិយភាគ
# អារក្ខទាយកវគ្គ ទី ៣២
# អារក្ខទាយកត្ថេរាបទានទី ១

[ ១១ ] ខ្ញុំបានឲ្យគេធ្វើរបងផង ខ្ញុំបានថ្វាយជនអ្នករក្សាផង ដល់ព្រះមុនីព្រះនាមធម្មទស្សី ទ្រង់ជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈ ដោយសេសសល់នៃកម្មនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអារក្ខទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អារក្ខទាយកត្ថេរាបទាន ។

# ភោជនទាយកត្ថេរាបទានទី ២

[ ១២ ] ព្រះជិនស្រី ទ្រង់មានព្រះជាតិដ៏ល្អ ដូចលំពង់សាលព្រឹក្ស ទ្រង់មានកម្ពស់សមដូចដើមម្រុំ ទ្រង់រុងរឿងសព្វកាល ដូចលំពង់ឥន្ទព្រឹក្ស ឰដ៏អាកាស ។ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយភោជនដល់ព្រះវេស្សភូអង្គនោះ ដែលជាទេវតាក្រៃលែងជាងទេវតា ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះពុទ្ធជាសយម្ភូ ទ្រង់ឈ្នះមារ ទ្រង់អនុមោទនាភោជនទានរបស់ខ្ញុំនោះថា ផលចូរសម្រេចដល់អ្នកក្នុងភពដែលអ្នកកើតចុះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភោជនទាន ។ ក្នុងកប្បទី ២៥ អំពីកប្បនេះ ខ្ញុំបានកើតជា ស្តេចចក្កពត្តិមួយអង្គ ព្រះនាមអមិត្តកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះភោជនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ភោជនទាយកត្ថេរាបទាន ។**

## គតសញ្ញកត្ថេរាបទានទី ៣

[ ១៣ ] ខ្ញុំបានឃើញព្រះជិនស្រី ព្រះនាមសិទ្ធត្ថ ស្តេចពុទ្ធដំណើរទៅកាន់ឋានសួគ៌ ឰដ៏អាកាសដែលមិនមានស្នាមជើង ខ្ញុំបានឃើញនូវចីវរព្រះសម្មាសម្ពុទ្ធដែលខ្យល់បក់ត្រូវហើយ សេចក្តីត្រេកអររបស់ខ្ញុំ ទុកជាគ្រឿងបូជា ព្រោះឃើញដំណើរព្រះមុនីក្នុងខណៈនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគតសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ គតសញ្ញកត្ថេរាបទាន ។**

# អារក្ខទាយកវគ្គ ទី ៣២

## អដ្ឋកថា អារក្ខទាយកត្ថេរាបទាន ជាដើម

[ ១១-១៣ ] *អបទានទី ១ ទី ២ និងទី ៣ ក្នុងអារក្ខទាយកវគ្គទី ៣២ មានអត្ថដ៏ងាយហើយ ។*

*អដ្ឋកថាអារក្ខទាយកត្ថេរាបទានជាដើម ចប់*

# សត្តបទុមិយត្ថេរាបទានទី ៤

[ ១៤ ] ខ្ញុំជាព្រាហ្មណ៍ឈ្មោះនេសាទ នៅទៀបឆ្នេរស្ទឹង បានបោសសម្អាតអាស្រមដោយផ្កាឈូក ។ ខ្ញុំមានសេចក្ដីរីករាយកើតឡើង ព្រោះឃើញព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ ជាលោកនាយក ទ្រង់មានសម្បុរដូចមាស កាលដែលទ្រង់ពុទ្ធដំណើរទៅតាមព្រៃ ។ ខ្ញុំបានក្រោកទទួលព្រះសម្ពុទ្ធ ទ្រង់ជាធ្មេមក្នុងលោក ប្រសើរជាងពួកនរៈ ហើយនាំទៅឯអាស្រម រួចរោយរាយដោយផ្កាឈូក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ៤ ជាតិ ព្រះនាម បាទវរៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តបទុមិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សត្តបទុមិយត្ថេរាបទាន ។**

# អដ្ឋកថា

# សត្តុបទុមិយត្ថេរាបទាន

[ ១៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះថា

បទថា **ជលជគ្គេហិ ឱកិរឹ** សេចក្ដីថា ខ្ញុំបានយកផ្កាទាំងឡាយ មានផ្កាឧប្បលនិងផ្កាឈូកជាដើមយ៉ាងល្អដែលកើតក្នុងទឹកមកបូជា ។

អដ្ឋកថាសត្តុបទុមិយត្ថេរាបទាន ចប់

# បុប្ផាសនទាយកត្ថេរាបទានទី ៥

[ ១៥ ] ( ខ្ញុំបានឃើញ ) នូវព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ទ្រង់ឈ្នះមារ ទ្រង់មានសម្បុរដូចមាស ឬដូចព្រះអាទិត្យមានរស្មីច្រើន ដែលស្តេចយាង ក្នុងទីជិតខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លា បានក្រោកទទួលព្រះសម្ពុទ្ធអង្គនោះ ហើយនិមន្តឲ្យស្តេចចូលទៅឯអាស្រម ហើយថ្វាយអាសនៈផ្កា ។ កាលនោះ ខ្ញុំមានសេចក្តីរីករាយកើតឡើង ទើបផ្គងអញ្ជលី ធ្វើចិត្តឲ្យជ្រះថ្លាចំពោះព្រះពុទ្ធ ហើយបង្អោនចិត្តទៅរកអំពើនោះថា បុណ្យណាដែលខ្ញុំបានធ្វើហើយចំពោះព្រះសយម្ភូ ទ្រង់ឈ្នះមារ ខ្ញុំសូមឲ្យជាអ្នកប្រាសចាកមន្ទិល ក្នុងព្រះពុទ្ធសាសនា ដោយកុសលកម្មទាំងអស់នោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយអាសនៈផ្កា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផាសនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បុប្ផាសនទាយកត្ថេរាបទាន ។**

# អដ្ឋកថា

# បុប្ផសនទាយកត្ថេរាបទាន

[ ១៥ ] *អបទានទី ៥ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាបុប្ផសនទាយកត្ថេរាបទាន ចប់*

# អាសនត្ថវិកត្ថេរាបទាន ទី ៦

[ ១៦ ] កាលនោះ ខ្ញុំដើរសំដៅទៅឯឧត្តមចេតិយនៃព្រះលោកពន្ធុ ព្រះនាមសិខី ដែលនៅក្នុងព្រៃធំ ។ កាលខ្ញុំដើរចេញមកអំពីព្រៃវិញ ក៏បានឃើញព្រះពុទ្ធគង់លើសីហាសនៈ[១] ខ្ញុំធ្វើសំពត់ឆៀងស្មាម្ខាង ហើយធ្វើអញ្ជលីសរសើរព្រះលោកនាយក ។ លុះខ្ញុំសរសើរព្រះសម្ពុទ្ធអគ្គនាយកក្នុងលោកអស់ចំណែកមួយថ្ងៃ ជាអ្នកមានចិត្តរីករាយ បានពោលវាចានេះថា បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គមានព្យាយាមធំ ជាចម្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈ ព្រះអង្គជាសព្វញ្ញុពុទ្ធ ។ លុះខ្ញុំបានសរសើរព្រះសម្ពុទ្ធព្រះនាមសិខី ដោយការធ្វើនិមិត្តហើយ ក៏ថ្វាយបង្គំព្រះអង្គដែលទ្រង់កំពុងគង់នៅ រួចដើរចេញទៅ ឈមមុខទៅកាន់ឧត្តរទិស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានសរសើរព្រះពុទ្ធ ទ្រង់ប្រសើរជាងពួកអ្នកប្រាជ្ញ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើត ជាស្តេចចក្កពត្តិ ៧ ជាតិ ព្រះនាមអតុល្យៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាសនត្ថវិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

### ចប់ អាសនត្ថវិកត្ថេរាបទាន ។

---

១-គួរប្រែថា ក៏បានឃើញសីហាសនៈ ព្រោះព្រះមានព្រះភាគបរិនិព្វានហើយ ( អដ្ឋកថា ) ។

# អដ្ឋកថា

# អាសនត្ថវិកត្ថេរាបទាន

[ ១៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះថា បទថា **ចេតិយំ ឧត្តមំ នាម សិខិនោ លោកពន្ធុនោ** បានដល់ ព្រះចេតិយឈ្មោះថា **ឧត្តម** របស់ព្រះមានព្រះភាគ ព្រះនាមថាសិខី ជាផៅពង្ស គឺញាតិរបស់លោកទាំង ៣ ភ្ជាប់សេចក្ដីថា ដែលជាព្រៃធំ គឺក្នុងព្រៃធំដែលប្រាសចាកមនុស្សសញ្ចរទៅមក មិនមានមនុស្សច្រឡូកច្រឡំ ។ បទថា **អន្ធាហិណ្ឌាមហំ តទា** សេចក្ដីថា ក្នុងកាលនោះ ខ្ញុំជាបុគ្គលខ្វាក់ ព្រោះវង្វេងផ្លូវក្នុងព្រៃ មិនមែនខ្វះភ្នែក សេចក្ដីថា ខ្ញុំត្រាច់ស្វែងរកផ្លូវ ។ បទថា **បវនា និក្ខមន្តេន** សេចក្ដីថា ខ្ញុំចេញចាកព្រៃធំបានជួបសីហាសនៈ គឺអាសនៈដ៏ប្រសើរ មួយ៉ាងទៀត សេចក្ដីថា ខ្ញុំបានឃើញអាសនៈរបស់ព្រះមានព្រះភាគដូចសីហៈ ។ បទថា **ឯកំសំ អញ្ជលឹ កត្វា** សេចក្ដីថា ខ្ញុំធ្វើសំពត់ឆៀងស្មាឆ្វេង ហើយផ្គងអញ្ជលីលើសិរសា ។ បទថា **សន្ថវិំ លោក-នាយកំ** សេចក្ដីថា ខ្ញុំបានធ្វើការសរសើរព្រះលោកនាយកអង្គនោះ ដែលញុំាងសត្វលោកទាំង ៣ ឲ្យដល់ព្រះនិព្វាន ។

អដ្ឋកថាអាសនត្ថវិកត្ថេរាបទាន ចប់

# សទ្ទសញ្ញកត្ថេរាបទានទី ៧

[ ១៧ ] ព្រះពុទ្ធព្រះនាមសុទស្សនៈ មានព្យាយាមធំ ទ្រង់សម្តែងនូវអមតបទ មានពួកសាវ័កចោមរោម ទ្រង់គង់នៅក្នុងផ្ទះដ៏ប្រសើរ ទ្រង់សង្គ្រោះមហាជនដោយព្រះវាចាដ៏ពីរោះ សំឡេងសរសើរព្រះពុទ្ធផ្សាយទៅពេញទេវលោកនិងមនុស្សលោក ។ ខ្ញុំបានស្តាប់ពាក្យឃោសនាហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លា ក្នុងសំឡេងសរសើរព្រះមហេសី ទ្រង់ញុំាងប្រយោជន៍ឲ្យសម្រេច ទើបខ្ញុំថ្វាយបង្គំព្រះលោកនាយក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ សទ្ទសញ្ញកត្ថេរាបទាន ។

## អដ្ឋកថា

## សទ្ធសញ្ញកត្ថេរាបទាន

[ ១៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា បទថា **សុទស្សនោ មហាវីរោ** ក្លាប់សេចក្តីថា ព្រះមានព្រះភាគ ព្រះនាមថា សិទ្ធត្ថៈ ទ្រង់មានព្រះរូបឆោមល្អគួរមើល គឺមានព្រះរូបគួរពេញចិត្ត ទ្រង់មានព្រះសរីរៈដល់ព្រមដោយមហាបុរិសលក្ខណៈ ៣២ ទ្រង់មានវិរិយៈច្រើន ។ បទថា **វសតិយរមុត្តមេ** សេចក្តីថា គង់ក្នុងវិហារដ៏ប្រសើរ ។

អដ្ឋកថាសទ្ធសញ្ញកត្ថេរាបទាន ចប់

# តិរំសិយត្ថេរាបទានទី ៨

[ ១៨ ] ( ខ្ញុំបានឃើញ ) នូវព្រះសិទ្ធត្ថ ទ្រង់ញុំាងទិសទាំងឡាយឲ្យភ្លឺ គង់នៅត្រង់ចន្លោះភ្នំ ជាអភិជាតិ ទ្រង់មានរស្មីរុងរឿង ដូចកេសររាជសីហ៍ ឬដូចគំនរភ្លើងលើភ្នំ ។ ខ្ញុំមានបីតិកើតឡើង ព្រោះឃើញពន្លឺព្រះអាទិត្យផង ពន្លឺព្រះចន្ទផង ពន្លឺព្រះពុទ្ធផង មានសភាពដូចគ្នា ។ ខ្ញុំឃើញពន្លឺទាំង ៣ ឃើញសាវកដ៏ឧត្តម ហើយធ្វើស្បែកខ្លាឃ្មុំចៀងស្មាម្ខាង រួចសរសើរព្រះលោកនាយក ។ សេចក្តីពិតថា ពន្លឺដ៏វិសេស ៣ យ៉ាង ក្នុងលោក គឺព្រះចន្ទ ១ ព្រះអាទិត្យ ១ ព្រះពុទ្ធជាលោកនាយក ១ ជាពន្លឺកម្ចាត់បង់នូវងងឹតក្នុងលោក ។ ខ្ញុំបានអាងឧបមា ហើយសរសើរព្រះមហាមុនី ព្រោះខ្ញុំបានសរ-សើរព្រះពុទ្ធ ក៏រីករាយក្នុងឋានសួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានសរសើរពុទ្ធគុណ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ ក្នុងកប្បទី ៦១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិមួយអង្គ ព្រះនាមញាណវរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិរំសិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តិរំសិយត្ថេរាបទាន ។**

# ឆាលិបុប្ផិយត្ថេរាបទានទី ៩

[ ១៩ ] កាលនោះ ខ្ញុំបានកើតជាអ្នកក្លួរាស់ នៅក្បែរត្រើយទន្លេសិន្ធុ បានប្រកបក្នុងការងាររបស់ជនដទៃ ចិញ្ចឹមជីវិតដោយថ្លៃឈ្នួលរបស់ជនដទៃ ។ កាលខ្ញុំដើរទៅតាមទន្លេសិន្ធុ ក៏បានឃើញព្រះជិនស្រី ព្រះនាមសិទ្ធត្ថ ទ្រង់គង់នៅដោយសមាធិ ទ្រង់មានរស្មីរុងរឿងដូចផ្កាឈូករីក ។ កាលនោះ ខ្ញុំបានកាត់ផ្កាឈូក ៧ ទាំងទង ដាក់ប្រទូលលើក្បាល នាំយកទៅបូជាព្រះសម្ពុទ្ធជាព្រះអាទិច្ចពន្ធុ ។ ខ្ញុំបានចូលទៅជិតព្រះសម្ពុទ្ធ ដែលទ្រង់មានសម្បុរដូចមាស ទ្រង់គង់ស្ងឹងស្ងាធិនៅជិតត្រើយទន្លេ ព្រះអង្គដូចជារីមាតង្គៈចុះប្រេង ៣ អន្លើ ដែលគ្រុបសង្កត់បានដោយកម្រ ទ្រង់មានបញ្ញាចាស់ មានឥន្ទ្រិយអប់រំហើយ ទើបខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសាស្តាជាម្ចាស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនាលិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ នាលិបុប្ផិយត្ថេរាបទាន ។**

# កុមុទមាលិយត្ថេរាបទានទី ១០

[ ២០ ] ខ្ញុំយកកម្រងផ្កាកុមុទ ទៅបូជាព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវិបស្សី ជាឧសភៈដ៏ប្រសើរ ទ្រង់មានព្យាយាម ជាអ្នកស្វែងរកនូវគុណដ៏ធំ ទ្រង់ឈ្នះមារ ជាមហាវីរបុរស ដូចរាជសីហ៍ ជាអភិជាតិ ទ្រង់គួរទទួលគ្រឿងបូជា កំពុងពុទ្ធដំណើរក្នុងប្រក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមុទមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ កុមុទមាលិយត្ថេរាបទាន ។**

## ឧទ្ទាន

អារក្ខទាយកត្ថេរាបទាន ១ ភោជនទាយកត្ថេរាបទាន ១ គតសញ្ញកត្ថេរាបទាន ១ បទុមិយត្ថេរាបទាន ១ បុប្ផាសនទាយកត្ថេរាបទាន ១ អាសនត្ថវិកត្ថេរាបទាន ១ សទ្ទសញ្ញកត្ថេរាបទាន ១ តិរំសិយត្ថេរាបទាន ១ នាលិបុប្ផិយត្ថេរាបទាន ១ កុមុទមាលិយត្ថេរាបទាន ១ មានគាថា ៥៧ ។

**ចប់ អារក្ខទាយកវគ្គ ទី ៣២ ។**

# អដ្ឋកថា

# តិរំសិយត្ថេរាបទាន ជាដើម

*[ ១៨ ] អបទានទី ៨ ទី ៩ និងទី ១០ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាតិរំសិយត្ថេរាបទានជាដើម ចប់*

*អារក្ខទាយកវគ្គ ទី ៣២ ចប់*

# ឧម្មាបុប្ផិយវគ្គ ទី ៣៣

## ឧម្មាបុប្ផិយត្ថេរាបទានទី ១

[ ២១ ] ខ្ញុំបានឃើញព្រះសិទ្ធត្ថប្រសើរជាងពួកនរៈ ទ្រង់មានព្រះទ័យតម្កល់មាំខ្ជាប់ខ្ជួន ទ្រង់ឈ្នះមារ ទ្រង់ចូលសមាធិ ។ ខ្ញុំកាន់យកផ្កា ត្រកៀតបូជាព្រះពុទ្ធ ផ្កាទាំងអស់មានក្បាលតែមួយ មានទងឡើងលើ មានមុខចុះក្រោម វិចិត្រល្អ ដូចជាកម្រោលផ្កា ប្រតិស្ឋានព្ធដ៏អាកាស ខ្ញុំបានកើតក្នុងឋានតុសិត ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥៥ អំពីកប្បនេះ ក្នុងកាលនោះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិមួយអង្គព្រះនាមសមន្តច្ឆទនៈ ជាធំលើផែនដី ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧម្មាបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧម្មាបុប្ផិយត្ថេរាបទាន ។**

# បុឡិនបូជកត្ថេរាបទានទី ២

[ ២២ ] ខ្ញុំបានឃើញព្រះពុទ្ធ ប្រសើរជាងនរៈ ទ្រង់យាងយាសដូចលំពង់ថ្វាន់ ឬដូចនិសភអាជានេយ្យ ទ្រង់រុងរឿង ភ្លឺស្វាង ដូចផ្កាយព្រឹក ។ ខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសាស្តា ហើយសរសើរព្រះសាស្តា ខ្ញុំរីករាយដោយកុសលកម្មរបស់ខ្លួន ។ ខ្ញុំបានកើបខ្សាច់ដ៏ស្អាត ដក់មួយថ្នក់ យកទៅរោយរាយត្រង់ផ្លូវដែលព្រះមហេសី ព្រះនាមវិបស្សី ស្តេចយាងទៅ ។ លំដាប់នោះខ្ញុំមានចិត្តជ្រះថ្លា បានចាក់ខ្សាច់ពាក់កណ្តាល ត្រង់បង្អា សម្រាប់សម្រាកក្នុងវេលាថ្ងៃនៃព្រះពុទ្ធ ទ្រង់ជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានរោយរាយខ្សាច់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការរោយរាយខ្សាច់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិនបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បុឡិនបូជកត្ថេរាបទាន ។**

# ហាសជនកត្ថេរាបទានទី ៣

[ ២៣ ] ខ្ញុំបានឃើញបំសុកូលិកចីវរ របស់ព្រះសាស្តា ដែលព្យួរលើចុងឈើ ហើយផ្គងអញ្ជលីបន្ទឹវាចាឡើងយ៉ាងខ្លាំង ។ សេចក្តីរីករាយ ក៏កើតមានដល់ខ្ញុំ ព្រោះបានឃើញអំពីចម្ងាយ ទើបខ្ញុំផ្គងអញ្ជលីញ៉ាំងចិត្ត ឲ្យជ្រះថ្លាក្រៃលែង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះហាសជនកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ហាសជនកត្ថេរាបទាន ។**

# យញ្ញសាមិកត្ថេរាបទានទី ៤

[ ២៤ ] ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីឆ្នាំកំណើត បានចេះចប់មន្ត្រ បានទ្រទ្រង់វង្សត្រកូល ខ្ញុំបានលើកតម្កើងយញ្ញវិធី ។ កាលនោះ ខ្ញុំនាំយកសត្វចិញ្ចឹម ៨ ម៉ឺន ៤ ពាន់ មកចងក្រៀកនឹងសសរខ្ទឹម បម្រុងទុកនឹងសម្លាប់បូជាយញ្ញ ។ ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ ទ្រង់ញុំាងប្រយោជន៍ទាំងអស់ ឲ្យសម្រេច ទ្រង់ទម្លាក់ចោលនូវរបស់មិនជាប្រយោជន៍ក្នុងត្រៃលោក ទ្រង់ដូចជាមុខគប់ភ្លើងត្រូវខ្យល់បក់ ឬដូចរងើកឧសគគីរ ពុំនោះសោត ដូចព្រះអាទិត្យដែលទើបនឹងរះឡើង ឬដូចព្រះចន្ទពេញវង់ ទ្រង់ចូលមកជិតខ្ញុំ ហើយត្រាស់ព្រះពុទ្ធដីកានេះថា នែកុមារ ការមិនបៀតបៀនសត្វទាំងអស់ រមែងពេញចិត្តតថាគត ការវៀរចាកការលួច ការប្រព្រឹត្តកន្លង ( បរទារកម្ម ) និងការផឹកទឹកស្រវឹង ១ សេចក្តីត្រេកអរចំពោះការប្រព្រឹត្តស្មើ ១ ភាពជាពហុស្សូត ១ កតញ្ញុតា ១ ធម៌ទាំងនេះ បណ្ឌិតសរសើរក្នុងបច្ចុប្បន្ន ទាំងបរលោក ។ អ្នកចូរអប់រំធម៌ទាំងនេះ ហើយត្រេកអរនឹងប្រយោជន៍សព្វសត្វ ចូរញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះពុទ្ធ ហើយអប់រំនូវមគ្គដ៏ប្រសើរ ។ លុះព្រះសព្វញ្ញូ ជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ទ្រង់ត្រាស់នូវភាសិត ប្រៀនប្រដៅខ្ញុំយ៉ាងនេះហើយ ទើបស្តេចពុទ្ធដំណើរទៅកាន់អាកាសទៅ ។ ខ្ញុំបានជម្រះចិត្តក្នុងកាលមុន ហើយញុំាងចិត្តឲ្យជ្រះថ្លា ក្នុងកាលជាខាងក្រោយ ក៏បានចូលទៅកើតក្នុងឋានតុសិត ដោយការធ្វើចិត្តឲ្យជ្រះថ្លានោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ

៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះយញ្ញសាមិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ យញ្ញសាមិកត្ថេរាបទាន ។

# និមិត្តសញ្ញកត្ថេរាបទានទី ៩

[ ២៥ ] ខ្ញុំនៅក្នុងអាស្រម ទៀបឆ្នេរស្ទឹងចន្ទភាគា បានក្រឡេកឃើញម្រឹគមានសម្បុរដូចមាស ដែលកំពុងត្រាច់ទៅក្នុងព្រៃធំ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាចំពោះម្រឹគ ហើយនឹកដល់ព្រះសម្ពុទ្ធជាច្បងក្នុងលោក ទាំងនឹកដល់ព្រះពុទ្ធដទៃៗទៀតដោយចិត្តជ្រះថ្លានោះថា ព្រះពុទ្ធទាំងឡាយណា ដែលកន្លងទៅហើយក្តី ដែលកំពុងត្រាស់ដឹងក្នុងបច្ចុប្បន្ននេះក្តី ដែលនឹងមកត្រាស់ដឹងក្នុងអនាគតកាលក្តី ព្រះពុទ្ធទាំង ៣ ពួកនោះ រុងរឿងដូចជាស្តេចម្រឹគយ៉ាងនេះឯង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិមួយព្រះអង្គ ព្រះនាមអរញ្ញសត្ត ជាម្ចាស់ផែនដី ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤

វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនិមិត្តសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ និមិត្តសញ្ញកត្ថេរាបទាន ។

## អន្នសំសាវកត្ថេរាបទានទី ៦

[ ២៦ ] ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស ប្រាកដស្មើគ្រឿងបូជាមាស មានលក្ខណៈ ៣២ ប្រការដែលកំពុងទ្រង់ពុទ្ធដំណើរទៅត្រង់រានផ្សារ ។ ខ្ញុំនាំព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ទ្រង់ញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេច មិនញាប់ញ័រដោយកិលេស ទ្រង់ឈ្នះមារ ហើយខ្ញុំញ៉ាំងព្រះមហាមុនីអង្គនោះ ឲ្យសោយចង្ហាន់ ។ កាលនោះ ព្រះមុនីទ្រង់ប្រកបដោយករុណា ទ្រង់ញ៉ាំងខ្ញុំឲ្យភ្លឺស្វាងក្នុងលោក ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាចំពោះព្រះពុទ្ធហើយបានរីករាយក្នុងឋានសួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការថ្វាយចង្ហាន់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអន្ទសំសាវកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អន្ទសំសាវកត្ថេរាបទាន ។

# ឧម្មាបុប្ផិយវគ្គ ទី ៣៣

## អដ្ឋកថាឧម្មាបុប្ផិយត្ថេរាបទាន ជាដើម

[ ២១-២៦ ] អបទានទី ១ ទី ២ ទី ៣ ទី ៤ ទី ៥ និងទី ៦ ក្នុងឧម្មាបុប្ផិយវគ្គទី ៣៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាឧម្មាបុប្ផិយត្ថេរាបទានជាដើម ចប់

# និគ្គុណ្ឋិបុប្ផិយត្ថេរាបទានទី ៧

[ ២៧ ] កាលណាទេវតានឹងច្យុតចាកពួកទេវតា ដោយអស់អាយុ សំឡេង ៣ យ៉ាងរបស់ពួកទេវតាអ្នករីករាយតាម តែងលាន់ឮឡើងថា ម្នាល អ្នកដ៏ចម្រើន បើអ្នកចុះចាកទេវលោកនេះ ចូរទៅកាន់សុគតិ កើតជាមួយនឹងពួកមនុស្សចុះ លុះអ្នកបានកើតជាមនុស្សហើយ ចូរបាននូវសទ្ធាដ៏ប្រសើរចំពោះព្រះសទ្ធម្ម សទ្ធានោះដែលអ្នកតម្កល់មាំហើយ នឹងកើតជាឫសខ្ជាប់ខ្ជួន មិនកម្រើកក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគទ្រង់សម្តែងល្អហើយ ដរាបដល់អស់ជីវិត ។ អ្នកចូរធ្វើនូវកុសលដោយកាយ ចូរធ្វើកុសលដោយវាចាឲ្យច្រើន ចូរធ្វើកុសលដោយចិត្ត មិនមានព្យាបាទ មិនមានឧបធិ ។ អ្នកចូរធ្វើបុណ្យឲ្យច្រើនជាងនោះ គឺធ្វើបុណ្យនោះឲ្យច្រើន ដោយការបរិច្ចាគទាន ហើយតាំងនៅក្នុងព្រហ្មចរិយៈ គឺព្រះសទ្ធម្មដ៏ប្រសើរដទៃទៀតចុះ ។ ម្នាលទេវតា អ្នកចូរមក ( កាន់ទេវលោក ) នេះវិញឲ្យរឿយៗ ដោយសេចក្តីអនុគ្រោះនេះ ដូចពួកអ្នកប្រាជ្ញតែងត្រេកអរកេទេវតាដ៏ប្រសើរដែលច្យុត ។ កាលនោះ ខ្ញុំមានសេចក្តីតក់ស្លុត ក្នុងទីប្រជុំពួកទេវតាថា អាត្មាអញច្យុតចាកទេវលោកនេះ នឹងទៅកាន់កំណើតណាអេះ ។ ស្រាប់តែមានសមណៈមានឥន្ទ្រិយអប់រំហើយ ជ្រាបសេចក្តីសង្វេគរបស់ខ្ញុំ សមណៈនោះ មានសេចក្តីប្រាថ្នានឹងស្រង់ខ្ញុំ បានមកកាន់សំណាក់ខ្ញុំ ។ កាលនោះ សាវករបស់ព្រះបទុមុត្តរៈ ព្រះនាមសុមនៈ បានប្រៀនប្រដៅនូវអត្ថនិងធម៌ ហើយញុំាងខ្ញុំឲ្យសង្វេគ ។

**ចប់ ភាណវារៈ ទី ១២ ។**

ខ្ញុំបានស្តាប់ពាក្យនៃព្រះថេរៈនោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធជាម្ចាស់ ខ្ញុំថ្វាយបង្គំព្រះថេរៈ ជាអ្នកប្រាជ្ញអង្គនោះ មិនយូរប៉ុន្មាន ខ្ញុំក៏ធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំនោះត្រូវកុសលមូលដាស់តឿន ក៏បានទៅកើតក្នុងទីនោះដដែល កាលខ្ញុំនៅក្នុងផ្ទៃមាតា កុសលក៏ទ្រទ្រង់ខ្ញុំក្នុងផ្ទៃនៃមាតាទៀត ។ លុះខ្ញុំច្យុតចាកកាយនោះ ក៏បានទៅកើតក្នុងឋានត្រៃត្រិង្ស កាលនោះខ្ញុំមិនបានឃើញទោមនស្ស ក្នុងរវាងនោះសោះ ។ ខ្ញុំច្យុតចាកឋានតាវត្តិង្សវិញ បានចុះមកកាន់ផ្ទៃមាតា លុះចេញចាកផ្ទៃហើយ ខ្ញុំបានស្គាល់សេចក្តីទុក្ខតែបន្តិចបន្តួច ។ ខ្ញុំមានអាយុ ៧ ឆ្នាំ បានចូលទៅកាន់អារាមរបស់ព្រះមានព្រះភាគ ព្រះនាមគោតមជាសក្យបុត្ត ព្រះអង្គប្រកបដោយតាទិគុណ ។ ខ្ញុំបានឃើញពួកភិក្ខុ ក្នុងអារាមនោះ លោកអ្នកធ្វើតាម ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ក្នុងពុទ្ធដីកាជាប្រធាន គឺសាសនាដែលទូលំទូលាយ មានជនចុះចូលច្រើន ។ ក្នុងពេលនោះ ព្រះរាជាក្នុងក្រុងសាវត្ថីព្រះនាមកោសលស្តេចធ្វើរាជដំណើរទៅកាន់ដើមពោធិព្រឹក្សដ៏ឧត្តម ដោយរាជរថដែលទឹមដំរីដ៏ប្រសើរ ។ លុះខ្ញុំឃើញដំរីដ៏ប្រសើរនៃព្រះរាជាអង្គនោះ ក៏នឹកឃើញបុព្វកម្មរបស់ខ្លួន បានផ្គងអញ្ជលី ដើរទៅក្នុងសម័យនោះដែរ ។ ខ្ញុំបានអាយុ ៧ ឆ្នាំ ក៏បានចូលទៅកាន់ផ្នួសក្នុងសាសនា ឯព្រះអានន្ទជាសាវក អ្នកមានគតិល្អ មានប្រាជ្ញាខ្ជាប់ខ្ជួន មានស្មារតី ជាពហុស្សូត មានសេចក្តីរុងរឿង តែងបម្រើព្រះសម្ពុទ្ធ លោកញ៉ាំងព្រះទ័យព្រះរាជាឲ្យជ្រះថ្លា ហើយញ៉ាំងព្រះរាជាឲ្យប្រគល់កាយថ្វាយខ្លួន ( ជាឧបាសកក្នុងពុទ្ធសាសនា ) ។ ខ្ញុំបានស្តាប់

ធម៌ព្រះអានន្ទត្ថេរនោះ ហើយក៏រឭកឃើញបុព្វកម្ម ខ្ញុំបានសម្រេចព្រះអរហត្ត ទាំងកំពុងឈរក្នុងទីនោះឯង ។ បន្ទាប់មក ខ្ញុំធ្វើចីវរឆៀងស្មាម្ខាង ធ្វើអញ្ជលីលើសិរ្យៈ ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបន្លឺវាចានេះថា បពិត្រព្រះនាសកៈ ជាច្បងក្នុងលោក ជាធំជាងសត្វជើងពីរ ក្នុងភពមុន ខ្ញុំបានយកផ្កានិគ្គុណ្ឌិព្រឹក្ស ទៅតម្កល់ទុកហើយលើអាសនៈដ៏ប្រសើរ ថ្វាយព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ជាធំជាងសត្វជើងពីរ ព្រះអង្គប្រកបដោយតាទិគុណ ឥឡូវនេះ ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់ បានដល់នូវអចលដ្ឋាន គឺព្រះនិព្វានដោយកុសលកម្មនោះ ។ ក្នុងកប្បទី ២៥.០០០ ខ្ញុំបានកើតជាស្តេច ជាអធិបតីលើមនុស្ស ឋិតនៅអស់ ៨ អព្ទុទៈ និងនិរព្ទុទៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនិគ្គុណ្ឌិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ។

# អដ្ឋកថា

# និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន

[ ២៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា បទថា **សមយំ អគមាសហំ** សេចក្តីថា ខ្ញុំបានទៅរកពួកជនគឺស្ថានទីដែលមនុស្សមកប្រជុំគ្នា ។ បទថា **អព្ពុទនិរព្ពុទានិ** សេចក្តីថា ក្នុងកប្បទី ២៥.០០០ អំពីកប្បនេះទៅ បានជាស្តេចចក្កពត្តិក្នុងមួយកប្ប ៨ ដង មានព្រះជន្មាយុច្រើន ដល់នូវអព្ពុទៈក៏មាន និរព្ពុទៈក៏មាន តាមអាយុ ព្រោះលោកបានពោលទុកថា មួយរយសែនបកោដិ[1]ជា ១ អព្ពុទៈ មួយរយសែនអព្ពុទៈ ជា ១ និរព្ពុទៈ ដូច្នេះ ។

### អដ្ឋកថានិគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ចប់

---

១-មួយបកោដិសរសេរលេខ ១ ហើយថែមលេខសូន្យ ១៤ ។

# សុមនាវេឡិយត្ថេរាបទានទី ៨

[ ២៨ ] ជនទាំងពួងមកប្រជុំគ្នា ធ្វើមហាបូជាចំពោះព្រះមានព្រះភាគ ព្រះនាមវេស្សភូ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ ។ កាលនោះ ខ្ញុំយកដុំបាយអ ធ្វើជាភួងផ្កាម្លិះដាក់បូជា ពីមុខអាសនៈ ដ៏ប្រសើរ ។ ជនទាំងអស់មកប្រជុំគ្នា ក្រឡេកមើលផ្កាដ៏ប្រសើរនោះ ហើយគិតគ្នាថា អ្នកណាបានបូជាផ្កានេះ ចំពោះព្រះពុទ្ធដ៏ប្រសើរ ប្រកបដោយតាទិគុណ ។ ហេតុតែចិត្តជ្រះថ្លានោះ ខ្ញុំបានទៅកើតឯឋាននិម្មានរតី ទទួលរងកុសលរបស់ខ្លួន ដែលខ្លួនធ្វើទុកល្អហើយក្នុងកាលមុន ។ ខ្ញុំទៅយកកំណើតណាៗ ទោះបីជាទេវតាឬជាមនុស្ស រមែងជាទីស្រឡាញ់របស់ជនទាំងពួង នេះជាផលនៃការបូជាផ្កា ។ ខ្ញុំពុំស្គាល់នូវការតិះដៀល ចំពោះពួកលោក ដែលមានសេចក្ដីសង្រួម និងមានតបធម៌ដែលខ្ញុំធ្វើហើយដោយកាយវាចា ឬដោយចិត្តឡើយ ។ ដោយសុចរិតនោះផង ដោយការតម្កល់នូវចិត្តនោះផង ខ្ញុំក៏ត្រូវអ្នកទាំងពួងបូជាហើយ នេះជាផលនៃការមិនតិះដៀល ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្ដេចចក្កពត្តិព្រះនាមសហស្សារៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនាវេឡិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សុមនាវេឡិយត្ថេរាបទាន ។**

# បុប្ផច្ឆត្តិយត្ថេរាបទានទី ៩

[ ២៩ ] កាលព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ ទ្រង់ប្រកាសនូវសច្ចៈ ញុំាំងពួកសត្វឲ្យរំលត់ទុក្ខ ខ្ញុំបានយកផ្កាឈូកដែលដុះក្នុងទឹក ជាទីរីករាយនៃចិត្ត ធ្វើជាឆត្រផ្កា ហើយបូជា ព្រះសម្ពុទ្ធ ។ ឯព្រះសាស្តា ព្រះនាមសិទ្ធត្ថ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់ឋិតនៅក្នុងពួកភិក្ខុ ហើយសម្តែងនូវគាថា ទាំងនេះថា បុគ្គលណា ញុំាំងចិត្តឲ្យជ្រះថ្លា បានបាំងឆត្រផ្កា ថ្វាយតថាគត បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ ដោយចិត្តជ្រះថ្លានោះឡើយ ។ លុះព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ ជាលោកនាយក ទ្រង់ត្រាស់គាថានេះហើយ ទ្រង់បញ្ជូនបរិស័ទទៅ រួចហើយស្តេចពុទ្ធដំណើរទៅកាន់អាកាស ដែលជាទីរីករាយនៃសត្វស្វាប ។ កាលព្រះសម្ពុទ្ធជាទេវតារបស់មនុស្ស ទ្រង់ក្រោកឡើង ស្វេតច្ឆត្រក៏អណ្តែតឡើង ឆត្រដ៏ឧត្តម បានអណ្តែតទៅពីខាងមុខ ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាឆត្រ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រផ្កា ។ ក្នុងកប្បទី ៧៤ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ មានព្រះនាមជលសិខៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផច្ឆត្តិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បុប្ផច្ឆត្តិយត្ថេរាបទាន ។**

# សបរិវារច្ឆត្តទាយកត្ថេរាបទានទី ១០

[ ៣០ ] ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់បង្អុរនូវភ្លៀងគឺធម៌ ដូចជាទឹកភ្លៀងបង្អុរចុះអំពីអាកាស ។ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធអង្គនោះ កំពុងសម្តែងអមតបទ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយបានទៅកាន់ផ្ទះរបស់ខ្លួនវិញ ។ ខ្ញុំកាន់ឆត្រដែលស្អិតស្អាងហើយ ដើរចូលទៅរកព្រះសម្ពុទ្ធដ៏ប្រសើរ ជាងពួកនរៈ ខ្ញុំជាអ្នកមានចិត្តរីករាយ បានលើកឡើង ( នូវឆត្រ ) ទៅឰដ៏អាកាស ។ ( ឆត្រនោះមានលម្អ ) ដូចជាយានដែលជាងផ្តុំស្រួលហើយ ឬដូចសាវ័កជាឆ្នើម ដែលមានឥន្ទ្រិយទូន្មានល្អហើយ អណ្តែតទៅរកព្រះសម្ពុទ្ធ ហើយប្រតិស្ឋានទៅលើព្រះសិរ្សៈ ។ ព្រះពុទ្ធអគ្គនាយកក្នុងលោក ទ្រង់មានសេចក្តីអនុគ្រោះ ប្រកបដោយសេចក្តីករុណា ទ្រង់គង់នៅក្នុងពួកភិក្ខុ ហើយសម្តែងនូវគាថាទាំងនេះថា បុគ្គលណាបានថ្វាយឆត្រនេះ ដែលតាក់តែងគួរជាទីរីករាយនៃចិត្ត បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ ដោយចិត្តជ្រះថ្លានោះឡើយ ។ បុគ្គលនោះនឹងបានជាទេវរាជក្នុងទេវលោកអស់វារៈ ៧ ដង នឹងបានជាស្តេចចក្កពត្តិ ៣២ ដង ។ នៅមួយសែនកប្បទៀតនឹងមានព្រះសាស្តាព្រះនាមគោតមៈ កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងមកត្រាស់ដឹងក្នុងលោក បុគ្គលនោះនឹងបានជាធម្មទាយាទ ជាឱរស ជាធម្មនិម្មិតរបស់ព្រះគោតមនោះ នឹងកំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ហើយនឹងបរិនិព្វាន ។ ខ្ញុំដឹងនូវព្រះវាចាដ៏អង់អាច ដែលព្រះសម្ពុទ្ធសម្តែងហើយ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ធ្វើសេចក្តីរីករាយឲ្យកើតឡើង យ៉ាងខ្លាំង ។ ខ្ញុំលះបង់

កំណើតមនុស្សហើយ ក៏បានទៅកាន់កំណើតជាទិព្វ វិមានរបស់ខ្ញុំ ឧត្តមខ្ពស់ត្រដែត ជាទីរីករាយនៃចិត្ត ។ កាលខ្ញុំចេញពីវិមាន គេរមែងបាំងស្វេតច្ឆត្រឲ្យខ្ញុំបានសញ្ញាក្នុងកាលនោះ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំច្យុតចាកទេវលោកមកកើតជាមនុស្ស បានជាស្តេចចក្កពត្តិ ៣៦ ជាតិ ។ ខ្ញុំច្យុតចាកកាយនោះ មកកាន់បុរីឈ្មោះតាវត្តិង្ស ហើយអន្ទោលទៅមកតាមលំដាប់ ក៏បានមកកាន់កំណើតមនុស្សនេះទៀត ។ ពួកទេវតាបាំងស្វេតច្ឆត្រឲ្យខ្ញុំ ខ្ញុំកាលដែលចុះកាន់ផ្ទៃនៃមាតា ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើតក៏បានចូលទៅកាន់ផ្នួស ។ ព្រាហ្មណ៍ឈ្មោះសុនន្ទ ជាអ្នកចេះចប់មន្ត្រ ព្រាហ្មណ៍នោះ កាន់យកឆត្រជាវិការៈនៃកែវផ្ទេក ប្រគេនដល់អគ្គសាវក ។ ព្រះសារីបុត្ត ជាអគ្គសាវក ជាអ្នកមានព្យាយាមធំ មានថ្វីព្រះឱស្ឋដ៏ប្រសើរ បានអនុមោទនា ខ្ញុំបានស្តាប់ នូវអនុមោទនារបស់ព្រះសារីបុត្តនោះហើយ ក៏បាននឹកឃើញបុញ្ញកម្ម ។ ខ្ញុំបានផ្គងអញ្ជលី ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយរឭកបុញ្ញកម្ម ក៏បានដល់ព្រះអរហត្ត ។ ខ្ញុំក្រោកអំពីអាសនៈនោះ ហើយធ្វើអញ្ជលីលើក្បាល ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយពោលវាចានេះថា ក្នុងមួយសែនកប្បអំពីកប្បនេះ ព្រះពុទ្ធដ៏ប្រសើរ ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា ត្រាស់ឡើងក្នុងលោក ។ ខ្ញុំបានថ្វាយឆត្រដ៏វិចិត្រ តាក់តែងល្អហើយ ដល់ព្រះបទុមុត្តរៈអង្គនោះ ឯព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់ទទួលហើយ ដោយព្រះហស្តទាំងពីរ ។ ឱ ! ព្រះពុទ្ធ ឱ ! ព្រះធម៌ ឱ! សម្បទានៃព្រះសាស្តារបស់យើង ខ្ញុំមិនដែលទៅកាន់ទុគ្គតិ ដោយ

ការថ្វាយធត្រមួយប៉ុណ្ណោះ ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយហើយ ខ្ញុំគាស់រំលើងកពទាំងពួងហើយ ខ្ញុំកំណាត់ដីងនូវអាសវៈទាំងពួងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈឡើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសបរិវារច្ឆត្តទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ សបរិវារច្ឆត្តទាយកត្ថេរាបទាន ។

## ឧទ្ទាន

ឧម្មាបុប្ផិយត្ថេរាបទាន ១ បុឡិនបូជកត្ថេរាបទាន ១ ហាសជនកត្ថេរាបទាន ១ យញ្ញសាមិកត្ថេរាបទាន ១ និមិត្តសញ្ញកត្ថេរាបទាន ១ អន្នសំសាវកត្ថេរាបទាន ១ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ១ សុមនាវេឡិយត្ថេរាបទាន ១ បុប្ផច្ឆត្តិយត្ថេរាបទាន ១ សបរិវារច្ឆត្តទាយកត្ថេរាបទាន ១ មានគាថា ៧០០[១]។

## ចប់ ឧម្មាបុប្ផិយវគ្គ ទី ៣៣ ។

---

១-បាលីថា សត្តសតុត្តរា គួរប្រែថា ១០៧ ។

# អដ្ឋកថា

## សុមនាវេឡិយត្ថេរាបទាន ជាដើម

[ ២៨-៣០ ] អបទានទី ៨ ទី ៩ និងទី ១០ មានអត្ថប្រាកដជាក់ច្បាស់ហើយនោះឯង ។

*អដ្ឋកថាសុមនាវេឡិយត្ថេរាបទាន ជាដើម ចប់*

*ឧម្មាបុប្ផិយវគ្គ ទី ៣៣ ចប់*

# គន្ធោទកវគ្គ ទី ៣៤

## គន្ធធូបិយត្ថេរាបទាន ទី ១

[ ៣១ ] ខ្ញុំបានថ្វាយធូបក្រអូប ដល់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថ ឯធូបក្រអូបនោះ ស្រោបដោយផ្កាម្លិះ ជារបស់សមគួរដល់ព្រះពុទ្ធ ។ ខ្ញុំបានឃើញព្រះពុទ្ធ ជាអគ្គនាយកក្នុងលោក ប្រាកដស្មើដោយចេតិយមាស ទ្រង់រុងរឿងដូចរាជព្រឹក្ស ឬដូចភ្លើងកំពុងឆេះ ទ្រង់អង់អាចក្រៃលែងដូចជាខ្លាធំ ឬដូចកេសររាជសីហ៍ ជាអភិជាត ព្រះអង្គប្រសើរជាងពួកសមណៈ មានភិក្ខុសង្ឃចោមរោម ទ្រង់កំពុងគង់នៅ ។ លុះខ្ញុំឃើញហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លា ផ្គងអញ្ជលីថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា បែរមុខទៅកាន់ទិសឧត្តរហើយចៀសចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាគ្រឿងក្រអូប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាគ្រឿងក្រអូប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធធូបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ គន្ធធូបិយត្ថេរាបទាន ។**

# ឧទកបូជកត្ថេរាបទានទី ២

[ ៣២ ] ( ខ្ញុំបានឃើញ ) នូវព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានវណ្ណៈដូចមាស កំពុងពុទ្ធដំណើរទៅឰដ៏អាកាស រុងរឿងដូចភ្លើងឆេះខ្លាញ់ ឬដូចភ្លើងកំពុងឆេះ ខ្ញុំក្បង់យកទឹកដោយដៃ សាចឡើងទៅឰដ៏អាកាស ឯព្រះពុទ្ធជាឥសីទ្រង់ព្យាយាមធំ ប្រកបដោយសេចក្តីករុណា ទ្រង់ទទួលយក ។ ព្រះសាស្តាព្រះនាមបទុមុត្តរៈ ប្រថាប់នៅឰដ៏អាកាស ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ទើបត្រាស់នូវគាថានេះថា អ្នកនឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ដោយការថ្វាយទឹកនេះផង ដោយការញុំាងបីតិឲ្យកើតឡើងផង ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ខ្ញុំព្រះអង្គលះបង់នូវការឈ្នះនិងការចាញ់ ហើយបានដល់នូវអចលដ្ឋាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ១៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្កពត្តិ ៣ ជាតិ ព្រះនាមសហស្សរាជ ទ្រង់មានសមុទ្រទាំង ៤ ជាទីបំផុត ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧទកបូជកត្ថេរាបទាន ។**

# បុន្នាគបុប្ផិយត្ថេរាបទានទី ៣

[ ៣៣ ] ខ្ញុំបានកើតជាព្រានព្រៃ អាស្រ័យនៅក្នុងព្រៃធំ បានឃើញនូវឈើបុន្នាគ ដែលមានផ្ការីក ក៏នឹកដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបេះយកផ្កាដែលមានក្លិនក្រអូបឈ្ងុយឈ្ងប់ល្អនោះ ធ្វើជាព្រះស្តូបលើផ្នូកខ្សាច់ ហើយបូជាចំពោះព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៩១ ខ្ញុំបានកើតជាស្តេចចក្កពត្តិមួយព្រះអង្គ ព្រះនាមតមោនុទៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុន្នាគបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បុន្នាគបុប្ផិយត្ថេរាបទាន ។**

# ឯកទុស្សទាយកត្ថេរាបទានទី ៤

[ ៣៤ ] ខ្ញុំបានកើតជាអ្នកនាំស្មៅ នៅក្នុងក្រុងហង្សវតី តែងចិញ្ចឹមជីវិតដោយការនាំស្មៅ ទាំងចិញ្ចឹមប្រពន្ធកូន ដោយការនាំស្មៅនោះដែរ ។ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ជានាយកក្នុងលោក ទ្រង់ញ៉ាំងងងឹតអន្ធការឲ្យវិនាស ហើយត្រាស់ដឹងហើយ ។ កាល

នោះ ខ្ញុំអង្គុយក្នុងផ្ទះរបស់ខ្លួន ហើយគិតយ៉ាងនេះថា ព្រះពុទ្ធកើតឡើងហើយ ក្នុងលោក ឯទេយ្យធម៌របស់អាត្មាអញមិនមាន អាត្មាអញមាន តែសាដក មួយនេះ បើអាត្មាអញមិនមានការឲ្យអ្វីមួយទេ នោះការពាល់ត្រូវនូវនរក នាំ មកនូវទុក្ខ ហេតុនោះ អាត្មាអញនឹងបណ្តុះទក្ខិណាទាន ។ លុះខ្ញុំគិតយ៉ាងនេះ រួចហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ខ្ញុំបានយកសំពត់មួយថ្វាយព្រះសម្ពុទ្ធ ដ៏ប្រសើរ លុះថ្វាយសំពត់មួយរួចហើយ ក៏ស្រែកហ៊ោឡើងថា បពិត្រព្រះអង្គ ទ្រង់មានព្យាយាម ជាមហាមុនី បើព្រះអង្គជាព្រះពុទ្ធពិត សូមចម្លងខ្ញុំព្រះអង្គ ផង ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួល គ្រឿងបូជា កាលសម្តែងទានរបស់ខ្ញុំ ទ្រង់បានធ្វើអនុមោទនាដល់ខ្ញុំថា កុលបុត្ត នេះនឹងមិនទៅកាន់វិនិបាត អស់មួយសែនកប្ប ដោយផលនៃសំពត់មួយនេះ ផង ដោយការតម្កល់ទុកនូវចេតនាផង នឹងបានកើតជាព្រះឥន្ទ្រ គ្រងទេវរាជ្យ អស់ ៣៦ ដង នឹងកើតជាស្តេចចក្រពត្តិ ៣៣ ដង នឹងគ្រប់គ្រងប្រទេស រាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប អ្នកកាលអន្ទោលទៅ ក្នុង ទេវលោកនិងមនុស្សលោក នឹងមានរូបល្អ មានគុណធម៌បរិបូណ៌ មានរាង កាយមិនវិកលវិការៈ សំពត់ច្រើនរាប់មិនបាននឹងកើតឡើង ( ដល់អ្នក ) គួរតាមសេចក្តីប្រាថ្នា ។ លុះព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ ត្រាស់នូវពាក្យនេះហើយ ស្តេចហោះឡើងទៅកាន់អាកាស ដូចស្តេចហង្ស ហើរក្នុងអាកាស ។ ខ្ញុំបានទៅយកកំណើតណាៗ ទោះបីជាទេវតាឬមនុស្ស ខ្ញុំ មិនដែលខ្វះខាតភោគៈសោះឡើយ នេះជាផលនៃសំពត់មួយ ។ សំពត់តែង

កើតឡើងដល់ខ្ញុំរាល់ជំហាន ខាងក្រោមខ្ញុំឈរលើសំពត់ ខាងលើសំពត់ជាដំបូលបាំងខ្ញុំ ។ ក្នុងថ្ងៃនេះ សូម្បីខ្ញុំប្រាថ្នានឹងគ្របក៏អាចគ្របព្រៃនិងភ្នំ រហូតចក្កវាឡ ដោយសំពត់ទាំងឡាយបាន ។ ខ្ញុំកាលអន្ទោលទៅក្នុងកពតូចកពធំជាអ្នកមានសម្បុរល្អដូចមាស តែងអន្ទោលទៅក្នុងកពតូចកពធំដោយផលនៃការថ្វាយសំពត់មួយនោះ ។ ខ្ញុំមិនចេះអស់ផលនៃសំពត់មួយ ក្នុងទីណាមួយឡើយ នេះជាជាតិបំផុតរបស់ខ្ញុំ កុសលកម្មនោះ ឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះផងទៀត ។ ក្នុងកប្បទីមួយសែនកប្បអំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់មួយ ។ ខ្ញុំដុតបំផ្លាញពួកកិលេសអស់ហើយ ខ្ញុំគាស់រំលើងកពទាំងពួងអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទឹងហើយ ដូច្នោះដែរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទុស្សទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ ឯកទុស្សទាយកត្ថេរាបទាន ។

# ផុស្សិតកម្មិយត្ថេរាបទានទី ៩

[ ៣៥ ] កាលនោះ ព្រះសម្ពុទ្ធព្រះនាមវិបស្សី ជាច្បងក្នុងលោក ប្រសើរជាងនរជន បរិបូណ៌ដោយព្រះខីណាស្រព ទ្រង់គង់នៅក្នុងសង្ឃារាម ។ ព្រះវិបស្សីលោកនាយកអង្គនោះ ស្ដេចចេញអំពីទ្វារអារាម មួយអន្លើដោយព្រះខីណាស្រព ៨ សែនអង្គ ។ ខ្ញុំស្លៀកស្បែកខ្លាឃ្មុំ ដណ្ដប់សម្បកឈើ ហើយផងយកទឹកអណ្ដូង កាន់ដើរចូលទៅគាល់ព្រះសម្ពុទ្ធ ។ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា មានសេចក្ដីត្រេកអរកើតឡើង ក៏ធ្វើអញ្ជលី យកទឹកអណ្ដូងនោះ ប្រោះព្រំព្រះសម្ពុទ្ធ ។ ហេតុតែកុសលកម្មនោះ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ សម្ដែងនូវកម្មនោះដល់ខ្ញុំ ហើយស្ដេចពុទ្ធដំណើរទៅកាន់ទីគួរតាមប្រាថ្នា ខ្ញុំបានបូជាព្រះជិនស្រី ដោយទឹកប្រាំពាន់តំណក់ បានសោយទេវរាជ្យ ៣ ពាន់ដងដោយកន្ទះ ( ២៥០០ ) ។ ខ្ញុំបានកើតជាស្ដេចចក្កពត្តិ ៣ ពាន់ដងដោយកន្ទះ បានដល់អរហត្តដោយកុសលកម្មដ៏សេសសល់ ។ ខ្ញុំបានជាស្ដេចនៃទេវតា ជាធំជាងពួកមនុស្ស ក្នុងកាលណា កាលនោះ ឈ្មោះរបស់ខ្ញុំនោះ ក៏ឈ្មោះថា ផុស្សិតៈ ។ មួយទៀត កាលខ្ញុំកើតជាទេវតា ឬកើតជាមនុស្ស គ្រាប់ភ្លៀងរមែងបង្អុរចុះដល់ខ្ញុំ មួយព្យាមដោយជុំវិញ ។ ខ្ញុំគាស់រំលើងភពចោលហើយ ខ្ញុំដុតបំផ្លាញពួកកិលេសអស់ហើយ ខ្ញុំជាអ្នកអស់អាសវៈទាំងពួងហើយ នេះជាផលនៃតំណក់ទឹក ។ កាយរបស់ខ្ញុំមានក្លិនក្រអូបផ្សាយទៅ ដូចក្លិននៃខ្លឹមចន្ទន៍ ក្លិនដែលជាប់នឹងសរីរៈរបស់ខ្ញុំ រមែងផ្សាយទៅបានក្នុងទីកន្ទះក្រោស ( ២៥០ ជួរធ្នូ ) ។ ពួកជនគ្រាន់តែធុំក្លិនខ្ញុំ ក៏ស្គាល់ខ្ញុំដែលមានក្លិនទិព្វផ្សព្វផ្សាយ ប្រកបដោយបុញ្ញកម្មថា

ឱ! ផុស្សិតៈមកក្នុងទីនេះហើយ ។ សូម្បីតែមែកឈើ ស្លឹកឈើ កំណាត់ឈើ និងស្មៅ ក៏ហាក់ដូចជាជីងបំណងរបស់ខ្ញុំ ដោយសព្វគ្រប់ ហើយបញ្ចេញនូវកិច្ចក្នុងខណៈនោះ ។ ក្នុងមួយសែនកប្បអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយនូវតំណក់ទឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃតំណក់ទឹក ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះផុស្សិតកម្មិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ផុស្សិតកម្មិយត្ថេរាបទាន ។**

# បភង្ករត្ថេរាបទានទី ៦

[ ៣៦ ] ចេតិយរបស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ តាំងនៅក្នុងព្រៃធំ ជាទីកុះករដោយម្រឹគសាហាវ ។ បុគ្គលណាមួយ មិនអាចនឹងទៅថ្វាយបង្គំចេតិយបានឡើយ ចេតិយនោះត្រូវស្មៅនិងឈើវល្លិរួបរឹតរលើងរលំ ។ កាលនោះ ខ្ញុំជាអ្នកធ្វើការងារក្នុងព្រៃ ជាមួយនឹងបិតានិងជីតា ក៏បានឃើញព្រះស្តូបក្នុងព្រៃធំ ដែលមានស្មៅ វល្លិ រួបរឹតរលើងរលំនោះ ។ លុះខ្ញុំឃើញពុទ្ធស្តូបហើយ ក៏តាំងចិត្តគោរពថា ព្រះស្តូបរបស់ព្រះសម្ពុទ្ធដ៏ប្រសើរនេះ នៅក្នុងព្រៃ រលើងរលំខូច

ខាតអស់ អ្នកស្គាល់គុណនិងទោសនៃចេតិយនោះ បើមិនបានជម្រះនូវពុទ្ធ-ស្តូប ដែលមិនកំបាំង មិនសមគួរ ត្រឡប់ទៅប្រកបការងារដទៃវិញ ការណ៍នោះមិនសមគួរទេ ។ ទើបខ្ញុំជម្រះស្មៅនិងឈើវល្លិ លើព្រះចេតិយ ហើយថ្វាយបង្គំ រួចថយក្រោយអស់ ៨ ជំហាន រួចដើរចេញទៅ ។ លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំបានសាងល្អនោះផង ដោយការតាំងចេតនានោះផង ។ វិមានរបស់ខ្ញុំដែលបុញ្ញកម្មតាក់តែងល្អហើយ ក្នុងឋានតាវត្តិង្សនោះ មានវណ្ណៈភ្លឺផ្លេកដូចមាស មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ខ្ញុំបានសោយទេវរាជ្យអស់ ៣០០ ដង បានកើតជាស្តេចចក្កពត្តិ ២៥ ដងទៀត ។ ខ្ញុំកាលអន្ទោលទៅក្នុងភពធំភពតូច រមែងបានភោគៈច្រើន ការខ្វះខាតដោយភោគៈរបស់ខ្ញុំមិនមានឡើយ នេះជាផលនៃការជម្រះ ។ កាលខ្ញុំទៅក្នុងព្រៃធំ តែងទៅដោយគ្រែស្នែង ឬជិះលើគជិន្ទ ខ្ញុំទៅកាន់ទិសណាៗ ព្រៃរមែងសម្រេចជាទីពឹង ( របស់ខ្ញុំក្នុងទិសនោះៗ ) ។ ខ្ញុំប្រកបហើយដោយបុញ្ញកម្ម មិនដែលឃើញដង្គត់ឬបន្លាដោយចក្ខុឡើយ ដង្គត់ជាដើមនោះ តែងចៀសចេញទៅឯង ៗ ។ ខ្ញុំមិនដែលកើតរោគឃ្លង់ ពក ស្រែង ឬតជ្រូកឃ្លង់ដែក ដំណួចពិស ឬកមរមាស់ឡើយ នេះជាផលនៃការជម្រះ ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំមិនដែលស្គាល់ពក ឬផ្លូច កើតក្នុងកាយរបស់ខ្ញុំទេ ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំតែងអន្ទោលទៅកើតក្នុងភពពីរ

គឺទេវតា ឬមនុស្ស ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំមានសម្បុរដូចមាស មានរស្មីរុងរឿងក្នុងទីទាំងពួង ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀតគឺ ព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ សេចក្តីមិនគាប់ចិត្តតែងចៀសវាង សេចក្តីគាប់ចិត្ត តែងប្រាកដឡើង ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ចិត្តរបស់ខ្ញុំស្អាតល្អ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តខ្ជាប់ខ្ជួន ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំអង្គុយលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការជម្រះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបកុឌ្ឌរត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ បកុឌ្ឌរត្ថេរាបទាន ។

# តិណកុដិទាយកត្ថេរាបទានទី ៧

[ ៣៧ ] ខ្ញុំជាកម្មករនៃជនដទៃ នៅក្នុងក្រុងឈ្មោះពន្ធុមតី ប្រកបការងារនៃជនដទៃ ពឹងផ្អែកដោយថ្លៃឈ្នួលនៃជនដទៃ ។ កាលនោះ ខ្ញុំទៅអង្គុយក្នុងទីស្ងាត់ ហើយគិតយ៉ាងនេះថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ឯការបរិច្ចាគរបស់អាត្មាអញមិនទាន់មាន កាលនេះ គួរតែអាត្មាជម្រះនូវគតិ ខណៈប្រាកដដល់អាត្មាអញហើយ ការពាល់ត្រូវនូវនរករមែងជាទុក្ខរបស់ពួកសត្វដែលមិនមានបុណ្យ ។ លុះខ្ញុំគិតយ៉ាងនេះហើយ ទើបចូលទៅរកបុគ្គលអ្នកម្ចាស់ការ ហើយសូមផ្អាកការងារមួយថ្ងៃ រួចដើរចូលទៅក្នុងព្រៃធំ ។ កាលនោះ ខ្ញុំយកស្មៅឈើនិងវល្លិមកហើយ ខ្ញុំបោះឈើ ៣ កំណាត់ ធ្វើជាកុដិស្មៅ ទើបខ្ញុំថ្វាយកុដិនោះ ដើម្បីប្រយោជន៍ដល់សង្ឃ ហើយវិលចូលមករកបុគ្គលជាម្ចាស់ការក្នុងថ្ងៃនោះ ។ ហេតុតែកុសលកម្មដែលខ្ញុំសាងល្អហើយនោះ ខ្ញុំក៏បានទៅកើតក្នុងឋានតាវត្តិង្ស មានវិមានដ៏វិសេសវិសាលដែលបុញ្ញកម្មតាក់តែងហើយ ក្នុងឋានតាវត្តិង្សនោះ ព្រោះតែកុដិស្មៅរបស់ខ្ញុំ ។ វិមាននោះជាវិការៈនៃកែវមណីខៀវ មានកម្ពស់មួយពាន់ជួរកូនសរ មានជាន់ ១០០ បរិបូណ៌ដោយទង់ ឯប្រាសាទកំពូលមួយសែន កើតឡើងក្នុងវិមាននៃខ្ញុំនោះ ។ ខ្ញុំទៅយកកំណើតណា ៗ ទោះបីជាទេវតាឬជាមនុស្ស ប្រាសាទហាក់ដូចជាដឹងបំណងរបស់ខ្ញុំ ហើយផុសឡើង ។ ភ័យក្តី សេចក្តីតក់ស្លុតក្តី ការព្រឺរោមក្តី មិនដែលមានដល់ខ្ញុំឡើយ ខ្ញុំមិនដែលស្គាល់សេចក្តីតក់ស្លុត នេះជាផលនៃកុដិស្មៅ ។ សត្វទាំងពួង គឺរាជសីហ៍ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន រមែងចៀសវាងខ្ញុំ នេះជាផលនៃកុដិស្មៅ ។ សត្វទាំងនោះ

គឺពស់តូចពស់ធំ ក្អូត ពស់មានពិស កុម្ភណ្ឌ និងអារក្សទឹក រមែងចៀសវាងខ្ញុំ នេះជាផលនៃកុដិស្មៅ ។ ខ្ញុំមិនយល់សប្តិនូវសុបិនអាក្រក់សោះ ស្មារតីរបស់ខ្ញុំក៏តាំងនៅមាំ នេះជាផលនៃកុដិស្មៅ ។ ព្រោះតែកុដិស្មៅនោះ ខ្ញុំបានសោយសម្បត្តិទាំងឡាយ បានធ្វើឲ្យជាក់ច្បាស់នូវធម៌របស់ព្រះមាន ព្រះភាគ ព្រះនាមគោតម ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកុដិស្មៅ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណកុដិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តិណកុដិទាយកត្ថេរាបទាន ។**

# ឧត្តរេយ្យទាយកត្ថេរាបទានទី ៨

[ ៣៨ ] កាលនោះ ខ្ញុំជាព្រាហ្មណ៍នៅក្នុងនគរហង្សវតី ជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ។ ជាអ្នកមានជាតិខ្ពង់ខ្ពស់ផង ជាអ្នកសិក្សាស្ទាត់ផង មានពួកសិស្សចោមរោមផង កាលនោះ ខ្ញុំចេញអំពីទីក្រុង ដើម្បីនឹងទៅងូតទឹក ។ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ស្តេចពុទ្ធដំណើរទៅកាន់ទីក្រុង

មួយអន្ទើដោយព្រះទីណាស្រេពមួយពាន់អន្ត ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធដែល មានព្រះរូបល្អដូចមាស ទ្រង់មិនញាប់ញ័រ ដូចរូបដែលគេកសាង មានពួក ព្រះអរហន្តចោមរោម លុះខ្ញុំឃើញហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លា ។ ខ្ញុំមាន ចិត្តជ្រះថ្លា មានចិត្តរីករាយ ធ្វើនូវអញ្ជលីលើត្បូង ហើយនមស្ការចំពោះព្រះ សម្ពុទ្ធទ្រង់មានវត្តល្អ ហើយថ្វាយសំពត់សាដក ។ ខ្ញុំផ្គងអញ្ជលី ទាំងសង ខាង ហើយលើកឡើងនូវសំពត់សាដកនោះ ពួកពុទ្ធបរិស័ទ មានត្រឹមណា សំពត់សាដក ក៏គ្របត្រឹមនោះ ។ កាលនោះឯង សាដកនោះ គ្របទៅលើ ភិក្ខុបរិស័ទ មានចំនួនច្រើនរូប ដែលកំពុងត្រាច់ទៅបិណ្ឌបាត ធ្វើឲ្យខ្ញុំរីករាយ ចិត្តជាខ្លាំងក្រៃលែង ។ កាលខ្ញុំចេញអំពីផ្ទះ ព្រះសយម្ភូជាអគ្គបុគ្គលសាស្តា- ចារ្យ ទ្រង់ប្រថាប់ត្រង់ថ្នល់ ហើយធ្វើអនុមោទនាថា បុគ្គលណាមានចិត្ត ជ្រះថ្លា មានចិត្តសោមនស្ស បានថ្វាយសាដកដល់តថាគត តថាគតនឹងសរសើរ បុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ បុគ្គលអ្នកថ្វាយ សាដកនេះ នឹងបានរីករាយក្នុងទេវលោកអស់ ៣០.០០០ កប្ប កើតជា ព្រះឥន្ទ្រសោយទេវរាជ្យ ៥០ ដង បុគ្គលអ្នកបរិបូណ៌ដោយបុញ្ញកម្មនេះ កាល នៅក្នុងទេវលោក មានសំពត់បិទបាំងដោយជុំវិញ ១០០ យោជន៍ នឹងបាន ជាស្តេចចក្កពត្តិ ៣៦ ដង សោយបទេសរាជ្យដ៏ធំទូលាយ រាប់បានមួយ- អសង្ខេយ្យកប្ប បុគ្គលដែលបរិបូណ៌ដោយបុញ្ញកម្មនេះ កាលអន្ទោលទៅក្នុង ភព វត្ថុទាំងពួងដែលចិត្តចង់បាន នឹងកើតមួយរំពេច ។ បុគ្គលនេះនឹងបាន សំពត់ទាំងឡាយ គឺសំពត់សូត្រ សំពត់រោមសត្វ សំពត់សម្បកឈើ និង

សំពត់កប្បាស ដ៏មានតម្លៃច្រើន ។ បុគ្គលនេះនឹងបាននូវសម្បត្តិទាំងពួងតាមចិត្តប្រាថ្នា នឹងបានទទួលនូវផលនៃសំពត់មួយនេះសព្វកាល ។ ខាងក្រោយមក បុគ្គលនោះ ត្រូវកុសលមូលដាស់តឿន នឹងបានបួស ហើយនឹងធ្វើឲ្យជាក់ច្បាស់នូវធម៌របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ឱ ហ្ន៎ ! កុសលកម្មដែលខ្ញុំបានសាងល្អហើយ ចំពោះព្រះសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ព្រោះតែបានថ្វាយសំពត់សាដកមួយ ខ្ញុំក៏បានដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ។ កាលខ្ញុំនៅក្នុងមណ្ឌបក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ដំបូលសំពត់តែងបិទបាំងខ្ញុំ ប្រវែងមួយព្យាមដោយជុំវិញ ។ ខ្ញុំស្លៀកដណ្តប់ចីវរប្បច្ច័យ មិនបាច់សុំជនដទៃផង ជាអ្នកបាននូវបាយនិងទឹកផង នេះជាផលនៃសំពត់សាដក ។ ក្នុងមួយសែនកប្បអំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់សាដក ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧត្តរេយ្យទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឧត្តរេយ្យទាយកត្ថេរាបទាន ។**

# ធម្មស្សវនិយត្ថេរាបទានទី ៩

[ ៣៩ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង កំពុងប្រកាសសច្ចៈ ៤ ចម្លងមហាជន ។ សម័យនោះ ខ្ញុំជាជដិលមានតបៈដ៏ខ្ពង់ខ្ពស់ កំពុងលោះសំពត់សម្បកឈើ ហោះទៅឰដ៏អាកាស ។ តែខ្ញុំមិនអាចនឹងទៅពីខាងលើនៃព្រះសម្ពុទ្ធដ៏ប្រសើរបាន ក្នុងកាលនោះ ខ្ញុំក៏ខានធ្វើដំណើរទៅ ដូចសត្វស្លាបដែលជាប់នៅនឹងភ្នំ ។ ទើបខ្ញុំគិតថា ការខកដំណើរបែបនេះ អាត្មាអញមិនធ្លាប់កើតមានទេ អាត្មាអញទៅឰដ៏អាកាសម្តងនេះ ដូចបើកក្អែកក្នុងទឹក ប្រហែលមានមនុស្សអស្ចារ្យ អង្គុយនៅឰដ៏ខាងក្រោមទេដឹង បើដូច្នោះ អាត្មាអញនឹងស្វែងរកមនុស្សនេះ បើឃើញ គង់នឹងបានប្រយោជន៍ខ្លះមិនខានឡើយ ។ កាលនោះ ខ្ញុំចុះអំពីអាកាសមក បានស្តាប់ព្រះសូរសៀងព្រះសាស្តា ដែលកំពុងសម្តែងអនិច្ចតាធម៌ ខ្ញុំក៏បានរៀននូវអនិច្ចតាធម៌នោះ ។ លុះខ្ញុំរៀនអនិច្ចសញ្ញាហើយ ក៏ដើរទៅកាន់អាស្រមរបស់ខ្ញុំ ខ្ញុំនៅជរាបដល់អស់អាយុ ក៏ធ្វើមរណកាលក្នុងទីនោះ ។ កាលជវនចិត្តទីបំផុតកំពុងប្រព្រឹត្តទៅ ខ្ញុំនឹកឃើញនូវការស្តាប់ធម៌នោះ ក៏បានទៅកើតឯឋានតាវត្តិង្ស ព្រោះកុសលកម្មដែលខ្ញុំធ្វើនោះ ។ ខ្ញុំបានរីករាយក្នុងទេវលោកអស់ ៣០.០០០ កប្ប បានសោយទេវរាជ្យ ៥១ ដង ។ ខ្ញុំបានកើតជាស្តេចចក្កពត្តិអស់ ៧១ ដង បានសោយប្រទេសរាជ្យដ៏ធំ រាប់បានមួយអសង្ខេយ្យជាតិ ។ មានសមណៈមួយអង្គ មានឥន្ទ្រិយអប់រំហើយ អង្គុយក្នុងផ្ទះរបស់បិតាខ្ញុំ សម្តែងនូវគាថាទាក់ទងអនិច្ចវត្ថុ ។ ខ្ញុំកាលអន្ទោលទៅក្នុងភពតូចភពធំ តែងនឹកឃើញសញ្ញានោះ តែមិនទាន់បានត្រាស់ដឹងនូវធម៌ជាទីបំផុត គឺ

ព្រះនិព្វានជាអច្ចុតបទនៅឡើយថា សង្ខារទាំងឡាយមិនទៀងមែនពិត មានការកើតឡើងហើយ វិនាសទៅវិញជាធម្មតា លុះកើតឡើងហើយ រមែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងនោះ ទើបនាំមកនូវសេចក្ដីសុខ ។ លុះខ្ញុំស្ដាប់គាថាប្រដាប់ដោយអនិច្ចវត្ថុហើយ ក៏រឮកឃើញនូវបុព្វកម្ម ខ្ញុំអង្គុយនៅលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ដែលខ្ញុំដល់ព្រះអរហត្តនោះ ខ្ញុំអាយុ ៧ ឆ្នាំ ព្រះពុទ្ធមានចក្ខុ ទ្រង់ជ្រាបគុណរបស់ខ្ញុំ ទើបទ្រង់ឲ្យឧបសម្បទាដល់ខ្ញុំ ។ ខ្ញុំបានញុំាងករណីយកិច្ចឲ្យសម្រេចហើយ តាំងពីនៅជាកុមារភាព គឺកិច្ចអ្វីក្នុងសាសនារបស់ព្រះសក្យបុត្ត ខ្ញុំធ្វើឲ្យចប់ស្រេចក្នុងថ្ងៃនេះហើយ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្ដាប់ព្រះសទ្ធម្ម ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មស្សវនិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ធម្មស្សវនិយត្ថេរាបទាន ។

# ឧក្ខិត្តបទុមិយត្ថេរាបទានទី ១០

[ ៤០ ] កាលនោះ ខ្ញុំជាអ្នកក្រងផ្កា នៅក្នុងក្រុងហង្សវតី បានចុះទៅក្នុងស្រះឈូក ហើយកាច់យកផ្កាឈូក ។ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង មួយអន្លើដោយព្រះខីណាស្រពមួយសែនអង្គ ជាអ្នកមានចិត្តស្ងប់ម្ងាប់ ប្រកបដោយតាទិគុណ មានសន្តានស្អាត បានអភិញ្ញា ៦ និងមានឈាន ទ្រង់ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់ស្វែងរកសេចក្តីចម្រើនដល់ខ្ញុំ បានធ្វើពុទ្ធដំណើរមករកខ្ញុំ ។ កាលនោះ ខ្ញុំបានឃើញព្រះសយម្ភូ ជាលោក-នាយក ជាទេវតាក្រៃលែងជាងទេវតា ទើបកាច់ផ្កាឈូកត្រង់ទង បោះឡើងទៅនាអាកាស ។ ខ្ញុំប្រកាសថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ បើព្រះអង្គជាព្រះពុទ្ធ ជាច្បងក្នុងលោក ប្រសើរជាងពួកនរជនមែន សូមផ្កាឈូកទាំងនុ៎ះអណ្តែតទៅឯង សូមផ្កាឈូកទាំងនុ៎ះ បាំងពីខាងលើព្រះសិរ្សៈ ( របស់ព្រះអង្គ ) ចុះ ។ ព្រះសម្ពុទ្ធទ្រង់មានព្យាយាមធំ ជាច្បងក្នុងលោក ប្រសើរជាងពួកនរជន ទ្រង់អធិដ្ឋានហើយ ផ្កាឈូកទាំងនោះ ក៏បាំងពីខាងលើព្រះសិរ្សៈនៃព្រះអង្គ ដោយពុទ្ធានុភាព ។ ដោយកុសលកម្មដែលខ្ញុំធ្វើនោះផង ដោយការតាំងចេតនានោះផង លុះខ្ញុំលះរាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានដែលបុញ្ញកម្មតាក់តែងល្អហើយសម្រាប់ខ្ញុំ ក្នុងឋានតាវត្តិង្សនោះ គេហៅថាសត្តបត្តៈ មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ខ្ញុំបានកើតជាព្រះឥន្ទ្រ សោយទេវរាជ្យអស់មួយពាន់ដង កើតជាស្តេចចក្រពត្តិអស់ ៧៥ ដង ។ ខ្ញុំបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ខ្ញុំសោយនូវកុសលកម្មរបស់ខ្លួន ដែលខ្លួនធ្វើ

ទុកល្អហើយក្នុងកាលមុន ។ ខ្ញុំសោយសម្បត្តិទាំងឡាយ ដោយការថ្វាយនូវផ្កាឈូកមួយនោះឯង ទាំងបានធ្វើឲ្យជាក់ច្បាស់នូវធម៌របស់ព្រះមានព្រះភាគព្រះនាមព្រះគោតម ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងឡាយខ្ញុំបានគាស់រំលើងអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទឹង ដូច្នោះឯង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាឈូកមួយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧក្ខិត្តបទុមិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ឧក្ខិត្តបទុមិយត្ថេរាបទាន ។

## ឧទ្ទាន

គន្ធធូបិយត្ថេរាបទាន ១ ឧទកបូជកត្ថេរាបទាន ១ បុន្នាគបុប្ផិយត្ថេរាបទាន ១ ឯកទុស្សទាយកត្ថេរាបទាន ១ ផុសិតកម្មិយត្ថេរាបទាន ១ បភង្ករត្ថេរាបទាន ១ តិណកុដិទាយកត្ថេរាបទាន ១ ឧត្តរេយ្យទាយកត្ថេរាបទាន ១ ធម្មស្សវនិយត្ថេរាបទាន ១ ឧក្ខិត្តបទុមិយត្ថេរាបទាន ១ មានគាថាជាប់គ្នាទាំងអស់ ១០១ ផង ៤៤ ផង ( ១៤៥ ) ។

## ចប់ គន្ធោទកវគ្គ ទី ៣៤ ។

# អដ្ឋកថា

# គន្ធធូបិយត្ថេរាបទាន ជាដើម

[ ៣១-៤០ ] *អបទានរបស់ព្រះគន្ធធូបិយត្ថេរក្នុងវគ្គទី ៣៤ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាគន្ធធូបិយត្ថេរាបទានជាដើម ចប់*

# ឯកបទុមវគ្គ ទី ៣៥

## ឯកបទុមិយត្ថេរាបទាន ទី ១

[ ៤១ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង កំពុងទ្រង់សម្តែងធម៌ឲ្យបណ្តាជនច្រើននាក់ ឆ្លងនូវភពតូចនិងភពធំ ។ កាលនោះ ខ្ញុំកើតជាស្តេចហង្សប្រសើរជាងសត្វស្លាបទាំងឡាយ បានចុះកាន់ជាតស្រះ ហើយលេងល្បែងហង្ស ។ ខណៈនោះ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលគ្រឿងបូជា បានស្តេចពុទ្ធដំណើរមកពីខាងលើជាតស្រះ ។ ខ្ញុំបានឃើញព្រះសយម្ភូលោកនាយក ជាទេវតាក្រៃលែងជាងទេវតា ក៏កាច់ផ្កាបទុមជាត គឺផ្កាឈូកជាទីរីករាយនៃចិត្តត្រង់ទង ខ្ញុំមានចិត្តជ្រះថ្លា បានពាំយកផ្កានោះដោយចំពុះ ហើយបោះទៅឰដ៏អាកាស បូជាព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់ត្រៃលោក ទ្រង់គួរទទួលគ្រឿងបូជា បានប្រថាប់នៅឰដ៏អាកាស ហើយធ្វើអនុមោទនាថា អ្នកនឹងមិនទៅកើតក្នុងវិនិបាត អស់មួយសែនកប្បដោយផ្កាឈូកមួយនេះផង ដោយការតាំងចេតនានេះផង ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ លុះទ្រង់សម្តែងនូវអនុមោទនានេះ ព្រមទាំងទ្រង់សរសើរកុសលកម្មរបស់ខ្ញុំរួចហើយ ស្តេចពុទ្ធដំណើរទៅកាន់ទីគួរតាមប្រាថ្នា ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះ

ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបទុមិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឯកបទុមិយត្ថេរាបទាន ។**

# តិណុប្បលមាលិយត្ថេរាបទានទី ២

[ ៤២ ] កាលនោះ ខ្ញុំកើតជាពានរ នៅទៀបភ្នំស្ទឹងចន្ទភាគា បានឃើញព្រះសម្ពុទ្ធ ប្រាសចាកធូលីគឺកិលេស ទ្រង់គង់នៅត្រង់ចន្លោះភ្នំ ។ ខ្ញុំមានចិត្តត្រេកអរ ព្រោះបានឃើញព្រះពុទ្ធ ទ្រង់ញុំាំងទិសទាំងពួងឲ្យភ្លឺ ប្រកបដោយលក្ខណៈនិងអនុព្យញ្ជនៈ ដូចស្តេចសាលព្រឹក្សដែលមានផ្ការីក ។ ខ្ញុំមានចិត្តខ្ពស់ឯក មានចិត្តរីករាយ មានចិត្តស្រស់ស្រាយដោយបីតិ បានប្រទូលលើក្បាលនូវផ្កាឧប្បល ៣ ថ្វាយព្រះអង្គ ។ លុះខ្ញុំបូជាផ្កាទាំងឡាយចំពោះព្រះមហេសីព្រះនាមវិបស្សីរួចហើយ ជាអ្នកមានសេចក្តីគោរព បែរមុខស្ទោះទៅកាន់ទិសឧត្តរ ដើរចេញទៅ ។ ខ្ញុំកំពុងមានចិត្តជ្រះថ្លាដើរត្រឡប់ថយក្រោយ ក៏ធ្លាក់ទៅក្នុងជ្រោះភ្នំ ដល់នូវការអស់ទៅនៃជីវិត ។ ដោយកុសលកម្មដែលខ្ញុំបានធ្វើនោះផង ដោយការតាំងចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយទេវរាជ្យអស់ ៣០០ ជង បានកើតជាស្តេចចក្កពត្តិអស់ ៥០០ ជង ។ ក្នុងកប្បទី ៩១

អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណុប្បលមាលិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

**ចប់ តិណុប្បលមាលិយត្ថេរាបទាន ។**

## ធជទាយកត្ថេរាបទានទី ៣

[ ៤៣ ] ព្រះសាស្ដាព្រះនាមតិស្សៈ ទ្រង់ជាច្បងក្នុងលោក ប្រសើរជាង ពួកនរជន ព្រោះអស់ឧបធិ ៣ ប្រការ ខ្ញុំបានឃើញ ( ព្រះអង្គ ) ហើយ លើកឡើងនូវទង់ថ្វាយ ។ ដោយកុសលកម្មដែលខ្ញុំធ្វើនោះផង ដោយការ តាំងចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅ កើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយទេវរាជ្យអស់ ៣០០ ដង បានជាស្ដេច ចក្កពត្តិអស់ ៥០០ ដង ។ បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បាន មួយអសង្ខេយ្យកប្ប ខ្ញុំទទួលកុសលកម្មរបស់ខ្លួនដែលខ្លួនធ្វើល្អហើយក្នុងកព មុន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាន ធ្វើនូវកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទង់ ។ សូម្បី ថ្ងៃនេះ ខ្ញុំមានប្រាថ្នានឹងគ្រប ក៏អាចគ្របនូវព្រៃនិងភ្នំ ដោយសំពត់សម្បក

ឈើបាន នេះជាផលនៃអំពើដែលខ្ញុំធ្វើហើយក្នុងកពនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធជទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ធជទាយកត្ថេរាបទាន ។**

# តីណិកិង្កណិបូជកត្ថេរាបទានទី ៤

[ ៤៤ ] មានភ្នំមួយឈ្មោះភូតគណៈ នៅជិតព្រៃហិមពាន្ត ខ្ញុំបានឃើញសំពត់បង្សុកូលដែលគេព្យួរលើចុងឈើក្បែរភ្នំនោះ ។ កាលនោះ ខ្ញុំជាអ្នករីករាយ មានចិត្តត្រេកអរ បានបេះផ្កាកណ្តឹង ៣ បូជាចំពោះសំពត់ បង្សុកូលនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាកណ្តឹង ៣ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិកិង្កណិបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តីណិកិង្កណិបូជកត្ថេរាបទាន ។**

## នឡាគារិកត្ថេរាបទានទី ៥

[ ៤៥ ] មានភ្នំមួយឈ្មោះហារិកៈ នៅជិតព្រៃហិមពាន្ត កាលនោះ ព្រះពុទ្ធព្រះនាមសយម្ភូ ស្តេចគង់នៅក្បែរគល់ឈើមួយ ។ ខ្ញុំបានធ្វើរោងបបុសប្រក់ដោយស្មៅ ខ្ញុំជម្រះទីចង្ក្រម ថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ១៤ ខ្ញុំបានរីករាយក្នុងទេវលោក ខ្ញុំបានសោយទេវរាជ្យ ៧៤ ដង បានកើតជាស្តេចចក្កពត្តិ ៧៧ ដង សោយប្រទេសរាជ្យដ៏ធំទូលាយរាប់បានមួយអសង្ខេយ្យកប្ប ។ វិមានជាលំនៅរបស់ខ្ញុំខ្ពស់ទទុង ដូចលំពង់ដើមឥន្ទព្រឹក្សដ៏ខ្ពស់ មានសសរមួយពាន់ដើម មានលំអឥតប្តឹងបាន មានស្មើរុងរឿងក្នុងផ្ទៃ ។ ខ្ញុំបានសោយសម្បត្តិទាំងពីរ ត្រូវកុសលមូលជាស់តឿន ក៏បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមគោតម ។ ខ្ញុំមានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់រម្ងាប់ ជាអ្នកមិនមានឧបធិ មិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទឹងរួចហើយ ដូច្នោះឯង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនឡាគារិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

### ចប់ នឡាគារិកត្ថេរាបទាន ។

## ចម្បកបុប្ផិយត្ថេរាបទានទី ៦

[ ៤៦ ] មានភ្នំមួយ ឈ្មោះឆាបលៈ នៅជិតព្រៃហិមពាន្ត ព្រះពុទ្ធព្រះនាមសុទស្សនៈ ស្តេចគង់ត្រង់ចន្លោះភ្នំ ។ កាលនោះ ខ្ញុំកាន់យកផ្កាមានសម្បុរដូចមាស ហើយហោះទៅតាមអាកាស បានឃើញព្រះសម្ពុទ្ធដែលប្រាសចាកធូលី គឺកិលេស ស្តេចទ្រង់ធ្វងឱឃៈហើយ ទ្រង់មិនមានអាសវៈ ។ លុះឃើញ ខ្ញុំតម្កល់នូវផ្កាចម្ប៉ា ៧ លើក្បាល បូជាដល់ព្រះសម្ពុទ្ធជាសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចម្បកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំង នេះដោយប្រការដូច្នេះ ។

**ចប់ ចម្បកបុប្ផិយត្ថេរាបទាន ។**

## បទុមបូជកត្ថេរាបទានទី ៧

[ ៤៧ ] មានភ្នំមួយឈ្មោះរោមសៈ នៅជិតព្រៃហិមពាន្ត កាលនោះព្រះពុទ្ធព្រះនាមសោភិតៈ ទ្រង់គង់នៅត្រង់ទីវាល ។ ខ្ញុំចេញអំពីលំនៅ ហើយកាន់យកនូវផ្កាឈូកបាំងថ្វាយព្រះសម្ពុទ្ធ លុះខ្ញុំបាំងថ្វាយអស់មួយថ្ងៃហើយត្រឡប់ចូលកាន់លំនៅវិញ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែល

ខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បទុមបូជកត្ថេរាបទាន ។**

**ចប់ ភាណវារៈ ទី ១៣ ។**

# តិណមុដ្ឋិទាយកត្ថេរាបទានទី ៨

[ ៤៨ ] មានភ្នំមួយឈ្មោះលម្ពកៈ នៅជិតព្រៃហិមពាន្ត ព្រះសម្ពុទ្ធព្រះនាមឧបតិស្សៈ ទ្រង់ចង្រ្កមក្នុងទីវាលជិតភ្នំនោះ ។ កាលនោះ ខ្ញុំបានកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញព្រះសយម្ភូនោះ ជាទេវតាក្រៃលែងជាងទេវតាទ្រង់ឈ្នះមារ ។ លុះឃើញហើយ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយស្មៅមួយក្តាប់ដល់ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ សម្រាប់ក្រាលគង់ ។ លុះខ្ញុំថ្វាយដល់ព្រះសម្ពុទ្ធ ជាទេវតាក្រៃលែងជាងទេវតាហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាដ៏ក្រៃលែង ថ្វាយបង្គំព្រះសម្ពុទ្ធឈមមុខទៅកាន់ទិសឧត្តរហើយដើរចេញទៅ ។ ខ្ញុំកំពុងដើរទៅ មិនយូរប៉ុន្មាន ស្តេចម្រឹគ គឺសីហៈក៏ខាំខ្ញុំ ខ្ញុំដែលត្រូវសីហៈខាំផ្តួលហើយនោះ ក៏ធ្វើមរណកាលត្រង់កន្លែងនោះ ។

ព្រោះកុសលកម្មដែលខ្ញុំធ្វើហើយ ចំពោះព្រះសម្ពុទ្ធដ៏ប្រសើរមិនមានអាសវៈ ក្នុងពេលជិតមរណៈនោះ ខ្ញុំក៏បានទៅកើតឯឋានទេវលោក ដូចកម្ទាំងសរ ដែលរបូតចេញ ។ ប្រាសាទជាវិការៈនៃកែវមណីមានពណ៌ខៀវដែលបុញ្ញ-កម្មនិម្មិតហើយសម្រាប់ខ្ញុំ ក្នុងទេវលោកនោះ ជាប្រាសាទដ៏ល្អ មានកម្ពស់មួយពាន់ជួរកូនសរ មានជាន់ ១០០ បរិបូណ៌ដោយទង់ ។ ពន្លឺនៃប្រាសាទនោះផ្សាយចេញទៅ ដូចព្រះអាទិត្យរះឡើង ខ្ញុំជាអ្នកប្រាថ្នា រីករាយក្នុងកាមកុះករដោយស្រីទេពកញ្ញា ។ ខ្ញុំច្យុតចាកទេវលោកហើយ ត្រូវកុសលមូលដាស់តឿន ក៏បានមកកាន់មនុស្សភាព ហើយដល់នូវការក្ស័យនៃអាសវៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន ថ្វាយស្មៅសម្រាប់អង្គុយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្មៅមួយក្តាប់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណមុដ្ឋិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ តិណមុដ្ឋិទាយកត្ថេរាបទាន ។

## តិន្ទុកផលទាយកត្ថេរាបទានទី ៩

[ ៤៩ ] ខ្ញុំឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី គឺកិលេស ទ្រង់ធ្វើឱ្យ:ហើយ មិនមានអាសវ: ស្ដេចគង់ក្នុងចន្លោះភ្នំ រុងរឿងដូចផ្កាកណិការ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានឃើញដើមទន្លាប់ដែលមានផ្លែ ទើបកាច់យកទាំងទង ថ្វាយព្រះវេស្សភូ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែទន្លាប់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែទន្លាប់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិន្ទុកផលទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តិន្ទុកផលទាយកត្ថេរាបទាន ។**

## ឯកញ្ជលិយត្ថេរាបទានទី ១០

[ ៥០ ] កាលនោះ ព្រះសម្ពុទ្ធព្រះនាមរេវត: ស្ដេចគង់នៅទៀបផ្លូវស្ទឹង ខ្ញុំបានឃើញព្រះពុទ្ធ ដែលប្រាសចាកធូលី គឺកិលេស ដូចព្រះអាទិត្យមានរស្មីលឿង ឬដូចមុខភ្លើងគប់ ដែលត្រូវខ្យល់បក់ហើយ ពុំនោះសោតដូចរងើកភ្លើងនៃឧសគគីរ ទ្រង់រុងរឿងដូចផ្កាយព្រឹក ខ្ញុំធ្វើអញ្ជលីម្ដង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើអញ្ជលី ខ្ញុំមិន

ដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើអញ្ជលី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកញ្ជលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឯកញ្ជលិយត្ថេរាបទាន ។**

**ឧទ្ទាន**

ឯកបទុមិយត្ថេរាបទាន ១ តីណុប្បលមាលិយត្ថេរាបទាន ១ ធជទាយកត្ថេរាបទាន ១ តីណិកិង្កណិបូជកត្ថេរាបទាន ១ នឡាគារិកត្ថេរាបទាន ១ ចម្បកបុប្ផិយត្ថេរាបទាន ១ បទុមបូជកត្ថេរាបទាន ១ តិណមុដ្ឋិទាយកត្ថេរាបទាន ១ តិន្ទុកផលទាយកត្ថេរាបទាន ១ ឯកញ្ជលិយត្ថេរាបទាន ១ ចំនួនគាថា ៦៦ គាថា ដែលពួកអ្នកប្រាជ្ញរាប់ឃើញហើយ ។

**ចប់ ឯកបទុមវគ្គ ទី ៣៥ ។**

## អដ្ឋកថា

## ឯកបទុមិយត្ថេរាបទាន ជាដើម

[ ៤១-៥០ ] *អបទានរបស់ព្រះឯកបទុមិយត្ថេរជាដើមក្នុងវគ្គទី ៣៥ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាឯកបទុមិយត្ថេរាបទានជាដើម ចប់*

*ឯកបទុមវគ្គទី ៣៥ ចប់*

# សទ្ទសញ្ញិកវគ្គ ទី ៣៦

## សទ្ទសញ្ញិកត្ថេរាបទាន ទី ១

[ ៥១ ] ពីជាតិមុន ខ្ញុំជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះសម្ពុទ្ធ មានពួកទេវតាចោមរោម ក្នុងទីនោះ ដែលកំពុងទ្រង់ប្រកាសនូវសច្ចៈ ៤ ស្រោចស្រង់មហាជន ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីកាដ៏ពីរោះ ឧបមាដូចសម្រែក នៃករវិក ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសូរសៀងគឹកកងរបស់ព្រះមុនី ព្រះនាមសិខី ជាលោកពន្ធុ មានព្រះសូរសៀងដូចសំឡេងនៃព្រហ្ម ហើយដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃសេចក្តីជ្រះថ្លា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សទ្ទសញ្ញិកត្ថេរាបទាន ។

## យវកលាបិយត្ថេរាបទាន ទី ២

[ ៥២ ] ក្នុងកាលនោះ ខ្ញុំជាអ្នកធ្វើស្រែនៃស្រូវដំណើបនៅក្នុងនគរ អរុណវតី បានឃើញព្រះសម្ពុទ្ធក្នុងផ្លូវ ក៏បានក្រាលកណ្តាប់ស្រូវដំណើប ( ថ្វាយព្រះអង្គ ) ។ ព្រះសិខី ព្រះអង្គជាអគ្គនាយកក្នុងលោក មានសេចក្តី

អនុគ្រោះ មានសេចក្ដីករុណា ទ្រង់ជ្រាបនូវសេចក្ដីត្រិះរិះរបស់ខ្ញុំ ហើយគង់លើកម្រាលនៃស្រូវដំណើបនោះ ។ ខ្ញុំលុះបានឃើញ ( ព្រះសម្ពុទ្ធនោះ ) ព្រះអង្គគ្មានមន្ទិល មានឈានដ៏ប្រសើរ ជាអ្នកដឹកនាំ ( សត្វលោក ) កំពុងគង់នៅ ក៏ញុំាងប្រាមោទ្យឲ្យកើតឡើង ហើយធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសល-កម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាលកណ្ដាប់ស្រូវដំណើប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយវកលាបិយត្ថេរ មានអាយុបានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ យវកលាបិយត្ថេរាបទាន ។**

# កឹសុកបូជកត្ថេរាបទានទី ៣

[ ៥៣ ] ខ្ញុំបានឃើញផ្កាចាររឹក ហើយបេះ ផ្គងអញ្ជលីឡើងនឹកដល់ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ បូជាបោះទៅឰដ៏អាកាស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកឹសុកបូជកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កឹសុកបូជកត្ថេរាបទាន ។**

## សកោដកកោរណ្ឌទាយកត្ថេរាបទានទី ៤

[ ៥៤ ] ខ្ញុំបានឃើញស្នាមព្រះបាទរបស់ព្រះសិខី ជាផៅពង្សនៃលោក ដែលទ្រង់ជាន់ទុក ហើយធ្វើនូវស្បែកខ្លាទៀងស្នាម្ខាង ថ្វាយបង្គំស្នាមព្រះ-បាទដ៏ប្រសើរ ។ ខ្ញុំឃើញនូវដើមឈើដែលដុះលើផែនដី ឈ្មោះកោរណ្ឌព្រឹក្សមានផ្ការីក ហើយក៏កាច់យកទាំងត្រួយ មកបូជានូវចក្ក ពួដ៏ស្នាមព្រះបាទ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសល-កម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសកោដកកោរណ្ឌទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សកោដកកោរណ្ឌទាយកត្ថេរាបទាន ។**

## ទណ្ឌទាយកត្ថេរាបទានទី ៥

[ ៥៥ ] ក្នុងកាលនោះ ខ្ញុំបានចូលទៅក្នុងព្រៃធំ ហើយកាប់នូវឫស្សី យកមកធ្វើបង្កាន់ដៃប្រគេនដល់ព្រះសង្ឃ ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំថ្វាយបង្គំព្រះសង្ឃដែលមានវត្តដ៏ល្អ លុះប្រគេននូវបង្កាន់ដៃហើយ ក៏បែរមុខឆ្ពោះកាន់ឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានប្រគេននូវបង្កាន់ដៃ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការប្រគេនបង្កាន់ដៃ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះទណ្ឌទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ ទណ្ឌទាយកត្ថេរាបទាន ។

## អម្ពយាគុទាយកត្ថេរាបទានទី ៦

[ ៥៦ ] ព្រះបច្ចេកសម្ពុទ្ធ ព្រះនាមសតរង្សី ត្រាស់ដឹងឯង គ្មានសត្រូវផ្ចាលផ្ចាញ់បាន ទ្រង់ចេញអំពីសមាធិ ហើយស្តេចសំដៅមករកខ្ញុំដើម្បីភិក្ខា ។ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធ ដែលមានព្រះហឫទ័យស្អាត ខ្ញុំមានចិត្តជ្រះថ្លាបានប្រគេនបបរស្វាយ ដល់ព្រះបច្ចេកពុទ្ធនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ

ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបបរស្វាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពយាគុទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ អម្ពយាគុទាយកត្ថេរាបទាន ។**

# បុដកបូជកត្ថេរាបទានទី ៧

[ ៥៧ ] ព្រះពុទ្ធព្រះនាមវិបស្សី ជានាយកនៃលោក ទ្រង់ស្តេចចេញអំពីបន្លាសម្រាប់សម្រាកក្នុងវេលាថ្ងៃ ទ្រង់ធ្វើព្រះដំណើរទៅដើម្បីភិក្ខា បានទ្រង់ចូលសំដៅទៅរកខ្ញុំ ។ លំដាប់នោះ ខ្ញុំមានបីតិសោមនស្ស ក៏បានប្រគេននូវកញ្ចប់អំបិលដល់ព្រះពុទ្ធជាបុគ្គលប្រសើរ ប្រកបដោយតាទិគុណ ដោយសារកុសលនេះ ក៏បានរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកញ្ចប់អំបិល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយកញ្ចប់អំបិល ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដកបូជកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុដកបូជកត្ថេរាបទាន ។

# វច្ឆទាយកត្ថេរាបទានទី ៨

[ ៥៨ ] ខ្ញុំជ្រះថ្លាបានប្រគេនគ្រែមួយ ដល់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជាតាទិបុគ្គល ដោយដៃរបស់ខ្លួន ។ ដោយការថ្វាយគ្រែនោះ ខ្ញុំក៏បាននូវយានដំរី យានសេះ ជាយានទិព្វ ទាំងបានដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយគ្រែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយគ្រែ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវច្ឆទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វច្ឆទាយកត្ថេរាបទាន ។

## សរណាគមនិយត្ថេរាបទានទី ៩

[ ៥៩ ] ក្នុងកាលនោះ ភិក្ខុនិងខ្ញុំជាអាជីវក បានឡើងជិះទូក កាលទូលបែកធ្លាយ ភិក្ខុបានឲ្យសរណាគមន៍ដល់ខ្ញុំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលភិក្ខុបានឲ្យសរណាគមន៍ដល់ខ្ញុំ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសរណាគមន៍ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណាគមនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សរណាគមនិយត្ថេរាបទាន ។**

## បិណ្ឌទាតិកត្ថេរាបទានទី ១០

[ ៦០ ] កាលនោះ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ គង់នៅក្នុងព្រៃធំ ខ្ញុំចេញអំពីឋានតុសិតមកក្នុងទីនេះ បានថ្វាយបិណ្ឌបាត ។ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធព្រះនាមតិស្សៈ ព្រះអង្គមានយសធំ ហើយក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយត្រឡប់ទៅកាន់ឋានតុសិតវិញ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបិណ្ឌបាត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិណ្ឌបាតិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បិណ្ឌបាតិកត្ថេរាបទាន ។**

**ឧទ្ទាន**

សទ្ទសញ្ញិកត្ថេរាបទាន ១ យវកលាបិយត្ថេរាបទាន ១ កឹសុកបូជកត្ថេរាបទាន ១ សកោដកកោរណ្ឌបុប្ផិយត្ថេរាបទាន ១ អាលម្ពលទ ឬទណ្ឌទាយកត្ថេរាបទាន ១ អម្ពយាគុទាយកត្ថេរាបទាន ១ បុជកបូជកត្ថេរាបទាន ១ វច្ឆទាយកត្ថេរាបទាន ១ សរណាគមនិយត្ថេរាបទាន ១ បិណ្ឌបាតិកត្ថេរាបទាន ១ មានគាថា ៤០ ។

**ចប់ សទ្ទសញ្ញិកវគ្គទី ៣៦ ។**

## អដ្ឋកថា

## សទ្ទសញ្ញិកត្ថេរាបទាន ជាដើម

[ ៥១-៦០ ] អបទានរបស់ព្រះសទ្ទសញ្ញិកត្ថេរជាដើមក្នុងវគ្គទី ៣៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសទ្ទសញ្ញិកត្ថេរាបទានជាដើម ចប់

សទ្ទសញ្ញិកវគ្គទី ៣៦ ចប់

# មណ្ឌារវបុប្ផិយវគ្គ ទី ៣៧

## មណ្ឌារវិយត្ថេរាបទានទី ១

[ ៦១ ] ខ្ញុំជាទេវតាកំលោះឈ្មោះមង្គលៈ ចេញអំពីឋានតាវត្តិង្ស ហើយមកក្នុងទីនេះ បានយកផ្កាមន្ទារវៈ បាំងលើព្រះសិរ្សៈនៃព្រះពុទ្ធព្រះនាមវិបស្សី ព្រះអង្គស្វែងនូវគុណដ៏ធំ ដែលគង់នៅដោយសមាធិ លុះខ្ញុំបាំងថ្វាយអស់ ៧ ថ្ងៃហើយ ទើបបានទៅកាន់ទេវលោកវិញ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមន្ទារវិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ មន្ទារវិយត្ថេរាបទាន ។**

## កក្ការុបុប្ផិយត្ថេរាបទានទី ២

[ ៦២ ] ខ្ញុំចេញអំពីទេវលោកជាន់យាមៈ មកក្នុងទីនេះ បានឃើញព្រះគោតម ជាសិរីវឌ្ឍយគោត្ត ហើយយកផ្កាត្រឡាចបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ

ហើយ ។

បានឮថា ព្រះកក្ការុបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កក្ការុបុប្ផិយត្ថេរាបទាន ។**

# ភិសមុឡាលទាយកត្ថេរាបទានទី ៣

[ ៦៣ ] ព្រះសម្ពុទ្ធព្រះនាមផុស្សៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រាថ្នានូវវិវេក ទ្រង់ប្រកបដោយបញ្ញា បានស្តេចមកក្នុងសំណាក់របស់ខ្ញុំ ។ ខ្ញុំបានញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះជិនស្រី ព្រះអង្គប្រកបដោយមហាករុណានោះ ហើយបានយកក្រអៅឈូកថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយក្រអៅឈូក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយក្រអៅឈូក ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសមុឡាលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ភិសមុឡាលទាយកត្ថេរាបទាន ។**

# កេសរបុប្ផិយត្ថេរាបទានទី ៤

[ ៦៤ ] ក្នុងកាលនោះ ខ្ញុំកើតជាវិជ្ជាធរ នៅលើភ្នំហិមពាន្ត បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាករាគៈ មានយសធំ កំពុងចង្ក្រម ។ លុះឃើញហើយខ្ញុំបានតម្កល់ផ្កាកេសរ[១] ៣ ទង លើក្បាល ហើយនាំចូលទៅបូជាព្រះសម្ពុទ្ធព្រះនាមវេស្សភូ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកេសរបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ កេសរបុប្ផិយត្ថេរាបទាន ។**

---

១-ផ្កាបុសនាគ ។

# អង្កោលបុប្ផិយត្ថេរាបទានទី ៥

[ ៦៥ ] ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមបទុមៈ គង់នៅលើភ្នំចិត្ត-កូដ ខ្ញុំបានឃើញព្រះពុទ្ធជាសយម្ភូអគ្គនោះហើយ ក៏ចូលទៅជិត ។ ក្នុងកាលនោះ ខ្ញុំបានឃើញផ្កាអង្កោលរីក ហើយបេះកាន់ដើរចូលទៅ បូជាព្រះជិនស្រីសម្ពុទ្ធព្រះនាមបទុមៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអង្កោលបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អង្កោលបុប្ផិយត្ថេរាបទាន ។**

# កកុធបុប្ផិយត្ថេរាបទានទី ៦

[ ៦៦ ] ខ្ញុំអង្គុយលើប្រាសាទដ៏ប្រសើរ បានឃើញព្រះសម្ពុទ្ធជាលោកនាយក ព្រះអង្គមានវណ្ណៈដូចមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ប្រាកដស្មើដោយគ្រឿងបូជាមាស កំពុងស្តេចទៅកាន់ចន្លោះនៃរានផ្សារ ខ្ញុំបានយកផ្កាកកុធ បូជាព្រះពុទ្ធព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ

ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកទម្ពបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កទម្ពបុប្ផិយត្ថេរាបទាន ។**

# ឧទ្ទាលកបុប្ផិយត្ថេរាបទានទី ៧

[ ៦៧ ] ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមសុជាត ព្រះអង្គគង់នៅលើប្រាំងនៃទន្លេគង្គា ខ្ញុំបានយកផ្ការាជព្រឹក្សបូជាព្រះពុទ្ធ ទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទ្ទាលកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឧទ្ទាលកបុប្ផិយត្ថេរាបទាន ។**

# ឯកចម្បកបុប្ផិយត្ថេរាបទានទី ៨

[ ៦៨ ] ព្រះសម្ពុទ្ធមានព្រះហឫទ័យស្ងប់រម្ងាប់ គង់នៅនាចន្លោះភ្នំ ខ្ញុំបាន យកផ្កាចម្ប៉ាមួយ ដើរចូលទៅគាល់ព្រះសម្ពុទ្ធដ៏ឧត្តម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានកាន់ផ្កានោះដោយដៃទាំងពីរ ហើយបូជាព្រះបច្ចេកមុនីដ៏ ឧត្តមដែលទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែល ខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកចម្បកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឯកចម្បកបុប្ផិយត្ថេរាបទាន ។**

# តិមិរបុប្ផិយត្ថេរាបទានទី ៩

[ ៦៩ ] ខ្ញុំទៅតាមទីបណ្តោយខ្សែទឹក បានឃើញព្រះពុទ្ធជិតធ្វេរស្ទឹងចន្ទ- ភាគា ទ្រង់ប្រាសចាកធូលីគឺរាគៈ ទ្រង់ដូចសាលរាជព្រឹក្សមានផ្ការីក ។ ខ្ញុំ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ចំពោះព្រះបច្ចេកមុនីដ៏ឧត្តម បាននាំយកផ្កា តិមិរព្រឹក្ស មករោយលើព្រះកេសព្រះអង្គ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ

ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិមិរបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ តិមិរបុប្ផិយត្ថេរាបទាន ។**

# សលឡបុប្ផិយត្ថេរាបទានទី ១០

[ ៧០ ] ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរ នៅទៀបច្រាំងស្ទឹងចន្ទភាគា បានឃើញ ( នូវព្រះវិបស្សីសម្ពុទ្ធ ) ព្រះអង្គជាទេវតាកន្លងទេវតា ប្រសើរជាងពួកនរជន កំពុងចង្ក្រមក្នុងទីនោះ ។ ខ្ញុំបានបេះផ្កាស្រល់ បូជាដល់ព្រះពុទ្ធដ៏ប្រសើរ ឯព្រះសម្ពុទ្ធមានព្យាយាមធំ ទ្រង់បានស្រង់ក្លិនផ្កាស្រល់ ជាក្លិនទិព្វ ។ ក្នុងកាលនោះឯង ព្រះវិបស្សីសម្ពុទ្ធ ជាលោកនាយក មានព្យាយាមធំ ទ្រង់បានទទួលហើយ ស្រង់ក្លិនផ្ការបស់ខ្ញុំ ដែលខ្ញុំកំពុងតែក្រឡេកមើល ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានផ្គងអញ្ជលីថ្វាយបង្គំព្រះទិបទុត្តមាចារ្យ ហើយឡើងទៅលើភ្នំវិញ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ

ដោយប្រការដូច្នេះ ។

ចប់ សលឡបុប្ផិយត្ថេរាបទាន ។

ឧទ្ទាន

មន្ទារវិយត្ថេរាបទាន ១ កក្ការុបុប្ផិយត្ថេរាបទាន ១ ភិសមុឡាលទាយកត្ថេរាបទាន ១ កេសរបុប្ផិយត្ថេរាបទាន ១ អង្កោលបុប្ផិយត្ថេរាបទាន ១ កទម្ពបុប្ផិយត្ថេរាបទាន ១ ឧទ្ទាលកបុប្ផិយត្ថេរាបទាន ១ ឯកចម្បកបុប្ផិយត្ថេរាបទាន ១ តិមិរបុប្ផិយត្ថេរាបទាន ១ សលឡបុប្ផិយត្ថេរាបទាន ១ មានគាថា ៤០ ។

ចប់ មន្ទារវបុប្ផិយវគ្គ ទី ៣៧ ។

# អដ្ឋកថា

## មន្ទារវិយត្ថេរាបទាន ជាដើម

[ ៦១-៧០ ] អបទានរបស់ព្រះមន្ទារវិបុប្ផិយត្ថេរជាដើមក្នុងវគ្គទី ៣៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាមន្ទារវិយត្ថេរាបទានជាដើម ចប់

មន្ទារវបុប្ផិយវគ្គទី ៣៧ ចប់

# ពោធិវន្ទនវគ្គ ទី ៣៨

## ពោធិវន្ទកត្ថេរាបទាន ទី ១

[ ៧១ ] ខ្ញុំបានឃើញដើមប្រទៀងដ៏រុងរឿង ជាឈើដុះលើផែនដី ហើយខ្ញុំធ្វើ ( នូវសំពត់ ) ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីថ្វាយបង្គំនូវដើមប្រទៀង ។ ខ្ញុំផ្គងអញ្ជលី ធ្វើសេចក្តីគោរពក្នុងចិត្ត ថ្វាយបង្គំដើមប្រទៀង ហាក់ដូចជាព្រះសម្ពុទ្ធព្រះនាមវិបស្សីគង់នៅចំពោះមុខ ព្រះអង្គស្អាតទាំងក្នុង ស្អាតទាំងក្រៅ ទ្រង់រួចស្រឡះចាកវដ្តទុក្ខ មិនមានអាសវៈ ដែលត្រៃលោកបូជាហើយ មានព្រះករុណាញាណដូចសាគរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំពោធិព្រឹក្ស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិវន្ទកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ពោធិវន្ទកត្ថេរាបទាន ។**

# ចាជលិបុប្ផិយត្ថេរាបទានទី ២

[ ៧២ ] ព្រះជិនស្រីមានព្រះភាគ ព្រះនាមវិបស្សី ព្រះអង្គត្រាស់ដឹង ឯង ជាបុគ្គលដ៏ប្រសើរ មានពពួកសិស្សហែហម ហើយស្តេចចូលទៅកាន់ពន្ធុមតីនគរ ។ ខ្ញុំបានដក់ផ្កាប្រទៀង ៣ ទងក្នុងថ្នក់ ខ្ញុំប្រាថ្នានឹងកក់ក្បាល ខ្ញុំបានដើរទៅកាន់ឆ្នេរស្ទឹង ។ ខ្ញុំចេញអំពីក្រុងពន្ធុមតី បានឃើញព្រះពុទ្ធ ជាលោកនាយក ទ្រង់ដូចជាដើមរាជព្រឹក្សដ៏រុងរឿង កំពុងឆេះ ទ្រង់ដូចជាខ្លាធំ ឬដូចគោឧសភដ៏ប្រសើរ ឬក៏ដូចកេសររាជសីហ៍ មានជាតិដ៏ខ្ពស់ ព្រះអង្គប្រសើរជាងពួកសមណៈ កំពុងស្តេចទៅ ដោយមានភិក្ខុសង្ឃចោមរោម ខ្ញុំជ្រះថ្លាចំពោះព្រះសុគតអង្គនោះ ទ្រង់លាងមន្ទិល គឺកិលេស ហើយខ្ញុំកាន់យកផ្កាប្រទៀងទាំង ៣ ទង បូជាព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបាជលិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

ចប់ បាជលិបុប្ផិយត្ថេរាបទាន ។

# តីណុប្បលមាលិយត្ថេរាបទានទី ៣

[ ៧៣ ] ក្នុងកាលនោះ ខ្ញុំកើតជាស្វា នៅទៀបឆ្នេរស្ទឹងចន្ទភាគា បាន ឃើញព្រះពុទ្ធដែលប្រាសធូលី គឺរាគៈ គង់នៅនាចន្លោះភ្នំ ។ លុះខ្ញុំបានឃើញ ( ព្រះសម្ពុទ្ធនោះ ) ទ្រង់ប្រកបដោយលក្ខណៈនិងព្យញ្ជនៈ ដែលកំពុងញុំាង ទិសទាំងពួងឲ្យភ្លឺស្វាង ដូចជាផ្កាសាលរាជព្រឹក្សរីកហើយ ខ្ញុំក៏មានចិត្តត្រេក អរ ។ លុះខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តសោមនស្ស មានចិត្តរីករាយដោយបីតិ ហើយបូជាផ្កាទាំង ៣ លើព្រះសិរ្សៈ ។ លុះខ្ញុំបូជាផ្កាទាំងឡាយ ដល់ព្រះ ផុស្សសម្ពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំហើយ ខ្ញុំក៏ធ្វើសេចក្តីគោរព រួចបែរ មុខ ឆ្ពោះទៅកាន់ឧត្តរទិស ដើរចៀសចេញទៅ ។ ខ្ញុំកំពុងដើរថយក្រោយ ទាំង មានចិត្តជ្រះថ្លា ក៏ធ្លាក់ទៅក្នុងជ្រោះភ្នំដល់នូវការអស់ទៅនៃជីវិត ដោយកុសល កម្មដែលខ្ញុំធ្វើនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបុរិមជាតិ នោះហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស បានសោយទេវរាជ្យអស់បីរយដង បានជាស្តេចចក្កពត្តិអស់ប្រាំរយដង ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះ ហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណុប្បលមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

**ចប់ តីណុប្បលមាលិយត្ថេរាបទាន ។**

# បត្តិបុប្ផិយត្ថេរាបទានទី ៤

[ ៧៤ ] វេលាដែលព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គស្វែងរកនូវគុណដ៏ធំ បរិនិព្វានហើយ ពួកជនទាំងអស់នោះ នាំគ្នាមកប្រជុំ រំកិលនូវព្រះសរីរៈ កាលកំពុងរំកិលព្រះសរីរៈ កំពុងវាយស្គរ ( លាន់ឮគឹកកងរំពង ) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាជាចំណែកបុណ្យ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះសរីរៈ ។ ឱ ! ខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់តើហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបត្តិបុប្ផិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បត្តិបុប្ផិយត្ថេរាបទាន ។**

# សត្តបណ្ណិយត្ថេរាបទានទី ៩

[ ៧៥ ] ព្រះសម្ពុទ្ធព្រះនាមសុមនៈ ជាលោកនាយក ទ្រង់ត្រាស់ឡើង ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជានូវផ្កាសត្តបណ្ណិ ( ដល់ព្រះអង្គ ) ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន បូជាផ្កាសត្តបណ្ណិ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កាសត្តបណ្ណិ ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ កិលេសទាំង-ឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តបណ្ណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សត្តបណ្ណិយត្ថេរាបទាន ។**

# គន្ធមុដ្ឋិយត្ថេរាបទានទី ៦

[ ៧៦ ] កាលគេកំពុងធ្វើជើងក្ករ កាលក្លិនក្រអូបផ្សេងៗកំពុងប្រជុំព្រម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាមួយក្តាប់ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាជើងក្ករ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងក្ករ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធមុដ្ឋិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ គន្ធមុដ្ឋិយត្ថេរាបទាន ។**

# ចិតកបូជកត្ថេរាបទានទី ៧

[ ៧៧ ] កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈបរិនិព្វាន កាលគេកំពុងលើកជើងក្ករ ខ្ញុំបានបូជាផ្កាកាំងក្ដ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងក្ករ ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា

៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ចិតកបូជកត្ថេរាបទាន ។**

# សុមនតាលវណ្ដិយត្ថេរាបទានទី ៨

[ ៧៨ ] ខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោតដែលគេរំលេចដោយផ្កាម្ទេះទាំងឡាយ ដល់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ខ្ញុំបានបាំងថ្វាយព្រះពុទ្ធ មានយសធំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោត ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្ចិតស្លឹកត្នោត ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ

ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនតាលវណ្តិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សុមនតាលវណ្តិយត្ថេរាបទាន ។**

## សុមនទាមិយត្ថេរាបទានទី ៩

[ ៧៩ ] ខ្ញុំធ្វើកម្រងផ្កាម្លិះ ហើយឈរបាំងថ្វាយចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ព្រះអង្គមានកិលេសលាងហើយ មានតបធម៌ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាកម្រងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រងផ្កាម្លិះ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនទាមិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សុមនទាមិយត្ថេរាបទាន ។**

# កាសុមារិផលទាយកត្ថេរាបទានទី ១០

[ ៨០ ] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលីគឺរាគៈ ជាច្បង ក្នុងលោក ប្រសើរជាងនរៈ ដែលគង់នៅនាចន្លោះភ្នំ ទ្រង់រុងរឿងដូចផ្កាកណិការ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើអញ្ជលីលើត្បូងហើយ កាន់ផ្លែកាសុមារិព្រឹក្ស ថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកាសុមារិផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កាសុមារិផលទាយកត្ថេរាបទាន ។**

ឧទ្ទាន

ពោធិវន្ទកត្ថេរាបទាន ១ បាដលិបុប្ផិយត្ថេរាបទាន ១ តីណុប្បលមាលិយត្ថេរាបទាន ១ បត្តិបុប្ផិយត្ថេរាបទាន ១ សត្តបណ្ណិយត្ថេរាបទាន ១ គន្ធមុដ្ឋិយត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ សុមនតាលវណ្តិយត្ថេរាបទាន ១ សុមនទាមិយត្ថេរាបទាន ១ កាសុមារិផលទាយកត្ថេរាបទាន ១ មានគាថា ៥៩ ។

ចប់ ពោធិវន្ទនវគ្គទី ៣៨ ។

## ពោធិវន្ទនវគ្គ ទី ៣៨

### អដ្ឋកថា ពោធិវន្ទកត្ថេរាបទាន ជាដើម

[ ៧១-៨០ ] អបទានរបស់ព្រះពោធិវន្ទកត្ថេរជាដើម ក្នុងវគ្គទី ៣៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពោធិវន្ទកត្ថេរាបទានជាដើម ចប់

ពោធិវន្ទនវគ្គទី ៣៨ ចប់

# អម្ពដផលវគ្គ ទី ៣៩

## អម្ពដផលទាយកត្ថេរាបទាន ទី ១

[ ៨១ ] ព្រះសម្ពុទ្ធមានព្រះភាគ ព្រះនាមសតរង្សី ព្រះអង្គត្រាស់ដឹង ឯង ទ្រង់ឈ្នះកិលេស មានប្រាថ្នានូវវិវេក បានចេញទៅដើម្បីគោចរ ។ ខ្ញុំមានផ្លែឈើក្នុងដៃ បានឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ ដ៏ប្រសើរជាងនរៈ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ហើយបានថ្វាយផ្លែម្កាក់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពដផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ អម្ពដផលទាយកត្ថេរាបទាន ។**

# លពុជទាយកត្ថេរាបទានទី ២

[ ៨២ ] ក្នុងកាលនោះ ខ្ញុំជាអារាមិកជន ( អ្នកថែសួនច្បារ ) នៅក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ កំពុងស្តេចទៅឰដ៏អាកាស ។ ខ្ញុំបានយកផ្លែខ្នុរសម្រាប់ថ្វាយព្រះពុទ្ធដ៏ប្រសើរ ឯព្រះសម្ពុទ្ធមានយសដ៏ធំ មានព្រះហឫទ័យស្ងប់រម្ងាប់ បានទ្រង់ឋិតនៅឰដ៏អាកាស ទទួលយក ។ ខ្ញុំមានការកើតឡើងនៃបីតិ ដែលជាគុណនាំមកនូវសេចក្តីសុខ ក្នុងបច្ចុប្បន្ន ព្រោះតែថ្វាយផ្លែខ្នុរដល់ព្រះពុទ្ធ ដោយចិត្តជ្រះថ្លា ។ ក្នុងកាលនោះឯង ខ្ញុំមានបីតិដ៏ទូលំទូលាយផង មានសេចក្តីសុខដ៏ឧត្តមផង រតនៈតែងកើតឡើងដល់ខ្ញុំដែលកើតហើយក្នុងឋានទាំងពួង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលពុជទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ លពុជទាយកត្ថេរាបទាន ។**

## ឧទុម្ពរផលទាយកត្ថេរាបទានទី ៣

[ ៨៣ ] ព្រះពុទ្ធជាបុរសខ្ពង់ខ្ពស់ គង់នៅទៀបច្រាំងស្ទឹងវិនតា ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ មានព្រះហឫទ័យតម្កល់មាំមានអារម្មណ៍តែមួយ ។ ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះសម្ពុទ្ធនោះ ព្រះអង្គលាងមន្ទិលគឺកិលេស ខ្ញុំក៏បានយកផ្លែឧទុម្ពរ ថ្វាយដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរ ដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទុម្ពរផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឧទុម្ពរផលទាយកត្ថេរាបទាន ។**

# មិលក្ខុផលទាយកត្ថេរាបទានទី ៤

[ ៨៤ ] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គយល់ឃើញនូវប្រយោជន៍ មានយសធំ ត្រង់ចន្លោះព្រៃ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែមិលក្ខុព្រឹក្ស ( ដីប៉ី ) ។ ក្នុងកប្បទី ១.៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមិលក្ខុផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ មិលក្ខុផលទាយកត្ថេរាបទាន ។**

# ផារុសផលទាយកត្ថេរាបទានទី ៩

[ ៨៥ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គមានវណ្ណៈដូចមាស ព្រះអង្គគួរទទួលនូវគ្រឿងសក្ការៈ ដែលពួកជននាំមកបូជា កំពុងស្តេចទៅក្នុងច្រកហើយខ្ញុំប្រគេនផ្លែមាក់ប្រាង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់តើហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះផារុសផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ផារុសផលទាយកត្ថេរាបទាន ។**

# វល្លិផលទាយកត្ថេរាបទានទី ៦

[ ៨៦ ] ក្នុងកាលនោះ ជនទាំងពួងមកប្រជុំគ្នាក្នុងព្រៃ ជនទាំងឡាយនោះ បាននាំគ្នាស្វែងរកផ្លែឈើ ក៏បាននូវផ្លែឈើ ។ ក្នុងកាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេស ក្នុងទីនោះ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែវល្លិ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវល្លិផលទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ វល្លិផលទាយកត្ថេរាបទាន ។**

## កទលិផលទាយកត្ថេរាបទានទី ៧

[ ៨៧ ] ខ្ញុំបានឃើញព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទក្នុងថ្ងៃទី ១៥ កើត ឬក៏ដូចទីបរុក្ខ ( ដើមឈើប្រចាំទ្វីប ) ដ៏រុងរឿង ។ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្លែចេកថ្វាយព្រះ-សាស្តា ហើយថ្វាយបង្គំ ដើរចេញទៅ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកទលិផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កទលិផលទាយកត្ថេរាបទាន ។**

## បទសផលទាយកត្ថេរាបទានទី ៨

[ ៨៨ ] ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមអជ្ជុនៈ ព្រះអង្គបរិបូណ៌ដោយចរណៈផង ជាអ្នកប្រាជ្ញឈ្លាសវៃក្នុងសមាធិផង គង់នៅក្នុងហិមវន្តប្រទេស ។ ខ្ញុំបានយកផ្លែខ្នុរទាំងស្រស់ ប្រមាណប៉ុនក្អម តម្កល់លើស្លឹកឈើមានសណ្ឋានដូចឆត្រ ថ្វាយដល់ព្រះសាស្តា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទសផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បទសផលទាយកត្ថេរាបទាន ។**

# អម្ពដផលវគ្គ ទី ៣៩

## អដ្ឋកថា អម្ពដផលទាយកត្ថេរាបទាន ជាដើម

*[ ៨១-៨៨ ] អបទានទី ១ ទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ទី ៧ និងទី ៨ ក្នុងអម្ពដផលវគ្គទី ៣៩ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាអម្ពដផលទាយកត្ថេរាបទានជាដើម ចប់*

# សោណកោដិវិសត្ថេរាបទានទី ៩

[ ៨៩ ] ក្នុងសាសនានៃព្រះពុទ្ធព្រះនាមវិបស្សី ខ្ញុំបានធ្វើគុហាមួយក្នុងរាជធានី ឈ្មោះពន្ធុមតី ដើម្បីសង្ឃ ដែលមកអំពីទិសទាំង ៤ ។ ខ្ញុំបានចំណាយសំពត់ក្រាលទីគុហាដោយសំពត់ ខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តសោមនស្ស ក៏ធ្វើនូវសេចក្ដីប្រាថ្នាក្នុងកាលនោះថា ខ្ញុំសូមឲ្យព្រះសម្ពុទ្ធប្រោសប្រាណផង សូមឲ្យបានបព្វជ្ជាផង សូមពាល់ត្រូវនូវព្រះនិព្វានដ៏ប្រសើរ ជាសន្តិសុខ ដ៏ឧត្តមផង កុំបីអាក់ខាន ។ ដោយកុសលមូលនោះឯង ខ្ញុំអន្ទោលទៅកើតជាទេវតានិងមនុស្ស បានធ្វើបុណ្យហើយរុងរឿងអស់ ៩០ កប្ប ។ ក្នុងភពជាទីបំផុតនេះ ខ្ញុំបានកើតជាបុត្តឯក របស់សេដ្ឋីដ៏ប្រសើរ ក្នុងក្រុងចម្ប៉ា ដោយសំណល់នៃបុញ្ញកម្មនោះ ។ ធនុះរបស់បិតានៃខ្ញុំនេះ បានកើតឡើងថា អាត្មាអញនឹងឲ្យដល់កុមារនូវទ្រព្យ ២០ កោដិ មិនឲ្យខ្វះខាត ព្រោះពុថា ខ្ញុំកើតហើយ ។ រោមទាំងឡាយនៃខ្ញុំប្រវែង ៤ ធ្នាប់ ដុះត្រង់ផ្ទៃនៃបាតជើងទាំងគូ ជារោមល្អិត មានសម្ផស្សទន់ល្អដូចប៉ុយគ ។ កន្លងទៅ ៩១ កប្ប នឹងកប្បនេះហើយ ខ្ញុំមិនដែលស្គាល់ដាក់ជើងជាន់លើទីដែលគេមិនក្រាលឡើយ ។ ខ្ញុំបានឲ្យព្រះសម្ពុទ្ធទ្រង់ប្រោសប្រាណ ខ្ញុំបានចូលទៅកាន់ផ្នួស ខ្ញុំបានដល់ព្រះអរហត្តហើយ ខ្ញុំជាបុគ្គលមានសេចក្ដី ត្រជាក់ត្រជាំកើតឡើងហើយ ជាបុគ្គលមានទុក្ខរំលត់អស់ហើយ ។ ព្រះសម្ពុទ្ធព្រះអង្គយល់ឃើញសព្វ បានសម្ដែងថា បណ្ដាបុគ្គលដែលមានព្យាយាមប្រារព្ធដ៏ប្រសើរ ខ្ញុំនេះជាបុគ្គលមានអាសវៈអស់ហើយ ជាព្រះអរហន្ត បានអភិញ្ញា ៦ មានឫទ្ធិដ៏ច្រើន ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែល

ខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃលេណទាន ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរី កាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។ ព្រះសោណកោដិវីសត្ថេរ បានព្យាករដោយសេចក្តីពិស្តារនូវប្រស្នាដែលភិក្ខុសង្ឃសួរហើយ ជិតមហាស្រះឈ្មោះអនោតត្ត ។

បានឮថា ព្រះសោណកោដិវីសត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ សោណកោដិវីសត្ថេរាបទាន ។

# អដ្ឋកថា
# សោណកោដិវីសត្ថេរាបទាន

[ ៨៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះថា អបទានរបស់ព្រះសោណកោដិវីសត្ថេរ មានពាក្យផ្តើមថា **វិបស្សិនោ ទាវចនេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា វិបស្សី កើតក្នុងត្រកូលសេដ្ឋីមានសម្បត្តិច្រើន លុះចម្រើនវ័យហើយក៏បានជាសេដ្ឋី ។ ថ្ងៃមួយទៅកាន់វិហារជាមួយពួកឧបាសក បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មានចិត្តជ្រះថ្លា បានបូកបាយអក្នុងទីចង្ក្រមរបស់ព្រះមានព្រះភាគ និងធ្វើគុហា ( ទីសម្ងំ ) មួយកន្លែង បានក្រាលផ្ទៃដីដោយសំពត់មានពណ៌ផ្សេងៗ និងធ្វើពិដានទុកខាងលើ វេរថ្វាយដល់សង្ឃដែលមកអំពីទិសទាំង ៤ បានថ្វាយមហាទានអស់ ៧ ថ្ងៃ បានធ្វើការតាំងបណិធានទុក ព្រះសាស្តាទ្រង់បានធ្វើអនុមោទនាហើយ ។ ដោយកុសលកម្មនោះ កុលបុត្តនោះ បានអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងកប្បនេះ កាលព្រះកស្សបទសពលបរិនិព្វានហើយ កាលព្រះមានព្រះភាគនៃយើង ទ្រង់មិនទាន់កើតឡើង កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ក្នុងនគរពារាណសី លុះចម្រើនវ័យហើយ បានសាងបណ្ណសាលាទុកត្រង់ឆ្នេរស្ទឹងគង្គា បានទំនុកបម្រុងព្រះ

បច្ចេកពុទ្ធ ១ អង្គជាប្រចាំដោយបច្ច័យ ៤ អស់កាល ៣ ខែ ដោយសេចក្តីគោរព ។ ព្រះបច្ចេកពុទ្ធអង្គនោះ ចេញវស្សាហើយ មានបរិក្ខារគ្រប់បរិបូណ៌ បានទៅកាន់ភ្នំគន្ធមាទន៍នោះឯង ។ កុលបុត្តនោះ បានធ្វើបុណ្យជាច្រើនក្នុងជាតិនោះ ដរាបដល់អស់ជីវិត ចុតិចាកជាតិនោះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគនៃយើង កុលបុត្តនេះ បដិសន្ធិក្នុងផ្ទះរបស់អគ្គសេដ្ឋី ក្នុងនគរចម្ប៉ា ។ តាំងពីកុលបុត្តនេះបដិសន្ធិ គំនរនៃភោគសម្បត្តិដ៏ច្រើនកើតឡើងដល់សេដ្ឋី ។ ក្នុងថ្ងៃដែលកុលបុត្តនោះប្រសូតចាកផ្ទៃមាតា លាភសក្ការៈនិងការរាប់អានជាច្រើន ក៏បានកើតមានពេញព្រះនគរ ។ ដោយផលបុណ្យដែលបានបរិច្ចាគសំពត់កម្ពលក្រហម ដែលមានតម្លៃមួយសែនដល់ព្រះបច្ចេកពុទ្ធក្នុងកាលមុន ទើបកុលបុត្តនោះ មានពណ៌សម្បុរដូចមាស និងមានអត្តភាពសុខមាលជាតិក្រៃលែង ដោយហេតុនោះ ទើបពួកញាតិដាក់ឈ្មោះថា សោណៈ ។ កុលបុត្តនោះ ចម្រើនវ័យមួយអន្លើដោយបរិវារច្រើន បាតដៃនិងបាតជើងរបស់កុលបុត្តនោះ មានពណ៌ដូចផ្កាសិរមាន់ មានសម្ផស្សទន់ដូចគ្នានឹងសំឡីដែលគេថ្ពិចអស់មួយរយដង ព្រោះបាតដៃនិងបាតជើងទាំងពីរ មានដុះរោមជារង្វង់ ដូចគ្នានឹងកុណ្ឌលកែវមណី កាលកុលបុត្តនោះចម្រើនវ័យហើយ ពួកញាតិបានសាងប្រាសាទ ៣ ដែលសមគួរដល់រដូវទាំង ៣ ឲ្យដល់កុលបុត្តនេះ និងប្រគល់ស្រីរបាំឲ្យ កុលបុត្តនោះ សោយសម្បត្តិដ៏ធំនៅក្នុងប្រាសាទនោះដូចទេវកុមារ ។

កាលព្រះមានព្រះភាគនៃយើង បានសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ

សម្តែងព្រះធម្មចក្កដ៏ប្រសើរ គង់នៅក្នុងនគររាជគ្រឹះ ត្រូវព្រះបាទពិម្ពិសារត្រាស់ឲ្យចូលគាល់ ទើបមកកាន់នគររាជគ្រឹះ មួយអន្លើដោយអ្នកស្រុក ៨ ម៉ឺននាក់ ហើយទៅកាន់សម្នាក់របស់ព្រះសាស្តា បានស្តាប់ធម៌ហើយ បានទូវសទ្ធា សូមអនុញ្ញាតមាតាបិតា ហើយបួសក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ លុះបានឧបសម្បទាហើយ រៀននូវកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ទៅកាន់សីតវនដើម្បីចៀសអំពីការប្រឡូកប្រឡំដោយពួកជន កាលនៅក្នុងទីនោះលោកគិតថា សរីរៈរបស់អញល្អិតសុខុម គង់សម្រេចសេចក្តីសុខបែបសប្បាយៗ មិនបាន អញគួរបំពេញសមណធម៌ ដោយធ្វើកាយឲ្យលំបាកដូច្នេះហើយ ទើបអធិដ្ឋានការបង្រ្កមតែម្យ៉ាង ផ្តើមប្រកបសេចក្តីព្យាយាមកាលជើងទាំងពីរបើមក៏ដោយ ក៏មិនគិតដល់ទុក្ខវេទនា ធ្វើសេចក្តីព្យាយាមដ៏ខ្លាំងក្លា តែមិនអាចធ្វើគុណវិសេសឲ្យកើតឡើងបាន ព្រោះប្រារព្ធព្យាយាមតឹងពេក ទើបគិតថា អញព្យាយាមដល់ម្ល៉េះ ក៏មិនអាចធ្វើមគ្គនិងផលឲ្យកើតឡើងបាន អញបួសធ្វើអ្វី សឹកទៅសោយសម្បត្តិនឹងធ្វើបុណ្យឲ្យច្រើន ល្អជាង ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបវារចិត្តរបស់កុលបុត្តនោះ ទើបយាងទៅកាន់ទីនោះ ទ្រង់ប្រទានឱវាទឧបមាដោយខ្សែពិណ កាលទ្រង់សម្តែងវិធីប្រកបព្យាយាមឲ្យស្មើ និងទ្រង់ជម្រះកម្មដ្ឋានឲ្យ ហើយយាងទៅកាន់ភ្នំគិជ្ឈកូដ ។ ចំណែកព្រះសោណៈ បានទទួលឱវាទអំពីសម្នាក់របស់ព្រះសាស្តាហើយ ប្រកបសេចក្តីព្យាយាមឲ្យស្មើ ចម្រើនវិបស្សនាហើយ បានតាំងនៅក្នុងអរហត្ត ។

ព្រះសោណៈនោះ បានជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **វិបស្សិនោ ចាវចនេ** ដូច្នេះជាដើម ។

បទថា **វិបស្សី** ក្នុងអបទាននោះ សំដៅសេចក្តីថា ឃើញដោយ វិសេស ឬឃើញបានច្រើនយ៉ាង ។ បទថា **ចាវចនេ** សេចក្តីថា ឈ្មោះថា **ចាវចន** ព្រោះលោកហៅដោយទូទៅ បានដល់ ព្រះត្រៃបិដក អធិប្បាយថា ក្នុងបាវចនៈរបស់ព្រះវិបស្សីសម្មាសម្ពុទ្ធនោះ ។ បទថា **លេណំ** សេចក្តីថា ឈ្មោះថា **លេណ** ព្រោះជាទីពួន ជាទីពឹង បានដល់ វិហារ ។ បទថា **ពន្ធុមា-រាជធានិយា** ញែកវិគ្គហៈថា ឈ្មោះថា **ពន្ធុ** គឺទាក់ទងគ្នា គឺសម្ព័ន្ធគ្នានឹងគ្នា មកដោយអំណាចការបន្តអំពីត្រកូល បានដល់ ញាតិ ។ ឈ្មោះថា **ពន្ធុមា** ព្រោះញាតិនៅប្រចាំក្នុងទីនោះ ន័យមួយទៀត ឈ្មោះថា **ពន្ធុមា** ព្រោះមានការទាក់ទងគ្នា ។ ឈ្មោះថា **រាជធានី** ព្រោះជាទីប្រថាប់នៅរបស់ព្រះរាជា នគរពន្ធុមាផង ជារាជធានីផង រួមគ្នាជា **ពន្ធុមារាជធានី** ភ្ជាប់សេចក្តីថា ខ្ញុំបានសាងទីសម្ងំ គឺវិហារត្រង់រាជធានីរបស់ព្រះបាទពន្ធុមានោះ ។ ពាក្យដ៏សេសក្នុងអបទាននេះ មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាសោណកោដិវីសត្ថេរាបទាន ចប់

# បុព្វកម្មបិលោតិឆាមពុទ្ធាបទាន ទី ១០

[ ៩០ ] ព្រះលោកនាយក មានភិក្ខុសង្ឃច្រើនចោមរោម ទ្រង់គង់លើផ្ទៃនៃថ្មជាទីរីកកាយ ជិតស្រះអនោតត្ត រុងរឿងដោយរតនៈផ្សេងៗ ក្នុងចន្លោះនៃព្រៃ មានក្លិនផ្កាផ្សេងៗ ទ្រង់ព្យាករនូវបុព្វកម្មរបស់ព្រះអង្គ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវអំពើរបស់តថាគតដែលបានធ្វើទុកមកហើយ ដូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេនកំណាត់សំពត់ ។ ក្នុងកាលនោះ តថាគតបានប្រាថ្នាជាព្រះសម្ពុទ្ធជាដំបូង ដើម្បីការត្រាស់ដឹង ឯសេចក្តីប្រាថ្នានោះ ក៏ឲ្យផលក្នុងការបានត្រាស់ជាព្រះពុទ្ធ ដោយអំណាចនៃបិលោតិកម្ម ។ ក្នុងកាលមុន តថាគតកើតជានាយគោបាល កៀងមេគោទៅកាន់ទីគោចរ បានឃើញមេគោកំពុងផឹកទឹកល្អក់ ហើយដេញចេញ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតស្រេកទឹក ហើយមិនបានផឹក ដូចសេចក្តីប្រាថ្នា ។ កាលភពមុន ក្នុងជាតិដទៃ តថាគតជាអ្នកលេង ឈ្មោះបុនាលិ បានពោលបង្កាច់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរភី ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។ ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ រងទុក្ខវេទនាអស់ពាន់នៃឆ្នាំដ៏ច្រើន ។ ដោយសំណល់នៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតបាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។ មួយទៀត តថាគតពោលបង្កាច់សាវ័ក ឈ្មោះនន្ទ របស់ព្រះពុទ្ធ ទ្រង់គ្របសង្កត់នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅក្នុងនរកអស់កាលដ៏យូរ ព្រោះការពោលបង្កាច់នូវសាវ័កនោះ ។ តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ

ចំនួនមួយហ្មឺនឆ្នាំ លុះតថាគតបានមកជាមនុស្ស ក៏បាននូវការពោលបង្កាច់ជាច្រើន ។ ដោយសំណល់នៃកម្មនោះ នាងចិញ្ចមាណវិកា មកពោលបង្កាច់តថាគត ក្នុងប្រជុំជន ដោយពាក្យមិនពិត ។ តថាគតកើតជាព្រាហ្មណ៍ តែងជាអ្នកចេះមន្ត្រ មានគេធ្វើសក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ ក្នុងព្រៃធំ ។ ឥសីភិមៈ បានអភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគតបានឃើញឥសីនោះ លោកជាអ្នកមិនប្រទូស្ត និមន្តមក ក៏បានពោលបង្កាច់ ។ លំដាប់នោះ តថាគតនិយាយនឹងពួកសិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម កាលតថាគតនិយាយប្រាប់ ឯពួកមាណព ក៏បានរីករាយតាម ។ លំដាប់នោះ មាណពទាំងអស់ ត្រាច់ទៅសូមក្នុងត្រកូលតូចធំ និយាយប្រាប់មហាជនថា ឥសីនេះ ជាអ្នកបរិភោគកាម ។ ដោយវិបាកនៃកម្មនោះ ភិក្ខុទាំងអស់ចំនួន ៥០០ នេះ ក៏បាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។ កាលភពមុន តថាគតសម្លាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឲ្យប៉ះនឹងថ្ម ។ ដោយវិបាកនៃកម្មនោះ ទេវទត្តបានប្រមៀលថ្ម ដុំថ្មក៏រមៀលមកប៉ះអង្គុដ្ឋបាទ ( មេជើង ) នៃតថាគត ។ កាលពីជាតិមុន តថាគតជាទារក កំពុងលេងក្នុងផ្លូវធំ បានឃើញព្រះបច្ចេកពុទ្ធ ក៏ដុតព្រៃទាំងមូលក្បែរផ្លូវ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ ទេវទត្តក៏ប្រើខ្មាន់ធ្នូ ឲ្យសម្លាប់តថាគត ។ កាលពីជាតិមុន តថាគតកើតជាហ្មដំរី បានបរដំរីបំព្រេចព្រះបច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត ។ ដោយវិបាកនៃកម្មនោះ ដំរីនាឡាគិរីចុះប្រេង កាច ចូលមកព្រេច

តថាគតក្នុងគិរិព្វជបុរីដ៏ប្រសើរ ( រាជគហៈ ) ។ តថាគតកើតជាស្តេចឈ្មោះ
បត្តិកៈ បានយកលំពែងសម្លាប់បុរសទាំងឡាយ ដោយវិបាកនៃកម្មនោះ
តថាគតឆេះក្នុងភ្លើងនរកក្លាខ្លាំង ។ ដោយសំណល់នៃកម្មនោះ ក្នុងកាល
ឥឡូវនេះ កម្មវិបាកនោះ ក៏ធ្វើឲ្យរបកស្បែកជើងទាំងអស់ របស់តថាគត
ព្រោះថា កម្មនៅតែមិនទាន់វិនាស ។ តថាគតកើតជាទារកនៃព្រានត្រី ក្នុង
កេវដ្តគ្រាម បានឃើញពួកជនអ្នកសម្លាប់ត្រី ក៏កើតសោមនស្ស ។ ដោយវិបាក
នៃកម្មនោះ ស្តេចវិដដុភៈសម្លាប់ពួកសក្យៈ ក្នុងកាលណា ទុក្ខក្នុងក្បាលក៏
មានដល់តថាគត ( ក្នុងកាលនោះ ) ព្រោះពួកសក្យៈ ត្រូវគេសម្លាប់ ។
តថាគតបានពោលផ្តន្ទា នូវពួកសាវកក្នុងសាសនានៃព្រះពុទ្ធ ព្រះនាមផុស្សៈ
ថា ចូរលោកទាំងឡាយ ទំពាស៊ីបរិភោគនូវបាយដំណើបចុះ កុំបរិភោគនូវ
បាយស្រូវសាលីឡើយ ។ ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគតនៅ
ក្នុងស្រុកវេរញ្ជា ព្រាហ្មណ៍និមន្តឲ្យឆាន់តែបាយដំណើបអស់ ៣ ខែ ។
តថាគតបានហាមឃាត់កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយ
វិបាកនៃកម្មនោះ ជំងឺខ្នងក៏កើតឡើងដល់តថាគត ។ តថាគតកើតជាពេទ្យបាន
ដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្ត ដោយវិបាកនៃកម្មនោះ ជំងឺចុះឈាមក៏កើតឡើងដល់
តថាគត ។ ក្នុងភពមួយនោះ តថាគតកើតជាជោតិបាល បានជួញផ្ចាល់ព្រះ
សុគត ព្រះនាមកស្សបៈថា ព្រោះអ្វីក៏ថាត្រាស់ដឹង ពោធិញ្ញាណជាទីផូរផង់
គេរកបានដោយកម្រក្រៃលែង ។ ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្ត
ទុក្ករកិរិយាជាច្រើន ក្នុងឧរុវេលប្រទេសអស់ ៦ វស្សាទើបបានត្រាស់ដឹង

ឡើង ។ តថាគតមិនបាននូវពោធិញ្ញាណ ដ៏ឧត្តមដោយផ្លូវនុ៎ះទេ តថាគត ហេតុតែបុព្វកម្មនោះដាស់តឿន ក៏ស្វែងរកតាមផ្លូវខុស ។ តថាគតមានបុណ្យ និងបាបអស់រលីងហើយ បានវៀរបង់នូវកម្តៅទាំងពួង មិនមានសេចក្តីសោក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះជិនស្រី ទ្រង់ដល់នូវអភិញ្ញានិងពលៈទាំងពួង បានព្យាករដោយសេចក្តីពិស្តារ ដល់ភិក្ខុសង្ឃ ជិតមហាស្រះឈ្មោះអនោតត្ត ដូចរៀបរាប់មកនេះឯង ។

បានឮថា ព្រះមានព្រះភាគ បានសម្តែងនូវពុទ្ធាបទានឈ្មោះ បុព្វកម្មបិលោតិ ជាធម្មបរិយាយដែលជាបុព្វចរិតរបស់ព្រះអង្គ ដោយប្រការដូច្នេះ ។

**ចប់ បុព្វកម្មបិលោតិនាមពុទ្ធាបទាន ។**

**ឧទ្ទាន**

អម្ពដផលទាយកត្ថេរាបទាន ១ លពុជទាយកត្ថេរាបទាន ១ ឧទុម្ពរផលទាយកត្ថេរាបទាន ១ មិលក្ខុផលទាយកត្ថេរាបទាន ១ ផារុសផលទាយកត្ថេរាបទាន ១ វល្លិផលទាយកត្ថេរាបទាន ១ កទលិផលទាយកត្ថេរាបទាន ១ បនសផលទាយកត្ថេរាបទាន ១ សោណកោដិវីសត្ថេរាបទាន ១ បុព្វកម្មបិលោតាបទាននៃព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណដ៏ធំ ១ មានគាថា ៩១ ពួកអ្នកប្រាជ្ញបានរាប់ឃើញហើយ ។

**ចប់ អម្ពដផលវគ្គ ទី ៣៩ ។**

**ចប់ ភាណវារៈ ទី ១៤ ។**

# អដ្ឋកថា

# បុព្វកម្មបិលោតិឆាមពុទ្ធាបទាន

[ ៩០ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១០ ដូចតទៅនេះថា បទថា **អនោតត្តសរាសន្នេ** សេចក្តីថា ឈ្មោះថា **អនោតត្ត** ព្រោះជាទីមិនមានកម្តៅរបស់ព្រះចន្ទនិងព្រះអាទិត្យផ្សាយទៅដល់ ព្រោះបាំងដោយកំពូលភ្នំច្រើនកំពូល ឈ្មោះថា **សរ** ព្រោះជាដែនហូរទៅ គឺជាដែនកើតហើយហូរទៅរបស់ស្ទឹងធំ អធិប្បាយថា ស្ទឹងធំដែលហូរចេញតាមច្រក សីហៈជាដើម វិលប្រទក្សិណ ៣ ជុំ ហើយហូរទៅតាមច្រកដែលផ្តើមហូរចេញមិនក្តៅផង ជាស្រះផង រួមគ្នាជាអនោតត្តស្រះ អធិប្បាយថា ក្នុងទីជិតស្រះនោះ គឺក្បែរអនោតត្តស្រះ បានដល់ ក្នុងទីជិតអនោតត្តស្រះនោះ ។ បទថា **រមណីយេ** សេចក្តីថា ក្នុងទីដែលគួរជាទីត្រេកអរនៃចិត្តនោះឈ្មោះថា **រម-ណីយ** ព្រោះជាទីដែលទេវតា ទានវៈ គន្ធព្វ កិន្នរ ពស់ និងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធជាដើម គប្បីត្រេកអរ គឺគប្បីជាប់ចិត្ត ។ បទថា **សិលាតលេ** សេចក្តីថា ផ្ទាំងនៃសិលាជាភ្នំថ្មក្រាស់ ។ បទថា **នានារតនបជ្ជោតេ** សេចក្តីថា រុងរឿងដោយកែវច្រើនប្រការ មានកែវទទឹមនិងកែវពិទូរ្យជាដើម ។ បទថា **នានាគន្ធវនន្តរេ** ក្នុងចន្លោះព្រៃ ជាព្រៃផ្កាដែលមានក្លិនក្រអូបច្រើនប្រភេទ ដូចជាចន្ទន៍ ក្រស្នា កប្បូរ រាជព្រឹក្សស្វាក្រអូប អសោក ខ្ទឹង បុសនាគ និងរំចេក ជាដើម ច្រើនប្រភេទ ។

សេចក្តីថា ព្រះមានព្រះភាគជាលោកនាយកជាព្រះសម្មាសម្ពុទ្ធនៃលោក

ទាំង ៣ ចោមរោមដោយមហាភិក្ខុសង្ឃ ដែលឈ្មោះថា **មហា** ព្រោះធំក្រៃលែងដោយគុណ និងព្រោះធំក្រៃលែងដោយចំនួន ប្រថាប់គង់លើសិលាសនៈនោះ ទ្រង់ព្យាករកម្មចាស់របស់ព្រះអង្គ គឺទ្រង់ធ្វើឲ្យប្រាកដច្បាស់ជាពិសេស ។ ពាក្យដ៏សេសក្នុងអបទាននេះ មានអត្ថដឹងបានងាយហើយ ព្រោះបានពោលទុកហើយ ក្នុងពុទ្ធាបទានខាងដើម និងព្រោះមានអត្ថងាយយល់ហើយ ។ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ នាំមកទុកជារឿងមួយក្នុងវគ្គ ក្នុងអបទាននេះ ព្រោះរឿងដែលរៀបចំទុកក្នុងពុទ្ធាបទាននោះ ចង្អុលឲ្យឃើញកុសលកម្មនិងអកុសលកម្ម ។

**អដ្ឋកថាបុព្វកម្មបិលោតិនាមពុទ្ធាបទាន ចប់**

**អម្ពដផលវគ្គ ទី ៣៩ ចប់**

# បិលិន្ទវគ្គ ទី ៤០

## បិលិន្ទវច្ឆត្ថេរាបទាន ទី ១

[ ៩១ ] ខ្ញុំជាឆ្មាំទ្វារ ក្នុងនគរហង្សវតី ខ្ញុំសន្សំភោគសម្បត្តិជាអក្ខោភិនី រាប់មិនបាន ទុកក្នុងផ្ទះ ។ ក្នុងកាលនោះ ខ្ញុំទៅអង្គុយក្នុងទីស្ងាត់ ហើយញ៉ាំងចិត្តឲ្យរីករាយ គឺអង្គុយក្នុងប្រាសាទដ៏ប្រសើរហើយគិតយ៉ាងនេះថា ភោគសម្បត្តិរបស់អញមានច្រើន ទីខាងក្នុងបុរីរបស់អញក៏ធំទូលាយ សូម្បីព្រះរាជាព្រះនាមអានន្ទ ជាធំលើផែនដី ក៏ទ្រង់ហៅរកអញ ។ ព្រះពុទ្ធនេះជាមុនី កើតឡើងព្រោះអាស្រ័យហេតុ ក៏កើតឡើងហើយ ទាំងភោគសម្បត្តិរបស់អញ ក៏មាន អញនឹងថ្វាយទានចំពោះព្រះសាស្តា ។ វត្ថុទានដ៏ប្រសើរ គឺបង្អែកក្នុងបល្ល័ង្កលើដំរី និងវត្ថុមានចំនួនច្រើន ព្រះអង្គម្ចាស់ព្រះនាមបទុមៈ បានថ្វាយចំពោះព្រះពុទ្ធជិនសិរី ។ ឯអញនឹងថ្វាយទានចំពោះព្រះសង្ឃ ជាពួកដ៏ប្រសើរខ្ពង់ខ្ពស់ ព្រោះទានដ៏ប្រសើរ អញមិនធ្លាប់ថ្វាយឡើយ អញជាអាទិកម្មិកបុគ្គល ។

សេចក្តីសុខជាផលនៃអំពើណា ក្នុងការបូជា អញនឹងគិតនូវអំពើនោះឲ្យច្រើន អញបានឃើញបរិក្ខារទាន ជាទីញ៉ាំងសេចក្តីត្រិះរិះរបស់អញឲ្យពេញ ។ អញនឹងឲ្យនូវបរិក្ខារ ចំពោះព្រះសង្ឃ ជាពួកដ៏ប្រសើរខ្ពង់ខ្ពស់ ( ព្រោះថា ) អញមិនដែលឲ្យទានដល់ពួកជនដទៃសោះ អញជាអាទិកម្មិកបុគ្គល ។

ខណៈនោះ ខ្ញុំចូលទៅរកពួកជាងត្បាញផែង ហើយឲ្យធ្វើឆត្រ រួចឲ្យគេប្រមូលឆត្រមួយសែនទុកក្នុងទីមួយ ។ ឲ្យគេប្រមូលសំពត់មួយសែន ទុកក្នុងទីមួយ ឲ្យគេប្រមូលបាត្រមួយសែន ទុកក្នុងទីមួយ ។ ខ្ញុំឲ្យគេធ្វើកាំបិតព្រា

កាំបិតកោរ ម្ជុលនិងកាំបិតកាត់ក្រចកឲ្យសមគួរដល់វត្ថុនោះ ហើយឲ្យគេទុកក្នុងទីខាងក្រោមឆត្រ ។ ខ្ញុំឲ្យគេធ្វើផ្ចិតសម្រាប់បក់ និងផ្ចិតស្លឹកត្នោត ផ្ចិតស្លាបក្ងោក ផ្ចិតរោមកន្ទុយចាមរី តម្រងទឹក និងវត្ថុសម្រាប់ទ្រប្រេង ឲ្យសមគួរដល់វត្ថុនោះ ខ្ញុំឲ្យគេធ្វើបំពង់ម្ជុល ខ្សែអាយោគ វត្ថុពន្ធចង្កេះ និងជើងបាត្រដែលធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានញ៉ាំងភេសជ្ជៈទាំងឡាយឲ្យពេញក្នុងភាជន៍សម្រាប់បរិភោគនិងក្នុងថ្លិលលោហៈ ហើយទុកក្នុងទីខាងក្រោមឆត្រ ។ ខ្ញុំបានញ៉ាំងភាជន៍ទាំងអស់ឲ្យពេញដោយលំពាន់ ស្បូវក្លាំង ឈើឯម ដីប្លី និងម្រេច សម៉ ខ្ញី ។ ខ្ញុំឲ្យគេធ្វើស្បែកជើង ទ្រនាប់ជើង សំពត់សម្រាប់ជូតទឹក និងឈើច្រត់ដែលគេធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ( ខ្ញុំឲ្យគេធ្វើ ) នូវថ្នាំឱសថ ថ្នាំបន្តក់ភ្នែក ចង្កឹះ ធម្មក្រកដ៏ប្រសើរ កូនសោរ និងប្រអប់កូនសោរ ដែលបុគ្គលដេរដោយចេស មានពណ៌ ៥ ។ ខ្ញុំឲ្យគេធ្វើនូវសំពត់អាយោគ ខ្សៀ ជើងប្រទីប ល័ក្កចាន់ និងជប ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានឲ្យគេធ្វើនូវបទ្ទាស កាំបិតកាត់ក្រចក កន្ធារត្រចៀក និងថង់យាម ដាក់ភេសជ្ជៈ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានឲ្យគេធ្វើនូវគ្រែដ៏វិសេស តាំង និងបល្ល័ង្ក សុទ្ធតែមានជើង ៤ ឲ្យសមគួរដល់វត្ថុនោះ ហើយឲ្យទុកក្នុងទីខាងក្រោមឆត្រ ។ ខ្ញុំបានឲ្យគេធ្វើនូវពូកញាត់ដោយរោម ពូកញាត់ដោយសំឡីពូកដេរភ្ជាប់និងតាំង និងខ្នើយដែលគេធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំឲ្យគេធ្វើនូវកុរុវិន្ទៈ គឺខ្សែសម្រាប់ដុសក្អែល ក្រមួនឃ្មុំ ជើងក្រានដុតប្រេងសម្រាប់កម្តៅដៃ និងគ្រែសិរីវដិផលកៈដ៏ស្អាត ព្រមទាំងកម្រាល ។ ខ្ញុំឲ្យគេធ្វើសេនា-

សនៈ គ្រឿងជូតជើង ទីដេក ទីអង្គុយ ឈើច្រត់ ឈើស្ទួន់ ឈើរងជើង និងគ្រឿងក្រអូប សម្រាប់លាបសីសៈ ។ ខ្ញុំឲ្យគេធ្វើដែកភ្លើង តាំងផែនក្តារ គ្របបាត្រ ថាស ពោយសម្រាប់ដងទឹក លំអិតសម្រាប់ផ្លូត និងស្នូកសម្រាប់ជ្រលក់ ។ ( ខ្ញុំបានឲ្យគេធ្វើ ) សំពត់ជូតមុខ សំពត់ផ្លូតទឹក សំពត់សម្រាប់ផ្លូតទឹកភ្លៀង និសីទនៈ សំពត់បិទបូស និងស្បង់ ។ ខ្ញុំឲ្យគេធ្វើចីពរ សង្ឃាដី ថ្នាំហិត ប្រាសជុសធ្មេញ ទឹកជ្រក់ វត្ថុប្រៃ ទឹកឃ្មុំនិងទឹកដោះជូរ ។ វត្ថុណាឈ្មោះថាដែលគេគប្បីឲ្យ គឺក្រមួនឃ្មុំ កំណាត់សំពត់ កន្ទ្រេងជូតមុខ និងចេស ឬវត្ថុណាគួរដល់ព្រះសាស្តា ខ្ញុំក៏ប្រមូលរបស់ទាំងអស់នុ៎ះ ហើយនាំចូលទៅគាល់ព្រះរាជាព្រះនាមអានន្ទ ព្រះអង្គជាអ្នកចម្រើនពួកជន ជាអ្នកមានយសធំ ។ ខ្ញុំក្រាបថ្វាយបង្គំដោយត្បូង រួចក្រាបទូលថា យើងទាំងពីរនាក់មានជាតិ ខ្ពង់ខ្ពស់ស្មើគ្នា មានយសថ្កុំថ្កើងស្មើគ្នា ។ យើងទាំងពីរនាក់ជាសាធារណៈ ប្រព្រឹត្តទៅតាមគ្នាក្នុងសុខនិងទុក្ខ បពិត្រព្រះអង្គអ្នកទូន្មានសត្រូវ សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត មានព្រះអង្គជាទីតាំង ។ បពិត្រព្រះបរមក្សត្រ បើព្រះអង្គអាច ក៏សូមបន្ទោបង់សេចក្តីទុក្ខនោះចុះ សេចក្តីទុក្ខរបស់ព្រះអង្គក៏ដូចជាទុក្ខរបស់ខ្ញុំ ចិត្តរបស់យើងទាំងពីរនាក់រមែងមានក្នុងទីដូចគ្នា ។ បើព្រះអង្គ ជ្រាបស្រេចហើយ ព្រះអង្គគប្បីដោះទុក្ខនោះចេញ បពិត្រមហារាជ សូមព្រះអង្គជ្រាបនូវទុក្ខដែលខ្ញុំព្រះអង្គបន្ទោបង់បានដោយក្រចុះ ។ សូមព្រះអង្គមានព្រះបន្ទូលទៅមើល តើទ្រព្យទាំងប៉ុន្មានក្នុងដែន និងជីវិតទាំងប៉ុន្មានរបស់ខ្ញុំ ទ្រព្យនុ៎ះឯង ព្រះអង្គលះបង់បានដោយកម្រឬទេ ។ បើព្រះអង្គមាន

សេចក្តីត្រូវការដោយទ្រព្យនិងជីវិតនុ៎ះ ខ្ញុំព្រះអង្គនឹងថ្វាយ ដោយឥតញាប់ញ័រ បពិត្រព្រះសម្មតិទេព ព្រះអង្គធ្លាប់មានបន្ទូលនឹងខ្ញុំមកហើយ តែព្រះបន្ទូលនោះច្រើនតែខុស ។ ខ្ញុំនឹងជីងនូវព្រះអង្គដែលឋិតនៅក្នុងធម៌ទាំងពួងក្នុងថ្ងៃនេះ ព្រះអង្គតែងបៀតបៀនចំពោះខ្ញុំ ដែលជាអ្នកឲ្យទានខ្លាំងពេក ។ ព្រះអង្គមានប្រយោជន៍អ្វីដោយការចរចាគ្នា សូមព្រះអង្គប្រាប់ខ្ញុំនូវហេតុដែលព្រះអង្គប្រាថ្នាចុះ បពិត្រមហារាជ ឯខ្ញុំព្រះអង្គចង់បានព្រះពុទ្ធ ជាបុគ្គលប្រសើរខ្ពង់ខ្ពស់ ។ ខ្ញុំនឹងញ៉ាំងព្រះសម្ពុទ្ធឲ្យឆាន់ សូមកុំឲ្យជីវិតរបស់ខ្ញុំមានទោសឡើយ ខ្ញុំថ្វាយពរដទៃដល់ព្រះអង្គថា ព្រះតថាគត មិនត្រូវអ្នកណានិមន្តឡើយ ។ ព្រះពុទ្ធដូចជាកែវមណីជោតិរស មិនត្រូវឲ្យដល់អ្នកណាមួយទេ បពិត្រព្រះសម្មតិទេព ក្រែងព្រះអង្គធ្លាប់មានព្រះបន្ទូលហើយថា ជីវិតមានប្រយោជន៍ជាដរាប ។ ព្រះអង្គកាលឲ្យនូវជីវិត គួរឲ្យព្រះតថាគតដល់ខ្ញុំ ព្រះជិនស្រីជាមហាវីរបុរស ដែលគេត្រូវតែតម្កល់ទុក មិនត្រូវឲ្យដល់បុគ្គលណាមួយឡើយ ។ ព្រះពុទ្ធខ្ញុំមិនទាន់ទទួលទេ សូមព្រះអង្គទទួលទ្រព្យ ដែលរាប់មិនបានចុះ ខ្ញុំព្រះអង្គនឹងដល់នូវការវិនិច្ឆ័យ នឹងសួរក្នុងទីវិនិច្ឆ័យ ។ ពួកតុលាការនឹងពោលនូវពាក្យដ៏ល្អិត យ៉ាងណា ខ្ញុំនឹងសួរតបពាក្យនោះ យ៉ាងនោះ ខ្ញុំចាប់ព្រះហស្តព្រះរាជា ដើរទៅកាន់ទីវិនិច្ឆ័យ ។ ខ្ញុំបានពោលពាក្យនេះចំពោះមុខពួកតុលាការថា សូមពួកអ្នកតុលាការស្តាប់ពាក្យខ្ញុំ ដ្បិតព្រះរាជាបានប្រទានពរដល់ខ្ញុំ ។ ខ្ញុំមិនតម្កល់ទុកនូវវត្ថុអ្វីមួយ សូម្បីតែជីវិតក៏បវារណាដែរ កាលព្រះរាជាបានប្រទានពរដល់ខ្ញុំហើយ ខ្ញុំក៏ទទួលយកនូវព្រះពុទ្ធ ជាបុគ្គល

ប្រសើរ ។ ព្រះរាជាបានប្រទានព្រះពុទ្ធល្អហើយ អ្នកទាំងឡាយចូរកាត់នូវសេចក្ដីសង្ស័យរបស់ខ្ញុំ ខ្ញុំនឹងស្ដាប់នូវព្រះឱង្ការរបស់ព្រះអង្គ ជាស្ដេចរក្សាផែនដី ។ ( អ្នកតុលាការពោលថា ) យើងស្ដាប់ពាក្យរបស់ជនទាំងពីរហើយ នឹងកាត់សេចក្ដីសង្ស័យក្នុងរឿងនុ៎ះ ដូចតទៅនេះ បពិត្រព្រះសម្មតិទេព ពរទាំងពួងដែលព្រះអង្គប្រទានហើយ ដល់ឆ្មាំទ្វារនេះ ជាពរដែលគេត្រូវតែកាន់យកទាំងអស់ ។ ខ្ញុំមិនតម្កល់ទុកនូវវត្ថុអ្វីមួយ សូម្បីតែជីវិតក៏បរិវារណាដែរ ខ្ញុំស៊ូដល់នូវសេចក្ដីលំបាក ដរាបដល់អស់ជីវិតប្រសើរជាង ។ ខ្ញុំដឹងច្បាស់នូវព្រះអង្គនេះដែលដល់នូវទុក្ខក្រៃលែងហើយ បានប្រទានពរដែលគេត្រូវតែកាន់យកទាំងអស់ បពិត្រព្រះសម្មតិទេព ព្រះអង្គជាបរាជ័យហើយ គួរតែព្រះរាជានុញ្ញាតឲ្យព្រះតថាគតដល់ឆ្មាំទ្វារនោះចុះ ។ សេចក្ដីសង្ស័យរបស់អ្នកទាំងពីរនាក់ ខ្ញុំកាត់រួចហើយ សូមព្រះអង្គឋិតនៅក្នុងរោងដ៏សមគួរចុះ ។ ព្រះរាជាឋិតនៅក្នុងរោងនោះហើយ ក៏ពោលពាក្យនេះ ចំពោះពួកតុលាការថា អ្នកទាំងឡាយចូរឲ្យដល់ខ្ញុំដោយប្រពៃចុះ ខ្ញុំត្រូវបានព្រះពុទ្ធម្ដងដែរ ខ្ញុំញ៉ាំងសេចក្ដីប្រាថ្នារបស់អ្នកឲ្យពេញហើយ ខ្ញុំសូមនិមន្តព្រះតថាគតឲ្យឆាន់ផង ។ អ្នកតុលាការពោលនឹងខ្ញុំជាអ្នកឆ្មាំទ្វារថា អ្នកចូរថ្វាយបង្គំមហាក្សត្រ ព្រះនាមអានន្ទចំពោះមុខពួកតុលាការ ហើយថ្វាយព្រះសម្ពុទ្ធដល់ព្រះរាជាព្រះនាមអានន្ទមានយសវិញផង ។ ខ្ញុំក៏មានចិត្តត្រេកអរីករាយ ហើយចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅគាល់ព្រះសម្ពុទ្ធព្រះអង្គជាអ្នកចូងនូវឱឃៈ មិនមានអាសវៈហើយ ខ្ញុំក៏បានថ្វាយបង្គំដោយត្បូង ក្រាបបង្គំទូលពាក្យនេះថា បពិត្រព្រះអង្គមានបញ្ញា

ចក្ខុ សូមព្រះអង្គព្រមទាំងភិក្ខុអ្នកសង្រួមឥន្ទ្រិយ ចំនួនមួយសែនរូប ទទួលនិមន្តន៍ឲ្យទាន ។ សូមព្រះអង្គញុំាងចិត្តរបស់ខ្ញុំឲ្យរីករាយ ហើយស្ដេចចូលមកកាន់និវេសន៍របស់ខ្ញុំ ។ ឯព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវការបូជា ទ្រង់មានចក្ខុ ជ្រាបសេចក្ដីត្រិះរិះរបស់ខ្ញុំហើយ ក៏ទទួលនិមន្តន៍ ។ ខ្ញុំដឹងនូវការទទួលនិមន្តន៍ហើយ ទើបថ្វាយបង្គំលាព្រះសាស្ដា ។ ខ្ញុំមានចិត្តត្រេកអររីករាយយ៉ាងក្រៃពេក ទើបចូលទៅកាន់និវេសន៍ ប្រមូលពួកមិត្តនិងអាមាត្យ ហើយពោលពាក្យនេះថា ព្រះសម្ពុទ្ធ ដូចជាកែវមណីជោតិរស ដែលគេបានដោយក្រក្រៃលែង ឥឡូវនេះ ខ្ញុំបានហើយ ខ្ញុំនឹងបូជាព្រះអង្គដោយវត្ថុដូចម្ដេច ព្រោះព្រះជិនស្រី ជាអ្នកប្រាជ្ញ ប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម រកបុគ្គលប្ដឹងផងមិនបាន មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបបាន ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើដូចគ្នា ប្រសើរជាងជនឥតមានបុគ្គលជាគម្រប់ពីរ ។ ពិតណាស់ ការកសាងដ៏សមគួរដល់ព្រះពុទ្ធ យើងធ្វើបានដោយក្រ ( ហេតុនោះ ) យើងទាំងឡាយ ចូរប្រមូលផ្កាផ្សេងៗធ្វើមណ្ឌបដោយផ្កា ។ បុប្ផជាតនុ៎ះ គឺផ្កាឧប្បល ផ្កាឈូក ផ្កាម្លិះរួត ផ្ការំដួល ជាផ្កាដ៏សមគួរដល់ព្រះពុទ្ធ នឹងបានឈ្មោះថាជាគ្រឿងបូជាគ្រប់យ៉ាង ។ ខ្ញុំបានឲ្យគេយកផ្កាចម្ប៉ានិងផ្កាខ្ទឹង ធ្វើជាមណ្ឌប ហើយក្រាលអាសនៈ មួយសែនក្នុងម្លប់ឆត្រ ។ អាសនៈរបស់ខ្ញុំ ខាងក្រោយបង្អស់ ដល់នូវតម្លៃមួយរយកហាបណៈជាយ៉ាងក្រៃលែង ខ្ញុំក្រាលអាសនៈមួយសែនក្នុងម្លប់ឆត្រ ។ ខ្ញុំចាត់ចែងបាយនិងទឹករួចហើយ ទៅក្រាបទូលនូវ

កត្តកាល កាលដែលខ្ញុំក្រាបទូលកត្តកាលហើយ ព្រះមហាមុនីព្រះនាមបទុមុត្តរៈ ទ្រង់ស្តេចចូលមកកាន់និវេសនដ្ឋានរបស់ខ្ញុំ ដែលបាំងឆត្រអំពីខាងលើ ក្នុងមណ្ឌបដែលធ្វើអំពីផ្កាវិកដ៏ល្អ ( ជាមួយ ) នឹងពួកភិក្ខុមួយសែនអង្គ ជាអ្នកសង្រួមឥន្ទ្រិយ ។ ព្រះពុទ្ធជាបុរសឧត្តម ( ព្រមទាំង ) ពួកភិក្ខុមួយសែនអង្គ ជាអ្នកសង្រួមឥន្ទ្រិយ ក៏គង់នៅគ្រប់ចំនួនឆត្រមួយសែន និងអាសនៈមួយ-សែន ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ សូមព្រះអង្គទទួលកប្បិយវត្ថុដែលឥតទោស ។ ឯព្រះបទុមុត្តរៈសម្ពុទ្ធ ជ្រាបច្បាស់នូវលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា ជាមហាមុនី ព្រះអង្គប្រាថ្នាដើម្បីចម្លងខ្ញុំ ក៏ទ្រង់ទទួលវត្ថុនោះ ខ្ញុំបានប្រគេនបាត្រផ្សេងដោយឡែក ដល់ភិក្ខុមួយរូបៗ ។ ពួកភិក្ខុក៏លះបង់បាត្រដែលខ្លួនធ្លាប់មាន ហើយទ្រទ្រង់នូវបាត្រជាវិការៈនៃលោហៈ ។ ព្រះពុទ្ធទ្រង់គង់ក្នុងមណ្ឌប ជាវិការៈនៃផ្កាអស់ ៧ យប់ ៧ ថ្ងៃ ទ្រង់ញុាំងពួកសត្វជាច្រើនឲ្យត្រាស់ដឹង ទ្រង់ញុាំងធម្មចក្កឲ្យប្រព្រឹត្តទៅ កាលញុាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ( ក៏ទ្រង់គង់នៅ ) ខាងក្រោមមណ្ឌបជាវិការនៃផ្កា ។ ពួកសត្វ ៨ ម៉ឺន ៤ ពាន់ ក៏បានត្រាស់ដឹងមគ្គផល លុះដល់ថ្ងៃជាគម្រប់ ៧ ព្រះមហាមុនីព្រះនាមបទុមុត្តរៈ ព្រះអង្គគង់នៅក្នុងម្លប់ឆត្រ បានសម្តែងនូវគាថាទាំងនេះថា មាណពណា បានឲ្យទានដ៏ប្រសើរ ជាទានមិនខ្វះខាត ដល់តថាគត តថាគតនឹងសរសើរមាណពនោះ ហេតុនោះ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យរបស់តថាគត កាលសម្តែងដូចតទៅនេះចុះ សេនាប្រកបដោយអង្គ ៤ គឺ ដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ នឹងចោមរោមនូវមាណពនោះជានិច្ច នេះ

ជាផលនៃទានទាំងពួង ។ យានដំរី យានសេះ គ្រែស្នែង រថទ្រង់គ្រឿង នឹងបម្រើមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ រថ ៦ ម៉ឺនដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ នឹងចោមរោមមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ តូរ្យតន្ត្រី ៦ ម៉ឺន និងស្គរដែលគេតាក់តែងល្អ នឹងប្រគំឲ្យមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ ពួកនាងនារី ៨ ម៉ឺន ៦ ពាន់នាក់ ដែលតាក់តែងល្អ មានសំពត់និងគ្រឿងប្រដាប់ដ៏វិចិត្រ ពាក់កុណ្ឌលនៃកែវមណី និងកែវមុក្តា មានមុខទូលាយ ស្រស់ស្រាយ មានត្រគាកល្អ មានចង្កេះរៀវ នឹងចោមរោមមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ មាណពនោះនឹងរីករាយក្នុងទេវលោកអស់ ៣០ ពាន់កប្ប នឹងបានជាព្រះឥន្ទសោយរាជ្យក្នុងទេវលោក មួយពាន់ដង នឹងបានជាស្តេចចក្កពត្តិ-មួយពាន់ដង នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ ដែលរាប់បានមួយអសង្ខេយ្យកប្ប កាលមាណពនោះនៅក្នុងទេវលោក ជាអ្នកព្រមព្រៀងដោយបុញ្ញកម្ម ។ ឆត្រកែវនឹងបាំងក្នុងទីបំផុតទេវលោកទៀត មាណពនេះនឹងប្រាថ្នានូវគ្រឿងបាំងដែលកើតអំពីសំពត់និងផ្កា ក្នុងកាលណា ( ទេវបុត្ត ) ដឹងនូវចិត្តរបស់មាណពនេះ នឹងបាំងអស់កាលជានិច្ច ( ក្នុងកាលនោះ ) ។ មាណពនោះ ច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន ជាអ្នកប្រកបដោយបុញ្ញកម្ម នឹងមានផៅសន្តានដ៏ប្រសើរ ។ ក្នុងមួយសែនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ក្នុងលោក ។ ព្រះគោតមសក្យបុង្គវៈ ទ្រង់ជ្រាបហេតុទាំងអស់នុ៎ះហើយ ទ្រង់គង់នៅក្នុង

ពួកភិក្ខុហើយ តាំងមាណពនេះក្នុងទីជាឯតទគ្គៈ នឹងបានជាសាវ័ករបស់ព្រះ-សាស្តា ឈ្មោះបិលិន្ទវច្ឆៈ ។ បិលិន្ទវច្ឆត្ថេរនោះ មានពួកទេវតា អសុរ គន្ធព្វ ភិក្ខុ ភិក្ខុនី និងគ្រហស្ថ ធ្វើសក្ការៈដូចគ្នា បានជាទីស្រឡាញ់នៃជនទាំងពួង ជាអ្នកមិនមានអាសវៈ ។ បុញ្ញកម្មដែលខ្ញុំធ្វើហើយក្នុងកប្បទីមួយសែន ឲ្យផល ដល់ខ្ញុំក្នុងជាតិនេះ ។ ខ្ញុំរួចស្រឡះហើយ ដូចជាកម្ទាំងកូនសរ ខ្ញុំដុតបំផ្លាញ នូវកិលេសទាំងឡាយហើយ ឱ ! កម្មដែលខ្ញុំធ្វើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ ប្រសើរ ព្រោះហេតុដែលខ្ញុំធ្វើគ្រឿងសក្ការៈចំពោះបុញ្ញក្ខេត្ត ទើបខ្ញុំដល់នូវអចល បទគឺព្រះនិព្វាន ។ មាណពណា ជាប្រធានខាងដើម បានឲ្យទានដ៏ប្រសើរ មិនខ្វះខាត នេះជាផលនៃទានរបស់មាណពនោះ ។ ព្រោះតែខ្ញុំបានថ្វាយឆត្រ ចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃដ៏ឧត្តម ទើបបាននូវអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមិនស្គាល់ត្រជាក់ ១ ក្តៅ ១ ផង់ ធូលីមិនប្រឡាក់ ១ ខ្ញុំមិនមានឧបទ្រព ១ មិនមានចង្រៃ ១ ខ្ញុំត្រូវគេគោរព កោតក្រែងសព្វៗកាល ១ ខ្ញុំមានសម្បុរដ៏សុខុម ១ ខ្ញុំមានចិត្តក្លៀវក្លា ១ ។ កាលខ្ញុំអន្ទោលទៅក្នុងភពតូចធំ ឆត្រទាំងមួយសែន ប្រកបដោយគ្រឿង អលង្ការគ្រប់មុខ តែងបាំងលើក្បាលរបស់ខ្ញុំ ព្រោះហេតុនៃបុញ្ញកម្មនោះ វៀរ លែងតែជាតិនេះចេញ ព្រោះហេតុនោះ បានជាក្នុងជាតិនេះ ខ្ញុំមិនមានឆត្របាំង តែអំពើទាំងអស់ដែលខ្ញុំធ្វើហើយ នាំឲ្យបាននូវឆត្រគឺវិមុត្តិ ។ ព្រោះតែខ្ញុំថ្វាយ នូវសំពត់ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវ អានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានវណ្ណៈដូចមាស ១

ប្រាសចាកធូលី ១ ប្រកបដោយពន្លឺ ១ មានតេជះ ១ ខ្លួនរបស់ខ្ញុំជិតស្និទ្ធ ១ កាលខ្ញុំអន្ទោលទៅក្នុងកពតូចធំ សំពត់ទាំងមួយសែន ពណ៌ស លឿង និងក្រហម រមែងបាំងលើក្បាលខ្ញុំ ១ នេះជាផលនៃទានសំពត់ ខ្ញុំរមែងបាន នូវសំពត់កោសេយ្យពស្ត្រនិងសំពត់កម្ពល ១ បាននូវសំពត់ដែលធ្វើដោយ សំបកឈើ និងសំពត់ធ្វើដោយកប្បាសក្នុងទីទាំងពួង ១ ព្រោះអានិសង្សនៃ សំពត់ទាំងឡាយនោះ ។ ព្រោះតែខ្ញុំបានថ្វាយឆត្រ ចំពោះព្រះសុគត និងព្រះ សង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវអានិសង្ស ១០ ប្រការ ដ៏សមគួរ ដល់អំពើរបស់ខ្ញុំ គឺខ្ញុំរមែងប្រើប្រាស់ថាសមាស ១ ថាសកែវមណី ១ ថាស ប្រាក់ ១ ថាសដែលធ្វើអំពីកែវទទឹម គ្រប់កាលទាំងពួង ១ ខ្ញុំជាអ្នកមិនមាន ឧបទ្រព ១ មិនមានចង្រៃ ១ ខ្ញុំត្រូវគេគោរពកោតក្រែងគ្រប់កាល ១ ខ្ញុំជា អ្នកបាននូវបាយ ទឹក សំពត់ និងទីដេក ១ ភោគៈទាំងឡាយរបស់ខ្ញុំ មិន ដែលវិនាសបាត់ ១ ខ្ញុំមានចិត្តខ្ជាប់ខ្ជួន ១ ។ មិនតែប៉ុណ្ណោះ ខ្ញុំជាអ្នកពេញ ចិត្តនឹងធម៌គ្រប់កាល មិនមានកិលេស មិនមានអាសវៈ គុណធម៌ទាំងនេះ ជាប់តាមហើយក្នុងទេវលោក ទាំងក្នុងមនុស្សលោក ។ គុណធម៌ទាំងឡាយ ជាប់ដោយចំណងគឺចិត្ត រមែងមិនលះបង់ខ្ញុំ ក្នុងទីទាំងពួង ដូចស្រមោល មិន លះបង់រូប ។ ព្រោះតែខ្ញុំបានថ្វាយកាំបិតព្រាជាច្រើនដែលខ្ញុំធ្វើល្អហើយ ដល់ ព្រះពុទ្ធដ៏ប្រសើរ និងព្រះសង្ឃ ទើបបានអានិសង្ស ៨ ប្រការដ៏សមគួរដល់ អំពើរបស់ខ្ញុំ គឺខ្ញុំជាអ្នកក្លៀវក្លា ១ អង់អាច ១ មានបារមីក្នុងធម៌ជាគ្រឿង ក្លៀវក្លា ១ ខ្ញុំមានព្យាយាមខ្ជាប់ខ្ជួន ១ មានចិត្តផ្គងទុកគ្រប់កាល ១ ខ្ញុំរមែង

បាននូវញាណជាគ្រឿងកាត់បង់នូវកិលេស ១ ញាណដ៏សុខុម ១ ញាណដ៏ស្អាតឥតមានអ្វីប្រៀបស្មើ ក្នុងទីទាំងពួង ១ ដោយអានិសង្សនៃកាំបិតព្រាបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយកាំបិតជាច្រើន ជាកាំបិតមិនរីង មិនអាក្រក់ មិនបាច់សំលៀង ចំពោះព្រះពុទ្ធ និងព្រះសង្ឃ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបានកល្យាណមិត្ត ១ សេចក្តីព្យាយាម ១ កាំបិតគឺខន្តីនិងមេត្រី ១ កាំបិតគឺប្រាជ្ញាដ៏ប្រសើរ ព្រោះកាត់នូវសរគឺតណ្ហា ១ ញាណស្មើដោយកែវវជីរ ១ ដោយអានិសង្សនៃកាំបិតទាំងនោះ ។ ព្រោះតែខ្ញុំបានថ្វាយនូវម្ជុលទាំងឡាយចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំគួរគេនមស្ការ អាចកាត់សេចក្តីសង្ស័យ ១ មានរូបល្អមានភោគសម្បត្តិ ១ កាលអន្ទោលទៅក្នុងភពតូចធំ ជាអ្នកមានបញ្ញាមុតគ្រប់កាលទាំងពួង ១ ខ្ញុំឃើញនូវអត្ថដ៏ជ្រាលជ្រៅ និងហេតុដ៏ល្អិតដោយញាណ ១ ញាណរបស់ខ្ញុំស្មើដោយចុងនៃកែវវជីរ សម្រាប់កម្ចាត់នូវងងឹត ១ ។ ព្រោះតែខ្ញុំបានថ្វាយនូវកាំបិតកាត់ក្រចកចំពោះព្រះសុគត និងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបាននូវខ្ញុំប្រុសខ្ញុំស្រី ១ គោនិងសេះ ១ អ្នករបាំជាអ្នកបម្រើច្រើននាក់ ១ ជាងកំណោរ ១ អ្នកគ្រូជាអ្នកធ្វើបាយក្នុងទីទាំងពួង ១ ។ ព្រោះតែខ្ញុំបានថ្វាយផ្ចិតសម្រាប់បក់ និងផ្ចិតស្លឹកត្នោតដ៏ល្អចំពោះព្រះសុគត ទើបបានអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមិនស្គាល់នូវត្រជាក់និងក្តៅ ១ មិន

មានសេចក្ដីអន្ទះអន្ទែង ១ មិនស្គាល់នូវសេចក្ដីក្រវល់ក្រវាយ ជាគ្រឿងញ៉ាំងចិត្តខ្ញុំឲ្យក្ដៅ ១ ភ្លើងទាំងពួងរបស់ខ្ញុំគឺភ្លើងរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ ភ្លើងគឺមានះ ១ ភ្លើងគឺទិដ្ឋិ ១ ក៏រលត់អស់ហើយដោយអានិសង្សនៃការ ថ្វាយផ្ចិតរបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំបានថ្វាយផ្ចិតស្លាបក្ងោក និងផ្ចិតចាមរី ចំពោះព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបជាអ្នកមានកិលេសស្ងប់រម្ងាប់ មិនមានទីទួលគឺកិលេស ។ ព្រោះតែខ្ញុំបានថ្វាយសំពត់តម្រងទឹក និងធម្មក្រក ចំពោះព្រះសុគត ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំកន្លងផុតនូវជនទាំងពួង បាននូវអាយុជាទិព្វ ១ ពួកចោរជាសត្រូវកំហែងមិនបានគ្រប់កាលទាំងពួង ១ បុគ្គលមិនហ៊ានធ្វើនូវការបៀតបៀន ដោយគ្រឿងសស្ត្រាវុធ ១ ដោយថ្នាំពិស ១ សេចក្ដីស្លាប់ក្នុងចន្លោះមិនមាន ១ ដោយអានិសង្សនៃតម្រងទឹក និងធម្មក្រកទាំងនោះរបស់ខ្ញុំ ។ ព្រោះតែខ្ញុំបានថ្វាយវត្ថុសម្រាប់ទ្រប្រេង ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានរូបដូចមាស ១ មានវ័យដ៏ល្អ ១ មានចិត្តខ្ពស់ឡើងដោយល្អ ១ មានចិត្តមិនរវើរវាយ ១ មានគេគ្រប់គ្រងរក្សាហើយដោយការរក្សាគ្រប់យ៉ាង ១ ។ ព្រោះតែខ្ញុំបានថ្វាយបំពង់ម្ជុលចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវអានិសង្ស ៣ ប្រការដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបាននូវគុណធម៌ទាំងនេះ គឺសុខក្នុងចិត្ត ១ សុខក្នុងកាយ ១ សុខកើតអំពីឥរិយាបថ ១ ដោយអានិសង្សនៃបំពង់ម្ជុលនោះ ។ ព្រោះតែខ្ញុំបានថ្វាយ

សំពត់អង្សៈចំពោះព្រះជិនស្រីនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំតែងបាននូវព្រះសទ្ធម្មដ៏មាំមួន ១ រឭកឃើញនូវភពជាគម្រប់ពីរ ១ ជាអ្នកមានសម្បុរល្អក្នុងទីទាំងពួង ១ ដោយអានិសង្សនៃអង្សៈនោះ ។ ព្រោះតែខ្ញុំបានថ្វាយវត្ថពន្ធចង្កេះចំពោះព្រះជិនស្រីនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៦ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមិនញាប់ញ័រក្នុងសមាធិទាំងឡាយ ១ ជាអ្នកស្ទាត់ក្នុងសមាធិទាំងឡាយ ១ ជាអ្នកមានបរិស័ទមិនបែកខ្ញែក ១ ពាក្យសម្តីខ្ញុំគេតែងជឿស្តាប់សព្វកាល ១ ជាអ្នកមានសតិតាំងនៅមាំ ១ ខ្ញុំមិនមានសេចក្តីតក់ស្លុត ១ គុណធម៌ទាំងនេះ ជាប់តាមខ្ញុំទៅក្នុងទេវលោកនិងមនុស្សលោក ។ ព្រោះតែខ្ញុំបានថ្វាយនូវជើងបាត្រមានពណ៌ ៥ ចំពោះព្រះជិនស្រីនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបជាអ្នកមិនមានភ័យ មិនញាប់ញ័រដោយហេតុណាមួយ ។ ធម៌ទាំងឡាយណាមួយ ជាគ្រឿងដាស់តឿននូវសតិនិងបញ្ញា ដែលខ្ញុំបានចេះដឹងហើយ ធម៌ទាំងនោះ ខ្ញុំចងចាំទុកមិនភ្លេចឡើយ ធម៌ទាំងនោះ ខ្ញុំវិនិច្ឆ័យល្អហើយ ។ ព្រោះតែខ្ញុំបានថ្វាយកាជន៍ ជាគ្រឿងប្រើប្រាស់ ចំពោះព្រះពុទ្ធនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបាននូវកាជន៍ទាំងឡាយ ជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវផលិក ឬជាវិការៈនៃកែវទទឹម ១ បាននូវកិរិយា ខ្ញុំប្រុស ខ្ញុំស្រី ដំរី សេះ រថ ពលថ្មើរជើង ស្ត្រីជាអ្នកមានវត្តដល់ប្តី និងគ្រឿងប្រើប្រាស់គ្រប់កាលទាំងពួង ១ ខ្ញុំពិចារណានូវវិជ្ជា បទ

នៃមន្តអាគមផ្សេងៗជាច្រើន និងសិល្បៈទាំងពួង ជាគ្រឿងប្រើប្រាស់ គ្រប់កាលទាំងពួង ១ ។ ព្រោះតែខ្ញុំបានថ្វាយនូវថាសចំពោះព្រះសុគត និងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការដ៏សមគួរដល់អំពើរបស់ខ្ញុំ ។ គឺខ្ញុំបានថាសជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវផលិក ឬជាវិការៈនៃកែវទទឹម ១ បាននូវថាសឈ្មោះអស្សត្ថកៈ ដែលធ្វើអំពីផែនក្តារមានសណ្ឋានដូចស្លឹកឈូក ឬមានសណ្ឋានដូចស័ង្ខសម្រាប់ដាក់ទឹកឃ្មុំ ១ បាននូវគុណធម៌ទាំងនេះ គឺ វត្ត គុណ សេចក្តីប្រតិបត្តិក្នុងអាចារៈ និងកិរិយា ១ ដោយអានិសង្សនៃការថ្វាយនូវថាសនោះ ។ ព្រោះតែខ្ញុំបានថ្វាយនូវកេសជ្ជៈចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំជាអ្នកមានអាយុវែង ១ មានកម្លាំង ១ មានប្រាជ្ញា ១ មានពណ៌សម្បុរ ១ មានយស ១ មានសេចក្តីសុខ ១ មិនមានឧបទ្រព ១ មិនមានចង្រៃ ១ ត្រូវគេគោរពកោតក្រែងសព្វកាល ១ មិនមានការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ១ ដោយអានិសង្សនៃការថ្វាយកេសជ្ជៈរបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំបានថ្វាយនូវស្បែកជើងចំពោះព្រះជិនស្រីនិងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការដ៏សមគួរដល់អំពើរបស់ខ្ញុំ ។ គឺយានដំរី យានសេះ គ្រែស្នែង និងរថទ្រង់-គ្រឿង រថ ៦ ម៉ឺន តែងចោមរោមខ្ញុំគ្រប់កាលទាំងពួង ១ កាលខ្ញុំអន្ទោលទៅក្នុងភព ទ្រនាប់ជើងមាស ប្រាក់ ជាវិការៈកែវមណី ជាវិការៈកែវក្រហមតែងកើតឡើងគ្រប់ជំហាន ១ ( ទ្រនាប់ជើងទាំងនោះ ) រមែងនាំខ្ញុំឲ្យស្ទុះ

ទៅកាន់សម្មត្តនិយាម ជាគ្រឿងជម្រះនូវអាចារៈនិងគុណធម៌ ១ ខ្ញុំរមែងបាន
នូវគុណធម៌ទាំងនេះ ដោយអានិសង្សនៃការថ្វាយស្បែកជើងនោះ ។ ព្រោះតែ
ខ្ញុំបានថ្វាយទ្រនាប់ជើង ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់
ខ្ពស់ ទើបបានឡើងកាន់ទ្រនាប់ជើងគឺឫទ្ធិ សមតាមប្រាថ្នា ។ ព្រោះតែខ្ញុំបាន
ថ្វាយកន្សែងជូតមុខ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់
ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានវណ្ណៈដូច
មាស ១ ប្រាសចាកធូលី ១ ប្រកបដោយរស្មី ១ មានតេជះ ១ ខ្លួនខ្ញុំជិត
ស្និទ្ធផង់ធូលីមិនប្រឡាក់ ១ ។ ខ្ញុំបាននូវគុណធម៌ទាំងនេះ ដោយអានិសង្ស
នៃការថ្វាយកន្សែងជូតមុខនោះ ។ ព្រោះតែខ្ញុំបានថ្វាយឈើប្រត់ ចំពោះព្រះ
សុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ
ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានកូនច្រើន ១ ខ្ញុំមិនតក់ស្លុត ១ ខ្ញុំគេមិន
កំហែងបានគ្រប់កាល ត្រូវគេថែរក្សាដោយគ្រឿងរក្សាគ្រប់យ៉ាង ១ ខ្ញុំមិនស្គាល់
សេចក្តីភ្លាំងភ្លាត់ ១ ចិត្តរបស់ខ្ញុំមិនចេះភាន់ច្រឡំ ១ ។ ព្រោះតែខ្ញុំបានថ្វាយ
ឱសថបន្តក់ភ្នែកចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស
៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានភ្នែកទូលាយ ១ មានសម្បុរ
ស ១ លឿង ១ ក្រហម ១ មានភ្នែកថ្លាមិនល្អក់ ១ ជាអ្នកវៀរចាករោគ
គ្រប់យ៉ាង ១ ខ្ញុំបានចក្ខុទិព្វ ១ បញ្ញាចក្ខុដ៏ប្រសើរ ១ ខ្ញុំបានគុណធម៌ទាំងនេះ
ដោយអានិសង្សនៃការថ្វាយនូវឱសថបន្តក់ភ្នែកនោះ ។ ព្រោះតែខ្ញុំបានថ្វាយ
កូនសោចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានកូន

សោគឺញាណសម្រាប់បើកទ្វារព្រះធម៌ ។ ព្រោះតែខ្ញុំបានថ្វាយប្រអប់កូនសោចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ២ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំកាលត្រាច់ទៅក្នុងភព ជាអ្នកមិនមានសេចក្តីក្រោធ ១ មិនមានសេចក្តីតានតឹង ១ ។ ព្រោះតែខ្ញុំបានថ្វាយខ្សែអាយោគចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមិនញាប់ញ័រក្នុងសមាធិទាំងឡាយ ១ ជាអ្នកស្ទាត់ក្នុងសមាធិ ១ ខ្ញុំមានបរិស័ទមិនបែកខ្ញែក ១ មានពាក្យគួរអ្នកផងកាន់យកគ្រប់កាលទាំងពួង ១ ភោគសម្បត្តិ រមែងកើតឡើងដល់ខ្ញុំ កាលអន្ទោលទៅក្នុងភព ១ ។ ព្រោះតែខ្ញុំបានថ្វាយខ្សៀចំពោះព្រះជិនស្រីនិងព្រះ-សង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានសតិត្រង់ ១ សរសៃទាំងឡាយសន្ធានបានចងដោយល្អ ១ ខ្ញុំបានទីដេកទិព្វ ១ ដោយអានិសង្សនៃការថ្វាយខ្សៀនោះ ។ ព្រោះតែខ្ញុំបានថ្វាយប្រទីបចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំជាអ្នកមានជាតិខ្ពង់ខ្ពស់ ១ បរិបូណ៌ដោយអវយវៈ ១ មានប្រាជ្ញាដែលព្រះពុទ្ធសន្មតហើយ ១ ខ្ញុំបានគុណធម៌ទាំងនេះ ដោយអានិសង្សនៃការថ្វាយប្រទីបរបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំបានថ្វាយល័ក្កចាន់និងជបចំពោះព្រះពុទ្ធ និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺក្នុងកាលនោះ ខ្ញុំត្រូវគេគ្រប់គ្រង ១ ប្រកបដោយសេចក្តីសុខ ១

មានយសបរិវារច្រើន ១ មានដំណើរដ៏ប្រសើរ ១ មានខ្លួនដែលគេគួរគប់រក ដោយវិសេស ១ ចម្រើនសេចក្ដីសុខ ១ វៀរស្រឡះចាកចង្រៃគ្រប់យ៉ាង ១ ជាអ្នកបានទូវគុណធម៌ដ៏ទូលំទូលាយដោយការកម្រើក គឺសេចក្ដីរាប់អាន របស់ខ្ញុំ ១ មានសេចក្ដីតក់ស្លុតវៀរស្រឡះហើយ ១ ខ្ញុំបានល័ក្ខចាន់ជប មានពណ៌ ៤ និងដីរកែវ សេះកែវ វត្ថុទាំងនោះរបស់ខ្ញុំរមែងមិនវិនាស ១ នេះជាផលក្នុងការថ្វាយល័ក្ខចាន់ ។ ព្រោះតែខ្ញុំបានថ្វាយហត្ថលីល័ង្គចំពោះ ព្រះពុទ្ធនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបមានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺកាយរបស់ខ្ញុំបរិបូណ៌ដោយលក្ខណៈទាំងពួង ១ ប្រកបដោយអាយុវែង ១ ដោយបញ្ញា ១ ចិត្តតម្កល់មាំ ១ ផុតស្រឡះចាក សេចក្ដីលំបាកគ្រប់យ៉ាងសព្វកាល ១ ។ ព្រោះតែខ្ញុំបានថ្វាយកន្ត្រៃមានមុខស្មើង ដែលគេសំលៀងយ៉ាងល្អចំពោះព្រះសង្ឃ ទើបបានញាណដែលប៉ិនមិនបាន ដ៏ស្អាតសម្រាប់កាត់ផ្ដាច់នូវកិលេស ។ ព្រោះតែខ្ញុំបានថ្វាយចន្ទាសចំពោះព្រះ សុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវញាណដែលប៉ិនមិន បានដ៏ស្អាតសម្រាប់ដកនូវកិលេស ។ ព្រោះតែខ្ញុំបានថ្វាយនូវថ្នាំហិត ចំពោះ ព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺសទ្ធា ១ សីល ១ ហិរិ ១ គុណគឺឱត្តប្បៈ ១ សុតៈ ១ ចាគៈ ១ ខន្តី ១ គុណគឺបញ្ញារបស់ខ្ញុំជាគម្រប់ ៨ ។ ព្រោះតែខ្ញុំ បានថ្វាយតាំងចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើប បានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំកើតក្នុងត្រកូលខ្ពស់

ជាអ្នកមានភោគៈច្រើន ១ ជនទាំងពួងតែងគោរពកោតក្រែងចំពោះខ្ញុំ ១ កិត្តិសព្ទរបស់ខ្ញុំខ្ចរខ្ចាយទៅ ១ បល្ល័ង្កមានជ្រុង ៤ តែងចោមរោមខ្ញុំជានិច្ចអស់មួយសែនកប្ប ១ ខ្ញុំជាអ្នកត្រេកអរក្នុងការចែករំលែក ១ ។ ព្រោះតែខ្ញុំបានថ្វាយពូកចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៦ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំជាអ្នកមានចិត្តស្ងប់មានខ្លួនសមល្អ ត្រូវគេគោរពកោតក្រែង ១ មានចិត្តទន់ មានកាយល្អ ប្រកបដោយគ្រឿងប្រដាប់មានពណ៌ដូចមាស ១ បាននូវញាណដ៏ប្រសើរ ១ នេះជាផលនៃការថ្វាយពូក ខ្ញុំបាននូវកម្រាលផ្សេង ៗ ជាច្រើនបែប គឺតូលិកៈ ( កម្រាលដែលធ្វើដោយគរ ) វិកតិកៈ ( កម្រាលដែលធ្វើដោយរោមសត្វ ហើយវិចិត្រដោយរូបសត្វដ៏ប្លែកៗ ) កដិស្សៈ ( កម្រាលដែលប៉ាក់ឌិនចម្រុះមាសនិងសូត្រហើយចាក់ស្រេះដោយរតនៈ ) ចិត្តកៈ ( កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វសាហាវ ) វរបោត្ថកៈ ( កម្រាលដែលធ្វើដោយសំពត់សំបកឈើដ៏ប្រសើរ ) កម្ពលៈ ( កម្រាលដែលធ្វើដោយរោមសត្វ ) ១ ខ្ញុំបានកម្រាលទាំងឡាយគឺបាវារកៈដ៏ទន់ អជិនបវេណី ( កម្រាលដែលធ្វើដោយស្បែកខ្លាឃ្មុំ ) ដ៏ទន់ក្នុងទីផ្សេងៗ ១ នេះជាផលនៃការថ្វាយពូក កាលណា ខ្ញុំព្រឹកឃើញនូវខ្លួន កាលណា ខ្ញុំបានដល់នូវភាពជាអ្នកដឹងក្តី ខ្ញុំមិនមែនជាបុគ្គលទទេ គឺជាអ្នកមានគ្រែគឺឈានក្នុងកាលនោះ ១ នេះជាផលនៃការថ្វាយពូក ។ ព្រោះតែខ្ញុំបានថ្វាយខ្នើយចំពោះព្រះជិនស្រី និងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៦ ប្រការ ដ៏សមគួរដល់អំពើ

របស់ខ្ញុំ គឺខ្ញុំរមែងដាក់ក្បាលខ្ញុំលើខ្នើយរោមសត្វកែះ ខ្នើយផ្កាឈូក ឬខ្នើយចន្ទន៍ក្រហម គ្រប់កាលទាំងពួង ១ ខ្ញុំញ៉ាំងញាណឲ្យកើតឡើងក្នុងធម៌ទាំងនោះ គឺមគ្គមានអង្គ ៨ ដ៏ប្រសើរ និងសាមញ្ញផល ៤ អស់កាលជានិច្ច ១ ខ្ញុំញ៉ាំងញាណឲ្យកើតឡើងក្នុងធម៌ទាំងនោះ គឺ ទាន ទមៈ សញ្ញមៈ និងអប្បមញ្ញា មានរូបជាអារម្មណ៍គ្រប់កាលទាំងពួង ១ ខ្ញុំញ៉ាំងញាណឲ្យកើតឡើងក្នុងធម៌ទាំងនោះ គឺ វត្ត គុណ ការប្រៀបផ្ទឹមក្នុងអាចារៈនិងកិរិយាគ្រប់កាលទាំងពួង ១ ខ្ញុំញ៉ាំងញាណឲ្យកើតឡើងក្នុងធម៌ទាំងនោះ គឺការចង្រ្កម ការប្រឹងប្រែង ការព្យាយាម និងពោធិបក្ខិយធម៌ ហើយនៅតាមប្រាថ្នា ១ ខ្ញុំញ៉ាំងញាណឲ្យកើតឡើងក្នុងធម៌ទាំងនោះ គឺ សីល សមាធិ បញ្ញាវិមុត្តិដ៏ប្រសើរ ហើយនៅជាសុខ ១ ។ ព្រោះតែខ្ញុំបានថ្វាយតាំងផែនក្តារចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ២ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបានបល្ល័ង្កដ៏ប្រសើរដែលសម្រេចដោយមាស សម្រេចដោយកែវមណី ១ សម្រេចដោយភ្លុកនិងខ្លឹមជាច្រើន ១ នេះជាផលនៃតាំងផែនក្តារ ។ ព្រោះតែខ្ញុំបានថ្វាយតាំងមានជើងចំពោះព្រះជិនស្រី និងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ២ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបានយានដ៏ច្រើន នេះជាផលនៃតាំងមានជើង ១ ជនទាំងឡាយដទៃដែលជាអ្នករស់នៅដោយសារ គឺ ទាសី ទាសៈ ភរិយា ជនទាំងនោះតែងបម្រើនូវខ្ញុំដោយប្រពៃ នេះជាផលនៃតាំងមានជើង ១ ។ ព្រោះតែខ្ញុំបានថ្វាយប្រេងសម្រាប់លាបចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាន

អានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺភាពជាអ្នកមិនមានព្យាធិ ១ ភាពជាអ្នកមានរូបល្អ ១ ភាពជាអ្នកពិចារណាធម៌ដោយរហ័ស ១ ភាពជាអ្នកបានបាយនិងទឹក ១ ខ្ញុំមានអាយុវែងជាគម្រប់ ៥ ។ ព្រោះតែខ្ញុំបានថ្វាយទឹកដោះថ្លានិងប្រេងចំពោះព្រះសង្ឃ ដែលជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំជាបុគ្គលមានកម្លាំង ១ បរិបូណ៌ដោយរូប ១ ជាអ្នករីករាយ ១ ជាអ្នកមានកូនសព្វៗកាល ១ ជាអ្នកមិនមានជំងឺគ្រប់កាលទាំងពួង ១ នេះជាផលនៃទឹកដោះថ្លានិងប្រេង ។ ព្រោះតែខ្ញុំបានថ្វាយទឹកលុបមុខចំពោះព្រះសង្ឃ ដែលជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំជាបុគ្គលមានកដ៏ល្អ ១ មានសំឡេងពីរោះ ១ គ្មានរោគក្អក ១ គ្មានរោគហឺត ១ មានក្លិនផ្កាឧប្បលផ្សាយចេញអំពីមាត់ខ្ញុំគ្រប់កាលទាំងពួង ១ ។ ព្រោះតែខ្ញុំបានថ្វាយទឹកដោះជូរដ៏បរិបូណ៌ ចំពោះព្រះពុទ្ធនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបរិភោគកត្តគឺអមតៈនិងកាយគតាសតិដ៏ប្រសើរ ។ ព្រោះតែខ្ញុំបានថ្វាយទឹកឃ្មុំដែលប្រកបដោយពណ៌ ក្លិន និងរស ចំពោះព្រះជិនស្រី និងគណៈសង្ឃ ទើបបានវិមុត្តិរស រកអ្វីផ្ទឹមគ្មាន មិនមែនជាធម៌ផ្តេសផ្តាសឡើយ ។ ព្រោះតែខ្ញុំបានថ្វាយភោជនមានរសគួរតាមចំណាំ ចំពោះព្រះពុទ្ធនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានផល ៤ ដ៏សមគួរដល់អំពើរបស់ខ្ញុំ ។ ព្រោះតែខ្ញុំបានថ្វាយបាយនិងទឹកចំពោះព្រះពុទ្ធនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមាន

អាយុវែង ១ មានកម្លាំង ១ ជាអ្នកប្រាជ្ញ ១ មានពណ៌សម្បុរល្អ ១ មានយស ១ មានសេចក្តីសុខ ១ ជាអ្នកបានបាយ ១ ទឹក ១ ក្លៀវក្លា ១ មានប្រាជ្ញា ១ កាលខ្ញុំអន្ទោលទៅក្នុងភព តែងបានគុណធម៌ទាំងនេះឯង ។ ព្រោះតែខ្ញុំបានថ្វាយធូបក្រអូបចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានរាងកាយក្រអូប ១ មានយស ១ មានប្រាជ្ញារហ័ស ១ មានកេរ្តិ៍ឈ្មោះ ១ មានប្រាជ្ញាមុត ១ មានប្រាជ្ញាដូចផែនដី ១ មានប្រាជ្ញាស្រស់ស្រាយ ១ មានប្រាជ្ញាជ្រៅ ១ មានប្រាជ្ញាទូលាយ ១ មានប្រាជ្ញាស្ទុះលឿនទៅ ១ ខ្ញុំកាលអន្ទោលទៅក្នុងភពតូចភពធំ ជាអ្នកដល់នូវព្រះនិព្វាន ជាសន្តិសុខ ក្នុងកាលឥឡូវនេះ ព្រោះហេតុនៃការថ្វាយធូបក្រអូបនោះឯង ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិលិន្ទវច្ឆត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បិលិន្ទវច្ឆត្ថេរាបទាន ។**

# បិលិន្ទវច្ឆវគ្គ ទី ៤០

## អដ្ឋកថា បិលិន្ទវច្ឆត្ថេរាបទាន

[ ៩១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ ក្នុងបិលិន្ទវច្ឆវគ្គ ទី ៤០ ដូចតទៅនេះថា

អបទានរបស់ព្រះបិលិន្ទវច្ឆត្ថេរ មានពាក្យផ្ដើមថា **នគរេ ហំសវតិយា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ កើតក្នុងត្រកូលអ្នកយាមទ្វារក្នុងហង្សវតីនគរ មាននូវសម្បត្តិច្រើន មានភោគសម្បត្តិច្រើន សម្លឹងមើលគំនរទ្រព្យសម្បត្តិ ដែលសន្សំទុកច្រើនកោដិហើយ ទើបទៅអង្គុយក្នុងទីស្ងាត់គិតថា អញគួរកាន់យកទ្រព្យទាំងអស់នេះទុកក្នុងផ្លូវដែលត្រូវ ហើយសឹមទៅ ដូច្នេះ ទើបសម្រេចចិត្តថា អញគួរថ្វាយបរិក្ខារសព្វយ៉ាងដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទើបចាប់ផ្ដើមឲ្យជាងធ្វើឆត្រមួយសែន ឲ្យធ្វើបរិក្ខារប្រើប្រាស់គ្រប់យ៉ាងចំនួនមួយសែនផងដែរ ហើយនិមន្តព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈមកថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន កាលថ្វាយទាន ៧ ថ្ងៃយ៉ាងនេះហើយ ក្នុងថ្ងៃចុងក្រោយ បានប្រាថ្នាសូមសម្រេចព្រះនិព្វាន ហើយធ្វើបុណ្យដ៏ច្រើនដរាបដល់អស់ជីវិត ស្លាប់ហើយបានទៅកើតក្នុងទេវលោកសោយទិព្វសម្បត្តិច្រើនក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់ និង

បានសោយសម្បត្តិ មានចក្កពត្តិសម្បត្តិជាដើម ក្នុងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ រៀនចប់សិប្បសាស្ត្រគ្រប់យ៉ាងហើយ បានប្រាកដឈ្មោះថា បិលិន្ទវច្ឆៈ ដោយអំណាចគោត្ត ។

ថ្ងៃមួយបិលិន្ទវច្ឆៈនោះ បានស្តាប់ព្រះធម្មទេសនា ក្នុងសម្នាក់របស់ព្រះសាស្តាហើយ មាននូវសទ្ធាទើបចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទាននោះ ដោយអំណាចឧទ្ទាន ទើបពោលពាក្យថា **នគរេ ហំសវតិយា** ដូច្នេះជាដើម ។ អត្ថនៃឧទ្ទាននោះ ខ្ញុំបានពោលទុកហើយខាងដើមនោះឯង ។ បទថា **អាសឹ ទោវារិកោ អហំ** សេចក្តីថា ខ្ញុំបានជានាយទ្វារ រក្សាទ្វារព្រះរាជវាំងរបស់ព្រះរាជាក្នុងហង្សវតីនគរ ។ បទថា **អក្ខោភំ អមិតំ ភោគំ** សេចក្តីថា ព្រោះខ្លួនជារាជវល្លភៈ ទើបអ្នកដទៃមិនអាចធ្វើទ្រព្យឲ្យញាប់ញ័រ ឲ្យឃ្លាតចាកទីបាន ទ្រព្យដែលប្រមាណមិនបាន ទើបត្រូវសន្សំទុក ក្នុងផ្ទះរបស់ខ្ញុំជាគំនរ ។

បទថា **ពហូ មេធិគតា ភោគា** សេចក្តីថា ទើបខ្ញុំបាន គឺដល់ បានទទួលភោគៈដ៏ច្រើន ។ ឈ្មោះរបស់បរិក្ខារទាំងឡាយ មានកាំបិតតូចជាដើម ក៏ល្មមដឹងបានដោយងាយ ដោយការប្រកបទៅតាមលំដាប់អត្ថ ឯអានិសង្សនៃការថ្វាយគ្រឿងបរិក្ខារល្មមដឹងបានងាយដូចគ្នា ។

## អដ្ឋកថាបិលិន្ទវច្ឆត្ថេរាបទាន ចប់

# សេលត្ថេរាបទានទី ២

[ ៩២ ] ខ្ញុំជាម្ចាស់ផ្ទះ នៅក្នុងនគរហង្សវតី ប្រមូលពួកញាតិរបស់ខ្ញុំមក ហើយពោលពាក្យនេះថា ព្រះពុទ្ធជាបុញ្ញក្ខេត្តដ៏ប្រសើរ កើតហើយក្នុងលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជារបស់សត្វលោកទាំងពួង ។ ពួកក្សត្រ ពួកអ្នកនិគម និងពួកព្រាហ្មណមហាសាល មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកឧគ្គជន ( ម្តាយជាសូទ្រ: ឪពុកជាក្សត្រ ) ពួករាជបុត្ត ពួកវេស្ស: និងពួកព្រាហ្មណ៍ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកអ្នកជាំស្វ អ្នកគ្រួ អ្នកកាត់សក់ និងអ្នកធ្វើកម្រងផ្កា មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងជ្រលក់ ជាងតម្បាញ ជាងដេរប៉ាក់ និងស្រីអ្នកកាត់សក់ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងធ្វើកូនសរ ជាងក្រឡឹង ជាងធ្វើស្បែក និងជាងចាំង មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងដែក ពួកជាងមាស ជាងសំណនិងលោហ: មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកអ្នកស៊ីឈ្នួល ពួកអ្នកកាន់ទង់សំពត់ និងពួកទាសកម្មករជាច្រើន ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ពួកអ្នកដងទឹក ពួកអ្នករកឧស ពួកអ្នកភ្ជួររាស់ ពួកអ្នកនាំស្មៅ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ពួកអ្នកបេះផ្កា អ្នកក្រងផ្កា អ្នក

លក់បន្លែ និងអ្នកនាំផ្លែឈើ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ស្រីពេស្យា នាងកុម្ភទាសី ស្រីអ្នកលក់នំ និងអ្នកនេសាទត្រី ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ជនទាំងអស់ទុំះឯងមកប្រជុំគ្នា ចងគ្នាជាពួកក្នុងទីមួយ ( ហើយពោលថា ) យើងទាំងឡាយនឹងធ្វើនូវការកសាងចំពោះព្រះពុទ្ធ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ជនទាំងនោះស្តាប់ពាក្យខ្ញុំ ហើយក៏ចងពួកក្នុងខណៈនោះ បានឲ្យពួកជាងធ្វើឧបដ្ឋានសាលាដែលធ្វើដោយល្អ ថ្វាយព្រះភិក្ខុសង្ឃ ។ ខ្ញុំធ្វើសាលានោះរួចហើយក៏មានចិត្តរីករាយ មានចិត្តត្រេកអរ មានពួកជនទាំងអស់នោះ ហែហមចូលទៅគាល់ព្រះសម្ពុទ្ធ ។ លុះចូលទៅគាល់ព្រះសម្ពុទ្ធ ព្រះអង្គជាទីពឹងនៃលោក ប្រសើរជាងជន ហើយថ្វាយបង្គំព្រះបាទាព្រះសាស្តា រួចពោលនូវពាក្យនេះថា បពិត្រព្រះមុនីជាវីរបុរស ពួកបុរស ៣០០ នាក់នេះ ជាពួកតែមួយ វេរថ្វាយឧបដ្ឋានសាលាដែលធ្វើយ៉ាងល្អ ចំពោះព្រះអង្គ សូមព្រះអង្គមានបញ្ញាចក្ខុទទួល ( នូវសាលា ) ចំពោះមុខភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវគាថាទាំងឡាយនេះ ចំពោះមុខបុរសទាំង ៣០០ នាក់ថា ពួកបុរស ៣០០ នាក់ និងបុរសជាធំ ប្រព្រឹត្តត្រូវគ្នាតែបែបមួយ ដ្បិតពួកអ្នកទាំងអស់គ្នា ធ្វើអំពើនេះហើយ នឹងបានទទួលសម្បត្តិសុខ ។ លុះដល់បច្ឆិមភព អ្នកទាំងឡាយនឹងឃើញច្បាស់ព្រះនិព្វាន មានភាពដ៏ត្រជាក់ត្រជុំ ជាគុណជាតដ៏ប្រសើរ ឥតចាស់ឥតស្លាប់ ជាទីក្សេមក្សាន្ត ។ ព្រះសព្វញ្ញុពុទ្ធ ជាបុគ្គលប្រសើរ បានព្យាករយ៉ាងនេះ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកាហើយ ក៏ទទួលនូវសេចក្តីសោមនស្ស ។ ខ្ញុំ

រីករាយក្នុងទេវលោកអស់ ៣០ ពាន់កប្ប ខ្ញុំជាធំជាងទេវតា សោយទេវរាជ្យ អស់ ៥០០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិអស់មួយពាន់ដង បានសោយបទេស រាជ្យដ៏ទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ ពួកបរិស័ទបានមកជាផៅពង្ស ក្នុងរាជ្យជារបស់មនុស្សនេះ លុះដល់បច្ឆិមកព មានព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈ សន្សំទ្រព្យទុកបាន ៨០ កោដិ ។ ខ្ញុំក៏បានជាកូនរបស់វាសេដ្ឋព្រាហ្មណ៍នោះ ពាក្យថាសេលព្រាហ្មណ៍ ជាឈ្មោះរបស់ខ្ញុំ ៗ ជាអ្នកដល់នូវបារមីក្នុងធម្មន្ត ទាន ។ កាលខ្ញុំដើរទៅកាន់ទីសម្រាកស្ងួន ពួកសិស្សរបស់ខ្លួនចោមរោម ខ្ញុំ ឃើញគ្រឿងបូជាដែលគេចាត់ចែង ក៏ពោលពាក្យនេះនឹងកេនិយតាបស ដែល ពេញដោយភារៈ គឺផ្ទងសក់ថា លោកធ្វើអាវាហមង្គល ឬវិវាហមង្គល ឬក៏លោក អញ្ជើញព្រះរាជាមក ។ ( កេនិយតាបសតបថា ) ខ្ញុំមានប្រាថ្នាបូជានូវគ្រឿង បូជា ចំពោះព្រាហ្មណ៍ដែលទេវតាសន្មតហើយ ខ្ញុំមិនមែនអញ្ជើញព្រះរាជា ទេ គ្រឿងបូជាមិនមានដើម្បីខ្ញុំទេ ។ អាវាហមង្គលរបស់ខ្ញុំក៏មិនមាន ទាំងវិវាហ មង្គលរបស់ខ្ញុំក៏មិនមានដែរ ព្រះពុទ្ធព្រះអង្គទ្រង់ញុំាងសេចក្តីរីករាយរបស់ពួក សក្យៈឲ្យកើតឡើង ជាបុគ្គលប្រសើរក្នុងលោកព្រមទាំងទេវលោក ។ ព្រះ ពុទ្ធជាបុគ្គលមានប្រយោជន៍ និងសេចក្តីចម្រើនដល់សត្វលោកទាំងពួង នាំមក នូវសេចក្តីសុខដល់សព្វសត្វ ព្រះពុទ្ធនោះ ខ្ញុំបាននិមន្តហើយក្នុងថ្ងៃនេះ ការ ចាត់ចែងនុ៎ះ ដើម្បីព្រះសាស្តានុ៎ះទេតើ ។ ព្រះពុទ្ធទ្រង់មានពន្លឺនៃពណ៌ ដូច ផ្លែទន្លាប់ទុំ មានប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម មិនមានបុគ្គល ស្មើដោយរូប ខ្ញុំបាននិមន្តហើយដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះពុទ្ធជាទីពឹងនោះ

ព្រះអង្គរីកកាយ ដូចមាត់បាវមាសផង ប្រាកដស្មើដោយរងើកភ្លើងគគីរផង ជាមហាវីរបុរស ឧបមាដូចផ្ទេកបន្ទោរ ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ដូចជាភ្លើងលើកំពូលភ្នំ ឬដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ពុំនោះសោត ប្រាកដស្មើពណ៌ភ្លើងដែលឆេះព្រៃបបុស ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកប្រាជ្ញ មិនតក់ស្លុត មានភ័យកន្ទងផុតហើយ ធ្វើនូវទីបំផុតនៃភព ជាមហាវីរបុរស ឧបមាដូចសីហៈ ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកឈ្លាសវៃក្នុងធម៌របស់ព្រះពុទ្ធទាំងឡាយ ដែលពួកបុគ្គលដទៃ កំហែងមិនបានជាមហាវីរបុរស ឧបមាដូចដំរី ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ទ្រង់ឈ្លាសវៃក្នុងត្រៃយនៃព្រះសទ្ធម្ម ជាព្រះពុទ្ធនាគ មិនមានបុគ្គលស្មើ ជាមហាវីរ-បុរស ឧបមាដូចគោឧសភ ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ មានគុណឥតមានទីបំផុត មានយសរាប់មិនបាន មានលក្ខណៈទាំងអស់ដ៏វិចិត្រ ជាមហា-វីរបុរស ឧបមាដូចព្រះឥន្ទ្រ ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ទ្រង់ស្ទាត់ផងមានពួកផង មានអំណាចផង មានតេជៈផង គេបៀតបៀនមិនបានផង ជាមហាវីរបុរស ឧបមាដូចព្រហ្ម ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គមានធម៌ដ៏ប្រសើរលើស មានកម្លាំង ១០ ប្រការ ដល់នូវត្រើយនៃកម្លាំងតូចធំជាមហាវីរបុរស ឧបមាដូចផែនដី ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គកុះករដោយសីល និងសេចក្តីព្យាយាម ទ្រង់ញុំាងធម្មវិញ្ញាណឲ្យរំជួល ជាមហាវីរបុរស ឧបមាដូចសមុទ្រ ខ្ញុំបានទិមន្តហើយ ។ ព្រះពុទ្ធនោះ គេបៀតបៀនមិនបាន គេគ្របសង្កត់បានដោយក្រ ជាបុគ្គលមិនញាប់ញ័រ ខ្ពង់ខ្ពស់

ប្រសើរ ជាមហាវីរបុរស ឧបមាដូចភ្នំសិនេរុ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ទ្រង់មានញាណរកទីបំផុតគ្មាន ឥតមានបុគ្គលស្មើ រកបុគ្គលប្រឹងស្មើមិនមាន ដល់នូវភាពជាបុគ្គលប្រសើរ ជាមហាវីរបុរស មានឧបមាដូចមេឃ ខ្ញុំបាននិមន្តហើយ ។

## ចប់ ភាណវារ ទី ១៥ ។

ព្រះពុទ្ធនោះ ព្រះអង្គជាទីពឹងរបស់ពួកសត្វ ដែលមានភ័យភិត ជាទីពំនាក់នៃពួកសត្វដែលដល់នូវសរណៈ ជាមហាវីរបុរស ញ៉ាំងសត្វឲ្យស្រស់ស្រាយ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាទីអាស្រ័យនៃពួកបុគ្គលមានប្រាជ្ញា ជាបុញ្ញក្ខេត្តរបស់ពួកជនអ្នកស្វែងរកសុខ ព្រះអង្គជាអណ្តូងនៃរតនវត្ថុ ជាមហាវីរបុរស ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គញ៉ាំងសត្វឲ្យស្រស់ស្រាយ ធ្វើឲ្យទៅជាទេវតា ទ្រង់ឲ្យនូវសាមញ្ញផល ជាមហាវីរបុរស ឧបមាដូចមេឃ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ជាវីរបុរស ផុសឡើងហើយក្នុងលោក ទ្រង់បន្ទោបង់នូវងងឹតទាំងពួង ជាមហាវីរបុរស ឧបមាដូចព្រះអាទិត្យ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់បង្ហាញនូវសេចក្តីពិតក្នុងអារម្មណ៍និងវិមុត្តិទាំងឡាយ ជាមហាវីរបុរស ឧបមាដូចព្រះចន្ទ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គផុសឡើងហើយក្នុងលោក ប្រដាប់ហើយដោយលក្ខណៈទាំងឡាយ ជាមហាវីរបុរស មិនមានប្រមាណ ខ្ញុំបាននិមន្តហើយ ។ ញាណរបស់ព្រះពុទ្ធណា មិនមានប្រមាណ សីលរបស់

ព្រះពុទ្ធណា រកសេចក្តីប្រដូចគ្មាន វិមុត្តិរបស់ព្រះពុទ្ធណា រកអ្វីស្មើគ្មាន ព្រះពុទ្ធនោះ ខ្ញុំបាននិមន្តហើយ ។ សេចក្តីព្យាយាមរបស់ព្រះពុទ្ធណា ឥតមានអ្វីស្មើ កម្លាំងរបស់ព្រះពុទ្ធណា ដែលបុគ្គលគិតមិនឃើញ សេចក្តីប្រឹងប្រែងរបស់ព្រះពុទ្ធណា ជាឧបាយដ៏ប្រសើរ ព្រះពុទ្ធនោះ ខ្ញុំបាននិមន្តហើយ ។ ពិសទាំងពួង គឺរាគៈ ទោសៈ មោហៈ ដែលព្រះពុទ្ធអង្គណា គាស់រំលើងហើយ ព្រះពុទ្ធអង្គនោះ ជាមហាវីរបុរស មានឧបមាដូចឱសថ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ដូចបុគ្គលមានឱសថ ព្រះអង្គជាអ្នកបន្ទោបង់នូវព្យាធិគឺកិលេស ដែលជាទុក្ខច្រើនប្រការ ជាមហាវីរបុរស ឧបមាដូចផ្ទេកបន្ទោរ ខ្ញុំបាននិមន្តហើយ ។

កេនិយតាបសបានពោលឃោសនាថា ព្រះពុទ្ធ ។ ដូច្នេះ ការឃោសនានោះ ខ្ញុំបានឮដោយកម្រណាស់ ខ្ញុំមានបីតិកើតឡើង ព្រោះឮពាក្យឃោសនាថា ព្រះពុទ្ធ ។ ចិត្តរបស់ខ្ញុំឥតប្រកាន់ បីតិរបស់ខ្ញុំក៏ផ្សាយចេញទៅខាងក្រៅ ខ្ញុំនោះមានចិត្តប្រកបដោយបីតិ មានចិត្តស្ងប់ បានពោលពាក្យនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គជាចម្បងក្នុងលោក ប្រសើរជាងជន គង់នៅក្នុងទីណា ខ្ញុំនឹងទៅនមស្ការព្រះអង្គក្នុងទីនោះ ទ្រង់ជាអ្នកឲ្យនូវសាមញ្ញផល ។ ខ្ញុំមានសេចក្តីត្រេកអរកើតឡើង ធ្វើអញ្ជលីលើកដៃខាងស្តាំ ( សួរថា ) លោកចូរប្រាប់ខ្ញុំផងនូវព្រះពុទ្ធជាស្តេចហេតុធម៌ ទ្រង់បន្ទោបង់នូវសរគឺសេចក្តីសោក ។ ( កេនិយតាបសប្រាប់ថា ) អ្នកចូរមើលព្រៃធំទុំ ដែលហាក់ដូចជាមហាមេឃបើកស្រឡះ ឬដូចផ្កាអញ្ចនខៀវ ឬក៏ប្រាកដដូចជាសាគរ ព្រះពុទ្ធនោះ ជា

អ្នកប្រាជ្ញ ទូន្មាននូវបុគ្គលដែលមានខ្លួនមិនទាន់ទូន្មាន ទ្រង់ប្រៀនប្រដៅនូវពួកវេនេយ្យសត្វ ញុំាងវេនេយ្យសត្វឲ្យត្រាស់ដឹងនូវពោធិបក្ខិយធម៌ ទ្រង់គង់នៅក្នុងព្រៃធំនុ៎ះ ។ ខ្ញុំក៏ពិនិត្យមើលនូវព្រះជិនស្រី គួរទោដូចជាបុគ្គលស្រេកទឹក ឬដូចបុគ្គលឃ្លានបាយ ឬក៏ដូចមេគោដែលជាប់ចំពាក់នឹងកូនគោ ខ្ញុំជាអ្នកស្គាល់នូវអាចារៈនិងឧបចារៈ បានញុំាងពួកសិស្សរបស់ខ្លួនដែលកំពុងដើរទៅកាន់សំណាក់ព្រះជិនស្រី ឲ្យសិក្សានូវការប្រុងឲ្យសមតាមប្រពៃណីថា ម្នាលមាណពទាំងឡាយ ព្រះមានព្រះភាគទាំងឡាយ គេចូលទៅរកបានដោយក្រ ដូចជាសីហៈ ដែលត្រាច់ទៅតែឯង អ្នកទាំងឡាយ ចូរដើរដាក់ជើងជិតជើង ( សន្សឹមៗ ) ដើរមកចុះ ។ ព្រះពុទ្ធទាំងឡាយ អ្នកផងចូលទៅរកបានដោយក្រ ដូចជាពស់អាសិរពិសដ៏ឃោរឃៅ ដូចជាកេសររាជសីហ៍ជាស្តេចម្រឹគ ឬក៏ដូចជាដំរីកុញ្ជរបានបទដែលចុះប្រេង ។ ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរទប់នូវអាការក្អកនិងកណ្តាស់ ចូរដើរដាក់ជើងជិតជើង ចូលទៅកាន់សម្នាក់ព្រះពុទ្ធចុះ ។ ព្រះពុទ្ធទាំងឡាយ ព្រះអង្គធ្ងន់ព្រះទ័យ ក្នុងការពួនសម្ងំ ពេញព្រះហឫទ័យនឹងសំឡេងតិចៗ អ្នកផងចូលទៅរកបានដោយក្រ ចូលទៅជិតបានដោយលំបាក ជាគ្រូក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ កាលណា ខ្ញុំកំពុងសាកសួរប្រស្នា ឬកំពុងនិយាយរាក់ទាក់ កាលនោះ អ្នកទាំងឡាយចូរនិយាយសំឡេងតិច ៗ ចូរបិតនៅស្ងៀម ។ កាលណាព្រះពុទ្ធនោះ ទ្រង់សម្តែងព្រះសទ្ធម្ម ជាធម៌ក្សេម ដើម្បីដល់ព្រះនិព្វាន ( កាលនោះ ) អ្នកទាំងឡាយ ចូរត្រងត្រាប់ស្តាប់ ( សេចក្តីនោះ ) ដ្បិតការស្តាប់នូវព្រះ

សទ្ធម្មជាការល្អ ។ ខ្ញុំបានចូលទៅគាល់ព្រះសម្ពុទ្ធ ហើយនិយាយរាក់ទាក់ ( ជាមួយ ) នឹងព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ លុះបញ្ចប់ពាក្យនោះហើយ ក៏ពិនិត្យមើលលក្ខណៈទាំងឡាយ ។ ខ្ញុំមិនទាន់ឃើញលក្ខណៈ ២ ប្រការ ឃើញតែលក្ខណៈ ៣០ ប្រការ ទើបព្រះមុនីទ្រង់បង្ហាញដោយឫទ្ធិនូវគុយ្ហៈ ជាវត្ថុបិទបាំងដោយស្រោម ។ ព្រះជិនស្រីទ្រង់លៀនព្រះជិវ្ហា ហើយប៉ះពាល់នូវព្រះកាណ៌ និងព្រះនាសិកៈ បាំងនូវទីបំផុតព្រះនលាដៈទាំងអស់ ។ លុះខ្ញុំឃើញលក្ខណៈរបស់ព្រះអង្គដ៏បរិបូណ៌ព្រមទាំងអនុព្យញ្ជនៈ ក៏ដល់នូវសេចក្ដីចូលចិត្តថា ជាព្រះពុទ្ធ ហើយបួសជាមួយនឹងពួកសិស្ស ។ លុះខ្ញុំព្រមទាំងពួកសិស្ស ៣០០ នាក់ ចូលទៅកាន់ផ្នួសហើយ កាលមិនទាន់ដល់កន្លះខែនៅឡើយ ពួកយើងទាំងអស់ ក៏ដល់នូវសេចក្ដីរលត់ទុក្ខ ។ ជនទាំងឡាយ បានធ្វើនូវបុញ្ញកម្មជាមួយគ្នា ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ អន្ទោលទៅក្នុងទីជាមួយគ្នា វិលមកកើតក្នុងទីជាមួយគ្នា ។ ខ្ញុំបានប្រគេនបង្កង់ទាំងឡាយ ( ចំពោះសង្ឃ ) ហើយនៅក្នុងពួក ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុគឺអានិសង្ស ៨ ប្រការ គឺខ្ញុំត្រូវគេបូជាក្នុងទិសទាំងឡាយ ១ ភោគៈទាំងឡាយរបស់ខ្ញុំរាប់មិនអស់ ១ ខ្ញុំជាទីពឹងរបស់ពួកជនទាំងពួង ១ ខ្ញុំមិនមានសេចក្ដីតក់ស្លុត ១ ខ្ញុំមិនមានជំងឺទាំងឡាយ ១ ខ្ញុំរមែងរក្សាអាយុឲ្យរស់នៅវែង ១ ជាអ្នកមានសម្បុរថ្ងៃដ៏ល្អិត ១ កាលដែលភ្លៀងធ្លាក់ក្នុងអាវាស ខ្ញុំឲ្យនូវបង្កង់ ៨ ហើយនៅក្នុងពួក អំពើជាកុសលនេះ នាំឲ្យខ្ញុំបានបដិសម្ភិទា និងអរហត្ត នេះជាអានិសង្សគ្រប់ ៨ ។ បពិត្រព្រះមហាមុនី កូនរបស់ព្រះអង្គ

ឈ្មោះអដ្ឋគោបានសី មានព្រហ្មចរិយធម៌ជាទីបំផុត នៅចប់សព្វគ្រប់ហើយ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ ខ្ញុំបានឲ្យសសរ ៥ ហើយនៅក្នុងពួក ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺបានអានិសង្ស ៥ ប្រការ គឺខ្ញុំជាអ្នកមិនកម្រើកចាកមេត្តា ១ មានភោគៈមិនខ្វះខាត ១ មានពាក្យសម្តីគួរអ្នកផងកាន់យក ១ មិនកម្ចាត់បង់ ( នូវគុណនៃបុគ្គលដទៃ ) ១ ចិត្តរបស់ខ្ញុំមិនភ័ន្តច្រឡំ ខ្ញុំជាអ្នកមិនរឹងចចេសចំពោះបុគ្គលណាមួយ ១ ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំជាអ្នកមិនមានមន្ទិលក្នុងសាសនា ។ បពិត្រព្រះមុនី ជាមហាវីរបុរស ភិក្ខុជាសាវករបស់ព្រះអង្គ ប្រកបសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង មានកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ រមែងថ្វាយបង្គំព្រះអង្គ ។ ខ្ញុំបានធ្វើនូវបល្ល័ង្កដែលធ្វើដ៏ល្អ ហើយតាំងទុកក្នុងសាលា ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺអានិសង្ស ៥ ប្រការ គឺ ខ្ញុំកើតក្នុងត្រកូលខ្ពង់ខ្ពស់ ១ ជាអ្នកមានភោគៈច្រើន ១ ជាអ្នកមានសម្បត្តិគ្រប់មុខ ១ ខ្ញុំមិនមានសេចក្តីកំណាញ់ ១ បល្ល័ង្ករមែងផុសឡើងដល់ខ្ញុំ ក្នុងដំណើរដែលខ្ញុំប្រាថ្នា ១ ខ្ញុំរមែងទៅកាន់ទីដែលខ្ញុំប្រាថ្នា ព្រមដោយបល្ល័ង្កដ៏ប្រសើរ ។ ខ្ញុំបន្ទោបង់នូវងងឹតទាំងពួងបាន ព្រោះទាននៃបល្ល័ង្កនោះឯង បពិត្រព្រះមុនី ព្រះថេរៈដែលដល់នូវកម្លាំងនៃអភិញ្ញាទាំងពួង រមែងថ្វាយបង្គំនូវព្រះអង្គ ។ ខ្ញុំញ៉ាំងកិច្ចទាំងពួងដែលជាកិច្ចរបស់អ្នកដទៃនិងកិច្ចរបស់ខ្លួនឲ្យសម្រេច ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបានចូលទៅកាន់បុរីឥតមានភ័យ ។ ខ្ញុំបានឲ្យគ្រឿងប្រើប្រាស់ទុកក្នុងសាលាដែលកសាងស្រេចហើយ ដោយអំពើ

ដែលខ្ញុំធ្វើល្អនោះ ទើបបានដល់នូវភាពនៃខ្លួនជាបុគ្គលប្រសើរ ។ ពួកជនអ្នកទូន្មានណាទីមួយក្នុងលោក ពួកជនអ្នកទូន្មានទាំងនោះ រមែងទូន្មាននូវដំរីនិងសេះទាំងឡាយ ពួកជនអ្នកទូន្មានទាំងនោះ ធ្វើដោយហេតុផ្សេង ៗ ហើយទូន្មានដោយអំពើដ៏អាក្រក់ ។ បពិត្រព្រះមហាវីរបុរស ព្រះអង្គមិនមែនទូន្មាននូវពួកបុរសស្ត្រីដូច្នោះទេ ព្រះអង្គតែងទូន្មាននូវពួកជនដ៏ខ្ពង់ខ្ពស់ដែលគួរទូន្មានដោយហេតុមិនបាច់ប្រើដំបង មិនបាច់ប្រើគ្រឿងសស្ត្រាវុធ ។ បពិត្រព្រះមហាមុនី ព្រះអង្គឈ្លាសវៃក្នុងការទេសនា ទ្រង់សរសើរគុណនៃទាន បពិត្រព្រះមុនី ព្រះអង្គកាលសម្តែងនូវប្រស្នាតែមួយសោះ ក៏ញុំាងពួកបុរសទាំង ៣០០ នាក់ ឲ្យត្រាស់ដឹងធម៌បាន ។ ពួកយើងដែលព្រះអង្គជាសារថីបានទូន្មានហើយ ជាអ្នកមានចិត្តរួចស្រឡះ មិនមានអាសវៈ ដល់នូវកម្លាំងនៃអភិញ្ញាទាំងពួង មានទុក្ខរលត់ហើយ ព្រោះអស់ទៅនៃឧបធិក្កិលេស ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ភ័យគ្រប់យ៉ាងខ្ញុំកន្លងផុតហើយ នេះជាផលនៃការឲ្យសាលា ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ប្រការ ខ្ញុំបានដល់ហើយ ទាំងសាសនធម៌របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើចប់ហើយ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ

ជាអ្នកមិនមានអាសវៈ ដូចជាដំរីកាត់នូវទន្ទឹង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសេលត្ថេរមានអាយុ ព្រមទាំងបរិស័ទ បានពោលនូវគាថាទាំងនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

## ចប់ សេលត្ថេរាបទាន ។

# សព្វកិត្តិកត្ថេរាបទានទី ៣

[ ៩៣ ] ខ្ញុំបានឃើញព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ទ្រង់ភ្លឺដូចឈើប្រចាំទ្វីប ភ្លឺប្រាលដូចផ្កាយព្រឹក ពុំនោះដូចផ្លេកបន្ទោរព្ធដ៏អាកាស ។ ព្រះអង្គមិនខ្លាច មិនតក់ស្លុត ដូចកេសររាជសីហ៍ជាស្តេចម្រឹគ ទ្រង់ប្រកាសនូវពន្លឺគឺញាណ ទ្រង់ញាំញីនូវពួកតិត្ថិយ ។ ទ្រង់ស្រង់នូវសត្វលោកនេះ ទ្រង់ផ្តាច់បង់នូវសេចក្តីសង្ស័យទាំងអស់ មិនខ្លាចដូចស្តេចម្រឹគ ។ ខ្ញុំជាព្រាហ្មណ៍ អ្នកទ្រទ្រង់នូវជដានិងស្បែកខ្លា មានចិត្តត្រង់ មានព្យាយាម បានកាន់យកនូវសំពត់សម្បកឈើ ទៅក្រាលទៀបបាទមូល ។ បានយកខ្លឹមក្លាំពាក់ទៅលាបព្រះតថាគត លុះលាបព្រះសម្ពុទ្ធហើយ បានសរសើរព្រះលោកនាយក ដូច្នេះថា

បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់ស្រង់នូវសត្វលោកនេះ ទ្រង់បានឆ្លងនូវឱឃធម៌ ទ្រង់ធ្វើញាណដ៏ប្រសើរឧត្តម ឲ្យភ្លឺដោយពន្លឺគឺញាណ ។ ព្រះអង្គញុំាងធម្មចក្ក ឲ្យប្រព្រឹត្តទៅក្នុងលោក ទ្រង់ញាំញីនូវអន្យតិត្ថិយ ជាបុគ្គលប្រសើរ ទ្រង់ឈ្នះសង្គ្រាម ទ្រង់ញុំាងផែនដីឲ្យកម្រើក ។ ទិដ្ឋិទាំងអស់បែកធ្លាយក្នុងញាណរបស់ព្រះអង្គ ប្រៀបដូចរលកក្នុងមហាសមុទ្ទ រមែងបែកធ្លាយក្នុងទីបំផុតច្រាំង ។ សំណាញ់នៃព្រានត្រីដ៏ល្អិត ដែលគេបង់ចុះក្នុងស្រះ ពួកសត្វទាំងនោះ ដែលតាំងនៅក្នុងសំណាញ់ ត្រូវគេបៀតបៀនក្នុងខណៈនោះយ៉ាងណា ។ បពិត្រព្រះអង្គនិរទុក្ខ ពួកអន្យតិត្ថិយក្នុងលោក ជាមនុស្សវង្វេងប្រាសចាកសច្ចៈ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃញាណដ៏ប្រសើរ របស់ព្រះអង្គក៏យ៉ាងនោះដែរ ។ ព្រះអង្គជាទីពឹងរបស់ពួកជនដែលឥតផៅពង្ស ដូច

ជាពួកមនុស្សដែលជាទីពំនាក់នៃពួកជន ដែលហែលលិចលង់ក្នុងអន្លង់ ព្រះអង្គជាទីរឭករបស់សត្វដែលឋិតនៅក្នុងភ័យ ជាទីប្រព្រឹត្តទៅខាងមុខនៃពួកសត្វដែលត្រូវការក្នុងការរួចចាកកិលេស ។ ព្រះអង្គទ្រង់ត្រាច់ទៅតែមួយអង្គឯង រកបុគ្គលស្មើគ្មាន ទ្រង់ប្រកបដោយមេត្តានិងករុណា ទ្រង់មានប្រាជ្ញា ទ្រង់ប្រកបក្នុងការលះ ទ្រង់ស្ងាត់ជំនាញ ទ្រង់នឹងធឹង ជាលំនៅនៃគុណ ។ ព្រះអង្គជាអ្នកប្រាជ្ញ ប្រាសចាកការវង្វេង មិនញាប់ញ័រ មិនមានសេចក្តីសង្ស័យ ទ្រង់មានសេចក្តីសន្តោស មានទោសៈខ្ជាក់ចោលហើយ ព្រះអង្គមិនមានមន្ទិល ទ្រង់សង្រួមស្អាតបាត ។ ព្រះអង្គកន្លងនូវកិលេសជាគ្រឿងជាប់ចំពាក់ មានសេចក្តីស្រវឹងកន្លងហើយ ទ្រង់មានវិជ្ជា ៣ ទ្រង់ដល់នូវទីបំផុតនៃភព ទ្រង់កន្លងនូវធម៌ជាដែន មានព្រះទ័យធ្ងន់ក្នុងធម៌ ទ្រង់ផ្សាយសេចក្តីចម្រើន ទ្រង់សាបព្រោះប្រយោជន៍ ។ ព្រះអង្គជាអ្នកចម្លងពួកសត្វដូចសំពៅ ទ្រង់ធ្វើនូវសេចក្តីទំនុកបម្រុងដូចកំណប់ទ្រព្យ ទ្រង់មិនខ្លាចដូចរាជសីហ៍ ពុំនោះសោតដូចស្តេចដំរីដែលហ្វឹកហ្វឺនហើយ ។ ខ្ញុំលុះសរសើរព្រះមហាមុនី ព្រះនាមបទុ-មុត្តរៈដោយគាថាទាំង ១០ ហើយ ថ្វាយបង្គំព្រះបាទាព្រះសាស្តា រួចឈរនៅស្ងៀម ក្នុងកាលនោះ ។

ព្រះលោកវិទូព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់ជាសាស្តាឋិតនៅក្នុងពួកភិក្ខុ ទ្រង់បានពោលនូវគាថាទាំងនេះថា កុលបុត្តណាសរសើរនូវសីល បញ្ញា និងធម៌របស់តថាគត តថាគតនឹងសរសើរកុលបុត្តនោះ អ្នកទាំងឡាយចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុគ្គលនេះនឹង

រីករាយក្នុងលោក នឹងបានជាធំ គ្របសង្កត់ទេវតាដទៃ នឹងសោយនូវឥស្សរភាពអស់ ៦ ម៉ឺនកប្ប ។ ក្នុងកាលជាខាងក្រោយមក កុលបុត្តនោះនឹងចេញបួស ត្រូវកុសលមូលជាស់តឿនហើយ នឹងបួសក្នុងសាសនានៃព្រះគោតមមានព្រះភាគ ។ លុះបួសហើយ បានវៀរបង់នូវបាបកម្មដោយកាយ កំណត់ដឹងនូវអាសវធម៌ទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

មេឃកាលកម្ពុរ ធ្វើផែនដីនេះឲ្យឆ្អែត យ៉ាងណាមិញ បពិត្រព្រះមហាវីរៈ ព្រះអង្គទ្រង់ញ៉ាំងខ្ញុំឲ្យឆ្អែតដោយធម៌ ក៏យ៉ាងនោះដែរ ។ ខ្ញុំព្រះអង្គសរសើរនូវសីល បញ្ញា និងធម៌នៃព្រះលោកនាថ ជាអ្នកដល់នូវព្រះនិព្វានជាទីស្ងប់ដ៏ក្រៃលែង ជាបទមិនឃ្លៀងឃ្លាត ។ ធ្វើម្ដេចហ្ន៎ ! ព្រះមានព្រះភាគអង្គនោះទ្រង់មានចក្ខុនឹងឋិតនៅអស់កាលយូរ អាត្មាអញនឹងបានដឹងនូវធម៌ដែលមិនទាន់ដឹងផង នឹងឃើញនូវអមតបទផង ។ នេះជាបច្ឆិមជាតិរបស់ខ្ញុំ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ខ្ញុំដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានឡើយ ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធ

របស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើចប់ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វកិត្តិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សព្វកិត្តិកត្ថេរាបទាន ។**

# មធុទាយកត្ថេរាបទានទី ៤

[ ៩៤ ] អាស្រមបរមសាលារបស់ខ្ញុំ ជាងបានស្ថាបនាល្អហើយទៀបឆ្នេរទន្លេឈ្មោះសិន្ធុ ខ្ញុំបានឲ្យពួកសិស្សរៀនគម្ពីរឥតិហាសៈ ព្រមទាំងលក្ខណៈក្នុងអាស្រមនោះ ។ ពួកសិស្សខ្ញុំទាំងអម្បាលនោះ ជាអ្នកប្រាថ្នានូវធម៌ ជាអ្នកប្រាថ្នាដើម្បីស្តាប់នូវពាក្យប្រៀនប្រដៅដ៏ល្អ ជាអ្នកដល់នូវបារមីក្នុងឆឡង្គធម៌ ខ្ញុំបានទូន្មានហើយ ពួកសិស្សទាំងនោះ នៅក្បែរឆ្នេរទន្លេសិន្ធុ ។ ក្នុងកាលនោះ ពួកសិស្សដែលឈ្លាសក្នុងការកើតនិងដំណើរមកផង ក្នុងលក្ខណៈផង ស្វែងរកនូវប្រយោជន៍ដ៏ឧត្តមនៅក្នុងព្រៃធំ ។ កាលនោះឯង ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់កើតឡើងក្នុងលោក ទ្រង់ជាអ្នកដឹកនាំពួកសត្វ អនុគ្រោះយើងខ្ញុំ បានស្តេចចូលមកជិតខ្ញុំ ។ ខ្ញុំបានឃើញព្រះសុមេធៈ ជាលោកនាយកមានព្យាយាមធំ ស្តេចចូលមកដល់ហើយ ក៏ធ្វើកម្រាលស្មៅ ថ្វាយព្រះលោកជេដ្ឋ ខ្ញុំយកទឹកឃ្មុំអំពីព្រៃធំ មកថ្វាយព្រះពុទ្ធដ៏ប្រសើរ ។

ព្រះសម្ពុទ្ធទ្រង់សោយហើយសម្តែងនូវព្រះពុទ្ធដីកានេះថា កុលបុត្ត ណាជ្រះថ្លាបានថ្វាយទឹកឃ្មុំនោះដល់តថាគតដោយដៃរបស់ខ្លួន តថាគតនឹងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយចូរប្រុងស្តាប់ពាក្យតថាគត ដែលនឹងសម្តែងចុះ ។ ដោយអំណោយទឹកឃ្មុំនេះផង ដោយកម្រាលស្មៅនេះផង បុរសនេះនឹងរីករាយក្នុងទេវលោក អស់ ៣ ម៉ឺនកប្ប ។ កន្លងទៅ ៣ ម៉ឺនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលនៃឱក្កាករាជ នឹងត្រាស់ឡើងក្នុងលោក ។ ឯបុរសនេះ នឹងជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នក

មិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំច្យុតចាកទេវលោក មកចាប់ផ្ទៃនៃមាតាក្នុងមនុស្សលោកនេះ ភ្លៀងទឹកឃ្មុំបានបង្អុរចុះ គ្របទូវផែនដីដោយទឹកឃ្មុំ ។ ក្នុងពេលដែលខ្ញុំប្រសូតចេញមក ភ្លៀងទឹកឃ្មុំរមែងបង្អុរចុះមកឲ្យខ្ញុំអស់កាលជានិច្ចក្នុងទីនោះ ( ដូចជាគេចាក់ទឹក ) អំពីក្អម ផែនដីគេច្នងបានដោយក្រ ។ ខ្ញុំបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ជាអ្នកបានបាយទឹកជាប្រក្រតីនេះជាផលនៃទានទឹកឃ្មុំ ។ ខ្ញុំកើតក្នុងទេវលោកនិងមនុស្សលោក ជាអ្នកបានសម្រេចដូចសេចក្តីប្រាថ្នាគ្រប់ប្រការ ជាអ្នកដល់នូវធម៌ជាគ្រឿងអស់អាសវៈ ដោយទានទឹកឃ្មុំនោះឯង ។

កាលភ្លៀងបង្អុរចុះមក កាលស្មៅ ( ដុះ ) កម្ពស់ ៤ ធ្នាប់ កាលដើមឈើលើប្រឹថពីជាទីគួរសោបព្រោះ មានផ្ការីកល្អ ខ្ញុំមិនមានអាសវៈ ដល់នូវសេចក្តីសុខជានិច្ច នៅក្នុងផ្ទះស្ងាត់ទៀបគល់ឈើជាមណ្ឌប ។

ខ្ញុំបានកន្ទងបង់នូវភពទាំងឡាយ ដែលជាភពក្នុងបច្ចុប្បន្នរបស់ខ្ញុំ ក្នុងថ្ងៃនេះ អាសវៈរបស់ខ្ញុំអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣ ម៉ឺនអំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានទឹកឃ្មុំ ។ កិលេសទាំងឡាយ ខ្ញុំបានដុតចោលហើយ ភពទាំងអស់ខ្ញុំបានដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦

នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមធុទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ មធុទាយកត្ថេរាបទាន ។

# បទុមកូដាគារិកត្ថេរាបទានទី ៥

[ ៩៥ ] ព្រះភគវន្តសម្ពុទ្ធ ព្រះនាមបិយទស្សី ទ្រង់ត្រាស់ដឹងឯង ទ្រង់ជានាយកនៃសត្វលោក ទ្រង់ប្រាថ្នានូវសេចក្តីស្ងប់ស្ងាត់ ជាអ្នកប្រាជ្ញ ឆ្លៀវឆ្លាសក្នុងសមាធិ ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ជាបុរសខ្ពង់ខ្ពស់ ទ្រង់ចូលទៅកាន់ដងព្រៃ ទ្រង់ក្រាលនូវចីវរបំសុកូលហើយ គង់នៅហើយ ។ ក្នុងកាលនោះ ខ្ញុំបានកើតជាព្រានម្រឹគ ខ្ញុំកំពុងដើរស្វែងរកម្រឹគក្តាន់ក្នុងព្រៃធំ ។ ខ្ញុំបានឃើញក្នុងព្រៃនោះនូវព្រះសម្ពុទ្ធ ទ្រង់ឆ្លងនូវឱឃៈ មិនមានអាសវៈ ដូចដើមសាលរាជព្រឹក្សមានផ្ការីក ឬដូចព្រះអាទិត្យដែលរះឡើង ។ លុះខ្ញុំឃើញនូវព្រះបិយទស្សីសម្ពុទ្ធ ទ្រង់មានយសច្រើន ជាទេវតាកន្លងទេវតា ក្នុងកាលនោះ ខ្ញុំក៏ចុះកាន់ជាតស្រះ ហើយបេះផ្កាឈូក ។ ខ្ញុំបេះនាំយកផ្កាឈូក ជាទីរីករាយនៃចិត្ត ហើយធ្វើនូវកូដាគារស្តានប្រក់ដោយផ្កាឈូក ។ ព្រះមហាមុនី ព្រះនាមបិយទស្សីជិនស្រីសម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីអនុគ្រោះ ប្រកបដោយករុណា ទ្រង់គង់ក្នុងកូដាគារស្តានអស់ ៧ យប់ ៧ ថ្ងៃ ។ ខ្ញុំបកផ្កាឈូកចាស់ចោលចេញ ហើយប្រក់ផ្កាឈូកថ្មីវិញ រួចឈរផ្គងអញ្ជលី ។ ព្រះមហាមុនីព្រះនាមបិយទស្សី ជាលោកនាយក ទ្រង់ចេញអំពីសមាធិ ហើយគង់ប្រមើលមើលទិសទាំងឡាយ ។ គ្រានោះ ព្រះថេរៈឈ្មោះសុទស្សនៈ ជាឧបដ្ឋាកមានឫទ្ធិច្រើន បានជ្រាបព្រះទ័យនៃព្រះបិយទស្សីសម្ពុទ្ធជាសាស្តា ។ ព្រះថេរៈនោះ មានភិក្ខុ ៨ ម៉ឺនចោមរោម ហើយចូលទៅគាល់ព្រះលោកនាយក ដែលគង់ជាសុខ ក្នុងទីបំផុតព្រៃ ។ ក្នុងកាលនោះ ទេវតាទាំងឡាយទាំងអស់ដែលនៅអាស្រ័យក្នុងដងព្រៃទាំងប៉ុន្មាន បានដឹងព្រះទ័យនៃព្រះសម្ពុទ្ធ

ក៏មកប្រជុំគ្នា ។ កាលពួកយក្ស ពួកកុម្ភណ្ឌ ព្រមទាំងពួកអារក្ស មកប្រជុំគ្នាផង ភិក្ខុសង្ឃក៏បានមកដល់ព្រមផង ទើបព្រះជិនស្រី ទ្រង់ត្រាស់ព្រះគាថាទាំងឡាយថា

កុលបុត្តណាបានបូជាតថាគតអស់ ៧ ថ្ងៃ ទាំងបានធ្វើអាវាសដល់តថាគត ៗ នឹងសរសើរកុលបុត្តនោះ អ្នកទាំងឡាយចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ តថាគតនឹងសម្តែងនូវធម៌ដ៏ល្អិតជ្រាលជ្រៅ ដែលបុគ្គលកម្រយល់ឃើញបានដោយងាយ ដែលតថាគតប្រកាសល្អហើយដោយញាណ អ្នកទាំងឡាយចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះ នឹងបានគ្រប់គ្រងទេវរាជ្យអស់ ១៤ កប្ប ផ្ទះកំពូលដ៏ធំទូលាយរបស់ទេវតានោះ ប្រក់ដោយផ្កាឈូក ។ ផ្កាឈូកទាំងឡាយនឹងបាំងពួដ៏អាកាសនេះជាផលនៃបុព្វកម្ម បុរសនោះ នឹងអន្ទោលទៅប្រឡូកប្រឡំ ក្នុងកប្បទី ១.៤០០ ។ វិមានជាវិការៈនៃផ្កានឹងបាំងនៅពួដ៏អាកាសនោះ ទឹកនឹងមិនជាប់ក្នុងស្លឹកឈូក យ៉ាងណា កិលេសទាំងឡាយ នឹងមិនជាប់ក្នុងញាណរបស់បុរសនោះ យ៉ាងនោះដែរ បុរសនេះនឹងញុំាងនីវរណៈទាំង ៥ ឲ្យឃ្លាតចាកចិត្ត ។ បុរសនោះ នឹងញុំាង ចិត្តឲ្យកើតក្នុងនេក្ខម្មៈ ហើយចេញចាកផ្ទះទៅបួស លំដាប់នោះ វិមានជាវិការៈនៃផ្កា ដែលកំពុងបាំង ក៏នឹងចេញទៅតាមដែរ ។ ភិក្ខុនោះមានប្រាជ្ញា មានស្មារតី កាលនៅទៀបគល់ឈើ វិមានជាវិការៈនៃផ្កានឹងមកបាំងលើព្រះកេស ក្នុងទីនោះ ។ ភិក្ខុនោះ នឹងឲ្យបច្ច័យគឺចីវរ បិណ្ឌបាត និងទីដេក ទីអង្គុយ ដល់ភិក្ខុសង្ឃ ជាអ្នកមិនមានអាសវៈ ហើយនឹងបរិនិព្វាន ។

បុរសនោះចេញទៅកាន់បព្វជ្ជា ក្នុងដំណើរជាមួយនឹងផ្ទះកំពូល ឯផ្ទះកំពូល ក៏ទ្រទ្រង់បាំងភិក្ខុនោះដែលនៅទៀបគល់ឈើ ។

ចេតនារបស់ខ្ញុំ មិនមានក្នុងចីវរ និងចង្ហាន់បិណ្ឌបាតទេ ខ្ញុំប្រកបដោយបុញ្ញកម្ម ទើបបាននូវការសម្រេច ។ ខ្ញុំមានជាតិកំណើតរាប់ដោយកោដិនៃកប្បជាច្រើន ព្រះលោកនាយកទាំងនោះ ទ្រង់មានព្រះហឫទ័យផុតស្រឡះ និព្វានកន្លងផុតទៅទទេ ៗ ។ ក្នុងកប្បទី ១.៨០០ ព្រះលោកនាយក ព្រះនាមបិយទស្សី ( ទ្រង់ត្រាស់ឡើង ) ទើបខ្ញុំបានមកចាប់កំណើតជាព្រានម្រឹគ បានចូលទៅគាល់ព្រះអង្គ ។ ឥឡូវនេះ ខ្ញុំឃើញព្រះគោតមសម្ពុទ្ធ មានបញ្ញាចក្ខុ ទ្រង់មិនថោកទាប ខ្ញុំក៏ទៅគាល់ព្រះអង្គ ហើយចូលទៅកាន់ផ្នួស ។ ព្រះពុទ្ធជិនស្រីទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ បានសម្តែងនូវព្រះសទ្ធម្ម ខ្ញុំស្តាប់ធម៌របស់ព្រះអង្គ ក៏បានដល់នូវអចលបទ គឺព្រះនិព្វាន ជាឋានមិនកម្រើក ។ ខ្ញុំបានញុំាងព្រះសម្ពុទ្ធព្រះនាមគោតម ជាពូជពង្សនៃសក្យៈ ឲ្យទ្រង់ត្រេកអរហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធ-បូជា ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំអស់រលីងហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលមកក្នុងសម្នាក់នៃព្រះសម្ពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះសម្ពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង

សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមកូជាគារិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមកូជាគារិកត្ថេរាបទាន ។

# អដ្ឋកថា

# សេលត្ថេរាបទាន ជាដើម

[ ៩២-៩៥ ] អបទានទី ២ ទី ៣ ទី ៤ និងទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសេលត្ថេរាបទានជាដើម ចប់

# ពក្កុលត្ថេរាបទានទី ៦

[ ៩៦ ] ភ្នំឈ្មោះសោភិតៈនៅក្នុងទីជិតនៃព្រៃហិមពាន្ត អាស្រមដ៏ល្អរបស់ខ្ញុំ គឺពួកសិស្សរបស់ខ្ញុំកសាងហើយ ។ មណ្ឌបទាំងឡាយជាច្រើន ដើមឈើភ្ញើងមានផ្ការីកក៏មានក្នុងទីនោះ ដើមខ្វិត ដើមច្បា ដើមខ្នឹង ដើមរំចេកក៏មានក្នុងទីនោះ ជាច្រើន ដើមចង្អេរទ្រាយ ដើមពុទ្រា ដើមកន្ទួតព្រៃ ដើមមាក់ប្រាង វល្លិឃ្លោក ដើមស្វាយសមានផ្ការីក ក៏មានក្នុងទីនោះជាច្រើន ដើមរាក់ស ដើមល្មៀ ដើមចេក ដើមក្រូចថ្លុង ក៏មានក្នុងទីនោះ ដើមជន្ទាត់ដៃ ដើមអង្គ្រែង ដើមប្រយង្គុ ក៏មានច្រើនក្នុងទីនោះ ។ ដើមស្រូល ដើមស្រល់ ដើមកុម្ភ ដើមជ្រៃក្រឹម ដើមក្រសាំង ( ក៏មានក្នុងទីនោះ ) អាស្រមរបស់ខ្ញុំប្រាកដយ៉ាងនេះ ខ្ញុំព្រមទាំងពួកសិស្ស ក៏នៅក្នុងអាស្រមនោះ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សីជាសយម្ភូលោកនាយក ទ្រង់ស្វែងរកទីសម្រាប់ពួនសម្ងំ ស្តេចបានចូលមកកាន់អាស្រមរបស់ខ្ញុំ ។ លុះព្រះអនោមទស្សី ព្រះអង្គមានព្យាយាមច្រើន មានយសធំ កំពុងស្តេចចូលមក អាពាធបណ្តាលអំពីខ្យល់ ក៏បានតាំងឡើងដល់ព្រះលោកនាថក្នុងមួយរំពេច ។ ខ្ញុំកាលត្រាច់ទៅក្នុងព្រៃ បានឃើញព្រះលោកនាយក ក៏ចូលមកជិតព្រះសម្ពុទ្ធ ទ្រង់មានចក្ខុ មានយសច្រើន ។ លុះខ្ញុំបានឃើញឥរិយាបថ ក៏កំណត់ទុកក្នុងកាលនោះថា ព្យាធិទាំងឡាយ ពិតជានឹងកើតដល់ព្រះពុទ្ធ ដោយឥតសង្ស័យ ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយប្រញាប់ប្រញាល់ ខ្ញុំមានបំណងនឹងធ្វើថ្នាំក្នុងសំណាក់ពួកសិស្សរបស់ខ្ញុំ ខ្ញុំបានហៅពួកសិស្សក្នុងកាលនោះ ។ ពួកសិស្សទាំងអស់ជាអ្នកមានសេចក្តីគោរព បានទទួលស្តាប់ពាក្យរបស់ខ្ញុំ ហើយមកប្រជុំក្នុងទី

ជាមួយគ្នា ព្រោះពួកសិស្សទាំងនោះ ជាអ្នកមានសេចក្តីគោរពដល់ខ្ញុំជាគ្រូ ។ ខ្ញុំបានឡើងភ្នំជាប្រញាប់ ហើយបាននាំមកនូវឱសថទាំងអស់ ខ្ញុំធ្វើផ្សំនឹងទឹកសម្រាប់ផឹក បានថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ កាលព្រះសព្វញ្ញូ លោកនាយក មានព្យាយាមធំ កាលទ្រង់សោយហើយ រោគខ្យល់នៃព្រះសុគតទ្រង់ស្វែងរកគុណដ៏ធំ ក៏បានស្ងប់រម្ងាប់យ៉ាងឆាប់ ។ ព្រះអនោមទស្សី មានយសច្រើន ទ្រង់ឃើញសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ទ្រង់គង់លើអាសនៈរបស់ព្រះអង្គ រួចទ្រង់ពោលនូវគាថាទាំងនេះថា បុរសណា បានប្រគេនភេសជ្ជៈដល់តថាគតផង បានរម្ងាប់ព្យាធិរបស់តថាគតផង តថាគតនឹងសរសើរបុរសនោះ អ្នកទាំងឡាយចូរស្តាប់ភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះ នឹងត្រេកអរក្នុងទេវលោកអស់មួយសែនកប្ប នឹងរីករាយក្នុងការប្រគំតន្ត្រីក្នុងទេវលោកនោះសព្វកាល ។ លុះត្រឡប់ មកកាន់មនុស្សលោកវិញ ត្រូវកុសលមូលដាស់តឿន នឹងបានជាស្តេចចក្កពត្តិ អស់មួយពាន់ដង ។ ក្នុងកប្បទី ៥៥ បុរសនេះនឹងបានកើតជាក្សត្រសោយរាជ្យ ព្រះនាមអនោមិ ជាធំក្នុងជម្ពូទ្វីប ជាធំលើផែនដី ឈ្នះសង្គ្រាម មានសមុទ្ទទាំង ៤ ជាទីបំផុត ។ នឹងបានជាស្តេចចក្កពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ញ៉ាំងទេវតាក្នុងឋានតាវត្តិង្សឲ្យកម្រើក ហើយនឹងសោយនូវឥស្សរភាព ។ បុរសនេះ ទោះនឹងកើតជាទេវតាក្តី ជាមនុស្សក្តី នឹងមិនមានអាពាធ នឹងវៀរបង់នូវព្យាធិ ជាគ្រឿងក្តៅក្រហាយក្នុងលោក ។ ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេច

ឱក្កាកៈ ទ្រង់ត្រាស់ឡើងក្នុងលោក ។ ឯបុរសនេះ នឹងបានជាអ្នកទទួលនូវមត៌កក្នុងធម៌របស់ព្រះសាស្តានោះ ជាឱរសដែលធម៌និម្មិតហើយ ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈនឹងបរិនិព្វាន ។ បុរសនេះ នឹងដុតនូវកិលេសទាំងឡាយ ហើយច្រូងនូវខ្សែនៃតណ្ហា នឹងបានទីជាសាវ័កនៃព្រះសាស្តាឈ្មោះពក្កុលៈ ។ ព្រះមានព្រះភាគ ព្រះនាមគោតម ជាសក្យៈប្រសើរ ទ្រង់បានជ្រាបនូវដំណើរទាំងអស់នេះ ទ្រង់តង់ក្នុងពួកភិក្ខុ នឹងតាំងពក្កុលភិក្ខុក្នុងទីជាឯតទគ្គៈ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សីជាសយម្ភូលោកនាយកទ្រង់ប្រមើលមើលសេចក្តីស្ងប់ស្ងាត់ ក៏បានស្តេចចូលមកអាស្រមរបស់ខ្ញុំ។ លុះព្រះសព្វញ្ញូ ជាលោកនាយកទ្រង់មានព្យាយាមធំ ស្តេចចូលមកដល់ហើយ ខ្ញុំក៏ជ្រះថ្លាបានញុំាងព្រះអង្គឲ្យបាន់ឆ្អែតស្កប់ស្កល់ ដោយឱសថទាំងពួង ដោយដៃរបស់ខ្លួន ។ ខ្ញុំនោះបានធ្វើអំពើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ល្អ ខ្ញុំមិនអាចញុំាងអំពើដែលខ្ញុំធ្វើល្អហើយក្នុងកាលនោះឲ្យអស់ទៅបាន ព្រោះការដល់ព្រមដោយពូជ ។ ខ្ញុំឈ្មោះថាមានលាភ អត្តភាពជាមនុស្ស ឈ្មោះថាខ្ញុំបានល្អហើយ ដ្បិតខ្ញុំបានឃើញព្រះនាយក ខ្ញុំក៏បានដល់នូវអចលបទ គឺព្រះនិព្វានដោយសំណល់នៃកម្មនោះឯង ។ ព្រះគោតមជាសក្យៈដ៏ប្រសើរ ទ្រង់បានជ្រាបដំណើរទាំងអស់នេះ ទ្រង់តង់ក្នុងពួកភិក្ខុ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងអស់ខ្ញុំដកចោលហើយ អាសវៈទាំង

*អស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះសម្ពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះពក្កុលត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

**ចប់ ពក្កុលត្ថេរាបទាន ។**

# អដ្ឋកថា

## ពក្កុលត្ថេរាបទាន

[ ៩៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះថា អបទានរបស់ព្រះពាកុលត្ថេរ មានពាក្យផ្តើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។

បានឮថា ព្រះថេរៈអង្គនេះ ក្នុងអតីតកាលក្នុងទីបំផុតនៃ មួយអសង្ខេយ្យ និងមួយសែនអំពីកប្បនេះ មុនកាលដែលព្រះមានព្រះភាគព្រះនាមថាអនោមទស្សីកើតឡើងហើយ កុលបុត្តនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ រៀនចប់ត្រៃវេទ មិនឃើញសារៈក្នុងត្រៃវេទនោះ គិតថា អញនឹងស្វែងរកប្រយោជន៍ក្នុងកពខាងមុខ ទើបបួសជាឥសីត្រង់ជើងភ្នំ ជាអ្នកបានអភិញ្ញា ៥ និងសមាបត្តិ ៨ ។ ថ្ងៃមួយ បានដំណឹងថា ព្រះពុទ្ធទ្រង់កើតឡើង ទើបទៅកាន់សម្នាក់ព្រះសាស្តា ស្តាប់ធម៌ហើយ តាំងមាំក្នុងសរណៈបី កាលព្រះសាស្តាកើតអាពាធទាក់ទងដោយរោគខ្យល់ ទើបនាំយកថ្នាំមកអំពីព្រៃ រម្ងាប់រោគខ្យល់នោះ បង្អោនចិត្តទឹកដល់បុណ្យនោះ ក៏ដើម្បីប្រយោជន៍នៃភាពជាអ្នកមិនមានរោគភ័យ ចុតិចាកមនុស្សលោកនោះហើយ ក៏បានទៅកើតក្នុងព្រហ្មលោក ។ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ អស់មួយអសង្ខេយ្យ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងត្រកូលមួយកន្លែងក្នុងនគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ បានឃើញភិក្ខុមួយរូបដែលព្រះសាស្តាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈជាងភិក្ខុដែលមានអាពាធ

តិច ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបតាំងបណិធានទុកហើយ សន្សំកុសលកម្មដរាបដល់អស់ជីវិត អន្ទោលទៅក្នុងសុគតិតែម្យ៉ាង ។ មុនព្រះមានព្រះភាគព្រះនាមថាវិបស្សីទ្រង់កើតឡើង កុលបុត្តនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងពន្ធុមតីនគរ រៀនចប់សិល្បសាស្ត្រគ្រប់យ៉ាងហើយ មើលមិនឃើញសារៈក្នុងសិប្បៈនោះ ទើបបានចេញបួសជាឥសី ជាអ្នកបានឈាននិងអភិញ្ញា នៅត្រង់ជើងភ្នំ បានឮថា ព្រះពុទ្ធកើតឡើងហើយ ទើបបានទៅកាន់សម្នាក់របស់ព្រះសាស្តា បានតាំងនៅក្នុងសរណៈបី កាលភិក្ខុទាំងឡាយកើតនូវជំងឺព្រោះលម្អងស្មៅនិងផ្កាឈើ ទើបជួយព្យាបាលរោគនោះឲ្យស្ងប់ តាំងនៅក្នុងអត្តភាពនោះដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ បានកើតក្នុងព្រហ្មលោក ។ បន្ទាប់អំពីនោះក្នុងកប្បទី ៩១ លោកបានអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតក្នុងផ្ទះមានត្រកូលក្នុងនគរពារាណសី នៅជាឃរាវាស បានមើលឃើញមហាវិហារមួយខ្នងដែលគ្រាំគ្រាទ្រុឌទ្រោម ទើបឲ្យជាងកសាងទីនៅអាស្រ័យទាំងអស់ មានរោងឧបោសថជាដើមក្នុងវិហារនោះ បានចាត់ចែងប្រគេនភេសជ្ជៈគ្រប់ប្រភេទ សម្រាប់ភិក្ខុសង្ឃក្នុងវិហារនោះ សាងកុសលកម្មដរាបដល់អស់ជីវិត ហើយអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ អស់ ១ ពុទ្ធន្តរ ។ មុនព្រះមានព្រះភាគនៃយើងទ្រង់កើតឡើង កុលបុត្តនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងកោសម្ពី ។

កុលបុត្តនោះ ប្រសូតចាកផ្ទៃរបស់មាតាហើយ ពួកកីលៀងនាំទៅងូត

ទឹកត្រង់ស្ទឹងយមុនាដើម្បីការមិនមានរោគ របូតអំពីដៃរបស់ពួកកីលៀង ត្រូវត្រីត្របាក់ អ្នកប្រមង់បង់សំណាញ់ចាប់ត្រីនោះបាន ហើយលក់ឲ្យភរិយានៃសេដ្ឋីអ្នកក្រុងពារាណសី ។ នាងទទួលត្រីនោះទៅហើយ ខណៈដែលកំពុងវះបានឃើញទារកមិនមានរោគ ព្រោះផលបុណ្យដែលធ្វើទុកក្នុងកាលមុន ទើបស្រែកថា ខ្ញុំបានកូនប្រុសហើយ ហើយចិញ្ចឹមទុក ។ មាតាបិតាបង្កើតជ្រាបដំណឹងនោះហើយ មកហើយពោលថា ទារកនេះជាកូនរបស់ពួកយើង ចូរឲ្យកូននេះដល់យើងចុះ ដូច្នេះ កាលធ្វើការប្តឹងផ្តល់ ព្រះរាជាទ្រង់សាកសួរហើយ ទើបទ្រង់កាត់ក្តីថា ទារកនេះចូរជារបស់សាធារណៈនៃត្រកូលទាំងពីរ ព្រោះថា គេតាំងនៅដោយភាពជាទាយាទនៃត្រកូលទាំងពីរ ទើបបានទាមថាពាកុលៈ ។ ចម្រើនវ័យហើយ បានសោយសម្បត្តិជាច្រើនក្នុងត្រកូលសេដ្ឋីទាំងពីរ មួយត្រកូលៗ ៦ ខែ ។ លុះដល់ពេលទារកមកនៅជាមួយខ្លួន សេដ្ឋីពីរត្រកូលនោះ បានចងទូកជាប់គ្នា ឲ្យសាងមណ្ឌបរតនៈទុកលើទូកនោះ ឲ្យរៀបចំតន្ត្រីដែលប្រកបដោយអង្គ ៥ ឲ្យកុមារអង្គុយលើទូកនោះ ហែហមទៅកាន់ព្រំដែនទាំងពីរនគរតាមស្ទឹង ពួកសេដ្ឋីម្ខាងទៀត ក៏រៀបចំយ៉ាងនោះដូចគ្នា ទៅកាន់ទីនោះ លើកកុមារដាក់លើទូកនោះហើយនាំទៅ ។ កុមារនោះចម្រើនយ៉ាងនោះរហូតមានអាយុ ៨០ ឆ្នាំ ប្រាកដឈ្មោះថាឧកយសេដ្ឋីបុត្ត ។ កុលបុត្តនោះ បានទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ធម៌ហើយ មានទូវសទ្ធា បួសហើយ ព្យាយាមអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ។

កាលលោកជាព្រះអរហន្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ហិមវន្តស្សាវិទូរេ** ដូច្នេះជាដើម ។ អត្ថនៃពាក្យនោះ ខ្ញុំបានពោលទុកហើយខាងដើមនោះឯង អត្ថនៃបាលីនៃអបទានក៏ដឹងបានងាយនោះឯង ។ ព្រះពាកុលត្ថេរ សម្រេចអរហត្តហើយ មានជីវិតរស់នៅជាសុខដែលកើតអំពីវិមុត្តិ ជាបុគ្គលមានអាយុ ១៦០ ឆ្នាំ ទើបបរិនិព្វាន ។

## អដ្ឋកថាពក្កុលត្ថេរាបទាន ចប់

# គិរិមានដុត្តោរាបទានទី ៧

[ ៩៧ ] កិរិយារបស់ខ្ញុំ ធ្វើមរណកាលហើយ កូនប្រុសរបស់ខ្ញុំទៅកាន់ព្រៃស្មសានហើយ មាតាបិតានិងបងប្រុស គេដុតលើជើងថ្ករតែមួយ ។ ខ្ញុំមានខ្លួនក្តៅសព្វ ស្គមស្លេកស្លាំង ព្រោះតែសេចក្តីសោកនោះ មិនតែប៉ុណ្ណោះ ចិត្តរបស់ខ្ញុំ ក៏ក្រឡុកច្រួត ខ្ញុំត្រូវសេចក្តីសោកនោះគ្របសង្កត់ហើយ ។ ខ្ញុំលុះត្រូវសរគឺសេចក្តីសោកគ្របសង្កត់ហើយ ក៏បានចូលទៅកាន់ទីជាយព្រៃ បរិភោគតែផ្លែឈើដែលជ្រុះហើយនៅទៀបគល់ឈើ ។ ព្រះសម្ពុទ្ធជិនស្រី ព្រះនាមសុមេធៈ ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ ព្រះអង្គមានប្រាថ្នានឹងស្រង់ខ្ញុំ ទើបស្តេចមកក្នុងសម្នាក់របស់ខ្ញុំ ។ ខ្ញុំលុះឮសូរព្រះបាទនៃព្រះសុមេធសម្ពុទ្ធជាមហេសី ក៏បានងាកក្បាលរមិលមើលព្រះមហាមុនី ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្យាយាមធំ ស្តេចបានចូលមកជិតខ្ញុំ ខ្ញុំក៏មានបីតិកើតឡើង គ្រានោះ ខ្ញុំឃើញព្រះលោកនាយកនោះហើយ ជាអ្នកមានចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ។ ខ្ញុំត្រឡប់បានស្មារតីវិញ បានប្រគេនស្លឹកឈើមួយក្តាប់ ព្រះមានព្រះភាគ មានបញ្ញាចក្ខុ ទ្រង់គង់ក្នុងទីនោះ ដោយសេចក្តីអនុគ្រោះ ។

ព្រះសុមេធសម្ពុទ្ធមានជោគ ជាលោកនាយក លុះគង់ក្នុងទីនោះហើយទ្រង់សំម្តែងធម៌ជាគ្រឿងបន្ទោបង់នូវសរគឺសេចក្តីសោករបស់ខ្ញុំថា សត្វទាំងឡាយមកអំពីភពនោះ ក៏អ្នកមិនបានហៅមក ដល់ទៅអំពីភពនេះវិញ ក៏អ្នកមិនបានអនុញ្ញាតឲ្យទៅ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពួកសត្វស្លាបទាំងឡាយ កាលភ្លៀងបង្អុរចុះ ក៏នាំគ្នាហើរចូល ព្រោះចំណីរបស់ខ្លួន សត្វទាំងនោះ ហើរចូលទៅ ត្រឹមតែភ្លៀងកំពុង

ធ្លាក់ចុះ ។ កាលភ្លៀងរាំងហើយ សត្វទាំងឡាយនោះ ក៏ហើរទៅកាន់ទីតាមប្រាថ្នា យ៉ាងណាមិញ មាតាបិតារបស់អ្នក ក៏យ៉ាងនោះដែរ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពួកភ្ញៀវដែលទើបមកដល់ថ្មីៗ រមែងកម្រើកញាប់ញ័រក្នុងកាលទៅវិញ យ៉ាងណា មាតាបិតារបស់អ្នក ក៏យ៉ាងនោះដែរ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពស់សកសំណកចាស់ចោល ហើយលូនទៅយ៉ាងណា មាតាបិតារបស់អ្នក តែងតែលះបង់រាងកាយចោលក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

ខ្ញុំកាលបានដឹងព្រះវាចានៃព្រះពុទ្ធ ក៏លះបង់នូវសរ គឺសេចក្ដីសោកបានហើយញ៉ាំងប្រាមោទ្យឲ្យកើត បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ លុះខ្ញុំថ្វាយបង្គំព្រះមហានាគ ហើយបូជានូវផ្កាឈើក្អំ ដ៏បរិបូណ៌ដោយក្លិនជាទិព្វ ចំពោះព្រះលោកនាយកព្រះនាមសុមេធ: ។ ខ្ញុំបូជាព្រះសម្ពុទ្ធរួចធ្វើអញ្ជលីលើត្បូងរព្វកនូវគុណដ៏ប្រសើរ សរសើរព្រះលោកនាយកថា បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គជាសព្វញ្ញូលោកនាយក ទ្រង់ឆ្លងនូវវាលវដ្តសង្សារហើយ បពិត្រមហាមុនី ព្រះអង្គទ្រង់ស្រង់សត្វទាំងពួងដោយញាណ ។ បពិត្រព្រះមុនី ព្រះអង្គទ្រង់ផ្ដាច់បង់នូវសេចក្ដីងឿងឆ្ងល់ និងសេចក្ដីសង្ស័យ បពិត្រព្រះអង្គមានចក្ខុព្រះអង្គ ទ្រង់ញ៉ាំងមគ្គផលឲ្យសម្រេចដល់ខ្ញុំ ដោយញាណរបស់ព្រះអង្គ ។ ព្រះអរហន្តទាំងឡាយដែលដល់នូវសេចក្ដីសម្រេច បានអភិញ្ញា ៦ មានឫទ្ធិច្រើន ត្រាច់ទៅក្នុងអាកាសបាន ជាអ្នកប្រាជ្ញ តែងចោមរោមក្នុងខណៈនោះ ។ សាវកទាំងឡាយ កំពុងប្រតិបត្តិក្តី ជាសេក្ខបុគ្គលក្តី ឋិតនៅក្នុងផលក្តី សាវក

របស់ព្រះអង្គទាំងនោះ បែកផ្កាហើយ ដូចផ្កាឈូក ក្នុងពេលព្រះអាទិត្យទើបនឹងរះ ។ មហាសមុទ្ទមិនកម្រើក ជ្រៅថ្លឹងមិនបាន កម្របុគ្គលឆ្លងបាន យ៉ាងណា បពិត្រព្រះអង្គមានចក្ខុ ព្រះអង្គបរិបូណ៌ដោយញាណប្រមាណមិនបាន ក៏យ៉ាងនោះ ។ ខ្ញុំថ្វាយបង្គំព្រះជិនស្រីមានចក្ខុ មានយសច្រើន ហើយនមស្ការទិសទាំង ៤ ក៏ដើរថយក្រោយទៅ ។ កាលខ្ញុំច្យុតចាកទេវលោក អន្ទោលទៅក្នុងភពតូចភពធំ ចុះមកចាប់ផ្ទៃនៃមាតា ជាអ្នកដឹងខ្លួន មានស្មារតី ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស មានព្យាយាមកម្ចាត់បង់កិលេស មានប្រាជ្ញាចាស់ មានការពួនសម្ងំជាគោចរ ។ ក្នុងកាលនោះ ខ្ញុំតាំងសេចក្តីព្យាយាមញុំាងព្រះមហាមុនីឲ្យត្រេកអរ ហើយប្រព្រឹត្តទៅ ដូចព្រះចន្ទផុតស្រឡះចាកពពក ។ ខ្ញុំជាអ្នកប្រកបរឿយៗនូវវិវេក ស្ងប់ស្ងាត់ ឥតមានឧបធិក្កិលេសកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៣ ម៉ឺនព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះសម្ពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤

*វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា ព្រះគិរិមានន្ទត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។*

**ចប់ គិរិមានន្ទត្ថេរាបទាន ។**

# អដ្ឋកថា
# គិរិមានន្ទត្ថេរាបទាន

[ ៩៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា អបទានរបស់គិរិមានន្ទត្ថេរ មានពាក្យផ្ដើមថា **ភរិយា មេ កាលង្កតា** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាសុមេធៈ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ កាលភរិយានិងបុត្តអស់ជីវិត ត្រូវសរគឺសេចក្ដីសោកចាក់ដោត ទើបចូលព្រៃបរិភោគផ្លែឈើដែលជ្រុះឯង អាស្រ័យនៅត្រង់គល់ឈើ ។ ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមថាសុមេធៈ បានយាងទៅកាន់ទីនោះដើម្បីអនុគ្រោះ ទ្រង់សម្ដែងធម៌ដកនូវសរ គឺសេចក្ដីសោក ។ កុលបុត្តនោះស្ដាប់ធម៌ហើយ មានចិត្តជ្រះថ្លា យកផ្កាដែលមានក្លិនក្រអូប បូជាព្រះមានព្រះភាគ ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីដាក់លើសិរសា សរសើរព្រះមានព្រះភាគ ។ ដោយបុណ្យនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ បានសោយសេចក្ដីសុខក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាកូនបុរោហិតរបស់ព្រះបាទពិម្ពិសារក្នុងនគររាជគ្រឹះ ។ កុលបុត្តនោះមានឈ្មោះថាគិរិមានន្ទ ។ គិរិមានន្ទនោះ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញអានុភាពរបស់ព្រះពុទ្ធ ក្នុងគ្រាដែលព្រះសាស្ដាទ្រង់យាងមកកាន់នគររាជគ្រឹះ មានសទ្ធាបួសហើយ បំពេញសមណធម៌ ក្នុង

អាវាសក្បែរស្រុក ២-៣ ថ្ងៃ ហើយទៅកាន់នគររាជគ្រឹះ ដើម្បីថ្វាយបង្គំព្រះសាស្តា ។ ព្រះបាទពិម្ពិសារ បានជ្រាបថា លោកនិមន្តមក ទើបយាងចូលទៅរកហើយបវារណាថា និមន្តលោកម្ចាស់នៅទីនេះចុះ ខ្ញុំនឹងទំនុកបម្រុងដោយបច្ច័យ ៤ ដូច្នេះ ។ កាលព្រះរាជាយាងទៅហើយ ទ្រង់មិនបាននឹកដល់ព្រះតម្រាស់នោះ ព្រោះមានព្រះរាជករណីយកិច្ចច្រើន ទើបព្រះថេរៈនៅក្នុងទីវាលនោះឯង ពួកទេវតាបានឃាត់នូវភ្លៀងមិនឲ្យធ្លាក់ ព្រោះខ្លាចព្រះថេរៈសើម ។ ព្រះរាជាទ្រង់ពិចារណាដល់ហេតុដែលភ្លៀងមិនធ្លាក់ ទ្រង់ជ្រាបហើយទើបទ្រង់ត្រាស់ឲ្យពួកជាងសាងកុដិប្រគេនព្រះថេរៈ ព្រះថេរៈនៅក្នុងកុដិដោយការតាំងមាំនៃចិត្ត ព្រោះបានសេនាសនៈជាទីសប្បាយ ប្រកបព្យាយាមឲ្យស្មើ លើកចិត្តឡើងកាន់វិបស្សនា សម្រេចអរហត្តហើយ ។ កាលលោកបានសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ភរិ-យា មេ កាលង្កតា** ដូច្នេះ ជាដើម ។ ការប្រារព្ធនាមរបស់ព្រះមានព្រះភាគក្តី អនុសាសនីដែលព្រះមានព្រះភាគត្រាស់ប្រៀនប្រដៅក្តី ប្រវត្តិគឺអប-ទាននៃការសម្រេចមគ្គផលក្តី ដឹងបានងាយតាមគន្លងនៃពាក្យដែលមាន ។

## អដ្ឋកថាគិរិមានន្ទត្ថេរាបទាន ចប់

# សលឡមណ្ឌបិយត្ថេរាបទានទី ៨

[ ៩៨ ] កាលព្រះកកុសន្ធៈ ទ្រង់បានបន្សាត់បាប បានអប់រំព្រហ្មចរិយធម៌ហើយទ្រង់បរិនិព្វានទៅ ខ្ញុំបានយកកម្រងផ្កាស្រល់មកធ្វើជាមណ្ឌប ។ ខ្ញុំបានទៅកើតក្នុងឋានតាវត្តិង្ស បាននូវវិមានដ៏ឧត្តម គ្របសង្កត់នូវទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ខ្ញុំកាលដើរទៅមកក្តី ឈរក្តី ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ផ្កាស្រល់តែងគ្របបិទបាំងខ្ញុំ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡមណ្ឌបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សលឡមណ្ឌបិយត្ថេរាបទាន ។**

# សព្វទាយកត្ថេរាបទានទី ៩

[ ៩៩ ] លំនៅរបស់ខ្ញុំលយចូលទៅក្នុងមហាសមុទ្រ ដែលបុញ្ញកម្មនិម្មិតល្អហើយ ស្រះបោក្ខរណីដែលបុញ្ញកម្មនិម្មិតល្អហើយ ជាស្រះមានពួកសត្វចាក្រពាកយាសយំ ដេរដាសដោយដើមចន្ទុលណីផង ដោយផ្កាឈូក និងផ្កាឧប្បលផង ស៊ីងតាំងនៅដ៏ល្អ ជាទីរីករាយនៃចិត្ត តែងហូរចុះក្នុងស្រះបោក្ខ-រណីនោះ ។ ស្រះនោះ ដេរដាសដោយត្រីនិងអណ្តើក ជាទីប្រជុំនៃម្រឹគផ្សេងៗ គឹកកងដោយសំឡេងនៃក្ងោកនិងក្រៀល មួយអន្ទើដោយសត្វទាំងឡាយ មានសត្វតាវៅជាដើម ដែលមានសំឡេងពីរោះ ។ ពួកសត្វព្រាប ប្រវឹក ចាក្រ-ពាក ក្អែកទឹក ត្រដេវវិច សាលិកា ចង្កៀលខ្យង ប៉ោលតោក ( មានកុះករ ) ក្នុងស្រះនោះ ។ ពួកសត្វហង្ស ក្រៀល ខ្វែងស្រាក គ្រលេងគ្រលោងដ៏ច្រើន តែងបន្លឺសូរសេពួកងរំពង ស្រះនោះ បរិបូណ៌ដោយកែវ ៧ ប្រការ មានដីខ្សាច់ជាវិការៈនៃកែវមណីនិងកែវមុក្តា ។ ពួកដើមឈើជាវិការៈនៃមាសទាំងអស់ មានក្លិនផ្សេងៗ ផ្សាយចេញទៅ ញុំាងលំនៅ ( របស់ខ្ញុំ ) ឲ្យរុងរឿងទាំងថ្ងៃទាំងយប់ សព្វៗកាល ។ តូរ្យតន្ត្រី ៦ ម៉ឺន មកប្រគំរាល់វេលាល្ងាចព្រឹក ស្រី ៗ ១ ម៉ឺន ៦ ពាន់ តែងមកចោមរោមខ្ញុំសព្វ ៗ កាល ។ ខ្ញុំចេញអំពីលំនៅ មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះសុមេធៈ ជាលោកនាយក ដ៏មានយសធំអង្គនោះ ។ លុះថ្វាយបង្គំព្រះសម្ពុទ្ធហើយនិមន្តព្រះអង្គព្រមទាំងសិស្ស ព្រះសុមេធៈជាលោកនាយក ជាអ្នកប្រាជ្ញអង្គនោះទ្រង់បានទទួលនិមន្តន៍ ។ ព្រះមហាមុនី ទ្រង់ធ្វើធម្មកថាដល់ខ្ញុំ ហើយបញ្ជូនខ្ញុំទៅ ខ្ញុំក៏បានថ្វាយបង្គំព្រះសម្ពុទ្ធ ចូលទៅឯលំនៅរបស់ខ្ញុំ ។ ខ្ញុំបានហៅជន

ជាបរិស័ទមកថា អ្នកទាំងអស់គ្នាចូរប្រជុំគ្នា ព្រះសម្ពុទ្ធទ្រង់នឹងយាងមកកាន់លំនៅ ( របស់យើង ) ក្នុងបុព្វណ្ហសម័យ យើងឈ្មោះថា មានលាភហើយ អត្តភាពជាមនុស្សឈ្មោះថាយើងបានល្អហើយ ព្រោះយើងនៅរួមគ្នាយ៉ាងនេះ យើងនឹងធ្វើការបូជាដល់ព្រះពុទ្ធដ៏ប្រសើរ ជាសាស្តា ខ្ញុំនឹងតម្កល់បាយនិងទឹក ហើយក្រាបទូលនូវកត្តកាល ។ ព្រះលោកនាយក បាននិមន្តចូលទៅជាមួយនឹងភិក្ខុមួយសែនអង្គ ជាអ្នកស្ងាត់ក្នុងឈាន ។ ខ្ញុំបានធ្វើនូវការក្រោកទទួលព្រម ទាំងមានតូរ្យតន្ត្រីនិងចម្រៀងប្រគំជាកិត្តិយសផង ព្រះពុទ្ធជាបុរសឧត្តមទ្រង់គង់លើតាំងជាវិការៈនៃមាសទាំងអស់ ។ ដំបូលខាងលើជាវិការៈនៃមាសទាំងអស់ ក្នុងកាលនោះ ផ្ចិតទាំងឡាយ ក៏បក់ក្នុងចន្លោះនៃភិក្ខុសង្ឃ ។ ខ្ញុំបានញ៉ាំងភិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹកដ៏ច្រើន ខ្ញុំបានប្រគេនសំពត់មួយគូ ៗ ផ្សេង ៗ គ្នា ដល់ភិក្ខុសង្ឃ ។ ជនទាំងឡាយ ហៅព្រះពុទ្ធអង្គណាថាសុមេធៈ ព្រះពុទ្ធអង្គនោះ ទ្រង់ទទួលការបូជារបស់សត្វលោកទ្រង់គង់ក្នុងកណ្តាលភិក្ខុសង្ឃ បានពោលគាថាទាំងនេះថា

បុរសណា បានឲ្យតថាគតឆាន់ស្កប់ស្កល់ ដោយបាយនិងទឹកទាំងអស់នេះ តថាគតនឹងសរសើរនូវបុរសនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវពាក្យរបស់តថាគត ដែលនឹងសម្តែងចុះ ។ ក្នុងកប្បទី ១.៨០០ បុរសនេះ នឹងរីករាយក្នុងទេវលោក នឹងបានជាស្តេចចក្កពត្តិ មួយពាន់ជាតិ ។ នឹងកើតក្នុងកំណើតណា ទោះជាទេវតាឬជាមនុស្ស នឹងមានដំបូលជាវិការៈនៃមាសទាំងអស់បិទបាំងសព្វៗកាល ។ កន្លងពីនេះទៅ ៣ ម៉ឺនកប្បទៀត ព្រះសាស្តា

ទ្រង់ព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលនៃឱក្កាករាជ នឹងត្រាស់ឡើងក្នុងលោក ។ បុរសនេះ ជាអ្នកទទួលមតិកក្នុងធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ បានកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះ នឹងអង្គុយកណ្តាលភិក្ខុសង្ឃហើយបន្លឺនូវសីហនាទថា ជនទាំងឡាយតែងបាំងឆត្រលើជើងថ្កូវ អ្នកទាំងឡាយចូរដុតក្នុងខាងក្រោមនៃឆត្រចុះ ។

សាមញ្ញគុណ ខ្ញុំបានដល់ហើយ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ខ្ញុំមិនមានសេចក្តីក្តៅក្រហាយក្នុងមណ្ឌប ឬទៀបគល់ឈើឡើយ ។ ក្នុងកប្បទី ៣ ម៉ឺន ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសព្វទាន ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីកាត់ទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

### ចប់ សព្វទាយកត្ថេរាបទាន ។

# អជិតត្ថេរាបទានទី ១០

[ ១០០ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាលោកនាយក ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ស្តេចចូលទៅក្នុងព្រៃហិមពាន្ត ហើយគង់នៅ ។ ខ្ញុំមិនធ្លាប់ស្គាល់ព្រះសម្ពុទ្ធ ទាំងមិនធ្លាប់ឮសូរសព្ទគេប្រាប់អំពីព្រះអង្គ ខ្ញុំកំពុងដើរស្វែងរកកិច្ចក្នុងព្រៃដើម្បីខ្លួនខ្ញុំ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ក្នុងព្រៃនោះ លុះឃើញហើយ ក៏មានសេចក្តីត្រិះរិះថា សត្វនេះជាអ្វីហ្ន៎ ។ ខ្ញុំខំពិនិត្យមើលលក្ខណៈទាំងឡាយ ក៏បាននឹកឃើញនូវវិជ្ជារបស់ខ្ញុំថា សុភាសិតនេះ ខ្ញុំបានឮមកអំពីសម្នាក់នៃព្រះពុទ្ធ ជាអ្នកប្រាជ្ញ ។ បុរសនេះ ជាក់ជាព្រះពុទ្ធ សមដូចពាក្យនៃព្រះពុទ្ធទាំងនោះ បើដូច្នោះ អាត្មាអញគប្បីធ្វើសក្ការៈចំពោះព្រះអង្គ ព្រះអង្គនឹងញុំាងគតិរបស់អញឲ្យស្អាត ។ ខ្ញុំបានត្រឡប់មកកាន់អាស្រមដោយរួសរាន់ ហើយកាន់យកទឹកឃ្មុំ ប្រេង និងថ្លាង ដើរចូលទៅជិតព្រះលោកនាយក ។ ខ្ញុំបានកាន់យកឈើ ៣ កំណាត់ មកតម្កល់ទុកក្នុងទីវាល ហើយអុជប្រទីប ថ្វាយបង្គំអស់ ៨ លើក ។ ព្រះសម្ពុទ្ធជាបុរសដ៏ឧត្តម ជាលោកនាយក ទ្រង់គង់អស់ ៧ យប់ ៧ ថ្ងៃ លំដាប់តអំពីនោះមក ទ្រង់ក្រោកចាកអាសនៈ ក្នុងវេលាជាទីអស់នៃរាត្រី ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ អស់យប់និងថ្ងៃទាំងអស់ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយប្រទីបដល់ព្រះពុទ្ធ ដោយដៃរបស់ខ្លួន ។ គ្រឿងក្រអូបទាំងពួង ដែលកើតក្នុងព្រៃ មាននៅលើភ្នំគន្ធមាទន៍ ក៏មកក្នុងសម្នាក់នៃព្រះពុទ្ធដោយអានុភាពនៃព្រះពុទ្ធ ។ ឈើណាមួយ ដែលមានផ្ការីក ហើយមានផ្កាក្រអូប ឈើទាំងអស់នោះ ប្រជុំគ្នាហើយ ក្នុងកាលនោះ ដោយអានុភាពនៃ

ព្រះពុទ្ធ ។ នាគនិងគ្រុឌទាំងឡាយ ទាំងអំបាលម៉ាន ( ដែលនៅ ) ក្នុងព្រៃហិមពាន្ត សត្វទាំងពីរពួកនោះ មានប្រាថ្នាដើម្បីស្តាប់ធម៌ បាននាំគ្នាមកក្នុងសម្នាក់នៃព្រះពុទ្ធ ។ សមណៈឈ្មោះទេវលៈ ជាអគ្គសាវកនៃព្រះពុទ្ធ បានចូលមកកាន់សម្នាក់នៃព្រះពុទ្ធ ជាមួយនឹងភិក្ខុមួយសែនអង្គ ដែលជាអ្នកស្ងាត់ក្នុងឈាន ។ ព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវការបូជា ទ្រង់គង់នៅក្នុងកណ្តាលនៃពួកភិក្ខុ ហើយបានត្រាស់គាថាទាំងនេះថា

បុរសណាជ្រះថ្លា ហើយញុំាងប្រទីបឲ្យភ្លឺដោយដៃរបស់ខ្លួន ដើម្បីតថាគត តថាគតនឹងសរសើរនូវបុរសនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវពាក្យរបស់តថាគត ដែលនឹងសម្តែងចុះ ។ បុរសនេះ នឹងរីករាយក្នុងទេវលោកអស់ ៦ ម៉ឺនកប្ប នឹងបានសោយរាជ្យជាស្តេចចក្កពត្តិ អស់មួយពាន់ជង ។

## ចប់ ភាណវារៈ ទី ១៦ ។

បុរសនេះនឹងបានជាធំជាងទេវតា នឹងសោយរាជ្យក្នុងទេវលោកអស់ ៣៦ ជង នឹងសោយរាជ្យដ៏ធំទូលាយលើផែនដី អស់ ៧០០ ជង ។ នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប នឹងបានជាអ្នកមានចក្ខុជាទិព្វ ដោយផលនៃទីបទាននេះ ។ បុរសនេះ នឹងមើលឃើញ អស់ទីកន្លះក្រោសជុំវិញសព្វកាល កាលបើបុរសនេះ ច្យុតចាកទេវលោក ហើយមកកើត ( ក្នុងមនុស្សលោក ) នឹងមានគេទ្រទ្រង់ប្រទីបឲ្យទាំងយប់ទាំងថ្ងៃ ។

កាលបើបុរសអ្នកប្រកបដោយបុញ្ញកម្មនេះកើតឡើង ទីក្រុងត្រឹមណា នឹងភ្លឺរន្ទាលត្រឹមនោះ ។ បុរសនេះ ចាប់កំណើតណា ទោះជាទេវតា ឬជាមនុស្សជនទាំងឡាយនឹងបម្រើបុរសនេះ ដោយអំណាចនៃទីបទាននោះផង ដោយផលនៃប្រទីប ៨ ផង នេះជាផលនៃទីបទាន ។ កន្លងទៅមួយសែនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ នឹងត្រាស់ក្នុងលោក ។ បុរសនេះ ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតមនោះ ជាឱរសដែលធម៌និម្មិត នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះ នឹងបានជាសាវកនៃព្រះសាស្តា ឈ្មោះអជិត នឹងញុំាងព្រះសម្ពុទ្ធព្រះនាមគោតម ជាសក្យៈដ៏ប្រសើរឲ្យត្រេកអរ ។

ខ្ញុំត្រេកអរហើយក្នុងទេវលោក អស់ ៦ ម៉ឺនកប្ប ខ្ញុំមានប្រទីបចំនួនមួយរយ តែងភ្លឺរុងរឿងអស់កាលជានិច្ចក្នុងទីនោះ ។ រស្មីរបស់ខ្ញុំតែងផ្សាយទៅក្នុងទេវលោក ឬក្នុងមនុស្សលោក ខ្ញុំរឭកឃើញនូវព្រះពុទ្ធដ៏ប្រសើរហើយញុំាងសេចក្តីរីករាយក្រៃពេកឲ្យកើតឡើង ។ ខ្ញុំច្យុតចាកឋានតុសិត មកចាប់ផ្ទៃនៃមាតា កាលខ្ញុំកំពុងកើត ពន្លឺដ៏ធំទូលាយកើតប្រាកដឡើង ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស រួចចូលទៅរកពាវរីព្រាហ្មណ៍ ហើយដល់នូវភាពជាសិស្សនៃព្រាហ្មណ៍នោះ ។ កាលខ្ញុំនៅក្នុងព្រៃហិមពាន្ត បានឮនូវព្រះលោកនាយក កាលខ្ញុំស្វែងរកប្រយោជន៍ដ៏ឧត្តម បានចូលទៅគាល់ព្រះលោកនាយក ។ ព្រះសម្ពុទ្ធទ្រង់ជាអ្នកទូន្មាន បានទូន្មានខ្ញុំហើយ ទ្រង់ឆ្លងឱឃៈ មិនមានឧបធិក្កិលេស ព្រះសម្ពុទ្ធទ្រង់សម្តែងព្រះនិព្វាន ជាធម៌ញុំាងសត្វឲ្យរួចចាក

ទុក្ខទាំងពួង ។ ដំណើរមករបស់ខ្ញុំនោះសម្រេចហើយ ខ្ញុំបានញ៉ាំងព្រះមហាមុនីឲ្យត្រេកអរហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យប្រទីប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលទីបទាន ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអជិតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ អជិតត្ថេរាបទាន ។**

## ឧទ្ទាន

បិលិន្ទវច្ឆត្ថេរាបទាន ១ សេលត្ថេរាបទាន ១ សព្វកិត្តិកត្ថេរាបទាន ១ មធុទាយកត្ថេរាបទាន ១ បទុមកូដាគារិកត្ថេរាបទាន ១ ពក្កុលត្ថេរាបទាន ១ គិរិមានន្ទត្ថេរាបទាន ១ សលឡមណ្ឌបិយត្ថេរាបទាន ១ សព្វទាយកត្ថេរាបទាន ១ អជិតត្ថេរាបទាន ១ ឯគាថាលោករាប់ឃើញបាន ៥២៥ គាថា ។

## ចប់ បិលិន្ទវគ្គ ទី ៤០ ។

## មួយទៀត ឧទ្ទាននៃវគ្គ

បទុមកេសរិយវគ្គ ១ អារក្ខទាយកវគ្គ ១ ឧម្មាបុប្ផិយវគ្គ ១ គន្ធោទកវគ្គ ១ ឯកបទុមវគ្គ ១ សទ្ទសញ្ញិកវគ្គ ១ មន្ទារវបុប្ផិយវគ្គ ១ ពោធិវន្ទនវគ្គ ១ អម្ពដផលវគ្គ ១ បិលិន្ទវគ្គ ១ ចំណែកគាថា លោករាប់ឃើញបាន ១.១៧៤ គាថា ។

## ចប់ បទុមវគ្គទសកៈ ។

## ចប់ សតកៈ ទី ៤ ។

# អដ្ឋកថា

# សលឡមណ្ឌបិយត្ថេរាបទាន ជាដើម

[ ៩៨-១០០ ] *អបទានទី ៨ ទី ៩ និងទី ១០ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាសលឡមណ្ឌបិយត្ថេរាបទានជាដើម ចប់*

*បិលិន្ទវគ្គ ទី ៤០ ចប់*

# មេត្តេយ្យវគ្គ ទី ៤១

## តិស្សមេត្តេយ្យត្ថេរាបទាន ទី ១

[ ១០១ ] ខ្ញុំជាតាបសឈ្មោះសោភិតៈ អាស្រ័យនៅចុងញកភ្នំ បរិភោគតែផ្លែឈើដែលជ្រុះឯង នៅក្នុងចន្លោះភ្នំ ។ កាលនោះ ខ្ញុំកំពុងស្វែងរកប្រយោជន៍ដ៏ឧត្តម ដើម្បីនឹងឲ្យបានកើតក្នុងព្រហ្មលោក ខ្ញុំបាននាំយកឧសសម្រាប់ដុតភ្លើងមកដុតឲ្យឆេះ ។ ព្រះបទុមុត្តរៈជាលោកវិទូ ទ្រង់គួរទទួលនូវគ្រឿងបូជា ព្រះអង្គមានបំណងនឹងស្រោចស្រង់ខ្ញុំ ស្តេចពុទ្ធដំណើរមកក្នុងសម្នាក់ខ្ញុំ ( ទើបត្រាស់សួរថា )

ម្នាលអ្នកមានបុណ្យធំអ្នកធ្វើអ្វី អ្នកចូរឲ្យឧសសម្រាប់ដុតភ្លើងមកតថាគត តថាគតនឹងបម្រើភ្លើង សេចក្តីស្អាតនឹងមានដល់តថាគត ព្រោះការបម្រើភ្លើងនោះ ។ ម្នាលអ្នកជាមនុស្ស អ្នកជាមនុស្សល្អ ម្នាលទេវតា អ្នកចូរស្គាល់ចុះ អ្នកចូរបង្កាត់ភ្លើងចុះ ហ៏ ! នេះឧសសម្រាប់បង្កាត់ភ្លើងរបស់អ្នក ។ បន្ទាប់មកព្រះជិនស្រីទ្រង់កាន់យកឧស ហើយបង្កាត់ភ្លើងឲ្យឆេះឡើង ឯឧសក៏មិនឆេះក្នុងទីនោះ ព្រោះអាស្រ័យបាដិហារ្យរបស់ព្រះសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ទើបទ្រង់ត្រាស់ថា ភ្លើងរបស់អ្នកក៏មិនឆេះ គ្រឿងបូជារបស់អ្នកក៏មិនមានដែរ អំពើរបស់អ្នកនោះ ជារបស់ឥតប្រយោជន៍ អ្នកចូរបម្រើភ្លើងរបស់តថាគតវិញចុះ ។

បពិត្រព្រះអង្គជាមហាវីរបុរស សភាវៈអ្វីដែលព្រះអង្គហៅថាភ្លើងរបស់ព្រះអង្គ សូមព្រះអង្គសម្តែងប្រាប់នូវសភាវៈនុ៎ះដល់ខ្ញុំ យើងទាំងពីរនាក់នឹង

បម្រើភ្លើង ។

ការរលត់ធម៌ដែលជាហេតុ ១ ការដុតបំផ្លាញកិលេស ១ ការលះបង់ឥស្សរានិងមច្ឆរិយៈ ១ ទាំង ៣ នេះ ឈ្មោះថាភ្លើងជាគ្រឿងបូជារបស់តថាគត ។

បពិត្រព្រះអង្គជាមហាវីរបុរស ព្រះអង្គជាអ្វី បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាគោត្តអ្វី អាចារៈនិងសេចក្តីប្រតិបត្តិរបស់ព្រះអង្គ ខ្ញុំគាប់ចិត្តពេកណាស់ ។

តថាគតកើតក្នុងត្រកូលក្សត្រ ដល់នូវត្រៃយអភិញ្ញា អស់អាសវៈទាំងពួងហើយ ឥឡូវនេះ មិនមានភពថ្មីទេ ។

បពិត្រព្រះអង្គទ្រង់ធ្វើនូវពន្លឺ ទ្រង់កម្ចាត់បង់ងងឹត បើព្រះអង្គជាព្រះពុទ្ធមែន បពិត្រព្រះអង្គជាទេវតា ខ្ញុំនឹងនមស្ការព្រះអង្គ ព្រះអង្គធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ។

ទើបខ្ញុំក្រាលស្បែកខ្លាជាកម្រាល ហើយអារាធនាថា បពិត្រព្រះអង្គជាសព្វញ្ញូ សូមព្រះអង្គគង់លើកម្រាលនោះចុះ ខ្ញុំនឹងបម្រើព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់គង់លើស្បែកខ្លានោះ ដែលខ្ញុំក្រាលល្អហើយ ខ្ញុំនិមន្តព្រះសម្ពុទ្ធរួចហើយ ក៏ដើរចូលទៅក្នុងព្រៃភ្នំ ។ ខ្ញុំញុំាងការៈគឺអម្រែកឲ្យពេញ ហើយទៅនាំយកផ្លែទន្ទាប់ ថ្វាយផ្លែទន្ទាប់ចំពោះព្រះសម្ពុទ្ធ លាយដោយទឹកឃ្មុំ ។ គ្រានោះ កាលខ្ញុំសម្លឹងមើល ព្រះជិនសិរីក៏ទ្រង់សោយ ខ្ញុំកំពុងសម្លឹងមើលព្រះលោកនាយក ញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះលោកនាយកនោះ ។

ព្រះបទុមុត្តរៈ ជាលោកវិទូ ទ្រង់គួរទទួលនូវគ្រឿងបូជា ស្តេចគង់នៅនា

អាស្រមរបស់ខ្ញុំ ហើយត្រាស់គាថាទាំងនេះថា បុគ្គលណាជ្រះថ្លា ឲ្យតថាគត ឆាន់ផ្លែឈើ ដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែងដូចតទៅនេះ ។ បុគ្គលនោះនឹងបានសោយរាជ្យជាស្តេចទេវតាអស់ ២៥ ដង នឹងបានជាស្តេចចក្កពត្តិមួយពាន់ដង ។ បាយ ទឹក សំពត់ និងទីដេក ដ៏មានថ្លៃច្រើន ប្រកបហើយដោយបុញ្ញកម្ម ហាក់ដូចជាដឹងបំណងរបស់បុគ្គលអ្នកប្រកបដោយបុព្វកម្មនឹងកើតឡើងក្នុងខណៈនោះ ។ បុគ្គលនេះនឹងរីករាយ ជាអ្នកមិនមានរោគ សព្វៗកាល ។ បុគ្គលនេះបើទៅកាន់កំណើតណា ទោះជាទេវតាឬជាមនុស្ស នឹងជាអ្នកដល់នូវសេចក្តីសុខក្នុងទីទាំងពួង ។ បុគ្គលនោះ នឹងជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ដល់នូវត្រើយនៃត្រៃវេទ នឹងបានចូលទៅគាល់ព្រះសម្ពុទ្ធហើយ នឹងបានជាព្រះអរហន្ត ។

ខ្ញុំរឭកឃើញនូវខ្លួនក្នុងកាលណា ដល់នូវភាពជាអ្នកដឹងក្តី ក្នុងកាលណា កាលនោះ ខ្ញុំមិនមានសេចក្តីខ្វះខាត ដោយភោគៈឡើយ នេះជាផលនៃការថ្វាយផ្លែទន្លាប់ ។ ខ្ញុំបានដល់នូវធម៌ដ៏ប្រសើរ គាស់រំលើងនូវរាគៈ ទោសៈ មោហៈហើយ អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតទេ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទឹង ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ

ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិស្សមេត្តេយ្យត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ តិស្សមេត្តេយ្យត្ថេរាបទាន ទី ១ ។

# មេត្តេយ្យវគ្គ ទី ៤១

## អដ្ឋកថា តិស្សមេត្តេយ្យត្ថេរាបទាន

[ ១០១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ ក្នុងវគ្គទី ៤១ ដូចតទៅនេះថា

អបទានរបស់ព្រះតិស្សមេត្តេយ្យត្ថេរ មានពាក្យផ្តើមថា **បព្ភារកូដំ និស្សាយ** ដូច្នេះ ។

ក្នុងអបទាននោះ មានការប្លែកផ្សេងគ្នាត្រឹមតែប៉ុណ្ណោះថា លោកបួសជាតាបសហើយ បានថ្វាយស្បែកខ្លាជាទីប្រថាប់គង់ដល់ព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ ។ ពាក្យដ៏សេសងាយយល់បានងាយ តាមបាលីអបទាននោះឯង ។

អដ្ឋកថាតិស្សមេត្តេយ្យត្ថេរាបទាន ចប់

# បុណ្ណកត្ថេរាបទានទី ២

[ ១០២ ] ព្រះពុទ្ធជាសយម្ភូ ទ្រង់ឈ្មោះមារ គង់នៅក្នុងចន្លោះភ្នំ ដែលនៅអែបចុងញកព្រះអង្គមានអាពាធក្នុងទីនោះ ។ កាលព្រះពុទ្ធស្តេចបរិនិព្វានហើយ សំឡេងគឹកកង កើតមានជុំវិញអាស្រមរបស់ខ្ញុំ ក្នុងខណៈនោះ ពន្លឺក៏កើតឡើងក្នុងវេលានោះដែរ ។ ពួកសត្វសាហាវទាំងពួង គឺខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន និងកេសររាជសីហ៍ ក្នុងដងព្រៃទាំងអំបាលម៉ាន ក៏បន្លឺសំឡេងឡើងក្នុងខណៈនោះដែរ ។ ខ្ញុំបានឃើញសេចក្តីអស្ចារ្យនោះកើតហើយ ក៏ចូលទៅកាន់ញកភ្នំ បានឃើញព្រះសម្ពុទ្ធទ្រង់ឈ្មោះមារ ស្តេចបរិនិព្វានហើយ ត្រង់ញកភ្នំនោះ ។ ( លុះខ្ញុំឃើញ ) នូវព្រះសម្ពុទ្ធទ្រង់ឈ្មោះមារ ដែលបរិនិព្វានហើយ ទ្រង់ដូចជាសាលរាជព្រឹក្ស ដែលមានផ្ការីក ឬដូចជាព្រះអាទិត្យដែលទើបនឹងរះឡើង ពុំនោះសោត ដូចជារងើកភ្លើងដែលឥតមានអណ្តាត ។ ខ្ញុំបានធ្វើជើងថ្ករ បំពេញស្មៅនិងឧសក្នុងទីនោះ លុះខ្ញុំធ្វើជើងថ្ករដ៏វិចិត្ររួចហើយ ក៏បូជាសរីរសព ។ លុះខ្ញុំបូជាសរីរសពរួចហើយ ក៏ស្រោចស្រពនូវទឹកអប់លើព្រះធាតុ ខណៈនោះ ទេវតាដែលឋិតនៅឯដ៏អាកាស កាន់យកនូវឈ្មោះ ( ខ្ញុំ ) ថា អ្នកបំពេញកិច្ចនោះ ចំពោះព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ អ្នកនៅក្នុងសម្នាក់នៃព្រះមុនី ក្នុងកាលណា អ្នកនឹងបានឈ្មោះថាបុណ្ណកៈ ក្នុងកាលនោះ ។ លុះខ្ញុំច្យុតចាកកាយនោះហើយ ក៏បានទៅកើតក្នុងទេវលោក ក្លិនជាទិព្វបង្អុរចុះពីអាកាស ត្រង់កន្លែងដែលខ្ញុំនៅនោះ ។ កាលនោះ ឈ្មោះរបស់ខ្ញុំថាបុណ្ណកៈក្នុងទីនោះ ខ្ញុំកើតជាទេវតាឬជាមនុស្ស តែងបំពេញសេចក្តីបំណងបាន ។ នេះសរីរៈ ជាទីបំផុតរបស់ខ្ញុំ ភពជាទីបំផុត

កំពុងប្រព្រឹត្តទៅ សូម្បីក្នុងអត្តភាពនេះ គង់អ្នកផងប្រកាសនាម ( របស់ខ្ញុំ ) ជាបុណ្ណកៈ ។ ខ្ញុំបានញ៉ាំងព្រះសម្ពុទ្ធព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យត្រេកអរ ខ្ញុំកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាសិរីសេពនោះឯង ។ កិលេសទាំង-ឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីផ្ដាច់ខ្សែទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនានៃព្រះពុទ្ធខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុណ្ណកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ បុណ្ណកត្ថេរាបទាន ។

# អដ្ឋកថា

## បុណ្ណកត្ថេរាបទាន

[ ១០២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះថា អបទានរបស់ព្រះបុណ្ណកត្ថេរ មានពាក្យផ្តើមថា **បព្ភារកូដំ និស្សាយ** ដូច្នេះ ។

ក្នុងអបទាននោះ មានសេចក្តីប្លែកផ្សេងគ្នាត្រឹមតែប៉ុណ្ណេះថា លោកជាសេនាបតីយក្ខ នៅក្នុងព្រៃហិមពាន្ត បានសាងទីប្រជុំភ្លើង ( ជើងថ្ករ ) ដើម្បីព្រះបច្ចេកពុទ្ធដែលបរិព្វានហើយ ។ ពាក្យដ៏សេសដឹងបានងាយតាមគន្លងនៃបាលីនោះឯង ។

អដ្ឋកថាបុណ្ណកត្ថេរាបទាន ចប់

## មេត្តគុត្តេរាបទានទី ៣

[ ១០៣ ] មានភ្នំមួយឈ្មោះអសោកៈ នៅជិតព្រៃហិមពាន្ត ឯអាស្រមរបស់ខ្ញុំ វិស្សុកម្មទេវបុត្តនិម្មិតឲ្យហើយជិតភ្នំនោះ ។ ព្រះសម្ពុទ្ធព្រះនាមសុមេធ ជាកំពូលអ្នកប្រាជ្ញ ទ្រង់មានសេចក្ដីករុណា ទ្រង់ប្រដាប់ចីវរក្នុងបុព្វណ្ហសម័យ ហើយស្ដេចពុទ្ធដំណើរតម្រង់ទៅរកខ្ញុំដើម្បីបិណ្ឌបាត ។ ខ្ញុំ ( បានឃើញ ) នូវព្រះលោកនាយក ព្រះនាមសុមេធ ព្រះអង្គជាមហាវីរបុរស ស្ដេចចូលមកដល់ ទើបទទួលយកបាត្រព្រះសុគត ហើយបំពេញសប្បិនិងប្រេង ។ លុះខ្ញុំថ្វាយចំពោះព្រះលោកនាយកទ្រង់ព្រះនាមសុមេធៈ ជាព្រះពុទ្ធដ៏ប្រសើរហើយ ក៏ផ្គងអញ្ជលី ញុំាងសេចក្ដីរីករាយដ៏ខ្លាំងឲ្យកើតឡើង ។ ខ្ញុំកើតជាទេវតា ឬកើតជាមនុស្ស តែងបាននូវសេចក្ដីសុខដ៏ធំ ដោយការថ្វាយសប្បិនេះផង ដោយការតាំងចេតនានេះផង ។ ខ្ញុំវៀរកំណើតវិនិបាត តែងអន្ទោលទៅក្នុងភពតូចនិងភពធំ ក៏បានតាំងចិត្តប្រណិធានក្នុងភពនោះៗហើយ ឥឡូវនេះ ខ្ញុំបានដល់នូវអចលបទគឺព្រះនិព្វាន ។

ម្នាលព្រាហ្មណ៍ អ្នកឈ្មោះថាមានលាភហើយ អត្តភាពជាមនុស្ស ឈ្មោះថាអ្នកបានល្អហើយ ព្រោះអ្នកបានឃើញតថាគត ឯបុគ្គលនឹងដល់នូវអរហត្តផល ក៏ព្រោះអាស្រ័យការឃើញតថាគត ។ អ្នកត្រូវស្និទ្ធស្នាលចុះ កុំខ្លាចឡើយ អ្នកនឹងបានយសធំ នឹងរួចចាកជាតិ ព្រោះបានឲ្យសប្បិដល់តថាគត ។

ខ្ញុំកើតជាទេវតា ឬកើតជាមនុស្ស រមែងបាននូវសុខដ៏ធំ ដោយការថ្វាយសប្បិនេះផង ដោយការតាំងចេតនានេះផង ។

បុគ្គលនេះ នឹងរីករាយក្នុងទេវលោក ក្នុងកប្បទី ១៨ ដោយអធិការនេះ

ផង ដោយការប្រព្រឹត្តមេត្តាចិត្តនេះផង ។ នឹងបានជាស្តេចទេវតាអស់ ៥៤ ជង នឹងបានសោយប្រទេសរាជ្យធំទូលាយរាប់បានមួយអសង្ខេយ្យកប្ប ។ នឹងបានជាស្តេចចក្កពត្តិ មានសមុទ្ទទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ឈ្នះសង្គ្រាម ជាឥស្សរៈលើមណ្ឌលជម្ពូទ្វីបអស់ ៥១ ជង ។

មហាសមុទ្ទមិនរំកើប ផែនដីធ្ងន់គេទ្រទ្រង់បានដោយក្រ យ៉ាងណា ភោគៈទាំងឡាយរបស់ខ្ញុំ ប្រមាណមិនបាន ក៏យ៉ាងនោះដែរ ខ្ញុំឲ្យប្រាក់អស់ ៦០ កោដិ ហើយទើបចេញទៅបួស ខ្ញុំកំពុងស្វែងរកកុសល ក៏បានចូលទៅរកពាវរីព្រាហ្មណ៍ ។ ខ្ញុំបានរៀនលក្ខណមន្ត ប្រកបដោយអង្គ ៦ ក្នុងសម្នាក់ពាវរីព្រាហ្មណ៍នោះ បពិត្រព្រះមហាមុនី ព្រះអង្គកម្ចាត់បង់នូវងងឹតអន្ធការហើយ កើតឡើងហើយ ។ បពិត្រព្រះមហាមុនី ខ្ញុំមានបំណងចង់ចួបនឹងព្រះអង្គ ទើបមក ខ្ញុំបានស្តាប់ធម៌របស់ព្រះអង្គហើយ ក៏នឹងបានដល់នូវអចលបទ គឺព្រះនិព្វាន ។

ក្នុងកប្បទី ៣០ ពាន់ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសប្បិដល់ព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់សប្បិដែលខ្ញុំត្រូវសូមគេទេ ។ សប្បិដូចដឹងបំណងរបស់ខ្ញុំ ហើយកើតឡើងតាមសេចក្តីប្រាថ្នា សប្បិកើតឡើងហើយ ព្រោះដឹងចិត្តខ្ញុំ ខ្ញុំញ៉ាំងជនទាំងពួងឲ្យឆ្អែតស្កប់ស្កល់ ។ ឱ ! ព្រះពុទ្ធ ឱ ! ព្រះធម៌ ឱ! សម្បទានៃព្រះសាស្តារបស់ខ្ញុំ ខ្ញុំគ្រាន់តែថ្វាយសប្បិបន្តិចបន្តួចសោះត្រឡប់ជាបានសប្បិរាប់មិនអស់ ។ ទឹកក្នុងមហាសមុទ្ទដែលទល់នឹងភ្នំសុមេរុ ប្រៀបផ្ទឹមនិងសប្បិរបស់ខ្ញុំ គង់មិនដល់មួយភាគនៃចំណិត ។ ឱកាសនៃចក្កវាឡ

ទាំងប៉ុន្មាន ឱកាសនោះ គង់មិនល្មមនឹងសំពត់ទាំងឡាយ ដែលកើតឡើង សម្រាប់ខ្ញុំ ដែលឲ្យគេធ្វើជាគំនរឡើយ ។ ស្តេចភ្នំឈ្មោះហិមវន្ត ជាភ្នំដ៏ប្រសើរ គង់មិនដល់នូវការប្រៀបធៀបនឹងក្លិន ដែលជាប់នឹងកាយរបស់ខ្ញុំដែរ ។ ខ្ញុំ បានសំពត់គ្រឿងក្រអូប សប្បិនិងវត្ថុដទៃ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ទាំង បានព្រះនិព្វានដែលជាអសង្ខត: នេះជាផលនៃការថ្វាយសប្បិ ។ ក្នុងថ្ងៃនេះ ខ្ញុំមានសតិប្បដ្ឋានជាទីដេក មានសមាធិជ្ឈានជាគោចរ ញុំាងពោជ្ឈង្គឲ្យកើត នេះជាផលនៃការថ្វាយសប្បិ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភព ទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ខ្សែ ទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមេត្តគុត្តេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយ ប្រការដូច្នេះ ។

## ចប់ មេត្តគុត្តេរាបទាន ។

# អដ្ឋកថា

# មេត្តគុត្តោរាបទាន

*[ ១០៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះថា អបទានរបស់ព្រះមេត្តគុត្តេរ មានពាក្យផ្តើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។ សេចក្តីដែលផ្សេងគ្នា គឺលោកជាតាបសនៅក្នុងបណ្ណសាលា ត្រង់ភ្នំឈ្មោះអសោក ក្បែរព្រៃហិមពាន្តនោះ បានឃើញព្រះសម្មាសម្ពុទ្ធ ព្រះនាមថាសុមេធ ហើយទទួលបាត្រ យកសប្បិដាក់ទាល់តែពេញ ។ ពាក្យដ៏សេសនិងផលបុណ្យ ដឹងបានងាយហើយ ។ អត្ថនៃគាថាអបទាន ក៏ប្រាកដច្បាស់ហើយដូចគ្នា ។*

*អដ្ឋកថាមេត្តគុត្តោរាបទាន ចប់*

# ធោតកត្ថេរាបទាន ទី ៤

[ ១០៤ ] ទឹកស្ទឹងឈ្មោះភាគីរសី ហូរចេញមកអំពីព្រៃហិមពាន្ត ហើយហូរទៅតាមទ្វារក្រុងហង្សវតី ក្នុងខណៈនោះ ។ អារាមឈ្មោះសោភិត ដែលគេសាងល្អហើយនៅក្បែរឆ្នេរស្ទឹងគង្គា ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ជាលោកនាយក ស្តេចប្រថាប់នៅក្នុងអារាមនោះ ។ ព្រះមានព្រះភាគ មានពួកមនុស្សចោមរោមហើយ ដូចជាព្រះឥន្ទមានពួកទេវតាចោមរោម ស្តេចគង់នៅក្នុងអារាមនោះ ដូចកេសររាជសីហ៍ ដែលឥតមានសេចក្តីតក់ស្លុត ។ ខ្ញុំកើតជាព្រាហ្មណ៍មាននាមថាធទ្បូគ្គៈ នៅក្នុងនគរហង្សវតី បពិត្រព្រះមហាមុនី ឈ្មោះខ្ញុំយ៉ាងនេះ ។ កាលនោះ ពួកសិស្សចំនួន ១៨ រយនាក់ តែងចោមរោមខ្ញុំ ខ្ញុំព្រមព្រៀងដោយពួកសិស្សទាំងនោះ ក៏ចូលទៅកាន់ឆ្នេរស្ទឹងគង្គា ។ ខ្ញុំកំពុងឆ្លងស្ទឹងភាគីរសី បានឃើញពួកសមណៈ ជាបុគ្គលមិនកុហក ជាអ្នកបន្សាត់បង់នូវបាបត្រង់ឆ្នេរស្ទឹងគង្គានោះ ហើយខ្ញុំគិតយ៉ាងនេះក្នុងខណៈនោះថា ពួកសមណៈជាពុទ្ធបុត្ត មានយសធំទាំងនេះ ឆ្លងស្ទឹងទៅទាំងល្ងាចទាំងព្រឹក នាំឲ្យខ្លួនលំបាកខ្លួនសមណៈទាំងនោះ ក៏នឿយហត់ ។ ព្រះពុទ្ធអ្នកផងតែងពោលថា ជាកំពូលរបស់សត្វលោក ព្រមទាំងទេវលោក ឯអាត្មាអញមិនទាន់មានគ្រឿងសក្ការៈ គឺការជម្រះផ្លូវសម្រាប់ដើរទៅ ចំពោះទក្ខិណេយ្យបុគ្គលនៅឡើយ ។ បើដូច្នោះ គួរតែអាត្មាអញ ញុំាំងជនឲ្យធ្វើស្ពានត្រង់ស្ទឹងគង្គា ថ្វាយព្រះពុទ្ធដ៏ប្រសើរ លុះអាត្មាអញឲ្យគេធ្វើស្ពាននេះរួចហើយ ឈ្មោះថា អាត្មាអញបានឆ្លងនូវភពនេះ ។ ខ្ញុំបានចំណាយទ្រព្យរាប់រយរាប់ពាន់ ឲ្យគេធ្វើស្ពាន ខ្ញុំជឿថាសក្ការៈដែលខ្ញុំធ្វើហើយ ( នេះ ) នឹងមានផលធំទូលាយ ។ លុះខ្ញុំឲ្យគេធ្វើ

ស្ពាននោះរួចហើយ ក៏ចូលទៅគាល់ព្រះលោកនាយក ធ្វើអញ្ជលីលើត្បូងហើយ ក្រាបបង្គំទូលពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គចំណាយទ្រព្យរាប់រយរាប់ពាន់ ឲ្យគេធ្វើស្ពាននេះ ដើម្បីប្រយោជន៍ដល់ព្រះអង្គ សូមព្រះអង្គទទួលយកនូវស្ពានដ៏ធំនេះចុះ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់លោក គួរទទួលគ្រឿងបូជា ស្តេចគង់នៅកណ្តាលភិក្ខុសង្ឃ ហើយត្រាស់គាថាទាំងនេះថា បុគ្គលណាជ្រះថ្លា បានឲ្យគេធ្វើស្ពានដោយដៃខ្លួនឯង ដើម្បីតថាគត។ នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែងដូចតទៅនេះ

បុគ្គលនេះ បើទុកជាធ្លាក់ទៅក្នុងជ្រោះ ឬធ្លាក់ពីភ្នំឬដើមឈើក្តី ច្យុតហើយក្តី រមែងបាននូវទីឈរ នេះជាផលនៃការឲ្យស្ពាន ។ សត្រូវទាំងឡាយមិនគ្របសង្កត់ ( នូវបុគ្គលនេះបាន ) ដូចជាខ្យល់ មិនអាចគ្របសង្កត់ដើមជ្រៃដែលមានឫសដុះមាំ នេះជាផលនៃការឲ្យស្ពាន ។ ចោរទាំងឡាយមិនអាចនឹងគ្របសង្កត់បុគ្គលនេះបានទេ ពួកក្សត្រ ក៏មិនមើលងាយបានដែរ ( បុគ្គលនេះ ) នឹងឆ្លងផុតសត្រូវទាំងពួង នេះជាផលនៃការឲ្យស្ពាន ។ បុគ្គលប្រកបដោយបុញ្ញកម្មនេះ បើទុកជានៅក្នុងទីវាល ដែលហាលដោយកម្តៅថ្ងៃដ៏ក្លាខ្លាំង ក៏នឹងមិនមានវេទនាឡើយ ។ យានដ៏រីដែលជាបុញ្ញកម្មនិម្មិតល្អ ហើយក្នុងទេវលោក ឬក្នុងមនុស្សលោកនឹងកើតឡើង ក្នុងខណៈនោះ ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់បុគ្គលនោះ ។ សេះសិន្ធពមួយពាន់ មានសន្ទុះលឿនដូចខ្យល់ជាពាហនៈដ៏រហ័ស នឹងចូលទៅបម្រើ ( បុគ្គលនោះ ) ទាំងល្ងាចទាំង

ព្រឹក នេះជាផលនៃការឲ្យស្ពាន ។ បុគ្គលនេះ លុះមកកាន់អត្តភាពជាមនុស្ស នឹងបានសេចក្តីសុខ មួយទៀត យានដ៏រីនឹងកើតដល់បុគ្គលនេះ ដែលកើតជាមនុស្សក្នុងលោកនេះ ។ កន្លងទៅមួយសែនកប្បទៀត នឹងមានព្រះបរមសាស្តា ព្រះនាមគោតម កើតក្នុងត្រកូលព្រះបាទឱក្កាករាជ ត្រាស់ឡើងក្នុងលោក ។ បុគ្គលនេះ នឹងបានទទួលមត៌កក្នុងធម៌របស់ព្រះពុទ្ធអង្គនោះ ជាឱរសដែលធម៌និម្មិតហើយនឹងកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈនឹងបរិនិព្វាន ។

ឱហ្ន៎! អំពើដែលខ្ញុំធ្វើល្អហើយ ចំពោះព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ខ្ញុំធ្វើគ្រឿងសក្ការៈចំពោះព្រះពុទ្ធអង្គនោះហើយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ខ្ញុំមានចិត្តបញ្ជូនទៅកាន់សេចក្តីព្យាយាម ជាអ្នកស្ងប់រម្ងាប់ មិនមានឧបក្កិលេស មិនមានអាសវៈ ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញចោលហើយ ភពទាំងពួងខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជាទាំង ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជោតកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ជោតកត្ថេរាបទាន ។**

# អដ្ឋកថា

# ជោតកត្ថេរាបទាន

[ ១០៤ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះថា អបទានរបស់ព្រះជោតកត្ថេរ មានពាក្យផ្ដើមថា* **គង្គា ភាគីរថី នាម** *ដូច្នេះ ។*

*ក្នុងអបទាននោះ មានការប្លែកផ្សេងគ្នាត្រឹមប៉ុណ្ណោះថា លោកជាព្រាហ្មណ៍ បានឃើញពួកភិក្ខុកំពុងឆ្លងស្ទឹង ឈ្មោះថាភាគីរថី ហើយមានចិត្តជ្រះថ្លា ឲ្យធ្វើស្ពានហើយ វេរថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ អត្ថនៃគាថាដែលសម្ដែងដល់ផលបុណ្យ ដឹងបានងាយហើយ តាមទំនងនៃអត្ថនោះឯង ។*

*អដ្ឋកថាជោតកត្ថេរាបទាន ចប់*

# ឧបសីវត្ថេរាបទានទី ៥

[ ១០៥ ] មានភ្នំមួយឈ្មោះអនោមៈ នៅជិតព្រៃហិមពាន្ត អាស្រម របស់ខ្ញុំធ្វើល្អហើយ បណ្ណសាលា ខ្ញុំក៏បានកសាងល្អហើយដែរ ។ មានស្ទឹង មួយ មានកំពង់រាបល្អ គួរជាទីរីករាយនៃចិត្ត តែងហូរចុះទៅក្នុងទីនោះ មាន ឈូកនិងឧប្បលជាច្រើន ដុះនៅតាមកំពង់ជាលំដាប់ ។ ឯត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ ត្រីឆ្ពិន ( មានក្នុងកំពង់នោះ ) ទឹកស្ទឹងដ៏ដេរដាស ដោយត្រីនិងអណ្តើក រមែងហូរទៅ ក្នុងកាលនោះ ។ ក្នុងទីនោះ មានតិមិរ-ព្រឹក្ស មានផ្ការីក ដើមអសោកមានផ្កាតូចៗ ទាំងក្រូចឆ្មារនិងក្រូចភ្លា ទោរ ទៅកាន់អាស្រមរបស់ខ្ញុំ ។ ក្នុងទីនោះ មានដើមខ្វែងគង់ និងព្រៃម្ទិះរូត មាន ផ្ការីក ដើមរាំង ដើមស្រល់ និងដើមចម្ប៉ាជាច្រើន មានផ្ការីកក្នុងទីនោះដែរ ។ ដើមអង្គ្រង ដើមរំដួល ដើមចំបក់ ដើមធ្នង់ និងដើមចេកទុំ មានផ្ការីក ពួក ឈើទាំងនោះ សុទ្ធតែមានផ្ការីកហើយ នៅជិតអាស្រមរបស់ខ្ញុំ ។ ដើមរាជព្រឹក្ស ដើមប្រទៀង ដើមយុក្កា និងដើមប្រយង្គ សឹងដ៏ដេរដាសដោយវល្លិបាស អស់ កន្ទុះយោជន៍ជុំវិញ ។ ដើមមាតករព្រឹក្ស ម្ទិះរូត ប្រទៀង ឈើភ្លើង អង្កោល និងតាលកុជព្រឹក្ស ជាច្រើនក្នុងទីនោះ សុទ្ធតែជាឈើមានផ្ការីក ។ ស្មៅ ក្រវាញជ្រូកជាច្រើន សុទ្ធតែជាស្មៅមានផ្ការីកក្បែរអាស្រមរបស់ខ្ញុំនោះ បណ្តា ឈើមានផ្កាទាំងនុ៎ះ ពួកឈើច្រើន សុទ្ធតែល្អៗ ។ ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង និងសម៉ពិភេទក៍ ផ្សាយក្លិននោះ ជុំវិញអាស្រមខ្ញុំ ។ ដើមពុទ្រា ដើម រាក់ខ្មៅ ដើមញ្ញៅ មាក់ប្រាង ទន្លាប់ ទ្រយឹង ស្រគំ ពង្រ ។ ដើមខ្នុរសម្ល ខ្នុរណាំង ចេក ដើមច័ន ក៏មានក្នុងទីនោះ ដើមម្កាក់ និងដើមគុយ ក៏មាន

ច្រើនក្នុងទីនោះដែរ ។ ដើមគូលែន អាលកព្រឹក្ស និងសណ្តែកព្រៃ សុទ្ធតែជាឈើមានផ្លែ នៅជិតអាស្រមរបស់ខ្ញុំ តពីនោះទៅ មានផ្លែសាវម៉ាវជាច្រើន ។ អវជព្រឹក្ស ពេញដោយផ្លែទុំ ដើមមិលក្ខព្រឹក្ស ដើមឧទុម្ពរ ដីប៉ី ម្រេច ជ្រៃ និងដើម ក្រសាំង មានក្នុងទីនោះ ។ ដើមឧទុម្ពរជាច្រើន ខ្លះផ្លែទុំ ខ្លះផ្លែខ្ចី ដើមឈើក្រៅពីនេះជាច្រើន សុទ្ធតែជាឈើមានផ្លែ ជិតអាស្រមរបស់ខ្ញុំ ។ សូម្បីឈើ មានផ្កាជាច្រើន គឺដើមកន្ទ្រំ ដើមក្ទម្ព និងដើមពុកធ្លា មានផ្ការីក នៅជិតអាស្រមរបស់ខ្ញុំ ។ អាលកព្រឹក្សនិងតាលកព្រឹក្ស មាននៅជិតអាស្រម របស់ខ្ញុំ មានជាតស្រះធំមួយ នៅជិតអាស្រមរបស់ខ្ញុំ ។ ស្រះនោះ មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់ល្អ គួរជាទីរីករាយនៃចិត្ត មានទាំងឈូកក្រហម និងឧប្បលជាច្រើន លាយចម្រុះដោយឈូកសនៅក្នុងស្រះនោះ ទាំងដេរដាស ដោយព្រលិត សាយកាយដោយក្លិនផ្សេងៗ ដើមឈូកកំពុងចាប់ផ្លែ ( ក្រពុំ ) ពួកដើមកេសរឯទៀតៗកំពុងរីកផ្កា ឈូកនិងផ្កាកណិការជាច្រើនមានត្របក- ផ្កាសំយុងចុះក្រោម មានទឹកហូរចេញអំពីក្រអៅឈូក ផ្អែមដូចទឹកឃ្មុំ មានទឹក ហូរចេញអំពីមើមឈូក ធ្លាញ់ដូចទឹកដោះស្រស់និងទឹកដោះថ្លា ផ្កាកុមុទ ស្វាយ- ក្រអូប ផ្ការយិតាព្រឹក្សជាច្រើន ប្រកបដោយក្លិនផ្សេងៗ រមែងប្រាកដដោយក្លិន នោះជុំវិញ ។ ឆ្នេរជាតស្រះ មានដើមកាកេតជាច្រើនមានផ្ការីក ដើមកុឡាប មានផ្កាល្អ ឈូកសមានក្លិនក្រអូប ។ ក្រពើ ក្រពា ជាសត្វចាប់គេស៊ី ក៏ កើតនៅក្នុងស្រះនោះ ពស់ថ្លាន់ ជាសត្វរបរិត ក៏មានច្រើនក្នុងស្រះនោះដែរ ។ មានត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ និងត្រីឆ្ពិន ដ៏ដេរដាសដោយ

ត្រីនិងអណ្តើក ដោយកន្លែងដែលធ្លាប់អាស្រ័យនៅ ។ ព្រាប ប្រវឹក ខ្វែក ក្អែកទឹក ត្រដេវវិច ចាក្រពាក ចង្កៀលខ្យង ព្រហិត ។ មានពួកសត្វកង្កែន លលក ខ្វែង ជាសត្វហើរដ៏ច្រើន ក្ងោចចក កូនសេក ក្តាន់ ទ្រាយ ជាច្រើន ។ ពួកម្រឹគ គឺកាសេនិយម្រឹគនិងតិលកម្រឹគ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី ចូលទៅអាស្រ័យនឹងស្រះនោះ ។ ពួកស្វា ពួកកិន្នរ ក៏ប្រាកដជិតអាស្រម ខ្ញុំ ខ្ញុំស្រង់ក្លិនទាំងនោះ ហើយបរិភោគផ្លែឈើទាំងឡាយ ។ ខ្ញុំផឹកទឹកក្រអូបនៅក្នុងអាស្រមរបស់ខ្ញុំ មានម្រឹគទ្រាយ ជ្រូក ប្រើស និងពួកសត្វមានរូបតូចៗ ។ ភ្លើងមានពន្លឺដ៏រុងរឿងនៅជិតអាស្រមរបស់ខ្ញុំ ពួកសត្វហង្ស ក្រៀល ក្ងោក និងតាវៅ ជាសត្វមានប្រយោជន៍ តែងអាស្រ័យនៅក្បែរអាស្រមរបស់ខ្ញុំដែរ ។ ក្នុងទីនោះ មានឆ្មា ខ្លែងស្រាក កេងកង ជាច្រើន និងបិសាច អសុរ កុម្ភណ្ឌ និងអារក្សជាច្រើន ។ ពួកគ្រុឌ នាគ និងពួកឥសី មានអានុភាពច្រើន មានចិត្តស្ងប់ តម្កល់មាំ នៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងអស់ ទ្រទ្រង់នូវកន្ទីទឹក ស្លៀកសំពត់ស្បែកខ្លា ពេញដោយការៈគឺផ្នួងសក់ នៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងនោះ ក្រឡេកមើលប្រមាណមួយជួរនឹម ជាបុគ្គលមានប្រាជ្ញា មានកិរិយាប្រព្រឹត្តស្ងប់ជាប្រក្រតី ជាអ្នកត្រេកអរតាមមានតាមបាននៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងនោះ រលាស់សំពត់សំបកឈើដំនូវស្បែកខ្លា ជាអ្នករឹងប៉ឹងដោយកម្លាំងរបស់ខ្លួន ទៅឰដ៏អាកាសក្នុងកាលនោះ ។ ពួកឥសីទាំងនោះ នាំមកនូវទឹកថ្មីៗ ឈើនិងឧស ចូលទៅប្រកបដោយខ្លួនឯង នេះជាផលនៃសប្បាដិហារិយៈ ។ ពួកឥសីទាំងនោះកាន់យក

ស្នូកលោហជាតិ នៅក្នុងកណ្តាលព្រៃ ដូចជាដំរីដ៏ប្រសើរ ឬដូចកេសររាជ-សីហ៍ មិនមានសេចក្តីតក់ស្លុតឡើយ ។ ពួកឥសីខ្លះ ទៅកាន់គោយានទ្វីប ខ្លះទៅកាន់បុព្វវិទេហទ្វីប ខ្លះទៅកាន់ឧត្តរកុរុទ្វីប ដោយមិនអើពើនឹងសំពត់-កម្ពលរបស់ខ្លួន ។ ពួកឥសីទាំងនោះ នាំយកបិណ្ឌបាតអំពីទ្វីបនោះៗ មកឆាន់ជាមួយគ្នា កាលបើពួកឥសីទាំងអស់ មានតេជះដ៏ខ្ពង់ខ្ពស់ ប្រកបដោយតាទិគុណ ចៀសចេញទៅហើយ ព្រៃក៏លាន់ឮកងរំពងឡើងដោយសំឡេងនៃស្បែកខ្លាក្នុងកាលនោះ ។ បពិត្រព្រះអង្គមានព្យាយាមធំ ពួកសិស្សរបស់ខ្ញុំទាំងនោះ ប្រាកដបែបនេះ សុទ្ធតែជាអ្នកមានតបៈដ៏ខ្ពង់ខ្ពស់ ខ្ញុំមានពួកសិស្សទាំងនោះចោមរោមហើយ នៅក្នុងអាស្រមរបស់ខ្ញុំ ។ ពួកសិស្សទាំងនុ៎ះ ដែលមកប្រជុំគ្នា ជាអ្នកត្រេកអរដោយកុសលកម្មរបស់ខ្លួន មានខ្លួនទូន្មានហើយ ជាអ្នកមានសេចក្តីប្រាថ្នា ចំពោះកុសលកម្មរបស់ខ្លួន មានសីល មានប្រាជ្ញា-ចាស់ ជាអ្នកឈ្លាសវៃក្នុងអប្បមញ្ញាទាំងឡាយ ធ្វើឲ្យខ្ញុំរីករាយ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់ត្រៃលោក គួរទទួលនូវគ្រឿងបូជា ជាអ្នកដឹកនាំសត្វលោក មានព្យាយាម មានប្រាជ្ញាចាស់ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវសម័យ ស្តេចយាងចូលមកជិត ព្រះសម្ពុទ្ធទ្រង់កាន់បាត្រ ស្តេចចូលមកដើម្បីភិក្ខា ។ ( ខ្ញុំបានឃើញ ) នូវព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ មានព្យាយាមធំ ទ្រង់ស្តេចចូលមកហើយ ក៏ក្រាលកម្រាលស្មៅ ហើយរោយ-រាយដោយផ្កាឈើ ។ ខ្ញុំមានចិត្តតក់ស្លុត មិនអាចតាំងនៅបាន ក៏និមន្តព្រះសម្ពុទ្ធឲ្យគង់ ហើយឡើងភ្នំយ៉ាងឆាប់ កាន់យកនូវខ្លឹមក្រស្នា ។ ខ្ញុំបានបេះ

យកផ្លែខ្នុរប៉ុនថ្នាំង មានក្លិនក្រអូប ជាទីរីករាយនៃទេវតា ហើយលើកលី នាំចូលទៅថ្វាយព្រះលោកនាយក ។ លុះខ្ញុំថ្វាយផ្លែខ្នុរ ចំពោះព្រះពុទ្ធរួចហើយ លាបនូវខ្ទឹមក្រស្នា ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់ត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់គង់ក្នុងកណ្ដាលពួកឥសី ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានឲ្យផ្លែខ្នុរ ខ្ទឹមក្រស្នា និងអាសនៈដល់តថាគតៗ នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្ដាប់ តថាគតនឹងសម្ដែង ដូចតទៅនេះ បុគ្គលនេះកាលនៅក្នុងស្រុកក្ដី ក្នុងព្រៃក្ដី ក្នុងញកភ្នំក្ដី ក្នុងគុហាក្ដី ភោជននឹងកើតឡើង ព្រោះដឹងចិត្តរបស់បុគ្គលនេះ នរៈនេះ បើទៅកើតក្នុងទេវលោក ឬមនុស្សលោក នឹងឆ្អែតស្កប់ស្កល់ដោយភោជនផង ដោយសំពត់ផង នរៈនេះ បើអន្ទោលទៅកាន់កំណើតណា ទោះជាទេវតាឬជាមនុស្ស នឹងជាអ្នកមានភោគៈមិនរំកើបញាប់ញ័រ ។ នឹងត្រេកអរក្នុងទេវលោកអស់ ៣ ម៉ឺនកប្ប នឹងបានជាស្ដេចចក្កពត្តិមួយពាន់ដង ។ នឹងបានសោយរាជ្យជាស្ដេចទេវតា ៧១ ដង នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្ដាព្រះនាមគោតម កើតក្នុងត្រកូលព្រះបាទឱក្កាករាជ ត្រាស់ដឹងក្នុងលោក នរៈនេះ នឹងបានទទួលមត៌កក្នុងធម៌របស់ព្រះពុទ្ធនោះ ជាឱរសដែលធម៌និម្មិតហើយ មាននាមឧបសីវៈ នឹងបានជាសាវ័កនៃព្រះសាស្ដា ។ នរៈនេះ នឹងមិនមានអាសវៈ ព្រោះកំណត់ដឹងអាសវៈទាំង

ពួង ។

លោកដែលត្រូវបានដោយល្អ ខ្ញុំបានហើយ ព្រោះខ្ញុំបានជួបនឹងព្រះលោកនាយក ។ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចហើយ ។ ខ្ញុំ ( កាលទៅ ) ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក្នុងញកភ្នំក្តីក្នុងគុហាក្តី ភោជនរមែងកើតឡើងដល់ខ្ញុំ ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបសីវត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ ឧបសីវត្ថេរាបទាន ។

# អដ្ឋកថា
# ឧបសីវត្ថេរាបទាន

[ ១០៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះថា អបទានរបស់ព្រះឧបសីវត្ថេរ មានពាក្យផ្ដើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។ ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ លះនូវឃរាវាសបួសជាឥសី នៅក្នុងព្រៃហិមពាន្ត ឃើញព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ បានលាតនូវគ្រឿងកម្រាលដែលធ្វើដោយស្មៅថ្វាយ ហើយធ្វើការបូជាដោយផ្កាសាលព្រឹក្សដល់ព្រះមានព្រះភាគ ដែលគង់លើកម្រាលនោះ នេះជាសេចក្ដីផ្សេងគ្នា ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

## អដ្ឋកថាឧបសីវត្ថេរាបទាន ចប់

# ឆត្តការត្ថាបទានទី ៦

[ ១០៦ ] ក្នុងកពមុន ខ្ញុំកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ កំពុងស្វែងរកម្រឹគប្រើស ស្រាប់តែបានជួបព្រះសយម្ភូ ។ គ្រានោះ ព្រះសយម្ភូសម្ពុទ្ធ ព្រះនាមអនុរុទ្ធ ទ្រង់ឈ្នះមារ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ប្រាថ្នានូវទីដ៏ស្ងប់-ស្ងាត់ ស្តេចយាងចូលទៅក្នុងព្រៃ ។ ខ្ញុំយកឈើ ៤ កំណាត់ មកបញ្ឈរទុកក្នុងទីជា ៤ ធ្វើបារាំដ៏វិចិត្រយ៉ាងល្អ ប្រក់ដោយផ្កាឈូកទាំងឡាយ ។ ខ្ញុំប្រក់បារាំរួចហើយ ក៏ថ្វាយបង្គំព្រះសយម្ភូ គេវៀងធ្នូចោលក្នុងទីនោះ ហើយចូលទៅកាន់ផ្នួស ។ កាលខ្ញុំទើបតែនឹងបួស ខ្ញុំក៏មានព្យាធិកើតឡើង ខ្ញុំនឹកឃើញនូវបុព្វកម្ម ហើយធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំប្រកបដោយបុព្វកម្ម បានទៅកើតក្នុងឋានតុសិត វិមានជាវិការៈនៃមាស កើតឡើងតាមសេចក្តីប្រាថ្នាក្នុងទីនោះ ។ ខ្ញុំអធិដ្ឋាននូវវាហនៈ ដែលទឹមដោយសេះមួយពាន់ ជាយានទិព្វ ខ្ញុំឡើងកាន់យាននោះ ហើយទៅតាមសេចក្តីប្រាថ្នា ។ កាលបើខ្ញុំដែលបុញ្ញកម្មនាំអំពីទីនោះមក ខ្ញុំបានកើតជាទេវតា បារាំបិទបាំងខ្ញុំអស់ទីមួយរយយោជន៍ជុំវិញ ។ ខ្ញុំនោះ ដេកលើដំណេកដោយរួសរាន់ ដែលគេមិនបានប្រក់ហើយ គ្រាន់តែក្រាលដោយផ្កា ស្រាប់តែផ្កាឈូកធ្លាក់ចុះអំពីអាកាស មកបិទបាំងអស់កាលជានិច្ច ។ កាលថ្ងៃបណ្តើរកួនកំពុងញាប់ញ័រ កាលកម្តៅថ្ងៃកំពុងក្តៅ កម្តៅឥតក្តៅដល់ខ្ញុំឡើយ នេះជាផលនៃការឲ្យបារាំ ។ ខ្ញុំបានកន្លងផុតទុគ្គតិ អបាយទាំងឡាយខ្ញុំបានបិទហើយ កម្តៅក្នុងបារាំក្តី ទៀបគល់នៃឈើក្តី ឥតមានដល់ខ្ញុំឡើយ ។ ខ្ញុំអធិដ្ឋានទឹកសមុទ្ទ ឲ្យទៅជាផែនដី ហើយឆ្លងនូវទឹកប្រៃ ព្រោះអំពើដែលខ្ញុំបានធ្វើល្អហើយនោះ នេះជាផលនៃ

ពុទ្ធបូជា ។ ខ្ញុំធ្វើផ្លូវច្រូដ៏អាកាស ហើយទៅច្រូដ៏អាកាសបាន ឱហ្ន៎ ! អំពើដែលខ្ញុំធ្វើល្អហើយ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំដឹងខន្ធរបស់ខ្លួននិងសត្វដទៃដែលអាស្រ័យនៅក្នុងកាលមុន ទិព្វចក្ខុខ្ញុំបានជម្រះហើយ អាសវៈទាំងឡាយរបស់ខ្ញុំអស់រលីងហើយ នេះជាផលនៃពុទ្ធបូជា ។ ជាតិខាងមុខ ខ្ញុំបានលះបង់ហើយ ខ្ញុំបានជាឱរសនៃព្រះពុទ្ធ ជាអ្នកទទួលមត៌កក្នុងព្រះសទ្ធម្ម នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំបានញុំាងព្រះសុគតព្រះនាមគោតម ជាសក្យៈដ៏ប្រសើរឲ្យប្រោសប្រាណ ជាអ្នកទ្រទ្រង់ធម៌ ជាអ្នកទទួលមត៌កក្នុងធម៌ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំបានបម្រើព្រះសម្ពុទ្ធព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ហើយបានក្រាបទូលសួរផ្លូវដែលគប្បីទៅកាន់ត្រើយគឺព្រះនិព្វាន ចំពោះព្រះលោកនាយក ។ ព្រះពុទ្ធដែលខ្ញុំអារាធនាហើយ ទ្រង់សម្តែងនូវបទគឺព្រះនិព្វាន ជាគុណជាតដ៏ល្អិតជ្រាលជ្រៅ ខ្ញុំលុះបានស្តាប់ធម៌របស់ព្រះពុទ្ធនោះហើយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ឱហ្ន៎ ! អំពើល្អខ្ញុំបានធ្វើហើយ ខ្ញុំបានរួចស្រឡះចាកជាតិហើយ មានអាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរ ដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ

ហើយ ។

បានឮថា ព្រះនន្ទកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ នន្ទកត្ថេរាបទាន ។**

# អដ្ឋកថា

## នន្ទកត្ថេរាបទាន

[ ១០៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះថា អបទានរបស់ព្រះនន្ទកត្ថេរ មានពាក្យផ្តើមថា **មិគលុទ្ទោ បុរេ អាសឹ** ដូច្នេះ ។

បានឮថា ព្រះថេរៈអង្គនេះ ក្នុងកាលដែលព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតជាសត្វករវិក ធ្វើសំឡេងយំដ៏ពីរោះ ធ្វើប្រទក្សិណព្រះសាស្តា ។ ក្នុងជាតិតមក កើតជាសត្វក្ងោកនៅត្រង់គុហាដែលជាលំនៅរបស់ព្រះបច្ចេកពុទ្ធមួយអង្គ មានចិត្តជ្រះថ្លា បានបន្លឺសំឡេងយំដ៏ពីរោះ ១ ថ្ងៃ ៣ ដង បានធ្វើបុណ្យច្រើនទុកក្នុងភពនោះៗ យ៉ាងនេះហើយក្នុងសាសនាព្រះមានព្រះភាគនៃយើង កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរសាវត្ថី មានឈ្មោះថានន្ទកៈ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ហើយចេញបួសចម្រើនវិបស្សនា បានសម្រេចអរហត្ត ក្នុងកាលតមក ព្រះថេរៈរឭកដល់

បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមក ក្នុងកាលមុន ទើបពោលពាក្យថា **មិគលុទ្ទោ បុរេ អាសឹ** ដូច្នេះជាដើម ។ ក្នុងអបទាននោះ មានសេចក្តីប្លែកគ្នាថា សាងមណ្ឌបហើយ យកផ្កាឈូក ទាំងឡាយប្រក់ប្រគេនដល់ព្រះបច្ចេកពុទ្ធប៉ុណ្ណោះ ។

## អដ្ឋកថាឧទុកត្ថោរាបទាន ចប់

# ហោមកត្ថេរាបទានទី ៧

[ ១០៧ ] កាលនោះ ខ្ញុំជាតាបស ឈ្មោះ អនោមៈ បានធ្វើអាស្រម បណ្ណសាលាដ៏វិចិត្រល្អ នៅអែបទីងចុងញកភ្នំ ។ ខ្ញុំនោះ បានសម្រេចនូវតបកម្ម ខ្ញុំដល់នូវការសម្រេចក្នុងកម្លាំងរបស់ខ្លួន ជាអ្នកក្លាហានក្នុងភាពនៃខ្លួនជាសមណៈ ជាអ្នកមានព្យាយាមដុតបំផ្លាញកិលេស មានប្រាជ្ញាចាស់ ជាអ្នកប្រាជ្ញ ជាអ្នកក្លៀវក្លាក្នុងលទ្ធិរបស់ខ្លួន វាងវៃក្នុងវាទៈរបស់បុគ្គលដទៃមួយទៀត ជាអ្នកតាំងនៅលើផែនដីនិងអាកាសបាន វាងវៃក្នុងឧបាទវយធម៌ ។ ខ្ញុំប្រាសចាកសេចក្ដីសោក មិនមានការប្រណាំងប្រជែង មានអាហារតិច មិនមានសេចក្ដីប្រាថ្នា ជាអ្នកត្រេកអរដោយលាភនិងអលាភ មានឈាន ត្រេកអរក្នុងឈាន ជាអ្នកប្រាជ្ញ ។ កាលនោះ ព្រះសម្ពុទ្ធព្រះនាមបិយទស្សី ជាអ្នកប្រាជ្ញដ៏ប្រសើរ ប្រកបដោយករុណា ព្រះអង្គប្រាថ្នាដើម្បីចម្លងនូវសត្វទាំងឡាយ ទ្រង់ផ្សាយព្រះទ័យករុណា ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ទ្រង់ឃើញនូវជនដែលគួរឲ្យត្រាស់ដឹង ព្រះអង្គជាអ្នកប្រាជ្ញ ជាអ្នកឲ្យឱវាទ ស្ដេចទៅក្នុងចក្កវាឡមួយពាន់ ។ ព្រះអង្គមានប្រាថ្នាស្រោចស្រង់ខ្ញុំ ស្ដេចយាងចូលទៅកាន់អាស្រមរបស់ខ្ញុំ ព្រះជិនស្រីខ្ញុំមិនដែលឃើញទាំងមិនធ្លាប់បានឮអំពីសម្នាក់អ្នកណាមួយ ក្នុងកាលមុនឡើយ ។ ខ្ញុំបានសុបិនទិម្មិតកើតឡើងលក្ខណៈទាំងឡាយ បានប្រកាសល្អហើយ ខ្ញុំជាអ្នកឋិតនៅលើផែនដីនិងអាកាស ឈ្លាសវៃក្នុងបទនៃនក្ខត្តឫក្ស ។ ខ្ញុំនោះ បានស្ដាប់ធម៌របស់ព្រះពុទ្ធហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ខ្ញុំទោះឈរឬអង្គុយ តែងនឹកឃើញព្រះអង្គជានិច្ច ។ កាលខ្ញុំកំពុងនឹកយ៉ាងនេះ ព្រះមានព្រះភាគ ក៏ទ្រង់នឹកដល់

ខ្ញុំដែរ ខ្ញុំកំពុងតែនឹកព្រះពុទ្ធ បីតិក៏កើតមានដល់ខ្ញុំក្នុងខណៈនោះ ។ ព្រះមហាមុនី ទ្រង់ស្តេចចូលមករកខ្ញុំ អស់កាលម្តងទៀត កាលបើព្រះអង្គស្តេចមកដល់ហើយ ខ្ញុំឥតស្គាល់ថា នោះជាព្រះពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរឡើយ ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ប្រកបដោយករុណា ទ្រង់អនុគ្រោះខ្ញុំ បានញ៉ាំងខ្ញុំឲ្យស្គាល់ព្រះអង្គថា តថាគតជាព្រះពុទ្ធក្នុងលោក ព្រមទាំងទេវលោក ។ ខ្ញុំបានស្គាល់ច្បាស់នូវព្រះសម្ពុទ្ធ ព្រះនាមបិយទស្សី ជាមហាមុនី ហើយក៏ញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ក្រាបទូលពាក្យនេះថា ពួកជនទាំងអស់ តែងអង្គុយលើតាំងក្តី លើបល្ល័ង្កក្តី លើតាំងវែងក្តី ព្រះអង្គមានសេចក្តីអាណិតអាសូរ ដល់សត្វទាំងពួង សូមគង់លើអាសនៈដ៏រុងរឿង ។ ខ្ញុំបាននិម្មិតតាំងជាវិការៈនៃកែវទាំងពួង ជាអាសនៈដែលខ្ញុំនិម្មិតដោយឫទ្ធិ ថ្វាយព្រះមហាមុនីព្រះនាមបិយទស្សីក្នុងខណៈនោះ ។ កាលព្រះអង្គគង់លើតាំងកែវ ដែលនិម្មិតដោយឫទ្ធិ ខ្ញុំបានថ្វាយផ្លែព្រីងប៉ុនក្អមក្នុងខណៈនោះ ។ ព្រះមហាមុនីទ្រង់ញ៉ាំងសេចក្តីរីករាយឲ្យកើតដល់ខ្ញុំ ហើយទ្រង់សោយ ( ផ្លែព្រីងនោះ ) គ្រានោះ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះសាស្តា ។ ចំណែកព្រះមានព្រះភាគ ព្រះនាមបិយទស្សី ព្រះអង្គប្រសើរបំផុតក្នុងលោក ប្រសើរជាងនរៈ ទ្រង់គង់លើអាសនៈកែវ ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានថ្វាយតាំងជាវិការៈនៃកែវ និងផ្លែព្រីងទិព្វដល់តថាគត ក្នុងកាលនោះ តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតនឹងសម្តែង ដូចតទៅនេះ

បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៧៧ កប្ប នឹងបានជាស្តេចចក្កពត្តិអស់ ៧៥ ដង ។ នឹងបានជាព្រះឥន្ទ្រសោយទេវរាជ្យអស់ ៣២ ដង នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់បានមួយអសង្ខេយ្យកប្ប ។ បុគ្គលនោះ នឹងបាននូវបល្ល័ង្កជាវិការៈនៃមាស ជាវិការៈនៃវត្ថុជាទីគាប់ចិត្ត ជាវិការៈនៃកែវទទឹម ជាវិការៈនៃកែវជាច្រើន ដែលបុញ្ញកម្មបានតាក់តែងល្អហើយ ។ បល្ល័ង្កទាំងឡាយជាច្រើន ចោមរោមបុគ្គលអ្នកប្រកបដោយបុញ្ញកម្មនោះ សូម្បីកាលដើរទៅដើរមកសព្វៗកាល ។ ផ្ទះមានកំពូល ប្រាសាទ និងទីសម្រាប់ដេក មានតម្លៃច្រើន នឹងកើតក្នុងខណៈនោះ ព្រោះដឹងចិត្តរបស់បុគ្គលនេះ ។ ដំរី ៦០ ពាន់ ដែលគេស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាដំរីដ៏ប្រសើរមានខ្សែជង្គន់មាស ប្រកបដោយគ្រឿងតាក់តែងក្បាលជាវិការៈនៃមាស ។ ដំរីទាំងនោះដែលពួកហ្មមានដៃកាន់លំពែងស្នែងក្របី និងកង្វេរឡើងជិះហើយ នឹងបម្រើបុគ្គលនេះ នេះជាផលនៃការថ្វាយតាំងជាវិការៈនៃកែវ ។ សេះ ៦០ ពាន់ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ជាអាជានេយ្យអំពីកំណើត ជាសេះសិន្ធព្វ ជាពាហនៈដ៏លឿន ។ សេះទាំងនោះ ដែលនាយសារថី មានដៃកាន់ធ្នូ និងខែលឡើងជិះហើយ នឹងបម្រើបុគ្គលនេះ នេះជាផលនៃការថ្វាយតាំងជាវិការៈនៃកែវ ។ រថទាំង ៦០ ពាន់ដែលតាក់តែងដោយគ្រឿងប្រដាប់គ្រប់យ៉ាង បិទបាំងដោយស្បែកខ្លាដំបង ខ្លាធំ ដែលគេប្រដាប់ហើយ លើកទង់ជ័យ មានពួកនាយសារថី មានដៃកាន់ធ្នូនិងខែល ឡើងជិះហើយ នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃការថ្វាយតាំងជាវិការៈនៃកែវ ។ ពួក

មេគោមានទឹកដោះ ៦០ ពាន់ មេគោនិងពួកគោឧសភដ៏ប្រសើរ នឹងញ៉ាំងកូនទាំងឡាយឲ្យកើត នេះជាផលនៃការថ្វាយតាំងជាវិការៈនៃកែវ ។ ពួកស្ត្រី ១៦ ពាន់ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមុក្តា កែវមណី និងកុណ្ឌល ទាំងមានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ ទាំងមានចង្កេះរៀវ នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃការថ្វាយតាំង ជាវិការៈនៃកែវ ។ ក្នុងកប្បទី ១.៨០០ នឹងមានព្រះពុទ្ធ ព្រះនាមគោតម មានបញ្ញាចក្ខុ ទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ត្រាស់ដឹងក្នុងលោក ។ បុគ្គលនេះមានសេចក្តីខ្វល់ខ្វាយ នឹងបួសព្រោះអាស្រ័យការឃើញនូវព្រះពុទ្ធអង្គនោះ បានញ៉ាំងព្រះសាស្តាឲ្យត្រេកអរ នឹងរីករាយក្នុងសាសនា ។ បុគ្គលនេះ បានស្តាប់ធម៌របស់ព្រះពុទ្ធអង្គនោះហើយ នឹងដុតបំផ្លាញនូវកិលេសទាំងឡាយ កំណត់ដឹងនូវអាសវៈទាំងពួង ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ។

សេចក្តីព្យាយាមរបស់ខ្ញុំ គួរនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ខ្ញុំប្រាថ្នានូវប្រយោជន៍ដ៏ឧត្តមក្នុងសាសនា ។ នេះជារាងកាយខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំកំពុងប្រព្រឹត្តទៅ ខ្ញុំមានអាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់តាមលំដាប់

ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះហេមកត្ថេរមានអាយុបានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ហេមកត្ថេរាបទាន ។**

**ចប់ ភាណវារៈ ទី ១៨ ។**

# អដ្ឋកថា

## ហោមកត្ថេរាបទាន

[ ១០៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា អបទានរបស់ព្រះហោមកត្ថេរ មានពាក្យផ្ដើមថា **បត្តារក្ខដំ និស្សាយ** ដូច្នេះ ។

ក្នុងអបទាននោះ មានសេចក្ដីប្លែកត្រឹមតែប៉ុណ្ណោះថា លោកបានបួសជាឥសីនៅត្រង់ព្រៃហិមពាន្ត បានឃើញព្រះមានព្រះភាគព្រះនាមថា បិយទស្សី ដែលទ្រង់យាងចូលទៅរក ទើបក្រាលតាំងដែលធ្វើដោយកែវថ្វាយ ហើយបានឈរ កាលព្រះពុទ្ធគង់លើកម្រាលនោះ បាននាំយកនំកុម្មាសនិងផ្លែព្រីងមកថ្វាយ ដើម្បីឲ្យកុលបុត្តនោះមានចិត្តជ្រះថ្លា ទើបព្រះមានព្រះភាគទ្រង់សោយផ្លៃឈើនោះ ។

អដ្ឋកថាហោមកត្ថេរាបទាន ចប់

# គោធេយ្យត្ថេរាបទានទី ៨

[ ១០៨ ] គ្រានោះ ក្នុងកេតុមតីបុរីដ៏ឧត្តម ព្រះរាជាព្រះនាមវិជិតជ័យ ជាស្តេចក្លៀវក្លា បរិបូណ៌ដោយព្យាយាម នៅគ្រប់គ្រងបុរី ។ កាលព្រះរាជាអន្តនោះធ្វេសប្រហែសហើយ ពួកជនជាសត្រូវនៅក្នុងដែនឧត្តរៈនិងតុណ្ឌិកៈបន្តគ្នាឡើង លុកលុយដែនក្នុងកាលនោះ ។ កាលអ្នកបច្ចន្តគ្រាមបះបោរឡើងហើយ ព្រះរាជាទ្រង់ឲ្យប្រជុំគ្នាយ៉ាងប្រញាប់ គឺទ្រង់ញុំាងអាមាត្យ និងរាជទូតទាំង-ឡាយ ឲ្យសង្កត់សង្កិនសត្រូវក្នុងកាលនោះ ។ ពលដំរី ពលសេះ ពលពាក់គ្រឿងក្រោះ ពលកាន់ធ្នូ និងពលរថទាំងអស់ សុទ្ធតែជាអ្នកក្លៀវក្លាមកប្រជុំគ្នាក្នុងកាលនោះ ។ ពួកអ្នកគ្រួ ពួកអ្នកខ្វាន់ព្រះកេស ពួកអ្នកផ្ងូតទឹក ពួកអ្នកធ្វើផ្កាកម្រងទាំងអស់ សុទ្ធតែជាពួកពិជ័យសង្គ្រាមដ៏ក្លាហានមកប្រជុំគ្នាក្នុងកាលនោះ ។ ពួកបុរសមានដាវក្នុងដៃ មានធ្នូនិងខែលក្នុងដៃទាំងអស់ សុទ្ធតែជាពួកពិជ័យសង្គ្រាមដ៏កាច មកប្រជុំគ្នាក្នុងកាលនោះ ។ ពួកដំរីដ៏ប្រសើរ មានអាយុ ៦០ ឆ្នាំ មានខ្សែជង្គន់និងគ្រឿងប្រដាប់ជាវិការៈនៃមាសសុទ្ធតែជាដំរីចុះប្រេង ៣ អន្លើទាំងអស់ មកប្រជុំគ្នាក្នុងទីនោះ ។ ក្រុមយុទ្ធ-នាធិការទាំងអស់ ដែលមានការងារធ្វើហើយ ជាអ្នកអត់ធ្មត់ចំពោះត្រជាក់ក្តៅនិងការបន្ទោបង់នូវលាមកមកប្រជុំគ្នាក្នុងកាលនោះ ។ សំឡេងស័ង្ខ សំឡេងស្គរ ជាសំឡេងលាន់ឮឡើង ពួកជនទាំងអស់នោះរីករាយដោយសំឡេងនុ៎ះមកប្រជុំគ្នាក្នុងកាលនោះ ។ ពួកជនទាំងអស់ ចាក់ផ្តួលដោយច្បូក កាំបិត-ចៀស្បែក ធ្នូ និងលំពែងស្នែងក្របី មកប្រជុំគ្នាក្នុងកាលនោះ ។ កាលនោះខ្ញុំហ្នឹងឯង ជាស្តេចឈ្នះសង្គ្រាមដែលគេមិនធ្លាប់ឈ្នះ ពាក់គ្រឿងក្រោះ បាន

យកដែកស្រួចចាក់សត្វ ៦០ ពាន់ ឲ្យតក់ស្លុត ។ ពួកមនុស្សបានស្រែកកង វំពងថា ឱហ្ន៎ ស្តេចនេះ មិនប្រកបដោយធម៌ទេ កាលបើស្តេចនេះ ទៅធ្លាក់ ក្នុងនរកកាលណា កាលនោះ យើងទើបនឹងមានទីបំផុតនៃទុក្ខ ។ កាលនោះ ខ្ញុំដេកលើដំណាក់ ស្រាប់តែឃើញសត្វនរក ខ្ញុំដេកឥតលក់ទាំងថ្ងៃទាំងយប់ ពួកនិរយបាលទាំងនោះ គំរាមខ្ញុំដោយដែកស្រួច ។ ខ្ញុំគិតថា ប្រយោជន៍អ្វី ដោយរាជ្យ ពាហនៈ និងពល ដែលអញប្រមាទហើយ រាជ្យនិងពលទាំងនោះ មិនអាចទ្រទ្រង់អញបានឡើយ មានតែញ៉ាំងអញឲ្យតក់ស្លុតសព្វ ៗ កាល ។ ប្រយោជន៍អ្វីដោយកូនប្រពន្ធ និងរាជ្យទាំងអស់របស់អញ បើដូច្នោះ អាត្មាអញគួរតែបួស នឹងជម្រះផ្លូវសម្រាប់ទៅកាន់ ( ព្រះនិព្វាន ) ។ ខ្ញុំឥតអាឡោះអាល័យ បានលះបង់ពួកដំរី ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ជាដំរីដ៏ប្រសើរ មានខ្សែជង្គង់មាស ប្រកបដោយគ្រឿងតាក់តែងក្បាលជាវិការៈនៃមាស ដែលពួកហ្មដំរីមានដៃកាន់លំពែងស្នែងក្របី និងកង្វេរឡើងជិះហើយក្នុងទីសមរភូមិ ខ្ញុំក្តៅក្រហាយសព្វដោយកម្មរបស់ខ្លួន ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំលះបោលនូវសេះ ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង នូវសេះអាជានេយ្យអំពីកំណើត និងសេះសិន្ធវៈជាពាហនៈដ៏លឿន ដែលពួកនាយសារថីមានធ្នូក្នុងដៃ និងពាក់គ្រឿងក្រោះ ឡើងជិះហើយ ទាំងអស់នោះ ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំបានលះបង់នូវរាជរថចំនួន ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ដែលប្រកបស្រោប បិទបាំងដោយស្បែកខ្លាដំបងនិងខ្លាធំ មានទង់ជ័យលើកឡើង ទាំង

អស់នោះ ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំលះបង់នូវមេគោដែលមានទឹកដោះ ៦០ ពាន់ និងគ្រឿងសម្រាប់ទ្រកាដង់ទាំងអស់ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំលះបង់ពួកស្រី ៦០ ពាន់ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់យ៉ាងមានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រពាក់កែវមណីនិងកុណ្ឌល មានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ មានចង្កេះមូលរៀវ កំពុងកន្ទក់កន្ទេញ ទាំងនោះ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំលះបង់ស្រុក ៦០ ពាន់ បរិបូណ៌ដោយវត្ថុគ្រប់យ៉ាង និងរាជ្យនោះ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំចេញចាកនគរហើយ ចូលទៅកាន់ព្រៃហេមពាន្ត សាងអាស្រមមួយទៀបឆ្នេរស្ទឹងភាគីរសី ។ ខ្ញុំធ្វើបណ្ណសាលា រួចហើយធ្វើរោងភ្លើង ខ្ញុំមានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅហើយ ក្នុងអាស្រម ។ កាលខ្ញុំចម្រើនឈាននៅក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ខ្ញុំមិនមានសេចក្តីតក់ស្លុតឡើយ ខ្ញុំមិនដែលចួបប្រទះភ័យ ដែលគួរឲ្យខ្លាចឡើយ ។ ព្រះសម្ពុទ្ធព្រះនាមសុមេធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ប្រកបដោយករុណា ទ្រង់រុងរឿងដោយពន្លឺគឺញាណកើតឡើងក្នុងលោក ក្នុងខណៈនោះឯង ។ យក្សមួយមានឫទ្ធិច្រើន នៅជិតអាស្រមរបស់ខ្ញុំ កាលព្រះពុទ្ធដ៏ប្រសើរកើតឡើងហើយ ក៏ប្រាប់ខ្ញុំក្នុងកាលនោះថា ព្រះពុទ្ធព្រះនាមសុមេធ មានបញ្ញាចក្ខុកើតហើយក្នុងលោក ទ្រង់ញុំាងប្រជុំជនទាំងអស់ឲ្យឆ្លងហើយ ទ្រង់មុខជាចម្លងអ្នកដែរ ។ ខ្ញុំមានសេចក្តីស្ញប់ស្ញែងកើតឡើងក្នុងខណៈនោះ ព្រោះឮពាក្យយក្សនោះ ខ្ញុំគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ហើយរៀបចំនូវអាស្រម ។ ខ្ញុំលះបង់ឧស សម្រាប់ដុតភ្លើង រៀបក្រាល

កម្រាល រួចថ្វាយបង្គំអាស្រមហើយចេញអំពីព្រៃធំ ។ ខ្ញុំកាន់យកខ្លឹមចន្ទន៍ អំពីព្រៃធំនោះ ហើយចេញពីស្រុកមួយ ចូលទៅកាន់ស្រុកមួយ ចេញពីបុរីមួយ ចូលទៅកាន់បុរីមួយ ស្វែងរកព្រះពុទ្ធ ជាទេវតាដ៏ប្រសើរជាងទេវតា ហើយចូលគាល់ព្រះលោកនាយក ។

សម័យនោះឯង ព្រះមានព្រះភាគ ព្រះនាមសុមេធជា លោកនាយក ទ្រង់កំពុងប្រកាសនូវសច្ចៈ ៤ ញុំាងប្រជុំជនដ៏ច្រើននាក់ឲ្យត្រាស់ដឹង ។ ខ្ញុំផ្គងអញ្ជលីប្រណម្យលើក្បាល ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយពោលនូវគាថាទាំងនេះថា កាលបើផ្កាម្លិះកំពុងរីក ក្លិននោះក៏ផ្សាយទៅបានតែក្នុងទីជិត កាលបើផ្កាចម្ប៉ា ផ្កាខ្ទឹង ផ្កាម្លិះ ផ្ការំដួល ផ្ការកេត និងផ្ការាំងកំពុងរីក ក្លិនក៏ផ្សាយទៅបានតែក្នុងទីបណ្តោយខ្យល់ បពិត្រព្រះអង្គជាមហាវីរបុរស ព្រះអង្គតែងផ្សាយដោយក្លិន គឺគុណធម៌ សព្វទិសទី ។ ខ្ញុំព្រះអង្គចេញចាកព្រៃហិមពាន្តមកក្នុងទីនេះ ព្រោះបានធុំក្លិនព្រះអង្គ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់ប្រសើរបំផុតក្នុងលោក មានយសច្រើន ខ្ញុំព្រះអង្គសូមបូជាចំពោះព្រះអង្គ ។ ខ្ញុំបានលុបលាបព្រះសុមេធ ជាលោកនាយក ដោយខ្លឹមចន្ទន៍ដ៏ប្រសើរ រួចហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា អង្គុយនៅស្ងៀម ក្នុងខណៈនោះ ។

ព្រះមានព្រះភាគ ព្រះនាមសុមេធ ប្រសើរបំផុតក្នុងលោក ប្រសើរជាងពួកនរៈ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយត្រាស់គាថាទាំងនេះថា បុគ្គលណា បានសរសើរគុណតថាគត ទាំងបានបូជាខ្លឹមចន្ទន៍ដល់តថាគត តថាគតនឹងសរសើរបុគ្គលនោះអ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែងចុះ ។ បុគ្គលនេះ នឹង

មានពាក្យសម្ដីគេគួរជឿ ជាបុគ្គលប្រសើរ មានចិត្តត្រង់ មានព្យាយាមដុត កម្ដៅកិលេស មានពន្លឺអស់ ២៥ កប្ប ។ បុគ្គលនេះ នឹងត្រេកអរក្នុងទេវ-លោកអស់ ២៦ រយកប្ប នឹងបានជាស្ដេចចក្កពត្តិអស់មួយពាន់ដង នឹងបាន ជាព្រះឥន្ទសោយរាជ្យជាស្ដេចទេវតាអស់ ៣៣ ដង នឹងបានសោយប្រទេស រាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ មនុស្សនេះឯង លុះច្យុត ចាកទីនោះមក នឹងបានទៅកើតជាមនុស្ស ប្រកបដោយបុញ្ញកម្ម នឹងមានផៅ ពង្សដ៏ប្រសើរ ។ ព្រាហ្មណ៍ម្នាក់ឈ្មោះពាវរី ជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ បរិបូណ៌ដោយលក្ខណៈ ៣ យ៉ាង ។ បុគ្គលនេះ នឹងបានជាសិស្សពាវរីព្រាហ្មណ៍នោះ ជាអ្នកដល់ត្រើយនៃមន្ត បានចូលគាល់ ព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ។

ខ្ញុំបានទូលសួរនូវប្រស្នាដ៏ល្អិត ហើយញ៉ាំងចិត្តឲ្យរីករាយ កំណត់ដឹង អាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ភ្លើង ៣ យ៉ាងរបស់ខ្ញុំបានរលត់ ហើយ ភពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ កិលេសទាំងពួងខ្ញុំបានដុតបំផ្លាញចោលហើយ ភព ទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរ កាត់ផ្ដាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ល្អ

ណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតោរេយ្យត្ថេរមានអាយុបានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ តោរេយ្យត្ថេរាបទាន ។

# អដ្ឋកថា

## តោទេយ្យត្ថេរាបទាន

[ ១០៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះថា អបទានរបស់ព្រះតោទេយ្យត្ថេរ មានពាក្យផ្ដើមថា **រាជាសិ វិជយោ នាម** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រាជាសិ វិជយោ នាម** សេចក្ដីថា បានជាព្រះរាជាព្រះនាមថាវិជ័យ ព្រោះទ្រង់ឈ្នះសង្គ្រាមគ្រប់លើក តាំងអំពីនៅក្មេង និងព្រោះទ្រង់ធ្វើមហាជនឲ្យត្រេកអរ គឺឲ្យជាប់ចិត្តដោយសង្គហវត្ថុ ៤ ប្រការ ។ បទថា **កេតុមតីបុរុត្តមេ** សេចក្ដីថា ទង់សំពត់ លោកហៅថា **កេតុ** ន័យម្យ៉ាងទៀត សសរគោលរតនៈដែលគេបោះត្រង់កណ្ដាលនគរ ដើម្បីលម្អព្រះនគរនោះ មានទង់ដែលលើកឡើងជាប្រចាំ ស្រស់ល្អ ហេតុនោះទើបឈ្មោះថា កេតុមតីនគរ ។ ឈ្មោះថា បុរៈ ព្រោះធ្វើចិត្តរបស់មហាជនទាំងអស់ឲ្យពេញដោយទ្រព្យនិងធញ្ញជាតិ ។ មានទង់ផង ជាបុរៈផង ឧត្តមផង ហេតុនោះទើបឈ្មោះថា កេតុមតីបុរុត្តមៈ ។ ក្នុងកណ្ដាលនគរកេតុមតីដ៏ឧត្តមនោះ ។ បទថា **សូរោ វិក្កមសម្បន្នោ** សេចក្ដីថា ព្រះរាជាឈ្មោះថាវិជ័យ ទ្រង់ជាអ្នកក្លាហាន សម្បូរដោយវិរិយភាព ប្រថាប់នៅ ។ មានសេចក្ដីប្លែកត្រឹមតែប៉ុណ្ណះថា ព្រះរាជាទ្រង់លះនគរដ៏ស្តុកស្តម្ភ ទ្រព្យ និងពាហនៈគ្រប់យ៉ាង ចូលព្រៃហិមពាន្ត បួសជាឥសី បានឃើញព្រះមានព្រះភាគព្រះនាមថា សុមេធ កើតនូវសោមនស្ស ធ្វើនូវការបូជាដោយខ្លឹមចន្ទន៍ ។

**អដ្ឋកថាតោទេយ្យត្ថេរាបទាន ចប់**

# ជតុកណ្ណិកត្ថេរាបទានទី ៩

[ ១០៩ ] កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្ត នៅក្នុងនគរហង្សវតី ជាអ្នកឆ្អែតស្កប់ស្កល់ ដោយកាមគុណទាំងឡាយ ញុំាំងគេឲ្យបោមរោម ។ កាលនោះខ្ញុំឡើងកាន់ប្រាសាទទាំង ៣ ប្រើប្រាស់ភោគៈច្រើន ញុំាំងគេឲ្យបោមរោមដោយការរាំ ច្រៀង ក្នុងប្រាសាទនោះ ។ តូរ្យតន្ត្រី ប្រកបដោយការប្រគុំដ៏ពីរោះ ដែលគេនាំមកដើម្បីខ្ញុំ ពួកស្រីទាំងអស់ កាលត្រេកអរមែងដឹកនាំនូវចិត្តខ្ញុំ ។ ពួកស្រីកំពុងពេញល្បែង ពួកស្រីតឿ ពួកស្រីពេញរូបរាង ពួកស្រីចំទង់ ពួកស្រីឡើងរាំ និងពួកស្រីគ្ងុក តែងបោមរោមខ្ញុំសព្វ ៗ កាល ។ ពួកអ្នកប្រគុំ ពួកអ្នកជំស្គរ ពួកអ្នករបាំជាច្រើនគ្នា ពួករបាំប្រុសស្រី តែងបោមរោមខ្ញុំសព្វៗកាល ។ ពួកជាងកំណោរ ពួកអ្នកផ្លុតទឹក ពួកអ្នកជាំស្វ ពួកអ្នកធ្វើផ្កាកម្រង ពួកសុបាសកជន ពួកអ្នកប្រជាល់ ពួកអ្នកចំបាប់ ទាំងអស់នោះ តែងបោមរោមខ្ញុំសព្វៗ កាល ។ កាលពួកជនទាំងនុ៎ះកំពុងលេង ក្នុងការបាញ់ធ្នូដែលសិក្សាស្ទាត់ហើយ ខ្ញុំឥតស្គាល់យប់និងថ្ងៃឡើយ ដូចជាព្រះឥន្ទបិតនៅក្នុងតាវត្តិង្សបុរី ។ ពួកអ្នកដើរផ្លូវ ពួកអ្នកកំព្រា ពួកយាចក ពួកអ្នកដើរជាច្រើនគ្នា អ្នកទាំងអស់នោះ តែងចូលទៅសុំទានក្នុងផ្ទះខ្ញុំជានិច្ច ។ ពួកសមណៈនិងព្រាហ្មណ៍ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ញុំាំងបុណ្យឲ្យចម្រើនដល់ខ្ញុំ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកនិគ្រន្ថទាំងអស់នោះ គឺពួកបដកៈ លដុកៈ បុប្ផសាជកៈ ទណ្ឌិកៈ ឯកសិខៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកប្រព្រឹត្តចិញ្ចឹមជីវិតដោយប្រពៃ ពួកអ្នកប្ងន់ដណ្តើមទ្រព្យគេ ពួកអ្នកប្រព្រឹត្តធម៌ដូចគោ ពួកអ្នកប្រព្រឹត្តធម៌ដូចទេវតា ពួកអ្នកទ្រទ្រង់ល្អងធូលីទាំងនុ៎ះ តែងមកកាន់ផ្ទះខ្ញុំ ។

ពួកអ្នកប្រព្រឹត្តធម៌ ពួកអ្នកដល់នូវការសម្រេចហេតុផ្សេងៗ ពួកអ្នកប្រជុំគ្នារម្ងាប់ការក្រោធ ពួកអ្នកមានតបៈ និងពួកអ្នកប្រព្រឹត្តនៅក្នុងព្រៃជាច្រើន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនខ្វាក់ ពួកទមិឡ ពួកអ្នកដែនសាកុឡៈ ពួកអ្នកដែនមលយាលកៈ ពួកអ្នកដែនសវរៈ និងពួកអ្នកដែនយោនកៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកដែនគន្ធកៈ ពួកអ្នកដែនមុណ្ឌកៈ ពួកអ្នកដែនកុដ្ឋលៈ ពួកអ្នកដែនសានុវិន្ទកៈ ពួកអ្នកដែនអារាព និងពួកអ្នកដែនចិន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកអាស្រ័យនៅក្នុំអលសន្ទកៈ ពួកអ្នកអាស្រ័យនៅភ្នំបល្លវៈ ពួកអ្នកឡើងកំពូលភ្នំ និងពួកបេតបុត្តអ្នកនៅក្រៅដែន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនមធុរៈ ពួកជនអ្នកនៅក្នុងដែនកោសល ពួកជនអ្នកនៅក្នុងដែនកាសី ពួកជនអ្នកនៅក្នុងដែនហត្ថិបុរី ពួកជនអ្នកនៅក្នុងដែនឥសិន្ទៈ និងពួកជនអ្នកនៅក្នុងដែនមក្កលៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនចេលាវកៈ ពួកជនអ្នកនៅក្នុងដែនអារម្ពៈ ពួកជនអ្នកនៅក្នុងដែនឱភាសៈ ពួកជនអ្នកនៅក្នុងដែនមេឃលៈ ពួកជនអ្នកនៅក្នុងដែនខុទ្ទកៈ និងពួកជនអ្នកនៅក្នុងដែនសុទ្ទកៈ ជាច្រើន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនរោហកៈ ពួកជនអ្នកនៅក្នុងដែនសិន្ធវៈ ពួកជនអ្នកនៅក្នុងដែនចិត្តកៈ ពួកជនអ្នកនៅក្នុងដែនឯកកណ្ណិកៈ ពួកជនអ្នកនៅក្នុងដែនសុរដ្ឋៈ និងពួកជនអ្នកនៅក្នុងដែនអបរន្តៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកកុមារនៅក្នុងដែនសុប្បារកៈ នៅក្នុងដែនមលយៈ នៅក្នុងសោណភូមិ នៅក្នុងដែនវិជ្ជហារ ពួកជនទាំងអស់នោះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងផ្កាកម្រង ពួកជាងតម្បាញ ពួកជាងធ្វើស្បែក ពួកជាង

ចាំងឈើ ពួកអ្នកធ្វើការងារ និងពួកស្មូនឆ្នាំង តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងកែវមណី ពួកជាងលោហៈ ពួកជាងមាស ពួកជាងត្បាញសំពត់ និងពួកជាងសំណ ទាំងអស់នោះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងកូនសរ ពួកជាងក្រឡឹង ពួកជាងតម្បាញ ពួកអ្នកធ្វើទឹកអប់ ពួកជាងជ្រលក់ និងពួកជាងផុល តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកស្លប្រេង ពួកអ្នកនាំឧស ពួកអ្នកជងទឹក ពួកអ្នកចិញ្ច្រាំសាច់ ពួកអ្នកជាំស្ល និងពួកអ្នកឈ្លាសវៃក្នុងសំឡេង តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកចាំទ្វារ ពួកអ្នករក្សាអគ្គ ពួកអ្នកក្រងផ្កា ពួកអ្នកចាក់-ចោលផ្កា ពួកអ្នកជិះដំរី និងពួកគង្វាលដំរី តែងមកកាន់ផ្ទះខ្ញុំ ។ ខ្ញុំបានឲ្យសាមគ្គីដល់ស្តេចឈ្មោះអានន្ទៈ ខ្ញុំបំពេញសេចក្តីខ្វះខាតដោយរតនៈមានពណ៌ ៧ ។ ពួកជនជាច្រើនទាំងអស់ណា មានវណ្ណៈផ្សេងៗគ្នា ដែលខ្ញុំបានពណ៌នារួចហើយ ខ្ញុំដឹងចិត្តនៃជននោះ ហើយឲ្យឆ្អែតស្កប់ស្កល់ដោយរតនវត្ថុ ។ កាលបើគេនិយាយពាក្យពីរោះ កាលបើគេទូងស្គរឡើង កាលបើគេផ្លុំស័ង្ខឡើង ខ្ញុំត្រេកអរតែក្នុងផ្ទះរបស់ខ្លួន ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈព្រមទាំងព្រះខីណាស្រពមួយសែនអង្គ កើតមានឡើងហើយ ។ ព្រះសម្ពុទ្ធមានចក្ខុ ព្រមដោយភិក្ខុទាំងឡាយ ទ្រង់ស្តេចទៅតាមថ្នល់ រុងរឿងដូចជាដើមទីបព្រឹក្ស ដែលញុំាងទិសទាំងពួងឲ្យភ្លឺ ។ កាលបើព្រះលោកនាយកស្តេចយាងទៅ ស្គរទាំងពួងក៏លាន់ឮឡើង រស្មីរបស់ព្រះពុទ្ធក៏ផ្សាយចេញទៅហាក់ដូចព្រះអាទិត្យទើបនឹងរះ ។ ខណៈនោះ ពន្លឺដ៏ធំទូលាយ ចាំងចូលទៅក្នុងផ្ទះទាំងឡាយ ដោយរស្មីផ្សាយចូលទៅតាមចន្លោះសន្ទះទ្វារ ។ ខ្ញុំបាន

ឃើញរស្មីរបស់ព្រះពុទ្ធហើយ បានប្រាប់បរិស័ទខ្ញុំថា ព្រះពុទ្ធដ៏ប្រសើរស្តេចយាងមកតាមថ្នល់នេះ ដោយឥតសង្ស័យ ។ ខ្ញុំបានចុះអំពីប្រាសាទដោយរហ័ស ទៅរង់ចាំពាក់កណ្តាលផ្លូវ ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយក្រាបបង្គំទូលថា សូមព្រះពុទ្ធព្រះនាមបទុមុត្តរៈ អនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះពុទ្ធជាអ្នកប្រាជ្ញអង្គនោះ ទ្រង់ទទួលនិមន្តន៍ មួយអន្លើដោយពួកភិក្ខុមួយសែនអង្គ ។ លុះខ្ញុំនិមន្តព្រះសម្ពុទ្ធរួចហើយ នាំព្រះអង្គទៅឯផ្ទះរបស់ខ្ញុំ ញ៉ាំងព្រះមហាមុនី ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹកក្នុងផ្ទះនោះ ។ ខ្ញុំបានដឹងកាលដ៏គួរនៃព្រះពុទ្ធដ៏ប្រសើរ ជាតាទិបុគ្គល ទ្រង់ឆាន់រួចហើយ ក៏បម្រើព្រះពុទ្ធដ៏ប្រសើរដោយតូរ្យតន្ត្រីព្រមទាំងចម្រៀង ។ ព្រះសម្ពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់គង់នៅខាងក្នុងផ្ទះ ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានបម្រើតថាគត ដោយតូរ្យតន្ត្រីផង បានថ្វាយបាយនិងទឹកផង ដល់តថាគត តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតនឹងសម្តែងដូចតទៅនេះ នរៈនេះ នឹងមានគ្រឿងបរិភោគច្រើន ព្រមទាំងមាសប្រាក់ ភោជន នឹងបានសោយឯករាជ្យក្នុងទ្វីប ៤ ។ នរៈនេះ នឹងសមាទានសីល ៥ ត្រេកអរក្នុងកុសលកម្មបថ ១០ ប្រព្រឹត្តសមាទានកុសលធម៌ ហើយនឹងញ៉ាំងបរិស័ទឲ្យសិក្សា ។ តូរ្យតន្ត្រីមួយសែន និងពួកនារីមានខ្លួនប្រដាប់ប្រដា តែងគាល់បម្រើនរៈនេះជានិច្ច នេះជាផលនៃការបម្រើ ។ នរៈនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បានជាព្រះឥន្ទ្រសោយ

រាជ្យជាស្តេចទេវតា អស់ ៦៤ ដង ។ នឹងបានជាស្តេចចក្កពត្តិ អស់ ៧៤ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់បានមួយអសង្ខេយ្យកប្ប ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងត្រកូលព្រះបាទឱក្កាករាជ ត្រាស់ដឹងក្នុងលោក ។ នរៈនេះ បើចូលទៅកាន់កំណើតណា ទោះជាទេវតាឬជាមនុស្ស នឹងជាអ្នកមានភោគៈមិនខ្វះខាត ក្នុងបច្ឆិមជាតិ នឹងបាននូវភាពជាមនុស្ស ។ ក្នុងកាលនោះ នរៈនេះ ជាអ្នកស្វាធ្យាយមន្ត ដល់នូវត្រើយនៃវេទទាំង ៣ កាលស្វែងរកប្រយោជន៍ដ៏ឧត្តម នឹងត្រាច់ទៅតាមផែនដី ។ នរៈនោះ លុះកាលជាខាងក្រោយ ក៏ចេញបួស ត្រូវកុសលមូលដាស់តឿន នឹងត្រេកអរក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមគោតម ។ នរៈនេះនឹងញ៉ាំងព្រះសម្ពុទ្ធព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យប្រោសប្រាណ នឹងដុតកម្តៅនូវកិលេសទាំងឡាយ ហើយបានជាព្រះអរហន្ត ។

ថ្ងៃនេះ ខ្ញុំនៅក្នុងសាសនានៃព្រះពុទ្ធជាសក្យបុត្ត ខ្ញុំឥតភ័យ ដូចជាស្តេចខ្លាធំ ឬដូចកេសររាជសីហ៍ជាស្តេចម្រឹគនៅក្នុងព្រៃ ។ ខ្ញុំមិនដែលឃើញនូវកំណើតរបស់ខ្ញុំក្នុងទេវលោកកម្សត់ ឬក្នុងកំណើតមនុស្សកម្សត់ ឬក៏ក្នុងទុគ្គតិឡើយ នេះជាផលនៃការបម្រើ ។ ខ្ញុំជាអ្នកប្រកបក្នុងវិវេក ជាអ្នកមានចិត្តស្ងប់ មិនមានឧបធិ មិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នក មិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ

ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជតុកណ្ណិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ជតុកណ្ណិកត្ថេរាបទាន ។**

## អដ្ឋកថា

## ជតុកណ្ណិកត្ថេរាបទាន

[ ១០៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះថា អបទានរបស់ព្រះជតុកណ្ណិកត្ថេរ មានពាក្យផ្តើមថា **នគរេ ហំសវតិយា** ដូច្នេះ ។

ក្នុងរឿងនោះ មានសេចក្តីប្លែកដូចតទៅនេះ គឺលោកជាកូនសេដ្ឋី នៅក្នុងប្រាសាទមាស ជាអ្នកនៅដល់ព្រមដោយកាមគុណ ៥ ជាអ្នកសេពគប់មនុស្សក្នុងនគរគ្រប់គ្នា និងសេពគប់ជាមួយមនុស្សអ្នកចេះសិប្បៈគ្រប់គ្នា ។

**អដ្ឋកថាជតុកណ្ណិកត្ថេរាបទាន ចប់**

# ឧទេនត្ថេរាបទានទី ១០

[ ១១០ ] មានភ្នំមួយឈ្មោះ បទុម: នៅជិតព្រៃហិមពាន្ត ខ្ញុំបានធ្វើអាស្រមមួយយ៉ាងល្អ ទាំងសាងបណ្ណសាលាមួយដ៏ល្អដែរ ។ នៅជិតអាស្រមនោះ មានស្ទឹងដែលមានកំពង់ល្អ ជាទីរីករាយនៃចិត្ត ស្ទឹងទាំងនោះ មានទឹកថ្លា មានទឹកត្រជាក់ តែងហូរទៅសព្វៗកាល ។ កាលនោះ ពួកត្រីស្វាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្ដាយ ត្រីថ្កិន ត្រីទាំងនុ៎ះ នៅក្នុងស្ទឹង នាំឲ្យល្អស្ទឹង ។ ស្ទឹងនោះ ដ៏ដេរដាសដោយដើមស្វាយ ដើមព្រីង ដើមថ្វាន់ ដើមតង្កៀបក្ដាម ដើមរាជព្រឹក្ស និងដើមប្រទៀង នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមអង្កោល វល្លិបាសមានផ្ការីក ជាឈើធ្វើដូចជាមានកិច្ចកល មានក្លិនផ្សព្វផ្សាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមរំដួល ម្ទេះរួត ខ្ទឹង រាំងភ្នំ មានផ្ការីក មានក្លិនជាទិព្វសាយកាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមស្រល ដើមស្រល់ ដើមកុម្ភ មានផ្ការីក ដូចជាធ្លាក់មកក្នុងដៃ មានក្លិនជាទិព្វសាយកាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង សម៉ពិភេទក៍ ពុទ្រា រាក់ខ្មៅ ញ្ញៅ ជាឈើមានផ្លែច្រើន នៅជិតអាស្រមរបស់ខ្ញុំ ។ ដើមក្លាំពាក់ និងដើមចេក បញ្ចេញផ្កា ជិតអាស្រមរបស់ខ្ញុំនោះ ក្លិនជាទិព្វសាយកាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមអសោក វរីព្រឹក្ស និងដើមស្ដៅ ជាឈើមានផ្ការីក ក្លិនជាទិព្វ សាយកាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមក្រូចឆ្មារ ក្រូចភ្លា និងតិមិរព្រឹក្ស មានផ្ការីកក្នុងទីនោះ ក្លិនជាទិព្វសាយកាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ និគ្គុណ្ឌិព្រឹក្ស សិរិនិគ្គុណ្ឌីព្រឹក្ស និងដើមចម្ប៉ា មានផ្ការីកក្នុងទីនោះ ក្លិនជាទិព្វសាយកាយទៅ នាំឲ្យល្អអាស្រម

របស់ខ្ញុំ ។ ស្រះបោក្ខរណីនៅជិត ( អាស្រមនោះ ) មានពួកសត្វចាក្រពាក យំគឹកកង ដេរដាសដោយផ្កាលំចង់ ផ្កាឈូក និងផ្កាឧប្បល ។ ( ស្រះបោក្ខ-រណីនោះ ) មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់ល្អ ជាទីរីករាយនៃចិត្ត មានទឹកថ្លា ដូចជាកែវផលិក នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ឈូកក្រហម ឈូកសនិងឧប្បល បញ្ចេញផ្កាក្នុងស្រះនោះ ដេរដាសដោយផ្កាលំចង់ទាំង-ឡាយ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ពួកត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ ត្រីថ្កិន ពួកត្រីទាំងនោះហែលទៅមកក្នុងស្រះនោះ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ក្រពើ ក្រពា អណ្តើក ជាសត្វចាប់គេស៊ី និងពស់ថ្លាន់ជាសត្វរួបរឹត នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ពួកព្រាប ប្រវឹក ចាក្រពាក ក្អែកទឹក ត្រដេវវិច និងសាលិកា នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ នយិតាព្រឹក្ស ស្វាយ ក្រអូប ដើមការកេត មានផ្ការីកក្នុងទីនោះ ក្លិនជាទិព្វសាយកាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន ត្រាច់ទៅមករៀយៗក្នុងព្រៃធំ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ( ពួកតាបស ) ពេញដោយការៈគឺជ្ជងសក់ ស្លៀកពាក់សំពត់ស្បែកខ្លា ត្រាច់ទៅរៀយៗក្នុងព្រៃធំ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ តាបសពួកខ្លះ ទ្រទ្រង់ស្បែកខ្លា មានប្រាជ្ញាចាស់ប្រព្រឹត្តស្ងប់ស្ងាប់ ជាអ្នកមានអាហារតិច តាបសទាំងអស់នោះ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ គ្រានោះ តាបសទាំងនោះ កាន់យកនូវដងរែកនិងសម្រែក ចូលទៅក្នុងព្រៃ បរិភោគមើមឈើនិងផ្លែឈើ នៅជិតអាស្រមរបស់ខ្ញុំ ។ តាបសទាំងនោះ មិនបាននាំមកនូវឧសនិងទឹក សម្រាប់លាងជើងឡើយ ( វត្ថុទាំង

នោះ ) គឺទេវតានាំមកដោយខ្លួនឯង ដោយអានុភាពនៃតាបសទាំងអស់ ។ ពួកឥសី ៨៤ ពាន់រូប មកប្រជុំគ្នាក្នុងទីនោះ ពួកឥសីទាំងអស់នុ៎ះ សុទ្ធតែជាអ្នកមានឈាន ស្វែងរក ប្រយោជន៍ដ៏ឧត្តម ។ ក្នុងកាលនោះ ឥសីទាំងអស់នោះ ជាអ្នកមានតបៈ ប្រព្រឹត្តធម៌ដ៏ប្រសើរ មានអប្បនាឈានជាស់តឿនហើយ ត្រាច់ទៅតាមអាកាស នៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងនោះជាអ្នកមានចិត្តនឹងធឹង មានកិរិយាប្រព្រឹត្តស្ងប់ ប្រជុំគ្នាអស់ ៥ ថ្ងៃ ថ្វាយបង្គំលាគ្នានឹងគ្នា មានមុខឆ្ពោះទៅកាន់ទិស ហើយចៀសចេញទៅ ។ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ឈ្នះសត្រូវ ព្រះអង្គកម្ចាត់បង់ងងឹត ទ្រង់កើតឡើងក្នុងខណៈនោះ ។ មានយក្សមួយ មានឫទ្ធិច្រើននៅជិតអាស្រមរបស់ខ្ញុំ យក្សនោះ សរសើរព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈប្រាប់ខ្ញុំថា ព្រះពុទ្ធអង្គនុ៎ះ ជាមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើងហើយ ម្នាលអ្នកនិទ្ទិក្ខ អ្នកចូរទៅគាល់ព្រះសម្ពុទ្ធយ៉ាងឆាប់ៗ ។ ខ្ញុំបានឮពាក្យយក្សហើយ មានចិត្តជ្រះថ្លា រៀបចំអាស្រមស្រេចហើយ ក៏ចេញអំពីព្រៃធំក្នុងកាលនោះ ។ កាលបើសំពត់ត្រូវភ្លើងឆេះអស់ហើយ ខ្ញុំចេញអំពីអាស្រមនៅអស់មួយរាត្រី ហើយចូលទៅរកព្រះលោកនាយក ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវលោក គួរទទួលនូវគ្រឿងបូជា ទ្រង់កំពុងប្រកាសសច្ចៈ ៤ សម្តែងនូវអមតបទគឺព្រះនិព្វាន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ កាន់យកផ្កាឈូករីកល្អ ចូលទៅថ្វាយព្រះមហេសី ហើយថ្វាយបង្គំព្រះពុទ្ធ ។ ខ្ញុំបូជាព្រះសម្ពុទ្ធ ជាលោកនាយក ព្រះនាមបទុមុត្តរៈ រួចហើយធ្វើ

ស្បែកខ្លាធៀងស្នាម្ខាង ហើយពោលសរសើរព្រះលោកនាយកថា ព្រះសម្ពុទ្ធ ជាបុគ្គលមិនមានអាសវៈ គង់នៅក្នុងទីនេះ ដោយញាណណា ខ្ញុំសរសើរនូវញាណនោះ អ្នកទាំងឡាយចូរស្តាប់ ខ្ញុំនឹងសម្តែង ។ ព្រះអង្គកាត់នូវខ្សែសំសារវដ្តបានហើយ ទ្រង់ញុំាងសព្វសត្វទាំងឡាយឲ្យឆ្លងផុតបានទៀត ពួកសត្វទាំងនោះ ឆ្លងនូវខ្សែនៃតណ្ហាបាន ព្រោះតែបានស្តាប់ធម៌របស់ព្រះអង្គ ។ មិនតែប៉ុណ្ណោះ ព្រះអង្គជាគ្រូ ជាទីប្រព្រឹត្តទៅ ក្នុងលោកខាងមុខរបស់សត្វទាំងឡាយ ជាទីពឹង ជាប្រទីបដ៏ឧត្តមជាងសត្វជើងពីរ ដូចជាទង់ ឬដូចជាទង់-ជ័យ ពុំនោះសោត ដូចប្រាសាទ ។ ពួកឈ្មួញជាច្រើនក្រុមទាំងប៉ុន្មានក្នុងលោក តែងពោលថា ព្រះអង្គជាបុគ្គលប្រសើរ ប្រកបដោយបញ្ញា ពួកជនទាំងនោះ សុទ្ធតែលុះក្នុងសំណាញ់ញាណរបស់ព្រះអង្គ ។ ព្រះអង្គប្រកបដោយបញ្ញា ទ្រង់ ញុំាងប្រជុំជនច្រើនឲ្យឆ្លងទុក្ខដោយញាណរបស់ព្រះអង្គ ជនទាំងឡាយនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខបាន ព្រោះអាស្រ័យនូវការឃើញព្រះអង្គ ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ក្លិនណានីមួយតែងផ្សាយទៅក្នុងលោក បពិត្រព្រះមហាមុនី ក្លិននោះ ពុំស្មើដោយក្លិនរបស់ព្រះអង្គជាបុញ្ញក្ខេត្តឡើយ ។ បពិត្រព្រះមហាមុនី ព្រះអង្គមានចក្ខុ សូមញុំាងពួកសត្វឲ្យរួចចាកកំណើតតិរច្ឆាននិងនរក សូមសម្តែងនូវសន្តិបទគឺព្រះនិព្វាន ឥតមានបច្ច័យតាក់តែងឲ្យទាន ។

ព្រះលោកវិទូ ព្រះនាមបទុមុត្តរៈ ព្រះអង្គគួរទទួលនូវគ្រឿងបូជា ទ្រង់គង់នៅក្នុងភិក្ខុសង្ឃ ហើយត្រាស់គាថាទាំងនេះថា បុគ្គលណា មានចិត្តជ្រះ

ថា បានបូជាញាណតថាគតដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែងដូចតទៅនេះ បុគ្គលនេះនឹងត្រេកអរក្នុងទេវលោកអស់ ៣០ ពាន់កប្ប នឹងបានជាស្តេចចក្កពត្តិ អស់មួយពាន់ដង ។

ខ្ញុំជាអ្នកមានលាភ ដែលគេត្រូវបានដោយប្រពៃបានហើយ ព្រោះបានញុំាងព្រះសម្ពុទ្ធ ព្រះអង្គមានវត្តដ៏ល្អ ឲ្យត្រេកអរ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញចោលហើយ ភពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទេនត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឧទេនត្ថេរាបទាន ។**

## ឧទ្ទាន

តិស្សមេត្តេយ្យត្ថេរាបទាន ១ បុណ្ណកត្ថេរាបទាន ១ មេត្តគុត្ថេរាបទាន ១ ធោតកត្ថេរាបទាន ១ ឧបសីវត្ថេរាបទាន ១ នន្ទកត្ថេរាបទាន ១ ហេមកត្ថេរាបទាន ១ ជាគម្រប់ ៧ ក្នុង

អបទាននោះ ។ គោទេយ្យត្ថេរាបទាន ១ ជតុកណ្ណិកត្ថេរាបទាន ១ ឧទេនត្ថេរាបទាន ១ សុទ្ធតែមានយសច្រើន ក្នុងមេត្តេយ្យវគ្គនេះ មានគាថា ៣៨៣ ។

**ចប់ មេត្តេយ្យវគ្គ ទី ៤១ ។**

## អដ្ឋកថា

## ឧទេនត្ថេរាបទាន

[ ១១០ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១០ ដូចតទៅនេះថា អបទានរបស់ព្រះឧទេនត្ថេរមានពាក្យផ្តើមថា **ហិមវន្តស្សាវិទូរេ** ដូច្នេះ ។ ក្នុងអបទាននោះ មានសេចក្តីប្លែកត្រឹមតែប៉ុណ្ណោះថា លោកបានបួសជាតាបស អាស្រ័យភ្នំបទុមក្បែរព្រៃហិមពាន្ត បានកាន់យកផ្កាឈូកមកបូជាដល់ព្រះមានព្រះភាគ ។ ពាក្យដ៏សេសក្នុងទីទាំងពួងមានអត្ថងាយយល់ហើយ ។

អដ្ឋកថាឧទេនត្ថេរាបទាន ចប់

មេត្តេយ្យវគ្គទី ៤១ ចប់

# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទាន

## ចតុត្ថភាគ

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## ភទ្ទាលិវគ្គទី ៤២

## ភទ្ទាលិត្ថេរាបទានទី ១

[ ១ ] *ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ជាបុគ្គលខ្ពង់ខ្ពស់ ប្រកបដោយសេចក្ដីករុណា ជាអ្នកប្រាជ្ញ ប្រាថ្នាសេចក្ដីស្ងប់ស្ងាត់ ព្រះអង្គប្រសើរក្នុងលោក ទ្រង់បានស្ដេចចូលទៅក្នុងព្រៃហិមពាន្ត ។ ព្រះលោកនាយកព្រះនាមសុមេធៈ ជាបុរសដ៏ប្រសើរ លុះទ្រង់ស្ដេចចូលទៅក្នុងព្រៃហិមពាន្តហើយគង់ពែនភ្នែន ។ ព្រះពុទ្ធជាលោកនាយក ព្រះនាមសុមេធៈអង្គនោះ ជាបុរសដ៏ប្រសើរ ទ្រង់គង់ចូលសមាធិអស់ ៧ យប់ ៧ ថ្ងៃ ។ ខ្ញុំរែកអម្រែកបរិក្ខារសំដៅចូលទៅរកព្រៃ ហើយឃើញព្រះសម្ពុទ្ធក្នុងព្រៃនោះ ព្រះអង្គមានឱឃៈឆ្លងហើយ មិនមានអាសវៈ ។ គ្រានោះ ខ្ញុំកាន់អំបោស បោសអាស្រម ហើយលើកឈើ ៤ កំណាត់បញ្ឈរធ្វើជាបារាំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្កាឈើប្រក់បារាំ ហើយថ្វាយបង្គំព្រះលោកនាយក ។ ពួកជនតែងហៅនូវព្រះសម្ពុទ្ធអង្គណា ដែលទ្រង់មានបញ្ញាដូចផែនដី មានបញ្ញាល្អថាសុមេធៈ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយបានសម្ដែងគាថាដូចខាងក្រោមនេះ ។ ពួកទេវតាទាំងអស់ បានដឹងព្រះពុទ្ធដីការបស់ព្រះពុទ្ធហើយ*

ក៏មកជួបជុំប្រាប់គ្នាថា ព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គមានចក្ខុ នឹងសម្តែងធម៌ ដោយឥតសង្ស័យ ។ ព្រះសម្ពុទ្ធព្រះនាមសុមេធះ ព្រះអង្គគួរទទួលនូវគ្រឿងបូជា ទ្រង់គង់ក្នុងកណ្តាលពួកទេវតា ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណាបាំងបារាំដែលប្រក់ដោយផ្កាឈើ ថ្វាយតថាគត អស់ ៧ ថ្ងៃ តថាគតនឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរចាំស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនោះ បើបានកើតជាទេវតា ឬកើតជាមនុស្ស នឹងមានសម្បុរដូចមាស ជាអ្នកមានភោគៈច្រើន បរិភោគកាមគុណជាប្រក្រតី ។ ដំរី ៦០ ពាន់ ដែលគេស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ជាដំរីមានខ្សែជង្គន់មាស ប្រកបដោយគ្រឿងតាក់តែងក្បាល ជាវិការៈនៃមាស ដែលពួកហ្មដំរី មានដៃកាន់លំពែងស្នែងក្របីនិងកង្វេរ ជិះមកកាន់ទីបម្រើនរៈនេះរាល់ពេលល្ងាចព្រឹក ។ ឯនរៈនេះនឹងមានពួកដំរីនោះចោមរោម ហើយសប្បាយរីករាយ សេះ ៦០ ពាន់ ដែលគេស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់បែប ជាសេះអាជានេយ្យ និងសេះសិន្ធព ពីកំណើត ជាពាហនៈលឿន មានពួកនាយសារថី ទ្រទ្រង់នូវខែលនិងធ្នូឡើងជិះ នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ រថ ៦០ ពាន់ ដែលគេតាក់តែងដោយប្រដាប់គ្រប់យ៉ាង បិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ គេចងល្អហើយ លើកទង់ជ័យ មានពួកនាយសារថី មានដៃកាន់ធ្នូនិងខែលឡើងជិះ នឹងចោមរោមបុគ្គលនោះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ស្រុកសួយ ៦០ ពាន់ បរិបូណ៌ដោយសព្វគ្រប់ ជាស្រុកមានទ្រព្យនិងស្រូវជាច្រើន ជារបស់សម្រេចល្អដោយប្រការ

ទាំងពួង នឹងកើតមានប្រាកដសព្វកាល នេះជាផលនៃពុទ្ធបូជា ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពលថ្មើរជើង នឹងមកចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ បុគ្គលនោះនឹងរីករាយក្នុងទេវលោកអស់ ១.៨០០ កប្ប នឹងបានកើតជាស្តេចចក្រពត្តិអស់ ១ ពាន់ដង ។ នឹងសោយទេវរាជ្យអស់ ៣ រយដង នឹងសោយបទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ។ កន្លងទៅ ៣០ ពាន់កប្ប នឹងមានព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលនៃព្រះបាទឱក្កាករាជត្រាស់ដឹងក្នុងលោក ។ ( ព្រះសុមេធសម្ពុទ្ធទ្រង់ត្រាស់ថា ) ខ្ញុំនឹងបានទទួលមត៌កក្នុងធម៌ ជាឱរសដែលធម៌និម្មិតហើយរបស់ព្រះសាស្តានោះ ជាបុគ្គលកំណត់ដឹងនូវអាសវៈទាំងពួង ឥតមានអាសវៈ ។

ក្នុងរវាង ៣០ ពាន់កប្ប ខ្ញុំបានឃើញព្រះលោកនាយក អាស្រ័យនូវចន្លោះនេះ ហើយស្វះស្វែងរកនូវអមតបទគឺនិព្វាន ។ ខ្ញុំឈ្មោះថា មានលាភហើយ អត្តភាពជាមនុស្សឈ្មោះថាខ្ញុំបានល្អហើយ ព្រោះខ្ញុំបានដឹងនូវពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ វិជ្ជាបីខ្ញុំបានដល់តាមលំដាប់ហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ លុះខ្ញុំពោលសរសើរចំពោះ ព្រះញាណរួចហើយ ក៏បានដល់នូវអមតបទគឺនិព្វាន ។ ខ្ញុំចូលទៅកើតក្នុងកំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ខ្ញុំរមែងបានសេចក្តីសុខក្នុងទីទាំងពួង នេះជាផលរបស់ខ្ញុំក្នុងការពោលសរសើរញាណ ។ នេះរាងកាយជាខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុត

កំពុងប្រព្រឹត្តទៅ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវចំណង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកច្ចាលិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កច្ចាលិត្ថេរាបទាន ។**

# ឯកច្ចត្ថិយត្ថេរាបទានទី ២

[ ២ ] ខ្ញុំបានធ្វើអាស្រមដ៏ល្អ ចាក់ដីខ្សាច់ដ៏ស្អាត ហើយសាងបណ្ណ-សាលាយ៉ាងល្អ ទៀបច្នេរស្ទឹងចន្ទភាគា ។ ស្ទឹង ( នោះ ) មានច្រាំងទាប មានកំពង់រាបស្មើ ជាទីរីករាយនៃចិត្ត បរិបូណ៌ដោយសត្វត្រីនិងអណ្តើក មានសត្វក្រពើនៅអាស្រ័យ ។ ពួកសត្វខ្លាឃ្មុំ ក្ងោក ខ្លាដំបង ករវិក និងសត្វសាលិកា តែងបន្លឺសំឡេងសព្វៗកាល សត្វទាំងនុ៎ះ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកតាវៅ មានសំឡេងពីរោះ និងហង្សមានសូរសេព្ទពីរោះ តែងយំឆ្លើយឆ្លងគ្នា ( សព្វៗកាល ) សត្វទាំងនុ៎ះ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អក្នុងទីនោះ ។ ពួកសីហៈ ខ្លាធំ ជ្រូក កុក ឆ្កែព្រៃ និងខ្លារខិន តែងបន្លឺសំឡេងក្បែរជ្រោះភ្នំ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកម្រឹគទ្រាយ ម្រឹគខ្ទីង ចចក និងជ្រូកជាច្រើន តែងបន្លឺសំឡេងក្បែរជ្រោះភ្នំ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមរាជព្រឹក្ស ដើមចម្ប៉ា ដើមប្រទៀង ដើមឈើភ្លើង ដើមរំដួល និងដើមអសោក ក៏ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមអង្កោល ដើមយុថ្កា ដើមសត្តបាណ៌ ដើមបាស ដើមកន្ទឹសនិងដើមកណិការ បញ្ចេញផ្កាក្បែរអាស្រមរបស់ខ្ញុំ ។ ពួកដើមខ្ទឹង ដើមរាំងភ្នំ ដើមស្រល់ និងដើមស្វាយស មានផ្ការីកនៅក្នុងទីនោះ ក្លិនជាទិព្វសាយកាយ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមពោធិ ដើមធ្នង់ ដើមជន្ទាត់ដៃ ដើមរាំងភ្នំ និងដើមផ្កាថ្ងៅ មានផ្ការីកធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមស្វាយ ដើមព្រីង ដើមតង្កៀបក្តាមដើមរាំងអន្ទក់ និងដើមក្ទៅនាង ក្លិនជាទិព្វក្រអូបសាយកាយ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមអសោក ដើមខ្វិត្ត ដើមទួនស្រី មានផ្ការីក ក្លិនជាទិព្វ

សាយកាយ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ដើមក្ទម្ព ដើមចេក ដើមសណ្តែកព្រៃ ដែលគេដាំទ្រទ្រង់ផ្លែជានិច្ច ធ្វើអាស្រមរបស់ខ្ញុំល្អ ។ ពួកដើមសម៉ ដើមកន្ទួតព្រៃ ដើមស្វាយ ដើមព្រីង ដើមសម៉ពិភេទក៍ ដើមក្របៅ ដើមពក់ខ្មៅ ដើមញ្ញៅមានផ្លែជិតអាស្រមរបស់ខ្ញុំ ។ នៅទីជិតស្រះបោក្ខរណី មានកំពង់រាបស្មើ ជាទីរីករាយចិត្ត ដ៏ដេរដាសដោយលំចង់ ផ្កាឈូក និងផ្កាឧប្បល ។ ពួកដើមឈូក កំពុងចាប់ផ្លែ ( នោប ) ពួកដើមឈើមានកេសរឯទៀតៗ បញ្ចេញផ្ការីក មានទង ដើមកណ្ណិកា មានស្លឹកជ្រុះបញ្ចេញផ្កានៅទៀបអាស្រមរបស់ខ្ញុំ ។ ពួកត្រីស្វាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ និងត្រីផ្ទិន កំពុងត្រាច់ទៅមក ក្នុងទឹកថ្លា ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមនយិតាព្រឹក្ស ដើមស្វាយក្រអូប ដើមការកេត មាននៅទៀបលំដាប់ប្រាំង ក្លិនជាទិព្វសាយកាយទៅធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ក្លិនជាទិព្វសាយកាយ ហូរចេញមកពីក្រអៅឈូកនិងមើមឈូក ដូចទឹកដោះរាវនិងទឹកដោះថ្លា ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ផ្នូកខ្សាច់ដ៏ល្អ ដេរដាស ជ្រួតជ្រាបដោយទឹកក្នុងទីនោះ និងដើមសេតព្រឹក្សមានផ្កាពោយចុះ ក៏ផ្ការីក ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកតាបសទាំងអស់ពេញទៅដោយការៈ គឺផ្នួងសក់ ស្លៀកសំពត់ស្បែកខ្លាទាំងទ្រទ្រង់នូវសំពត់សម្បកឈើ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ( ពួកតាបសទាំងនោះ ) ក្រឡេកមើលប្រមាណមួយជួរនឹម ជាបុគ្គលមានបញ្ញាចាស់ មានកិរិយាប្រព្រឹត្តដ៏ស្ងប់ស្ងាត់ជាប្រក្រតី មិនមានសេចក្តីប្រាថ្នាក្នុងការជាប់ចំពាក់ដោយកាម នៅក្នុងអាស្រមរបស់ខ្ញុំ ។ ពួកតាបសទាំងអស់នោះ មានក្រចកនិងរោមក្លៀកដុះវែងៗ

មានមន្ទិលផ្សេញ មានធូលីលើក្បាល ទ្រទ្រង់នូវធូលីនិងភក់ នៅក្នុងអាស្រម របស់ខ្ញុំ ។ ពួកតាបសទាំងនោះ ដល់នូវអភិញ្ញាបារមី សុទ្ធតែត្រាច់ទៅឰដ៏អាកាសបាន តាបសទាំងនុ៎ះហោះទៅកាន់អាកាស ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ គ្រានោះ ខ្ញុំមានពួកសិស្សទាំងនោះចោមរោមជាបរិវារ នៅក្នុងព្រៃធំ ស្ងៀមស្ងាត់ស្ងប់ស្ងាល់ ដោយសេចក្តីរីករាយក្នុងឈាន ឥតដឹងយប់និងថ្ងៃ ។ សម័យនោះព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាអ្នកប្រាជ្ញធំ ព្រះអង្គជានាយកនៃសត្វលោក ទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ទ្រង់កើតឡើងក្នុងលោក គ្រានោះ មានសិស្សមួយរូបចូលមកក្នុងសម្នាក់ខ្ញុំ សិស្សនោះមានប្រាថ្នានឹងរៀននូវមន្តទាំងឡាយឈ្មោះឆឡង្គលក្ខណៈ ។ ព្រះពុទ្ធព្រះនាមអត្ថទស្សី ជាអ្នកប្រាជ្ញដ៏ប្រសើរផុតទ្រង់កើតក្នុងលោក កំពុងប្រកាសនូវសច្ចៈ ៤ ហើយសម្តែងនូវអមតបទគឺនិព្វាន ។ ខ្ញុំមានសេចក្តីត្រេកអរ ស្រស់ស្រាយរីករាយ ជាទីអាស្រ័យនៅនៃពួកអ្នកមានចិត្តជាធម៌ បានចេញអំពីអាស្រម ហើយពោលពាក្យនេះថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ទ្រង់មានលក្ខណៈដ៏សំខាន់ ៣២ ប្រការដូច្នេះ អ្នករាល់គ្នាចូរមក យើងនឹងទៅក្នុងសម្នាក់នៃព្រះសម្មាសម្ពុទ្ធ ។ ពួកតាបសទាំងនោះ ជាអ្នកធ្វើតាមឱវាទខ្ញុំ ដល់នូវបារមីក្នុងព្រះសទ្ធម្ម ជាអ្នកស្វែងរកនូវប្រយោជន៍ដ៏ប្រសើរ បានទទួលថាសាធុ ។ ពួកតាបសទាំងនោះ សឹងពេញទៅដោយភារៈគឺផ្នួងសក់ ស្លៀកពាក់ស្បែកខ្លា កំពុងស្វែងរកប្រយោជន៍ដ៏ឧត្តម ចេញចាកព្រៃក្នុងកាលនោះ ។ គាប់ជួនសម័យនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី ព្រះអង្គមានយសធំ កំពុងប្រកាសសច្ចៈ ៤ សម្តែងនូវ

អមតបទគឺនិព្វាន ។ ខ្ញុំបានកាន់ស្វេតច្ឆត្រ បាំងថ្វាយព្រះពុទ្ធដ៏ប្រសើរ លុះបាំងថ្វាយអស់មួយថ្ងៃហើយ ខ្ញុំថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ ចំណែកខាងព្រះមានព្រះភាគព្រះនាមអត្ថទស្សី ទ្រង់ជាច្បងក្នុងលោក ជានរៈដ៏ប្រសើរ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយត្រាស់នូវគាថាទាំងនេះថា

បុគ្គលណាមានចិត្តជ្រះថ្លា បានបាំងឆត្រថ្វាយតថាគត ដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនេះកាលកើតជាទេវតា ឬកើតជាមនុស្ស ពួកជននឹងបាំងឆត្រឲ្យសព្វៗកាល នេះជាផលនៃការថ្វាយឆត្រ ។ បុគ្គលនោះ នឹងរីករាយក្នុងទេវលោកអស់ ៧៧ កប្ប នឹងបានជាស្តេចចក្កពត្តិអស់ ១.០០០ ដង ។ ម្យ៉ាងទៀត បុគ្គលនោះ នឹងបានសោយទេវរាជ្យជាស្តេចនៃទេវតាអស់ ៧៧ ដង នឹងសោយបទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ កន្លងទៅ ១.៨០០ កប្ប ព្រះពុទ្ធព្រះនាមគោតម ជាសក្យដ៏ប្រសើរបំផុត ព្រះអង្គមានបញ្ញាចក្ខុ ទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ នឹងកើតឡើង ។ បុគ្គលនោះ នឹងបានទទួលមត៌កក្នុងធម៌របស់ព្រះពុទ្ធអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

កាលណាខ្ញុំបានធ្វើនូវកុសលកម្ម គឺបាំងឆត្រថ្វាយព្រះពុទ្ធ ក្នុងចន្លោះនេះ ខ្ញុំមិនដែលស្គាល់ស្វេតច្ឆត្រដែលគេមិនបាំងឲ្យខ្ញុំឡើយ ។ នេះរាងកាយជាទីបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំកំពុងប្រព្រឹត្តទៅ ចំណែកការបាំងឆត្រលើក្បាលអស់កាលជានិច្ចមានដរាបដល់ថ្ងៃនេះ ។ ឱហ្ន៎! អំពើល្អខ្ញុំធ្វើដោយ

ប្រពៃហើយចំពោះព្រះពុទ្ធព្រះនាម អត្ថទស្សី ព្រះអង្គប្រកបដោយតាទិគុណ ខ្ញុំមានអាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើតាមរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកច្ឆត្តិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ ឯកច្ឆត្តិយត្ថេរាបទាន ។

# តិណសូលកជាតនិយត្ថេរាបទានទី៣

[ ៣ ] កាលនោះ ខ្ញុំបានពិចារណានូវជាតិ ជរា និងមរណៈ ខ្ញុំតែ-ម្នាក់ឯងចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ។ កាលខ្ញុំសញ្ចរទៅតាមលំដាប់ បានចូលទៅកាន់ច្រាំងនៃទន្លេគង្គា ក៏ឃើញផែនដីដុះពេញស្មើ នៅទៀបច្រាំងទន្លេគង្គានោះ ។ ខ្ញុំបានសាងអាស្រមត្រង់ទីនោះ ហើយនៅក្នុងអាស្រមរបស់ខ្ញុំ ទីចង្រ្កមដែលខ្ញុំបានធ្វើល្អហើយ សឹងប្រកបដោយពួកសត្វស្លាបផ្សេងៗ ។ ពួកសត្វតែងចូលមកជិតខ្ញុំផង បន្លឺសំឡេងគួរឲ្យចាប់ចិត្តផង ខ្ញុំត្រេកអររីករាយជាមួយនឹងសត្វទាំងនោះ ហើយនៅក្នុងអាស្រម ។ ស្តេចម្រឹគមានជើង ៤ នៅជិតអាស្រមរបស់ខ្ញុំ ស្តេចម្រឹគនោះតែងចេញអំពីលំនៅ មកស្រែកគំរាមដូចជារន្ទះ ។ កាលស្តេចម្រឹគបន្លឺសំឡេងឡើង ខ្ញុំក៏មានសេចក្តីរីករាយកើតឡើង ខ្ញុំកំពុងស្វះស្វែងរកស្តេចម្រឹគ ស្រាប់តែប្រទះឃើញព្រះលោកនាយក ។ លុះខ្ញុំឃើញព្រះពុទ្ធព្រះនាមតិស្សៈ ជាទេវតាក្រៃលែងជាងទេវតា ជានាយកប្រសើររបស់សត្វលោកហើយ ខ្ញុំមានចិត្តត្រេកអររីករាយ បានបូជាកេសរផ្កាខ្ទឹង ។ ខ្ញុំសរសើរព្រះលោកនាយក ព្រះអង្គកំពុងរុងរឿង ដូចជាព្រះអាទិត្យកាលរះឡើង ឬដូចជាស្តេចឈើមានផ្ការីក ពុំនោះសោតដូចជាផ្កាយព្រឹកថា បពិត្រព្រះសព្វញ្ញូ ព្រះអង្គទ្រង់ធ្វើខ្ញុំ ព្រមទាំងទេវតាឲ្យរុងរឿងដោយញាណរបស់ព្រះអង្គ ពួកជនបានធ្វើព្រះអង្គឲ្យត្រេកអរហើយ រមែងរួចចាកជាតិ ។ ពួកជនដែលត្រូវរាគៈនិងទោសៈគ្របសង្កត់ហើយ រមែងធ្លាក់ចុះក្នុងអវិចិនរក ព្រោះកិរិយាមិនឃើញនូវព្រះសព្វញ្ញុពុទ្ធ ទ្រង់ឃើញហេតុទាំងពួង ។ ពួកសត្វទាំងអស់ រួចស្រឡះចាកកពពាល់ត្រូវនូវអមតបទ គឺព្រះនិព្វានព្រោះអាស្រ័យ

នូវការឃើញព្រះអង្គ ជាសព្វញ្ញូលោកនាយក ។ កាលណាព្រះពុទ្ធទាំងឡាយ ព្រះអង្គមានបញ្ញាចក្ខុ ជាអ្នកធ្វើនូវពន្លឺកើតឡើង ព្រះពុទ្ធទាំងឡាយនោះរមែង ជុតកិលេស ហើយបង្ហាញនូវពន្លឺក្នុងកាលនោះ ។ ខ្ញុំសរសើរព្រះសម្ពុទ្ធព្រះ នាមតិស្សៈជានាយកដ៏ប្រសើររបស់សត្វលោក ហើយបានបូជាផ្កាម្ទិះរួត ដោយ ចិត្តរីករាយ ។ ឯព្រះពុទ្ធព្រះនាមតិស្សៈជានាយក ដ៏ប្រសើរនៃសត្វលោក ទ្រង់បានជ្រាបច្បាស់នូវសេចក្តីត្រិះរិះរបស់ខ្ញុំ ទ្រង់គង់លើអាសនៈរបស់ព្រះ អង្គ ហើយសម្តែងនូវគាថាទាំងនេះថា

បុគ្គលណាមានសេចក្តីជ្រះថ្លា បានបាំងតថាគតដោយផ្កាទាំងឡាយដោយ ដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគត សម្តែងចុះ ។ បុគ្គលនោះនឹងសោយទេវរាជ្យ ជាស្តេចនៃទេវតាអស់ ២៥ ដង នឹងបានជាស្តេចចក្កពត្តិអស់ ៧៥ ដង ។ នឹងបានសោយប្រទេសរាជ្យ ដ៏ធំ ទូលាយរាប់ជាតិមិនអស់ នេះជាអានិសង្សនៃកម្ម គឺកិរិយាបូជានូវផ្កានោះ ។ បុរសនេះ ដែលបានបាំងតថាគតដោយផ្កាទាំងឡាយ ទាំងល្ងាចទាំងព្រឹកនឹង ទៅជាអ្នកប្រកបដោយបុញ្ញកម្ម ផលនឹងកើតប្រាកដចំពោះមុខ ។ បុរសនេះ ប្រាថ្នាវត្ថុណាៗដោយកាមទាំងឡាយ វត្ថុនោះៗ នឹងកើតប្រាកដ នឹងញុំាង សេចក្តីប្រាថ្នាឲ្យពេញលេញ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំដុតបំផ្លាញពួកកិលេសចោលហើយ ជាអ្នកដឹងច្បាស់ ទាំងមានស្មារតី អង្គុយលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ខ្ញុំកំពុងដើរ កំពុងដេក កំពុងអង្គុយឬឈរ ក៏នឹកទៅរកព្រះពុទ្ធដ៏ប្រសើរក្នុងកាលនោះ ។ ក្នុងទីនោះ

ខ្ញុំឥតមានសេចក្តីខ្វះខាត ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ និងសេនា-សនប្បច្ច័យសោះឡើយ នេះជាផលនៃពុទ្ធបូជា ។ ឥឡូវនេះ ខ្ញុំនោះបានដល់នូវអមតបទគឺព្រះនិព្វានជាគុណជាតស្ងប់ប្រសើរ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសូលកធាទនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តិណសូលកធាទនិយត្ថេរាបទាន ។**

# ភទ្ទាលិវគ្គ ទី ៤២

## អដ្ឋកថា ភទ្ទាលិត្ថេរាបទាន ជាដើម

[ ១-៣ ] អបទានទី ១ ទី ២ និងទី ៣ ក្នុងវគ្គទី ៤២ មានអត្ថដឹងបានងាយ តាមគន្លងនៃអត្ថនោះឯង ។

អដ្ឋកថាភទ្ទាលិត្ថេរាបទានជាដើម ចប់

# មធុមំសទាយកត្ថេរាបទាន ទី ៤

[ ៤ ] ខ្ញុំជាអ្នកសម្លាប់ជ្រូកនៅក្នុងក្រុងពន្ធុមតី បានចម្អិនគ្រឿងទេស ហើយរោយលើសាច់មានរសឆ្ងាញ់ ។ ខ្ញុំចូលទៅកាន់ទីប្រជុំ ហើយបានយកបាត្រមួយ មកដាក់បំពេញដោយសាច់ឆ្ងាញ់នោះ ហើយប្រគេនដល់ព្រះភិក្ខុសង្ឃ ។ កាលនោះ ភិក្ខុអង្គណាជាថេរៈចាស់ជាងគេ ខ្ញុំក៏ប្រគេនភិក្ខុនោះ ខ្ញុំបាននូវសេចក្តីសុខដ៏ធំទូលាយ ដោយសារការបំពេញបាត្រ ដោយសាច់ឆ្ងាញ់នោះ ។ ខ្ញុំបានទទួលនូវសម្បត្តិទាំងពីរ ត្រូវកុសលមូលដាស់តឿន ក៏បានដុតបំផ្លាញកិលេសក្នុងបច្ឆិមភពដែលកំពុងប្រព្រឹត្តទៅ ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាក្នុងទីនោះហើយ បានទៅកើតឯឋានតាវត្តិង្ស ខ្ញុំធីក្តីផឹកក្តី តែងបានសេចក្តីសុខដ៏ធំទូលាយក្នុងឋាននោះ ។ ខ្ញុំតែងរឭកឃើញនូវបុព្វកម្មក្នុងមណ្ឌបឬទៀបគល់ឈើ ភ្លៀងគឺបាយនិងទឹកតែងបង្អុរចុះដល់ខ្ញុំក្នុងខណៈនោះ ។ នេះរាងកាយ ខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ចំណែកខាងបាយនិងទឹក រមែងបង្អុរចុះមកដើម្បីខ្ញុំក្នុងទីនេះសព្វៗកាល ។ ខ្ញុំអន្ទោលទៅក្នុងភព កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ដោយការឲ្យនូវសាច់មានរសឆ្ងាញ់នោះឯង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវសាច់មានរសឆ្ងាញ់នោះឯង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់

ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមធុមំសទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ មធុមំសទាយកត្ថេរាបទាន ។

# អដ្ឋកថា

# មធុមំសទាយកត្ថេរាបទាន

[ ៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះថា អបទានរបស់ព្រះមធុមំសទាយកត្ថេរ មានពាក្យផ្ដើមថា **ឆគរេ ពន្ធុមតិយា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សូករិកោ** បានដល់ លក់សាច់ជ្រូកចិញ្ចឹមជីវិត ។ បទថា **ឧក្កោដកំ រន្ធយិត្វា** សេចក្ដីថា ខ្ញុំស្ងោរសាច់វាវនិងសួត ហើយផ្សំ គឺដាក់ក្នុងសាច់ដែលផ្សំទឹកឃ្មុំ អធិប្បាយថា យកសាច់នោះ ដាក់ពេញបាត្រ ហើយប្រគេនដល់ភិក្ខុសង្ឃ ដោយបុញ្ញកម្មនោះ ក្នុងពុទ្ធុប្បាទកាលនេះ ខ្ញុំបួសហើយ បានសម្រេចអរហត្ត ។

**អដ្ឋកថាមធុមំសទាយកត្ថេរាបទាន ចប់ ។**

## នាគបល្លវកត្ថេរាបទាន ទី ៥

[ ៥ ] ខ្ញុំនៅក្នុងឧទ្យានរបស់ព្រះរាជាក្នុងក្រុងពន្ធុមតី ឯព្រះលោកនាយក គង់ជិតអាស្រមរបស់ខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកស្លឹក ខ្ចីទៅបូជាព្រះពុទ្ធ ហើយថ្វាយបង្គំព្រះសុគត ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាស្លឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគបល្លវកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

### ចប់ នាគបល្លវកត្ថេរាបទាន ។

## ឯកទីបិយត្ថេរាបទាន ទី ៦

[ ៦ ] កាលព្រះសុគតព្រះនាមសិទ្ធត្ថៈជាលោកនាយក ទ្រង់បរិនិព្វាន ហើយ ពួកមនុស្សនិងទេវតាទាំងអស់ នាំគ្នាបូជាព្រះពុទ្ធដ៏ឧត្តមជាងសត្វជើង ពីរ ។ ក៏កាលដែលព្រះសិទ្ធត្ថៈជាលោកនាយកដែលគេលើកដាក់លើជើងថ្ករ ហើយ ពួកមនុស្សព្រមទាំងទេវតា នាំគ្នាបូជាជើងថ្ករនៃព្រះសាស្តាតាមសម-គួរដល់កម្លាំងនៃសទ្ធារបស់ខ្លួន ។ ខ្ញុំបានអុជប្រទីបក្នុងទីជិតជើងថ្ករ ប្រទីបរបស់ខ្ញុំឆេះនៅដរាបព្រះអាទិត្យរះឡើង ។ ខ្ញុំបានលះបង់នូវរាងកាយជារបស់មនុស្ស ទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្លួនធ្វើល្អហើយនោះផង ដោយការតម្កល់ចេតនានោះផង ។ វិមានរបស់ខ្ញុំដែលបុញ្ញកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ គេរមែងស្គាល់ថា វិមានឈ្មោះឯកទីបៈ ព្រោះមានប្រទីប ១ សែនរុងរឿងក្នុងវិមានរបស់ខ្ញុំនោះ ។ រាងកាយរបស់ខ្ញុំ រមែងរុងរឿងសព្វកាល ដូចព្រះអាទិត្យកាលរះឡើង ពន្លឺសរីរៈរបស់ខ្ញុំរមែងមានសព្វ ៗ កាល ជាងពន្លឺទាំងឡាយ ខ្ញុំមានភ្នែកមើលទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំ កន្លងភ្នំមួយរយយោជន៍ជុំវិញ ។ ខ្ញុំបានត្រេកអរក្នុងទេវលោកអស់ ៧៧ ដង បានសោយរាជ្យជាស្តេចទេវតាអស់ ៣១ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិអស់ ២៨ ដង សោយបទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ កាលខ្ញុំច្យុតចាកទេវលោកមកកើតក្នុងផ្ទៃមាតា សូម្បីកាលខ្ញុំនៅក្នុងផ្ទៃមាតា ភ្នែករបស់ខ្ញុំឥតខូចខាតឡើយ ។ ខ្ញុំមានអាយុ ៤ ឆ្នាំ បានចូលទៅកាន់ផ្នួស មិនទាន់បានកន្លះខែ ខ្ញុំក៏បានសម្រេចអរហត្ត ។ ខ្ញុំបានជម្រះទិព្វចក្ខុ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ កិលេសទាំងអស់ខ្ញុំបានផ្តាច់ផ្តិលហើយ នេះជាផល

នៃប្រទីបមួយ ។ ខ្ញុំមើលឃើញទៅខាងក្រៅជញ្ជាំង ទាំងខាងក្រៅភ្នំ កន្ទង ភ្នំទាំងអស់ នេះជាផលនៃប្រទីបមួយ ។ ប្រទេសទាំងឡាយដែលមិនរាបស្មើ ត្រឡប់ទៅជារាបស្មើសម្រាប់ខ្ញុំ ខ្ញុំមិនមានងងឹត ខ្ញុំមិនដែលឃើញងងឹតអ័ព្ទ ឡើយ នេះជាផលនៃប្រទីបមួយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះ ហេតុដែលខ្ញុំបានថ្វាយប្រទីបក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃប្រទីបមួយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្ទឹង ។

ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទីបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឯកទីបិយត្ថេរាបទាន ។**

## ឧច្ចង្គបុប្ផិយត្ថេរាបទាន ទី ៧

[ ៧ ] កាលនោះ ខ្ញុំជាអ្នកក្រងផ្កានៅក្នុងក្រុងពន្ធុមតី ខ្ញុំបានដាក់ផ្កាពេញថ្នក់ ហើយដើរសំដៅផ្សារ ។ សម័យនោះ ព្រះមានព្រះភាគជាលោកនាយក មានភិក្ខុសង្ឃចោមរោម កំពុងស្តេចទៅដោយអានុភាពដ៏ធំ ។ ខ្ញុំបានឃើញព្រះវិបស្សី ព្រះអង្គបំភ្លឺលោក ទ្រង់ចម្លងសត្វលោក ហើយយកផ្កាអំពីថ្នក់បូជាព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធដ៏ប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧច្ចង្គបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧច្ចង្គបុប្ផិយត្ថេរាបទាន ។**

# យាគុទាយកត្ថេរាបទានទី ៨

[ ៨ ] កាលនោះ ខ្ញុំនាំភ្ញៀវរបស់ខ្ញុំមកកាន់ស្រុកតូច បានឃើញស្ទឹងមានទឹកពេញព្រៀប ហើយដើរចូលទៅកាន់អារាមរបស់សង្ឃ ។ ភិក្ខុទាំងនោះជាអ្នកនៅក្នុងព្រៃ ទ្រទ្រង់នូវធុតង្គៈ មានឈាន មានចីវរ ដ៏សៅហ្មង ត្រេកអរក្នុងទីស្ងាត់ ជាអ្នកប្រាជ្ញ នៅក្នុងអារាមរបស់សង្ឃ ។ ភិក្ខុទាំងនោះ លោកជាអ្នករួចស្រឡះល្អហើយ ប្រកបដោយតាទិគុណ មានដំណើរដាច់ហើយ ភិក្ខុទាំងនោះមានស្មឹងស្មះផ្លូវ ក៏ខានទៅបិណ្ឌបាត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ មានចិត្តត្រេកអរ ហើយធ្វើអញ្ជលីយកអង្ករធ្វើបបរ ប្រគេនយាគុ-ទាន ខ្ញុំមានចិត្តជ្រះថ្លា ប្រគេនបបរដែលចម្អិនហើយដោយដៃរបស់ខ្លួន ប្រាវព្ធកម្មរបស់ខ្លួន បានទៅកើតឯឋានតាវត្តិង្ស ។ វិមានជាវិការៈនៃកែវមណី កើតសម្រាប់ខ្ញុំក្នុងពួកទេវតាឋានតាវត្តិង្ស ខ្ញុំប្រកបដោយពួកនារី ត្រេកអរក្នុងវិមានដ៏ប្រសើរ ។ ខ្ញុំបានជាព្រះឥន្ទ សោយរាជ្យជាស្តេចនៃទេវតាអស់ ៣៣ ដងបានសោយរាជ្យដ៏ធំ ជាស្តេចចក្កពត្តិអស់ ៣០ ដង បានសោយប្រទេស-រាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំសោយនូវយសក្នុងទេវលោក និងមនុស្សលោក ។ ក្នុងកាលដែលដល់នូវភពជាទីបំផុត ខ្ញុំបានលះបង់សម្បត្តិអស់ព្រមទាំងសក់ដែលកោរកាត់ រួចហើយចូលទៅកាន់ផ្នួស ។ ម្យ៉ាងទៀត កាលខ្ញុំពិចារណានូវសាកសពដោយកិរិយាអស់ទៅនិងការសូន្យទៅ ក៏បានសម្រេចព្រះអរហត្ត ដោយការបំពេញនូវសិក្ខាក្នុងកាលមុន ។ ទានដ៏ប្រសើរខ្ញុំបានឲ្យហើយដោយប្រពៃ ទានកើតឡើងដោយដៃ ខ្ញុំបានប្រកបប្រពៃហើយ ខ្ញុំជាបុគ្គលបានដល់នូវអចលបទ គឺនិព្វានដោយយាគុទាននោះឯង ។ ខ្ញុំមិនដែល

ស្គាល់សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ការឈឺចុកចាប់ ក្រវល់ក្រវាយ និងសេចក្ដីក្ដៅក្រហាយចិត្តដែលកើតឡើយ នេះជាផលនៃយាគុទាន ។ ខ្ញុំបានប្រគេនបបរដល់ព្រះភិក្ខុសង្ឃ ជាបុញ្ញខេត្តដ៏ប្រសើររួចហើយ ក៏បាននូវអានិសង្ស ៥ ប្រការ ឱហ្ន៎ ! ភាពនៃបបរ ខ្ញុំបានបូជាស្រួលហើយ ។ ( អានិសង្ស ៥ ប្រការនោះគឺ ) ភាពជាអ្នកមិនមានជំងឺតម្កាត់ ១ ភាពជាអ្នកមានរូបរាងល្អ ១ ភាពជាអ្នកត្រាស់ដឹងនូវធម៌ឆាប់ ១ ភាពជាអ្នកបានបាយនិងទឹកជាប្រក្រតី ១ ខ្ញុំមានអាយុវែងជាគម្រប់ ៥ ។ បុគ្គលណាមួយ កាលធ្វើសេចក្ដីត្រេកអរឲ្យកើត គប្បីប្រគេនបបរចំពោះព្រះសង្ឃ បុគ្គលនោះឈ្មោះថាបណ្ឌិត តែងទទួលនូវឋានៈ ៥ ប្រការនេះឯង ។ ករណីយកិច្ចទាំងអស់ ខ្ញុំបានធ្វើរួចហើយ កពទាំងឡាយ ខ្ញុំបានគាស់រំលើងចោលហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានទេ ។ ខ្ញុំនោះតែងដើរទៅកាន់ស្រុកតូច-ធំ និងបុរីតូច-ធំ តែងថ្វាយបង្គំនូវព្រះសម្ពុទ្ធនិងព្រះធម៌ជាសភាវៈដ៏ល្អ ។ ក្នុងកប្បទី ៣០ ពាន់ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំពុំដែលស្គាល់ទុគ្គតិ នេះជាផលនៃយាគុទាន ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ កពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចស្រេចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង

សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយាគុទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យាគុទាយកត្ថេរាបទាន ។

# បត្ថោទនទាយកត្ថេរាបទាន ទី ៩

[ ៩ ] កាលពីកពមុន ខ្ញុំបានកើតជាប្រើព្រៃ ប្រកបការក្នុងព្រៃរឿយៗ បានយកបាយដែលចម្អិនដោយអង្ករចំនួនមួយនាឡិ ហើយដើរទៅធ្វើការងារ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាព្រះសយម្ភូ ទ្រង់ឈ្នះមារ ព្រះអង្គកំពុងស្តេចចេញពីព្រៃទៅបិណ្ឌបាតក្នុងទីនោះ លុះខ្ញុំបានឃើញហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាថា អញរវល់តែប្រកបក្នុងការងារឲ្យអ្នកដទៃ ចំណែកបុណ្យរបស់អញមិនមានឥឡូវនេះ បាយដែលចម្អិនដោយអង្ករមួយនាឡិនេះមាន អញនឹងនិមន្តព្រះមុនីនេះឲ្យឆាន់បាយនេះ ។ ខ្ញុំយកបាយដែលចម្អិនដោយអង្ករមួយនាឡិថ្វាយព្រះសយម្ភូ កាលខ្ញុំកំពុងតែសម្លឹងមើលព្រះមហាមុនីទ្រង់សោយ ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលធ្វើល្អហើយនោះផង ដោយការតម្កល់ចេតនានោះផង ។ ខ្ញុំបានជាព្រះឥន្ទ្រសោយរាជ្យជាស្តេចទេវតាអស់ ៣២ ដង បានជាស្តេចចក្កពត្តិអស់ ៣៣

ជន ។ បានសោយរាជ្យជាក្សត្រប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំជាអ្នកដល់សេចក្ដីសុខ មានយស នេះជាផលនៃបាយដែលចម្អិនដោយអង្ករមួយនាឡិ ។ ខ្ញុំកាលអន្ទោលទៅមកក្នុងភពតូចនិងភពធំ រមែងបានទ្រព្យរាប់មិនអស់ ខ្ញុំមិនដែលមានការខ្វះខាតភោគៈឡើយ នេះជាផលនៃបាយដែលចម្អិនដោយអង្ករមួយនាឡិ ។ ភោគៈទាំងឡាយដែលមានចំណែកប្រៀបដូចខ្សែទឹកទន្លេរមែងកើតសម្រាប់ខ្ញុំ ខ្ញុំមិនអាចរាប់ភោគៈទាំងនោះ ឲ្យសព្វគ្រប់បានឡើយ នេះជាផលនៃបាយដែលចម្អិនដោយអង្ករមួយនាឡិ ។ ( ពួកជនតែងពោលថា ) អ្នកចូរទំពាស៊ីចំណីនេះ ចូរបរិភោគអាហារនេះ ចូរដេកលើដំណេកនេះ ព្រោះហេតុនេះ ខ្ញុំជាបុគ្គលបានសុខស្រួល នេះជាផលនៃបាយដែលចម្អិនដោយអង្ករមួយនាឡិ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបាយដែលចម្អិនដោយអង្ករមួយនាឡិ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញចោលហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្ដាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦

នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបត្តោទនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បត្តោទនទាយកត្ថេរាបទាន ។**

## មញ្ចទាយកត្ថេរាបទាន ទី ១០

[ ១០ ] កាលព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ប្រកបដោយសេចក្តីករុណា ទ្រង់បរិនិព្វានហើយ កាលសាសនាកំពុងផ្សាយចេញទៅ មានពួកទេវតានិងមនុស្សធ្វើសក្ការៈហើយ ។ ខ្ញុំកើតជាមនុស្សចណ្ឌាល អ្នកធ្វើតាំងឈ្មោះអាសន្ទិ ( តាំងមានជ្រុង ៤ ស្មើ ) ក្នុងទីនោះ ខ្ញុំរស់នៅដោយការងារនោះ ទាំងបានចិញ្ចឹមទារកនិងប្រពន្ធដោយការងារនោះដែរ ។ ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើតាំងឈ្មោះអាសន្ទិ វិចិត្រយ៉ាងល្អដោយដៃរបស់ខ្លួន ហើយនាំចូលទៅប្រគេនព្រះភិក្ខុសង្ឃដោយខ្លួនឯង ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្លួនធ្វើល្អហើយនោះផង ដោយការតម្កល់ចេតនានោះផង ។ ខ្ញុំកាលទៅកាន់ទេវលោក រមែងរីករាយក្នុងពួកទេវតានៅឋានតាវត្តិង្ស ទីសម្រាប់ដេកមានថ្ងៃច្រើន ក៏កើតឡើងតាម

សេចក្តីប្រាថ្នា ( របស់ខ្ញុំ ) ។ ខ្ញុំបានជាព្រះឥន្ទ សោយរាជ្យជាស្តេចនៃទេវតាអស់ ៥០ ដង ទាំងបានជាស្តេចចក្រពត្តិអស់ ៨០ ដង ។ ខ្ញុំបានសោយ-រាជ្យជាក្សត្រប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំជាបុគ្គលមានសេចក្តីសុខ មានយស នេះជាផលនៃការថ្វាយគ្រែ ។ កាលខ្ញុំច្យុតចាកទេវលោកមកកាន់ភពជារបស់មនុស្សវិញ ទីសម្រាប់ដេកដ៏ល្អ មានតម្លៃច្រើន ក៏កើតឡើងឯងៗសម្រាប់ខ្ញុំ ។ នេះរាងកាយខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំកំពុងតែប្រព្រឹត្តទៅ ថ្ងៃនេះទីសម្រាប់ដេកក៏កើតឡើង ( សម្រាប់ខ្ញុំ ) ក្នុងកាលជាទីដេក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានប្រគេនគ្រែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយគ្រែ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមញ្ចទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ មញ្ចទាយកត្ថេរាបទាន ។**

## ឧទ្ទាន

កទ្ទាលិត្ថេរាបទាន ១ ឯកច្ឆត្តិយត្ថេរាបទាន ១ តិណសូលកឆាទនិយត្ថេរាបទាន ១ មធុមំសទាយកត្ថេរាបទាន ១ នាគបល្លវកត្ថេរាបទាន ១ ឯកទីបិយត្ថេរាបទាន ១ ឧច្ឆង្គបុប្ផិយ-ត្ថេរាបទាន ១ យាគុទាយកត្ថេរាបទាន ១ បត្ថោទនទាយក-ត្ថេរាបទាន ១ មញ្ចទាយកត្ថេរាបទាន ១ ឯគាថារាប់ទៅឃើញមានចំនួន ២២១ គាថា ។

## ចប់ កទ្ទាលិវគ្គ ទី ៤២ ។

# អដ្ឋកថា

# នាគបលូវកត្ថេរាបទាន ជាដើម

[ ៥-១០ ] អបទានទី ៥ របស់ព្រះនាគបលូវកត្ថេរក្តី អបទានទី ៦ របស់ព្រះឯកទីបិយត្ថេរក្តី អបទានទី ៧ របស់ព្រះឧច្ឆង្គបុប្ផិយត្ថេរក្តី អបទានទី ៨ របស់ព្រះយាគុទាយកត្ថេរក្តី អបទានទី ៩ របស់ព្រះបត្ថោទនទាយកត្ថេរក្តី អបទានទី ១០ របស់ព្រះមញ្ចទាយកត្ថេរក្តី មានអត្ថដ៏ងាយទាំងអស់ហើយ ។

អដ្ឋកថានាគបលូវកត្ថេរាបទានជាដើម ចប់

# សកឹសម្មជ្ជកវគ្គ ទី ៤៣

## សកឹសម្មជ្ជកត្ថេរាបទានទី ១

[ ១១ ] ខ្ញុំ ( បានឃើញ ) ដើមប្រទៀងជាពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះមានព្រះភាគព្រះនាមវិបស្សី លុះខ្ញុំបានឃើញឈើដ៏ប្រសើរនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាចំពោះឈើនោះ ។ ខ្ញុំចាប់យកអំបោស ហើយបោសដើមពោធិព្រឹក្សក្នុងពេលនោះភ្លាម លុះខ្ញុំបានបោសរួចហើយ ក៏ថ្វាយបង្គំដើមប្រទៀងជាពោធិព្រឹក្សនោះ ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាចំពោះពោធិព្រឹក្សនោះ រួចធ្វើអញ្ជលីលើក្បាល នមស្ការពោធិព្រឹក្សនោះ ហើយដើរថយក្រោយទៅ ។ កាលខ្ញុំកំពុងនឹកចំពោះពោធិព្រឹក្សដ៏ប្រសើរ ហើយដើរបណ្ដើរ តាមផ្លូវជាទីត្រាច់ទៅស្រាប់តែពស់ថ្លាន់មួយ ជាសត្វក្លាហាន មានកម្លាំងច្រើនរួបរឹតខ្ញុំ ។ អំពើដែលខ្ញុំបានធ្វើក្នុងពេលថ្មី ៗ ក៏ញុំាងខ្ញុំឲ្យត្រេកអរចំពោះផល ចំណែកឯពស់ថ្លាន់លេបរាងកាយខ្ញុំចូលបាត់ទៅ ខ្ញុំបានទៅរីករាយក្នុងទេវលោក ។ ចិត្តរបស់ខ្ញុំឥតមានកករល្អក់ឡើយ ជាចិត្តស្អាតសព្វៗកាល ខ្ញុំមិនដែលស្គាល់នូវសរ គឺសេចក្ដីសោក ដែលជាហេតុញុំាងចិត្តរបស់ខ្ញុំឲ្យក្ដៅក្រហាយឡើយ ។ រោគឃ្លង់ រោគបូស រោគស្រែង រោគឆ្កួតជ្រូក ឃ្លង់ដែក ដំណួចពិសរមាស់ ខ្ញុំពុំដែលមានឡើយ នេះជាផលនៃការបោសសម្អាត ។ សេចក្ដីសោកនិងសេចក្ដីក្តៅក្នុងហឫទ័យ ខ្ញុំមិនដែលមានទេ ចិត្តរបស់ខ្ញុំជាចិត្តត្រង់ មិនក័ន្តកាំង នេះជាផលនៃការបោសសម្អាត ។ ខ្ញុំដល់នូវសមាធិម្ដងទៀត ចិត្តនៃខ្ញុំជាធម្មជាតបរិសុទ្ធិ ខ្ញុំប្រាថ្នាសមាធិណាៗ សមាធិនោះៗ រមែងសម្រេច

ដល់ខ្ញុំ ។ ខ្ញុំមិនដែលត្រេកត្រអាលចំពោះរបស់ដែលគួរត្រេកត្រអាល ម្យ៉ាងទៀត ខ្ញុំមិនដែលប្រទូស្តចំពោះរបស់ដែលគួរប្រទូស្ត មិនបានវង្វេងចំពោះរបស់ដែលគួរវង្វេង នេះជាផលនៃការបោសសម្អាត ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអំពើល្អក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបោសសម្អាត ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្នឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសកឹសម្មជ្ជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ សកឹសម្មជ្ជកត្ថេរាបទាន ។

# ឯកធុស្សទាយកត្ថេរាបទានទី ២

[ ១២ ] ខ្ញុំកើតជាអ្នកនាំស្នៀ នៅក្នុងក្រុងហង្សវតី ខ្ញុំចិញ្ចឹមជីវិតដោយការនាំស្នៀទាំងចិញ្ចឹមកូនប្រពន្ធដោយការនាំស្នៀនោះ ។ ព្រះជិនសិរីព្រះនាមបទុមុត្តរៈ ព្រះអង្គដល់ត្រើយនៃធម៌ទាំងពួង ជានាយកនៃសត្វលោក ទ្រង់កើតឡើង ញុំាងងងឹតអន្ធការឲ្យវិនាស ។ ខ្ញុំអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ហើយគិតយ៉ាងនេះក្នុងខណៈនោះថា ព្រះពុទ្ធទ្រង់ត្រាស់ហើយក្នុងលោក ទេយ្យធម៌អាត្មាអញមិនមាន ។ អាត្មាអញមានតែសាដកមួយនេះ ( បើថ្វាយទៅ ) ពុំមានអ្នកណាមួយផ្តល់ឲ្យអាត្មាអញ ការពាល់ត្រូវនូវនរកជាទុក្ខ បើយ៉ាងនេះ អាត្មាអញនឹងបណ្តុះនូវទក្ខិណាទាន ។ ខ្ញុំលុះគិតឃើញយ៉ាងនេះហើយក៏ធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានយកសំពត់មួយថ្វាយព្រះពុទ្ធដ៏ប្រសើរ ។ លុះថ្វាយសំពត់រួចហើយ ខ្ញុំស្រែកហ៊ោឡើងថា បពិត្រព្រះមហាមុនីមានព្យាយាម បើព្រះអង្គជាព្រះពុទ្ធសូមចម្លងខ្ញុំព្រះអង្គផង ។ ព្រះពុទ្ធព្រះនាម បទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់សរសើរទានរបស់ខ្ញុំ ហើយធ្វើអនុមោទនាដល់ខ្ញុំថា

បុរសនេះ មិនទៅកាន់វិនិបាតអស់សែនកប្ប ដោយការឲ្យសំពត់មួយនេះផង ដោយការតម្កល់ចេតនានេះផង ។ បុរសនេះ នឹងបានជាព្រះឥន្ទសោយរាជ្យជាស្តេចនៃទេវតាអស់ ៣៦ ដង នឹងបានជាស្តេចចក្កពត្តិអស់ ៣៣ ដង ។ នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ កាលអន្ទោលទៅក្នុងទេវលោក ឬក្នុងមនុស្សលោក ជាអ្នកមានរូបល្អ បរិបូណ៌ដោយគុណមានរាងកាយកំពុងប្រព្រឹត្តទៅ នឹងបាននូវសំពត់តាមសេចក្តីប្រាថ្នា ជាអក្ខោ-

ភិនីរាប់មិនអស់ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជាអ្នកប្រាជ្ញ លុះត្រាស់ភាសិតនេះហើយ ទ្រង់ហោះទៅឯអាកាស ដូចជារាជហង្សក្រាលហើរពួដ៏អាកាស ។

ខ្ញុំចូលទៅកាន់កំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ខ្ញុំមិនដែលមានការខ្វះខាតគោគៈឡើយ នេះជាផលនៃសំពត់មួយ ។ សំពត់តែងកើតសម្រាប់ខ្ញុំរាល់ជំហានៗ ខាងក្រោមខ្ញុំឈរលើសំពត់ ខាងលើមានសំពត់បាំងឲ្យខ្ញុំ ។ ថ្ងៃនេះខ្ញុំប្រាថ្នាបិទបាំងទីព្រមទាំងព្រៃ និងភ្នំរហូតចក្កវាឡ ក៏អាចគ្របទីនោះដោយសំពត់បាន ។ ខ្ញុំកាលអន្ទោលទៅក្នុងភពតូចភពធំ មានសម្បុរល្អដូចមាស តែងអន្ទោលទៅក្នុងភពតូចភពធំដោយសារផលនៃសំពត់មួយនោះឯង ។ ខ្ញុំបាននូវភាពជាភិក្ខុក្នុងទីនេះ ព្រោះអាស្រ័យផលនៃសំពត់មួយ ម្យ៉ាងទៀតជាតិនេះជាទីបំផុតរបស់ខ្ញុំ អំពើនេះសោត ឲ្យផលដល់ខ្ញុំក្នុងជាតិនេះ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសំពត់មួយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទុស្សទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ឯកទុស្សទាយកត្ថេរាបទាន ។**

# ឯកាសនទាយកត្ថេរាបទាន ទី ៣

[ ១៣ ] មានភ្នំមួយឈ្មោះកសិកៈដែលនៅជិតព្រៃហិមពាន្ត ខ្ញុំបានធ្វើអាស្រមមួយយ៉ាងល្អ ទាំងបានកសាងបណ្ណសាលាមួយដ៏ល្អល្អះ នៅក្បែរភ្នំនោះ ។ កាលនោះ ខ្ញុំមាននាមថានារទៈ តែគេស្គាល់ខ្ញុំថាកស្សបៈវិញ ខ្ញុំកំពុងស្វែងរកមគ្គដ៏ស្អាត នៅជិតភ្នំកសិកៈ ។ ព្រះជិនសិរីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រាថ្នារកវិវេក បានស្តេចយាងមកតាមផ្លូវអាកាស ។ ខ្ញុំបានឃើញរស្មីព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ កំពុងយាងលើទីបំផុតនៃព្រៃ ក៏បានតាក់តែងគ្រែឈើ ហើយក្រាលស្បែកខ្លាថ្វាយ ។ ខ្ញុំលុះក្រាលអាសនៈរួចហើយ ក៏ប្រណម្យអញ្ជលីលើក្បាល បានទទួលសោមនស្ស ហើយពោលពាក្យនេះថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ព្រះអង្គជាពេទ្យវះអ្នកព្យាបាលពួកជំងឺ បពិត្រព្រះនាយក សូមព្រះអង្គប្រទាននូវការព្យាបាលរោគដល់ខ្ញុំព្រះអង្គ ដែលរោគៈកំពុងគ្របសង្កត់ ។ បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ពួកជនណាជាអ្នកត្រូវការដោយបុណ្យ បើបានឃើញព្រះអង្គជាព្រះពុទ្ធដ៏ប្រសើរ តែងដល់នូវការសម្រេចប្រយោជន៍ដ៏ទៀងទាត់ ការ

មិនមានសេចក្តីគ្រាំគ្រា គប្បីមានដល់ជនទាំងនោះ ។ ទេយ្យវត្ថុដែលខ្ញុំគួរថ្វាយចំពោះព្រះអង្គមិនមាន ( ព្រោះ ) ខ្ញុំជាអ្នកបរិភោគតែផ្លែឈើដែលជ្រុះឯង នេះអាសនៈរបស់ខ្ញុំ សូមព្រះអង្គគង់លើគ្រែឈើនេះចុះ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈនោះ ដូចកេសររាជសីហ៍ ដែលឥតតក់ស្លុត ទ្រង់បង្អែបង្អង់ អស់កាលមួយស្របក់ ហើយទើបត្រាស់ពាក្យនេះថា

អ្នកចូរស្ងប់ស្ងាត់ស្ងួនស្នាលចុះ កុំកិតភ័យឡើយ ( ព្រោះ ) ព្រះពុទ្ធមានរស្មីដ៏រុងរឿង អ្នកបានហើយ អាសនៈណាដែលអ្នកប្រាថ្នាហើយ អាសនៈទាំងអស់នោះនឹងបរិបូណ៌ដល់អ្នក ។ បុណ្យដែលអ្នកធ្វើល្អហើយក្នុងបុញ្ញក្ខេត្តដ៏ប្រសើរមិនមែនជាបុណ្យតិចតួចទេ ចិត្តរបស់បុគ្គលណា ដែលបានតម្កល់ល្អហើយបុគ្គលនោះ អាចរើខ្លួនបាន ។ ដោយការប្រគេនអាសនៈនេះផង ដោយការតម្កល់ចេតនានេះផង បុគ្គលនោះនឹងមិនទៅកាន់វិនិបាតអស់មួយសែនកប្ប ។ បុគ្គលនោះនឹងបានជាព្រះឥន្ទ្រសោយរាជ្យជាស្តេចទេវតាអស់ ៥០ ដង នឹងបានជាស្តេចចក្កពត្តិអស់ ៨០ ដង ។ នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ កាលបើអន្ទោលទៅក្នុងសង្សារ នឹងជាអ្នកបានសេចក្តីសុខស្រួលក្នុងទីទាំងពួង ។ ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ព្រះនាមបទុមុត្តរៈ លុះត្រាស់ភាសិតនេះហើយ ក៏ហោះឡើងទៅឯនភាល័យ ដូចជារាជហង្សក្រាលហើរឡើងដ៏អាកាស ។

ខ្ញុំតែងបាននូវវត្ថុទាំងអស់នោះគឺ យានដំរី យានសេះ ព្រមទាំងរថនិងរថទ្រង់គ្រឿង នេះជាផលនៃអាសនៈមួយ ។ កាលណាខ្ញុំចូលទៅក្នុងព្រៃប្រាថ្នារកអាសនៈ ស្រាប់តែបល្ល័ង្កផុសលេចឡើង ព្រោះបានដឹងនូវសេចក្តី

ត្រិះរិះរបស់ខ្ញុំ ( ក្នុងកាលនោះ ) ។ កាលណាបើខ្ញុំទៅនៅកណ្តាលទឹក ប្រាថ្នារកអាសនៈ ស្រាប់តែបល្ល័ង្កផុសលេចឡើង ព្រោះបានដឹងសេចក្តីត្រិះរិះរបស់ខ្ញុំ កាលនោះ ។ ខ្ញុំចូលទៅកាន់កំណើតណា ៗ ទោះជាទេវតាឬជាមនុស្ស បល្ល័ង្កមួយសែន តែងចោមរោមខ្ញុំសព្វកាល ។ ខ្ញុំតែងអន្ទោលទៅមកក្នុងភពពីរ គឺទេវតានិងមនុស្ស មិ្យាងទៀត តែងកើតក្នុងត្រកូលពីរ គឺក្សត្រនិងព្រាហ្មណ៍ ។ ព្រោះខ្ញុំបានថ្វាយអាសនៈមួយចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ ទើបដឹងបល្ល័ង្កគឺធម៌ ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអាសនៈមួយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ ឯកាសនទាយកត្ថេរាបទាន ។

# សត្តកទម្ពបុប្ផិយត្ថេរាបទានទី ៤

[ ១៤ ] មានភ្នំខ្ពស់មួយឈ្មោះ កទម្ពៈ នៅជិតព្រៃហិមពាន្ត មានព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គនោះ ទ្រង់គង់នៅខាងភ្នំនោះ ។ ខ្ញុំឃើញផ្កាកូម្ព បានផ្គងអញ្ជលីកាន់ផ្កា ៧ ចង្កោម ហើយថ្វាយដោយចិត្តពេញលេញ ។ ខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអំពើជាកុសលក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តកទម្ពបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សត្តកទម្ពបុប្ផិយត្ថេរាបទាន ។**

# គោរណ្ឌបុប្ផិយត្ថេរាបទានទី ៥

[ ១៥ ] កាលកពមុន ខ្ញុំកើតជាបុរសអ្នកធ្វើការងារក្នុងព្រៃជាមួយនឹងបិតានិងជីតាខ្ញុំ ខ្ញុំរស់នៅដោយការសម្លាប់សត្វ ឯកុសលរបស់ខ្ញុំ មិនមានឡើយ ។ ព្រះលោកនាយកដ៏ប្រសើរព្រះនាមតិស្សៈ ព្រះអង្គមានបញ្ញាចក្ខុគង់នៅជិតលំនៅរបស់ខ្ញុំ ទ្រង់សម្តែងស្នាមព្រះបាទបីអន្លើដោយសេចក្តីអនុគ្រោះ ។ ខ្ញុំឃើញស្នាមព្រះបាទានៃព្រះសាស្តាព្រះនាមតិស្សៈដែលទ្រង់ជាន់ទុកហើយ ក៏មានចិត្តត្រេកអររីករាយ បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះស្នាមព្រះបាទា ។ ខ្ញុំឃើញដើមល្ហុងខ្វែរមានផ្ការីក ជាឈើដុះលើផែនដីហើយ ក៏កាន់យកផ្កាព្រមទាំងសណ្តង់ បូជាចំពោះស្នាមព្រះបាទាដ៏ប្រសើរ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលុះលះបង់រាងកាយជារបស់មនុស្ស ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ខ្ញុំទៅយកកំណើតណាៗទោះជាទេវតាឬជាមនុស្ស ខ្ញុំតែងមានសម្បុរព្រមទាំងរស្មីដូចល្ហុងខ្វែរ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើអំពើល្អក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាស្នាមព្រះបាទ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ កពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោរណ្ឌបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កោរណ្ឌបុប្ផិយត្ថេរាបទាន ។**

# យជមណ្ឌទាយកត្ថេរាបទានទី ៦

[ ១៦ ] ខ្ញុំបានឃើញនូវព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះល្អ ព្រះអង្គជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ដែលស្តេចចូលទៅគង់ក្នុងព្រៃធំហើយ ត្រូវអាពាធកើតអំពីខ្យល់បៀតបៀន ។ លុះខ្ញុំឃើញហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លា បានថ្វាយទឹកដោះថ្លា ព្រោះកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ព្រោះសេចក្តីកោតក្រែងនោះផង ទន្លេគង្គាឈ្មោះភាគីរសីនេះ និងមហាសមុទ្ទទាំង ៤ ក៏ញុំាងទឹកដោះឲ្យសម្រេចដល់ខ្ញុំ មួយទៀត ផែនដីជាសការៈដ៏ធំនេះ ប្រមាណមិនបាន រាប់មិនអស់ ក៏កើតទៅជាទឹកឃ្មុំ និងស្ករក្រាម ព្រោះដឹងតម្រិះរបស់ខ្ញុំ ។ ដើមឈើទាំងឡាយនេះ ជាឈើដុះលើផែនដី ដែលឋិតនៅក្នុងទិសទាំងបួន ឈើទាំងនោះក៏កើតទៅជាដើមកល្បព្រឹក្ស ព្រោះដឹងតម្រិះរបស់ខ្ញុំ ។ ខ្ញុំបានកើតជាព្រះឥន្ទ្រសោយរាជ្យជាស្តេចទេវតាអស់ ៥០ ដង ។ បានជាស្តេចចក្កពត្តិ ៥១ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកដោះថ្លា ។ កិលេសទាំង

ឡាយ ខ្ញុំដុតបំផ្លាញហើយ កពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយជមណ្ឌទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ យជមណ្ឌទាយកត្ថេរាបទាន ។**

# ឯកធម្មស្សវនីយត្ថេរាបទាន ទី ៧

[ ១៧ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រកាសនូវសច្ចៈទាំង ៤ បានញុំាងជនច្រើនឲ្យឆ្លងទុក្ខហើយ ។ សម័យនោះ ខ្ញុំជាជដិលមានតបធម៌ដ៏ខ្ពង់ខ្ពស់ រលាស់នូវចីវរសម្បកឈើហើយហោះទៅឰដ៏អាកាសក្នុងកាលនោះ ។ ខ្ញុំមិនហ៊ានហោះទៅខាងលើព្រះពុទ្ធដ៏ប្រសើរឡើយ ខ្ញុំមិនបាននូវដំណើរទៅមុខ ប្រៀបដូចសត្វស្លាបដែលទើសទាក់នឹងភ្នំ ។ កាលបើយ៉ាងនេះ ខ្ញុំចុះទៅក្នុងទឹក ហើយហោះទៅឰដ៏អាកាសទៀត ( តែខ្ញុំទៅមុខមិនរួច ) ការញុំាងឥរិយាបថឲ្យកម្រើកបែប

នេះ ខ្ញុំមិនធ្លាប់មានទេ ។ ( ខ្ញុំគិតថា ) ធ្វើដូចម្ដេចហ្ន៎ អាត្មាអញនឹងបាន ដឹងហេតុការណ៍នេះអេះ បើដូច្នោះ មានតែអាត្មាអញ នឹងស្វែងរកនូវហេតុ ការណ៍នោះ ។ ខ្ញុំក៏ចុះអំពីអាកាស បានឮនូវសំឡេងនៃព្រះសាស្ដា ដែល កំពុងសម្ដែងនូវអនិច្ចតាធម៌ ដោយសំឡេងដ៏ពីរោះ គួរឹកករាយ គួរស្ដាប់ ខ្ញុំ ក៏ចងចាំអនិច្ចតាធម៌នោះក្នុងកាលនោះ ។ លុះខ្ញុំចងចាំនូវអនិច្ចសញ្ញាហើយ ក៏បានទៅឯអាស្រមរបស់ខ្ញុំវិញ ខ្ញុំនៅទីនោះដរាបលុះអស់អាយុ ហើយធ្វើ-មរណ កាលក្នុងអាស្រមនោះ ។ កាលកពខាងក្រោយកំពុងប្រព្រឹត្តទៅ ខ្ញុំក៏ នឹកឃើញនូវការស្ដាប់ព្រះសទ្ធម្ម ព្រោះអំពើដែលខ្ញុំធ្វើល្អនោះផង ព្រោះការ តាំងទុកនូវចេតនានោះផង ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បាន ទៅកើតក្នុងឋានតាវត្តិង្ស ខ្ញុំត្រេកអរក្នុងទេវលោកអស់ ៣ ម៉ឺនកប្ប ។ ខ្ញុំបាន សោយទេវរាជ្យជាស្ដេចនៃពួកទេវតាអស់ ៥១ ដង បានជាស្ដេចចក្កពត្តិអស់ ៣១ ដង ។ បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំបាន សោយនូវបុណ្យរបស់ខ្លួន ដល់នូវសេចក្ដីសុខក្នុងកពតូចនិងកពធំ ។ កាលខ្ញុំ អន្ទោលទៅក្នុងកពតូចនិងកពធំ តែងនឹកឃើញនូវសញ្ញានោះ តែមិនអាចនឹង ចាក់ធ្លុះនូវនិព្វានជាបទមិនឃ្លៀងឃ្លាតបានដោយហេតុណាមួយឡើយ ។ មាន សមណៈមួយរូប មានឥន្ទ្រិយអប់រំហើយ គង់នៅក្នុងផ្ទះនៃបិតារបស់ខ្ញុំហើយ សម្ដែងនូវគាថា ពោលនូវអនិច្ចតាធម៌ក្នុងផ្ទះនោះថា ឱហ្ន៎ សង្ខារទាំងឡាយ មិនទៀងទេ មានកិរិយាកើតឡើងនិងការវិនាសទៅវិញជាធម្មតា លុះកើត ឡើងហើយរមែងរលត់ទៅវិញ លុះតែការរម្ងាប់សង្ខារទាំងឡាយនោះ ទើប

នាំមកនូវសេចក្ដីសុខ ។ ខ្ញុំបានស្ដាប់ធម៌ព្រមទាំងគាថា ហើយទើបឃើញនូវសញ្ញាទាំងពួង អង្គុយលើអាសនៈមួយ ក៏ដល់នូវព្រះអរហត្ត ។ ខ្ញុំបានដល់ព្រះអរហត្តតាំងពីអាយុ ៧ ឆ្នាំ ព្រះសម្ពុទ្ធបានញុំាងខ្ញុំឲ្យបានឧបសម្បទា នេះជាផលនៃការស្ដាប់ព្រះធម៌ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្ដាប់ធម៌ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្ដាប់ធម៌ កិលេសទាំងឡាយខ្ញុំបានដុតចោលហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីកាត់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកធម្មស្សវនិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ ឯកធម្មស្សវនិយត្ថេរាបទាន ។

# សុចិន្តិតត្ថេរាបទានទី ៨

[ ១៨ ] កាលនោះ ខ្ញុំជាអ្នកស្រែនៅក្នុងនគរហង្សវតី ចិញ្ចឹមជីវិតដោយកសិកម្ម ចិញ្ចឹមនូវប្រពន្ធនិងកូនក៏ដោយកសិកម្មនោះដែរ ។ កាលនោះស្រែ ( របស់ខ្ញុំ ) មានស្រូវបរិបូណ៌ នេះជាផលរបស់ខ្ញុំ កាលស្រូវទុំបរិបូណ៌ហើយ ក្នុងកាលណោះ ខ្ញុំគិតយ៉ាងនេះថា អាត្មាអញ មិនទាន់បានឲ្យទានដ៏ប្រសើរ ចំពោះព្រះសង្ឃសោះ បរិភោគតែខ្លួនឯង ( អំពើនេះ ) មិនសមរម្យ មិនសមគួរដល់អាត្មាអញដែលជាអ្នកដឹងនូវគុណ និងទោសឡើយ ។ ព្រះសម្ពុទ្ធមិនមានបុគ្គលស្មើក្នុងលោក ទ្រង់មានព្រះលក្ខណៈ ៣២ ដ៏ប្រសើរ ទាំងព្រះសង្ឃមានចិត្តអប់រំហើយ ជាស្រែបុណ្យដ៏ប្រសើរ ( មានក្នុងលោកហើយ ) ។ អញនឹងប្រគេននូវសម្ទូងថ្មី ជាទានចំពោះព្រះភិក្ខុសង្ឃនោះមុនគេ លុះខ្ញុំគិតយ៉ាងនេះហើយ ជាអ្នករីករាយ មានចិត្តប្រកបដោយបីតិ ។ ខ្ញុំយកស្រូវអំពីស្រែ ចូលទៅរកព្រះសម្ពុទ្ធ លុះចូលទៅដល់ព្រះសម្ពុទ្ធ ព្រះអង្គជាច្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈហើយ ក៏ថ្វាយបង្គំព្រះបាទានៃព្រះសាស្តា រួចក្រាបទូលថា បពិត្រព្រះមុនី សម្ទូងថ្មី ( របស់ខ្ញុំ ) បរិបូណ៌ហើយ ទាំងព្រះអង្គក៏គង់នៅក្នុងទីនេះ បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គអាស្រ័យនូវសេចក្តីអនុគ្រោះ ហើយទទួលនិមន្តន៍ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គួរទទួលនូវគ្រឿងបូជា ព្រះអង្គជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ទ្រង់សម្តែងនូវពាក្យនេះថា បុគ្គល ៤ ពួក កំពុងប្រតិបត្តិ បុគ្គល ៤ ពួកឋិតនៅក្នុងផល ។ នេះជាសង្ឃមានព្រះទ័យស្លូតត្រង់ ប្រកបដោយបញ្ញានិងសីល ទានដែលមនុស្សទាំងឡាយអ្នកបូជា

ជាសត្វប្រាថ្នាបុណ្យ កាលធ្វើនូវការសន្សំបុណ្យ បានឲ្យហើយចំពោះព្រះសង្ឃ រមែងមានផលច្រើន ឯសម្បទានៃអ្នកនេះ ដែលអ្នកតម្កល់ឲ្យចំពោះព្រះសង្ឃនោះ ក៏មានផលច្រើនដូច្នោះដែរ ។ អ្នកចូរឧទ្ទិសចំពោះសង្ឃ ហើយនាំភិក្ខុទាំងឡាយទៅឯផ្ទះរបស់ខ្លួន រួចប្រគេននូវវត្ថុដែលអ្នកតាក់តែងរួចហើយ ដែលមានក្នុងផ្ទះដល់ភិក្ខុសង្ឃចុះ ។ ខ្ញុំក៏បានឧទ្ទិសចំពោះសង្ឃ ហើយនាំភិក្ខុទាំងឡាយទៅឯផ្ទះ វត្ថុណាដែលខ្ញុំតាក់តែងហើយក្នុងផ្ទះ ខ្ញុំក៏ប្រគេនវត្ថុនោះដល់ភិក្ខុសង្ឃ ខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ ក៏ទៅកើតក្នុងឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំបានធ្វើល្អហើយនោះផង ដោយការតាំងទុកនូវចេតនានោះផង ។ វិមានរបស់ខ្ញុំមានពណ៌ល្អ មានរស្មីភ្លឺផ្លេក ដែលបុញ្ញកម្មតាក់តែងហើយក្នុងទេវលោកនោះ ជាវិមានមានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។

## ចប់ ភាណវារៈទី ១៩ ។

លំនៅរបស់ខ្ញុំដេរដាសកុះករដោយពួកនារី ខ្ញុំបរិភោគផង ផឹកផង នៅក្នុងឋានទេវតានោះ ខ្ញុំបានសោយទេវរាជ្យជាស្តេចនៃទេវតាអស់ ៣.០០០ ដង បានជាស្តេចចក្រពត្តិអស់ ៥០០ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំកាលអន្ទោលទៅក្នុងភពតូចភពធំ រមែងបាននូវទ្រព្យរាប់មិនអស់ ខ្ញុំមិនមានការខ្វះខាតដោយភោគៈទាំងឡាយឡើយ នេះជាផលនៃសម្បទានថ្មី ។ ខ្ញុំបាននូវវត្ថុគ្រប់មុខនេះ គឺយានដំរី យានសេះ គ្រែស្នែង រថទ្រង់គ្រឿង នេះជាផលនៃសម្បទានថ្មី ។ ខ្ញុំបាននូវវត្ថុគ្រប់មុខនេះ គឺសំពត់ថ្មី

ផ្លែឈើថ្មី និងភោជនថ្មោង មានឱជារសដ៏លើសលុប នេះជាផលនៃសម្មជ្ជថ្មី ។ ខ្ញុំបានទូវវត្ថុគ្រប់មុខនេះ គឺសំពត់សូត្រ សំពត់កម្ពល សំពត់សម្បកឈើ និងសំពត់ធ្វើដោយកប្បាស នេះជាផលនៃសម្មជ្ជថ្មី ។ ខ្ញុំបានទូវវត្ថុគ្រប់មុខ នេះគឺពួកខ្ញុំស្រី ពួកខ្ញុំប្រុស និងពួកនារីរូបឆើត មានខ្លួនតាក់តែងល្អហើយ នេះជាផលនៃសម្មជ្ជថ្មី ។ ខ្ញុំមិនមានសម្ផស្សត្រជាក់ និងក្តៅប៉ះពាល់ឡើយ ទាំងមិនមានសេចក្តីក្តៅក្រហល់ក្រហាយ ម្យ៉ាងទៀត ទុក្ខប្រព្រឹត្តទៅក្នុងចិត្តមិនមានក្នុងហឫទ័យរបស់ខ្ញុំឡើយ ។ ខ្ញុំបានទូវពាក្យពីរោះទាំងអស់នេះថា សូមអ្នកពីសាទូវវត្ថុនេះ សូមអ្នកបរិភោគទូវវត្ថុនេះ សូមអ្នកសម្រាន្តលើទីសយនៈនេះ នេះជាផលនៃសម្មជ្ជថ្មី នេះរាងកាយខាងក្រោយបំផុត ឥឡូវនេះ កពខាងក្រោយកំពុងប្រព្រឹត្តទៅក្នុងថ្ងៃនេះ ទេយ្យធម៌របស់ខ្ញុំតែងញុំាងខ្ញុំឲ្យត្រេកអរសព្វៗកាល ។ ខ្ញុំបានឲ្យសម្មជ្ជថ្មី ចំពោះព្រះសង្ឃជាគណៈដ៏ប្រសើរឧត្តម ហើយបានទូវអានិសង្ស ៨ ដ៏សមគួរដល់កម្មរបស់ខ្ញុំ គឺខ្ញុំជាអ្នកមានសម្បុរល្អ ១ មានយស ១ មានភោគៈច្រើនមិនមានអន្តរាយ ១ មានចំណីច្រើនសព្វៗកាល ១ មានបរិស័ទមិនបែកខ្ញែកសព្វៗកាល ១ ។ ជនទាំងឡាយណាមួយដែលអាស្រ័យនៅលើផែនដី ជនទាំងនោះ តែងគោរពកោតក្រែងខ្ញុំ ១ ទេយ្យធម៌ណាមួយ ( មាន ) ខ្ញុំតែងបាន ( នូវទេយ្យធម៌នោះ ) មុនៗគេ ១ ។ ទាយកទាំងឡាយ តែងរំលងនូវភិក្ខុសង្ឃទាំងអស់ ហើយឲ្យដល់ខ្ញុំតែម្នាក់ឯងក្នុងកណ្តាលនៃភិក្ខុសង្ឃ ឬក្នុងទីចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធដ៏ប្រសើរ ១ ។ ខ្ញុំឲ្យនូវសម្មជ្ជថ្មីជាដំបូងចំពោះព្រះសង្ឃ ជាគណៈ

ដ៏ឧត្តម ទើបបាននូវអានិសង្សទាំងនេះ នេះជាផលនៃសមូនប្ចី ។ ក្នុងកប្បទី មួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យនូវទានក្នុងកាលនោះ ខ្ញុំមិន ដែលស្គាល់ទុគ្គតិ នេះជាផលនៃសមូនប្ចី ។ កិលេសទាំងឡាយ ខ្ញុំដុតបោល ហើយ ភពទាំងអស់ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរី កាត់នូវទន្ទឹង ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរ ល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុចិន្តិតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយ ប្រការដូច្នេះ ។

ចប់ សុចិន្តិតត្ថេរាបទាន ។

# សោណ្ណកិង្កណិយត្ថេរាបទានទី ៩

[ ១៩ ] ខ្ញុំចេញទៅកាន់ផ្សារដោយសទ្ធា ទ្រទ្រង់ចីវរសម្បកឈើ ពីង ផ្អែកនូវតបោកម្ម ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សី ជា ច្បងក្នុងលោក ប្រសើរជាងនរៈ បានត្រាស់ឡើងហើយចម្លងនូវមហាជន ។ កម្លាំងរបស់ខ្ញុំអស់ហើយ ដោយសារព្យាធិយ៉ាងធ្ងន់ ខ្ញុំរឭកនូវព្រះសម្ពុទ្ធដ៏ ប្រសើរ ហើយធ្វើព្រះស្តូបដ៏ឧត្តមលើផ្នកខ្សាច់ ។ ខ្ញុំមានចិត្តរីករាយ មាន

ចិត្តខ្ពង់ខ្ពស់ មានសេចក្តីជ្រះថ្លា បានរោយរាយនូវផ្កាកណ្ណិងមាសទាំងឡាយ ។ ខ្ញុំបម្រើនូវព្រះស្តូបនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ដោយចិត្តជ្រះថ្លានោះ ដូចជាបម្រើព្រះសម្ពុទ្ធក្នុងទីចំពោះព្រះភក្ត្រ ។ កាលខ្ញុំទៅកើតក្នុងទេវលោក រមែងបាននូវសេចក្តីសុខដ៏ធំទូលាយ ជាអ្នកមានសម្បុរដូចមាសក្នុងទេវលោកនោះ នេះជាផលនៃពុទ្ធបូជា ។ នារីទាំងឡាយរបស់ខ្ញុំ ៨០ កោដិ មានខ្លួនតាក់តែងល្អៗ បម្រើខ្ញុំសព្វៗកាល នេះជាផលនៃពុទ្ធបូជា តូរ្យតន្ត្រី ៦ ម៉ឺន ស្គរ នទាត ស័ង្ខ សំភោរ និងស្គរធំ មានសំឡេងពីរោះប្រគំក្នុងទីនោះ ។ ដំរីទាំងឡាយ ៨ ម៉ឺន ៤ ពាន់ ប្រដាប់តាក់តែងល្អ ដំរីមាតង្គៈទាំងឡាយចុះប្រេង ៣ អន្លើ អាយុ ៦០ ឆ្នាំ ទើបថយកម្លាំង ដ៏ដេរដាសដោយបណ្តាញមាស ធ្វើនូវការបម្រើខ្ញុំ ខ្ញុំមិនមានការខ្វះខាតពួកពលក្នុងភពឡើយ ។ ខ្ញុំតែងទទួលផលនៃផ្កាកណ្ណិងមាស ខ្ញុំសោយរាជ្យជាស្តេចនៃទេវតាអស់ ៥៨ ដង ។ ខ្ញុំបានជាស្តេចចក្កពត្តិអស់ ៧១ ដងបាន សោយរាជ្យលើផែនដីអស់ ១០១ ដង ។ ឥឡូវនេះ ខ្ញុំបានដល់ព្រះនិព្វាន ឈ្មោះអមតៈជាបទដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយកម្រ សំយោជនៈទាំងឡាយ ( របស់ខ្ញុំ ) អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតចោលអស់ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរផ្តាច់នូវទន្លីង ។ ឱ! ដំណើរដែល

ខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោណ្ណកឹកណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សោណ្ណកឹកណិយត្ថេរាបទាន ។**

# សោវណ្ណកោន្តរិកត្ថេរាបទាន ទី ១០

[ ២០ ] ( ខ្ញុំបានឃើញ ) នូវព្រះពុទ្ធ ព្រះអង្គមានព្រះហឫទ័យអប់រំហើយ មានព្រះហឫទ័យទូន្មានហើយ មានព្រះហឫទ័យតម្កល់ខ្ជាប់ខ្ជួនហើយ ទ្រង់ប្រព្រឹត្តត្រេកអរក្នុងការរម្ងាប់ចិត្ត ដែលជាគន្លងប្រសើរ ទ្រង់ឆ្លងនូវជំនន់ ទ្រង់ត្រាស់ដឹងប្រពៃ ទ្រង់មានឈាន ត្រេកអរក្នុងឈាន ទ្រង់ចូលកាន់សមាបត្តិ មានកិរិយាសង្រួមនូវឥន្ទ្រិយ ។ ( លុះឃើញហើយ ) ខ្ញុំដងទឹកដោយសម្បកឃ្លោក ហើយចូលទៅគាល់ព្រះសម្ពុទ្ធប្រសើរ ខ្ញុំលាងនូវព្រះបាទានៃព្រះសម្ពុទ្ធ ហើយថ្វាយសម្បកឃ្លោកនោះ ។ ចំណែកព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់បង្គាប់ខ្ញុំថា អ្នកចូរយកទឹកដោយសម្បកឃ្លោកនេះ ហើយដាក់ក្នុងទីជិតបាទាតថាគតចុះ ។ ខ្ញុំក៏ទទួលថា សាធុ ដោយសេចក្តីគោរព

ចំពោះព្រះសាស្តា ហើយយកទឹកដោយសម្បកឃ្លោកចូលទៅថ្វាយព្រះសម្ពុទ្ធ ដ៏ប្រសើរ ។ ព្រះសម្ពុទ្ធទ្រង់មានព្យាយាមធំ បានញុំាងចិត្តរបស់ខ្ញុំឲ្យរលត់ ទ្រង់អនុមោទនាថា តម្រិះត្រូវចូរសម្រេចដល់អ្នក ដោយកិរិយាឲ្យនូវសម្បក ឃ្លោកនេះចុះ ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំត្រេកអរក្នុងទេវលោក ថែមទាំងបានជាស្តេចចក្កពត្តិ ៣៣ ដង ។ កាលខ្ញុំដើរឬឈរក្នុងវេលាថ្ងៃ ឬ ក្នុងវេលាយប់ ជនទាំងឡាយតែងឈរកាន់ឈើច្រត់ជាវិការៈនៃមាស នៅពី ខាងមុខខ្ញុំ ។ ព្រោះខ្ញុំថ្វាយសម្បកឃ្លោកដល់ព្រះសម្ពុទ្ធ ទើបខ្ញុំបានឈើច្រត់ ជាវិការៈនៃមាស ការបូជាសូម្បីតែបន្តិចបន្តួចដែលជនធ្វើហើយចំពោះបុគ្គល ទាំងឡាយដែលមិនញាប់ញ័រដោយលោកធម៌ រមែងប្រែទៅជាគ្រឿងបូជាដ៏ធំ ទូលាយ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយ សម្បកឃ្លោកក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសម្បក ឃ្លោក ។ កិលេសទាំងឡាយខ្ញុំដុតចោលអស់ហើយ ភពទាំងអស់ ខ្ញុំគាស់ រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះសម្ពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោវណ្ណកោន្តរិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

**ចប់ សោវណ្ណកោន្តរិកត្ថេរាបទាន ។**

## ឧទ្ទាន

សកឹសម្មជ្ជកត្ថេរាបទាន ១ ឯកទុស្សទាយកត្ថេរាបទាន ១ ឯកាសនទាយកត្ថេរាបទាន ១ សត្តកទម្ពបុប្ផិយត្ថេរាបទាន ១ កោរណ្ឌបុប្ផិយត្ថេរាបទាន ១ ឃដមណ្ឌទាយកត្ថេរាបទាន ១ ឯកធម្មស្សវនិយត្ថេរាបទាន ១ សុចិន្តិតត្ថេរាបទាន ១ សោណ្ណកឹកណិយត្ថេរាបទាន ១ សោវណ្ណកោន្តរិកត្ថេរាបទាន ១ ក្នុងសកឹសម្មជ្ជកវគ្គនេះ មានគាថា ១៧២ ។

## ចប់ សកឹសម្មជ្ជកវគ្គ ទី ៤៣ ។

# សក្កីសម្មជ្ជកវគ្គ ទី ៤៣

## អដ្ឋកថា សក្កីសម្មជ្ជកត្ថេរាបទាន ជាដើម

[ ១១-២០ ] អបទានរបស់ព្រះថេរៈទាំងអស់ក្នុងវគ្គទី ៤៣ មានអត្ថងាយយល់ហើយនោះឯង ផ្សេងគ្នាត្រឹមតែឈ្មោះរបស់ព្រះថេរៈ និងបុណ្យរបស់ព្រះថេរៈប៉ុណ្ណោះ ។

*អដ្ឋកថាសក្កីសម្មជ្ជកត្ថេរាបទានជាដើម ចប់*

# ឯកវិហារិវគ្គ ទី ៤៤

## ឯកវិហារិយត្ថេរាបទានទី ១

[ ២១ ] ព្រះសម្ពុទ្ធព្រះនាមកស្សបៈដោយគោត្ត ព្រះអង្គមានផៅពង្សប្រសើរ ទ្រង់មានយសប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់ត្រាស់ឡើងហើយក្នុងកប្បនេះ ។ ព្រះអង្គមិនមានធម៌នាំឲ្យយឺតយូរ មិនជាប់អារម្មណ៍ ទ្រង់មានព្រះហឫទ័យស្មើអាកាស ព្រះអង្គច្រើនទៅដោយធម៌ដ៏សូន្យចាកកិលេស ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ទ្រង់ត្រេកអរក្នុងអនិមិត្ត គង់នៅហើយ ។ ព្រះអង្គមានព្រះហឫទ័យមិនជាប់ចំពាក់ មិនមានកិលេសជាគ្រឿងលាប មិនប្រឡូកប្រឡំក្នុងត្រកូលនិងពួកគណៈ ព្រះអង្គជាអ្នកប្រាជ្ញប្រកបដោយករុណាដ៏ធំ ទ្រង់ឈ្លាសវៃក្នុងឧបាយជាគ្រឿងណែនាំ ។ ព្រះអង្គប្រកបក្នុងកិច្ចរបស់បុគ្គលដទៃ ទ្រង់ទូន្មានពួកមនុស្សព្រមទាំងទេវតា ឲ្យទៅកាន់ផ្លូវជាទីទៅកាន់ព្រះនិព្វាន ជាគ្រឿងញ៉ាំងភក់គឺគតិឲ្យរីងស្ងួត ។ ព្រះអង្គជាអ្នកចម្លងសត្វលោក ទ្រង់គង់នៅក្នុងកណ្តាលនៃបរិស័ទធំ ( ទ្រង់សម្តែង ) នូវអមតៈ គឺព្រះនិព្វានដែលជាគ្រឿងត្រេកអរយ៉ាងក្រៃលែង ជាគ្រឿងរាំងរានូវជរានិងមរណៈបាន ។ ព្រះតថាគត ទ្រង់ជាទីពឹងនៃសត្វលោក ព្រះអង្គមានសំឡេងដូចសត្វករវិក មានសំឡេងគឹកកងដូចជាសំឡេងនៃព្រហ្ម ទ្រង់ស្រោចស្រង់ពពួកសត្វដែលដល់ហើយនូវសេចក្តីវិនាស មិនមានអ្នកដឹកនាំ ព្រះអង្គឲ្យរួចចាកទុក្ខធំ ។ ព្រះអង្គជានាយកនៃសត្វលោក ទ្រង់សម្តែងធម៌ដ៏ប្រាសចាកធូលី ខ្ញុំបានឃើញហើយ ទាំងបានស្តាប់ធម៌របស់ព្រះអង្គ ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសស្រេចហើយ ក៏ប្រឹងយកចិត្តទុកដាក់នឹង

សាសនានៃព្រះជិនស្រី ត្រូវសេចក្តីជាប់ចំពាក់បៀតបៀន ក៏នៅក្នុងព្រៃជាទីរីករាយតែម្នាក់ឯង ។ ការចេញចាកពួកដោយកាយរបស់ខ្លួននៃខ្ញុំ ជាហេតុនៃការចេញចាកពួក ដោយចិត្តនៃខ្ញុំ ដែលជាអ្នកឃើញភ័យក្នុងការជាប់ចំពាក់ក៏មានមកដល់ខ្ញុំ ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកវិហារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឯកវិហារិយត្ថេរាបទាន ។**

# ឯកសង្ខិយត្ថេរាបទាន ទី ២

[ ២២ ] មានពិធីធ្វើដើមពោធិព្រឹក្សរបស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី មហាជនមកជួបជុំគ្នាបូជាដើមពោធិព្រឹក្សដ៏ឧត្តម ។ ដើមពោធិព្រឹក្សប្រាកដដូច្នេះរបស់ព្រះសាស្តាអង្គណាដែលជនទាំងឡាយគួរបូជា ព្រះសាស្តាអង្គនោះ ជាព្រះសម្ពុទ្ធដ៏ប្រសើរ ទ្រង់មានប្រាជ្ញា ព្រះអង្គប្រាសចាកសេចក្តី

សោកដ៏ធំ ។ លំដាប់នោះ ខ្ញុំកាន់ស្ល័ទ្ធចូលទៅបម្រើពោធិព្រឹក្ស ខ្ញុំផ្ទុំស្ល័ទ្ធហើយ ថ្វាយបង្គំពោធិព្រឹក្សដ៏ឧត្តមតែរាល់ៗថ្ងៃ ។ កុសលកម្មដែលខ្ញុំធ្វើហើយក្នុងទីជិត ខ្ញុំក៏បានទៅកើតក្នុងទេវលោក សាកសព ខ្ញុំទម្លាក់ចោលហើយ ខ្ញុំតែងត្រេកអរក្នុងទេវលោក ។ ខ្ញុំតែងត្រេកត្រអាល ស្រស់ស្រាយរីករាយនឹងតូរ្យតន្ត្រី ៦ ម៉ឺន តូរ្យតន្ត្រីនោះ តែងបម្រើខ្ញុំសព្វៗកាល នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧១ ខ្ញុំបានកើតជាស្ដេចឈ្មោះសុទស្សនៈ ជាអ្នកឈ្នះសង្គ្រាម មានសមុទ្ទទាំង ៤ ជាព្រំប្រទល់ ជាឥស្សរៈក្នុងជម្ពូទ្វីប ។ លំដាប់នោះ តូរ្យតន្ត្រី ៨០០ តែងចោមរោមខ្ញុំសព្វៗកាល ខ្ញុំបានទទួលផលនៃកុសលកម្មរបស់ខ្លួន នេះជាផលនៃការបម្រើ ។ ខ្ញុំកើតក្នុងកំណើតណាៗ ទោះជាទេវតាឬជាមនុស្ស កាលដែលខ្ញុំឋិតនៅក្នុងផ្ទៃនៃមាតា ស្គរទាំងឡាយតែងប្រគំសព្វៗកាល ។ ព្រោះខ្ញុំបម្រើនូវព្រះសម្ពុទ្ធ ទើបបានសម្បត្តិទាំងឡាយ ហើយដល់នូវព្រះនិព្វាន ជាបទដ៏ក្សេម មិនមានមន្ទិល មិនចេះស្លាប់ មិនកម្រើក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរផ្ដាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំ

ក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកសន្និយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឯកសន្និយត្ថេរាបទាន ។**

# ចាដិហិរសញ្ញកត្ថេរាបទានទី ៣

[ ២៣ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា ក្នុងកាលនោះ ព្រះអង្គស្តេចចូលទៅក្នុងទីក្រុង មួយអន្លើដោយភិក្ខុមួយសែនអង្គសុទ្ធតែជាអ្នកស្ងាត់ស្ងៀម ។ កាលព្រះសម្ពុទ្ធទ្រង់មានព្រះហឫទ័យស្ងប់រម្ងាប់ មិនញាប់ញ័រដោយលោកធម៌ ស្តេចចូលទៅក្នុងទីក្រុង ក្នុងខណៈនោះមានសំឡេងគឹកកងក្នុងការក្រោកទទួល ត្រង់ច្រកផ្លូវ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធស្តេចចូលទៅក្នុងបុរី ពិណទាំងឡាយ បុគ្គលឥតប្រគំ ឥតវាយឡើយក៏ស្រាប់តែប្រគំដោយខ្លួនឯង ដោយអានុភាពនៃព្រះពុទ្ធ ។ ខ្ញុំក៏នមស្ការនូវព្រះពុទ្ធដ៏ប្រសើរ ព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញធំផង ឃើញនូវបាដិហារ្យហើយញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងបាដិហារ្យនោះផងថា ឱ ! ព្រះពុទ្ធ ឱ ! ព្រះធម៌ ឱ ! សម្បទានៃព្រះសាស្តារបស់យើងទាំងឡាយ តូរ្យតន្ត្រីទាំងឡាយ សូម្បីឥតចេតនាសោះ ក៏បែរជាប្រគំដោយខ្លួនឯង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ

នេះជាផលនៃសេចក្ដីសម្គាល់ក្នុងព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំបានដុត បំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមាន អាសវៈ ដូចជាដំរីដ៏ប្រសើរផ្ដាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ហើយ ។

បានឮថា ព្រះបាដិហិរសញ្ញកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បាដិហិរសញ្ញកត្ថេរាបទាន ។**

# ញាណត្ថវិកត្ថេរាបទានទី ៤

[ ២៤ ] ខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់រុងរឿងដូច ផ្កាកណិការ ឬដូចដើមទីបព្រឹក្សដ៏ភ្លឺព្រោងព្រាត ពុំនោះសោត ដូចជាមាស ភ្លឺរន្ទាលប្រាលឆ្អៅ ។ ខ្ញុំតម្កល់ទុកនូវឋូទឹក សំពត់សម្បកឈើ និងកុណ្ឌីទឹក ហើយធ្វើសំពត់ស្បែកខ្លាធៀងស្មាម្ខាង ពោលសរសើរនូវព្រះពុទ្ធដ៏ប្រសើរថា បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ដ៏ជេរជាសដោយ បណ្ដាញគឺមោហៈ ទ្រង់សម្ដែងនូវពន្លឺគឺញាណ ព្រះអង្គទ្រង់ឆ្លងទុក្ខផុតហើយ

ព្រះអង្គទ្រង់ស្រោចស្រង់នូវលោកទាំងអស់នេះដែលមិនទាន់រើខ្លួនរួច ដំណើរនៃផែនដីមានកំណត់ត្រឹមណា សេចក្តីប្រៀបផ្ទឹមដោយញាណរបស់ព្រះអង្គមិនមានកំណត់ត្រឹមនោះឡើយ ។ ព្រះសម្ពុទ្ធដែលអ្នកប្រាជ្ញទាំងឡាយហៅថា សព្វញ្ញូ សព្វញ្ញូ ព្រោះញាណនោះ ខ្ញុំសូមថ្វាយបង្គំនូវព្រះសព្វញ្ញូអង្គនោះ ដែលមានព្យាយាមធំ ទាំងមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំពោលសរសើរនូវព្រះសម្ពុទ្ធដ៏ប្រសើរ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសរសើរនូវព្រះញាណ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុង សម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិរួចហើយ ។

បានឮថា ព្រះញាណត្ថវិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ញាណត្ថវិកត្ថេរាបទាន ។

## ឧច្ចង្គណ្ហិកត្ថេរាបទានទី ៥

[ ២៥ ] ខ្ញុំកើតជាអ្នករក្សាទ្វារក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ព្រះអង្គមានធូលីទៅប្រាសហើយ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកអំពៅមួយកំណាត់ទៅថ្វាយព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវិបស្សី ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយអំពៅ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអំពៅមួយកំណាត់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧច្ចង្គណ្ឌិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧច្ចង្គណ្ឌិកត្ថេរាបទាន ។**

## កលម្ពទាយកត្ថេរាបទានទី ៦

[ ២៦ ] ព្រះសម្ពុទ្ធព្រះនាមវេមសៈ គង់នៅក្នុងចន្លោះភ្នំ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយដំឡូងដូងដល់ព្រះសម្ពុទ្ធអង្គនោះដោយដៃនៃខ្លួន ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដំឡូងដូង ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ដំណើរដែល ខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកលម្ពទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ កលម្ពទាយកត្ថេរាបទាន ។

## អម្ពាដកទាយកត្ថេរាបទានទី ៧

[ ២៧ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាព្រះសយម្ភូ គង់នៅក្នុងព្រៃធំ ព្រះអង្គទ្រង់ឈ្នះកិលេសមារ ហើយយកផ្លែម្កាក់ទៅថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែម្កាក់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែម្កាក់ ។ កិលេសទាំងឡាយ

ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពាដកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អម្ពាដកទាយកត្ថេរាបទាន ។**

# ហរីតកិទាយកត្ថេរាបទានទី ៨

[ ២៨ ] ខ្ញុំកំពុងតែនាំយកនូវផ្លែសម៉ ផ្លែកន្ទួតព្រៃ ផ្លែស្វាយ ផ្លែព្រីង ផ្លែសម៉ពិភេទក៍ ផ្លែពុទ្រា ផ្លែក្រខុប និងផ្លែព្នៅដោយខ្លួនឯង ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ព្រះអង្គគង់នៅក្នុងញកភ្នំ ទ្រង់មានឈាន ត្រេកអរក្នុងឈាន ជាមហាមុនីដ៏មាំមួនដែលកំពុងត្រូវអាពាធបៀតបៀន ។ ខ្ញុំយកផ្លែសម៉ទៅថ្វាយព្រះសយម្ភូ ភេសជ្ជៈគ្រាន់តែខ្ញុំធ្វើរួចហើយ ព្យាធិក៏រម្ងាប់ក្នុងខណៈនោះភ្លាម ។ ព្រះសម្ពុទ្ធទ្រង់លះបង់សេចក្តីក្រវល់ក្រវាយ បានធ្វើអនុមោទនា ព្រោះភេសជ្ជៈទាននេះផង ព្រោះការរម្ងាប់នូវព្យាធិនេះផងថា អ្នក

កើតជាទេវតាក្តី ជាមនុស្សក្តី ឬកើតក្នុងជាតិដទៃក្តី សូមឲ្យជាអ្នកដល់នូវសេចក្តីសុខក្នុងទីទាំងពួង មួយទៀត សូមកុំឲ្យព្យាធិកើតមានដល់អ្នកឡើយ ។ ព្រះសម្ពុទ្ធជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស ជាអ្នកប្រាជ្ញ លុះត្រាស់ពាក្យនេះហើយ ក៏ទ្រង់ហោះទៅឯអាកាស ដូចជាស្តេចហង្សដែលហើរទៅឰដ៏អាកាស ។ កាលដែលខ្ញុំបានថ្វាយផ្លែសម៉ដល់ព្រះសយម្ភូ ជាមហេសី ព្យាធិក៏មិនកើតឡើងដល់ខ្ញុំរហូតជាតិនេះ ។ នេះរាងកាយខាងក្រោយបំផុតរបស់ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយភេសជ្ជៈក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះហរីតកិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ហរីតកិទាយកត្ថេរាបទាន ។**

# អម្ពបិណ្ឌិយត្ថេរាបទានទី ៩

[ ២៩ ] កាលនោះ ខ្ញុំកើតជាស្តេចដំរីមានភ្លុកងទន្ទាំ មានកម្លាំងច្រើន កំពុងត្រាច់ទៅក្នុងព្រៃធំ ក៏បានឃើញព្រះបរមលោកនាយក ។ ខ្ញុំបានយកផ្លែស្វាយមួយចង្កោម ថ្វាយព្រះសាស្តា ឯព្រះសិទ្ធត្ថៈ ទ្រង់មានព្យាយាមធំ ជាលោកនាយក ទ្រង់បានទទួល ។ កាលនោះ ខ្ញុំកំពុងតែសម្លឹងមើលព្រះជិនស្រីទ្រង់សោយហើយ ខ្ញុំក៏ញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គ ហើយបានទៅកើតក្នុងឋានតុសិត ។ ខ្ញុំច្យុតចាកឋានតុសិតនោះមក បានជាស្តេចចក្កពត្តិសោយនូវសម្បត្តិទាំងឡាយដោយឧបាយនុ៎ះឯង ។ ខ្ញុំមានចិត្តបញ្ជូនទៅកាន់ព្យាយាម ជាអ្នកស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពបិណ្ឌិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អម្ពបិណ្ឌិយត្ថេរាបទាន ។**

# ជម្ពុផលិយត្ថេរាបទានទី ១០

[ ៣០ ] កាលព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈជាច្បងក្នុងលោក ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ទ្រទ្រង់នូវយសដ៏ឧត្តម ទ្រង់ស្តេចយាងបិណ្ឌបាត ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែឈើថ្នាំង ចូលទៅថ្វាយព្រះសាស្តាព្រះអង្គជាទក្ខិណេយ្យបុគ្គល ជាអ្នកប្រាជ្ញធ្ងើម ( ហើយពោលថា ) បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ប្រសើរជាងពួកជន ខ្ញុំព្រះអង្គសូមលះបង់នូវការឈ្នះនិងការចាញ់ ហើយដល់នូវធម៌មិនកម្រើកគឺព្រះនិព្វាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានថ្នាំង ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជម្ពុផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ជម្ពុផលិយត្ថេរាបទាន ។**

## ឧទ្ទាន

ឯកវិហារិយត្ថេរាបទាន ១ ឯកសង្ខិយត្ថេរាបទាន ១ បាដិហិរសញ្ញកត្ថេរាបទាន ១ ញាណត្ថវិកត្ថេរាបទាន ១ ឧច្ឆុខណ្ឌិកត្ថេរាបទាន ១ កលម្ពទាយកត្ថេរាបទាន ១ អម្ពាដកទាយកត្ថេរាបទាន ១ ហរីតកិទាយកត្ថេរាបទាន ១ អម្ពបិណ្ឌិយត្ថេរាបទាន ១ ជម្ពុផលិយត្ថេរាបទាន ១ ជាគម្រប់ ១០ គាថាចំនួន ៨៦ អ្នកប្រាជ្ញបានរាប់ឃើញហើយ ។

## ចប់ ឯកវិហារិកវគ្គ ទី ៤៤ ។

# ឯកវិហារិវគ្គ ទី ៤៤

## អដ្ឋកថា ឯកវិហារិយត្ថេរាបទាន ជាដើម

*[ ២១-៣០ ] អបទានក្នុងវគ្គទី ៤៤ ទាំងអស់ ប្រាកដច្បាស់ហើយដូចគ្នា ផ្សេងគ្នាត្រឹមតែបុណ្យ និងផ្សេងគ្នាត្រឹមតែផល ( វិបាក ) ប៉ុណ្ណោះ ។*

*អដ្ឋកថាឯកវិហារិយត្ថេរាបទានជាដើម ចប់*

# វិភេទកិវគ្គ ទី ៤៥

## វិភេទកពីជិយត្ថេរាបទាន ទី ១

[ ៣១ ] ព្រះសម្ពុទ្ធព្រះនាមកកុសន្ធៈ មានព្យាយាមធំ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គទ្រង់ចៀសចេញចាកពួក ហើយស្តេចទៅតាមចន្លោះព្រៃ ។ ខ្ញុំយកផ្លែសម៉ពិភេទក៍ដោតនឹងវល្លិ៍ សម័យនោះ ព្រះមានព្រះភាគទ្រង់ចម្រើនឈានត្រង់ចន្លោះភ្នំ ខ្ញុំបានឃើញព្រះមានព្រះភាគ ជាទេវតាក្រៃលែងជាងទេវតា ក៏មានចិត្តជ្រះថ្លា ហើយថ្វាយផ្លែសម៉ពិភេទក៍ដល់ព្រះអង្គ ជាអ្នកប្រាជ្ញ ជាទក្ខិណេយ្យបុគ្គល ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែសម៉ពិភេទក៍ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែសម៉ពិភេទក៍ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវិភេទកពីជិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ វិភេទកពីជិយត្ថេរាបទាន ។**

# វិភេទកវគ្គ ទី ៤៥

## អដ្ឋកថា វិភេទកពីជិយត្ថេរាបទាន

[ ៣១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ វគ្គទី ៤៥ ដូចតទៅនេះថា

អបទានរបស់ព្រះវិភីដកមិញ្ជិយត្ថេរ មានពាក្យផ្ដើមថា **កកុសន្ធោ មហាវីរោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពីជមិញ្ជមទាសហំ** សេចក្ដីថា ខ្ញុំបានពុះផ្លែសម៉ាពិភេក ហើយកាន់យកគ្រាប់ក្នុងពូជ ផ្សំជាមួយទឹកឃ្មុំនិងស្ករក្រាម ថ្វាយដល់ព្រះមានព្រះភាគ ព្រះនាមថាកកុសន្ធៈ ។

អដ្ឋកថា វិភេទកពីជិយត្ថេរាបទាន ចប់

# កោលទាយកត្ថេរាបទានទី ២

[ ៣២ ] កាលនោះ ខ្ញុំស្លៀកស្បែកខ្លា ទ្រទ្រង់សំពត់សម្បកឈើ បាន
រែកផ្លែពុទ្រាមួយអម្រែក ទៅឯអាស្រមរបស់ខ្ញុំ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធ
ព្រះនាមសិខី ព្រះអង្គមិនមានបុគ្គលជាគម្រប់ពីរ រុងរឿងសព្វៗកាល ទ្រង់
ស្តេចចូលទៅក្នុងអាស្រមរបស់ខ្ញុំតែមួយព្រះអង្គឯង ។ ខ្ញុំញុំាងចិត្តរបស់ខ្លួន
ឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គមានវត្តល្អ រួចកាន់យកនូវផ្លែ
ពុទ្រាដោយដៃទាំងពីរថ្វាយដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ
ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែពុទ្រា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ
នេះជាផលនៃការថ្វាយផ្លែពុទ្រា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ
ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ
កាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជា
ដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើ
ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់
ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ
ដោយប្រការដូច្នេះ ។

**ចប់ កោលទាយកត្ថេរាបទាន ។**

# វេឡុវផលិយត្ថេរាបទានទី ៣

[ ៣៣ ] អាស្រមរបស់ខ្ញុំ ខ្ញុំបានធ្វើល្អហើយ ទៀបឆ្នេរស្ទឹងចន្ទភាគា ជាអាស្រមដ៏ដេរដាសដោយដើមញ្ញៅ ទាំងមានពួកឈើផ្សេង ៗ ដុះនៅក្បែរ អាស្រមនោះ ខ្ញុំបានឃើញផ្លែញ្ញៅមានក្លិនក្រអូប បានបេះផ្លែញ្ញៅនោះ ដាក់ពេញភារៈ គឺអង្រែក ហើយត្រេកអរ មានចិត្តសង្វេគ នឹកដល់ព្រះសម្ពុទ្ធ ដ៏ប្រសើរ ។ ខ្ញុំបានចូលទៅគាល់ព្រះអង្គ ព្រះនាមកកុសន្ធៈ ហើយថ្វាយផ្លែញ្ញៅទុំដល់ព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ជាស្រែបុណ្យ ដោយចិត្តជ្រះថ្លា ។ ក្នុងកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែញ្ញៅក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែញ្ញៅ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញចេញហើយ ភពទាំងអស់ខ្ញុំបានដករំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេឡុវផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ វេឡុវផលិយត្ថេរាបទាន ។**

## ភល្លាតកទាយកត្ថេរាបទានទី ៤

[ ៣៤ ] ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ទ្រង់ស្តេចទៅកាន់ជាយព្រៃធំ ព្រះអង្គដូចជាសាលរាជព្រឹក្ស មានផ្ការីកហើយ ។ ខ្ញុំក្រាលកម្រាលស្មៅ រួចហើយអារាធនាព្រះសម្ពុទ្ធដ៏ប្រសើរថា សូមព្រះសម្ពុទ្ធអនុគ្រោះខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គប្រាថ្នានឹងថ្វាយចង្ហាន់ ។ ឯព្រះសម្ពុទ្ធទ្រង់ព្រះនាមអត្ថទស្សី ទ្រង់អនុគ្រោះ ប្រកបដោយករុណា ទ្រង់មានយសធំ ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ហើយស្តេចចូលទៅក្នុងអាស្រមរបស់ខ្ញុំ ។ ព្រះសម្ពុទ្ធស្តេចចូលទៅគង់លើកម្រាលស្លឹកឈើ ខ្ញុំបានយកផ្លែក្រខុបថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ។ កាលខ្ញុំកំពុងសម្លឹងមើល ព្រះជិនស្រីទ្រង់សោយរួចហើយ ខ្ញុំក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គ ហើយថ្វាយបង្គំព្រះជិនស្រីក្នុងកាលនោះ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភល្លាតកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ភល្លាតកទាយកត្ថេរាបទាន ។**

# ឧម្មាបុប្ផិយត្ថេរាបទានទី ៥

[ ៣៥ ] កាលដើមជ្រៃជាពោធិព្រឹក្សដុះឡើង មានពន្លឺខៀវខ្ចី ខ្ញុំបានយកកម្រងផ្កាកប្បាស ទៅបូជាពោធិព្រឹក្សនោះ ។ ក្នុងកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាពោធិព្រឹក្សក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាពោធិព្រឹក្ស ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧម្មាបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧម្មាបុប្ផិយត្ថេរាបទាន ។**

# អម្ពាដកិយត្ថេរាបទានទី ៦

[ ៣៦ ] ព្រះសម្ពុទ្ធព្រះនាមវេស្សភូ ជាអ្នកប្រាជ្ញ ស្តេចចូលទៅក្នុងសាលវ័ន ( ព្រៃរាំងភ្នំ ) ដែលមានផ្ការីកល្អ ហើយគង់ក្បែរជ្រោះភ្នំដែលគេទៅបានដោយលំបាក ដូចកេសររាជសីហ៍ ជាសត្វមានជាតិខ្ពស់ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាម្កាក់ចំពោះព្រះសម្ពុទ្ធ ជាស្រែបុណ្យ

ដែលមានព្យាយាមធំ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពាដកិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អម្ពាដកិយត្ថេរាបទាន ។**

# សីហាសនិកត្ថេរាបទានទី ៧

[ ៣៧ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយសីហាសនៈ ដល់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ព្រះអង្គស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ។ ខ្ញុំនៅក្នុងទីណាៗ ក្នុងទេវលោក ឬក្នុងមនុស្សលោក រមែងបាននូវវិមានដ៏ធំទូលាយ ក្នុងទីនោះៗ នេះជាផលនៃសីហាសនៈ ។ បល្ល័ង្កទាំងឡាយដ៏ច្រើន សុទ្ធតែជាវិការៈនៃមាសនិងប្រាក់ផង ជាវិការៈនៃកែវក្រហម

*ផង ជាវិការៈនៃកែវមណីផង តែងកើតឡើងសម្រាប់ខ្ញុំសព្វៗកាល ។ ខ្ញុំកើតក្នុងត្រកូលខ្ពស់ ព្រោះតែធ្វើអាសនៈទៀបដើមពោធិព្រឹក្សថ្វាយព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ឱ ! ភាពនៃព្រះធម៌ជាធម៌ដ៏ល្អ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវសីហាសនៈក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសីហាសនៈ ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះសីហាសនិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។*

## *ចប់ សីហាសនិកត្ថេរាបទាន ។*

# ទានបីបិយត្ថេរាបទានទី ៨

[ ៣៨ ] ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ជាអ្នកប្រាជ្ញធំ ប្រកបដោយករុណា ទ្រង់ចម្លងនូវសត្វទាំងឡាយដ៏ច្រើន ព្រះអង្គមានយសធំ ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើតាំងសម្រាប់វេទព្រះបាទ ទុកក្នុងទីជិតនៃសីហាសនៈរបស់ព្រះសម្ពុទ្ធព្រះនាម សុមេធៈ ព្រះអង្គស្វែងរកនូវគុណធំនោះ ។ ខ្ញុំធ្វើកុសលមានសុខជាវិបាក មានសុខជាកម្រៃ ប្រកបដោយបុញ្ញកម្ម ក៏ទៅកើតក្នុងឋានតាវត្តិង្ស ។ កាលខ្ញុំនៅក្នុងទេវលោកនោះ ជាអ្នកប្រកបដោយបុញ្ញកម្ម កាលខ្ញុំដកជើងផុតឡើង តាំងជាវិការៈនៃមាស ក៏កើតឡើងសម្រាប់ខ្ញុំ ។ ឱ! ជាលាភរបស់គេហើយ ឱ! អត្តភាពជាមនុស្សឈ្មោះថាគេបានល្អហើយ ព្រោះថា ជនទាំងឡាយបាននូវការចូលទៅអែបស្តាប់ ធ្វើនូវគ្រឿងសក្ការៈ ថ្វាយព្រះសម្ពុទ្ធ ដែលទ្រង់បរិនិព្វានហើយ រមែងបាននូវសេចក្តីសុខដ៏ធំទូលាយ ។ អំពើខ្ញុំធ្វើល្អហើយ ខ្ញុំប្រកបល្អហើយក្នុងការជួញ ខ្ញុំបានតាំងជាវិការៈនៃមាស ព្រោះតែខ្ញុំធ្វើនូវតាំងសម្រាប់វេទព្រះបាទ ។ ខ្ញុំចេញទៅក្នុងទិសណាៗ ដោយកិច្ចណានីមួយ ខ្ញុំក៏ជាន់លើតាំងមាស នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានធ្វើនូវអំពើកុសលក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃតាំងសម្រាប់វេទព្រះបាទ ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ! ដំណើរដែលខ្ញុំបានមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤

វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបាទបីបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បាទបីបិយត្ថេរាបទាន ។**

# វេទិយការកត្ថេរាបទានទី ៩

[ ៣៩ ] ខ្ញុំកសាងកំពែងដ៏ល្អ ទៀបដើមពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ។ ភណ្ឌៈទាំងឡាយដ៏ប្រសើរលើសលុបដែលគេធ្វើហើយក្តី គេមិនទាន់ធ្វើហើយក្តី រមែងធ្លាក់ចុះមកអំពីអាកាស នេះជាផលនៃកំពែង ។ ខ្ញុំស្ទុះចូលទៅក្នុងពួកសង្គ្រាមជាទីគួរខ្លាចដោយចំណែកទាំងពីរ ក៏មិនឃើញនូវភ័យដែលគួរខ្លាច នេះជាផលនៃកំពែង វិមានដ៏ល្អរមែងកើតឡើង ទីដេកទាំងឡាយជារបស់មានតម្លៃច្រើន ក៏កើតឡើងព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ នេះជាផលនៃកំពែង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកំពែងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកំពែង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ! ដំណើរដែលខ្ញុំ មកក្នុងសម្នាក់នៃ

ព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេទិយការកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ វេទិយការកត្ថេរាបទាន ។**

## ពោធិឃរការកត្ថេរាបទាន ទី ១០

[ ៤០ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើវេទិនៃដើមពោធិព្រឹក្សរបស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ព្រះអង្គជាធំជាងសត្វជើងពីរ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ខ្ញុំបានទៅកើតក្នុងឋានតុសិត នៅក្នុងផ្ទះកែវសម្លស្សទាំងឡាយត្រជាក់ក្តី ក្តៅក្តី ខ្យល់ក្តី មិនដែលពាល់ត្រូវខ្លួនខ្ញុំឡើយ ។ ក្នុងកប្បទី ៦៥ អំពីកប្បនេះ ខ្ញុំកើតជាស្តេចចក្កពត្តិ នគររបស់ស្តេចនោះឈ្មោះកាសិកៈ ដែលវិស្សកម្មទេវបុត្តសាងថ្វាយ ។ ( នគរនោះ ) មានបណ្តោយ ១០ យោជន៍ ទំហំ ៨ យោជន៍ ឈើក្តី វល្លិក្តី ដីស្អិតក្តី មិនមានក្នុងនគរនោះឡើយ ។ ប្រាសាទឈ្មោះមង្គលៈ ដែលវិស្សុកម្មទេវបុត្តសាងថ្វាយ មានទទឹង ១ យោជន៍ ទំហំកន្លះយោជន៍ ។ សសរ ៨៤០០០ សឹងជាវិការៈនៃមាស ប្រាសាទកំពូលជាវិការៈនៃកែវមណី ជំបូលជាវិការៈ

នៃប្រាក់ ។ ផ្ទះជាវិការៈនៃមាសទាំងអស់ ដែលវិស្សុកម្មទេវបុត្តសាងថ្វាយហើយ ផ្ទះនុ៎ះ ខ្ញុំនៅអាស្រ័យហើយ នេះជាផលនៃការឲ្យនូវខឿន ។ ខ្ញុំបានសោយនូវភពជារបស់ទេវតានិងមនុស្សទាំងអស់នោះហើយ ដល់នូវព្រះនិព្វានជាបទដ៏ស្ងប់ប្រសើរក្នុងថ្ងៃនេះ ។ ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានធ្វើខឿនពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវខឿន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិឃរការកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ពោធិឃរការកត្ថេរាបទាន ។**

## ឧទ្ទាន

វិភេទកពីជិយត្ថេរាបទាន ១ កោលទាយកត្ថេរាបទាន ១ វេលុវផលិយត្ថេរាបទាន ១ កល្លាតកទាយកត្ថេរាបទាន ១ ឧម្មាបុប្ផិយត្ថេរាបទាន ១ អម្ពាដកិយត្ថេរាបទាន ១ សីហាសនិកត្ថេរាបទាន ១ បាទបីឋិយត្ថេរាបទាន ១ វេទិយការកត្ថេរាបទាន ១ ពោធិឃរការកត្ថេរាបទាន ១ គាថាទាំង-ឡាយដែលលោកសម្តែងទុកហើយក្នុងវគ្គនេះ រាប់ទៅឃើញទាំងអស់មានចំនួន ៧៩ គាថា ។

## ចប់ វិភេទកិវគ្គ ទី ៤៥ ។

# អដ្ឋកថា

# កោលទាយកត្ថេរាបទាន ជាដើម

[ ៣២-៤០ ] អបទានទាំងអស់ មានអបទានទី ២ ជាដើមទៅ មានអត្ថដ៏ងបានងាយហើយ ឈ្មោះរបស់ព្រះថេរៈទាំងឡាយដែលផ្សេងគ្នាជាដើម ក៏គប្បីជ្រាបបានតាមគន្លងព្រះបាលីនោះឯង ។

អដ្ឋកថាកោលទាយកត្ថេរាបទានជាដើម ចប់

# ជគតិវគ្គ ទី ៤៦

## ជគតិទាយកត្ថេរាបទាន ទី ១

[ ៤១ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឲ្យគេពូនផែនដី ជិតដើមពោធិព្រឹក្សដ៏ឧត្តម របស់ព្រះមហាមុនី ព្រះនាមធម្មទស្សី ។ ខ្ញុំរបូតធ្លាក់ក្នុងជ្រោះក្តី អំពីភ្នំក្តី អំពីដើមឈើក្តី រមែងបាននូវទីពឹង នេះជាផលនៃការពូនផែនដី ។ ចោរទាំងឡាយមិនហ៊ានបៀតបៀនខ្ញុំ ក្សត្រទាំងឡាយមិនហ៊ានមើលងាយខ្ញុំ ខ្ញុំកន្លងផុតនូវសត្រូវទាំងពួង នេះជាផលនៃការពូនផែនដី ។ ខ្ញុំកើតក្នុងកំណើតណាៗ ទោះជាទេវតាឬជាមនុស្ស អ្នកផងតែងបូជាក្នុងទីទាំងពួង នេះជាផលនៃការពូនផែនដី ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យគេពូនផែនដីក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការពូនផែនដី ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជគតិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ជគតិទាយកត្ថេរាបទាន ។**

# មោរហត្ថិយត្ថេរាបទានទី ២

[ ៤២ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្តិតស្លាបក្ងោកចូលទៅថ្វាយព្រះលោកនាយក ។ ភ្លើងទាំងបីរបស់ខ្ញុំរលត់ហើយ ខ្ញុំបាននូវសេចក្តីសុខដ៏ធំទូលាយ ដោយសារផ្តិតស្លាបក្ងោកនេះផង ដោយការតម្កល់នូវចេតនានេះផង ។ ឱហ្ន៎ ព្រះពុទ្ធ ឱហ្ន៎ ព្រះធម៌ ឱហ្ន៎ សម្បទារបស់ព្រះសាស្តានៃយើងទាំងឡាយ ខ្ញុំបាននូវសេចក្តីសុខដ៏ធំទូលាយ ព្រោះបានថ្វាយផ្តិតស្លាបក្ងោក ។ ភ្លើងទាំង ៣ របស់ខ្ញុំរលត់ហើយ ភពទាំងពួងខ្ញុំដកចោលហើយ អាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្តិតស្លាបក្ងោក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោរហត្ថិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ មោរហត្ថិយត្ថេរាបទាន ។**

# សីហាសនពីជិយត្ថេរាបទានទី ៣

[ ៤៣ ] ខ្ញុំបានទៅថ្វាយបង្គំពោធិព្រឹក្ស របស់ព្រះមានព្រះភាគព្រះនាមតិស្សៈ រួចហើយខ្ញុំកាន់ផ្ចិតបក់នូវសីហាសនៈ ( អាសនៈដ៏ប្រសើរ ) ដែលគេតម្កល់ក្នុងទីនោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបក់នូវសីហាសនៈក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបក់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីហាសនពីជិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សីហាសនពីជិយត្ថេរាបទាន ។**

# តិណុក្កុជារិយត្ថេរាបទានទី ៤

[ ៤៤ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានអុជគប់ភ្លើង ៣ ( តម្កល់ទុក ) ត្រង់ដើមពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំអុជគប់ភ្លើងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវគប់ភ្លើង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណុក្កុជារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ តិណុក្កុជារិយត្ថេរាបទាន ។**

# អគ្គមនទាយកត្ថេរាបទានទី ៥

[ ៤៥ ] ខ្ញុំបានថ្វាយកម្រាលសម្រាប់ជាន់ដល់ព្រះមុនីព្រះនាមកកុសន្ធៈ ជាទីណាសវព្រាហ្មណ៍ មានព្រហ្មចរិយធម៌នៅហើយ ដែលស្តេចទៅកាន់ទីជាទីសម្រាកក្នុងវេលាថ្ងៃ ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាលសម្រាប់ជាន់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអគ្គមនទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អគ្គមនទាយកត្ថេរាបទាន ។**

# វនកោរណ្ឌិយត្ថេរាបទានទី ៦

[ ៤៦ ] ខ្ញុំបានយកផ្កាកន្ទុយដំរីក្នុងព្រៃ ទៅបូជាចំពោះព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈមានព្រះភាគ ជាធំក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ក្នុងកប្បទី ៩៤ អពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវនកោរណ្ឌិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ វនកោរណ្ឌិយត្ថេរាបទាន ។**

**ចប់ ភាណវារៈទី ២០ ។**

# ឯកច្ឆត្តិយត្ថេរាបទានទី ៧

[ ៤៧ ] ផែនដីកំពុងក្តៅដូចរងើកភ្លើង ផែនដីកំពុងប្រព្រឹត្តទៅដូចជាផេះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ចង្ក្រមក្នុងទីវាល ។ ខ្ញុំបានបាំងឆត្រ-សដើរទៅកាន់ផ្លូវឆ្ងាយ ខ្ញុំឃើញព្រះសម្ពុទ្ធហើយ ក៏កើតគំនិតក្នុងទីនោះថា ផែនដីផ្សាយចេញនូវថ្ងៃបណ្តើរកូន ផែនដីនេះក្តៅដូចជារងើកភ្លើង ខ្យល់ធំខ្លាំងតាំងឡើង បំប៉ើងនូវធូលីទៅកាន់សរីរកាយ ។ ឆត្រនេះសម្រាប់ការពារខ្យល់និងកម្តៅថ្ងៃ កម្ចាត់បង់នូវត្រជាក់និងក្តៅ សូមព្រះអង្គទទួលយកនូវឆត្រនេះចុះ ខ្ញុំព្រះអង្គនឹងបានព្រះនិព្វាន ។ កាលនោះព្រះជិនស្រីព្រះនាមបទុមុត្តរៈ មានយសច្រើន ទ្រង់អនុគ្រោះប្រកបដោយសេចក្តីករុណា ទ្រង់បានទទួលយក ព្រោះជ្រាបនូវតម្រិះរបស់ខ្ញុំ ។ ខ្ញុំកើតជាព្រះឥន្ទជាស្តេចទេវតាសោយរាជ្យក្នុងទេវលោកអស់ ៣០ កប្ប បានជាស្តេចចក្កពត្តិអស់ ៥០០ ដង ។ បានសោយបទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំបានទទួលផលនៃកម្មរបស់ខ្លួនដែលខ្លួនធ្វើល្អហើយក្នុងកាលមុន ។ នេះជាតិជាទីបំផុតរបស់ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ ថ្ងៃនេះឆត្រសគេតែងបាំងឲ្យខ្ញុំសព្វ ៗ កាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយឆត្រ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ

ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកប្ចត្តិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឯកប្ចត្តិយត្ថេរាបទាន ។**

# ជាតិបុប្ផិយត្ថេរាបទានទី ៨

[ ៤៨ ] កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈមានយសធំ ទ្រង់បរិនិព្វានហើយ ខ្ញុំយកផ្កាដាក់ក្នុងប្រអប់ទៅបូជានូវព្រះសរីរៈព្រះអង្គ ។ ព្រោះញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសរីរៈនោះ ខ្ញុំក៏បានទៅកើតក្នុងទេវលោកឈ្មោះនិម្មានរតី លុះខ្ញុំទៅកើតក្នុងទេវលោកហើយ រឭកឃើញនូវបុព្វកម្មនោះ ។ ភ្លៀងផ្កាបង្អុរចុះមកអំពីអាកាសសម្រាប់ខ្ញុំសព្វ ៗ កាល ខ្ញុំកើតក្នុងពួកមនុស្សបានជាស្តេចមានយសច្រើន ។ ភ្លៀងផ្កាបង្អុរចុះមកក្នុងទីនោះសព្វ ៗ កាលសម្រាប់ខ្ញុំ ដែលជាអ្នកឃើញនូវធម៌ទាំងពួងដោយរហ័ស ព្រោះការបូជាផ្កាចំពោះព្រះសរីរកាយនៃព្រះពុទ្ធ ។ នេះភពជាទីបំផុតរបស់ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ ថ្ងៃនេះភ្លៀងផ្កាបង្អុរចុះសម្រាប់ខ្ញុំក្នុងកាលទាំងពួង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជានូវព្រះសរីរកាយ ។ កិលេសទាំង-ឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះជាតិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ជាតិបុប្ផិយត្ថេរាបទាន ។**

# សត្តិបណ្ណិយត្ថេរាបទានទី ៩

[ ៤៩ ] កាលព្រះសរីរៈ ( នៃព្រះសម្ពុទ្ធ ) ដែលពួកជនកំពុងហែចេញ ស្គរគេកំពុងប្រគំថ្វាយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាម្ទិះ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះសរីរៈ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសត្តិបណ្ណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សត្តិបណ្ណិយត្ថេរាបទាន ។**

## គន្ធបូជកត្ថេរាបទានទី ១០

[ ៥០ ] កាលពួកជនកំពុងធ្វើជើងថ្កូវ កំពុងនាំមកនូវគ្រឿងក្រអូបផ្សេងៗ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជានូវគ្រឿងក្រអូបមួយក្តាប់ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាជើងថ្កូវក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្កូវ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគន្ធបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ គន្ធបូជកត្ថេរាបទាន ។**

## ឧទ្ទាន

ជគតិទាយកត្ថេរាបទាន ១ មោរហត្ថិយត្ថេរាបទាន ១ សីហាសនពីជិយត្ថេរាបទាន ១ តិណុក្កធារិយត្ថេរាបទាន ១ អក្កមនទាយកត្ថេរាបទាន ១ វនកោរណ្ឌិយត្ថេរាបទាន ១ ឯកច្ឆត្តិយត្ថេរាបទាន ១ ជាតិបុប្ផិយត្ថេរាបទាន ១ សត្តិបណ្ណិយត្ថេរាបទាន ១ គន្ធបូជកត្ថេរាបទាន ១ ជាគម្រប់ ១០ ឯគាថាមានចំនួន ៦៧ ដែលពួកអ្នកប្រាជ្ញរាប់ឃើញហើយ ។

## ចប់ ជគតិទាយកវគ្គ ទី ៤៦ ។

# ជគតិវគ្គ ទី ៤៦

## អដ្ឋកថា ជគតិទាយកត្ថេរាបទាន ជាដើម

[ ៤១-៥០ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ ជាដើម ក្នុងវគ្គទី ៤៦ ដូចតទៅនេះថា

បទថា **ជគតី ការយិំ អហំ** សេចក្តីថា ខ្ញុំបានធ្វើរបៀងជុំវិញដើមពោធិព្រឹក្សដ៏ឧត្តម ។ អបទានទាំងអស់ មានអបទានទី ២ ជាដើមតទៅ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាជគតិទាយកត្ថេរាបទានជាដើម ចប់

ជគតិវគ្គទី ៤៦ ចប់

# សាលបុប្ផិវគ្គ ទី ៤៧

## សាលកុសុមិយត្ថេរាបទាន ទី ១

[ ៥១ ] កាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈទ្រង់បរិនិព្វានហើយ ខ្ញុំបានបូជាផ្កាវាំងចំពោះជើងថ្ករដែលគេលើកឡើងហើយ ។ ក្នុងកប្បទីមួយ-សែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសាលកុសុមិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សាលកុសុមិយត្ថេរាបទាន ។

# ចិតកបូជកត្ថេរាបទានទី ២

[ ៥២ ] កាលព្រះមានព្រះភាគព្រះនាមសិខី ជាលោកពន្ធុ ដែលជនកំពុងបូជាភ្លើង ខ្ញុំបានបូជាផ្កាចម្ប៉ា ៨ ទង ចំពោះជើងថ្កូវ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ចិតកបូជកត្ថេរាបទាន ។**

# ចិតកនិព្វាបកត្ថេរាបទានទី ៣

[ ៥៣ ] កាលសរីរៈរបស់ព្រះវេស្សភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ដែលជនកំពុងបូជាភ្លើង ខ្ញុំបានយកទឹកអប់រំលត់ជើងថ្ករ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំរំលត់ជើងថ្ករ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកអប់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកនិព្វាបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ចិតកនិព្វាបកត្ថេរាបទាន ។**

## សេតុទាយកត្ថេរាបទានទី ៤

[ ៥៤ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឲ្យគេធ្វើស្ពានថ្វាយក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគព្រះនាមវិបស្សី កំពុងចង្ក្រម ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យគេធ្វើស្ពានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្ពាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសេតុទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សេតុទាយកត្ថេរាបទាន ។**

# សុមនតាលវណ្ដិយត្ថេរាបទានទី ៩

[ ៥៥ ] ខ្ញុំបានយកផាងស្លឹកត្នោត មកស្រោបដោយផ្កាម្លិះ ហើយចាំង ថ្វាយព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ទ្រង់មានយសធំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំថ្វាយផាងស្លឹកត្នោតក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផាងស្លឹកត្នោត ។ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនតាលវណ្ដិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

### ចប់ សុមនតាលវណ្ដិយត្ថេរាបទាន ។

# អវដផលិយត្ថេរាបទានទី ៦

[ ៥៦ ] ព្រះសម្ពុទ្ធមានព្រះភាគ ជាសយម្ភូ ទ្រង់មានរស្មីច្រើន[1] ព្រះអង្គឈ្នះកិលេសមារ ទ្រង់ប្រាថ្នានូវវិវេក ស្តេចចេញទៅដើម្បីគោចរ ។ ខ្ញុំកាន់ផ្លែឈើក្នុងដៃ លុះឃើញព្រះពុទ្ធដ៏ប្រសើរជាងពួកនរៈហើយ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយនូវផ្លែឈើឥតទងនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអវដផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ អវដផលិយត្ថេរាបទាន ។

---

១-ពាក្យថា ទ្រង់មានរស្មីច្រើន គឺព្រះសតរង្សីបច្ចេកពុទ្ធនោះឯង ។

# លពុជផលទាយកត្ថេរាបទានទី ៧

[ ៥៧ ] ក្នុងកាលនោះ ខ្ញុំជាញ្រោមវត្តក្នុងនគរពន្ធុមវតី បានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលី កំពុងស្តេចយាងទៅក្នុងអាកាស ។ ខ្ញុំបានយកផ្លែខ្នុរសម្លទៅថ្វាយដល់ព្រះពុទ្ធប្រសើរ ឯព្រះពុទ្ធមានយសច្រើន ទ្រង់ឈរទទួលក្នុងអាកាស ព្រះអង្គញុំាងសេចក្តីត្រេកអរឲ្យកើតដល់ខ្ញុំ ទ្រង់នាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះបានថ្វាយផ្លែខ្នុរដល់ព្រះពុទ្ធ ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកាលណោះ ខ្ញុំបាននូវបីតិដ៏ធំទូលាយ ជាសុខដ៏ឧត្តម កែវតែងកើតឡើងសម្រាប់ខ្ញុំដែលកើតក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែខ្នុរក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែខ្នុរ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលពុជផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ លពុជផលទាយកត្ថេរាបទាន ។**

## មិលក្ខុផលទាយកត្ថេរាបទានទី ៨

[ ៥៨ ] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមអត្ថទស្សី មានយសច្រើន គង់នៅក្នុងចន្លោះព្រៃ ហើយមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែល្មៀប ( ដល់ព្រះអង្គ ) ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានឲ្យនូវផ្លែល្មៀបក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែល្មៀប ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមិលក្ខុផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ មិលក្ខុផលទាយកត្ថេរាបទាន ។**

# សយម្បដិភាណិយត្ថេរាបទាន ទី ៩

[ ៥៩ ] ខ្ញុំបានសរសើរថា ព្រះពុទ្ធជាទេវតាក្រៃលែងជាងទេវតា ព្រះអង្គប្រសើរជាងនរៈ មានព្រះដំណើរល្ហោសល្ហន់ បីដូចដើមថ្ងាន់ត្រូវខ្យល់ ទ្រង់កំពុងស្តេចទៅតាមប្រក បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះពុទ្ធទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ទ្រង់ចម្លងនូវជនច្រើន ទ្រង់រុងរឿងដោយពន្លឺគឺញាណ បុគ្គលណាឃើញហើយនឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះលោកនាយក ទ្រង់ស្តេចទៅជាមួយនឹងព្រះខីណាស្រពមួយសែន ដែលស្ទាត់ជំនាញ ទ្រង់ស្រង់នូវសត្វទាំងឡាយដ៏ច្រើន បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះពុទ្ធនាំមកនូវធម្មភេរី ទ្រង់ញាំញីនូវពួកតិរ្ថិយ បន្លឺឡើងនូវសីហនាទ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ពួកទេវតាព្រមទាំងព្រហ្ម រហូតដល់ព្រហ្មលោក មកសួរនូវបញ្ហាដ៏ល្អិត អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ពួកជនព្រមទាំងទេវតា ធ្វើនូវអញ្ជលីបួងសួងចំពោះព្រះពុទ្ធអង្គណា រមែងបានទទួលនូវបុណ្យដោយសារព្រះពុទ្ធអង្គនោះ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ជនទាំងពួងមកព្រមគ្នា ហើយបវារណាព្រះពុទ្ធមានចក្ខុ ព្រះអង្គដែលគេអារាធនាហើយរមែងមិនញាប់ញ័រ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ស្គរជាច្រើនរមែងបន្លឺឡើង ដំរីទាំងឡាយដែលចុះប្រេងរមែងបន្លឺឡើងចំពោះព្រះសម្ពុទ្ធអង្គណា កាលដែលស្តេចចូលទៅក្នុងទីក្រុង បុគ្គលណាឃើញ ( ព្រះពុទ្ធអង្គនោះ ) ហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ឯពន្លឺនៃព្រះពុទ្ធអង្គណាដែលកំពុងស្តេចទៅតាមថ្នល់រមែងរុងរឿងសព្វៗកាល រស្មីទាំងឡាយ (របស់

ព្រះពុទ្ធអង្គនោះ ) ខ្ពង់ខ្ពស់ឡើងក្រៃពេក បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ បុគ្គលឮ ( នូវសំឡេង ) នៃព្រះពុទ្ធ កាលពោលក្នុងចក្កវាឡ ព្រះអង្គញ៉ាំងសត្វទាំងអស់ឲ្យដឹងច្បាស់ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ក្នុងកប្បទីមួយសែនអំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរនូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសរសើរ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសយម្បុជិកាណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ សយម្បុជិកាណិយត្ថេរាបទាន ។

# និមិត្តព្យាករណ៍យក្ខោរាបទានទី ១០

[ ៦០ ] កាលណោះ ខ្ញុំចូលទៅក្នុងព្រៃហិមពាន្ត បង្ហាញមន្តដល់ពួកសិស្ស ឯសិស្សចំនួន ៥៤.០០០ នាក់ បានបម្រើខ្ញុំ ។ សិស្សទាំងអស់នោះជាអ្នករៀនវេទ ដល់នូវបារមីក្នុងអង្គ ៦ រីងប៉ឹងដោយវិជ្ជារបស់ខ្លួន នៅក្នុងព្រៃហិមពាន្ត ។ ទេវបុត្តមួយអង្គ មានយសច្រើន បានច្យុតចាកពួកទេវតាក្នុងឋានតុសិត មកចាប់ផ្ទៃព្រះមាតា ជាអ្នកដឹងខ្លួន មានស្មារតី ។ កាលព្រះសម្ពុទ្ធបានត្រាស់ លោកធាតុមួយម៉ឺនញាប់ញ័រ កាលព្រះនាយកទ្រង់បានត្រាស់ ពួកជនខ្វាក់ភ្នែកក៏បានភ្លឺភ្នែក ។ ផែនដីនេះទាំងមូលញាប់ញ័រហើយដោយប្រការ ៦ មហាជនក៏តក់ស្លុតព្រោះឮសំឡេងគឹកកង ។ ជនទាំងអស់បានទៅប្រជុំគ្នាក្នុងសម្នាក់ខ្ញុំ សួរខ្ញុំថា ផែនដីនេះញាប់ញ័រ តើនឹងមានផលដូចម្តេច ។ កាលណោះ ខ្ញុំប្រាប់ពួកជនទាំងនោះថា អ្នកទាំងឡាយកុំខ្លាចអ្វីឡើយ ភ័យនឹងមិនកើតដល់អ្នកទាំងឡាយទេ អ្នកទាំងអស់គ្នា កុំរង្កៀសឡើយ ការណ៍ដែលកើតឡើងនេះ ប្រកបដោយសេចក្តីសុខនិងសេចក្តីចម្រើនទេតើ ។ ផែនដីនេះ បើហេតុទាំង ៨ យ៉ាង ប៉ះពាល់ហើយ រមែងញ័រ និមិត្តទាំងឡាយប្រាកដឡើង ពន្លឺដ៏ធំទូលាយប្រាកដឡើង ក៏ព្រោះហេតុនោះ ។ ព្រះពុទ្ធប្រសើរទ្រង់មានចក្ខុ នឹងត្រាស់ដោយឥតសង្ស័យ ខ្ញុំញុាំងប្រជុំជនឲ្យដឹងច្បាស់ហើយ ទើបសម្តែងនូវសីល ៥ ពួកជនទាំងនោះ លុះបានស្តាប់នូវសីល ៥ ផង នូវការកើតឡើងនៃព្រះពុទ្ធដែលបុគ្គលរកបានដោយកម្រផង ក៏មានចិត្តអណ្តែតឡើង មានចិត្តរីករាយ ជាអ្នកត្រេកអរស្រស់ស្រាយ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានព្យាករនូវនិមិត្តក្នុងកាល

នោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការពយាករ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនិមិត្តព្យាករណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ និមិត្តព្យាករណិយត្ថេរាបទាន ។**

**ឧទ្ទាន**

សាលកុសុមិយត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ ចិតកនិព្វាបកត្ថេរាបទាន ១ សេតុទាយកត្ថេរាបទាន ១ តាលវណ្តិយត្ថេរាបទាន ១ អវដផលិយត្ថេរាបទាន ១ លពុជទាយកត្ថេរាបទាន ១ មិលក្ខុផលទាយកត្ថេរាបទាន ១ សយម្បដិភាណិយត្ថេរាបទាន ១ និមិត្តព្យាករណិយត្ថេរាបទាន ១ ឯគាថា ៧២ ពួកអ្នកប្រាជ្ញបានរាប់ឃើញហើយ ។

**ចប់ សាលបុប្ផិវគ្គ ទី ៤៧ ។**

# សាលបុប្ផិវគ្គ ទី ៤៧

## អដ្ឋកថា សាលកុសុមិយត្ថេរាបទាន ជាដើម

[ ៥១-៦០ ] ចាប់អំពីអបទានទី ១ ជាដើមទៅ ក្នុងវគ្គទី ៤៧ មានអត្ថដឹងបានងាយហើយតាមគន្លងនៃព្រះបាលីនោះឯង ។

*អដ្ឋកថាសាលកុសុមិយត្ថេរាបទានជាដើម ចប់*

# ធម្មាលិវគ្គ ទី ៤៨

## ធម្មាលិយត្ថេរាបទានទី ១

[ ៦១ ] ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស ជាលោកនាយក ទ្រង់គួរទទួលនូវគ្រឿងបូជា ស្តេចទៅតាមជាយព្រៃធំ ។ ខ្ញុំកាន់យកកម្រងផ្កាបបុស ហើយចេញទៅក្នុងខណៈនោះ បានឃើញព្រះសម្ពុទ្ធ ទ្រង់ធ្វងឱឃៈ ព្រះអង្គមិនមានអាសវៈ គង់នៅក្នុងព្រៃនោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាកម្រងផ្កាបបុសចំពោះព្រះពុទ្ធ ជាទក្ខិណេយ្យបុគ្គល ព្រះអង្គមានព្យាយាមច្រើន ទ្រង់អនុគ្រោះសព្វសត្វលោក ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ធម្មាលិយត្ថេរាបទាន ។**

# មណិបូជកត្ថេរាបទានទី ២

[ ៦២ ] ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រាថ្នានូវវិវេក កំពុងតែស្តេចទៅតាមអាកាស ។ មានជាតស្រះដ៏ធំមួយនៅជិតព្រៃហិមពាន្ត ឯលំនៅរបស់ខ្ញុំដែលប្រកបដោយបុញ្ញកម្ម នៅជិតស្រះនោះ ។ ខ្ញុំចេញអំពីលំនៅ បានឃើញព្រះលោកនាយក ទ្រង់ភ្លឺដូចផ្ការាជព្រឹក្ស រុងរឿងដូចជាភ្លើង ខ្ញុំមិនឃើញផ្កាដែលគួរបេះថ្វាយ ទើបគិតថាអញនឹងបូជាអ្វីដល់ព្រះលោកនាយក ឲ្យចិត្តរបស់ខ្លួនជ្រះថ្លាហើយ ថ្វាយបង្គំព្រះសាស្ដាអេះ ។ ខ្ញុំយកកែវមណីប្រដាប់ក្បាលនៃខ្ញុំ បូជាព្រះលោកនាយករួចប្រាថ្នាថា សូមឲ្យផលដ៏ចម្រើនសម្រេចដល់ខ្ញុំ ដោយសារបូជាកែវមណីនេះ ។ ព្រះសាស្ដាព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់ត្រៃលោក ព្រះអង្គទទួលគ្រឿងបូជា ទ្រង់ឈរសម្ដែងក្នុងអាកាសនូវគាថានេះថា តម្រិះនោះសូមឲ្យសម្រេចដល់អ្នក អ្នកចូរបាននូវសេចក្ដីសុខដ៏ធំទូលាយ អ្នកចូរបាននូវយសដ៏ធំដោយការបូជានូវកែវមណីនេះចុះ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈលុះពោលពាក្យនេះហើយ ទើបស្តេចហួសទៅ ចិត្តដែលគេតម្កល់ទុកចំពោះបុគ្គលណា ( បុគ្គលនោះ ) គឺព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំកើតជាព្រះឥន្ទជាស្តេចទេវតាសោយទេវរាជ្យអស់ ៦០ កប្ប បានជាស្ដេចចក្កពត្តិច្រើនរយដង ។ ខ្ញុំកាលកើតជាទេវតា មានសតិ បានរឭកឃើញនូវបុញ្ញកម្ម ឯកែវមណី ជាវត្ថុជាតុធ្វើពន្លឺ ក៏កើតឡើងសម្រាប់ខ្ញុំ ។ ខ្ញុំគ្រប់គ្រងនារី ៨៦.០០០ សឹងមានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់នូវកែវមណី និងកុណ្ឌល ។ នារីទាំងនោះ មានមុខទូលាយ ញញឹមស្រស់ មានត្រគាកល្អ មានចង្កេះរៀវ តែង

ចោមរោមខ្ញុំជានិច្ច នេះជាផលនៃការបូជាកែវមណី ។ កណ្ឌៈទាំងឡាយ របស់ខ្ញុំ ជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវក្រហមដែល ជាផងរចនាល្អ ជាគ្រឿងប្រដាប់សម្រេចតាមសេចក្ដីប្រាថ្នា ។ ផ្ទះកំពូល គុហា គួររីករាយ ទីដេកមានថ្លៃច្រើនតែងកើតឡើង សមតាមសេចក្ដីប្រាថ្នា ព្រោះ ជីងតម្រិះរបស់ខ្ញុំ ។ ឱ ! ជាលាភរបស់គេហើយ ឱ ! អត្តភាពជាមនុស្ស ឈ្មោះថាគេបានល្អហើយ ព្រោះហេតុដែលគេបានទូវការចូលទៅអែបស្ដាប់ ព្រះធម៌ជាបុញ្ញក្ខេត្តរបស់មនុស្ស ជាឱសថរបស់សត្វទាំងពួង ។ អំពើដែល ខ្ញុំធ្វើល្អហើយ ព្រោះខ្ញុំបានឃើញព្រះពុទ្ធជានាយក ខ្ញុំរួចស្រឡះហើយចាក វិនិបាត ខ្ញុំបានដល់នូវអចលបទគឺព្រះនិព្វាន ។ ខ្ញុំទៅកាន់កំណើរណាៗ ទោះ ជាទេវតាឬជាមនុស្ស ពន្លឺតែងមានសម្រាប់ខ្ញុំទាំងថ្ងៃទាំងយប់សព្វៗ កាល ។ ខ្ញុំសោយសម្បត្តិទាំងឡាយ ដោយសារការបូជានូវកែវមណីនោះឯង ពន្លឺគឺ ញាណខ្ញុំឃើញហើយ ខ្ញុំបានដល់នូវអចលបទគឺព្រះនិព្វាន ។ ក្នុងកប្បទីមួយ-សែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាកែវមណីក្នុងកាលនោះ ខ្ញុំមិនដែល ស្គាល់ទុគ្គតិ នេះជាផលនៃការបូជាកែវមណី ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបាន កាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃ ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើ ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមណិបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មណិបូជកត្ថេរាបទាន ។

# នឡមាលិវគ្គ ទី ៤៨

## អដ្ឋកថានឡមាលិយត្ថេរាបទាន ជាដើម

[ ៦១-៦២ ] អបទានទី ១ ទី ២ ក្នុងវគ្គទី ៤៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថានឡមាលិយត្ថេរាបទានជាដើម ចប់

# ឧក្កាសតិកត្ថេរាបទានទី ៣

[ ៦៣ ] កាលនោះ ព្រះមានព្រះភាគជាមុនីព្រះនាមកោសិកៈ ព្រះអង្គមានឈាន ត្រេកអរក្នុងឈាន អភិរម្យក្នុងវិវេក គង់នៅលើភ្នំចិត្តកូដ ខ្ញុំមានពួកនារីចោមរោម ដើរចូលទៅក្នុងព្រៃហិមពាន្ត បានឃើញព្រះពុទ្ធព្រះនាមកោសិកៈ ដូចព្រះចន្ទពេញបូណ៌មី ។ ក្នុងកាលនោះ ខ្ញុំកាន់គប់ភ្លើង ១០០ ឈរព័ទ្ធបំភ្លឺព្រះពុទ្ធអស់ ៧ យប់ ៧ ថ្ងៃ ខ្ញុំត្រឡប់ទៅផ្ទះវិញក្នុងថ្ងៃទី ៨ ។ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះពុទ្ធព្រះនាមកោសិកៈ ជាព្រះសយម្ភូទ្រង់ឈ្នះកិលេស ព្រះអង្គស្ដេចចេញ ខ្ញុំបានថ្វាយភិក្ខាមួយចម្អែត ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាធំក្នុងលោក ប្រសើរជាងពួកនរៈ ខ្ញុំទៅកើតក្នុងឋានតុសិតដោយកម្មនោះ នេះជាផលនៃភិក្ខាមួយចម្អែត ។ ពន្លឺរមែងមានដល់ខ្ញុំទាំងថ្ងៃទាំងយប់ សព្វៗកាល ខ្ញុំផ្សាយពន្លឺទៅកាន់ទី ១០០ យោជន៍ដោយជុំវិញ ។ ក្នុងកប្បទី ៥៥ ខ្ញុំបានជាស្ដេចចក្កពត្តិឈ្មោះសង្គ្រាម មានសមុទ្រទាំង ៤ ជាព្រំប្រទល់ ជាធំក្នុងមណ្ឌលនៃជម្ពូទ្វីប ។ ក្នុងកាលនោះ នគររបស់ខ្ញុំសម្បូរកុះករ ដែលវិស្សុកម្មនិម្មិតល្អហើយ ទីក្រុងនោះមានបណ្ដោយប្រវែង ៣០ យោជន៍ ទទឹងប្រវែង ២០ យោជន៍ ទីក្រុងនោះឈ្មោះសោភនៈ ដែលវិស្សុកម្មនិម្មិតហើយ ជាទីស្ងប់ស្ងាត់ចាកសំឡេងទាំង ១០ ប្រការ ប្រកបដោយភ្លេងប្រគំដ៏ពីរោះ ។ ក្នុងនគរនោះមិនមានវល្លិ៍ ឈើ ដីស្អិត មានរបស់សុទ្ធតែមាសទាំងអស់ រុងរឿងអស់កាលជានិច្ច ។ ទាំងមានរបស់ ៣ យ៉ាងនេះគឺ កំពែង ៤ ជ្រុង ១ របៀបដើមត្នោតជាវិការៈនៃកែវមណី ក្នុងទីពាក់កណ្ដាល ដែលវិស្សុកម្មនិម្មិតល្អហើយ ១ស្រះបោក្ខរណីមួយម៉ឺន មានឈូក

ឧប្បលព្រោងព្រាត ដេរជាសដោយឈូកសជាដើម ផ្កាយក្និទផ្សេងៗ ១ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបំភ្លឺគប់ភ្លើងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបំភ្លឺគប់ភ្លើង ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧក្កាសតិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ឧក្កាសតិកត្ថេរាបទាន ។

# អដ្ឋកថា

# ឧក្កាសតិកត្ថេរាបទាន

[ ៦៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះថា

បទថា **កោសិយោ នាម ភគវា** បានដល់ ព្រះបច្ចេកពុទ្ធឈ្មោះថា កោសិយៈ ព្រោះកើតក្នុងកោសិយគោត្ត ។ បទថា **ចិត្តកូដេ** សេចក្ដីថា បណ្ដាកំពូលភ្នំដូចជាភ្នំចិត្តកូដ ភ្នំកៃលាសកូដ និងភ្នំសានុកូដជាដើម ដែលព័ទ្ធជុំវិញអនោតត្តស្រះ ព្រះបច្ចេកពុទ្ធអង្គនោះ ឋិតនៅត្រង់ភ្នំចិត្តកូដ ដែលវិចិត្រទៅដោយរតនៈ និងឱសថជាដើមច្រើនប្រភេទ ។

អដ្ឋកថាឧក្កាសតិកត្ថេរាបទាន ចប់

# សុមនវីជនិយត្ថេរាបទានទី ៤

[ ៦៤ ] ខ្ញុំមានចិត្តរីករាយចំពោះពោធិព្រឹក្សដ៏ឧត្តមរបស់ព្រះមានព្រះភាគព្រះនាមវិបស្សី ហើយយកផ្លិតទៅបក់ថ្វាយនូវពោធិព្រឹក្សដ៏ឧត្តម ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបក់នូវពោធិព្រឹក្សដ៏ឧត្តមក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបក់ផ្លិត ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនវីជនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សុមនវីជនិយត្ថេរាបទាន ។**

# កុម្មាសទាយកត្ថេរាបទាន ទី ៥

[ ៦៥ ] កាលព្រះពុទ្ធព្រះនាមវិបស្សី ទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់ស្តេចទៅដើម្បីបិណ្ឌបាត ខ្ញុំឃើញបាត្រទទេហើយ ក៏ដាក់នំឲ្យពេញ ( បាត្រ ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យនូវភិក្ខាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃនំ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុម្មាសទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ កុម្មាសទាយកត្ថេរាបទាន ។

## អដ្ឋកថា
## សុមនវីជនិយត្ថេរាបទាន ជាដើម

[ ៦៤-៦៥ ] អបទានរបស់ព្រះសុមនវីជនិយត្ថេរាបទាននិងព្រះកុម្មាសទាយកត្ថេរាបទាន មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសុមនវីជនិយត្ថេរាបទានជាដើម ចប់

# កុសដ្ឋកទាយកត្ថេរាបទានទី ៦

[ ៦៦ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយស្បូវ ៨ ក្តាប់ ដល់ព្រះមានព្រះភាគព្រះនាមកស្សបៈ ជាខីណាសវព្រាហ្មណ៍ ព្រះអង្គមានព្រហ្មចរិយធម៌នៅរួចហើយ ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយស្បូវ ៨ ក្តាប់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បូវ ៨ ក្តាប់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុសដ្ឋកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ កុសដ្ឋកទាយកត្ថេរាបទាន ។

## អដ្ឋកថា

## កុសដ្ឋកទាយកត្ថេរាបទាន

[ ៦៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះថា

បទថា **កុសដ្ឋកមទាសហំ** សេចក្តីថា បណ្តាភត្តដូចជាបក្ខិកភត្ត ឧបោសថិកភត្ត ធុវភត្ត និងសលាកភត្តជាដើម ខ្ញុំបានថ្វាយសលាកភត្ត ៨ ដែលគប្បីថ្វាយដោយធ្វើជាស្លាក ។

*អដ្ឋកថាកុសដ្ឋកទាយកត្ថេរាបទាន ចប់*

# គិរិបុន្នាគិយត្ថេរាបទានទី ៧

[ ៦៧ ] គ្រានោះព្រះសម្ពុទ្ធ ព្រះនាមសោភិតៈ ទ្រង់គង់លើភ្នំចិត្តកូដ ខ្ញុំយកផ្កាបុសនាគភ្នំ ទៅបូជាព្រះសយម្ភូ ។ ក្នុងកប្បទី ៩៤ អពីកទូកប្បនេះ ព្រោះហេតុដែលខ្ញុំបូជានូវព្រះសម្ពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគិរិបុន្នាគិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ គិរិបុន្នាគិយត្ថេរាបទាន ។**

# អដ្ឋកថា

# គិរិបុន្នាគិយត្ថេរាបទាន

[ ៦៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា បទថា **សោភិតោ នាម សម្ពុទ្ធោ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធមានព្រះនាមថា សោភិតៈ ព្រោះទ្រង់មានព្រះសរីរៈល្អ ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងរស្មីផ្សាយចេញជុំវិញមួយព្យាយាម ទាំងចំណែកបណ្តោយនិងទទឹង ។

*អដ្ឋកថាគិរិបុន្នាគិយត្ថេរាបទាន ចប់*

# វល្លិការផលទាយកត្ថេរាបទានទី ៨

[ ៦៨ ] គ្រានោះ ព្រះសម្ពុទ្ធព្រះនាមសុមនៈ គង់នៅក្នុងក្រុងឈ្មោះតក្ករា ខ្ញុំបានយកផ្លែគុយទៅថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវល្លិការផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ វល្លិការផលទាយកត្ថេរាបទាន ។

# អដ្ឋកថា

## វល្លិការផលទាយកត្ថេរាបទាន

[ ៦៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះថា

បទថា **តក្ករាយំ វសី តទា** សេចក្ដីថា រាជធានីឈ្មោះថាតក្ករា ព្រោះជាទីនៅប្រចាំរបស់ប្រជាជនដែលបំពេញបុញ្ញកិរិយាវត្ថុ ១០ ប្រការក្នុងកាលនោះ ទ្រង់គង់នៅត្រង់តក្ករានគរនោះ ។

អដ្ឋកថាវល្លិការផលទាយកត្ថេរាបទាន ចប់

# ទានជិនាយកត្ថេរាបទានទី ៩

[ ៦៩ ] ព្រះមានព្រះភាគព្រះនាមអនោមទស្សីជាធំក្នុងលោក ប្រសើរជាងនរៈមានចក្ខុ ទ្រង់ចេញអំពីរោងសម្រាកក្នុងវេលាថ្ងៃ ស្តេចទៅតាមថ្នល់ ។ ខ្ញុំពាក់ស្បែកជើងដែលខ្ញុំធ្វើល្អហើយ ដើរទៅកាន់ផ្លូវឆ្ងាយ បានឃើញព្រះសម្ពុទ្ធទ្រង់ស្តេចទៅដោយព្រះបាទាទទេ ព្រះអង្គមានព្រះកាយ ប្រកបដោយគ្រឿងប្រដាប់ដូចមាស ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា យកស្បែកជើងទៅតម្កល់ទុកជិតព្រះបាទា ហើយពោលនូវពាក្យនេះថា បពិត្រព្រះសុគតជាធំជានាយក មានព្យាយាមច្រើន សូមព្រះអង្គពាក់នូវស្បែកជើង ខ្ញុំព្រះអង្គនឹងបាននូវផលអំពីស្បែកជើងនេះ សូមឲ្យសម្រេចប្រយោជន៍នោះដល់ខ្ញុំ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ ទ្រង់ពាក់នូវស្បែកជើងហើយត្រាស់ព្រះពុទ្ធដីកានេះថា បុគ្គលណាមានចិត្តជ្រះថ្លា បានថ្វាយស្បែកជើងដល់តថាគត ដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ ទេវតាទាំងអស់ បានដឹងនូវវាចារបស់ព្រះពុទ្ធ ក៏មកប្រជុំគ្នា មានចិត្តខ្ពស់ឡើង មានចិត្តរីករាយ មានសេចក្តីត្រេកអរ ធ្វើនូវអញ្ជលី ។ បុគ្គលនេះ នឹងដល់នូវសេចក្តីសុខ ព្រោះការថ្វាយនូវស្បែកជើង នឹងសោយរាជ្យជាស្តេចទេវតាអស់ ៥៥ ដង ។ នឹងបានជាស្តេចចក្កពត្តិមួយពាន់ដង នឹងសោយបទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ព្រះសាស្តាមាននាមថាគោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈ នឹងបានត្រាស់ក្នុងលោក ។ ( បុរសនេះ ) នឹងបានជាអ្នកទទួលនូវមតិកក្នុងធម៌របស់ព្រះ

គោតមនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ( បុរសនេះឯង ) បើកើតក្នុងទេវលោក ឬក្នុងមនុស្សលោក រមែងជាអ្នកមានប្រាជ្ញា នឹងបាននូវយានមានចំណែកប្រៀបដោយយានទេវតា ។

ប្រាសាទ វិមាស ដ៏វិប្រដាប់ព្រមហើយ រថដែលទឹមដោយសេះអាជានេយ្យ រមែងកើតប្រាកដដល់ខ្ញុំសព្វៗកាល ។ ខ្ញុំទុកជាកាលចេញទៅអំពីលំនៅ តែងចេញទៅដោយរថ កាលសក់ទាំងឡាយគេកំពុងកោរកាត់ ខ្ញុំក៏បានដល់អរហត្ត ។ ឱ ! ជាលាភរបស់ខ្ញុំហើយ អត្តភាពជាមនុស្សឈ្មោះថាខ្ញុំបានល្អហើយ ការជួញខ្ញុំប្រកបល្អហើយ ព្រោះខ្ញុំបានថ្វាយស្បែកជើងមួយសម្រាប់ ក៏បានដល់អចលបទ គឺ ព្រះនិព្វាន ។ ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យស្បែកជើងក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្បែកជើង ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបានធិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បានធិទាយកត្ថេរាបទាន ។**

# អដ្ឋកថា

# ធានធិទាយកត្ថេរាបទាន

[ ៦៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះថា

បទថា **ធានធី សុកតំ គយ្ហ** សេចក្តីថា ខ្ញុំពាក់គូនៃស្បែកជើងដែលសម្រេចដោយអាការយ៉ាងល្អហើយ ។

*អដ្ឋកថាបានធិទាយកត្ថេរាបទាន ចប់*

# បុឡិនចង្កមិយត្ថេរាបទានទី ១០

[ ៧០ ] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃ កំពុងស្វែងរកសត្វឈ្លូស ក៏បានឃើញនូវទីចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ចំពោះព្រះសុគតទ្រង់មានសិរី ហើយកើបយកដីខ្សាច់មួយថ្នក់ មករោយរាយ ក្នុងទីចង្ក្រម ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានរោយរាយនូវដីខ្សាច់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដីខ្សាច់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិនចង្កមិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បុឡិនចង្កមិយត្ថេរាបទាន ។**

## ឧទ្ទាន

នឡមាលិយត្ថេរាបទាន ១ មណិបូជកត្ថេរាបទាន ១ ឧក្កាសតិកត្ថេរាបទាន ១ វីជនិយត្ថេរាបទាន ១ កុម្មាសទាយកត្ថេរាបទាន ១ កុសដ្ឋកទាយកត្ថេរាបទាន ១ គិរិបុន្នាគិយត្ថេរាបទាន ១ វល្លិការផលទាយកត្ថេរាបទាន ១ បានធិទាយកត្ថេរាបទាន ១ បុឡិនចង្កមិយត្ថេរាបទាន ១ ឯគាថាមានចំនួន ៩៥ ពួកអ្នកប្រាជ្ញរាប់ឃើញហើយ ។

ចប់ នឡមាលិវគ្គ ទី ៤៨ ។

# អដ្ឋកថា

## បុឡិនចង្កមិយត្ថេរាបទាន

[ ៧០ ] អបទានទី ១០ មានអត្ថដ៏ងាយហើយ ។

អដ្ឋកថាបុឡិនចង្កមិយត្ថេរាបទាន ចប់

នឡមាលិវគ្គទី ៤៨ ចប់

# បណ្ឌុកូលវគ្គ ទី ៤៩

## បណ្ឌុកូលសញ្ញកត្ថេរាបទាន ទី ១

[ ៧១ ] ព្រះជិនស្រីមានព្រះភាគព្រះនាមតិស្សៈ ជាព្រះសយម្ភូ ជាលោកនាយក ព្រះអង្គបានតម្កល់ទុកនូវសំពត់បំសុកូលហើយ ស្តេចចូលទៅក្នុងវិហារ ។ ខ្ញុំបានកាន់យកធ្នូដែលខ្លួនរៀបចំស្រេចហើយ មានទាំងទឹកបំពង់ កាន់ទាំងដាវដើរចូលទៅក្នុងព្រៃ ។ គ្រានោះ ខ្ញុំបានឃើញសំពត់បំសុកូលដែលព្រះអង្គពាក់ទុកលើចុងឈើ ក្នុងទីនោះ ខ្ញុំបានដាក់បំពង់ព្រួញចុះក្នុងទីនោះឯងហើយបានធ្វើអញ្ជលីលើសិរ្សៈ ។ ខ្ញុំមានចិត្តជ្រះថ្លា រីករាយដោយបីតិ ដ៏ធំទូលាយ នឹករឭកចំពោះព្រះពុទ្ធដ៏ប្រសើរ ហើយថ្វាយបង្គំនូវសំពត់បំសុកូល ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំនូវសំពត់បំសុកូលក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញអស់ហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបំសុកូលសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បណ្ឌុកូលសញ្ញកត្ថេរាបទាន ។**

# បង្សុកូលវគ្គ ទី ៤៩

## អដ្ឋកថា បង្សុកូលសញ្ញកត្ថេរាបទាន

[ ៧១ ] *អបទានទី ១ ក្នុងវគ្គទី ៤៩ មានអត្ថដ៏ងាយហើយ ។*

*អដ្ឋកថាបង្សុកូលសញ្ញកត្ថេរាបទាន ចប់*

# ពុទ្ធសញ្ញកត្ថេរាបទានទី ២

[ ៧២ ] ខ្ញុំជាអ្នកស្វាធ្យាយមន្ត ចេះចាំនូវមន្ត ដល់នូវត្រើយនៃត្រៃវេទ ក្នុងលក្ខណសាស្ត្រ និងឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។ ក្នុងកាលនោះ ពួកសិស្សរបស់ខ្ញុំ មកកាន់ ( សម្នាក់ ) នៃខ្ញុំ ប្រៀបដូចជាខ្សែទឹកស្ទឹង ខ្ញុំក៏បានបង្ហាញមន្តដល់សិស្សទាំងនោះ ឥតមានខ្ជិល ច្រអូសទាំងយប់ទាំងថ្ងៃ ។ លំដាប់នោះឯង ព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថៈ បាន កើតឡើងហើយក្នុងលោក ទ្រង់ញុំាងសេចក្តីងងឹតដ៏ក្រៃលែងឲ្យវិនាសហើយ ញុំាងពន្លឺគឺញាណឲ្យប្រព្រឹត្តទៅ ។ ក្នុងកាលនោះ មានសិស្សម្នាក់របស់ខ្ញុំ បានប្រាប់ដល់ពួកសិស្សរបស់ខ្ញុំ លុះពួកសិស្សទាំងនោះឮហើយ ទើបប្រាប់ សេចក្តីនោះដល់ខ្ញុំ ( ខ្ញុំក៏បានគិតថា ) ព្រះសព្វញ្ញូជាលោកនាយក ព្រះអង្គ បានកើតឡើង ក្នុងលោកហើយ ជនតែងប្រព្រឹត្តតាមនូវព្រះសម្មាសម្ពុទ្ធអង្គ នោះ ឯអាត្មាអញគ្មានលាភនឹងគេសោះ ។ ព្រះពុទ្ធទាំងឡាយ មានចក្ខុ មានយសធំ ព្រះអង្គទ្រង់កើតឡើង ព្រោះអាស្រ័យហេតុ បើដូច្នោះ អាត្មា អញគួរទៅមើល ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គជាលោកនាយក ។ ខ្ញុំ បានកាន់យកស្បែកខ្លា សំពត់សម្បកឈើ និងកុណ្ឌិទឹករបស់ខ្ញុំ ចេញអំពី អាស្រម ហើយហៅពួកសិស្សមកប្រាប់ថា ការឃើញនូវព្រះពុទ្ធជាលោក-នាយក កម្របុគ្គលបានដោយងាយ ដូចជាផ្កាឧទុម្ពរ ឬដូចជារូបនៃសត្វ ទន្សាយក្នុងដួងព្រះចន្ទ ឬក៏ដូចជាទឹកដោះនៃសត្វក្អែក ព្រះសម្មាសម្ពុទ្ធ ព្រះ អង្គកើតឡើងក្នុងលោក និងភាពជាមនុស្សទាំងពីរនេះ កម្របុគ្គលបានដោយ ងាយ កាលបើហេតុទាំងពីរនេះមានហើយ ការស្តាប់ធម៌ក៏កម្របុគ្គលបាន

ឆាយដែរ ។ ព្រះសម្មាសម្ពុទ្ធបានកើតហើយក្នុងលោក ពួកយើងឈ្មោះថា បាននូវចក្ខុ សេចក្តីចម្រើននឹងមានដល់យើង អ្នកទាំងឡាយចូរមកចុះ យើងទាំងអស់នឹងនាំគ្នាទៅកាន់សម្នាក់ព្រះសម្មាសម្ពុទ្ធ ។ កាលនោះ ពួកតាបសទាំងអស់ ទ្រទ្រង់នូវកុណ្ឌីទឹក ស្លៀកពាក់ស្បែកខ្លាទាំងក្រចក តាបសទាំងនោះទ្រទ្រង់នូវភារៈគឺផ្នួងសក់ បានចេញទៅអំពីព្រៃ ។ តាបសទាំងនោះ ជាអ្នកស្វែងរកនូវប្រយោជន៍ដ៏ឧត្តម ក្រឡេកមើលមួយជួរនឹមដើរមក ឥតមានសេចក្តីតក់ស្លុត បីដូចជាកូននៃដំរី ឬដូចជាកេសររាជសីហ៍ ឥតមានសេចក្តីតក់ស្លុតឡើយ ។ តាបសទាំងអស់នោះ ជាអ្នកមិនតក់ស្លុត មិនឡេះឡោះមានប្រាជ្ញាធ្ងន់ធ្ងរ ជាអ្នកប្រព្រឹត្តរម្យទម តាបសទាំងអស់នោះ កាលត្រាច់រកផលាផល បានចូលទៅគាល់ព្រះពុទ្ធដ៏ប្រសើរ ។ ព្យាធិបានកើតឡើងដល់ខ្ញុំ ដែលនៅក្នុងប្រទេសប្រមាណមួយយោជន៍កន្លះ ( អំពីព្រះពុទ្ធគង់នៅ ) ខ្ញុំបាននឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសេចក្តីសម្គាល់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់នូវព្រះសម្មាសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំ

ក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ពុទ្ធសញ្ញកត្ថេរាបទាន ។**

# អដ្ឋកថា

# ពុទ្ធសញ្ញកត្ថេរាបទាន

[ ៧២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះថា

បទថា **អធិច្ចុប្បត្តិកា ពុទ្ធា** សេចក្តីថា ព្រះពុទ្ធទាំងឡាយជាអ្នកមានការកើតឡើងដ៏ប្រសើរ គឺមិនមានហេតុដទៃបណ្តាល បានដល់ កើតឯងប្រាសចាកបុគ្គលអាងដល់ ដូចជាទេវតា ព្រហ្ម និងមារជាដើម ឧប្បត្តិក គឺកើតឡើងដោយព្រះសយម្ភូញាណ ។

បទថា **ឧទុម្ពរិកបុប្ផំវ** បានដល់ ដូចគ្នានឹងផ្កាល្វាដែលរកបានដោយកម្រ គឺកើតឡើងបានដោយក្រ ។ បទថា **ចន្ទម្ហិ សសកំ យថា** បានដល់ ដូចគ្នានឹងរូបទន្សាយក្នុងព្រះចន្ទ ដែលរកបានដោយលំបាក ។ បទថា **វាយសានំ យថា ខីរំ** សេចក្តីថា ដូចគ្នានឹងខ្ញាញ់រាវរបស់ក្អែក ទោះគាប ប្របាប់ជានិច្ច គឺទាំងយប់ទាំងថ្ងៃ បានត្រឹមតែបន្តិច ក៏រកបានដោយក្រ យ៉ាងណា ព្រះលោកនាយកក៏រកបានដោយក្រ ព្រោះថា ជាព្រះពុទ្ធបាន ត្រូវបំពេញបារមីដល់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្បក៏មាន ៨ អសង្ខេយ្យ និងមួយសែនកប្បក៏មាន ទើបបានជាលោកនាយក ដូច្នោះ ។

អដ្ឋកថាពុទ្ធសញ្ញកត្ថេរាបទាន ចប់

# ភិសទាយកត្ថេរាបទានទី ៣

[ ៧៣ ] កាលនោះ ខ្ញុំបានចុះក្នុងស្រះបោក្ខរណី ដែលជីវនានាតែង អាស្រ័យ ខ្ញុំបានដកក្រអៅឈូកក្នុងស្រះនោះ ព្រោះហេតុនៃសេចក្តីស្រេក ឃ្លាន ។ សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគព្រះនាមបទុមុត្តរៈ ដែល មានព្រះហឫទ័យល្អ ទ្រទ្រង់នូវសំពត់កម្ពលក្រហម ស្តេចទៅតាមផ្លូវអាកាស ។ គ្រានោះ ខ្ញុំកំពុងរលាស់នូវសំពត់បំសុកូល បានឮសំឡេង ខ្ញុំក្រឡេកមើល ទៅខាងលើ ក៏បានឃើញព្រះលោកនាយក ។ ខ្ញុំឈរនៅក្នុងទីនោះឯង ហើយ បានអារាធនាព្រះលោកនាយក ទាំងកំពុងកាន់ក្រអៅឈូកមានរសផ្អែមដោយ ពាក្យថា ទឹករៈនិងសប្បិហូរចេញអំពីក្រអៅឈូក ។ សូមព្រះសម្មាសម្ពុទ្ធជា ម្ចាស់មានចក្ខុ ជាសាស្តា មានយសធំ ប្រកបដោយសេចក្តីករុណា ស្តេចចុះ អំពីអាកាសនោះ ហើយទ្រង់ទទួលដោយសេចក្តីអនុគ្រោះដល់ខ្ញុំ ។ ព្រះសម្មា សម្ពុទ្ធមានចក្ខុ ទ្រង់ទទួលភិក្ខារបស់ខ្ញុំ ដោយសេចក្តីអនុគ្រោះ លុះទ្រង់ទទួល ហើយ ទ្រង់ធ្វើអនុមោទនាដល់ខ្ញុំថា ម្នាលអ្នកមានបុណ្យច្រើន អ្នកចូរជា បុគ្គល ដល់នូវសេចក្តីសុខចុះ គតិរបស់អ្នកចូរសម្រេចចុះ អ្នកចូរបាននូវ សេចក្តីសុខដ៏ធំទូលាយ ដោយការឲ្យនូវក្រអៅឈូកនេះចុះ ។ ព្រះសម្មា សម្ពុទ្ធព្រះនាមបទុមុត្តរៈ លុះទ្រង់ត្រាស់អនុមោទនានេះហើយ ព្រះជិនស្រី សម្មាសម្ពុទ្ធ ទ្រង់ទទួលភិក្ខា ហើយស្តេចមកតាមផ្លូវអាកាស ។ ខ្ញុំបានកាន់ យកក្រអៅឈូកអំពីទីនោះ ហើយមកអាស្រមរបស់ខ្ញុំ ខ្ញុំបានព្យួរក្រអៅឈូក លើមែកឈើ ហើយនឹកនូវទានរបស់ខ្ញុំ ។ គ្រានោះ ខ្យល់ធំបានតាំងឡើង ហើយញុំាងព្រៃឲ្យញាប់ញ័រ អាកាសក៏បន្លឺឡើងដោយសំឡេងរន្ទះបាញ់ ។

ក្នុងកាលនោះ អសនិបាតធ្លាក់ត្រូវក្បាលខ្ញុំ ខ្ញុំនោះកំពុងអង្គុយ ក៏ធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំប្រកបដោយបុញ្ញកម្ម ហើយបានទៅកើតក្នុងឋានតុសិត សាកសពរបស់ខ្ញុំធ្លាក់ចុះ ខ្ញុំត្រេកអរក្នុងទេវលោក ពួកនារី ៨ ម៉ឺន ៦ ពាន់ តាក់តែងគ្រឿងប្រដាប់ប្រដា តែងបម្រើខ្ញុំទាំងល្ងាចទាំងព្រឹក នេះជាផលនៃការឲ្យក្រអៅឈូក ។ ក្នុងកាលនោះ ខ្ញុំបានមកកាន់កំណើតនៃមនុស្ស ដល់នូវសេចក្ដីសុខ សេចក្ដីខ្វះខាតកោតរបស់ខ្ញុំមិនមានឡើយ នេះជាផលនៃការថ្វាយក្រអៅឈូក ។ ខ្ញុំជាអ្នកត្រូវព្រះតាទិបុគ្គល ជាទេវតាកន្ទង់ទេវតានោះអនុគ្រោះហើយ ក៏មានអាសវៈទាំងពួងអស់ឥតសេសសល់ ឥឡូវនេះ ភពថ្មីរបស់ខ្ញុំមិនមានឡើយ ។ ក្នុងបក្សទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យភិក្ខា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យក្រអៅឈូក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ភិសទាយកត្ថេរាបទាន ។**

## អដ្ឋកថា

## ភិសទាយកត្ថេរាបទាន

[ ៧៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះថា

បទថា **មធុំ ភិសេហិ សវតិ** សេចក្តីថា ទឹកផ្អែមកំពុងហូរចេញចាកកេសរឈូក ។ បទថា **ខីរំ សប្បឹ មុឡាលិភិ** សេចក្តីថា ទឹកដោះនិងរសសប្បិកំពុងហូរចេញចាកក្រអៅឈូក អធិប្បាយថា ព្រោះហេតុនោះ សូមព្រះពុទ្ធទ្រង់ទទួលភិក្ខាទាំង ២ យ៉ាងនោះ របស់ខ្ញុំព្រះអង្គផងចុះ ។

*អដ្ឋកថាភិសទាយកត្ថេរាបទាន ចប់*

# ញាណត្ថវិកត្ថេរាបទានទី ៤

[ ៧៤ ] អាស្រមរបស់ខ្ញុំ គេធ្វើហើយក្នុងទិសទក្សិណនៃហិមវន្តប្រទេស ក្នុងកាលនោះ ខ្ញុំកំពុងស្វែងរកនូវប្រយោជន៍ដ៏ឧត្តម នៅតែក្នុងព្រៃ ។ ខ្ញុំជាអ្នកសន្តោសដោយលាភនិងអលាភ ជាអ្នកប្រព្រឹត្តមិនចិតសម្បក នៃមើមឈើនិងផ្លែឈើ ហើយនៅតែម្នាក់ឯង ។ ព្រះសម្ពុទ្ធព្រះនាមសុមេធៈ បានកើតក្នុងលោក ទ្រង់ស្រោចស្រង់នូវមហាជន ហើយប្រកាសនូវសច្ចធម៌ទាំង ៤ ក្នុងខណៈនោះ ។ ខ្ញុំមិនដែលបានស្តាប់នូវព្រះសម្ពុទ្ធ ទាំងឥតមានអ្នកណាមួយប្រៀនប្រដៅខ្ញុំឡើយ លុះកន្លង ៨ ឆ្នាំទៅ ទើបខ្ញុំបានស្តាប់ ព្រះលោកនាយក ។ ខ្ញុំបាននាំយកភ្លើងនិងឧសចេញហើយ បោសប្រាសអាស្រម រួចបានវែកនូវអម្រែកចេញទៅអំពីព្រៃធំ ។ ក្នុងកាលនោះ ខ្ញុំនៅក្នុងស្រុកនិងនិគមអស់មួយរាត្រី ៗ ហើយបានចូលទៅក្នុងក្រុងឈ្មោះចន្ទវតីដោយលំដាប់ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមសុមេធៈ ជាលោកនាយក ទ្រង់ស្រោចស្រង់នូវពពួកសត្វជាច្រើន កំពុងសម្តែងនូវអមតបទ ។ ខ្ញុំកន្លងនូវពួកជន ហើយថ្វាយបង្គំនូវពាក្យប្រដៅនៃព្រះជិនស្រី បានធ្វើនូវស្បែកខ្លាទៀងស្មាម្ខាង ហើយពោលសរសើរគុណនៃព្រះលោកនាយកថា

ព្រះអង្គជាសាស្តាដូចជាទង់ ដូចជាទង់ជ័យ ឬដូចប្រាសាទ ជាទីពឹងពំនាក់របស់ពួកសត្វ ជាប្រទីប ទ្រង់ឧត្តមជាងសត្វជើងពីរ ។

**ចប់ ភាណវារៈទី ២១ ។**

បពិត្រព្រះមុនី ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់មានព្រះប្រាជ្ញាដ៏ល្អិត ក្នុងទស្សនញ្ញាណ ទ្រង់ញ៉ាំងពួកជនឲ្យឆ្លង នឹងរកបុគ្គលដទៃជាអ្នកចម្លងឲ្យលើសលុបជាងព្រះអង្គក្នុងលោកមិនមានឡើយ ។ សមុទ្ទសាគរដ៏ឧត្តម បុគ្គលអាចនឹងប្រមាណដោយចុងស្បូវបាន ឯសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ បុគ្គលមិនអាចប្រមាណបានឡើយ ។ ផែនដីបុគ្គលអាចដាក់លើជងជញ្ជីង ដើម្បីថ្លឹងបាន បពិត្រព្រះអង្គមានចក្ខុ ( វត្ថុដទៃ ) ស្មើដោយបញ្ញារបស់ព្រះអង្គមិនមានឡើយ ។ អាកាសគេអាចវាស់ដោយខ្សែ ឬដោយអង្គុលីបាន បពិត្រព្រះសព្វញ្ញូ សីលរបស់ព្រះអង្គ បុគ្គលមិនអាចប្រមាណបានឡើយ ។ បពិត្រព្រះអង្គមានចក្ខុ ទឹកក្នុងមហាសមុទ្ទក្តី អាកាសក្តី ផែនដីក្តី របស់ទាំងអម្បាលនេះ បុគ្គលអាចប្រមាណបាន ឯព្រះអង្គឥតមានបុគ្គលប្រមាណបានឡើយ ។

គ្រានោះ ខ្ញុំបានសរសើរនូវព្រះសព្វញ្ញូមានយសធំ ដោយព្រះគាថាទាំងឡាយ ៦ ហើយឈរផ្គងនូវអញ្ជលីនៅស្ងៀម ។ ជនទាំងឡាយតែងហៅនូវព្រះមានព្រះភាគអង្គណា ដែលមានព្រះបញ្ញាដូចផែនដី ទ្រង់ទម្លាយបង់នូវកិលេស ថាសុមេធៈ ព្រះមានព្រះភាគអង្គនោះ ទ្រង់គង់នៅក្នុងកណ្តាលភិក្ខុសង្ឃ ហើយត្រាស់នូវព្រះគាថាទាំងឡាយនេះថា

បុគ្គលណា បានសរសើរញាណរបស់តថាគត ដោយចិត្តជ្រះថ្លា តថាគតនឹងសរសើរនូវបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់ពាក្យតថាគតសម្តែងចុះ ។ បុគ្គលនោះនឹងត្រេកអរក្នុងទេវលោកអស់ ៧៧ កប្ប នឹងបានជាធំ

ជាងទេវតាសោយរាជ្យជាស្តេចនៃទេវតាអស់មួយពាន់ដង ។ នឹងបានជាស្តេចចក្កពត្តិច្រើនរយជាតិ នឹងបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយ នឹងគណនារាប់មិនបាន ។ បើកើតជាទេវតាឬជាមនុស្ស នឹងជាអ្នកប្រកបដោយបុញ្ញកម្មមានសេចក្តីត្រិះរិះមិនឱនថយ ទាំងមានប្រាជ្ញាមោះមុត ។ កន្លងទៅ ៣០.០០០ កប្ប ព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលនៃស្តេចឱក្កាកៈ ត្រាស់ឡើងក្នុងលោក ។ ( កុលបុត្តនេះ ) ជាអ្នកមិនមានកង្វល់ ចេញចាកផ្ទះ ហើយបួស នឹងបានសម្រេចព្រះអរហត្តក្នុងអាយុ ៧ ឆ្នាំ រាប់អំពីឆ្នាំកំណើតមក ។

ខ្ញុំរឭកឃើញនូវខ្លួនដោយហេតុណា ខ្ញុំបានដល់នូវសាសនាដោយហេតុណា ក្នុងចន្លោះនេះ ខ្ញុំមិនធ្លាប់ដឹងនូវចេតនាដែលមិនជាទីត្រេកអរនៃចិត្តទេ ។ ខ្ញុំអន្ទោលទៅមកក្នុងភពតូចភពធំហើយ តែងទទួលនូវសម្បត្តិ ឯសេចក្តីខ្វះខាតកោតៈរបស់ខ្ញុំ ឥតមានឡើយ នេះជាផលក្នុងការសរសើរនូវព្រះញាណ ។ ភ្លើង ៣ ប្រការរបស់ខ្ញុំរលត់ហើយ ភពទាំងពួងខ្ញុំបានដកចោលចេញហើយ ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរនូវព្រះញាណក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលក្នុងការសរសើរនូវព្រះញាណ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ

៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះញាណត្ថវិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ញាណត្ថវិកត្ថេរាបទាន ។**

# ចន្ទនមាលិយត្ថេរាបទានទី ៩

[ ៧៥ ] ខ្ញុំលះបង់នូវកាមគុណទាំង ៥ ដែលមានសភាពជាទីស្រឡាញ់ ជាទីរីករាយនៃចិត្ត លះបង់នូវសម្បត្តិ ៨០ កោដិ ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសហើយ បានវៀរនូវបាបកម្មដោយកាយ លះបង់នូវវចីទុច្ចរិត ហើយនៅជិតច្រាំងស្ទឹង ។ ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ស្តេចបានចូលមករកខ្ញុំដែលកំពុងនៅតែម្នាក់ឯង ខ្ញុំក៏មិនស្គាល់ព្រះអង្គថាជាព្រះពុទ្ធទេ តែខ្ញុំបានធ្វើបដិសណ្ឋារៈ ។ លុះខ្ញុំធ្វើបដិសណ្ឋារៈហើយ បានសួរនូវនាមនិងគោត្តថា អ្នកជាទេវតាឬជាគន្ធព្វ ឬមួយអ្នកជាព្រះឥន្ទជាប់ឲ្យទានក្នុងកាលមុន អ្នកជាអ្វី អ្នកជាបុត្តរបស់បុគ្គលណា ឬអ្នកជាមហាព្រហ្មមកក្នុងទីនេះ បានញុំាងទិសទាំងពួងឲ្យភ្លឺប្រាល ដូចព្រះអាទិត្យកំពុងរះ ។ ម្នាលអ្នកនិទ្ទុក្ខ ចក្កទាំងឡាយមានកាំមួយពាន់ ប្រាកដក្នុងបាទា ( នៃអ្នក ) អ្នកជាអ្វី អ្នកជាបុត្តរបស់បុគ្គលណា ដូចម្តេចហ្ន៎ យើងនឹងស្គាល់អ្នក ។ សូមអ្នកប្រាប់នូវនាម និង

គោត្ត ( របស់អ្នក ) ចូរអ្នកនាំនូវសេចក្តីសង្ស័យរបស់ខ្ញុំចេញ ។

តថាគតមិនមែនជាទេវតា មិនមែនជាគន្ធព្វ តថាគតមិនមែនជាព្រះឥន្ទ្រ ធ្លាប់ឲ្យទានក្នុងកាលមុនទេ ។ មួយទៀត តថាគតមិនមែនជាព្រហ្មទេ តថាគតប្រសើរជាងជនទាំងនោះ បានកន្លងនូវវិស័យរបស់ជនទាំងនោះ ហើយផ្តាច់បង់នូវចំណងគឺកាម ។ តថាគតដុតបង់នូវកិលេសទាំងអស់ហើយ បានដល់នូវសេចក្តីត្រាស់ដឹងដ៏ប្រសើរ ។

ខ្ញុំបានស្តាប់នូវវាចារបស់ព្រះពុទ្ធនោះ ហើយពោលនូវពាក្យនេះថា បពិត្រព្រះមហាមុនី បើព្រះអង្គជាសព្វញ្ញុពុទ្ធ ជាមហាមុនី សូមព្រះអង្គគង់សិន ខ្ញុំនឹងបូជាព្រះអង្គ ព្រោះព្រះអង្គជាអ្នកធ្វើនូវទីបំផុតនៃទុក្ខបានហើយ ។ ខ្ញុំបានក្រាលនូវស្បែកខ្លាថ្វាយព្រះសាស្តា ព្រះមានព្រះភាគ ទ្រង់គង់លើស្បែកខ្លានោះ ដូចជាសត្វសីហៈដែលឋិតនៅលើញកនៃភ្នំ ។ ខ្ញុំបានឡើងភ្នំជាប្រញាប់ ហើយបេះយកផ្លែស្វាយ ផ្កាក្លៀនាង និងខ្លឹមចន្ទន៍ដ៏មានតម្លៃច្រើន ខ្ញុំបានលើកផ្គងនូវរបស់ទាំងអស់នុ៎ះជាប្រញាប់ បង្អោនចូលទៅរកព្រះលោកនាយក ខ្ញុំបានថ្វាយផ្លែឈើ បានបូជាផ្កាក្លៀនាង ដល់ព្រះពុទ្ធ ។ ខ្ញុំលាបនូវខ្លឹមចន្ទន៍ហើយបានថ្វាយបង្គំព្រះសាស្តា ខ្ញុំមានចិត្តជ្រះថ្លា រីករាយដោយបីតិដ៏ធំទូលាយ ។ ក្នុងកាលនោះ ព្រះសុមេធៈជាលោកនាយក ដែលកំពុងគង់លើស្បែកខ្លា ទ្រង់ញុំាងខ្ញុំឲ្យរីករាយ ហើយទ្រង់សម្តែងនូវកុសលកម្មរបស់ខ្ញុំថា

ក្នុងកប្បទី ២.៥០០ បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក ដោយហេតុទាំងពីរយ៉ាង គឺដោយការឲ្យនូវផ្លែឈើនេះផង ដោយការឲ្យគ្រឿងក្រអូបនិង

កម្រងផ្កានេះផង ។ បុគ្គលនេះ នឹងមានសេចក្តីត្រិះរិះមិនឱនថយ ប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ក្នុងកប្បទី ២.៦០០ បុគ្គលនេះនឹងដល់នូវភាពជាមនុស្ស ។ នឹងបានជាស្តេចចក្កពត្តិ មានសមុទ្ទទាំង ៤ ជាព្រំប្រទល់ ទាំងមានឫទ្ធិធំឯទីក្រុងឈ្មោះវេភារៈ ជាក្រុងដែលវិស្សកម្មទេវបុត្តនិម្មិតថ្វាយ ។ ទីក្រុងឈ្មោះវេភារៈនោះ ជាមាសទាំងអស់ ស្អិតស្អាងដោយរតនៈផ្សេងៗ បុគ្គលនេះនឹងអន្ទោលទៅកាន់កំណើតទាំងឡាយដោយឧបាយនេះឯង ។ បុគ្គលនេះនឹងមានសេចក្តីសុខក្នុងទីទាំងពួង គឺថាក្នុងទេវតា ឬក្នុងមនុស្សលោក លុះដល់បច្ឆិមភព នឹងបានជាព្រហ្មពន្ធុ ( ផៅពង្សនៃបុគ្គលដ៏ប្រសើរ ) ។ បុគ្គលនេះនឹងចេញចាកផ្ទះ ទៅជាអ្នកបួស ជាបុគ្គលដល់នូវត្រើយនៃអភិញ្ញា មិនមានអាសវៈ ហើយបរិនិព្វាន ។

ព្រះសម្ពុទ្ធព្រះនាម សុមេធៈ ជាលោកនាយក លុះទ្រង់ត្រាស់នូវកម្មរបស់ខ្ញុំនេះហើយ កាលខ្ញុំកំពុងតែសម្លឹងមើល ព្រះអង្គទ្រង់ស្តេចជៀសចេញទៅតាមផ្លូវអាកាស ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ចូលទៅកើតក្នុងភពតុសិត ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ លុះខ្ញុំច្យុតអំពីឋានតុសិត បានមកកើតក្នុងផ្ទៃនៃមាតា ខ្ញុំមិនខ្វះខាតភោគៈ ខ្ញុំនៅក្នុងគភ៌នៃមាតាណា កាលខ្ញុំនៅក្នុងគភ៌មាតានោះ បាយក្តី ទឹកក្តី ភោជនក្តី តែងកើតឡើងសម្រាប់មាតា តាមសេចក្តីប្រាថ្នារបស់ខ្ញុំ ។ ខ្ញុំមានអាយុ ៥ ឆ្នាំ រាប់អំពីឆ្នាំកំណើតមក បានចូលទៅកាន់ផ្នួស កាលដែលគេកំពុងតែកោរសក់ ខ្ញុំក៏បានសម្រេចព្រះអរហត្ត ។ ខ្ញុំកាលស្វែងរកនូវបុព្វកម្ម

( របស់ខ្ញុំ ) ក៏មិនបានឃើញបុព្វកម្មខាងអាយ តែបាននឹកឃើញនូវបុព្វកម្មរបស់ខ្ញុំក្នុងកប្បទី ៣០.០០០ ។ បពិត្របុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ខ្ញុំបានអាស្រ័យនូវសាសនារបស់ព្រះអង្គហើយ ទើបដល់នូវអចលបទ គឺព្រះនិព្វាន ។ ក្នុងកប្បទី ៣០.០០០ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចន្ទនមាលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ចន្ទនមាលិយត្ថេរាបទាន ។

# ធាតុបូជកត្ថេរាបទានទី ៦

[ ៧៦ ] កាលព្រះលោកនាថ ព្រះនាមសិទ្ធត្ថៈ ជាលោកនាយក ស្ដេចបរិនិព្វានហើយ ខ្ញុំបានប្រជុំពួកញាតិរបស់ខ្ញុំ ហើយធ្វើនូវការបូជាព្រះធាតុ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះធាតុក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះធាតុ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីដ៏ប្រសើរកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធាតុបូជកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ធាតុបូជកត្ថេរាបទាន ។**

## អដ្ឋកថា

## ញាណត្ថវិកត្ថេរាបទាន ជាដើម

[ ៧៤-៧៦ ] អបទានទី៤ ទី៥ ទី៦ មានអត្ថងាយយល់ហើយ ។

*អដ្ឋកថាញាណត្ថវិកត្ថេរាបទានជាដើម ចប់*

# បុប្ផិទុប្បាទកត្ថេរាបទានទី ៧

[ ៧៧ ] ខ្ញុំកើតជាតាបស ឈ្មោះទេវលៈនៅទៀបភ្នំហិមពាន្ត ពួកអមនុស្សបានតាក់តែងទីចង្ក្រមឲ្យខ្ញុំក្នុងព្រៃហិមពាន្តនោះ ។ ក្នុងកាលនោះឯង ខ្ញុំបានប្រដាប់នូវគ្រឿងប្រដាប់ គឺផ្នួងសក់ ទ្រទ្រង់នូវកុណ្ឌីទឹក កំពុងតែស្វែងរកនូវប្រយោជន៍ដ៏ឧត្តម ហើយចេញទៅអំពីព្រៃ ។ ក្នុងកាលនោះសិស្សទាំងឡាយរបស់ខ្ញុំ ប្រមាណ ៨៤.០០០ នាក់ បានចូលមកនៅបម្រើខ្ញុំ សិស្សទាំងនោះ មានសេចក្តីខ្វល់ខ្វាយក្នុងកិច្ចជារបស់ខ្លួន ហើយនៅក្នុងព្រៃ ។ ខ្ញុំបានចេញអំពីអាស្រម ហើយធ្វើព្រះចេតិយ ដ៏ហើយទៅដោយដីខ្សាច់ ខ្ញុំបានប្រមូលផ្កាផ្សេងៗ ហើយបូជានូវព្រះចេតិយនោះ ។ ខ្ញុំបានញុំាំងចិត្តឲ្យជ្រះថ្លាក្នុងចេតិយនោះ ហើយបានចូលទៅកាន់អាស្រមវិញ ។

ពួកសិស្សទាំងអស់នាំគ្នាមកហើយ បានសួរសេចក្តីនេះថា បពិត្រទេវៈលោកថ្វាយបង្គំនូវព្រះស្តូបណា ព្រះស្តូបនោះដែលលោកធ្វើហើយដោយដីខ្សាច់ ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយចង់ដឹង លោកកាលបើយើងខ្ញុំទាំងឡាយសួរហើយ សូមមេត្តាប្រាប់ដល់យើងខ្ញុំទាំងឡាយ ។

ព្រះសម្ពុទ្ធទាំងឡាយ ទ្រង់មានចក្ខុ មានយសធំ ( ប្រាកដ ) ក្នុងបទរបស់មន្តនៃអ្នកទាំងឡាយ យើងឃើញហើយតើ ខ្ញុំថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ជាព្រះពុទ្ធដ៏ប្រសើរ មានយសធំ ។

ព្រះសព្វញ្ញូទាំងនោះ ជាលោកនាយក ទ្រង់មានព្យាយាមធំ ប្រាកដដូចម្តេច មានគុណដូចម្តេច មានសីលដូចម្តេច ព្រះសម្ពុទ្ធទាំងនោះ មានយសធំប្រាកដដូចម្តេច ។

ព្រះពុទ្ធទាំងឡាយ មានលក្ខណៈ ៣២ មានព្រះទន្ត ៤០ គត់ មានកំណើតពីរដង ព្រះនេត្រនៃព្រះសម្មាសម្ពុទ្ធទាំងនោះ ស្រដៀងនឹងភ្នែកកូនគោ ប្រាកដស្មើដោយផ្លែនៃទំពាំងបាយជូរ ។ ព្រះសម្ពុទ្ធទាំងនោះ កាលស្តេចនឹងទៅ ទ្រង់ក្រឡេកមើលនូវទីចម្ងាយមួយជួរនឹមផង ព្រះជាណុនៃព្រះសម្មាសម្ពុទ្ធទាំងនោះ មិនលាន់ឮសូរផង សំឡេងទីតនៃព្រះជាណុរបស់ព្រះសម្មាសម្ពុទ្ធទាំងនោះ មិនឮសូរផង ។ ព្រះសម្ពុទ្ធទាំងនោះ កាលស្តេចទៅ ក៏ទ្រង់ទៅដោយល្អ ទៅមិនបានរួសរាន់ ( ទ្រង់ឈាន ) នូវព្រះបាទខាងស្តាំជាដំបូង នេះជាធម្មតានៃព្រះសម្ពុទ្ធទាំងឡាយ ។ មួយទៀត ព្រះពុទ្ធទាំងនោះ ទ្រង់មិនតក់ស្លុតបីដូចជាកេសររាជសីហ៍ ជាស្តេចនៃម្រឹគ ព្រះពុទ្ធទាំងឡាយទ្រង់មិនលើកតម្កើងព្រះអង្គឯងផង ទាំងមិនបន្ទះបន្ទាប់ពួកសត្វផង ។ ព្រះពុទ្ធទាំងឡាយទ្រង់ផុតស្រឡះចាកមានះ និងអតិមានះ ទ្រង់មានព្រះហឫទ័យស្មើចំពោះសត្វទាំងពួង ទ្រង់មិនលើកតម្កើងព្រះអង្គឯង នេះជាធម្មតានៃព្រះសម្ពុទ្ធទាំងឡាយ ។ មួយវិញទៀត ព្រះសម្ពុទ្ធទាំងឡាយនោះ កាលកើតឡើង ទ្រង់សម្តែងនូវពន្លឺ ទ្រង់ប្រកាសនូវផែនដីទាំងអស់នេះ មានប្រការ ៦ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធទាំងឡាយនុ៎ះ ទ្រង់ទតឃើញនូវនរក នរកតែងរលត់ទៅវិញ មហាមេឃបង្អុរភ្លៀងចុះមក នេះជាធម្មតានៃព្រះពុទ្ធទាំងឡាយ ។ ព្រះតថាគតទាំងនោះ ជាមហានាគប្រាកដដូច្នោះ ព្រះតថាគតទាំងនោះទ្រង់មានយសធំ គេមិនអាចថ្លឹងគុណបាន ព្រះតថាគតទាំងឡាយ ទ្រង់មិនប្រព្រឹត្តកន្លងចាកគុណ មានព្រះគុណគឺបុគ្គលមិនគប្បីរាប់បាន ។ ពួកសិស្ស

ទាំងអស់ជាអ្នកប្រកបដោយសេចក្តីគោរព បានអនុមោទនាតាមពាក្យរបស់ខ្ញុំ សិស្សទាំងឡាយនោះ បាននាំគ្នាប្រតិបត្តិគួរតាមសេចក្តីអង់អាច ទាំងគួរតាមកម្លាំងដោយប្រការដូច្នោះ ។ សិស្សទាំងឡាយនោះ ជាអ្នកមិនខ្ជិលប្រអូសក្នុងការងាររបស់ខ្លួន នាំគ្នាបូជានូវព្រះចេតិយខ្សាច់ សិស្សទាំងឡាយនោះ ជាអ្នកជឿតាមពាក្យរបស់ខ្ញុំ ជាអ្នកមានចិត្តដល់នូវភាពជាព្រះពុទ្ធ ។

ក្នុងកាលនោះ មានទេវបុត្តមួយអង្គ មានយសធំ ច្យុតចុះមកអំពីឋានតុសិត បានមកកើតក្នុងផ្ទៃមាតា លោកជាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ។ ខ្ញុំឋិតនៅក្នុងទីចង្ក្រមមិនឆ្ងាយអំពីអាស្រម ពួកសិស្សទាំងអស់ បានមកប្រជុំគ្នាក្នុងសម្នាក់របស់ខ្ញុំ ហើយសួរខ្ញុំថា ផែនដីបន្លឺដូចគោឧសភរាជ ស្រែកឡើងដូចស្តេចនៃម្រឹគ រោទ៍ឡើងដូចជាក្រពើ តើជាវិបាកអ្វីហ្ន៎ ។

ខ្ញុំកំពុងសរសើរនូវព្រះសម្ពុទ្ធអង្គណា ក្នុងទីជិតនៃព្រះស្តូបដែលធ្វើហើយដោយដីខ្សាច់ ឥឡូវនេះ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាគ្រូ បានស្តេចចូលទៅកាន់ផ្ទៃនៃមាតា ។ ខ្ញុំបានធ្វើធម្មកថាដល់សិស្សទាំងឡាយនោះហើយសរសើរនូវព្រះមហាមុនី រួចបញ្ជូនពួកសិស្សឲ្យត្រឡប់ទៅលំនៅជារបស់នៃខ្លួនវិញ ហើយខ្ញុំអង្គុយពែនភ្នែន ។ មួយទៀត ខ្ញុំអស់កម្លាំងណាស់ ព្រោះខ្ញុំមានរោគាព្យាធិជាទម្ងន់ ខ្ញុំរឭកនូវព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយក៏ធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកាលនោះ ពួកសិស្សទាំងអស់ បានមកប្រជុំគ្នាហើយធ្វើជើងថ្ករ រួចលើកសពរបស់ខ្ញុំដាក់លើជើងថ្ករ សិស្សទាំងឡាយនោះបានចោមរោមជើងថ្ករ ហើយធ្វើនូវអញ្ជលីលើសិរ្ស: មានសរគឺសេចក្តីសោក

គ្របសង្កត់ បានមកប្រជុំគ្នាហើយ យំកន្ទក់កន្ទេញ ។ កាលសិស្សទាំងឡាយនោះកំពុងតែយំរៀបរាប់ ខ្ញុំក៏មកកាន់ជើងថ្ករ ហើយបានពោលថា ម្នាលអ្នកទាំងឡាយមានបញ្ញាល្អ យើងហ្នឹងហើយជាអាចារ្យរបស់អ្នក អ្នកទាំងឡាយកុំសោកស្តាយឡើយ ។ អ្នកទាំងឡាយកុំខ្ជិលច្រអូស ចូរនាំគ្នាព្យាយាមក្នុងប្រយោជន៍របស់ខ្លួន ទាំងយប់ទាំងថ្ងៃចុះ អ្នកទាំងឡាយកុំមានសេចក្តីប្រមាទឡើយ ខណៈរបស់អ្នកទាំងឡាយដល់ប្រាកដហើយ ។ លុះខ្ញុំប្រៀនប្រដៅនូវពួកសិស្សរបស់ខ្លួនរួចហើយ ខ្ញុំក៏ត្រឡប់ទៅឯទេវលោកវិញ ខ្ញុំបានកើតក្នុងទេវលោកអស់ ១៨ កប្ប ខ្ញុំបានកើតជាស្តេចចក្រពត្តិអស់ ៥០០ ដង ខ្ញុំបានទទួលសម្បត្តិជាទេវតាអស់ច្រើនរយដង ។ ក្នុងកប្បទាំងឡាយដ៏សេសខ្ញុំបានអន្ទោលទៅកាន់ភពដ៏ច្រឡូកច្រឡំ តែខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការកសាងព្រះចេតិយខ្សាច់ ។ ឈើទាំងឡាយជាច្រើន តែងរីកផ្កាក្នុងខែជាទីរីកនៃផ្កាកោមុទ យ៉ាងណាមិញ ឯខ្លួនខ្ញុំក៏បានរីកហើយ ក្នុងលទ្ធិនៃព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គស្វែងរកនូវគុណដ៏ធំដូច្នោះដែរ ។ ខ្ញុំមានព្យាយាមជាទីនាំទៅនូវធុរៈ ដល់ហើយនូវព្រះនិព្វានជាទីអស់ទៅនៃយោគៈ ជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះសម្ពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ !

ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិនុប្បាទកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បុឡិនុប្បាទកត្ថេរាបទាន ។**

# អដ្ឋកថា

# បុឡិនុប្បាទកត្ថេរាបទាន

[ ៧៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា

បទថា **ចត្តាលីសទិជាបិ ច** សេចក្តីថា ធ្មេញ ឈ្មោះថា **ទិជា** ព្រោះកើត ២ ដង អធិប្បាយថា ធ្មេញ ឈ្មោះថា **ទិជា** ព្រោះធ្មេញដែលដុះឡើងក្នុងវ័យកុមារបាក់ទៅ ហើយមានធ្មេញកើតឡើងជាថ្មី ជាធ្មេញដូចគ្នា ។ ការព្យាករណ៍ ( តាបសឆ្លើយជាមួយសិស្ស ) បានពោលទុកហើយក្នុងនិទានខាងដើមនោះឯង ។

**អដ្ឋកថាបុឡិនុប្បាទកត្ថេរាបទាន ចប់**

# តរណិយត្ថេរាបទានទី ៨

[ ៧៨ ] ព្រះតថាគតមានព្រះភាគ ព្រះនាមអត្ថទស្សី ជាព្រះសយម្ភូ ជាលោកនាយក ស្តេចបានចូលទៅទៀបច្រាំងស្ទឹងវិនតា ។ ខ្ញុំជាអណ្តើក គោចរក្នុងទឹក បានងើបអំពីទឹក មានប្រាថ្នានឹងចម្លងនូវព្រះពុទ្ធជាម្ចាស់ បានចូលទៅជិតព្រះលោកនាយក ហើយពោលថា បពិត្រព្រះមហាមុនី សូមព្រះពុទ្ធជាម្ចាស់ព្រះនាមអត្ថទស្សី ទ្រង់ឡើងគង់លើខ្នងនៃខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងចម្លងព្រះអង្គ ព្រោះព្រះអង្គបានធ្វើនូវទីបំផុតនៃទុក្ខ ។ ព្រះអត្ថទស្សីមានយសធំ ជាលោកនាយក ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ក៏ឡើងគង់លើខ្នងរបស់ខ្ញុំ ។ វេលាណាខ្ញុំរឭកឃើញនូវខ្លួន វេលាណាខ្ញុំដល់នូវភាពដើនក្តីហើយ វេលានោះ ខ្ញុំមិនមានសេចក្តីសុខបែបនោះសោះឡើយ ដូចជាផ្ទៃនៃបាតជើង ( ដែលត្រូវបន្ទា ) មុត ។ ព្រះសម្ពុទ្ធព្រះនាមអត្ថទស្សី មានយសធំ ទ្រង់ឆ្លងដល់ត្រើយហើយ ព្រះអង្គឋិតនៅទៀបច្រាំងស្ទឹង ហើយទ្រង់ត្រាស់នូវព្រះគាថានេះថា

ចិត្តប្រព្រឹត្តទៅដរាបណា តថាគតឆ្លងនូវក្រសែនៃសេចក្តីសង្ស័យបានដរាបនោះ ចំណែកអណ្តើកនេះ នឹងបានកើតជាស្តេចមានបុណ្យ ព្រោះបានចម្លងនូវតថាគត ។ អណ្តើកនេះ នឹងត្រេកអរក្នុងទេវលោកអស់ ១.៨០០ កប្បដោយការចម្លងព្រះពុទ្ធនេះផង ដោយមេត្តាចិត្តដែលប្រព្រឹត្តទៅនេះផង ។ លុះច្យុតចាកទេវលោកមកក្នុងលោកនេះ ត្រូវកុសលមូលដាស់តឿន ហើយនឹងអង្គុយនៅលើអាសនៈតែមួយ ហើយឆ្លងនូវក្រសែនៃសេចក្តីសង្ស័យបាន ។

ពូជសូម្បីមានប្រមាណតិច ដែលបុគ្គលព្រោះហើយក្នុងស្រែដ៏ល្អ កាល

ភ្លៀងញ៉ាំងជារទឹកឲ្យធ្លាក់ចុះដោយល្អ ផលរមែងញ៉ាំងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ ។ ព្រះពុទ្ធខេត្តនេះ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ រមែងញ៉ាំងជារគឺផលឲ្យធ្លាក់ចុះដោយប្រពៃ ផលនឹងញ៉ាំងខ្ញុំឲ្យត្រេកអរបាន ក៏យ៉ាងនោះដែរ ។ ខ្ញុំជាអ្នកមានចិត្តបញ្ជូនទៅកាន់សេចក្តីព្យាយាម ហើយជាអ្នកស្ងប់រម្ងាប់ មិនមានឧបធិក្កិលេស បានកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបម្រុងព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតរណិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ តរណិយត្ថេរាបទាន ។**

# អដ្ឋកថា

# តរណិយត្ថេរាបទាន

[ ៧៨ ] អបទានទី ៨ មានអត្ថងាយយល់ហើយ ។

*អដ្ឋកថាតរណិយត្ថេរាបទាន ចប់*

# ធម្មរុចិត្ថេរាបទានទី ៩

[ ៧៩ ] កាលណាព្រះជិនសិរីសម្ពុទ្ធជាម្ចាស់ ព្រះនាមទីបង្ករៈ ទ្រង់ព្យាករនូវព្រះសុមេធតាបសថា សុមេធតាបសនេះនឹងបានត្រាស់ជា ព្រះពុទ្ធក្នុងអបរិមេយ្យកប្ប ( កប្បរាប់មិនបាន ) អំពីកប្បនេះ ។ ព្រះមាតាបង្កើតនៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ សុមេធតាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតមៈ ។ សុមេធតាបសនេះ តម្កល់ទុកនូវសេចក្តីព្យាយាមហើយ ធ្វើទុក្ករកិរិយា នឹងបានត្រាស់ដឹងជាព្រះសម្ពុទ្ធមានយសធំ ក្រោមម្លប់នៃអស្សត្ថព្រឹក្ស ។ ភិក្ខុឈ្មោះឧបតិស្សៈ ១ ឈ្មោះកោលិតៈ ១ នឹងបានជាសាវកដ៏ប្រសើរ ភិក្ខុជាអ្នកឧបដ្ឋាកមាននាមថាអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ ។ ភិក្ខុនីឈ្មោះខេមា ១ ឈ្មោះឧប្បលវណ្ណា ១ នឹងបានជាសាវិកាដ៏ប្រសើរ គហបតិឈ្មោះចិត្តៈ ១ ឈ្មោះអាឡវកៈ ១ នឹងបានជាឧបាសកដ៏ប្រសើរ ។ នាងខុជ្ជុត្តរា ១ នាងនន្ទមាតា ១ នឹងបានជាឧបាសិកាដ៏ប្រសើរ ដើមឈើសម្រាប់ត្រាស់ដឹងនៃអ្នកប្រាជ្ញអង្គនេះ គេហៅថាអស្សត្ថព្រឹក្ស ។

ពួកមនុស្សនិងទេវតា បានឮព្រះពុទ្ធដីកានេះ នៃព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណដ៏ធំ ឥតមានបុគ្គលណាស្មើ ក៏មានចិត្តរីករាយ នាំគ្នាធ្វើអញ្ជលីនមស្ការ ។ បពិត្រព្រះមហាមុនី កាលនោះ ខ្ញុំជាមាណពឈ្មោះមេឃៈ អ្នកសិក្សាប្រពៃ បានឮពាក្យព្យាករណ៍ដ៏ប្រសើរនៃសុមេធតាបស ។ ខ្ញុំស្និទ្ធស្នាលនឹងសុមេធតាបស មានករុណាជាលំនៅ ខ្ញុំក៏បានបួសតាមតាបសជាអ្នកមានព្យាយាម ដែលទ្រង់ផ្នួសនោះ ។ ខ្ញុំសង្រួមក្នុងបាតិមោក្ខផង ក្នុង

ឥន្ទ្រិយទាំង ៥ ផង មានអាជីវៈដ៏បរិសុទ្ធ មានសតិ ជាអ្នកប្រាជ្ញ ជាអ្នកធ្វើតាមពាក្យប្រដៅនៃព្រះជិនស្រី ។ កាលខ្ញុំនៅជាមួយនឹងបាបមិត្តណាមួយយ៉ាងនេះ ក៏បានប្រកបក្នុងអនាចារ ហើយឃ្លាតចាកផ្លូវដ៏ល្អ ។ ខ្ញុំជាអ្នកលុះក្នុងអំណាចវិតក្កៈ បានចៀសចេញអំពីសាសនា វេលាក្រោយមក ខ្ញុំបានប្រកបដោយបាបមិត្តអាក្រក់នោះទៀត ក៏ប្រព្រឹត្តធ្វើនូវមាតុឃាត ។ ខ្ញុំមានចិត្តប្រទូស្ត បានធ្វើអនន្តរិយកម្ម គឺសម្លាប់មាតា ខ្ញុំច្យុតអំពីអត្តភាពនោះ បានទៅកើតក្នុងមហាអវីចិនរកដ៏អាក្រក់ក្រៃពេក ។ ខ្ញុំទៅកើតក្នុងអសុរកាយ ដល់នូវសេចក្តីទុក្ខ អន្ទោលទៅអស់កាលជាយូរអង្វែង លែងបានឃើញព្រះសុមេធតាបស ជាអ្នកប្រាជ្ញប្រសើរជាងជន ។ ក្នុងកប្បនេះ ខ្ញុំបានកើតជាត្រីសមុទ្ទ ឈ្មោះតិមិង្គលៈ បានឃើញសំពៅក្នុងសាគរ ក៏ចូលទៅជិត ដើម្បីអាហារ ។ ពាណិជទាំងឡាយបានឃើញខ្ញុំហើយ ក៏មានសេចក្តីភិតភ័យបាននាំគ្នារំឭកគុណនៃព្រះពុទ្ធដ៏ប្រសើរថា គោតមៗ ដូច្នេះ ខ្ញុំក៏បានឮសំឡេងគឹកកងខ្លាំងដែលពួកពាណិជទាំងនោះពោលហើយ ។ ខ្ញុំរឭកឃើញនូវសញ្ញាអំពីដើម តអំពីនោះមក ខ្ញុំធ្វើនូវមរណកាល បានទៅកើតក្នុងកំណើតនៃព្រាហ្មណ៍ ជាត្រកូលស្តុកស្តម្ភក្នុងក្រុងសាវត្ថី ។ ខ្ញុំមានឈ្មោះធម្មរុចិ ជាអ្នកខ្ពើមរអើមនូវបាបទាំងពួង មានអាយុ ៧ ឆ្នាំ រាប់អំពីកំណើត បានឃើញព្រះពុទ្ធជាពន្លឺក្នុងលោក ។ ខ្ញុំបានទៅកាន់វត្តជេតពនដ៏ប្រសើរ ហើយចូលទៅកាន់ផ្នួស ចូលទៅជិតព្រះពុទ្ធអស់វារៈ ៣ ដង រាល់យប់រាល់ថ្ងៃ ។ កាលនោះ ព្រះមុនីបានទតឃើញខ្ញុំហើយ ក៏ត្រាស់ថា នែធម្មរុចិ អ្នកចូររឭក

តអំពីនោះទៅ ។ ខ្ញុំបានពោលនូវបុព្វកម្មដែលខ្លួនខ្ញុំបានអប់រំហើយ ថ្វាយព្រះពុទ្ធជាម្ចាស់ថា

ខ្ញុំខានបានឃើញព្រះពុទ្ធ មានបុញ្ញលក្ខណៈច្រើន មានវិសុទ្ធិជាបច្ច័យក្នុងកាលមុន អស់កាលយូរហើយ ទើបតែក្នុងថ្ងៃនេះ ខ្ញុំបានឃើញព្រះកាយរបស់ព្រះអង្គ ដ៏គួររមិលមើល រកបុគ្គលប្រៀបពុំបាន ។ ខ្ញុំបានតម្កល់បុណ្យចំពោះព្រះអង្គអស់កាលយូរ កិលេសទាំងឡាយខ្ញុំបានឲ្យរីងស្ងួត មិនមានសេសសល់ ដោយការរក្សាដ៏ស្អាត បពិត្រព្រះមហាមុនី ភ្នែកគឺញាណ មិនមានមន្ទិល ខ្ញុំបានជម្រះហើយអស់កាលយូរ ។ ខ្ញុំព្រះអង្គប្រកបជាមួយនឹងព្រះអង្គ អស់កាលដ៏យូរ មិនវិនាសក្នុងចន្លោះថ្មីទៀត អស់កាលដ៏យូរ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គប្រកបព្រមជាមួយនឹងព្រះអង្គម្តងទៀត បពិត្រព្រះគោតមៈ អំពើទាំងឡាយដែលខ្ញុំបានធ្វើ មិនវិនាសឡើយ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មរុចិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ធម្មរុចិត្ថេរាបទាន ។**

## អដ្ឋកថា

## ធម្មរុចិត្ថេរាបទាន

[ ៧៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះថា បទថា **តទាហំ មាណវោ អាសឹ** សេចក្ដីថា សុមេធបណ្ឌិត បានទទួលព្យាករណ៍អំពីសម្នាក់របស់ព្រះមានព្រះភាគព្រះនាមថាទីបង្ករ ក្នុងកាលណា ក្នុងកាលនោះ ខ្ញុំឈ្មោះថា មេឃៈ ជាព្រាហ្មណ៍កំលោះ បួសជាឥសី នៅជាមួយសុមេធតាបស ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ហើយប្រឡូកប្រឡំ ជាមួយមិត្តអាក្រក់ ព្រោះទោសដែលប្រឡូកប្រឡំទើបធ្លាក់ទៅក្នុងអំណាចវិតក្កៈដ៏លាមកជាដើម បានសោយទុក្ខដែលទាក់ទងដោយអណ្ដាតភ្លើងជាដើម ក្នុងនរក ដោយកម្ម គឺការសម្លាប់មាតា ចុតិចាកអត្តភាពនោះហើយ បានកើតជាត្រីធំឈ្មោះតិមិង្គលៈ ក្នុងសមុទ្ទ មានបំណងនឹងលេបសំពៅធំ ដែលត្រាច់ទៅកណ្ដាលសមុទ្ទ ទើបហែលទៅ ។ ពួកឈ្មួញឃើញខ្ញុំ ខ្លាច ស្រែកដោយសំឡេងខ្លាំងថា ឱ! ព្រះមានព្រះភាគគោតម ។ លំដាប់នោះ ដោយអំណាចវាសនាដែលបានអប់រំមកក្នុងកាលមុន ត្រីធំ ក៏កើតសេចក្ដីគោរពក្នុងព្រះពុទ្ធ ចុតិចាកអត្តភាពនោះហើយ បានកើតក្នុងត្រកូលព្រាហ្មណ៍ដែលសម្បូរដោយសម្បត្តិក្នុងក្រុងសាវត្ថី មានសទ្ធាជ្រះថ្លា បានស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ហើយចេញបួស បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ បានទៅកាន់ទីបម្រើ ១ ថ្ងៃ ៣ ដង វេលាព្រឹក ល្ងាច ថ្វាយបង្គំ ក្នុងកាលនោះ ព្រះមានព្រះភាគត្រាស់នឹងខ្ញុំថា ជាអ្នកត្រេកអរក្នុងធម៌មកអស់កាលយូរ ។ លំដាប់នោះ ព្រះថេរៈអង្គនោះពោលសរសើរដោយគាថាថា **សុចិរំ សតបុញ្ញ លក្ខណំ**

សេចក្ដីថា បពិត្រព្រះគោតម ទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយដ៏ចម្រើន ។ បទថា **បតិបុព្វេន វិសុទ្ធបច្ចយំ** សេចក្ដីថា ខ្ញុំមិនបានឃើញលោកអ្នកសន្សំហេតុនៃសេចក្ដីល្អ រហូតបរិបូណ៌ក្នុងបាទមូលរបស់ព្រះពុទ្ធទីបង្ករ ក្នុងកាលមុន អស់កាលយូរហើយ ។ បទថា **អហាមជ្ជ សុបេក្ខនំ** សេចក្ដីថា ក្នុងថ្ងៃនេះឯង ខ្ញុំបានឃើញហើយហ្ន៎នូវព្រះគោតម ទ្រង់មានព្រះសរីរៈរកបុគ្គលប្រៀបពុំបាន គឺមិនមានវត្ថុប្រៀបធៀប ដែលរាប់ថា ជាការឃើញដោយល្អ ជាការឃើញដែលស្អាតឬជាការឃើញដែលប្រសើរ ។ បទថា **សុចិរំ វិហត-តមោ មយា** សេចក្ដីថា ព្រះអង្គទ្រង់កម្ចាត់ងងឹតបានហើយដោយវិសេស គឺទ្រង់កម្ចាត់មោហៈបានហើយ សូម្បីខ្ញុំព្រះអង្គ ក៏បានសរសើរមកអស់កាលយូរ ។ បទថា **សុចិរក្ខេន ឆធី វិសោសិតា** សេចក្ដីថា ស្ទឹងគឺតណ្ហានេះ ដែលព្រះអង្គបានឲ្យរីងស្ងួតទៅដោយវិសេសហើយ គឺធ្វើមិនឲ្យកើតបានទៀត ដោយឥន្ទ្រិយដែលគ្រប់គ្រងយ៉ាងល្អ ។ បទថា **សុចិរំ អមលំ វិសោធិតំ** សេចក្ដីថា ខ្ញុំព្រះអង្គជម្រះព្រះនិព្វានឲ្យបរិសុទ្ធិដោយល្អហើយ អស់កាលយូរ វែង បិតថេរ គឺព្រះអង្គធ្វើ គឺបានសម្រេចហើយដោយល្អ ។ បទថា **ឆយនំ ញាណមយំ មហាមុនេ ចិរកាលសមង្គិតោ** សេចក្ដីថា បពិត្រព្រះមហាមុនី ដ៏ជាព្រះមហាសមណៈ ភ្នែកគឺញាណ គឺទិព្វចក្ខុ ដែលព្រះអង្គទ្រង់សម្រេច គឺដល់ព្រមហើយ អស់កាលយូរ ។ បទថា **អវិនដ្ឋោ បុន-រន្តរំ** សេចក្ដីថា ខ្ញុំព្រះអង្គបានវិនាស គឺវិនាសទៅក្នុងរវាងភព គឺក្នុងកណ្ដាលម្ដងហើយម្ដងទៀត អស់កាលយូរ ។ បទថា **បុនរជ្ជសមាគតោ តយា**

សេចក្តីថា ថ្ងៃនេះ គឺក្នុងពេលនេះ ខ្ញុំព្រះអង្គបានជួបព្រះអង្គ គឺមករួមជាមួយគ្នាទៀត ។ បទថា **ន ហិ នស្សន្តិ កតានិ គោតម** សេចក្តីថា បពិត្រព្រះគោតម គឺព្រះសព្វញ្ញុពុទ្ធ កម្មមានការ សេពគប់ជាដើម ដែលខ្ញុំព្រះអង្គបានធ្វើរួមជាមួយព្រះអង្គ មិនវិនាសទៅគឺមិនសូន្យទៅដរាបរំលត់ខន្ធបរិនិព្វាន ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយនោះឯង ។

## អដ្ឋកថាធម្មរុចិត្ថេរាបទាន ចប់

# សាលមណ្ឌបិយត្ថេរាបទាន ទី ១០

[ ៨០ ] អាស្រមដ៏ល្អរបស់ខ្ញុំ គេធ្វើលយចូលទៅក្នុងព្រៃរាំង សឹងដេរ ជាសដោយផ្កាំង កាលនោះខ្ញុំនៅក្នុងព្រៃ ។ ព្រះសម្ពុទ្ធមានព្រះភាគ ព្រះនាមបិយទស្សីជាព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់ប្រាថ្នាវិវេក បានស្តេចចូលទៅក្នុងព្រៃរាំង ។ ខ្ញុំបានចេញអំពីអាស្រមទៅក្នុងព្រៃ ក្នុងកាលនោះខ្ញុំកាលនឹងស្វែងរកនូវមើមឈើនិងផ្លែឈើ បានត្រាច់ទៅក្នុងព្រៃ ។ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ព្រះនាមបិយទស្សីមានយសធំ ព្រះអង្គគង់ចូលនិរោធសមាបត្តិដ៏រុងរឿងក្នុងព្រៃធំនោះ ។ ខ្ញុំបានតម្កល់ទុកនូវឈើ ៤ កំណាត់ពីខាងលើនៃព្រះសម្ពុទ្ធ ហើយធ្វើមណ្ឌបយ៉ាងល្អ ប្រក់ដោយផ្ការាំងទាំងឡាយ ។ ខ្ញុំបានទ្រទ្រង់នូវមណ្ឌបដែលប្រក់ដោយផ្ការាំងអស់ ៧ ថ្ងៃ ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងមណ្ឌបនោះ ទាំងបានថ្វាយបង្គំនូវព្រះពុទ្ធដ៏ប្រសើរ ។ សម័យនោះព្រះមានព្រះភាគជាបុរសដ៏ឧត្តម បានចេញអំពីសមាធិ ហើយគង់សម្លឹងមើលទិអំពីចម្ងាយប្រមាណមួយជួរនឹម ។ សាវកឈ្មោះវរុណៈ របស់ព្រះសាស្តា ព្រះនាមបិយទស្សី បានចូលទៅគាល់ព្រះលោកនាយក ជាមួយនឹងព្រះអរហន្តមួយសែនអង្គ ជាអ្នកស្ទាត់ជំនាញ ។ ឯព្រះជិនស្រីមានព្រះភាគព្រះនាមបិយទស្សី ជាធំក្នុងលោក ប្រសើរជាងនរៈ គង់ក្នុងកណ្តាលភិក្ខុសង្ឃហើយធ្វើនូវការញញឹមឲ្យប្រាកដ ។ ឧបដ្ឋាកឈ្មោះអនុរុទ្ធៈរបស់ព្រះសាស្តា ព្រះនាមបិយទស្សី ធ្វើចីវរឆៀងស្មាម្ខាង ហើយទូលសួរព្រះមហាមុនីថា បពិត្រព្រះមានព្រះភាគ សភាវៈដូចម្តេចហ្ន៎ ជាហេតុនៃព្រះសាស្តា ទ្រង់ធ្វើនូវការញញឹម ប្រហែលជាមានហេតុ បានជាព្រះសាស្តាទ្រង់ធ្វើនូវការញញឹម ។

មាណពណាទ្រទ្រង់នូវមណ្ឌប ដែលប្រក់ហើយដោយផ្កាពំង ដល់តថាគតអស់ ៧ ថ្ងៃ តថាគតវព្រកឃើញកុសលកម្មរបស់មាណព ទើបធ្វើនូវការញញឹមឲ្យប្រាកដ ។ បុណ្យណាឲ្យផលក្នុងទេវលោក ឬក្នុងមនុស្សលោក ឬឱកាសណាមិនសមល្មម តថាគតមិនឃើញនូវបុណ្យ ឬឱកាសនោះ ដែលមិនមានឱកាសឲ្យផលនោះឡើយ ។ កាលបុគ្គលនោះប្រកបដោយបុញ្ញកម្ម ហើយនៅក្នុងទេវលោក បរិស័ទទាំងប៉ុន្មានរបស់បុគ្គលនោះ នឹងដេរដាស ដូចជាផ្កាពំង ។ បុគ្គលប្រកបដោយបុញ្ញកម្មនោះ នឹងត្រេកត្រអាលដោយពួករបាំ ពួកចម្រៀង ពួកដេញដំប្រគំដ៏ជាទិព្វ ក្នុងទេវលោក សព្វៗកាល ។ បរិស័ទទាំងប៉ុន្មានរបស់បុគ្គលនោះ នឹងមានក្លិនក្រអូប ទាំងមានភ្លៀងជាវិការៈនៃផ្កាពំងនឹងធ្លាក់ចុះក្នុងខណៈនោះឯង ។ លុះបុគ្គលនេះ ច្យុតអំពីទេវលោកនោះមកកើតជាមនុស្ស នឹងមកកាន់ត្រកូលមនុស្ស មណ្ឌបប្រក់ដោយផ្កាពំងក្នុងមនុស្សលោកនេះ នឹងទ្រទ្រង់ ( នូវបុគ្គលនេះ ) សព្វៗកាល ។ របាំក្តី ចម្រៀងក្តី គ្រឿងដេញដំប្រគំក្តី នឹងចោមរោមនូវបុគ្គលនេះ អស់កាលជានិច្ចក្នុងមនុស្សលោកនេះ នេះជាផលនៃពុទ្ធបូជា ។ មួយទៀត កាលព្រះអាទិត្យរះឡើង ភ្លៀងជាវិការៈនៃផ្កាពំងនឹងធ្លាក់ចុះមក ឯភ្លៀងជាវិការៈនៃផ្កាពំងដ៏ប្រកបដោយបុញ្ញកម្ម នឹងធ្លាក់ចុះមកសព្វៗកាល ។ ក្នុងកប្បទី ១.៨០០ ព្រះសាស្តាព្រះនាមគោតមទ្រង់កើតក្នុងត្រកូលឱក្កាករាជ នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្តនេះនឹង បានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលនូវមត៌កក្នុងធម៌របស់ព្រះគោតមនោះ កំណត់ដឹងអាសវៈទាំងពួង ជា

អ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ កាលកុលបុត្តនោះត្រាស់ដឹងនូវធម៌ នឹងមានមណ្ឌប ប្រក់ដោយផ្កាពាំង កាលគេកំពុងបូជាលើជើងថ្ករ នឹងមានមណ្ឌបប្រក់ ដោយផ្កាពាំងក្នុងទីនោះ ។ លុះព្រះមហាមុនីព្រះនាមបិយទស្សី ទ្រង់ប្រកាសនូវវិបាករួចហើយ ទើបសម្តែងនូវព្រះធម៌ដល់បរិស័ទ ទ្រង់ញុំាងបរិស័ទឲ្យឆ្អែតដោយភ្លៀង គឺព្រះធម៌ ។

ខ្ញុំបានសោយរាជ្យជាស្តេចទេវតាក្នុងទេវលោកអស់ ៣០ កប្ប បានជាស្តេចចក្កពត្តិអស់ ៦៧ ដង ។ លុះខ្ញុំច្យុតចាកទេវលោកមកកើតក្នុងមនុស្សលោកនេះ ក៏បាននូវសេចក្តីសុខដ៏ធំទូលាយ មានទាំងមណ្ឌបដែលប្រក់ទៅដោយផ្កាពាំង នេះឯងជាផលនៃមណ្ឌប ។ នេះរាងកាយជាទីបំផុត ភពជាទីបំផុតរបស់ខ្ញុំកំពុងប្រព្រឹត្តទៅ មណ្ឌបប្រក់ដោយផ្កាពាំងតែងមានសព្វៗកាលក្នុងមនុស្សលោកនេះ ។ ខ្ញុំបានញុំាងព្រះមហាមុនី ព្រះនាមគោតម ព្រះអង្គប្រសើរក្នុងពួកសក្យៈ ឲ្យត្រេកអរហើយ បានដល់នូវអចលដ្ឋានគឺព្រះនិព្វាន ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់អស់ហើយ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំធ្វើឲ្យជាក់ច្បាស់បានហើយ ទាំង

សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសាលមណ្ឌបិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សាលមណ្ឌបិយត្ថេរាបទាន ។**

**ឧទ្ទាន**

បង្សុកូលសញ្ញកត្ថេរាបទាន ១ ពុទ្ធសញ្ញកត្ថេរាបទាន ១ ភិសទាយកត្ថេរាបទាន ១ ញាណត្ថវិកត្ថេរាបទាន ១ ចន្ទនមាលិយត្ថេរាបទាន ១ ធាតុបូជកត្ថេរាបទាន ១ បុឡិនុប្បាទកត្ថេរាបទាន ១ តរណិយត្ថេរាបទាន ១ ធម្មរុចិត្ថេរាបទាន ១ សាលមណ្ឌបិយត្ថេរាបទាន ១ មានគាថា ២១៩ ។

**ចប់ បង្សុកូលវគ្គ ទី ៤៩ ។**

# អដ្ឋកថា

## សាលមណ្ឌបិយត្ថេរាបទាន

[ ៨០ ] អបទានទី ១០ មានអត្ថដឹងបានងាយហើយ ។

អដ្ឋកថាសាលមណ្ឌបិយត្ថេរាបទាន ចប់

បង្សុកូលវគ្គទី ៤៩ ចប់

# កឹំកណិបុប្ផវគ្គ ទី ៥០

## តីណិកឹំកណិបុប្ផិយត្ថេរាបទានទី ១

[ ៨១ ] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់មិនមានធូលី ជានាយកក្នុងលោក ព្រះអង្គគង់នៅនាចន្លោះភ្នំ ទ្រង់រុងរឿងដូចជាផ្កាកណិការ ។ ខ្ញុំបានលើកយកនូវផ្កាកណ្តឹង ៣ ទង ថ្វាយព្រះសម្ពុទ្ធ លុះបូជាព្រះសម្មាសម្ពុទ្ធហើយ ខ្ញុំមានមុខបែរត្ឆោះ ដើរទៅកាន់ទិសខាងត្បូង ។ ដោយអំពើដែលខ្ញុំបានធ្វើហើយដោយល្អនោះផង ដោយចេតនាដែលខ្ញុំ បានតម្កល់ទុកនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិកឹំកណិបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តីណិកឹំកណិបុប្ផិយត្ថេរាបទាន ។

# បង្សុកូលបូជកត្ថេរាបទានទី ២

[ ៨២ ] មានភ្នំមួយឈ្មោះឧទព្វលៈ នៅជិតភ្នំហិមពាន្ត ក្នុងទីនោះ ខ្ញុំបានឃើញសំពត់បំសុកូលដែលគេពាក់លើចុងឈើ ។ ក្នុងកាលនោះ ខ្ញុំមានចិត្តត្រេកអររីករាយ បានបេះផ្កាកណ្ដឹង ៣ ទង ហើយ ថ្វាយចំពោះសំពត់បំសុកូលនោះ ។ ដោយអំពើដែលខ្ញុំបានធ្វើហើយដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំធ្វើនូវអំពើល្អក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ ព្រោះបានបូជាទង់ជ័យព្រះអរហន្ត ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបំសុកូលបូជកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បង្សុកូលបូជកត្ថេរាបទាន ។**

# កោរណ្ឌបុប្ផិយត្ថេរាបទានទី ៣

[ ៨៣ ] ក្នុងកាលមុន ខ្ញុំបានកើតជាអ្នកធ្វើការងារក្នុងព្រៃ ចិញ្ចឹមជីវិតដោយការសម្លាប់សត្វ តាមលំអាននៃជីតា កុសលរបស់ខ្ញុំមិនមាន ។ ព្រះចក្ខុមសម្ពុទ្ធ ជាព្រះលោកនាយកព្រះនាមតិស្សៈ ទ្រង់មានព្រះអធ្យាស្រ័យសង្គ្រោះដល់ខ្ញុំ បានសម្ដែងនូវស្នាមព្រះបាទា ៣ អន្លើ ។ ខ្ញុំបានឃើញនូវស្នាមព្រះបាទានៃព្រះសាស្តា ព្រះនាមតិស្សៈដែលទ្រង់ជាន់ទុក មានចិត្តត្រេកអររីករាយ បានញុំាងចិត្តឲ្យជ្រះថ្លាក្នុងស្នាមព្រះបាទា ។ ខ្ញុំបានឃើញនូវដើមកន្ទុយដំរីដុះលើផែនដីមានផ្ការីក ហើយកាច់យកផ្កាកន្ទុយដំរីនោះទាំងចង្កោមទៅបូជាស្នាមព្រះបាទាដ៏ប្រសើរ ។ ដោយអំពើដែលខ្ញុំបានធ្វើហើយដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ខ្ញុំចូលទៅកាន់កំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ក៏មានពណ៌សម្បុរដូចផ្កាកន្ទុយដំរីមានពន្លឺស្មើល្អ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាស្នាមព្រះបាទ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោរណ្ឌបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កោរណ្ឌបុប្ផិយត្ថេរាបទាន ។**

# កឹសុកបុប្ផិយត្ថេរាបទានទី ៤

[ ៨៤ ] ខ្ញុំបានឃើញផ្កាចារឹកហើយ ( បេះផ្កានោះ ) រួចផ្គងអញ្ជលីប្រណម្យឡើង នឹកដល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ហើយបានបូជា បោះផ្កានោះទៅឰដ៏អាកាស ។ ដោយអំពើដែលខ្ញុំបានធ្វើដោយល្អនោះផង ដោយចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សទៅ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកឹសុកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កឹសុកបុប្ផិយត្ថេរាបទាន ។**

# ឧបឌ្ឍទុស្សទាយកត្ថេរាបទានទី ៩

[ ៨៥ ] ក្នុងកាលនោះ សាវកនាមសុជាតៈរបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ លោកកំពុងស្វែងរកសំពត់បំសុកូលលើគំនរសំរាមក្បែរច្រក ។ ខ្ញុំជាអ្នកស៊ីឈ្នួលនៃបុគ្គលដទៃ ក្នុងនគរហង្សវតី បានប្រគេនសំពត់ពាក់កណ្ដាល ហើយថ្វាយបង្គំដោយសិរ្ស ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយចេតនាដែលខ្ញុំបានតម្កល់ទុកហើយនោះផង ខ្ញុំលះរាងកាយជារបស់មនុស្សទៅ ក៏បានទៅកើតឯឋានតាវត្តិង្ស ។ ខ្ញុំបានកើតជាព្រះឥន្ទសោយរាជ្យជាស្ដេចនៃទេវតាអស់ ៣៣ ដង ខ្ញុំបានកើតជាស្ដេចចក្កពត្តិអស់ ៧៧ ដង ។ ខ្ញុំបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំឥតមានភ័យអំពីទីណា តែងត្រេកអរព្រោះកិរិយាឲ្យនូវសំពត់ពាក់កណ្ដាល ។ ក្នុងថ្ងៃនេះ បើខ្ញុំប្រាថ្នាយកសំពត់ដែលកើតអំពីសម្បកឈើ មកប្រក់ព្រៃ និងភ្នំក៏សឹងបាននេះជាផលនៃការថ្វាយនូវសំពត់ពាក់កណ្ដាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃសំពត់ ពាក់កណ្ដាល ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបឌ្ឍទុស្សទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំង

នេះ ដោយប្រការដូច្នេះ ។

ចប់ ឧបឌ្ឍទុស្សទាយកត្ថេរាបទាន ។

# ឃតមណ្ឌទាយកត្ថេរាបទានទី ៦

[ ៨៦ ] ខ្ញុំបានឃើញព្រះមានព្រះភាគ ព្រះអង្គមានព្រះតម្រិះល្អ ជាធំក្នុងលោក ប្រសើរជាងនរៈ ស្តេចចូលទៅគង់ក្នុងព្រៃធំ ត្រូវអាពាធកើតអំពីខ្យល់បៀតបៀនហើយ ខ្ញុំក៏ញុំាងចិត្តឲ្យជ្រះថ្លា បាននាំយកទឹកដោះថ្លា ចូលទៅថ្វាយព្រះអង្គ ។ ព្រោះតែកុសលដែលខ្ញុំបានធ្វើហើយ បានសន្សំហើយ ស្ទឹងគង្គាភាគីរសីនេះ នឹងមហាសមុទ្ទទាំង ៤ ប្រែទៅជាទឹកដោះថ្លាសម្រាប់ខ្ញុំ ។ ផែនដីនេះជាវត្ថុដ៏ធំ មានប្រមាណមិនបាន រាប់មិនបាន ផែនដីនោះទៅជាស្ករក្រាម មានរសផ្អែមឆ្ងាញ់ ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ដើមឈើទាំងឡាយនេះ ដុះលើផែនដី ឋិតនៅក្នុងទិសទាំង ៤ ដើមឈើទាំងនោះកើតទៅជាដើមកល្បព្រឹក្ស ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ។ ខ្ញុំជាធំជាងទេវតា បានសោយរាជ្យជាស្តេចនៃទេវតាអស់ ៥០ ដង ។ ខ្ញុំបានជាស្តេចចក្កពត្តិអស់ ៥១ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកដោះថ្លា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបាន

កាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយតមណ្ឌទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ យតមណ្ឌទាយកត្ថេរាបទាន ។**

## ឧទកទាយកត្ថេរាបទានទី ៧

[ ៨៧ ] ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បានថ្វាយទឹកមួយក្អមចំពោះភិក្ខុសង្ឃដ៏ប្រសើរនៃព្រះបទុមុត្តរសម្ពុទ្ធ ។ ( ដោយកុសលកម្មនេះ ) បើខ្ញុំចង់បានទឹកសម្រាប់ផឹកលើកំពូលភ្នំ លើចុងឈើ ក្នុងអាកាស ឬក្នុងផែនដីក្នុងកាលណា ទឹកក៏កើតឡើងយ៉ាងឆាប់ដល់ខ្ញុំ ក្នុងកាលនោះ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧទកទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំ

បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧទកទាយកត្ថេរាបទាន ។**

# បុឡិនថូបិយត្ថេរាបទានទី ៨

[ ៨៨ ] ក្នុងទីជិតនៃព្រៃហិមពាន្ត មានភ្នំមួយឈ្មោះយមកៈ អាស្រមខ្ញុំបានធ្វើហើយ បណ្ណសាលាខ្ញុំក៏បានសាងល្អហើយ ក្បែរជើងភ្នំនោះ ។ ខ្ញុំជាជដិលឈ្មោះនារទៈ ជាអ្នកមានព្យាយាមខ្ពង់ខ្ពស់ សិស្ស ១៤.០០០ តែងបម្រើខ្ញុំសព្វវេលា ។ ខ្ញុំជាអ្នកចូលចិត្តសេចក្តីស្ងប់ស្ងាត់ មានចិត្តស្ងប់រម្ងាប់ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា មហាជនតែងបូជាអាត្មាអញ អញមិនបានបូជាអ្នកណាមួយ ។ ជនអ្នកឲ្យឱវាទដល់អាត្មាអញមិនមាន ជនអ្នកស្តីថាណាម្នាក់ក៏មិនមាន អាត្មាអញមិនមានអាចារ្យនិងឧបជ្ឈាយ៍ អាត្មាអញសម្រេចការនៅក្នុងព្រៃ ។ អាត្មាអញចូលទៅបម្រើបុគ្គលណាដែលមានចិត្តធ្ងន់ បុគ្គលនោះជាអាចារ្យរបស់អញមិនមាន ការនៅក្នុងព្រៃឈ្មោះថា ឥតប្រយោជន៍ ។ អាត្មាអញគប្បីស្វែងរកនូវគ្រូដែលគួរបូជា និងគ្រូដែលគួរសរសើរ អាត្មាអញនឹងនៅជាមួយបុគ្គលគួរជាពឹងអាស្រ័យបាននោះ ទើបបុគ្គលណាមួយ នឹង

មិនតិះដៀលអាត្មាអញឡើយ ។ ស្ទឹងមានច្រាំងរាក់ មានកំពង់ល្អ ជាទីរីក-
រាយនៃចិត្ត ដេរដាសដោយផ្លូកខ្សាច់សសុទ្ធ តាំងនៅជិតអាស្រមរបស់ខ្ញុំ ។
កាលនោះ ខ្ញុំបានដើរចូលទៅរកស្ទឹងឈ្មោះ អមរិកៈ ហើយប្រមូលយកផ្លូក
ខ្សាច់មកធ្វើជាបុឡិនចេតិយ ( ចេតិយខ្សាច់ ) ។ ព្រះសម្ពុទ្ធទាំងឡាយអង្គ
ណា ទ្រង់ធ្វើនូវទីបំផុតនៃភព ជាអ្នកប្រាជ្ញ ព្រះស្តូបនៃព្រះសម្ពុទ្ធទាំងឡាយ
នោះ ក៏ប្រាកដដូច្នោះ ខ្ញុំធ្វើនូវព្រះស្តូប នោះឲ្យជានិមិត្ត ។ លុះខ្ញុំធ្វើរួចហើយ
ខ្ញុំបានសាងនូវព្រះស្តូបជាវិការៈនៃមាសលើផ្លូកខ្សាច់ ខ្ញុំបានបូជានូវផ្កាកណ្តឹង
មាសអស់ ៣ ពាន់ ។ ខ្ញុំមានបីតិកើតហើយ ធ្វើនូវអញ្ជលីនមស្ការរាល់ល្ងាច
ព្រឹក ថ្វាយបង្គំចេតិយផ្លូកខ្សាច់ ហាក់ដូចជាថ្វាយបង្គំនូវព្រះសម្ពុទ្ធក្នុងទីចំពោះ
ព្រះភក្ត្រ ។ កាលណាកិលេសទាំងឡាយកើតឡើង វិតក្កៈទាំងឡាយដែល
អាស្រ័យនូវផ្ទះ គឺកាមគុណ ( កើតឡើងក្នុងកាលនោះ ) ខ្ញុំរឭកដល់ព្រះ
ស្តូបដែលខ្ញុំធ្វើល្អហើយ ខ្ញុំពិចារណាឃើញច្បាស់ក្នុងខណៈនោះឯង ។ ខ្ញុំបាន
ចូលទៅរក ព្រះស្តូបនៃព្រះលោកនាយក ទ្រង់ដឹកនាំសត្វដូចពួកឈ្មួញ ហើយ
ទូន្មានខ្លួនថា នៃអ្នកនិទ្ទុក្ខ បើអ្នកហានបិទបាំងកិលេស ការដែលអ្នកបិទបាំង
កិលេសនេះ ជាអំពើមិនគួរដល់អ្នកទេ ។ កាលណាខ្ញុំរំពឹងនឹកដល់ព្រះស្តូប
ឈ្មោះថាខ្ញុំមានសេចក្តីគោរពក្នុងកាលនោះ ខ្ញុំបានបន្ទោបង់នូវវិតក្កៈអាក្រក់
ដូចដំរីដ៏ប្រសើរដែលត្រូវគេចាក់ដោយកង្វេរ ។ មច្ចុរាជតែងញាំញីខ្ញុំកាលនៅ
យ៉ាងនេះ លុះខ្ញុំធ្វើមរណកាលក្នុងទីនោះ បានទៅកើតឯព្រហ្មលោក ។ ខ្ញុំ
នៅក្នុងព្រហ្មលោកដរាបដល់អស់អាយុ ហើយថយមកកើតក្នុងឋានត្រៃត្រិង្ស

បានជាធំជាងទេវតា សោយរាជ្យក្នុងទេវលោកអស់ ៨០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិអស់ ៣០០ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំបានសោយនូវផលនៃផ្កាកណ្ដឹងមាសទាំងនោះ ជន ២ ម៉ឺន ២ ពាន់ តែងចោមរោមខ្ញុំក្នុងភព ។ ព្រោះខ្ញុំបានសាងព្រះស្តូប លម្អងធូលីមិនប្រឡាក់កាយនៃខ្ញុំ ញើសទាំងឡាយក្នុងខ្លួនមិនហូរចេញ ខ្ញុំមានពន្លឺល្អ ។ ឱ! ព្រះស្តូបខ្ញុំបានធ្វើល្អហើយ ស្ទឹងឈ្មោះអមរិកៈ ខ្ញុំបានឃើញល្អហើយ ព្រោះខ្ញុំបានធ្វើព្រះស្តូបខ្សាច់ ទើបបានសម្រេចនូវព្រះនិព្វានជាធម្មជាតមិនកម្រើក ។ សត្វមានសេចក្តីប្រាថ្នាធ្វើកុសល ជាអ្នកប្រកាន់នូវធម៌មានខ្លឹម មិនចាំបាច់មានទីជាស្រែ ឬទីមិនជាស្រែឡើយ ស្រេចហើយត្រឹមតែសេចក្តីប្រតិបត្តិជាគុណមានខ្លឹម ។ បុរសមានកម្លាំងអាចឆ្លងសមុទ្រ ស្ទុះទៅក្នុងមហាសមុទ្របានព្រោះកាន់កំណាត់ឈើតូច ។ ខ្ញុំឆ្លងសមុទ្រធំ ព្រោះអាស្រ័យកំណាត់ឈើនេះនរជនគប្បីឆ្លងសមុទ្រដោយសេចក្តីព្យាយាមប្រឹងប្រែងមានឧបមាយ៉ាងណា ។ អំពើណាទោះតិចតួចក្តី ថោកទាបក្តី ដែលខ្ញុំធ្វើហើយ ខ្ញុំបានឆ្លងសង្សារព្រោះអាស្រ័យអំពើនោះ ក៏មានឧបមេយ្យយ៉ាងនោះឯង ។

លុះដល់បច្ឆិមភព ខ្ញុំត្រូវកុសលមូលដាស់តឿន បានកើតក្នុងត្រកូលមហាសាល ដែលស្តុកស្តម្ភល្អក្នុងក្រុងសាវត្ថី ។ មាតាបិតារបស់ខ្ញុំមានសទ្ធា បានយកព្រះពុទ្ធជាទីពឹង ជនទាំងពីរនាក់នោះក៏អនុវត្តតាមពុទ្ធសាសនា ។ ពួកជនបានកាន់យកក្រមរពោធិ ទៅធ្វើព្រះស្តូបជាវិការៈនៃមាស តែងនមស្ការចំពោះព្រះភក្ត្រព្រះសក្យបុត្តរាល់ល្ងាចព្រឹក ក្នុងថ្ងៃឧបោសថ ពួកជននាំយក

ព្រះស្តូបមាស ហើយពោលសរសើរគុណព្រះពុទ្ធ ញុំាងកាលមានយាម ៣ ឲ្យកន្លងទៅ ។ លុះខ្ញុំបានឃើញព្រះស្តូបហើយ ក៏រឭកឃើញនូវចេតិយផ្ទុក-ខ្សាច់ អង្គុយលើអាសនៈមួយ ក៏បានដល់អរហត្ត ។

## ចប់ ភាណវារៈទី ២២

កាលខ្ញុំស្វែងរកអ្នកប្រាជ្ញ បានជួបព្រះធម្មសេនាបតីនោះ ក៏ចេញចាកផ្ទះ ទៅបួសក្នុងសម្នាក់លោក ។ ខ្ញុំក៏បានសម្រេចអរហត្តក្នុងអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក ព្រះពុទ្ធមានចក្ខុទ្រង់ជ្រាបនូវគុណ បានឲ្យឧបសម្បទាដល់ខ្ញុំ ។ កាលខ្ញុំនៅជាទារក បានសម្រេចកិច្ចហើយ សោឡសកិច្ចក្នុងសាសនានៃព្រះសក្យបុត្ត ខ្ញុំធ្វើរួចហើយក្នុងថ្ងៃនេះ ។ បពិត្រព្រះមហាវីរៈ ខ្ញុំកន្លងពៀរនិងភ័យទាំងពួងហើយ កន្លងកិលេសជាគ្រឿងចំពាក់ទាំងពួងហើយ ជាអ្នកស្វែងរកគុណជាសាវករបស់ព្រះអង្គ នេះជាផលនៃព្រះស្តូបមាស ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិ-បត្តិហើយ ។

*បានឮថា ព្រះបុឡិនថូបិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។*

## *ចប់ បុឡិនថូបិយត្ថេរាបទាន ។*

# ឧឡុម្ពិកទាយកត្ថេរាបទានទី ៩

*[ ៨៩ ] ក្នុងទីមិនឆ្ងាយអំពីព្រៃហិមពាន្ត មានភ្នំមួយឈ្មោះហារិកៈ កាលនោះ ព្រះសយម្ភូសម្ពុទ្ធព្រះនាមនារទៈ គង់នៅទៀបគល់ឈើ ជិតភ្នំនោះ ។ ខ្ញុំបានធ្វើផ្ទះបបុស បិទបាំងដោយស្មៅ ជម្រះទីចង្ក្រម ថ្វាយដល់ព្រះសយម្ភូសម្ពុទ្ធ ។ ដោយអំពើដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ប្រាសាទរបស់ខ្ញុំ ដែលកុសលកម្មធ្វើល្អហើយក្នុងឋានតាវត្តិង្សនោះ គឺកុសលកម្មនិម្មិតធ្វើជាខ្ទមបបុសមានកម្ពស់ ៦០ យោជន៍ ទទឹង ៣០ យោជន៍ ។ ខ្ញុំរីករាយក្នុងទេវលោកអស់ ១៤ កប្ប បានសោយរាជ្យក្នុងទេវលោកអស់ ៧១ ដង ។ ខ្ញុំបានជាស្តេចចក្កពត្តិអស់ ៣៤ ដង បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ។ ខ្ញុំបានឡើងកាន់ធម្មប្រាសាទឧបមាដូចផ្ទះស្វាត់ដ៏ប្រសើរ ហើយសម្រេចសម្រាន្តតាមសមគួរក្នុងសាសនានៃព្រះសក្យបុត្ត ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើ*

កុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃខួមបបុស ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនឡកុដិកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ នឡកុដិកទាយកត្ថេរាបទាន ។**

## បិយាលផលទាយកត្ថេរាបទាន ទី ១០

[ ៩០ ] ក្នុងភពមុនខ្ញុំកើតជាព្រានម្រឹគ កាលនោះខ្ញុំបានត្រាច់ទៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធ ព្រះអង្គមិនមានធូលីគឺកិលេស ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែទ្រយឹងមកថ្វាយព្រះពុទ្ធដ៏ប្រសើរ ជាបុញ្ញក្ខេត្ត ព្រះអង្គមានព្យាយាម ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែទ្រយឹង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ

ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិយាលផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បិយាលផលទាយកត្ថេរាបទាន ។**

## ឧទ្ទាន

កឹកណិបុប្ផិយត្ថេរាបទាន ១ បំសុកូលបូជកត្ថេរាបទាន ១ កោរណ្ឌបុប្ផិយត្ថេរាបទាន ១ កឹសុកបុប្ផិយត្ថេរាបទាន ១ ឧបឌ្ឍទុស្សទាយកត្ថេរាបទាន ១ ឃតមណ្ឌទាយកត្ថេរាបទាន ១ ឧទកទាយកត្ថេរាបទាន ១ បុឡិនថូបិយត្ថេរាបទាន ១ នឡកុដិកទាយត្ថេរាបទាន ១ ជាគម្រប់ ៩ បិយាលផលទាយកត្ថេរាបទាន ១ ឯគាថាមានចំនួន ១០១ និងលើសពីនោះ ៩ គាថាទៀត ។

## ចប់ កឹកណិបុប្ផវគ្គ ទី ៥០ ។

## មួយទៀត ឧទ្ទាននៃវគ្គ

មេត្តេយ្យវគ្គ ១ កុណ្ឌលិវគ្គ ១ សកឹសម្មជ្ជកវគ្គ ១ ឯកវិហារិវគ្គ ១ វិភេទកវគ្គ ១ ជគតិវគ្គ ១ សាលបុប្ផិយវគ្គ ១ ។ នឡមាលិវគ្គ ១ បំសុកូលវគ្គ ១ កឹកណិបុប្ផិវគ្គ ១ ឯគាថាមានចំនួន ១.៤៨២ គាថា ។

## ចប់ មេត្តេយ្យវគ្គទសកៈ ប្រមាណនៃវយ ទី ៥ ។

# អដ្ឋកថា

# កិង្កណិបុប្ផិយវគ្គ ទី ៥០

[ ៨១-៩០ ] *អដ្ឋកថាកិង្កណិបុប្ផិវគ្គទី ៥០ មានអត្ថងាយយល់ហើយ ។*

*អដ្ឋកថាកិង្កណិបុប្ផិយវគ្គទី ៥០ ចប់*

# កណិការវគ្គ ទី ៥១

## តីណិកណិការបុប្ផិយត្ថេរាបទាន ទី ១

[ ៩១ ] ព្រះសម្ពុទ្ធព្រះនាមសុមេធៈ មានព្រះលក្ខណៈ ៣២ ដ៏ប្រសើរ មានសេចក្តីប្រាថ្នាក្នុងការស្ងប់ស្ងាត់ ទ្រង់ត្រាស់ដឹងដោយប្រពៃ បានស្តេចចូលទៅក្នុងព្រៃហិមពាន្ត ។ ព្រះមហាមុនី ទ្រង់ជាចម្បង ជាបុរសខ្ពង់ខ្ពស់ ប្រកបដោយសេចក្តីករុណា ស្តេចចុះកាន់ព្រៃហិមពាន្ត ហើយទ្រង់គង់ផ្គត់ព្រះភ្នែន ។ កាលនោះ ខ្ញុំកើតជាពិជ្យាធរ ជាអ្នកត្រាច់ទៅក្នុងអាកាស កាន់ច្បូកដែលធ្វើល្អហើយ បានហោះទៅព្ធដ៏អាកាស ក្នុងកាលនោះ ។ ព្រះសម្ពុទ្ធព្រះអង្គភ្លឺរុងរឿងក្នុងព្រៃ ដូចភ្លើងលើកំពូលភ្នំ ឬដូចព្រះចន្ទពេញបូណ៌មី ពុំនោះសោត ដូចស្តេចឈើដែលមានផ្ការីកស្គុសស្គាយ ។ ខ្ញុំចេញអំពីព្រៃ បានឃើញរស្មីព្រះពុទ្ធដែលផ្សាយចេញ ដូចពណ៌ភ្លើងដែលឆេះបបុស ហើយក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា ។ ខ្ញុំកំពុងតែជ្រើសរើសផ្កា ក៏បានឃើញផ្កាកណិការ មានក្លិនក្រអូបដូចក្លិនទិព្វ ហើយបាននាំយកផ្កា ៣ ទង ទៅបូជាព្រះសម្ពុទ្ធដ៏ប្រសើរ ។ ដោយអានុភាពនៃព្រះពុទ្ធ ផ្កាទាំង ៣ ទងរបស់ខ្ញុំក្នុងកាលនោះ មានទងឡើងលើ មានត្របកចុះក្រោម ធ្វើជាម្លប់បាំងថ្វាយព្រះសាស្តា ។ ដោយអំពើដែលធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានដែលកុសលសាងសម្រាប់ខ្ញុំក្នុងទីនោះ មានកម្ពស់ ៦០ យោជន៍ ទទឹង ៣០ យោជន៍ ពួកទេវតាតែងស្គាល់ថា កណិការវិមាន ។ ប្រាសាទមានកម្ពស់មួយពាន់សន្ទុះព្រួញ មានជាន់ ៧ បរិបូណ៌ដោយទង់ជាវិការៈនៃកែវមណី មានពណ៌

ទៀត ផ្ទះមានកំពូលមួយសែនមានប្រាកដក្នុងវិមានរបស់ខ្ញុំ ។ បល្ល័ង្កជាវិការៈនៃមាសក៏មាន ជាវិការៈនៃកែវមណីក៏មាន ជាវិការៈនៃកែវទទឹមក៏មាន ជាវិការៈនៃកែវផលិកក៏មាន គួរតាមប្រាថ្នា គួរតាមបំណង ។ មួយទៀត ទីដេកមានតម្លៃច្រើនដែលញាត់ដោយគរ ធ្វើដោយរោមសត្វ វិចិត្រដោយរោមសត្វ មានរោមសត្វសីហៈនិងខ្លាធំជាដើម ធ្វើដោយរោមសត្វមានរោមប្រាងឡើងតែម្ខាង ជាកម្រាលសមគួរដល់ខ្នើយ ។ កាលណាខ្ញុំចេញអំពីលំនៅ ហើយត្រាច់ទៅកាន់ទេវចារិក ប្រាថ្នានឹងទៅ តែងមានពួកទេវតាចោមរោម ។ ខ្ញុំឋិតនៅខាងក្រោមផ្កា ផ្កាប្រក់ខាងលើខ្ញុំ ទីមួយរយយោជន៍ជុំវិញ សុទ្ធសឹងបិទបាំងដោយផ្កាកណិការ ។ តូរ្យតន្ត្រី ៦ ម៉ឺន មកបម្រើខ្ញុំរាល់ល្ងាចព្រឹក ជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ តែងចោមរោមខ្ញុំជានិច្ច ។ ខ្ញុំត្រេកអរដោយរបាំ ចម្រៀង គ្រឿងដេញដំ និងគ្រឿងប្រគំក្នុងវិមាននោះ ខ្ញុំមានសេចក្តីប្រាថ្នាក្នុងកាម តែងរីករាយក្នុងតម្រេកនៃល្បែង ។ ខ្ញុំបរិភោគក្តី ផឹកក្តីក្នុងទីនោះ តែងរីករាយក្នុងឋានត្រៃត្រិង្សក្នុងកាលនោះ ខ្ញុំប្រកបដោយពួកនារី រីករាយក្នុងវិមានដ៏ឧត្តម ។ ខ្ញុំសោយរាជ្យក្នុងឋានទេវលោកអស់ ៥០០ ដង បានជាស្តេចចក្កពត្តិអស់ ៣០០ ដង ។ សោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ខ្ញុំកាលអន្ទោលទៅក្នុងភពតូច ភពធំ តែងបាននូវភោគសម្បត្តិច្រើន ។ ខ្ញុំមិនមានសេចក្តីខ្វះខាតដោយភោគសម្បត្តិ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ។ ខ្ញុំមិនដែលស្គាល់គតិដទៃទេ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងកើតក្នុងត្រកូល ២ គឺត្រកូល

ក្សត្រនិងត្រកូលព្រាហ្មណ៍ ។ ខ្ញុំមិនកើតក្នុងត្រកូលទាប នេះជាផលនៃពុទ្ធ-បូជា ខ្ញុំតែងបាននូវយានទាំងអស់នេះ គឺយានដំរី យានសេះ ព្រះសាលៀង រថទ្រង់គ្រឿង នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវរបស់ទាំងអស់នេះ គឺ ខ្ញុំស្រី ខ្ញុំប្រុស នារីដែលមានគ្រឿងតាក់តែងសមរម្យ នេះជាផលនៃពុទ្ធបូជា ខ្ញុំតែងបាននូវសំពត់ទាំងអស់នេះ គឺសំពត់កោសេយ្យពស្ត្រ សំពត់កម្ពល សំពត់ខោមពស្ត្រ និងសំពត់កប្បាសិកពស្ត្រ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវវត្ថុទាំងអស់នេះគឺ សំពត់ថ្មី ផ្លែឈើថ្មី ភោជនមានរសដ៏ប្រសើរថ្មី នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងបាននូវពាក្យពីរោះទាំងអស់នេះថា សូមអ្នកពិសានូវភោជនទាំងនេះ សូមបរិភោគភោជនទាំងនេះ សូមសម្រាន្តលើដំណេកនេះ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំមានគេបូជាក្នុងទីទាំងពួង យស ( កេរ្តិ៍ឈ្មោះ ) របស់ខ្ញុំ ខ្ចរខ្ចាយទៅក្នុងទិសទាំងពួង ។ ខ្ញុំមានសក្តិធំសព្វកាល មានបរិស័ទមិនបែកបាក់សព្វកាល ខ្ញុំជាបុរសឧត្តមជាងពួកញាតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំមិនដែលស្គាល់ត្រជាក់និងក្តៅ ឯសេចក្តីក្តៅក្រហាយក៏មិនមាន ទាំងសេចក្តីទុក្ខព្រួយក្នុងចិត្តក៏មិនមានក្នុងហឫទ័យរបស់ខ្ញុំ ។ ខ្ញុំជាអ្នកមានសម្បុរដូចមាស តែងអន្ទោលទៅក្នុងកពតូចកពធំ ខ្ញុំមិនដែលស្គាល់ភាពពណ៌អាក្រក់ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន បានមកកើតក្នុងបុរីសាវត្ថី ក្នុងត្រកូលមហាសាល ជាត្រកូលស្តុកស្តម្ភមាំមួន ។ ខ្ញុំលះបង់កាមគុណទាំង ៥ ហើយចូលទៅកាន់ផ្នួស ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីកំណើតមក បានដល់អរហត្ត ។ ព្រះសម្ពុទ្ធទ្រង់

មានចក្ខុ ជ្រាបច្បាស់នូវគុណរបស់ខ្ញុំ បានឲ្យឧបសម្បទាដល់ខ្ញុំ ខ្ញុំជាមនុស្ស កំលោះ គួរដល់ការបូជា នេះជាផលនៃពុទ្ធបូជា ។ ចក្ខុរបស់ខ្ញុំដ៏បរិសុទ្ធ ដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវត្រើយនៃអភិញ្ញា នេះជាផល នៃពុទ្ធបូជា ។ បដិសម្ភិទា ខ្ញុំបានសម្រេចដោយលំដាប់ ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងឥទ្ធិបាទ បានដល់ត្រើយក្នុងព្រះសទ្ធម្ម នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្ប ទី ៣ ម៉ឺន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះសម្ពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុត បំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះ បានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើ ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិកណិការបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តីណិកណិការបុប្ផិយត្ថេរាបទាន ។**

# ឯកបត្តទាយកត្ថេរាបទានទី ២

[ ៩២ ] ខ្ញុំកើតជាស្មូនឆ្នាំង ក្នុងនគរហង្សវតី ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី គឺកិលេស ទ្រង់ឆ្លងជំនន់ គឺកិលេស មិនមានអាសវៈ ។ ខ្ញុំបានថ្វាយបាត្រដី ដែលខ្ញុំធ្វើល្អហើយដល់ព្រះពុទ្ធដ៏ប្រសើរ ខ្ញុំថ្វាយបាត្រដល់ព្រះមានបុណ្យ មានព្រះហឫទ័យទៀងត្រង់ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំកាលកើតក្នុងភពតែងបានជាសមាសផង ជាសមាសក្រឡែប្រាក់ផង បានជាវិការៈនៃកែវមណីផង ។ ខ្ញុំតែងបរិភោគដោយភាជន៍ នេះជាផលនៃបុញ្ញកម្ម ខ្ញុំជាអ្នកប្រសើរដោយយសបរិវារជាងជនទាំងឡាយ ។ ពូជសូម្បីបន្តិចបន្តួចដែលគេសាបព្រោះក្នុងស្រែដ៏ល្អ កាលបើមេឃបង្អុរធារទឹកដោយប្រពៃ ផ្លែស្រូវរមែងញុំាងអ្នកស្រែឲ្យត្រេកអរ យ៉ាងណាមិញ ។ បត្តទាននេះ ដែលខ្ញុំសាបព្រោះក្នុងស្រែ គឺព្រះពុទ្ធ ធារទឹកគឺបីតិបង្អុរចុះមក ផលរមែងធ្វើឲ្យខ្ញុំត្រេកអរ ក៏យ៉ាងនោះដែរ ។ ស្រែទាំងប៉ុន្មានណា គឺព្រះសង្ឃក្តី គណៈក្តី ស្រែទាំងនោះស្មើដោយស្រែគឺព្រះពុទ្ធមិនមានឡើយ ព្រោះស្រែគឺព្រះពុទ្ធ អាចឲ្យសេចក្តីសុខដល់សត្វទាំងពួង ។ បពិត្របុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ខ្ញុំបានថ្វាយបាត្រមួយហើយ បានសម្រេចព្រះនិព្វានជាគុណជាតមិនកម្រើក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបាត្រក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបត្តទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់

ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបត្តទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកបត្តទាយកត្ថេរាបទាន ។

## កាសុមារិកផលទាយកត្ថេរាបទាន ទី ៣

[ ៩៣ ] ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី ជាច្បងក្នុងលោក ប្រសើរជាងនរៈ រុងរឿងដូចផ្កាកណិការ ទ្រង់គង់នៅក្នុងចន្លោះភ្នំ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយធ្វើនូវអញ្ជលីលើក្បាល បានយកផ្លែស្វាទុំ ទៅថ្វាយព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែស្វាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង

អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកាសុមារិកផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កាសុមារិកផលទាយកត្ថេរាបទាន ។**

# អវដផលិយត្ថេរាបទានទី ៤

[ ៩៤ ] ព្រះមានព្រះភាគទ្រង់មានស្មើច្រើន ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្មះមារ ក្រោកចាកទីស្ងប់ស្ងាត់ ស្តេចចេញទៅដើម្បីគោចរ ។ ខ្ញុំមានដៃកាន់ផ្លែឈើ ឃើញព្រះនរាសភៈ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយអវដផល ( ផ្លែឈើ ) ដល់ព្រះអង្គ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអវដផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អវដផលិយត្ថេរាបទាន ។

# ចារផលិយត្ថេរាបទានទី ៥

[ ៩៥ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជា កំពុងស្តេចពុទ្ធដំណើរទៅតាមច្រកហើយ បានប្រគេនចារផល ( ផ្លែឈើ ) ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចារផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចារផលិយត្ថេរាបទាន ។

# មាតុលុង្គផលទាយកត្ថេរាបទាន ទី ៦

[ ៩៦ ] ខ្ញុំបានឃើញនូវព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទពេញបូណ៌មី ឬក៏ដូចឈើប្រចាំទ្វីបដ៏រុងរឿង ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែក្រូចថ្លុងទៅថ្វាយព្រះសាស្តា ជាទក្ខិណេយ្យបុគ្គល ទ្រង់មានព្យាយាម ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមាតុលុង្គផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ មាតុលុង្គផលទាយកត្ថេរាបទាន ។**

# អជ្ជេលផលទាយកត្ថេរាបទានទី ៧

[ ៩៧ ] កាលនោះ ព្រះបច្ចេកសម្ពុទ្ធព្រះនាមអជិនៈ ទ្រង់បរិបូណ៌ដោយចរណៈ ឈ្លាសវៃក្នុងសមាធិ ជាអ្នកប្រាជ្ញ គង់នៅក្នុងព្រៃហិមពាន្ត ។ ខ្ញុំបានយកផ្លែអញ្ចលិព្រឹក្សស្រស់ៗប្រមាណប៉ុនក្អម ទាំងយកឆត្រស្លឹក ប្រគេនដល់ព្រះសាស្តា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអជ្ជេលផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ អជ្ជេលផលទាយកត្ថេរាបទាន ។**

# អមោរផលិយត្ថេរាបទានទី ៨

[ ៩៨ ] ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលនូវគ្រឿងបូជាដែលទ្រង់កំពុងតែស្តេចទៅតាមច្រក ហើយប្រគេនផ្លែអមោរ-ព្រឹក្ស ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្នឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអមោរផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អមោរផលិយត្ថេរាបទាន ។**

## តាលផលិយត្ថេរាបទានទី ៩

[ ៩៩ ] ព្រះមានព្រះភាគទ្រង់ព្រះនាមសតរង្សី ត្រាស់ដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ក្រោកចេញចាកទីស្ងប់ស្ងាត់ ហើយស្តេចទៅដើម្បីគោចរ ។ ខ្ញុំមានដៃកាន់ផ្លែឈើ ឃើញព្រះនរាសភៈ ក៏ចូលទៅជិត ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែត្នោត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតាលផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ តាលផលិយត្ថេរាបទាន ។**

## នាលិកេរផលទាយកត្ថេរាបទានទី ១០

[ ១០០ ] កាលនោះខ្ញុំជាព្រានមឹក្ក ក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលី កំពុងស្តេចទៅឰដ៏អាកាស ។ ខ្ញុំបានយកផ្លែដូងទៅថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ព្រះពុទ្ធទ្រង់មានយសធំ ឋិតនៅឰដ៏អាកាស ទ្រង់ទទួល ( ផ្លែដូងនោះ ) ។ ខ្ញុំមានការកើតបីតិ ជាទីនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះថ្វាយនូវផ្លែដូងដល់ព្រះពុទ្ធដោយចិត្តជ្រះថ្លា ។ កាលនោះ ខ្ញុំបាននូវបីតិដ៏ធំទូលាយផង នូវសេចក្តីសុខដ៏ឧត្តមផង រតនៈតែងកើតឡើងដល់ខ្ញុំដែលកើតក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ចក្ខុរបស់ខ្ញុំដ៏បរិសុទ្ធដូចជាទិព្វ ខ្ញុំជាអ្នកឈ្លាសវៃក្នុងសមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាលិកេរផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ នាលិកេរផលទាយកត្ថេរាបទាន ។**

## ឧទ្ទាន

តីណិកណិការបុប្ផិយត្ថេរាបទាន ១ ឯកបត្តទាយកត្ថេរាបទាន ១ កាសុមារិកផលទាយកត្ថេរាបទាន ១ អវដផលិយត្ថេរាបទាន ១ ចារផលិយត្ថេរាបទាន ១ មាតុលុង្គផលទាយកត្ថេរាបទាន ១ អជ្ជេលផលទាយកត្ថេរាបទាន ១ អមោរផលិយត្ថេរាបទាន ១ តាលផលិយត្ថេរាបទាន ១ នាលិកេរផលទាយកត្ថេរាបទាន ១ គាថាតាមដែលលោករាប់ទៅឃើញមានចំនួន ១០១ គាថា មិនមានការខ្វះនិងការលើស ។

# អដ្ឋកថា

# កណិការវគ្គ ទី ៥១

[ ៩១-១០០ ] អដ្ឋកថាកណិការវគ្គទី ៥១ មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាកណិការវគ្គទី ៥១ ចប់

# ផលទាយកវគ្គទី ៥២

## កុរញ្ជិយផលទាយកត្ថេរាបទានទី ១

[ ១០១ ] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគ ត្រាច់ទៅក្នុងព្រៃធំ បានឃើញព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលី ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា បានកាន់យកផ្លែកុរញ្ជិយព្រឹក្សថ្វាយព្រះពុទ្ធដ៏ប្រសើរ ជាបុញ្ញក្ខេត្តជាអ្នកប្រាជ្ញ ដោយដៃរបស់ខ្លួន ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុរញ្ជិយផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កុរញ្ជិយផលទាយកត្ថេរាបទាន ។**

## កបិដ្ឋផលទាយកត្ថេរាបទានទី ២

[ ១០២ ] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាស គួរទទួលគ្រឿងបូជា កំពុងស្តេចទៅតាមច្រក ហើយថ្វាយផ្លែខ្វិត ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកបិដ្ឋផលទាយកត្ថេរមានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កបិដ្ឋផលទាយកត្ថេរាបទាន ។**

## កោសុម្ភផលិយត្ថេរាបទានទី ៣

[ ១០៣ ] កាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់មានដំណើរល្វាសល្វន់ដូចលំពង់ថ្វាន់ត្រូវខ្យល់ ជាទេវតាកន្លងទេវតា ប្រសើរជាងនរៈ កំពុងស្តេចទៅតាមច្រក ហើយបានថ្វាយផ្លែសង្ឃ័រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល

នៃផលទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកោសុម្ពផលិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ កោសុម្ពផលិយត្ថេរាបទាន ។**

# កេតកបុប្ផិយត្ថេរាបទានទី ៤

[ ១០៤ ] ព្រះសម្ពុទ្ធជាបុរសខ្ពង់ខ្ពស់ ទ្រង់គង់នៅទៀបឆ្នេរស្ទឹងវិនតា ខ្ញុំបានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលីគឺកិលេស មានព្រះហឫទ័យមូលក្នុងអារម្មណ៍តែមួយ មានព្រះហឫទ័យតម្កល់មាំ ។ កាលនោះ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាកេត ដែលមានក្លិនក្រអូប ចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុង

សម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកេតកបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ កេតកបុប្ផិយត្ថេរាបទាន ។**

## នាគបុប្ផិយត្ថេរាបទានទី ៩

[ ១០៥ ] ខ្ញុំបានបូជាផ្កាខ្ទឹងចំពោះព្រះសម្ពុទ្ធ ទ្រង់មានវណ្ណៈដូចមាសគួរទទួលនូវគ្រឿងបូជា កំពុងស្តេចទៅតាមច្រក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ នាគបុប្ផិយត្ថេរាបទាន ។**

# អជ្ជុនបុប្ផិយត្ថេរាបទានទី ៦

[ ១០៦ ] កាលនោះ ខ្ញុំកើតជាកិន្នរ នៅទៀបឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ត្រេកអរ ធ្វើនូវអញ្ជលីកម្ម បានយកផ្កាអង្គ្រងទៅបូជាព្រះសយម្ភូ ។ ព្រោះអំពើដែលខ្ញុំធ្វើល្អនោះផង ព្រោះការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជាកិន្នរហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំជាធំជាងទេវតា បានសោយរាជ្យក្នុងទេវលោកអស់ ៣៦ ដង បានសោយរាជ្យជាស្តេចចក្កពត្តិមហារាជអស់ ១០ ដង ។ បានសោយប្រទេសរាជ្យដ៏ធំទូលាយរាប់ជាតិមិនអស់ ( ព្រោះ ) ពូជបានព្រោះក្នុងព្រះសយម្ភូជាស្រែដ៏ល្អ ។ ខ្ញុំមានកុសល ខ្ញុំបានចូលទៅកាន់ផ្នួស ខ្ញុំជាបុគ្គលគួរគេបូជា ក្នុងសាសនានៃព្រះសក្យបុត្ត ក្នុងថ្ងៃនេះ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ កពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអជ្ជុនបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ អជ្ជុនបុប្ផិយត្ថេរាបទាន ។**

# កុដជបុប្ផិយត្ថេរាបទានទី ៧

[ ១០៧ ] ក្នុងទីជិតនៃព្រៃហិមពាន្ត មានភ្នំមួយឈ្មោះអចលៈ ព្រះសម្ពុទ្ធព្រះនាមសុទស្សនៈ គង់នៅក្នុងចន្លោះភ្នំនោះ ។ ខ្ញុំបានយកផ្កាអំពីព្រៃហិមពាន្តហើយទៅកាន់អាកាស បានឃើញព្រះសម្ពុទ្ធទ្រង់ឆ្លងឱឃៈ មិនមានអាសវៈក្នុងទីនោះ ។ កាលនោះខ្ញុំ យកផ្កាអញ្ជ័នខៀវមកតម្កល់លើក្បាល ហើយបូជាព្រះពុទ្ធទ្រង់ត្រាស់ដឹងឯង ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុដជបុប្ផិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ កុដជបុប្ផិយត្ថេរាបទាន ។**

# ឃោសសញ្ញកត្ថេរាបទានទី ៨

[ ១០៨ ] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលី មានពួកទេវតាចោមរោមហើយ កំពុងប្រកាសនូវសច្ចៈ ៤ សម្ដែងនូវអមតបទ ។ ខ្ញុំបានស្ដាប់ធម៌ដ៏ពីរោះរបស់ព្រះពុទ្ធ ព្រះនាមសិខី ជាផៅពង្សនៃសត្វលោក ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាក្នុងឃោសសព្ទរបស់ព្រះសិខីសម្ពុទ្ធដែលរកបុគ្គលប្រៀបស្មើមិនមាន ខ្ញុំញុំាងចិត្តជ្រះថ្លាក្នុងព្រះអង្គហើយបានឆ្លងនូវភព ដែលសត្វហែលឆ្លងបានដោយកម្រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឃោសសញ្ញា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឃោសសញ្ញកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឃោសសញ្ញកត្ថេរាបទាន ។**

# សព្វផលទាយកត្ថេរាបទានទី ៩

[ ១០៩ ] កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ឈ្មោះវរុណៈ ជាអ្នកដល់ត្រើយនៃមន្ត្រ បានលះបង់បុត្ត ១០ នាក់ ហើយដើរចូលទៅក្នុងព្រៃ ។ ខ្ញុំបានធ្វើអាស្រមដ៏ល្អ បានធ្វើបណ្ណសាលាជាទីរីករាយនៃចិត្ត ដែលគេចាត់ចែងថ្នាក់យ៉ាងល្អ នៅក្នុងព្រៃធំ ។ កាលនោះ ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក គួរទទួលគ្រឿងបូជា ព្រះអង្គមានសេចក្តីប្រាថ្នាដើម្បីស្រោចស្រង់ខ្ញុំ បានស្តេចមកកាន់អាស្រមរបស់ខ្ញុំ ។ ពន្លឺដ៏ធំទូលាយក្នុងដងព្រៃទាំងប៉ុន្មាន ក៏កើតមានឡើង កាលនោះព្រៃធំ ក៏ភ្លឺប្រវាត់ដោយអានុភាពរបស់ព្រះពុទ្ធ ។ ខ្ញុំឃើញបាដិហារ្យរបស់ព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ខ្ញុំយកស្លឹកខ្ចប់ផ្លែឈើ ហើយរែកដើរមក ។ ខ្ញុំបានចូលទៅរកព្រះសម្ពុទ្ធ ហើយថ្វាយផ្លែនោះទាំងអម្រែក ព្រះសម្ពុទ្ធទ្រង់អនុគ្រោះដល់ខ្ញុំ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា អ្នកចូររែកនូវអម្រែកតាមក្រោយតថាគតមក កាលបើសង្ឃឆាន់ហើយ បុណ្យនឹងមានដល់អ្នក ។ ខ្ញុំយកកញ្ចប់នោះ ប្រគេនភិក្ខុសង្ឃ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសង្ឃនោះ ហើយក៏បានទៅកើតឯតុសិត ។ ខ្ញុំប្រកបដោយរបាំទិព្វ ចម្រៀងទិព្វ គ្រឿងប្រគំទិព្វក្នុងឋានសួគ៌នោះ ហើយសោយយសបរិវារដោយបុញ្ញកម្មនោះ ។ ខ្ញុំចូលទៅយកកំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ការខ្វះខាតភោគសម្បត្តិរបស់ខ្ញុំមិនមាន នេះជាផលនៃផលទាន ។ ទ្វីបទាំង ៤ ព្រមទាំងសមុទ្រ និងភ្នំមានត្រឹមណា ខ្ញុំសោយឥស្សរភាពកំណត់ត្រឹមនោះ ព្រោះថ្វាយនូវផ្លែឈើចំពោះព្រះពុទ្ធ ។ ពួកបក្សីទាំងប៉ុន្មានណា ហើរក្នុងអាកាស បក្សីទាំងនោះ

តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកយក្ខក្តី ភូតក្តី អារក្សក្តី កុម្ភណ្ឌក្តី គ្រុឌក្តី ទាំងប៉ុន្មានដែលនៅក្នុងដងព្រៃ តែងមកបម្រើខ្ញុំ ។ ពួកអណ្តើក ខ្លែ ឃ្មុំ របោម មូស សត្វទាំងពីរពួកនេះ តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកសត្វស្លាបឈ្មោះសុបណ្ណៈ ជាបក្សីមានកម្លាំងច្រើន សត្វទាំងនោះតែងយកខ្ញុំជាទីពឹង នេះជាផលនៃផលទាន ។ ពួកនាគណាមានអាយុវែង មានឫទ្ធិ មានយសធំ នាគទាំងនោះឯង តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកសត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែស្រុក ឆ្កែព្រៃ សត្វទាំងនោះឯង តែងលុះក្នុងអំណាចរបស់ខ្ញុំ នេះជាផលនៃផលទាន ។ ពួកទេវតាណាដែលឋិតនៅលើដើមឈើ និងស្មៅក្តី ឋិតនៅព្ធដ៏អាកាសក្តី ទេវតាទាំងអស់នោះឯង តែងយកខ្ញុំជាទីពឹង នេះជាផលនៃផលទាន ។ ខ្ញុំបានសម្រេចធម៌ដែលគេឃើញបានដោយកម្រ ជាធម៌ល្អិតជ្រាលជ្រៅដែលព្រះពុទ្ធទ្រង់ប្រកាសល្អហើយ នេះជាផលនៃផលទាន ។ ខ្ញុំបានវិមោក្ខ ៨ ជាអ្នកមិនមានអាសវៈ មានព្យាយាមដុតកម្តៅកិលេសមានប្រាជ្ញាចាស់ នេះជាផលនៃផលទាន ។ ពួកពុទ្ធបុត្តណា ដែលឋិតនៅក្នុងផល អស់ទោសៈហើយ មានយសច្រើន បណ្តាពុទ្ធបុត្តទាំងនោះ ខ្ញុំក៏ជាពុទ្ធបុត្តមួយដែរ នេះជាផលនៃផលទាន ។ ខ្ញុំបានសម្រេចអភិញ្ញាបារមី ត្រូវកុសលមូលដាស់តឿនហើយ ក៏បានកំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ។ ពុទ្ធបុត្តណា មានវិជ្ជា ៣ សម្រេចនូវឫទ្ធិ មានយសច្រើន សម្រេចនូវទិព្វសោត បណ្តាពុទ្ធបុត្តទាំងនោះ ខ្ញុំក៏ជាពុទ្ធបុត្តមួយដែរ ។

ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាល នោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុង សម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំ បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំង នេះ ដោយប្រការដូច្នេះ ។

**ចប់ សព្វផលទាយកត្ថេរាបទាន ។**

## បទុមធារិយត្ថេរាបទាន ទី ១០

[ ១១០ ] ក្នុងទីជិតព្រៃហិមពាន្ត មានភ្នំមួយឈ្មោះរោមសៈ កាលនោះ ព្រះសម្ពុទ្ធព្រះនាមអភិសម្ភវៈ ទ្រង់គង់ក្នុងទីវាលជិតភ្នំនោះ ។ ខ្ញុំចេញអំពី លំនៅ បានយកផ្កាឈូកបាំងថ្វាយព្រះអង្គ លុះខ្ញុំយកផ្កាឈូកមួយ បាំងថ្វាយ អស់មួយថ្ងៃហើយ ខ្ញុំត្រឡប់មកកាន់លំនៅវិញ ។ ក្នុងកប្បទី ៣១ អំពីកប្ប នេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរី

កាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមធារិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ បទុមធារិយត្ថេរាបទាន ។

## ឧទ្ទាន

កុរញ្ជិយផលទាយកត្ថេរាបទាន ១ កបិដ្ឋផលទាយកត្ថេរាបទាន ១ កោសុម្ភផលិយត្ថេរាបទាន ១ កេតកបុប្ផិយត្ថេរាបទាន ១ នាគបុប្ផិយត្ថេរាបទាន ១ អជ្ជុនបុប្ផិយត្ថេរាបទាន ១ កុដជបុប្ផិយត្ថេរាបទាន ១ ឃោសសញ្ញកត្ថេរាបទាន ១ សព្វផលទាយកត្ថេរាបទាន ១ បទុមធារិយត្ថេរាបទាន ១ រួបរួមគាថាក្នុងវគ្គនេះមាន ៨៣ គាថា ។

## ចប់ ផលទាយកវគ្គ ទី ៥២ ។

# អដ្ឋកថា

## ផលទាយកវគ្គ ទី ៥២

[ ១០១-១១០ ] *អដ្ឋកថាផលទាយកវគ្គទី ៥២ មានអត្ថងាយយល់ហើយ ។*

***អដ្ឋកថាផលទាយកវគ្គទី ៥២ ចប់***

# តិណទាយកវគ្គ ទី ៥៣

## តិណមុដ្ឋិទាយកត្ថេរាបទាន ទី ១

[ ១១១ ] នៅជិតភ្នំហិមពាន្ត មានភ្នំមួយឈ្មោះលម្ពកៈ ព្រះតិស្សសម្ពុទ្ធ ស្តេចចង្រ្កមនាទីវាលក្បែរភ្នំនោះ ។ ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះសម្ពុទ្ធជាទេវតាក្រៃលែងជាងទេវតា ខ្ញុំបានថ្វាយស្មៅមួយក្តាប់ ។ លុះខ្ញុំបានថ្វាយស្មៅដល់ព្រះសម្ពុទ្ធដើម្បីគង់ហើយ ញុំាងចិត្តឲ្យជ្រះថ្លា បានថ្វាយបង្គំព្រះសម្ពុទ្ធរួចបែរមុខទៅកាន់ឧត្តរទិស ដើរចេញទៅ ។ ស្រាប់តែមានស្តេចម្រឹគមកបៀតបៀនខ្ញុំ ដែលទើបនឹងដើរទៅក្នុងផ្លូវ ខ្ញុំត្រូវសត្វសីហៈបៀតបៀនហើយ ក៏ធ្វើមរណកាលក្នុងទីនោះ ។ អាសន្នកម្មដែលខ្ញុំធ្វើហើយចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គមិនមានអាសវៈ ខ្ញុំក៏បានទៅកើតក្នុងទេវលោក ដូចកម្លាំងកូនសរដែលផុតស្រឡះ ( ចាកបំពង់ព្រួញ ) ។ ប្រាសាទដ៏ល្អ ដែលបុញ្ញកម្មនិម្មិតហើយក្នុងទេវលោកនោះ មានកម្ពស់មួយពាន់សន្ទុះព្រួញ មានជាន់ ៧ បរិបូណ៌ដោយទង់ បិទបាំងដោយកែវមណីខៀវ ។ ពន្លឺរបស់ប្រាសាទនោះ តែងផ្សាយចេញដូចព្រះអាទិត្យដែលរះឡើង ប្រាសាទនោះកុះករដោយទេវកញ្ញា ខ្ញុំពេញចិត្តរីករាយក្នុងកាម ។ ខ្ញុំច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន បានមកកាន់អត្តភាពជាមនុស្ស ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកម្រាលអង្គុយក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្មៅមួយក្តាប់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំង

ពួនខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណមុដ្ឋិទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ តិណមុដ្ឋិទាយកត្ថេរាបទាន ។**

## បេចូកទាយកត្ថេរាបទាន ទី ២

[ ១១២ ] ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយបង្គន់មួយ ដោយដៃរបស់ខ្លួន ចំពោះព្រះមានព្រះភាគព្រះនាមវិបស្សី ជាច្បងក្នុងលោក ជាតាទិបុគ្គល ។ ខ្ញុំបានយានដំរី យានសេះ យានទិព្វ ហើយបានដល់នូវធម៌ជាទីក្ស័យនៃអាសវៈ ដោយសារការថ្វាយនូវបង្គន់នោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គន់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គន់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា

៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវេច្ចកទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ វេច្ចកទាយកត្ថេរាបទាន ។

# សរណាគមនិយត្ថេរាបទានទី ៣

[ ១១៣ ] ក្នុងកាលនោះ ភិក្ខុនិងខ្ញុំជាអ្នកប្រកបការចិញ្ចឹមជីវិត បានឡើងជិះសំពៅទៅជាមួយគ្នា កាលដែលសំពៅធ្លាយហើយ ភិក្ខុបានឲ្យសរណាគមន៍ដល់ខ្ញុំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលភិក្ខុនោះបានឲ្យសរណាគមន៍ដល់ខ្ញុំក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសរណាគមន៍ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណាគមនិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សរណាគមនិយត្ថេរាបទាន ។**

# អគ្គញ្ញុងទាយកត្ថេរាបទានទី ៤

[ ១១៤ ] ខ្ញុំនៅក្នុងព្រះរាជឧទ្យាន ក្បែរក្រុងពន្ធុមតី កាលនោះ ខ្ញុំស្លៀកសំពត់ស្បែក ទ្រទ្រង់លក្កចាន់ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានព្រះហឫទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់ជាឥសី ទ្រង់មានឈាន ត្រេកអរក្នុងឈាន ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់សម្រេចសេចក្ដីប្រាថ្នាទាំងពួងផង ទ្រង់ឆ្លងនូវអន្លង់ទាំងមិនមានអាសវៈផង ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយថ្នាំបន្តក់ភ្នែក ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថ្នាំបន្តក់ភ្នែក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអគ្គញ្ញុងទាយកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ អគ្គញ្ញុងទាយកត្ថេរាបទាន ។

# សុបជទាយកត្ថេរាបទានទី ៥

[ ១១៥ ] ព្រះលោកនាយកព្រះនាមវិបស្សី ចេញអំពីរោងសម្រាកក្នុងវេលាថ្ងៃ ខ្ញុំបានថ្វាយសំពត់មានសាច់ស្តើង ហើយបានរីករាយក្នុងឋានសួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ដ៏ល្អក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសំពត់ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើររបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុបជទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សុបជទាយកត្ថេរាបទាន ។**

# ទណ្ឌទាយកត្ថេរាបទានទី ៦

[ ១១៦ ] កាលនោះ ខ្ញុំដើរចូលទៅក្នុងព្រៃធំ បានកាប់ឫស្សីធ្វើជាបង្កាន់ដៃ ប្រគេនដល់ព្រះសង្ឃ ។ ខ្ញុំថ្វាយបង្គំនូវព្រះសង្ឃមានវត្តល្អ ដោយចិត្តជ្រះថ្លានោះ លុះខ្ញុំប្រគេនកំណាត់ឫស្សីបង្កាន់ដៃរួចហើយ ក៏បែរមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកំណាត់ឫស្សីក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យកំណាត់ឫស្សី ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះទណ្ឌទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ទណ្ឌទាយកត្ថេរាបទាន ។**

**ចប់ ភាណវារៈទី ២៣ ។**

# គិរិនេលបូជកត្ថេរាបទានទី ៧

[ ១១៧ ] ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគ ត្រាច់ទៅក្នុងព្រៃ បានឃើញព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលី ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយចំពោះព្រះសម្ពុទ្ធ ព្រះអង្គប្រកបដោយសេចក្តីករុណា ត្រេកអរចំពោះប្រយោជន៍របស់សព្វសត្វ ហើយបានបូជាផ្កាអញ្ចាញខៀវ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះគិរិនេលបូជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ចប់ គិរិនេលបូជកត្ថេរាបទាន ។

# ពោធិសម្មជ្ជកត្ថេរាបទានទី ៨

[ ១១៨ ] ក្នុងភពមុន ខ្ញុំបានរើសស្លឹកពោធិដែលជ្រុះក្នុងលានព្រះចេតិយ ហើយយកទៅចោល ខ្ញុំបាននូវគុណ ២០ ។ ខ្ញុំអន្ទោលទៅក្នុង ភពតូចភពធំ តែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ដោយតេជះនៃកម្មនោះ ។ លុះខ្ញុំច្យុតចាកទេវលោក មកកាន់ភពរបស់មនុស្ស តែងកើតក្នុងត្រកូលពីរ គឺក្សត្រនិងព្រាហ្មណ៍ ។ ខ្ញុំបរិបូណ៌ដោយអវយវៈតូចធំ មានកម្ពស់និងទំហំសមរម្យ មានរូបល្អ មានសម្បុរស្អាត មានរាងកាយពេញលេញ មិនខ្វះខាត ។ ខ្ញុំកើតក្នុងទេវលោក ឬក្នុងមនុស្សលោក ឬក៏ក្នុងភពណាមួយតែងមានសម្បុរល្អដូចមាស ឬ ប្រៀបដូចមាសឆ្អិន ។ សម្បុររបស់ខ្ញុំ ទន់ល្វន់ល្វាស ជិតស្និទ្ធ ល្អិត ផូរផង់សព្វៗកាល ព្រោះបានយកស្លឹកពោធិទៅចោល ទឹកដែលប្រឡាំដោយធូលី មិនដែលប្រឡាក់ក្នុងប្រជុំសរីរៈ ( របស់ខ្ញុំ ) ក្នុងកាលណាមួងឡើយ នេះជាផលក្នុងការយកស្លឹកពោធិទៅចោល ។ ខ្លួនរបស់ខ្ញុំនោះ ( បិតនៅ ) ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ក្តៅក្តី ឬត្រូវកម្តៅភ្លើងក្តី ញើសទាំងឡាយ ក៏មិនដែលហូរចេញ នេះជាផលក្នុងការយកស្លឹកពោធិទៅចោល ។ រោគឃ្លង់ ពក ស្រែង ប្រជ្រុយ បូស ដំណួចពិស មិនដែលមានក្នុងកាយ ( របស់ខ្ញុំឡើយ ) នេះជាផលក្នុងការយក ស្លឹកពោធិទៅចោល ។ គុណដទៃទៀតតែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺរោគទាំងឡាយមិនដែលកើតក្នុងកាយរបស់ខ្ញុំឡើយ នេះជាផលក្នុងការយកស្លឹកពោធិទៅចោល ។ គុណដទៃទៀតតែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺអន្តរាយជាគ្រឿងបៀតបៀនដែលកើតអំពីចិត្ត មិនដែលមានឡើយ នេះជា

ផលក្នុងការយកស្លឹកពោធិទៅចោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺពួកសត្រូវមិនដែលមានដល់ខ្ញុំនោះ នេះជាផលក្នុងការយកស្លឹកពោធិទៅចោល ។ គុណដទៃទៀតតែងកើតដល់ខ្ញុំនោះ ក្នុងភពតូចនិងភពធំ គឺភោគៈមិនដែលខ្វះខាតឡើយ នេះជាផលក្នុងការយកស្លឹកពោធិទៅចោល ។ គុណដទៃទៀត តែងកើតដល់ខ្ញុំនោះក្នុងភពតូចនិងភពធំ គឺភ័យអំពីភ្លើងនិងស្តេច អំពីចោរ និងទឹក មិនដែលមានឡើយ ។ មានគុណដទៃទៀត តែងកើតដល់ខ្ញុំនោះក្នុងភពតូចនិងភពធំ គឺពួកខ្ញុំស្រី ខ្ញុំប្រុស ជាអ្នកប្រព្រឹត្តតាម ជាអ្នកលុះអំណាចចិត្តរបស់ខ្ញុំ ។ បុគ្គលកើតក្នុងភពជារបស់មនុស្ស មានកំណត់អាយុ ត្រឹមណា អាយុរបស់ខ្ញុំមិនថយចុះអំពីកំណត់ត្រឹមនោះ តែងឋិតនៅដរាបដល់អស់អាយុ ។ ពួកជនទាំងអស់ អ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាសេចក្តីសុខ ទោះនៅខាងក្នុងក្តី ខាងក្រៅក្តី អ្នកនិគមក្តី អ្នកដែនក្តី សុទ្ធតែជាអ្នកប្រកបតាមខ្ញុំ ។ ខ្ញុំជាអ្នកមានភោគៈ មានយស មានសិរី មានពួកញាតិ ជាអ្នកឥតមានវេរា ប្រាសចាកសេចក្តីតក់ស្លុត តែងមានក្នុងភពសព្វៗកាល ។ ពួកទេវតា មនុស្ស អសុរ គន្ធព្វ យក្ខ អារក្សទឹក អ្នកទាំងអស់នោះ តែងរក្សាខ្ញុំ ដែលអន្ទោលទៅក្នុងភពសព្វៗកាល ។ ខ្ញុំទទួលយសទាំងពីរ ក្នុងទេវលោកផង ក្នុងមនុស្សលោកផង រួចខ្ញុំបានដល់នូវព្រះនិព្វាន ជាសិវដ្ឋានដ៏ប្រសើរ ក្នុងកាលជាទីបំផុត ។ បុរសណាឧទ្ទិសចំពោះព្រះសម្ពុទ្ធ ឬចំពោះដើមពោធិរបស់ព្រះសាស្តានោះ គប្បីទទួលនូវផលបុណ្យ ( ផលទាំងអស់ ) ឈ្មោះថាបុរសនោះបានដោយក្រដូចម្តេចបាន ។ បុគ្គល

( ដែលឋិតនៅ ) ក្នុងមគ្គ ក្នុងផល ក្នុងបរិយត្តិ ក្នុងគុណគឺឈាននិង អភិញ្ញា ជាបុគ្គលប្រសើរក្រៃលែងជាងពួកជនដទៃ ជាអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។ ក្នុងភពមុន ខ្ញុំមានចិត្តរីករាយ បានយកស្លឹកពោធិទៅចោល ទើបជាអ្នកបរិបូណ៌ដោយអង្គ ២០ នេះសព្វៗកាល ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុង សម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំ បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើ ឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិសម្មជ្ជកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ពោធិសម្មជ្ជកត្ថេរាបទាន ។**

# អាមណ្ឌផលទាយកត្ថេរាបទានទី ៩

[ ១១៩ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំង ពួង ជាលោកនាយក ទ្រង់ចេញចាកសមាធិហើយចង្ក្រម ។ កាលនោះ ខ្ញុំរែកនូវអម្រែក ដែលពេញដោយផ្លែឈើ បានឃើញព្រះសម្ពុទ្ធជាមហាមុនី ទ្រង់ប្រាសចាករាគៈ កំពុងចង្ក្រម ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ធ្វើ នូវអញ្ជលីលើសិរ្សៈ ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយថ្វាយផ្លែល្ហុង ។ ក្នុងកប្ប

ទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែល្អ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអាមណ្ឌផលទាយកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ អាមណ្ឌផលទាយកត្ថេរាបទាន ។**

# សុគន្ធត្ថេរាបទានទី ១០

[ ១២០ ] ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ ទ្រង់មានផៅពង្សដ៏ប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើងហើយ ។ ព្រះអង្គបរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈ ៣២ ដ៏ប្រសើរ មានពន្លឺមួយព្យាមជុំវិញ មានបណ្តាញរស្មីតាំងឡើង ។ ព្រះអង្គទ្រង់ញុំាងពួកជនឲ្យត្រេកអរ ដូចព្រះចន្ទ មានរស្មីដូចព្រះអាទិត្យ ទ្រង់ញុំាងសត្វឲ្យរលត់ទុក្ខដូចមហាមេឃ ទ្រង់ធ្វើនូវគុណដូចសាគរ ។ ព្រះអង្គមានសីលដូចផែនដី មានសមាធិដូចភ្នំហិមពាន្ត មានបញ្ញា ដូចអាកាស មិនជាប់ចំពាក់ដូចខ្យល់ ។

ព្រះអង្គមានគុណមិនខ្វះខាត មានធម៌ជាគ្រឿងអប់រំ ទ្រង់ក្លៀវក្លាក្នុងពួកបរិស័ទ ទ្រង់ស្រង់ឡើងនូវមហាជន ហើយប្រកាសនូវសច្ចធម៌ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្ត ក្នុងក្រុងពារាណសី មានយសធំ ជាអ្នកប្រសើរដោយទ្រព្យនិងស្រូវច្រើនក្រៃលែង ។ ខ្ញុំកាលត្រាច់ទៅកាន់ទីសម្រាកស្មង ក៏ចូលទៅក្នុងព្រៃមិគទាយ៍ បានឃើញព្រះសាស្តាជាទីពឹង កំពុងសម្តែងអមតបទ មានព្រះពុទ្ធដីកាជ្រះស្រឡះ មានសំឡេងស្មើដោយសត្វករវិក មានសន្ទឹកគឹកកង ដូចសត្វហង្ស ឬដូចស្គរ ទ្រង់ញ៉ាំងមហាជនឲ្យដឹងច្បាស់ ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធនោះ ជាទេវតាដ៏ក្រៃលែងជាងទេវតា ទាំងបានស្តាប់សំឡេងដ៏ពីរោះ ទើបលះភោគៈដ៏ច្រើន ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសយ៉ាងនេះហើយ មិនយូរប៉ុន្មាន ក៏បានជាពហុស្សូត ជាធម្មកថិក មានប្រាជ្ញាដ៏វិចិត្រ ។ ខ្ញុំជាអ្នកក្លៀវក្លាដោយគុណ បានពណ៌នាគុណរបស់ព្រះសាស្តា ដែលមានវណ្ណៈដូចមាស ក្នុងកណ្តាលបរិស័ទច្រើនជារឿយ ៗ ថា ព្រះពុទ្ធនុ៎ះ ជាព្រះខីណាស្រព ទ្រង់មិនមានទុក្ខ កាត់បង់នូវសេចក្តីសង្ស័យ ទ្រង់ដល់នូវការអស់នៃកម្មទាំងពួង មានព្រះហឫទ័យចុះស៊ប់ក្នុងព្រះនិព្វានជាទីអស់ទៅនៃឧបធិ ។ ព្រះមានព្រះភាគអង្គនុ៎ះ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ព្រះមានព្រះភាគអង្គនុ៎ះ ទ្រង់ប្រសើរដូចសីហៈ ព្រះអង្គញ៉ាំងព្រហ្មចក្កឲ្យប្រព្រឹត្តទៅដល់មនុស្សលោក ព្រមទាំងទេវលោក ទ្រង់ជាឥសីមានឥន្ទ្រិយទូន្មានហើយ ទ្រង់ទូន្មាននូវមហាជន ព្រះអង្គស្ងប់រម្ងាប់ហើយ ញ៉ាំងមហាជនឲ្យស្ងប់រម្ងាប់ ទ្រង់រលត់កិលេសហើយ ញ៉ាំងមហាជនឲ្យរលត់កិលេសផង

ព្រះអង្គត្រេកអរហើយ ញុំាំងមហាជនឲ្យត្រេកអរផង ។ ព្រះអង្គមានព្យាយាម អង់អាច ក្លាហាន មានប្រាជ្ញាប្រកបដោយសេចក្តីករុណា ទ្រង់ស្ទាត់ជំនាញ ទ្រង់ឈ្នះមារ ទ្រង់ឈ្នះមិនចាញ់វិញ ទ្រង់មិនឃ្នើសឃ្នង មិនមានអាល័យ ។ ព្រះមុនីទ្រង់មិនញាប់ញ័រ មិនឃ្វេងឃ្វាង ជាអ្នកប្រាជ្ញ មិនមានមោហៈ ឥត មានបុគ្គលស្មើ នាំទៅនូវធុរៈ ជាឧសភៈ ជានាគ ជាសីហៈ ទ្រង់អង់អាច ក្នុងពួកគ្រូទាំងឡាយ ។ ព្រះអង្គប្រាសចាករាគៈ មិនមានមន្ទិល ជាព្រហ្ម- មានវាទដ៏ក្លៀវក្លា ទ្រង់លះបង់នូវសត្រូវគឺកិលេស ទ្រង់មិនរឹងត្អឹង ប្រាស ចាកកូនសរគឺសេចក្តីសោក ឥតមានបុគ្គលស្មើ ជាឧសភៈ ជាអ្នកស្អាត ។ ព្រះអង្គជាព្រាហ្មណ៍ ជាសមណៈ ជាទីពឹង ជាពេទ្យ ទ្រង់កម្ចាត់បង់នូវសរ គឺសេចក្តីសោក ជាយោធា ត្រាស់ដឹងនូវសច្ចៈ ភ្ញាក់រឭកចាកការដេកលក់ មិនញាប់ញ័រ មានព្រះហឫទ័យទន់ត្រជាក់ ។ ព្រះអង្គមានការទូន្មានធ្វើហើយ ទ្រង់នាំទៅ ទ្រង់ធ្វើ ទ្រង់ណែនាំ ទ្រង់ប្រកាស ទ្រង់រីករាយ ទ្រង់លាងជម្រះ ទ្រង់កាត់ ( កិលេស ) ទ្រង់ស្រោចស្រង់ គួរគេសរសើរ ។ ព្រះអង្គមិន កម្រើក ( មិនរឹករវ ) ប្រាសចាកសរគឺសេចក្តីសោក មិនមានទុក្ខ មិនមាន សេចក្តីសង្ស័យ មិនញាប់ញ័រ ទ្រង់ប្រាសចាកធូលី ទ្រង់គាស់រំលើង ( កិលេស ) ទ្រង់ចងក្រង ទ្រង់ពោលប្រដៅ ទ្រង់ប្រកាស ។ ព្រះអង្គ ទ្រង់ចម្លង ទ្រង់ធ្វើប្រយោជន៍ ញុំាំងជនឲ្យធ្វើ ( ប្រយោជន៍ ) ទ្រង់រំលាយ កិលេស ទ្រង់ញុំាំងជនឲ្យដល់ ទ្រង់អត់ធន់ ទ្រង់សម្លាប់កិលេស ទ្រង់មាន ព្យាយាមកម្តៅកិលេស ទ្រង់ញុំាំងកិលេសឲ្យរីងស្ងួត ។ ព្រះអង្គទ្រង់ឋិតនៅ

ក្នុងសច្ចៈ ទ្រង់ស្មើដោយបុគ្គលស្មើគឺអតីតពុទ្ធ មិនមានសម្លាញ់ ទ្រង់អាល័យក្នុងសេចក្តីអាណិត មានសេចក្តីអស្ចារ្យ ទ្រង់មិនកុហក ទ្រង់ធ្វើ ជាឥសីទី ៧ ។ ព្រះជិនស្រីទ្រង់ឆ្លងផុតសេចក្តីសង្ស័យ មិនមានមានះ មានគុណប្រមាណមិនបាន មិនមានឧបមា ទ្រង់កន្លងនូវគន្លងពាក្យទាំងពួង ដល់នូវទីបំផុតនៃនេយ្យធម៌ទាំងពួង ។ សេចក្តីជ្រះថ្លាក្នុងព្រះជិនស្រីដ៏ប្រសើរដូចព្រះអាទិត្យនោះ ជាគុណនាំមកនូវព្រះនិព្វានឈ្មោះអមតៈ ព្រោះហេតុនោះសេចក្តីជឿស៊ប់ក្នុងព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី មានប្រយោជន៍ច្រើន ។ ខ្ញុំកំពុងពណ៌នាគុណនៃព្រះសម្ពុទ្ធដ៏ប្រសើរ ជាទីពឹងនៃសត្វក្នុងត្រៃលោកដោយគុណទាំងឡាយមានយ៉ាងនេះជាដើម ហើយសម្តែងធម្មកថាក្នុងកណ្តាលបរិស័ទ ។ ខ្ញុំច្យុតចាកអត្តភាពនោះហើយ ទទួលសេចក្តីសុខច្រើនក្នុងភពតុសិត លុះច្យុតចាកតុសិតនោះ មកកើតក្នុងពួកមនុស្ស ជាអ្នកមានក្លិនក្រអូប ។ ខ្យល់ដង្ហើមចេញរបស់ខ្ញុំក្តី ក្លិនមាត់ក្តី ក្លិនកាយក្តីដូចគ្នា ក្លិនរបស់ខ្ញុំនោះ ក្រអូបសព្វជានិច្ច ។ ក្លិនមាត់របស់ខ្ញុំដូចក្លិនផ្កាឈូក ឬផ្កាឧប្បលនិងផ្កាចម្ប៉ាសព្វៗកាល ទាំងសរីរៈរបស់ខ្ញុំប្រសើរផុតគេ តែងផ្សាយទៅសព្វ ៗ កាល ដូច្នោះដែរ ។ សេចក្តីអស្ចារ្យយ៉ាងក្រៃលែងទាំងអស់នោះ ជាផលនៃសេចក្តីសរសើរនូវគុណ អ្នកទាំងអស់គ្នាចូរស្តាប់នូវភាសិតរបស់ខ្ញុំ ដោយចិត្តនឹងនួនចុះ ។ លុះខ្ញុំសរសើរពុទ្ធគុណជាទីមកនៃប្រយោជន៍ ទាំងនាំមកនូវសេចក្តីសុខ ខ្ញុំមានចិត្តស្អាត ជាសង្ឃខ្វល់ខ្វាយតែនឹងសេចក្តីព្យាយាម ក្នុងធម៌ទាំងពួង ។ ព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់មានសេចក្តីសុខ ទ្រង់ត្រេកអរ

ទ្រង់រុងរឿង ជាទីស្រឡាញ់ ទាំងគួរមិលមើល ទ្រង់ពោលប្រដៅ មិនមាន បុគ្គលមើលងាយ មិនមានទោស មានប្រាជ្ញា ។ កាលបើព្រះជន្មាយុអស់ ហើយ បុគ្គលអ្នកគប់រកនូវព្រះពុទ្ធ តែងបានព្រះនិព្វានដោយងាយ ខ្ញុំនឹង សម្តែងនូវហេតុនៃគុណទាំងឡាយនោះ អ្នកទាំងឡាយ ចូរស្តាប់ហេតុនោះ ដោយគោរពចុះ ។ ខ្ញុំថ្វាយបង្គំនូវយសរបស់ព្រះមានព្រះភាគ ដោយការ ត្រិះរិះ សូម្បីខ្ញុំទៅកើតក្នុងភពណា ៗ តែងជាអ្នកមានយសក្នុងភពនោះ ៗ ដោយការត្រិះរិះនោះ ។ ខ្ញុំកាលសរសើរនូវព្រះសម្ពុទ្ធ ទ្រង់ធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ ព្រះធម៌ជាគុណស្ងប់រម្ងាប់ ជាអសង្ខតធម៌ ហើយជាអ្នក ដល់នូវសេចក្តីសុខ ជាអ្នកឲ្យនូវសេចក្តីសុខដល់ពួកសត្វ ក្នុងកាលនោះ ។ មួយទៀត ខ្ញុំកាលពោលសរសើរនូវគុណរបស់ព្រះពុទ្ធ ប្រកបដោយបីតិក្នុង ព្រះពុទ្ធ បានញុំាងសេចក្តីត្រេកអររបស់ខ្លួន និងសេចក្តីត្រេកអររបស់បុគ្គល ដទៃឲ្យកើត ជាអ្នកមានសេចក្តីត្រេកអរដោយសារហេតុនោះ ។ ព្រះជិនស្រី អង្គណា កន្លងផុតនូវពួកតិរ្ថិយ គ្របសង្កត់នូវពួកតិរ្ថិយដ៏អាក្រក់ ខ្ញុំពោល នូវគុណ សរសើរនូវព្រះនាយកអង្គនោះ ខ្ញុំមានសេចក្តីរុងរឿងដោយសារ ហេតុនោះ ។ ខ្ញុំធ្វើសេចក្តីស្រឡាញ់ ដល់ពួកជន ខ្ញុំពោលសរសើរគុណ ព្រះសម្ពុទ្ធ ខ្ញុំប្រាកដដូចព្រះចន្ទក្នុងសរទកាល ខ្ញុំជាទីស្រឡាញ់ គួរមិល-មើលដោយសារហេតុនោះ ។ ខ្ញុំសរសើរព្រះសុគតដោយវាចា សព្វគ្រប់ ដោយអំណាចនៃសេចក្តីអង់អាច ព្រោះហេតុនោះ ទើបខ្ញុំមាននាមថាវង្គីសៈ ជាអ្នកមានប្រាជ្ញាដ៏វិចិត្រ បពិត្រព្រះមហាមុនី ពួកជនពាលណា ដល់នូវ

សេចក្តីសង្ស័យ ហើយមើលងាយ ខ្ញុំសង្កត់សង្កិនជនពាលទាំងនោះ ដោយការគ្របសង្កត់តាមធម៌របស់ខ្លួននោះ ។ ខ្ញុំនាំចេញនូវកិលេសទាំងឡាយរបស់សត្វ ដោយការសរសើរនូវព្រះពុទ្ធ ទើបខ្ញុំមានចិត្តមិនប្រឡាក់កិលេសដោយកម្លាំងនៃកម្មនោះ ។ ខ្ញុំញ៉ាំងប្រាជ្ញាឲ្យកើតដល់ជនជាអ្នកស្តាប់ ជាអ្នកសម្តែងនូវពុទ្ធានុស្សតិ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកមានប្រាជ្ញា ជាអ្នកពិចារណាឃើញនូវអត្ថដ៏ល្អិត ។ ខ្ញុំអស់អាសវៈទាំងពួងហើយ ឆ្លងសមុទ្រគឺសង្សារវដ្តហើយ ខ្ញុំជាអ្នកស្ងាត់ជំនាញ មិនមានឧបាទាន ទាំងដល់នូវព្រះនិព្វាន ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំសរសើរព្រះជិនស្រីក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុគន្ធត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សុគន្ធត្ថេរាបទាន ។**

## ឧទ្ទាន

តិណមុដ្ឋិទាយកត្ថេរាបទាន ១ វេចូកទាយកត្ថេរាបទាន ១ សរណាគមនិយត្ថេរាបទាន ១ អព្ភញ្ជនទាយកត្ថេរាបទាន ១ សុបដទាយកត្ថេរាបទាន ១ ទណ្ឌទាយកត្ថេរាបទាន ១ គិរិនេលបូជកត្ថេរាបទាន ១ ពោធិសម្មជ្ជកត្ថេរាបទាន ១ អាមណ្ឌផលទាយកត្ថេរាបទាន ១ សុគន្ធត្ថេរាបទាន ១ ជាទី ១០ ឯគាថាក្នុងវគ្គនេះមាន ២២០ លោករាប់ហើយដោយសព្វគ្រប់ ។

### ចប់ តិណទាយកវគ្គ ទី ៥៣ ។

## អដ្ឋកថា

## តិណទាយកវគ្គ ទី ៥៣

[ ១១១-១២០ ] អដ្ឋកថាតិណទាយកវគ្គទី ៥៣ មានអត្ថងាយយល់ហើយ ។

### អដ្ឋកថាតិណទាយកវគ្គទី ៥៣ ចប់

# កច្ចាយនវគ្គ ទី ៥៤

## មហាកច្ចាយនត្ថេរាបទាន ទី ១

[ ១២១ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មិនញាប់ញ័រ ឥតមានបុគ្គលផ្ចាញ់បាន ជានាយក ទ្រង់ត្រាស់ឡើងក្នុងកប្បទីមួយសែនអំពីកទ្ទកប្បនេះ ។ ព្រះវីរសម្ពុទ្ធទ្រង់មានត្របកព្រះនេត្រដូចផ្កាឈូក មានព្រះឱស្ឋប្រាសចាកមន្ទិលដូចព្រះចន្ទ មានព្រះតចៈដូចមាស មានរស្មីរុងរឿងដូចព្រះអាទិត្យ ទ្រង់ជាទីត្រូវភ្នែកនិងចិត្តរបស់សត្វ ប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ទ្រង់កន្លងផុតគន្លងពាក្យទាំងពួង ត្រូវមនុស្សនិងទេវតាធ្វើសក្ការៈហើយ ។ ព្រះសម្ពុទ្ធ ទ្រង់ញុំាងពួកសត្វឲ្យត្រាស់ដឹង ទ្រង់មានសំឡេងពីរោះផ្សាយទៅ ទ្រង់មានសន្តានជាប់ដោយសេចក្តីករុណា ទ្រង់ក្លៀវក្លាក្នុងពួកបរិស័ទ ។ ព្រះសម្ពុទ្ធ ទ្រង់សម្តែងធម៌ពីរោះ ប្រកបដោយសច្ចៈ ៤ ទ្រង់ស្រង់ពួកសត្វដែលលិចចុះក្នុងភក់គឺមោហៈ ។ ក្នុងកាលនោះ ខ្ញុំកើតជាតាបស មានលំនៅក្នុងព្រៃហិមពាន្ត ត្រាច់ទៅតែម្នាក់ឯង ហោះទៅកាន់មនុស្សលោកតាមអាកាស បានឃើញព្រះជិនស្រី ។ ខ្ញុំចូលទៅកាន់សម្នាក់ព្រះជិនស្រីនោះ បានស្តាប់ធម្មទេសនារបស់ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ដែលកំពុងពណ៌នានូវគុណដ៏ធំរបស់សាវកថា ភាសិតដែលតថាគតពោលដោយបំព្រួញ សាវកនេះ ប្រកាសដោយពិស្តារបាន ញុំាងបរិស័ទនឹងតថាគតឲ្យត្រេកអរ ដូចកច្ចាយនភិក្ខុ ។ តថាគតមិនឃើញមានសាវកដទៃណាមួយ ក្នុងសាសនានេះយ៉ាងនេះឡើយ ព្រោះហេតុនោះ សាវកនេះ ជាអ្នកប្រសើរ ( ឋិតនៅ ) ក្នុងទីជាឯតទគ្គៈ

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះចុះ កាលនោះ ខ្ញុំមានសេចក្តីស្ងប់ស្ងៀម ព្រោះស្តាប់ពាក្យជាទីគាប់ចិត្តនោះ ទើបទៅកាន់ព្រៃហិមពាន្ត ដើរសន្សំបេះផ្កាឈើ ។ ខ្ញុំបូជាចំពោះព្រះសម្ពុទ្ធជាទីពឹងនៃលោក ហើយប្រាថ្នានូវតំណែងនោះ ។

កាលនោះ ព្រះសរណាលយសម្ពុទ្ធ ទ្រង់ជ្រាបអធ្យាស្រ័យដ៏ធំរបស់ខ្ញុំ ទ្រង់ព្យាករថា អ្នកទាំងឡាយចូរមើលនូវឥសីដ៏ប្រសើរនេះ មានស្បែកដូចមាស មិនមានមន្ទិល មានរោមខ្ពស់និងសាច់ពេញលេញ ឈរផ្គងអញ្ជលី មិនកម្រើក មានសេចក្តីរីករាយ មានភ្នែកពេញល្អ មានអធ្យាស្រ័យស្ងប់ចុះក្នុងការពណ៌នានូវពុទ្ធគុណ ជាអ្នកកើតអំពីធម៌ មានហឫទ័យខ្ពស់ ហាក់ដូចជាស្រោចស្រពដោយទឹកអម្រឹត ។

បពិត្រព្រះមហាមុនី លុះខ្ញុំឈរស្តាប់នូវគុណរបស់ព្រះកច្ចាយនភិក្ខុហើយ ក៏ប្រាថ្នានូវតំណែងនោះ ក្នុងសាសនានៃព្រះគោតម ក្នុងកាលជាអនាគត ។ ( ព្រះបទុមុត្តរៈទ្រង់ព្យាករថា ) តាបសនេះ នឹងបានជាធម្មទាយាទ ជាឱរសរបស់ព្រះគោតមនោះ ជាធម្មនិម្មិត មាននាមថាកច្ចានភិក្ខុ ជាសាវករបស់ព្រះសាស្តា ។ កច្ចានភិក្ខុនោះ នឹងបានជាពហុស្សូត មានញាណដ៏ប្រសើរ ជាអ្នកប្រាជ្ញ ដឹងនូវសេចក្តីអធិប្បាយ នឹងដល់នូវតំណែងនោះ ដូចជាតថាគតព្យាករហើយនេះ ។

ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងអន្ទោល

ទៅក្នុងភពពីរ គឺទេវតាឬមនុស្ស មិនដែលស្គាល់គតិដទៃឡើយ នេះជាផល នៃពុទ្ធបូជា ។ ខ្ញុំតែងកើតក្នុងត្រកូលពីរ គឺត្រកូលក្សត្រ ឬព្រាហ្មណ៍ មិនដែលកើតក្នុងត្រកូលទាបឡើយ នេះជាផលនៃពុទ្ធបូជា ។ ក្នុងបច្ឆិមភព ខ្ញុំកើតជាបុត្រនៃបុរោហិតរបស់ស្តេចព្រះនាមចណ្ឌបជ្ជោត ក្នុងបុរីឧជ្ជេនីជាទីរីករាយ ។ ខ្ញុំជាបុត្ររបស់តិរិដិវច្ឆព្រាហ្មណ៍ ជាអ្នកមានប្រាជ្ញាល្អិត ដល់នូវត្រើយនៃវេទ ឯមាតាខ្ញុំឈ្មោះនាងចន្ទបទុមា ខ្ញុំឈ្មោះកច្ចានៈ មានស្បែកល្អ ខ្ញុំដែលព្រះភូមិបាលបញ្ជូនទៅ ដើម្បីល្បងមើលព្រះសម្ពុទ្ធ ក៏បានឃើញព្រះនាយក ជានាយទ្វារនៃមោក្ខបុរី ទ្រង់សន្សំនូវគុណ ។ ខ្ញុំស្តាប់ពាក្យមិនមានមន្ទិល ជាពាក្យជម្រះនូវភក់គឺគតិក៏បានដល់នូវអមតធម៌ ជាទីរម្ងាប់ ជាមួយនឹងពួកបុរោហិតដ៏សេស ៧ នាក់ ។ ខ្ញុំជាអ្នកដឹងនូវសេចក្តីអធិប្បាយក្នុងបំណងធំនៃព្រះសុគត ព្រះអង្គទ្រង់តាំងខ្ញុំទុកក្នុងទីជាឯតទគ្គៈ ខ្ញុំមានសេចក្តីប្រាថ្នាសម្រេចល្អហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកច្ចាយនត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ មហាកច្ចាយនត្ថេរាបទាន ។**

# អដ្ឋកថា

# កច្ចាយនត្ថេរាបទាន

[ ១២១ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ ក្នុងវគ្គទី ៥៤ ដូចតទៅនេះថា

អបទានរបស់ព្រះមហាកច្ចាយនត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុន ៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះ ៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលគហបតីមហាសាល ចម្រើនវ័យហើយ ថ្ងៃមួយ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បានឃើញភិក្ខុមួយរូប ដែលព្រះសាស្ដាទ្រង់ស្ថាបនាទុកក្នុងតំណែងជាកំពូលជាងភិក្ខុ ដែលចែកអត្ថ ដែលព្រះសាស្ដាត្រាស់ទុកដោយសង្ខេបឲ្យពិស្ដារបាន ខ្លួនឯងក៏ប្រាថ្នានូវតំណែងនោះ ទើបតាំងបណិធានទុកហើយធ្វើបុណ្យមានទានជាដើម អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាសុមេធៈ កើតជាវិជ្ជាធរ ត្រាច់ទៅតាមអាកាស បានឃើញព្រះមានព្រះភាគ ដែលគង់ក្នុងព្រៃមួយកន្លែង មានចិត្តជ្រះថ្លា បានយកផ្កាកណិការមកធ្វើការបូជា ។

ដោយបុណ្យនោះ កុលបុត្តនោះ អន្ទោលទៅមកតែក្នុងសុគតិតែម្យ៉ាងប៉ុណ្ណោះ ក្នុងកាលដែលព្រះមានព្រះភាគព្រះនាមថាកស្សបៈ កុលបុត្តនោះ

កើតក្នុងផ្ទះមានត្រកូលក្នុងនគរពារាណសី កាលព្រះមានព្រះភាគបរិនិព្វានហើយ បានយកដុំឥដ្ឋមាសដែលមានតម្លៃមួយសែន ធ្វើការបូជាក្នុងទីសាងសុវណ្ណចេតិយ បានតាំងសេចក្ដីប្រាថ្នាទុកថា ដោយផលនៃបុណ្យនេះ សូមឲ្យសរីរៈរបស់ខ្ញុំមានពណ៌ដូចមាស គ្រប់ទីដែលកើតចុះ តាំងអំពីនោះមកបានធ្វើតែកុសលកម្មដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះបុរោហិតរបស់ស្ដេចចណ្ឌប្បជ្ជោត ក្នុងក្រុងឧជ្ជេនី ក្នុងថ្ងៃដាក់ឈ្មោះ មាតាគិតថា កូនរបស់អញមានសម្បុរកាយដូចមាស កាន់យកឈ្មោះរបស់ខ្លួនឯងមកដូច្នេះ ទើបដាក់ឈ្មោះថា កញ្ចនមាណព ។ កុលបុត្តនោះ ចម្រើនវ័យហើយ រៀនចប់ត្រៃវេទ អំណឹះឥតអំពីបិតាទៅ ក៏បានទទួលតំណែងបុរោហិត ជំនួសបិតាពោលដោយអំណាចគោត្តប្រាកដហើយថាកច្ចាយនៈ ។ តមកព្រះបាទចណ្ឌប្បជ្ជោតទ្រង់បានដំណឹងថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ទើបបញ្ជូនទៅ ដោយព្រះតម្រាស់ថា លោកអាចារ្យ សូមលោកទៅកាន់នគរនោះ ទូលនិមន្តព្រះសាស្ដាមកកាន់ទីនេះ ។ បុរោហិតនោះ មានខ្លួនជាគម្រប់ ៨ ចូលទៅគាល់ព្រះសាស្ដា ព្រះសាស្ដាទ្រង់បានសម្ដែងធម៌ដល់បុរោហិតនោះហើយ ។ ក្នុងកាលចប់ព្រះធម្មទេសនា បានតាំងនៅក្នុងអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ជាមួយនឹងមនុស្សទាំង ៧ នាក់ទៀត ។

លោកបានសម្រេចអរហត្តផលហើយយ៉ាងនេះ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន

ទើបពោលពាក្យថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះជាដើម ។ ពាក្យនោះមានអត្ថដូចពោលហើយខាងដើមនោះឯង ។ លំដាប់នោះ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា ពួកអ្នកចូរជាភិក្ខុចុះ ។ គ្រានោះ ពួកជនទាំងនោះមានសក់ និងពុកមាត់ប្រមាណ ២ ធ្នាប់ ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចព្រះថេរៈមានវស្សា ៦០ ។ ព្រះថេរៈធ្វើប្រយោជន៍របស់ខ្លួនឲ្យសម្រេចយ៉ាងនេះហើយ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទចណ្ឌប្បជ្ជោតប្រាថ្នានឹងថ្វាយបង្គំព្រះបាទា និងស្តាប់ធម៌របស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលកច្ចានៈ អ្នកនោះឯងចូរទៅកាន់នគរនោះ កាលអ្នកទៅហើយ ព្រះរាជានឹងជ្រះថ្លា ។ ព្រះថេរៈមានខ្លួនជាគម្រប់ ៨ បានទៅកាន់ទីនោះ តាមព្រះពុទ្ធដីការបស់ព្រះសាស្តា ធ្វើឲ្យព្រះរាជាទ្រង់ជ្រះថ្លាហើយ បានប្រតិស្ឋានព្រះសាសនាក្នុងអវន្តីជនបទស្រេចបាច់ហើយ ទើបត្រឡប់មកគាល់ព្រះសាស្តាវិញ ដោយអំណាចសេចក្តីប្រាថ្នាក្នុងកាលមុនរបស់ខ្លួន បករណ៍ទាំង ៣ គឺកច្ចាយនបករណ៍ ១ មហានិរុត្តិប្បករណ៍ ១ នេត្តិប្បករណ៍ ១ ក៏បានប្រាកដហើយកណ្តាលសង្ឃ ។ តមកលោកបានទទួលស្ថាបនាអំពីព្រះមានព្រះភាគ ដែលទ្រង់សន្តោសទុកក្នុងឯតទគ្គៈដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកចែកសេចក្តីធម៌ដែលតថាគតសម្តែងដោយសង្ខេបឲ្យពិស្តារបានដែលជាសាវករបស់តថាគតស្រេចនឹងមហាកច្ចានៈប្រសើរជាងគេ ដូច្នេះ ។ លោកនៅដោយសេចក្តីសុខដែលកើតអំពីអរហត្តផលនោះឯង ។

**អដ្ឋកថាកច្ចាយនត្ថេរាបទាន ចប់**

# វក្កលិត្ថេរាបទានទី ២

[ ១២២ ] ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះនាយកព្រះនាមបទុមុត្តរៈ មានព្រះនាមខ្ពង់ខ្ពស់ មានគុណរាប់មិនបាន ត្រាស់ឡើងហើយក្នុងលោក ។ ព្រះអង្គមានអាការៈនិងព្រះឱស្ឋដូចផ្កាឈូក មានព្រះឆវីវណ្ណល្អ មិនមានមន្ទិលដូចផ្កាឈូក មិនជាប់ចំពាក់ដោយលោក ដូចផ្កាឈូកមិនប្រឡាក់ដោយទឹក ។ ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះនេត្រដូចត្របកឈូក ជាទីត្រេកអរដូចផ្កាឈូក ទ្រង់មានក្លិនវិសេសដូចផ្កាឈូក ព្រោះហេតុនោះឯង ទើបព្រះអង្គទ្រង់ព្រះនាមថា បទុមុត្តរៈ ។ ព្រះអង្គជាច្បងក្នុងលោក ទ្រង់មិនមានមានះ មានឧបមាដូចភ្នែកនៃពួកជនខ្វាក់ ទ្រង់មានភេទស្ងប់រម្ងាប់ ជាកំណាប់នៃគុណ ទ្រង់មានករុណាគុណនិងបញ្ញាគុណដូចសាគរ ។ ជួនកាល ព្រះមហាវីរៈនោះ មានពួកព្រហ្មទេវតា និងអសុរបូជា ព្រះអង្គឧត្តមជាងពួកជន ក្នុងកណ្តាលប្រជុំជន ដែលកុះករដោយទេវតានិងមនុស្ស ។ ព្រះមហាវីរៈ ទ្រង់ញ៉ាំងបរិស័ទទាំងពួងឲ្យត្រេកអរដោយព្រះឱស្ឋមានក្លិនក្រអូបផង ដោយព្រះសូរសៀងដ៏ពីរោះផង ទ្រង់សរសើរសាវ័ករបស់ព្រះអង្គថាសាវ័កនេះជាសទ្ធាធិមុត្ត មានប្រាជ្ញាល្អ មានអាល័យក្នុងការឃើញតថាគត បុគ្គលដទៃបែបនេះ មិនមានដូចវក្កលិភិក្ខុនេះឡើយ ។ កាលនោះ ខ្ញុំកើតជាកូនរបស់ព្រាហ្មណ៍ នៅក្នុងក្រុងហង្សវតី លុះបានស្តាប់ ព្រះពុទ្ធដីកានោះហើយ ក៏ប្រាថ្នានូវតំណែងនោះ ។ កាលនោះ ខ្ញុំនិមន្តព្រះតថាគតទ្រង់មិនមានមន្ទិលនោះ ព្រមទាំងសាវ័កឲ្យគង់ឆាន់អស់ ៧ ថ្ងៃ ក្រោមបាំងសំពត់ ។ ខ្ញុំក្រាបចុះដោយសិរ្សៈ មុជចុះក្នុងសាគរគឺអនន្តគុណរបស់ព្រះអង្គ មានបីតិពេញលេញ ទើប

ពោលពាក្យនេះថា បពិត្រព្រះមហាមុនី ឥសីគឺភិក្ខុអង្គណាជាសទ្ធាធិមុត្តក្នុងសាសនានេះដែលព្រះអង្គសរសើរហើយថា ជាច្បងជាងពួកភិក្ខុអ្នកមានសទ្ធា ខ្ញុំព្រះអង្គសូមបានដូចភិក្ខុនោះ ក្នុងកាលអនាគត ។ លុះខ្ញុំពោលយ៉ាងនេះហើយ ទើបព្រះមហាមុនីទ្រង់ព្យាយាមធំ មានការឃើញមិនកំបាំង ទ្រង់បន្លឺឡើងនូវព្រះពុទ្ធដីកានេះ ក្នុងកណ្ដាលបរិស័ទថា

អ្នកទាំងឡាយ ចូរមើលមាណពនេះ ដែលស្លៀកសំពត់សាច់ម៉ដ្ឋ មានសម្បុរលឿង ជាអ្នកមានអវយវៈដូចគ្រឿងបូជា ដែលបិទដោយមាស ជាទីត្រូវភ្នែកត្រូវចិត្តរបស់ជន ។ មាណពនេះនឹងបានជាសាវករបស់ព្រះគោតមមហេសី ប្រសើរលើសជាងពួកភិក្ខុដែលជាសទ្ធាធិមុត្តក្នុងកាលជាអនាគត ។ មាណពនេះ ទោះកើតជាទេវតាឬជាមនុស្ស ជាអ្នកវៀរចាក សេចក្ដីក្ដៅក្រហាយទាំងពួង បរិបូណ៌ដោយភោគៈទាំងពួង ជាអ្នកអន្ទោលទៅទាំងមានសេចក្ដីសុខ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្ដាព្រះនាម គោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ មាណពនេះ នឹងបានជាធម្មទាយាទរបស់ព្រះអង្គ ជាឱរស ជាធម្មនិម្មិត មាននាមថាវក្កលិ ជាសាវករបស់ព្រះសាស្ដា ។

ខ្ញុំលះរាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយសេសនៃកម្មនោះផង ដោយការតាំងទុកនូវចេតនានោះផង ។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ ជាអ្នកមានសេចក្ដីសុខក្នុងភពទាំងពួង ខ្ញុំមកកើតក្នុងត្រកូលមួយក្នុងក្រុងសាវត្ថី ។ មាតាមានភ័យអំពីបីសាចបៀតបៀននូវខ្ញុំ ដែល

នៅល្អិតទន់ដូចទឹកដោះខាប់កំពុងនៅដេកផ្ងា ល្អិតទន់ដូចត្រួយឈើ ។ មាតាផ្ដេកខ្ញុំ ទៀបបាទមូលរបស់ព្រះមហេសី លុះគាត់មានចិត្តចង់ថ្វាយ ( ទើបពោលថា ) បពិត្រព្រះលោកនាថ ខ្ញុំព្រះអង្គថ្វាយទារកនេះចំពោះព្រះអង្គ បពិត្រព្រះនាយក ខ្ញុំព្រះអង្គសូមដល់នូវព្រះអង្គជាទីពឹងទីរឭក ។ គ្រានោះព្រះមហាមុនីនោះ ដែលជាទីពឹងនៃពួកសត្វអ្នកខ្លាច ទ្រង់ទទួលនូវខ្ញុំដោយព្រះហស្តដ៏ទន់ដូចផ្កា មានក្រឡាប្រទាក់ដូចសំណាញ់ មានជួរស្នាមវិលវង់ដូចចក្ក ។ ចាប់ដើមតាំងពីកាលនោះ ខ្ញុំបានព្រះសម្ពុទ្ធរក្សាហើយ ដោយអំពើមិនគួរគេរក្សាបាន ខ្ញុំរួចស្រឡះចាកព្យាធិទាំងពួង ចម្រើនដោយសេចក្ដីសុខ ។ បើខ្ញុំវៀរចាកព្រះសុគតហើយ ក៏កើតអផ្សុកមួយរំពេច លុះខ្ញុំអាយុ ៧ ឆ្នាំរាប់អំពីកំណើត ក៏បានចូលទៅកាន់ផ្នួស ។ ខ្ញុំមិនឆ្អែតចិត្តនឹងព្រះសុគត ទ្រង់ពេញលេញដោយបារមីទាំងពួង មានព្រះនេត្រខៀវស្រស់ មានព្រះរូបល្អពេញដោយរបស់ស្អាតទាំងអស់ ។ កាលនោះ ព្រះជិនស្រី ទ្រង់ជ្រាបថាខ្ញុំមានសេចក្ដីត្រេកអរក្នុងរូបរបស់ព្រះពុទ្ធហើយ ក៏ទ្រង់ទូន្មានខ្ញុំថា នៃវក្កលិកុំឡើយ អ្នកត្រេកអរក្នុងរូបដែលជនពាលត្រេកអរហើយ នឹងមានប្រយោជន៍អ្វី ព្រោះថាបុគ្គលណាជាបណ្ឌិត បានឃើញព្រះសទ្ធម្ម បុគ្គលនោះ ឈ្មោះថា ឃើញតថាគត បុគ្គលណាកាលមិនឃើញព្រះសទ្ធម្ម សូម្បីឃើញតថាគត បុគ្គលនោះ ក៏ឈ្មោះថាមិនឃើញដែរ ។ រាងកាយជារបស់មានទោសរកទីបំផុតគ្មាន មានឧបមាដូចដើមឈើមានពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់ ។ អ្នកគួរនឿយណាយចាកកាយនោះ គួរឃើញនូវ

ការកើតឡើង និងការសូន្យនៃខន្ធទាំងឡាយក្នុងរូបចុះ អ្នកនឹងដល់នូវព្រះនិព្វាន ជាទីបំផុតនៃកិលេសទាំងពួង ដោយសេចក្តីសុខ ។ លុះព្រះនាយកទ្រង់ស្វែងរកនូវប្រយោជន៍អង្គនោះ ប្រៀនប្រដៅខ្ញុំយ៉ាងនេះរួចហើយ ខ្ញុំក៏ឡើងភ្នំគិជ្ឈកូដ នៅសញ្ជប់សញ្ជឹងត្រង់ប្រកភ្នំ ។ ព្រះជិនស្រីមហាមុនី ទ្រង់ឋិតនៅនាជើងភ្នំ ញុំាងខ្ញុំឲ្យត្រេកអរ ទ្រង់ត្រាស់ហៅខ្ញុំថា ម្នាលវក្កលិ ខ្ញុំបានឮព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយ ។ កាលនោះ ខ្ញុំស្ទុះទៅត្រង់ជ្រោះភ្នំ មានជម្រៅច្រើនរយជួរបុរស ដើរទៅកាន់ផែនដីដោយស្រួល ដោយពុទ្ធានុភាព ។ ព្រះមហាមុនីទ្រង់សម្តែងធម៌ គឺការកើតឡើង និងការសូន្យនៃខន្ធទាំងឡាយម្តងទៀត ខ្ញុំបានដឹងនូវធម៌នោះហើយ ក៏បានដល់នូវអរហត្តផល ។ គ្រានោះ ព្រះសម្ពុទ្ធមានប្រាជ្ញាច្រើន ទ្រង់ដល់នូវទីបំផុតនៃចរណៈ ទ្រង់តាំងខ្ញុំជាកំពូលនៃពួកភិក្ខុដែលជាសទ្ធាធិមុត្ត ក្នុងកណ្តាលបរិស័ទច្រើន ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំ

បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវក្កលិត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ វក្កលិត្ថេរាបទាន ។**

# អដ្ឋកថា
# វក្កលិត្ថេរាបទាន

[ ១២២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះថា អបទានរបស់ព្រះវក្កលិត្ថេរ មានពាក្យផ្ដើមថា **ឥតោ សតសហស្សម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះជិនស្រីដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានទៅកាន់ព្រះវិហារ មួយអន្លើដោយឧបាសកទាំងឡាយដែលទៅគាល់ព្រះសាស្ដា ឈរស្ដាប់ធម៌ខាងចុងបរិស័ទ ឃើញភិក្ខុមួយរូបដែលព្រះសាស្ដាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈជាងភិក្ខុទាំងឡាយអ្នករួចផុតដោយសទ្ធា ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបបានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ បានតាំងបណិធានទុកហើយ ។ ព្រះសាស្ដាទ្រង់ឃើញថា ការប្រាថ្នារបស់កុលបុត្តនោះមិនមានអន្តរាយ ទើបទ្រង់ព្យាករ ។

កុលបុត្តនោះ បំពេញកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ បានកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរសាវត្ថី មាតាបិតាបានដាក់ឈ្មោះថាវក្កលិ ។

បណ្ដាបទទាំងនោះ បទថា **វក្កលិ** នោះ ពាក្យថា **វក្កលិ** ជាឈ្មោះ

នៃវត្ថុដែលមិនល្អ ដូចជាកំហុស ប្រជ្រុយជាដើម **កលិ** គឺទោសរបស់កុលបុត្តនោះទៅប្រាសហើយ វិនាសហើយ ព្រោះកុលបុត្តនោះដូចគ្នានឹងដុំមាសដែលដេញមន្ទិលហើយ ហេតុនោះទើបហៅថា **វក្កលិ** ព្រោះចុះ **វ** អាគម ។ វក្កលិនោះចម្រើនវ័យហើយ រៀនត្រៃវេទ ចប់ក្នុងសិប្បសាស្ត្រ របស់ពួកព្រាហ្មណ៍ ឃើញព្រះសាស្តាហើយ មិនឆ្អែតក្នុងការសម្លឹងមើលសម្បត្តិ គឺព្រះរូបកាយ ទើបដើរតាមព្រះសាស្តាទៅ កុលបុត្តនោះគិតថា បើអញនៅគ្រប់គ្រងផ្ទះ នឹងមិនបានឃើញព្រះសាស្តាសព្វកាល ទើបបួសក្នុងសម្នាក់របស់ព្រះសាស្តាក្នុងវេលាដទៃ វៀរលែងតែពេលឆាន់ និងពេលធ្វើសរីរកិច្ចប៉ុណ្ណោះ ទៅឈរក្នុងទីដែលអាចឃើញព្រះទសពលបាន បោះបង់ការងារដទៃ សម្លឹងមើលព្រះមានព្រះភាគតែម្យ៉ាង ។ ព្រះសាស្តា ទ្រង់រង់ចាំឲ្យព្រះថេរៈមានញាណចាស់ក្លា ទោះបីព្រះថេរៈសម្លឹងមើលព្រះរូបតែម្យ៉ាង ក៏មិនបានត្រាស់ពាក្យណាមួយ រហូតដល់ថ្ងៃមួយ ទើបត្រាស់ថា ម្នាលវក្កលិ ប្រយោជន៍អ្វីដោយការដែលអ្នកមើលរូបកាយស្អុយនេះ ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញតថាគត បុគ្គលណាឃើញតថា-គត បុគ្គលនោះឈ្មោះថាឃើញធម៌ ម្នាលវក្កលិ កាលឃើញធម៌ ក៏ឈ្មោះថាឃើញតថាគត កាលព្រះសាស្តាត្រាស់ទូន្មានយ៉ាងនេះ ព្រះថេរៈក៏មិនអាចលះបង់ការសម្លឹងមើលព្រះសាស្តា ហើយទៅក្នុងទីដទៃបាន ។ បន្ទាប់អំពីនោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា បើភិក្ខុនេះមិនបាននូវសេចក្តីសង្វេគ នឹងមិនបានត្រាស់ដឹង លុះដល់កៀកថ្ងៃចូលវស្សា ទើបទ្រង់បណ្តេញព្រះថេរៈទៅ

ដោយព្រះតម្រាស់ថា ម្នាលវក្កលិ ចូរអ្នកចៀសចេញទៅ ព្រះថេរៈត្រូវព្រះសាស្តាបណ្តេញ ទើបមិនអាចនៅចំពោះព្រះភក្រ្តនៃព្រះសាស្តាបាន គិតថា អញមិនបានឃើញព្រះសាស្តា នឹងមានជីវិតធ្វើអ្វី ដូច្នេះហើយ ឡើងទៅត្រង់មាត់ជ្រោះលើភ្នំគិជ្ឈកូដ ។ ព្រះសាស្តាទ្រង់ជ្រាបការប្រព្រឹត្តទៅនោះ របស់លោកហើយ ទ្រង់ព្រះតម្រិះថា ភិក្ខុនេះ បើមិនបានពាក្យលួងលោមចិត្តអំពីតថាគត នឹងសាបសូន្យឧបនិស្ស័យនៃមគ្គនិងផល ទើបទ្រង់បង្ហាញព្រះកាយបញ្ចេញឱកាស ត្រាស់ព្រះគាថា ( ក្នុងធម្មបទ ) ថា

**បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**

*ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។*

ទ្រង់លាព្រះហស្តត្រាស់ថា មកចុះវក្កលិ ។ ព្រះថេរៈធ្វើនូវបីតិនិងសោមនស្សដ៏មានកម្លាំងឲ្យកើតឡើងថា អញឃើញព្រះទសពលហើយ សូម្បីព្រះតម្រាស់ថា ចូរមក អញក៏បានឮហើយ មិនដឹងថាខ្លួននៅក្នុងទីណា ទើបលោតទៅក្នុងឱកាស ចំពោះព្រះភក្រ្តព្រះសាស្តា យកជើងម្ខាងជាន់ភ្នំ ពិចារណាព្រះគាថាដែលព្រះសាស្តាបានត្រាស់ប្រទាន សង្កត់បីតិក្នុងអាកាសនោះឯង សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ រឿងដែលពោលមកនេះ មកក្នុងអដ្ឋកថាអង្គុត្តរនិកាយ និងក្នុងអដ្ឋកថាធម្មបទ ។ ឯក្នុងអដ្ឋកថានេះ

អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះថា ព្រះវក្កលិ លុះបានទទួលឱវាទរបស់ព្រះសាស្តាដោយន័យជាដើមថា ម្នាលវក្កលិ ប្រយោជន៍អ្វីដោយការមើលកាយស្អុយនេះ ដូច្នេះហើយ ក៏នៅលើភ្នំគិជ្ឈកូដ ផ្តើមចម្រើនវិបស្សនា ព្រោះភាពជាអ្នកមានសទ្ធាច្រើន ទើបវិបស្សនាមិនឈមចុះកាន់វិថី ព្រះមានព្រះភាគ ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ជម្រះកម្មដ្ឋានឲ្យវក្កលិនោះ មិនអាចធ្វើវិបស្សនាឲ្យដល់ទីបំផុតបានឡើយ ។

តមក អាពាធទាក់ទងដោយខ្យល់កើតឡើងដល់ព្រះថេរៈ ព្រោះខ្វះអាហារ ព្រះមានព្រះភាគជ្រាបថា ព្រះថេរៈអាពាធទាក់ទងដោយរោគខ្យល់បៀតបៀន ទើបយាងទៅក្នុងទីនោះ កាលនឹងត្រាស់សួរ ទើបត្រាស់ថា

ម្នាលភិក្ខុ អ្នកត្រូវរោគដែលកើតអំពីខ្យល់ គ្របសង្កត់ហើយ
នៅក្នុងព្រៃធំ មានគោចរលះបង់ហើយ ( ក្រចតុប្បច្ច័យ )
ជាទីសៅហ្មង តើនឹងធ្វើដូចម្តេច ដូច្នេះ ។

ព្រះថេរៈបានស្តាប់ព្រះតម្រាស់នោះហើយ ទើបក្រាបទូល ៤ គាថាថា

ខ្ញុំព្រះអង្គ ផ្សាយចិត្តទៅកាន់កាយទាំងមូល ដោយសុខដែល
កើតអំពីបីតិដ៏លើសលុប អត់ទ្រាំនូវបច្ច័យដ៏សៅហ្មងនៅក្នុង
ព្រៃធំ ។ ខ្ញុំព្រះអង្គចម្រើនសតិប្បដ្ឋានទាំងឡាយផង សម្មប្ប-
ធានផង ឥទ្ធិបាទផង ឥន្ទ្រិយផង ពលៈផង ចម្រើនពោជ្ឈង្គៈ
ផង អដ្ឋង្គិកមគ្គផង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គឃើញ ( នូវ
សព្រហ្មចារីបុគ្គលទាំងឡាយ ) អ្នកមានព្យាយាមតឹងតែង

*ហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានព្យាយាមប្រឹង ប្រែងដ៏មាំអស់កាលជានិច្ច មានសេចក្តីព្រមព្រៀងគ្នា ប្រកប ដោយភាពជាសមណៈនៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គនឹករឿយៗ នូវព្រះសម្ពុទ្ធ ព្រះអង្គមានខ្លួនទូន្មានបានហើយ មានព្រះទ័យ តាំងមាំហើយ មិនខ្ជិលច្រអូសអស់យប់និងថ្ងៃនៅ ក្នុងព្រៃធំ ដូច្នេះ ។*

*អត្ថនៃគាថាទាំងនេះ ខ្ញុំបានពោលហើយក្នុងអដ្ឋកថាថេរគាថានោះឯង ។ ព្រះថេរៈព្យាយាមចម្រើនវិបស្សនាយ៉ាងនេះ បានសម្រេចអរហត្តហើយ ។ ព្រះវក្កលិត្ថេរនោះ កាលសម្រេចអរហត្តហើយ បានរឭកដល់បុព្វកម្មរបស់ ខ្លួន កើតនូវសោមនស្ស កាលនឹងប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាល មុន ទើបពោលពាក្យថា* **ឥតោ សតសហស្សម្ហិ** *ដូច្នេះជាដើម ។*

*បណ្តាបទទាំងនោះ បទថា* **ឥតោ** *សេចក្តីថា ក្នុងទីបំផុតមួយសែនកប្ប រាប់អំពីភទ្ទកប្បដែលព្រះពុទ្ធអង្គដំបូង ( ព្រះកកុសន្ធៈ ) ទ្រង់កើតឡើង ។ បទថា* **បទុមាការវទនោ** *បានដល់ មានព្រះភក្ត្រមានលម្អដូចផ្កាបទុមដែល រីកល្អហើយ ។ បទថា* **បទុមបត្តក្ខោ** *សេចក្តីថា មានព្រះនេត្រដូចគ្នានឹង ត្របកឈូកស ។ បទថា* **បទុមុត្តរគន្ធោវ** *សេចក្តីថា មានព្រះឱស្ឋមាន ក្លិនផ្កាឈូក ។ បទថា* **ចក្ខុទំ ធយន្ធូបមោ** *សេចក្តីថា ដូចភ្នែករបស់ពួក សត្វដែលប្រាសចាកភ្នែក គឺទ្រង់ប្រទានបញ្ញាចក្ខុជាដើមឲ្យដល់ពួកសត្វទាំង- ឡាយ ដោយព្រះធម្មទេសនា ។ បទថា* **សន្តវេសោ** *បានដល់ ទ្រង់មានការ*

ស្ងប់រម្ងាប់ជាសភាវៈ គឺទ្រង់មានឥរិយាបថស្ងប់រម្ងាប់ ។ បទថា **គុណាធិធិ** បានដល់ កំណាប់នៃគុណទាំងឡាយ អធិប្បាយថា ជាទីទទួលនូវពួកនៃព្រះគុណទាំងអស់ ។ បទថា **ករុណាមតិអាករោ** សេចក្ដីថា ជាប្រភពកើត គឺជាទីទទួលនូវសេចក្ដីករុណាដែលធ្វើចិត្តរបស់សាធុជនទាំងឡាយ ឲ្យញាប់ញ័រ និងជាទីទទួលនូវការដឹងដែលជាគ្រឿងវាស់ និងសម្រេចថា ប្រយោជន៍ ឬមិនមែនប្រយោជន៍ ។ បទថា **ព្រហ្មាសុរសុរច្ចិតោ** សេចក្ដីថា ជាបុគ្គលដែលព្រហ្ម អសុរ និងទេវតា គោរពបូជាហើយ ។ បទថា **មធុរេន រុតេន ច** ភ្ជាប់សេចក្ដីថា ទ្រង់ញុំាងជនទាំងអស់ឲ្យត្រេកអរដោយសំឡេងដ៏ពីរោះដូចសត្វករវិក ។ បទថា **សន្តាវី សាវកំ សកំ** សេចក្ដីថា ទ្រង់បានសរសើរ គឺទ្រង់ធ្វើនូវការសរសើរ នូវសាវករបស់ព្រះអង្គ ដោយព្រះធម្មទេសនាដ៏ពីរោះ ។ បទថា **សទ្ធាធិមុត្តោ** សេចក្ដីថា បង្អោនទៅ គឺតាំងមាំក្នុងព្រះសាសនា ដោយសទ្ធា គឺការជឿ ។ បទថា **មម ឧស្សុក្ខលាលសោ** សេចក្ដីថា ខ្វល់ខ្វាយ មានចិត្តក្នុងការមើលតថាគត ។ បទថា **តំ ឋានមភិរោចយឹ** សេចក្ដីថា ខ្ញុំពេញចិត្ត ត្រូវការ ប្រាថ្នាតំណែងសទ្ធាធិមុត្តនោះ ។ បទថា **បីតមដ្ឋនិវាសនំ** សេចក្ដីថា ដែលស្លៀកសំពត់សាច់ម៉ដ្តមានពណ៌ដូចមាស ។ បទថា **ហេមយញ្ញោបចិតង្គំ** សេចក្ដីថា មានអវយវៈដែលបុណ្យសន្សំឲ្យដូចគ្នានឹងព្យូរដោយសង្វារមាស ។ បទថា **ជលានិតសុខុមាលំ មំ** សេចក្ដីថា ជាអ្នកមានដៃនិងជើងល្អិតសុខុមដូចទឹកដោះខាប់ ។ បទថា **ជាតបល្លវកោមលំ** សេចក្ដីថា ទន់ដូចស្លឹកអសោកខ្ចីនិងត្របកឈូក ។ បទថា **បិសាចី-**

**ភយតជ្ជិតា** សេចក្តីថា ក្នុងគ្រានោះ ស្រីមេមត់ម្នាក់ គឺអារក្សម្នាក់ គំរាមធ្វើឲ្យខ្ញុំជាបុគ្គលបែបនោះ គឺជាកុមារឲ្យខ្លាច មាតាបិតាបានឲ្យខ្ញុំដេកទៀបបាទមូលរបស់ព្រះសម្មាសម្ពុទ្ធ អ្នកស្វែងរកគុណធំ អធិប្បាយថា មាតាបិតារបស់ខ្ញុំមានចិត្តតក់ស្លុត គឺកើតនូវការខ្លាច បានក្រាបទូលថា បពិត្រព្រះលោកនាថ ទ្រង់ជាលោកនាយក ខ្ញុំសូមថ្វាយទារកនេះដល់ព្រះអង្គ សូមទ្រង់ជាទីពឹងរបស់ទារកនេះផងចុះ ។ បទថា **តទា បដិគ្គហិ សោ មំ** សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលដែលមាតាបិតាថ្វាយខ្ញុំហើយនោះ ព្រះមានព្រះភាគអង្គនោះ ទ្រង់បានទទួលខ្ញុំដោយបាតព្រះហស្តដ៏ទន់ គឺបាតព្រះហស្តដ៏បរិសុទ្ធមានបណ្តាញ គឺប្រកបដោយក្រឡា បានដល់ ជាសំណាញ់ គឺជាស្នាមរូបចក្កជាដើម ។ បទថា **សព្វធារមិសម្ភូតំ** សេចក្តីថា ដែលកើតព្រមដោយព្រះបារមីសព្វយ៉ាង មានទានបារមីជាដើម ។ បទថា **ធីលក្ខិណយធំ វរំ** បានដល់ មានកែវភ្នែកពណ៌ខៀវស្និទ្ធ កើតអំពីបុញ្ញសម្ភារ អធិប្បាយថា បានមើលព្រះរូប ដូចជាព្រះហស្ត ព្រះបាទ និងព្រះសិរសាជាដើម របស់ព្រះមានព្រះភាគដែលមានលម្អគ្រប់យ៉ាង គឺដែលជេរជាស គឺរួមទុកដោយវណ្ណៈសណ្ឋានដ៏ល្អព្រមសព្វយ៉ាង ភ្លាប់សេចក្តីថា ខ្ញុំនៅ ( មើល ) ដោយមិនឆ្អែត ។

បទថា **តទា មំ ចរណន្តគោ** សេចក្តីថា កាលខ្ញុំបានសម្រេចអរហត្តហើយនោះ ព្រះមានព្រះភាគដែលទ្រង់ធ្វើទីបំផុតនៃចរណធម៌ ១៥ ប្រការមានសីលជាដើម អធិប្បាយថា ដែលដល់ទីបំផុត គឺទ្រង់ធ្វើឲ្យបរិបូណ៌ ។

បាលីថា **មរណន្តគោ** ដូច្នេះក៏មាន អធិប្បាយថា ដល់នូវទីបំផុតនៃសេចក្តីស្លាប់នោះគឺព្រះនិព្វាន ភ្ជាប់សេចក្តីថា ទ្រង់បានតាំងទុកក្នុងតំណែងដ៏ប្រសើរជាងពួកភិក្ខុ ដែលជាសទ្ធាធិមុត្ត ។ លោកពោលអធិប្បាយទុកថា លំដាប់នោះ ព្រះសាស្តាគង់កណ្តាលភិក្ខុសង្ឃ ទ្រង់ស្ថាបនាខ្ញុំទុកក្នុងតំណែងឯតទគ្គៈ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកមានសទ្ធាស៊ប់ដែលជាសាវករបស់តថាគត ស្រេចនឹងវក្កលិប្រសើរជាងគេ ដូច្នេះ ។ ពាក្យដ៏សេស មានអត្ថដឹងបានដោយងាយនោះឯង ។

## អដ្ឋកថាវក្កលិត្ថេរាបទាន ចប់

# មហាកប្បិនត្ថេរាបទានទី ៣

[ ១២៣ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់រុងរឿងដូចព្រះអាទិត្យរះឡើងឰដ៏អជតាកាសក្នុងសរទកាល ។ ព្រះអង្គ ទ្រង់ញ៉ាំងផ្កាឈូកគឺពួកវិនេយ្យសត្វឲ្យរីកដោយពន្លឺគឺព្រះពុទ្ធដីកា ព្រះនាយកទ្រង់ញ៉ាំងភក់គឺកិលេសឲ្យរីងស្ងួត ដោយរស្មីគឺប្រាជ្ញា ។ ព្រះនាយកទ្រង់សម្លាប់យសរបស់ពួកតិរ្ថិយដោយប្រាជ្ញា ដូចកែវជីរ ព្រះអង្គប្រកាសធម៌ក្នុងទីទាំងពួង ដូចព្រះអាទិត្យញ៉ាំងយប់និងថ្ងៃឲ្យភ្លឺសព្វ ។ ព្រះអង្គជាទីកើតនៃគុណទាំងឡាយ ដូចជាសាគរជាទីកើតនៃរតនៈទាំងឡាយ ទ្រង់តែងបង្អុរភ្លៀងគឺធម៌ ឲ្យដល់ពួកសត្វ ដូចមេឃបង្អុរភ្លៀង ។ កាលនោះ ខ្ញុំជាចៅក្រម ( អ្នកកាត់ក្តី ) ក្នុងនគរឈ្មោះហង្សវតី បានចូលទៅស្តាប់ធម៌របស់ព្រះមុនី ព្រះនាមបទុមុត្តរៈ ដែលកំពុងប្រទានឱវាទដល់ពួកភិក្ខុ កំពុងប្រកាសនូវគុណនៃសាវ័ក អ្នកមានសតិ ទ្រង់ញ៉ាំងចិត្តរបស់ខ្ញុំឲ្យរីករាយ ។ ខ្ញុំបានស្តាប់ហើយ ក៏មានបីតិ មានចិត្តរីករាយ និមន្តព្រះតថាគតព្រមទាំងភិក្ខុជាសិស្សឲ្យឆាន់ ហើយប្រាថ្នានូវតំណែងនោះ ។ កាលនោះ ព្រះនាយកទ្រង់មាន ចំណែកប្រៀបស្មើដោយសត្វហង្ស ទ្រង់បញ្ចេញព្រះវាចាដូចជាស្គរមានសំឡេងដូចសត្វហង្ស ដូច្នេះថា

អ្នកទាំងឡាយចូរមើលមហាមាត្យនុ៎ះ ជាអ្នកក្លៀវក្លាក្នុងការកាត់ក្តី ជាអ្នកមានរោមវៀវ មានចុងងង មានភ្នែកនិងមុខស្រស់បស់ល្អ រុងរឿងដូចសម្បុរកែវជុមុត្ត កំពុងក្រាបទៀបបាទមូលនៃតថាគត ជាអ្នកមានយសធំដោយបរិវារច្រើនដែលស្តេចទ្រង់ប្រទានឲ្យ ឯមហាមាត្យនុ៎ះ ប្រាថ្នានូវតំណែងរបស់

ភិក្ខុដែលជាអ្នកឈ្លាសក្នុងពាក្យ ដោយចិត្តរីករាយ មហាមាត្យ នុ៎ះនឹងមិន ទៅកាន់ទុគ្គតិអស់មួយសែនកប្ប ដោយចង្ហាន់បិណ្ឌបាតនេះផង ដោយការ បរិច្ចាគនេះផង ដោយការតាំងសេចក្ដីប្រាថ្នានេះផង ។ មហាមាត្យនុ៎ះនឹង ទទួលនូវសួស្តីរបស់ទេវតាក្នុងទេវលោក នូវភាពជាធំក្នុងមនុស្ស នឹងបាន ដល់នូវព្រះនិព្វានដោយសេសសល់នៃផល ។ ក្នុងកប្បទីមួយសែន អំពី កប្បនេះ ព្រះសាស្ដាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹង ត្រាស់ឡើងក្នុងលោក ។ ឯមហាមាត្យនេះនឹងបានជាធម្មទាយាទរបស់ ព្រះ គោតមនោះ ជាឱរសេ ជាធម្មនិម្មិត មាននាមថាកប្បិនៈ ជាសាវ័ករបស់ព្រះ សាស្ដានោះ ។

លំដាប់នោះ ខ្ញុំធ្វើសក្ការៈដ៏ល្អក្នុងសាសនារបស់ព្រះជិនស្រី លុះខ្ញុំលះ រាងកាយជារបស់មនុស្សហើយ ទៅកើតក្នុងឋានតុសិត ។ ខ្ញុំបានគ្រប់គ្រងនូវ ទេវរាជសម្បត្តិ និងមនុស្សរាជសម្បត្តិ ដោយស្កប់ស្កល់ហើយ ទើបខ្ញុំមក កើតក្នុងកំណើតកេណិយៈ ជិតក្រុងពារាណសី ។ ខ្ញុំមានបរិវារមួយសែន មាន ភរិយា បានចូលទៅបម្រើព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ យើងខ្ញុំទាំងអស់គ្នា ញ៉ាំងព្រះបច្ចេកពុទ្ធឲ្យឆាន់ផង ឲ្យស្លៀកពាក់ត្រៃចីវរផង អស់ ៣ ខែ ទើប ច្យុតចាកអត្តភាពនោះ ទៅកើតក្នុងឋានតាវត្តិង្ស ។ យើងទាំងអស់ច្យុតចាក ទេវតានោះ មកកាន់អត្តភាពរបស់មនុស្ស កើតក្នុងកុក្កុដបុរី ជិតព្រៃហិម ពាន្ត ។ ខ្ញុំជារាជបុត្តមាននាមថាកប្បិនៈ មានយសធំ ឯទេវតាដ៏សេស មក កើតក្នុងត្រកូលអាមាត្យហែហមខ្ញុំ ខ្ញុំដល់នូវសេចក្ដីសុខដោយរាជសម្បត្តិដ៏ធំ

សម្រេចសេចក្តីប្រាថ្នាទាំងពួង ខ្ញុំបានឮនូវការកើតឡើងនៃព្រះពុទ្ធ ដោយពួកពាណិជប្រាប់ថា ព្រះពុទ្ធត្រាស់ឡើងហើយក្នុងលោក ទ្រង់ជាបុគ្គលឯក ឥតមានបុគ្គលស្មើ ព្រះអង្គនោះ ទ្រង់ប្រកាសនូវព្រះសទ្ធម្ម គឺអមតៈ ជាសុខដ៏ឧត្តម ។ ឯពួកសិស្សរបស់ព្រះសម្ពុទ្ធអង្គនោះ ប្រកបព្យាយាមល្អ រួចស្រឡះចាកកិលេស ជាអ្នកមិនមានអាសវៈ លុះខ្ញុំស្តាប់ពាក្យរបស់ពាណិជទាំងនោះហើយ ក៏ធ្វើសក្ការៈចំពោះពួកពាណិជនោះ ។ ខ្ញុំព្រមទាំងអាមាត្យ ជាអ្នករាប់អានព្រះពុទ្ធ សូវលះរាជ្យចេញដើរទៅ បានឃើញស្ទឹងមហាចន្ទា មានទឹកពេញព្រៀប ។ ជាស្ទឹងមិនមានកំពង់ មិនមានឈើស្ន ( ស្ពាន ) គេឆ្លងបានដោយក្រ ជាស្ទឹងមានខ្សែទឹករហ័ស ខ្ញុំរឭកគុណព្រះសម្ពុទ្ធហើយ ក៏បានឆ្លងដោយសួស្តី ដោយគិតថា ប្រសិនបើព្រះសម្ពុទ្ធទ្រង់ឆ្លងនូវខ្សែទឹកគឺភពរួចហើយ ដល់នូវព្រះនិព្វានជាទីបំផុតនៃលោក ទ្រង់ជ្រាបច្បាស់ ( ត្រាស់ឡើងពិតមែន ) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេចដោយពាក្យសច្ចៈនេះ ។ ប្រសិនបើមគ្គជាដំណើរទៅកាន់ទីស្ងប់រម្ងាប់ ជាទីឲ្យនូវការរួចស្រឡះកិលេស ជាទីស្ងប់រម្ងាប់ ជាទីសុខ ( មានពិតមែន ) ដំណើររបស់ខ្ញុំសូមឲ្យសម្រេចដោយពាក្យសច្ចៈនេះ ។ ប្រសិនបើព្រះសង្ឃជាអ្នកឆ្លងផ្លូវលំបាករួចហើយ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ( មានពិតមែន ) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេចដោយពាក្យសច្ចៈនេះ ។ លុះខ្ញុំធ្វើសច្ចៈដ៏ប្រសើររួចហើយ ទឹកស្ទឹងក៏វាងខ្វះអស់អំពីផ្លូវ លំដាប់នោះ ខ្ញុំឆ្លងឡើងលើត្រើយស្ទឹងជាទីមនោរម្យ ដោយសុវត្ថិភាព ។ ខ្ញុំបានឃើញព្រះពុទ្ធទ្រង់គង់នៅ មានរស្មីដូចព្រះអាទិត្យដែល

រះឡើង ទ្រង់រុងរឿងដូចភ្នំមាស មានពន្លឺដូចដើមឈើប្រចាំទ្វីប ។ មានពួកសាវកចោមរោម ដូចព្រះចន្ទដែលប្រកបដោយពួកផ្កាយ ឬដូចជាទឹកហូរដែលទេវតាបង្អុរចុះមក ទ្រង់ជាទីរីករាយរបស់ពួកជន ។ ខ្ញុំព្រមទាំងអាមាត្យលុះថ្វាយបង្គំហើយ ចូលទៅកាន់ទីសមគួរ លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបអធ្យាស្រ័យ ហើយបានសម្តែងធម៌ ។ លុះយើងខ្ញុំស្តាប់ធម៌ស្អាត មិនមានមន្ទិល ទើបក្រាបទូលព្រះជិនស្រីថា បពិត្រព្រះអង្គដ៏ទ្រង់ព្យាយាមធំ សូមព្រះអង្គបំបួស យើងខ្ញុំនឹងឆ្លងភពទាំងឡាយ ។ ព្រះសម្ពុទ្ធជាព្រះមុនីទី ៧ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតពោលល្អហើយដល់អ្នកទាំងឡាយ ជាធម៌ប្រព្រឹត្តទៅដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយៈចុះ ។ ពួកយើងខ្ញុំទាំងអស់ ទ្រទ្រង់ភេទជាភិក្ខុ ដំណាលនឹងព្រះពុទ្ធដីកា លុះបានឧបសម្បទាហើយ ក៏បានជាសោតាបន្នបុគ្គលក្នុងសាសនា ។ លំដាប់នោះ ព្រះនាយកទ្រង់ស្តេចទៅកាន់វត្តជេតពន ទ្រង់ប្រៀនប្រដៅខ្ញុំ ឯខ្ញុំដែលព្រះជិនស្រីទ្រង់ប្រៀនប្រដៅហើយក៏បានដល់នូវព្រះអរហត្ត ។ លំដាប់នោះ ខ្ញុំប្រដៅពួកភិក្ខុមួយពាន់រូប ពួកភិក្ខុទាំងមួយពាន់នោះ ធ្វើតាមពាក្យប្រៀនប្រដៅរបស់ខ្ញុំ ក៏ទៅជាអ្នកមិនមានអាសវៈក្នុងកាលនោះ ។ ព្រះជិនស្រី ទ្រង់ត្រេកអរក្នុងគុណនោះ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈក្នុងកណ្តាលមហាជនថា កប្បិនភិក្ខុ ជាកំពូលនៃពួកសាវកអ្នកឲ្យឱវាទភិក្ខុ ។ ព្រះជិនស្រី ទ្រង់សម្តែងផលកម្មដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែនក្នុងសាសនានេះ ខ្ញុំមានចិត្តរួចស្រឡះហើយ ដូចជាសន្ទុះនៃ

កូនសរ ខ្ញុំដុតកិលេសទាំងឡាយរបស់ខ្ញុំហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកប្បិនត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ មហាកប្បិនត្ថេរាបទាន ។

# អដ្ឋកថា
# មហាកប្បិនត្ថេរាបទាន

[ ១២៣ ] គប្បីជ្រាបពាក្យអធិប្បាយ ក្នុងអបទានរបស់ព្រះមហាកប្បិ-នត្ថេរ ដែលមានពាក្យផ្ដើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ បានកើតក្នុងផ្ទះមានត្រកូលក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ កាលកំពុងស្ដាប់ព្រះធម្មទេសនាក្នុងសម្នាក់របស់ព្រះសាស្ដា បានឃើញភិក្ខុមួយរូបដែលព្រះសាស្ដាទ្រង់ស្ថាបនាទុកក្នុងតំណែងប្រសើរជាងភិក្ខុទាំងឡាយ ខាងឲ្យឱវាទ បានធ្វើនូវកម្មដ៏ក្រៃលែងឡើង ហើយប្រាថ្នាតំណែងនោះ ។

កុលបុត្តនោះ បានធ្វើកុសលកម្មទុកក្នុងជាតិនោះ ដរាបដល់អស់ជីវិតអន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ហើយកើតក្នុងផ្ទះរបស់មេជាងតម្បាញក្នុងស្រុកជាងតម្បាញមួយកន្លែងមិនឆ្ងាយអំពីក្រុងសាវត្ថី ក្នុងគ្រានោះ ព្រះបច្ចេកពុទ្ធប្រមាណ ១០០០ អង្គ ដែលនៅត្រង់ភ្នំហិមពាន្ត ៨ ខែ មកមកនៅក្នុងនគរក្នុងរដូវភ្លៀង ៤ ខែ ព្រះបច្ចេកពុទ្ធទាំងនោះ ហោះចុះមកព្រមគ្នាសម្រាកក្នុងទីមិនឆ្ងាយអំពីនគរពារាណសី ។ បានបញ្ជូនព្រះបច្ចេកពុទ្ធ ៨ អង្គទៅគាល់ព្រះរាជាដោយពាក្យថា ចូរទៅសូមកម្មាំងមក ដើម្បីធ្វើសេនាសនៈ ។ ក្នុងគ្រានោះ ព្រះរាជាទ្រង់មានពិធីវប្បមង្គល ( ច្រត់ព្រះនង្គ័ល ) ទ្រង់ជ្រាបថា ព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ទើបយាងចេញមកសួរដល់

ហេតុដែលលោកនាំគ្នាមក ហើយត្រាស់ថា បពិត្រលោកម្ចាស់ ថ្ងៃនេះមិនមែនឱកាស ស្អែកនេះ មានពិធីប្រត់ព្រះនង្គ័ល ក្នុងថ្ងៃទី ៣ ខ្ញុំនឹងធ្វើប្រគេន ហើយយាងចូលទៅ ដោយមិននិមន្តព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធចេញទៅ ដោយគិតថា នឹងទៅរកស្រុកដទៃ ។

ក្នុងសម័យនោះ ភរិយារបស់ជាងតម្បាញ ដើរទៅកាន់ក្រុងពារាណសី ដោយការងារឯណានីមួយ បានឃើញព្រះបច្ចេកពុទ្ធទាំងនោះ ទើបសាកសួរថា លោកម្ចាស់និមន្តមកពុំជួកាលព្រោះហេតុណា ត្រូវការអ្វីឬ ព្រះបច្ចេកពុទ្ធទាំងនោះ បានពោលរឿងតាំងអំពីដើមឲ្យស្តាប់ ។ ស្រីដែលសម្បូរដោយសទ្ធា ដល់ព្រមដោយបញ្ញា បានស្តាប់រឿងនោះហើយ ទើបនិមន្តថា បពិត្រលោកម្ចាស់ ស្អែកនេះ និមន្តទទួលភិក្ខារបស់ពួកខ្ញុំ ។ ព្រះបច្ចេកពុទ្ធពោលថា នែប្អូនស្រី ពួកអាត្មាមានច្រើន ។ ស្រីនោះសួរថា មានប៉ុន្មានអង្គ ព្រះបច្ចេកពុទ្ធឆ្លើយថា មានប្រមាណ ១០០០ អង្គ ។ ស្រីនោះពិតថា បពិត្រលោកម្ចាស់ ក្នុងស្រុករបស់ពួកខ្ញុំមានមនុស្សប្រមាណ ១០០០ ដូចគ្នា នឹងប្រគេនភិក្ខាដល់លោកម្ចាស់ម្នាក់មួយអង្គ សូមនិមន្តទទួលភិក្ខាចុះ ខ្ញុំនឹងឲ្យជាងធ្វើលំនៅសម្រាប់លោកម្ចាស់ទាំងឡាយ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ទទួលនិមន្តន៍ ។

ស្រីនោះចូលទៅកាន់ស្រុកឃោសនាថា នែអ្នកទាំងឡាយ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធប្រមាណ ១០០០ អង្គ បាននិមន្តលោកម្ចាស់ហើយ ពួកអ្នកចូរនាំគ្នាត្រៀមទីអង្គុយនិងអាហារ មានបបរនិងកត្តជាដើម សម្រាប់លោក

ម្ចាស់ទាំងឡាយ ដូច្នេះហើយ ឲ្យមនុស្សនាំគ្នាសាងមណ្ឌបកណ្តាលស្រុក បានក្រាលអាសនៈទាំងឡាយទុក ។ ស្អែកឡើង ទើបនិមន្តឲ្យព្រះបច្ចេកពុទ្ធទាំងឡាយគង់ហើយ អង្គាសដោយខាទនីយភោជនីយាហារដ៏ប្រណីត ក្នុងពេលស្រេចភត្តកិច្ច បាននាំស្រីទាំងអស់ក្នុងស្រុកនោះមកថ្វាយបង្គំព្រះបច្ចេក-ពុទ្ធទាំងឡាយ មួយអន្លើដោយស្រីទាំងនោះ និមន្តលោកឲ្យទទួលប្តេជ្ញាដើម្បីនៅចាំវស្សាអស់ត្រៃមាស ហើយបានឃោសនាក្នុងស្រុកទៀតថា នែអ្នកទាំងឡាយ បុរសម្នាក់អំពីត្រកូលមួយ ចូរកាន់កាំបិតនិងពូថៅជាដើម ចូលព្រៃនាំទព្វសម្ភារមក ហើយសាងលំនៅសម្រាប់លោកម្ចាស់ទាំងឡាយចុះ ។ ពួកអ្នកស្រុកបានស្តាប់ពាក្យរបស់នាងហើយ ត្រកូលមួយសាងបណ្ណសាលាមួយខ្នង ធ្វើការងាររកសាងទាំងយប់ទាំងថ្ងៃ រហូតបានបណ្ណសាលា ១០០០ ខ្នងស្រេចបាច់ហើយ ពិតព្រះបច្ចេកពុទ្ធ ដែលចូលទៅក្នុងបណ្ណសាលារបស់ខ្លួនថា ខ្ញុំនឹងបម្រើលោកម្ចាស់ដោយសេចក្តីគោរព ខ្ញុំនឹងបម្រើលោកម្ចាស់ដោយសេចក្តីគោរព ហើយនាំគ្នាបម្រើ លុះដល់ពេលចេញវស្សាហើយ ទើបករិយាជាងតម្បាញនោះពោលថា ពួកអ្នកចូរត្រៀមសំពត់ចីវរសម្រាប់ព្រះបច្ចេកពុទ្ធដែលចាំវស្សាក្នុងបណ្ណសាលារបស់ខ្លួនចុះ ហើយប្រគេនសំពត់ចីវរដែលមានតម្លៃមួយពាន់ ដល់ព្រះបច្ចេកពុទ្ធមួយអង្គមួយផ្ទាំង ។ ចេញវស្សាហើយ ព្រះបច្ចេកពុទ្ធទាំងឡាយធ្វើអនុមោទនាហើយចៀសចេញទៅ ពួកអ្នកស្រុកដែលធ្វើបុញ្ញកម្មនេះហើយ ចុតិចាកអត្តភាពនោះ បានទៅកើតក្នុងឋានតាវត្តិង្សទេវលោក បានឈ្មោះថា គណទេវតា ។

ទេវតាទាំងនោះ បានសោយទិព្វសម្បត្តិក្នុងឋានតាវត្តិង្សទេវលោកនោះហើយ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមថាកស្សបៈ បានមកកើតក្នុងផ្ទះរបស់កុដុម្ពិកៈ មេជាងតម្បាញក្នុងកាលមុន បានមកកើតជាកូនប្រុសនៃប្រធានកុដុម្ពិកៈ ភរិយារបស់មេជាងតម្បាញក្នុងកាលមុន ក៏បានមកកើតជាកូនស្រីរបស់ប្រធានកុដុម្ពិកៈម្នាក់ ពួកភរិយារបស់ជាងតម្បាញដ៏សេសក្នុងកាលមុនបានមកកើតជាពួកកូនស្រី របស់កុដុម្ពិកៈដ៏សេសទាំងឡាយ ស្រីទាំងនោះចម្រើនវ័យហើយ កាលនឹងទៅកាន់ត្រកូលដទៃ ក៏នាំគ្នាទៅកាន់ផ្ទះរបស់កុដុម្ពិកៈទាំងនោះ ។ ថ្ងៃមួយ កាលមានការប្រកាសឲ្យទៅស្តាប់ធម៌ ត្រង់ព្រះវិហារ ពួកកុដុម្ពិកៈទាំងនោះបានជ្រាបថា ព្រះសាស្តាទ្រង់សម្តែងធម៌ ទើបទៅកាន់វិហារមួយអន្លើដោយភរិយា ដោយបំណងថា ពួកយើងនឹងស្តាប់ធម៌ ។ ក្នុងខណៈដែលមនុស្សទាំងនោះចូលទៅកាន់ព្រះវិហារ ភ្លៀងក៏ធ្លាក់ចុះមក ពួកមនុស្សដែលមានភិក្ខុប្រចាំត្រកូល ឬមានញាតិដែល បួសជាសាមណេរ ជាដើម ក៏នាំគ្នាចូលទៅកាន់បរិវេណជាដើមរបស់ភិក្ខុ និងសាមណេរទាំងនោះ តែកុដុម្ពិកៈទាំងនោះ មិនអាចចូលទៅជ្រកក្នុងទីណាមួយបាន ព្រោះមិនមានបុគ្គលបែបនោះ ទើបបានឈរកណ្តាលព្រះវិហារ ( វត្ត ) នោះឯង តមកប្រធានកុដុម្ពិកៈពោលថា ម្នាលគ្នាយើង ចូរមើលអាការប្លែករបស់ពួកយើងចុះ ឈ្មោះថាកុលបុត្តដូចពួកយើង សមគួរដល់ការខ្មាស ដោយហេតុមានប្រមាណប៉ុណ្ណេះ ។ ពួកកុដុម្ពិកៈសួរថា លោកដ៏ចម្រើន ពួកយើងនឹងធ្វើដូចម្តេច ពួកយើងជួបនូវអាការប្លែកបែបនេះ ព្រោះមិនមានទីលំនៅរបស់អ្នក

ស្និទ្ធស្នាល ពួកយើងទាំងអស់គ្នានឹងរួបរួមទ្រព្យមកសាងបរិវេណ ប្រធាននៃពួកកុដុម្ពិកៈពោលថា សាធុ ។ ប្រធានកុដុម្ពិកៈ បានឲ្យទ្រព្យ ១០០០ អ្នកដ៏សេសបានឲ្យទ្រព្យ ៥០០ ពួកស្រីបានឲ្យទ្រព្យម្នាក់ៗ ២៥០ ។ កុដុម្ពិកៈទាំងនោះនាំទ្រព្យនោះមក ឲ្យធ្វើបរិវេណដើម្បីជាទីគង់របស់ព្រះសាស្តា មានផ្ទះកំពូល ១០០០ ជាបរិវារ ព្រោះនវកម្មនោះធំ កាលទ្រព្យមិនគ្រប់គ្រាន់ទើបនាំគ្នាចេញម្នាក់ពាក់កណ្តាលចំនួនទ្រព្យដែលបានបរិច្ចាគជំបូង ។ កាលបរិវេណសម្រេចហើយ ក៏ធ្វើនូវការឆ្លងព្រះវិហារ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយចាត់ចែងសំពត់ចីវរសម្រាប់ភិក្ខុ ២០០០០ អង្គ ឯភរិយារបស់កុដុម្ពិកៈ តាំងនៅដោយបញ្ញាខ្លួនឯង គិតថា អញនឹងមិនធ្វើឲ្យស្មើជាមួយពួកគេ នឹងបូជាព្រះសាស្តាឲ្យក្រៃលែងជាង ទើបកាន់យកប្រអប់ ដាក់ផ្កាននោង មួយអន្ទើដោយសំពត់សាដកដែលមានតម្លៃ ១០០០ ដែលមានពណ៌ដូចផ្កានោង ហើយយកផ្កានោងបូជាព្រះសាស្តា ដាក់សំពត់សាដកនោះទៀបបាទមូលរបស់ព្រះសាស្តា បានតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន សូមឲ្យសរីរៈរបស់ខ្ញុំព្រះអង្គមានពណ៌ដូចគ្នានឹងផ្កានោង គ្រប់ទីដែលខ្ញុំព្រះអង្គកើត នឹងសូមមានឈ្មោះជាអនោជាចុះ ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាថា ចូរសម្រេចដូចប្រាថ្នាចុះ ។ អ្នកទាំងនោះ តាំងនៅដរាបដល់អស់អាយុហើយ ចុតិចាកអត្តភាពនោះ បានកើតក្នុងទេវលោក ។ ក្នុងពុទ្ធុប្បាទកាលនេះ ទេវតាទាំងនោះ ចុតិចាកទេវលោកហើយ ប្រធានកុដុម្ពិកៈ កើតក្នុងរាជត្រកូលក្នុងកុក្កុដវតីនគរ ទ្រង់ដល់

នូវភាពជាអ្នកដឹងក្តីហើយ បានជាព្រះបាទមហាកប្បិន មនុស្សដ៏សេសបាន កើតក្នុងត្រកូលអាមាត្យ កិរិយារបស់កុដុម្ពិកៈ កើតក្នុងរាជត្រកូលក្នុងមទ្ទរដ្ឋ សាកលនគរ[(១)] ព្រះនាងមានព្រះសរីរៈល្អ មានសម្បុរដូចផ្កានោងនោះឯង ដោយហេតុនោះ ទើបព្រះជនកព្រះជននី ថ្វាយព្រះនាមថា អនោជា ដូចគ្នា ព្រះនាងចម្រើនវ័យហើយ បានទៅកាន់ព្រះរាជវាំងរបស់ព្រះបាទមហាកប្បិន មាននាមប្រាកដថា អនោជាទេវី ។

ពួកស្រីដ៏សេស បានទៅកើតក្នុងត្រកូលអាមាត្យ ចម្រើនវ័យហើយ បាន ទៅកាន់ផ្ទះរបស់បុត្តអាមាត្យទាំងនោះ ។ ជនទាំងអស់នោះ បានសោយសម្បត្តិ ដូចគ្នានឹងសម្បត្តិព្រះរាជា ក្នុងកាលណាស្តេចផែនដីទ្រង់ប្រដាប់ដោយគ្រឿង អលង្ការសព្វយ៉ាង យាងឡើងខ្នងដំរីត្រាច់ទៅ ក្នុងកាលនោះ អ្នកទាំងនោះ ក៏ត្រាច់ទៅយ៉ាងនោះដូចគ្នា កាលព្រះរាជាអង្គនោះ ត្រាច់ទៅដោយសេះ ឬ ដោយរថ ពួកជនទាំងនោះ ក៏ទៅយ៉ាងនោះដូចគ្នា ។ ព្រោះកម្លាំងបុណ្យ ទាំងឡាយដែលជនទាំងនោះសាងរួមគ្នាបែបនេះ ទើបសោយសម្បត្តិតែមួយ ដូចគ្នា ។ ព្រះរាជាមានសេះ ៥ គឺសេះឈ្មោះ វាលៈ ១ វាលវាហនៈ ១ បុប្ផៈ ១ បុប្ផវាទៈ ១ និងសេះឈ្មោះថា សុបត្តៈ ១ ។ បណ្តាសេះ ៥ នោះ ព្រះរាជាទ្រង់គង់លើសេះឈ្មោះថាសុបត្តៈ ដោយព្រះអង្គឯង ឯសេះ ៤ ទៀត បានប្រទានដល់អ្នកជិះសេះទាំងឡាយ ដើម្បីស៊ើបដំណឹង ។ ព្រះ រាជាឲ្យពួកមនុស្សទាំងនោះបរិភោគអំពីព្រលឹមហើយ ទ្រង់បញ្ជូនពួកជនទាំង

---

១-ក្នុងទី២ះជាសាគលនគរ ។

នោះទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកត្រាច់ទៅអស់ចម្ងាយផ្លូវ ២ ឬ ៣ យោជន៍ ស៊ើបមើលថា ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃ កើតឡើងហើយឬនៅ ហើយនាំសារដែលជាសុខមកប្រាប់ដល់យើង ពួកជនទាំងនោះ ចេញអំពីទ្វារទាំង ៤ ទិស ហើយត្រាច់ទៅបាន ២ ឬ ៣ យោជន៍ មិនបាននូវដំណឹងអ្វីឡើយ ទើបត្រឡប់មក ។

ថ្ងៃមួយ ព្រះរាជាយាងឡើងសេះសុបត្តៈ ទ្រង់មានអាមាត្យ ១០០០ ជាបរិវារ កំពុងយាងទៅកាន់ព្រះរាជឧទ្យាន បានទតឃើញពួកឈ្មួញប្រមាណ ៥០០ ដែលមានរាងកាយហត់នឿយ ខ្សោយកម្លាំង ចូលទៅកាន់ព្រះនគរ ហើយត្រិះរិះថា ពួកឈ្មួញទាំងនេះហត់នឿយ ខ្សោយកម្លាំង ព្រោះដើរផ្លូវឆ្ងាយ អញនឹងបានដំណឹងល្អណាមួយអំពីសម្នាក់នៃឈ្មួញទាំងនេះដោយពិត ទើបមានព្រះរាជតម្រាស់ឲ្យអាមាត្យទៅហៅពួកឈ្មួញទាំងនោះមក ហើយត្រាស់សួរថា ពួកអ្នកមកអំពីនគរណា ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព នគរមួយឈ្មោះថាសាវត្ថី មានក្នុងទីឆ្ងាយអំពីទីនេះ ២០០ យោជន៍ ពួកខ្ញុំព្រះអង្គ មកអំពីនគរនោះ ។ ព្រះរាជាត្រាស់ថា ក្នុងប្រទេសរបស់ពួកអ្នកមានដំណឹងអ្វីកើតឡើងខ្លះឬ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព ដំណឹងអ្វីដទៃមិនមាន ក្រៅអំពីដំណឹងដែលព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងហើយ ។ គ្រានោះឯង ព្រះរាជាទ្រង់មានព្រះសរីរៈ ត្រូវបីតិមានកម្លាំងពាល់ត្រូវហើយ មិនអាចកំណត់អ្វីបាន ទ្រង់នៅស្ងៀមមួយស្របក់ ហើយត្រាស់សួរទៀតថា នែអ្នក តើអ្នកនិយាយអ្វី ពួកឈ្មួញក៏ក្រាបទូលថា

ព្រះពុទ្ធទ្រង់កើតឡើងហើយ ។ លើកទី ២ លើកទី ៣ ព្រះរាជាក៏ទ្រង់ស្ងៀមមួយស្របក់បែបនោះទៀត ហើយត្រាស់សួរជាគម្រប់ ៤ ថា នែអ្នក តើអ្នកនិយាយអ្វី កាលពួកឈ្មួញក្រាបទូលថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ទើបត្រាស់ថា នែអ្នក ព្រោះការដែលបានស្តាប់ដំណឹងដែលជាសុខ ខ្ញុំនឹងឲ្យទ្រព្យមួយសែនដល់ពួកអ្នក ហើយត្រាស់សួរថា ដំណឹងអ្វីក្រៃលែងជាងនេះមានទៀតដែរឬទេ ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះធម៌កើតឡើងហើយ ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ស្ងៀមមួយស្របក់អស់វារៈ ៣ ដង ដូចគ្នានោះឯង ក្នុងវារៈទី ៤ កាលពួកឈ្មួញក្រាបទូលថា ព្រះធម៌កើតឡើងហើយ ទើបត្រាស់ថា ក្នុងវារៈនេះ ខ្ញុំក៏នឹងឲ្យទ្រព្យមួយសែនដល់ពួកអ្នក ហើយត្រាស់សួរថា ដំណឹងអ្វីក្រៅអំពីនេះមានទៀតដែរឬទេ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព មាន ព្រះសង្ឃកើតឡើងហើយ ។ ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ទ្រឹងមួយស្របក់ អស់វារៈ ៣ ដង ដូចមុននោះឯង ក្នុងវារៈទី ៤ កាលពួកឈ្មួញក្រាបទូលថា ព្រះសង្ឃកើតឡើងហើយ ទើបត្រាស់ថា សូម្បីក្នុងគ្រានេះ ខ្ញុំក៏ឲ្យទ្រព្យមួយសែនដល់ពួកអ្នក ហើយទ្រង់ទតអាមាត្យ ១០០០ នាក់ ត្រាស់សួរថា នែអ្នក ពួកយើងនឹងធ្វើដូចម្តេច ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ចុះទ្រង់នឹងធ្វើដូចម្តេច ។ ព្រះរាជាត្រាស់ថា នែបា ខ្ញុំបានស្តាប់ថា ព្រះពុទ្ធកើតឡើងហើយ ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ ខ្ញុំនឹងមិនវិលត្រឡប់ទៅវិញ ខ្ញុំឧទ្ទិសចំពោះព្រះមានព្រះភាគ ហើយបួសក្នុងសម្នាក់របស់ព្រះអង្គ ។

ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកខ្ញុំក៏នឹងបួសជាមួយព្រះអង្គ ។ ព្រះរាជាទ្រង់ឲ្យចារិកអក្សរក្នុងជំបារមាស ព្រះរាជទានដល់ពួកឈ្មួញ ហើយត្រាស់ថា ពួកអ្នកចូរប្រគល់ជំបារមាសនេះដល់ព្រះរាជទេវី ព្រះនាមថា អនោជា ព្រះរាជទេវីនោះនឹងព្រះរាជទានទ្រព្យ ៣ សែនដល់ពួកអ្នក កាលបើដូច្នោះ ពួកអ្នកគប្បីក្រាបទូលនឹងព្រះរាជទេវីនោះថា បានឮថា ព្រះរាជាទ្រង់ប្រគល់ភាពជាធំថ្វាយដល់ព្រះនាង សូមព្រះនាង សោយសម្បត្តិតាមសប្បាយចុះ បើព្រះនាងត្រាស់សួរថា ព្រះរាជារបស់ពួកអ្នកយាងទៅណា ពួកអ្នកគប្បីក្រាបទូលថា ព្រះរាជាត្រាស់ថា យើងនឹងបួសឧទ្ទិសព្រះសាស្តា ហើយយាងទៅ ។ ចំណែកពួកអាមាត្យក៏បញ្ជូនដំណឹងទៅប្រាប់ភរិយារៀងៗខ្លួនយ៉ាងនោះដូចគ្នា ។ ព្រះរាជាទ្រង់បញ្ជូនពួកឈ្មួញទៅហើយ ក៏ឡើងផែលសេះ មានអាមាត្យ ១០០០ ចោមរោម យាងទៅក្នុងខណៈនោះឯង ។

ក្នុងពេលទៀបភ្លឺថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក បានទតឃើញព្រះបាទមហាកប្បិនមួយអន្លើដោយបរិវារ ទ្រង់ព្រះតម្រិះថា ព្រះរាជាអង្គនេះ បានជ្រាបដំណឹងអំពីសម្នាក់របស់ពួកឈ្មួញថា ព្រះរតនត្រ័យកើតឡើងហើយ ទើបទ្រង់យកទ្រព្យ ៣ សែន បូជាពាក្យរបស់ពួកឈ្មួញទាំងនោះ ហើយទ្រង់លះរាជសម្បត្តិ មានអាមាត្យ ១០០០ ចោមរោម មានព្រះបំណងបួសឧទ្ទិសតថាគត នឹងបួសក្នុងថ្ងៃស្អែកនេះ ព្រះរាជាព្រមទាំងបរិវារ នឹងបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ តថាគតនឹងធ្វើការទទួល ដូច្នេះ ក្នុងថ្ងៃស្អែកឡើង ទ្រង់យាងទៅទទួលព្រះរាជា ដូច

ស្តេចចក្កពត្តិយាងទៅទទួលមេស្រុកតូចតាច ទើបទ្រង់កាន់បាត្រនិងចីវរយាង ទៅទទួលអស់ចម្ងាយផ្លូវ ១២០ យោជន៍ ទ្រង់គង់បញ្ចេញព្រះពុទ្ធរស្មី ដែលមានពណ៌ ៦ ប្រការ ត្រង់គល់ជ្រៃក្បែរស្ទឹងចន្ទភាគា ព្រះរាជាយាងមកដល់ស្ទឹងមួយ ត្រាស់សួរថា ស្ទឹងនេះឈ្មោះអ្វី ពួកអាមាត្យក្រាបទូលថា ស្ទឹងនេះឈ្មោះអបរច្ឆា ។ ព្រះរាជាត្រាស់សួរថា នែអ្នក ស្ទឹងនេះ មានទំហំប្រមាណប៉ុនណា ពួកអាមាត្យក្រាបទូលថា ស្ទឹងនេះជម្រៅ ១ គាវុត ទទឹង ២ គាវុត ព្រះរាជាត្រាស់សួរថា ក្នុងទីនេះ មានទូកឬក្បូនដែរឬទេ ពួកអាមាត្យក្រាបទូលថា មិនមានទេព្រះអង្គ ។ ព្រះរាជាត្រាស់ថា កាលយើងវល់រកពាហនៈ ឬទូកជាដើម ជាតិ គឺការកើត រមែងនាំចូលទៅរកជរា ជរារមែងនាំចូលទៅរកមរណៈ ។ ខ្ញុំជាអ្នកមិនមានសេចក្តីសង្ស័យ ចេញបួសឧទ្ទិសចំពោះព្រះរតនត្រ័យ ដោយអានុភាពនៃព្រះរតនត្រ័យនោះ ទឹកនេះកុំបីជាទឹកឡើយ ហើយទ្រង់រឭកដល់គុណរបស់ព្រះរតនត្រ័យ រឭកដល់ព្រះពុទ្ធគុណថា **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ** ដូច្នេះ ហើយយាងទៅលើផ្ទៃទឹក មួយអន្លើដោយបរិវារនិងសេះ ១០០០ សេះសិន្ធពទាំងឡាយរត់ទៅលើផ្ទៃទឹក ដូចរត់លើថ្មដាដូច្នោះ សេះទាំងអស់សើមត្រឹមតែចុងក្រចកប៉ុណ្ណោះ ។

ព្រះរាជាអង្គនោះ ទ្រង់ឆ្លងស្ទឹងនោះហើយ យាងទៅខាងមុខ ទតឃើញស្ទឹងដទៃទៀត ត្រាស់សួរថា ស្ទឹងនេះឈ្មោះអ្វី ពួកអាមាត្យក្រាបទូលថា ឈ្មោះនីលវាហា ព្រះរាជាត្រាស់សួរថា ស្ទឹងនេះមានទំហំប្រមាណប៉ុនណា

ពួកអាមាត្យក្រាបទូលថា ទាំងជម្រៅ ទាំងទទឹង មានប្រមាណកន្លះយោជន៍ ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលពោលហើយខាងដើមនោះឯង ។ ព្រះរាជាទតឃើញស្ទឹងនោះហើយ ទ្រង់រឭកដល់ព្រះធម្មគុណថា **ស្វាក្ខាតោ ភគវតា ធម្មោ** ដូច្នេះហើយ ក៏យាងឆ្លងទៅ ។ លុះព្រះរាជដំណើរផុតស្ទឹងទៅហើយ ព្រះរាជាទតឃើញស្ទឹងមួយទៀត ទើបត្រាស់សួរថា ស្ទឹងនេះឈ្មោះអ្វី ពួកអាមាត្យក្រាបទូលថា ឈ្មោះថាចន្ទភាគា ព្រះរាជាត្រាស់សួរថា ស្ទឹងនេះមានទំហំប៉ុន្មាន ពួកអាមាត្យក្រាបទូលថា ជម្រៅ និងទទឹង មានប្រវែង ១ យោជន៍ ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលពោលមកហើយខាងដើមនោះឯង ។ ព្រះរាជា ទតឃើញស្ទឹងនោះហើយ ទ្រង់ក៏រឭកដល់សង្ឃគុណថា **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះ ហើយយាងទៅ ។ លុះព្រះរាជាយាងឆ្លងស្ទឹងទៅ ទ្រង់ទតឃើញព្រះពុទ្ធរង្សីមានពណ៌ ៦ ផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្តា ធ្វើឲ្យមែក ប្រគាប និងស្លឹករបស់ដើមជ្រៃភ្លឺរុងរឿង ទើបទ្រង់ព្រះតម្រិះថា ពន្លឺនេះ មិនមែនពន្លឺរបស់ព្រះចន្ទ មិនមែនពន្លឺរបស់ព្រះអាទិត្យ មិនមែនពន្លឺរបស់ទេវតា មារ ព្រហ្ម គ្រុឌ និងនាគណាមួយឡើយ អញធ្វើដំណើរមកឧទ្ទិសសាស្តា ប្រហែលជាព្រះសម្មាសម្ពុទ្ធទ្រង់ ឃើញអញហើយ ទើបទ្រង់ចុះអំពីខ្នងសេះបង្អោនព្រះកាយចូលទៅគាល់ព្រះសាស្តាតាមជួរនៃព្រះរស្មី បានយាងចូលទៅខាងក្នុងព្រះពុទ្ធរស្មីដូចមុជដោយលម្អិតមនោសិលាដូច្នោះ ។ ទ្រង់ថ្វាយបង្គំព្រះសាស្តាហើយគង់ក្នុងទីដ៏សមគួរនាចំណែកម្ខាង មួយអន្លើដោយអាមាត្យ ១០០០ នាក់ ។

ព្រះសាស្តា ត្រាស់អនុបុព្វីកថាដល់ជនទាំងនោះ លុះចប់ព្រះធម្មទេសនា ព្រះរាជា មួយអន្លើដោយបរិវារក៏តាំងនៅក្នុងអរហត្តផល ។

លំដាប់នោះ ជនទាំងអស់ក្រោកឡើងហើយ ទូលសូមបព្វជ្ជា ។ ព្រះសាស្តាទ្រង់ពិចារណាថា បាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ នឹងមកប្រ-តិស្ឋានដល់កុលបុត្តទាំងនេះដែរឬហ្ន៎ ទ្រង់ជ្រាបថា កុលបុត្តទាំងនេះ ធ្លាប់ថ្វាយចីវរ ១០០០ ដល់ព្រះបច្ចេកពុទ្ធ ១០០០ អង្គ ក្នុងកាលព្រះពុទ្ធ ព្រះនាមកស្សបៈ បានថ្វាយចីវរ ២ ម៉ឺនផ្ទាំង ដល់ភិក្ខុ ២ ម៉ឺនអង្គ ការដែលបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិមកដល់កុលបុត្តទាំងនេះ មិនមែនជាហេតុអស្ចារ្យទេ ដូច្នេះហើយ ទ្រង់លាព្រះហស្តស្តាំត្រាស់ថា **ឯថ ភិក្ខវោ ចរថ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយ** ពួកអ្នកចូរមកជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ។ ក្នុងខណៈនោះឯង ភិក្ខុទាំងនោះក៏បានទ្រទ្រង់នូវបរិក្ខារ ៨ ដូចព្រះថេរៈមានវស្សា ៦០ ដូច្នោះ ហោះឡើងទៅកាន់អាកាស ហើយត្រឡប់ចុះមកថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

ឯឈ្មួញទាំងនោះ ទៅកាន់ព្រះរាជវាំង ហើយក្រាបទូលដំណឹងដែលព្រះរាជាបញ្ជូនទៅ ដល់ព្រះទេវីឲ្យព្រះនាងជ្រាប កាលព្រះទេវីត្រាស់ថា អ្នកចូរមក ទើបចូលទៅឈរក្នុងទីសមគួរនាចំណែកម្ខាង ។ ពេលនោះ ព្រះរាជទេវីក៏ត្រាស់សួរពួកឈ្មួញទាំងនោះថា នែបា ពួកអ្នកមកដើម្បីអ្វី ពួកឈ្មួញក៏ក្រាបទូលថា ព្រះរាជាទ្រង់បញ្ជូនពួកទូលព្រះបង្គំមកគាល់ព្រះនាង បានឮ

ថា សូមព្រះនាងព្រះរាជទានទ្រព្យ ៣ សែនដល់ពួកទូលព្រះបង្គំ ។ ព្រះរាជទេវីត្រាស់ថា នែបា ពួកអ្នកនិយាយច្រើនពេកហើយ ពួកអ្នកធ្វើប្រយោជន៍អ្វីក្នុងសម្នាក់របស់ព្រះរាជា ព្រះរាជាទ្រង់ជ្រះថ្លាក្នុងរឿងអ្វី ទើបត្រាស់ឲ្យព្រះរាជទានទ្រព្យដល់ម្ល៉េះដល់ពួកអ្នក ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះរាជទេវី ពួកទូលព្រះបង្គំមិនបានធ្វើរឿងអ្វីដទៃឡើយ គ្រាន់តែប្រាប់ដំណឹងមួយដល់ព្រះរាជាប៉ុណ្ណោះ ព្រះទេវីត្រាស់សួរថា នែបា អ្នកអាចប្រាប់ដំណឹងនោះដល់យើងផងបានដែរឬ ពួកឈ្មួញក្រាបទូលថា អាច ហើយខ្ពុរមាត់ដោយទឹកអំពីសុវណ្ណភិង្គារក្រាបទូលថា បពិត្រព្រះរាជទេវី ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះរាជទេវីអង្គនោះ លុះបានស្តាប់ពាក្យនោះហើយ ជាអ្នកមានសរីរៈដែលបីតិពាល់ត្រូវហើយ មិនអាចកំណត់អ្វីបាន អស់វារៈ ៣ ដងក្នុងលើកទី ៤ ព្រះនាងស្តាប់ថា ព្រះពុទ្ធកើតឡើងហើយ ទើបត្រាស់ថា នែបា ព្រោះបទនេះ ព្រះរាជាព្រះរាជទានទ្រព្យឲ្យអ្នកប៉ុន្មាន ពួកឈ្មួញទូលថា ១ សែន ។ ព្រះរាជទេវីត្រាស់ថា នែបា ព្រះរាជាមិនគួរស្តាប់ដំណឹងបែបនេះហើយព្រះរាជទានទ្រព្យ ១ សែនដល់ពួកអ្នក ខ្ញុំនឹងឲ្យទ្រព្យ ៣ សែនដល់ពួកអ្នក ព្រោះខ្ញុំក្រីក្របណ្ណាការ ពួកអ្នកបានក្រាបទូលរឿងអ្វីដទៃទៀតដែរឬ ពួកឈ្មួញទាំងនោះក្រាបទូលដំណឹង ២ ដ៏សេសឲ្យព្រះនាងជ្រាបថា រឿងនេះ និងរឿងនេះ ។ ព្រះរាជទេវីមិនអាចកំណត់អ្វីបាន អស់វារៈ ៣ ដង ដូចន័យដែលពោលហើយខាងដើមនោះឯង លើកទី ៤ បានព្រះរាជទានទ្រព្យម្តង ៣ សែន រួមសេចក្តីថា ពួកឈ្មួញទាំងនោះ បានទទួលទ្រព្យ

ទាំងអស់ ១២ សែន ។

លំដាប់នោះ ព្រះរាជទេវីក៏ត្រាស់សួរពួកឈ្នួញទាំងនោះថា នែបា ព្រះរាជាយាងទៅទីណា ពួកឈ្នួញក៏ក្រាបទូលថា បពិត្រព្រះទេវី ព្រះរាជាត្រាស់ថា យើងនឹងបួសឧទ្ទិសព្រះសាស្តា ហើយយាងទៅ ព្រះរាជទេវីត្រាស់សួរថា ដំណឹងអ្វីដែលព្រះរាជាអង្គនោះ បញ្ជូនដល់យើងមានដែរឬ ពួកឈ្នួញក្រាបទូលថា បានព្ធថា ទ្រង់លះបង់ភាពជាធំទាំងអស់ដល់ព្រះនាង បានព្ធថា សូមព្រះនាងសោយសម្បត្តិដោយសុខចុះ ។ ព្រះទេវីត្រាស់សួរថា នែបា ពួកអាមាត្យទៅណា ពួកឈ្នួញក៏ក្រាបទូលថា បពិត្រព្រះទេវី ពួកអាមាត្យទាំងនោះ ក៏ពោលថា ពួកយើងនឹងបួសជាមួយព្រះរាជា ហើយទៅ ។ ទើបព្រះទេវីអង្គនោះហៅភរិយារបស់អាមាត្យទាំងនោះមកត្រាស់ថា នែនាង ប្តីរបស់ពួកនាងឲ្យដំណឹងមកថា ពួកគេនឹងបួសជាមួយព្រះរាជា នាំគ្នាទៅហើយ ពួកនាងនឹងធ្វើដូចម្តេច ។ ពួកភរិយារបស់អាមាត្យទាំងនោះទូលសួរថា បពិត្រព្រះរាជទេវី ដំណឹងណាមួយដែលពួកប្តីបញ្ជូនមកដល់ពួកខ្ញុំម្ចាស់ មានដែរឬ ព្រះទេវីត្រាស់ថា បានព្ធថា អាមាត្យទាំងនោះ បានប្រគល់សម្បត្តិរបស់ខ្លួនដល់ពួកនាង បានព្ធថា ពួកនាងចូរប្រើប្រាស់សម្បត្តិតាមសប្បាយចុះ ពួកភរិយារបស់អាមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះទេវី ពួកយើងនឹងធ្វើដូចម្តេចល្អ ព្រះទេវីត្រាស់ថា ដំបូង ព្រះរាជារបស់ពួកយើងអង្គនោះ នៅក្នុងរវាងផ្លូវ យកទ្រព្យ ៣ សែន បូជាព្រះរតនត្រ័យ ហើយលះរាជសម្បត្តិដូចស្តោះដុំទឹកមាត់ យាងទៅ ដោយបំណងថានឹងបួស ឯយើងបានស្តាប់

ដំណឹងរបស់ព្រះរតនត្រ័យហើយ ក៏យកទ្រព្យ ៩ សែន បូជាព្រះរតនត្រ័យនោះហើយ ឈ្មោះថាសម្បត្តិនោះ មិនមែនជាទុក្ខដល់ព្រះរាជាតែម្យ៉ាងប៉ុណ្ណោះទេ រមែងជាទុក្ខដល់យើងដូចគ្នា អ្នកណានឹងលុតជង្គង់លើផែនដី ហើយយកមាត់ទទួលជុំទឹកមាត់ដែលព្រះរាជាស្តោះហើយនោះ យើងមិនមានសេចក្តីត្រូវការសម្បត្តិ យើងនឹងបួសឧទ្ទិសព្រះសាស្តា ។ ពួកកិរិយារបស់អាមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះរាជទេវី ពួកខ្ញុំម្ចាស់នឹងបួសជាមួយព្រះនាង ។ ព្រះរាជទេវី ត្រាស់ថា បើពួកនាងអាចជាការល្អ ។ ពួកកិរិយារបស់អាមាត្យទាំងនោះទូលថា ពួកខ្ញុំម្ចាស់ អាច ។ ព្រះរាជទេវីត្រាស់ថា បើដូច្នោះពួកនាងចូរមក ហើយត្រាស់ឲ្យត្រៀមរថ ១០០០ យាងឡើងរថចេញទៅមួយអន្លើដោយពួកកិរិយារបស់អាមាត្យទាំងនោះ ក្នុងរវាងផ្លូវ បានឃើញស្ទឹងទី ១ ត្រាស់សួរដូចព្រះរាជាត្រាស់សួរជំបូងនោះឯង ព្រះនាងបានស្តាប់ការប្រព្រឹត្តទៅទាំងអស់ហើយ ទើបត្រាស់ថា ពួកនាងចូរមើលផ្លូវដែលព្រះរាជាយាងទៅ កាលពួកកិរិយារបស់អាមាត្យទាំងនោះក្រាបទូលថា មិនឃើញស្នាមជើងសេះសិន្ធពឡើយ ទើបត្រាស់ថា ព្រះរាជាគង់ធ្វើសច្ចកិរិយាថា ខ្ញុំជាអ្នកចេញបួសឧទ្ទិសព្រះរតនត្រ័យ ហើយទ្រង់រឭកដល់ គុណនៃព្រះរតនត្រ័យ ទើបឆ្លងទៅបាន ឯយើងក៏ចេញបួសឧទ្ទិសព្រះរតនត្រ័យ ដោយអានុភាពនៃព្រះរតនត្រ័យ ទឹកនេះកុំជាទឹកឡើយ ព្រះនាងរឭកដល់គុណ ព្រះរតនត្រ័យ រថ ១០០០ ក៏ស្ទុះទៅបាន ទឹកដូចគ្នានឹងផែនថ្មដា រទេះទាំងអស់សើមត្រឹមតែខ្នងកង់ប៉ុណ្ណោះ ។ ស្ទឹង ២ ក្រៅអំពីនេះ ព្រះនាងនិងមនុស្ស

ទាំងអស់ក៏ចូលទៅបានហើយ ដោយឧបាយនោះឯង ។

ព្រះសាស្តាទ្រង់ជ្រាបថា ស្រីទាំងនោះមក ទ្រង់អធិដ្ឋាន ដោយមិនឲ្យស្រីទាំងនោះឃើញពួកភិក្ខុជាស្វាមីដែលអង្គុយក្នុងសម្នាក់របស់ព្រះអង្គ ព្រះទេវីយាងមក បានទតឃើញរស្មី ដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្តាហើយ ព្រះនាងក៏ចិន្តនាការដូចព្រះបាទមហាកប្បិនដូចគ្នា ហើយចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយប្រថាប់ឈរក្នុងទីសមគួរនាចំណែកម្ខាង ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទមហាកប្បិន យាងចេញបួសឧទ្ទិសចំពោះព្រះអង្គ ឥឡូវនេះ ព្រះបាទមហាកប្បិនប្រថាប់នៅក្នុងទីណា សូមទ្រង់បង្ហាញព្រះរាជាអង្គនោះ ដល់ពួកខ្ញុំម្ចាស់ចុះ ។ ព្រះសាស្តាត្រាស់ថា ពួកនាងចូរអង្គុយសិន ពួកនាងនឹងបានឃើញ ព្រះរាជាអង្គនោះក្នុងទីនេះឯង ។ ស្រីទាំងអស់នោះត្រេកអរ ពោលថា បានឮថា ពួកយើងអង្គុយក្នុងទីនេះឯង នឹងបានឃើញស្វាមីរបស់ពួកយើង ដូច្នេះ ទើបអង្គុយហើយ ។ ព្រះសាស្តាបានត្រាស់សម្តែងអនុបុព្វីកថា ក្នុងពេលចប់ទេសនាព្រះនាងអនោជាទេវី បានសម្រេចសោតាបត្តិផល មួយអន្លើដោយស្រីទាំងនោះ ។ ព្រះមហាកប្បិនត្ថេរ និងបរិវារ បានស្តាប់ព្រះធម្មទេសនាដែលព្រះសាស្តាទ្រង់សម្តែងដល់ស្រីទាំងនោះហើយ ក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ។ ក្នុងខណៈនោះ ព្រះសាស្តា ទ្រង់ធ្វើឲ្យស្រីទាំងនោះឃើញភិក្ខុទាំងនោះ ។ បើស្រីទាំងនោះ ឃើញស្វាមីរបស់ខ្លួនដែល ទ្រទ្រង់សំពត់កាសាយៈ មានក្បាលត្រងោល ក្នុងវេលាដែលមកដល់នោះឯង ចិត្ត

នឹងមិនមានអារម្មណ៍តែមួយ មិនអាចធ្វើមគ្គផលឲ្យកើតឡើងបាន ព្រោះហេតុនោះ តាំងអំពីពេលដែលពួកនាងមានសទ្ធាតាំងមាំមិនញាប់ញ័រហើយ ទើបព្រះសាស្ដាឲ្យស្រីទាំងនោះ ឃើញភិក្ខុទាំងនោះ ដែលបានសម្រេចអរហត្តហើយ ។ ចំណែកស្រីទាំងនោះ ឃើញភិក្ខុទាំងនោះហើយ ក៏ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា បពិត្រលោកម្ចាស់ កិច្ចនៃបព្វជិតរបស់លោកម្ចាស់ដល់ទីបំផុតហើយ ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្ដា ឈរក្នុងទីសមគួរនាចំណែកម្ខាង ហើយបានទូលសូមបព្វជ្ជា ។

កាលស្រីទាំងនោះ សូមបព្វជ្ជាយ៉ាងនេះ ព្រះសាស្ដាទ្រង់ព្រះតម្រិះឲ្យព្រះនាងឧប្បលវណ្ណាថេរីមក ។ ក្នុងខណៈដែលព្រះសាស្ដាទ្រង់ព្រះតម្រិះនោះឯង នាងឧប្បលវណ្ណាថេរី ក៏មកតាមអាកាស ទទួលយកស្រីទាំងនោះទៅកាន់សម្នាក់ភិក្ខុនីតាមអាកាស ហើយឲ្យបព្វជ្ជា មិនយូរប៉ុន្មាន ស្រីទាំងអស់នោះ ក៏បានសម្រេចអរហត្ត ព្រះសាស្ដាទ្រង់នាំភិក្ខុ ១០០០ រូប ទៅកាន់វត្តជេតពនតាមអាកាស បានឮមកថា ត្រង់វត្តជេតពននោះ ព្រះមហាកប្បិន ត្រាច់បន្លឺឧទានថា **អហោ សុខំ អហោ សុខំ** ឱ ! សុខហ្ន៎ ឱ ! សុខហ្ន៎ ក្នុងទីផ្សេងៗ មានទីសម្រាកពេលយប់ជាដើម ។ ភិក្ខុទាំងឡាយ ក្រាបទូលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកប្បិន ត្រាច់បន្លឺឧទានថា ឱ ! សុខហ្ន៎ ឱ ! សុខហ្ន៎ ប្រារព្ធដល់សេចក្ដីសុខដែលកើតអំពីរាជសម្បត្តិរបស់ខ្លួនទេដឹង ព្រះសាស្ដាត្រាស់ឲ្យហៅព្រះមហាកប្បិននោះមកហើយសួរថា ម្នាលកប្បិន បានឮថា អ្នកបន្លឺឧទានប្រារព្ធដល់សេចក្ដីសុខ

ដែលកើតអំពីកាមពិតឬ ព្រះមហាកប្បិនក្រាបទូលថា បពិត្រព្រះអង្គ ព្រះមានព្រះភាគទ្រង់ដឹងថា ខ្ញុំព្រះអង្គបន្លឺឧទានប្រារព្ធដល់សេចក្តីសុខនោះ ឬថា ខ្ញុំព្រះអង្គបន្លឺឧទានប្រារព្ធដល់សេចក្តីសុខដទៃ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្តរបស់តថាគត មិនបានបន្លឺឧទានប្រារព្ធដល់សេចក្តីសុខ ដែលកើតអំពីកាម ឬសេចក្តីសុខដែលកើតអំពីរាជសម្បត្តិនោះទេ តែធម្មបីតិ រមែងកើតឡើងដល់បុត្តរបស់តថាគត ដែលប្រព្រឹត្តធម៌ បុត្តតថាគតប្រារព្ធដល់អមតមហានិព្វានទើបបន្លឺឧទានដូច្នេះ កាលទ្រង់សម្តែងធម៌បន្តអនុសន្ធិ ទើបត្រាស់គាថា ( ក្នុងធម្មបទ ) ថា បណ្ឌិតដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល ដូច្នេះ ។

ថ្ងៃមួយ ព្រះសាស្តាទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មហាកប្បិនបានសម្តែងធម៌ដល់ភិក្ខុទាំងឡាយឬទេ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកប្បិនជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ប្រកបដោយសេចក្តីសុខ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ រមែងមិនឲ្យសូម្បីឱវាទ ។ ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅព្រះថេរៈមកហើយសួរថា ម្នាលកប្បិន បានឮថា អ្នកមិនឲ្យឱវាទ សូម្បីដល់ពួកភិក្ខុដែលជាអន្តេវាសិកពិតឬ ព្រះមហាកប្បិនក្រាបទូលថា ពិត ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើយ៉ាងនោះឡើយ តាំងអំពីថ្ងៃនេះទៅ អ្នកចូរសម្តែងធម៌ដល់ពួកភិក្ខុដែលចូលទៅរក ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះមាន

ព្រះភាគដោយសិរសាថា សាធុ ព្រះអង្គ ដូច្នេះហើយ ឲ្យឱវាទ ធ្វើព្រះថេរៈ ១០០០ ឲ្យតាំងនៅក្នុងអរហត្ត ដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះ ដោយហេតុនោះ ព្រះសាស្តាកាលស្ថាបនាសាវករបស់ព្រះអង្គទុកក្នុងតំណែងផ្សេងៗទើបទ្រង់តាំងលោកទុកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុជាសាវករបស់តថាគត ស្រេចនឹងមហាកប្បិនប្រសើរជាងគេ ដូច្នេះ ។

ព្រះថេរៈបានសម្រេចអរហត្តផលយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះជាដើម ។ បទថា **ឧទិ-តោ អជដាកាសេ** បានដល់ ប្រាកដ គឺតាំងឡើង ប្រាកដឡើង ក្នុងអា-កាសទាំងមូល អធិប្បាយថា ដូចព្រះអាទិត្យប្រាកដកណ្តាលអាកាស ក្នុងសរទកាល ។ បទថា **អក្ខុនស្មោ តទា អាសឹ** សេចក្តីថា ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈនោះ ខ្ញុំដែលគេស្គាល់ថាជាអាចារ្យដែលមានប្រក្រតីឃើញសារៈ គឺជាអ្នកមានប្រក្រតីឃើញប្រយោជន៍ ។

បទថា **សាវកស្ស កតាវិនោ** ក្ឋាប់សេចក្តីថា បានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ដែលធ្វើបុណ្យ គឺទ្រង់ប្រកបកិច្ចជាប់តគ្នាដែលកំពុងប្រកាសគុណរបស់សាវកដែលពោលទូន្មានភិក្ខុ គឺទ្រង់ស្ថាបនាទុកក្នុងតំណែងដ៏ប្រសើរ ដែលធ្វើចិត្តរបស់ខ្ញុំឲ្យត្រេកអរ ។ បទថា **ហំសសម-ភាគោ** បានដល់ ដែលយាងទៅដូចហង្ស ។ បទថា **ហំសទុន្ទុភិនិស្សនោ** ក្ឋាប់សេចក្តីថា មានព្រះសូរសៀងដូចហង្ស គឺមានព្រះតម្រាស់ដូចគ្នានឹង

សំឡេងស្គរតូចនិងស្គរធំ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរមើលមហាមាត្យនេះចុះ ។ បទថា **សមុគ្គតតនូរុហំ** សេចក្តីថា មានការព្រឺរោមព្រឺស្បែកដោយល្អ ឬថាមានចិត្តផ្សាយឡើង ។ បទថា **ជម្វូតវណ្ណំ** សេចក្តីថា មានវណ្ណៈស្មើដោយកែវមុក្តា គឺមានរស្មីផ្សាយចេញអំពីសរីរៈដ៏ល្អ ។ បទថា **បីណំសំ** ប្រែថា មានព្រះអង្សាពេញបរិបូណ៌ ។ បទថា **បសន្នយនា-ននំ** សេចក្តីថា មានព្រះនេត្រនិងទឹកមុខថ្លូរផង់ ។

បទថា **កតាវិនោ** ភ្ជាប់សេចក្តីថា មហាមាត្យនោះប្រាថ្នាតំណែងរបស់បុគ្គលដែលមានអធិការបានធ្វើទុកហើយ ដែលតាំងនៅក្នុងតំណែងឯតទគ្គៈ ព្រោះកុលបុត្តនោះមានចិត្តត្រេកអរតាម គឺមានចិត្តរីករាយ ។

បទថា **សតសោ អនុសាសិយ** សេចក្តីថា ប្រៀនប្រដៅដោយពាក្យដែលជាធម៌ស្មើ គឺតាមគួរដល់ហេតុ ។ បទថា **ពារាណសិយមាសន្នេ** បានដល់ ក្នុងស្រុកជាងតម្បាញ ជិតក្រុងពារាណសី ។ បទថា **ជាតោ កោលិយ ជាតិយំ** សេចក្តីថា កើតក្នុងត្រកូលអ្នកត្បាញសំពត់ គឺក្នុងត្រកូលជាងតម្បាញ ។ ពាក្យដ៏សេសមានអត្ថដ៏ងបានងាយហើយ ។

### អដ្ឋកថាមហាកប្បិនត្ថេរាបទាន ចប់

# ធម្មរុចិត្ថេរាបទានទី ៤

[ ១២៤ ] ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបនូវលោកទាំងពួង ព្រះអង្គមានចក្ខុ ទ្រង់កើតឡើងហើយ ។ ព្រះពុទ្ធទ្រង់ប្រទានឱវាទ ទ្រង់បំភ្លឺ ទ្រង់ចម្លងពួកសត្វទាំងពួង ទ្រង់ឈ្លាសក្នុងទេសនា ចម្លងប្រជុំជនដ៏ច្រើន ។ ព្រះអង្គមានសេចក្តីអនុគ្រោះ មានសេចក្តីករុណា ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង តែងញុំាងពួកតិរ្ថិយទាំងពួងដែលជួបប្រទះ ឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាងនេះ សាសនារបស់ព្រះអង្គមិនវឹកវរ ជាសាសនាសូន្យចាកពួកតិរ្ថិយ ជាសាសនាវិចិត្រដោយពួកព្រះអរហន្ត ដែលស្ទាត់ជំនាញ ជាតាទិបុគ្គល ។ ព្រះមហាមុនីអង្គនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មាយុមួយសែនឆ្នាំ ព្រះបទុមុត្តរៈអង្គនោះ កាលប្រតិស្ឋាននៅ ទ្រង់ចម្លងប្រជុំជនច្រើនកំណត់ត្រឹមនោះ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្ត មានយសធំក្នុងក្រុងហង្សវតី បានចូលទៅជិតព្រះសម្ពុទ្ធ ជាប្រទីបក្នុងលោក បានស្តាប់ធម្មទេសនា ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនី ទ្រង់សម្តែងនូវគុណនៃសាវករបស់ព្រះអង្គ ជាអ្នកក្រាលសេនាសនៈដល់ពួកភិក្ខុ ក៏មានចិត្តរីករាយ ។ ខ្ញុំធ្វើការកសាងចំពោះសង្ឃ ហើយក្រាបចុះទៀបព្រះបាទារបស់ព្រះមហេសីអង្គនោះដោយសិរៈ ប្រាថ្នានូវតំណែងនោះ ។ កាលនោះ ព្រះមហាវីរៈអង្គនោះ ទ្រង់សម្តែងសរសើរនូវកម្មរបស់ខ្ញុំថា

កុលបុត្តណា ញុំាងតថាគតជាលោកនាយក ព្រមទាំងភិក្ខុសង្ឃឲ្យឆាន់

អស់ ៧ ថ្ងៃ កុលបុត្តនោះ មានភ្នែកដូចត្របកឈូក មានស្មាដូចសត្វសីហៈ មានស្បែកដូចមាស ក្រាបចុះទៀបបាទមូលនៃតថាគត ហើយប្រាថ្នានូវទីដ៏ប្រសើរ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងបានត្រាស់ក្នុងលោក ។ កុលបុត្តនេះ នឹងបានជាសាវកបស់ព្រះពុទ្ធអង្គនោះ ប្រាកដនាមថាទព្វៈ ជាអ្នកក្រាលអាសនៈជាកំពូល ( នៃសាវកទាំងពួង ) ។

ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតាំងសេចក្តីប្រាថ្នានោះផង ។ ខ្ញុំបានទទួលទេវរាជសម្បត្តិអស់ ៣០០ ដង បានជាស្តេចចក្រពត្តិអស់ ៥០០ ដង ។ ខ្ញុំបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំដល់នូវសេចក្តីសុខក្នុងភពទាំងពួង ដោយអំណាចនៃកុសលកម្មនោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយកព្រះនាមវិបស្សី ទ្រង់មានព្រះនេត្ររុងរឿង ទ្រង់ឃើញច្បាស់នូវធម៌ទាំងពួង ទ្រង់ត្រាស់ឡើង ។ ខ្ញុំមានចិត្តប្រទូស្ត តិះដៀលសាវកអ្នកមិនមានអាសវៈទាំងពួងរបស់ព្រះអង្គ ជាតាទិបុគ្គល ហើយប្តេជ្ញាខ្លួនថាអាត្មាអញស្អាត ។ ( លុះមកខាងក្រោយ ) ខ្ញុំកាន់យកស្លាកហើយប្រគេនបាយលាយដោយទឹកដោះស្រស់ ដល់ពួកសាវក អ្នកស្វែងរកសីលគុណរបស់ព្រះវិបស្សីអង្គនោះ ទ្រង់មានព្យាយាម ជាងពួកនរៈ ។ ក្នុងកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ ទ្រង់មានយសធំប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ត្រាស់ឡើង ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំង

សាវ័ក ទ្រង់ញុំាងសាសនាឲ្យរុងរឿង ទ្រង់គ្របសង្កត់ពួកតិរ្ថិយអាក្រក់ ទ្រង់ណែនាំវេនេយ្យសត្វ ហើយបរិនិព្វាន ។ កាលព្រះលោកនាថព្រមទាំងសិស្សបរិនិព្វានហើយ កាលសាសនាសាបសូន្យហើយ ពួកទេវតាមានសេចក្តីតក់ស្លុត រំសាយសក់ មានមុខទទឹកដោយទឹកភ្នែក កន្ទក់កន្ទេញថា ព្រះសម្ពុទ្ធទ្រង់ប្រាប់ធម៌នឹងបរិនិព្វាន ពួកយើងនឹងមិនឃើញព្រះអង្គដែលមានវត្តល្អ នឹងមិនបានស្តាប់ព្រះសទ្ធម្ម ឱហ្ន៎ ពួកយើងចំជាអ្នកឥតបុណ្យមែន ។ កាលនោះឯង ផែនដីទាំងមូលនេះដែលជារបស់មិនញាប់ញ័រ ផែនដីនោះធំទូលាយផងសាគរព្រមទាំងលោកផង ក៏បែរជាបន្លឺសម្រែកករុណា ។ ស្គរទាំងឡាយក្នុងទិសទាំង ៤ ដែលមិនមែនជារបស់មនុស្ស ក៏បន្លឺឡើង រន្ទះទាំងឡាយជារបស់នាំមកនូវភ័យ ក៏ធ្លាក់ចុះជុំទិស ។ ភ្លើងគប់ទាំងឡាយ ក៏ធ្លាក់មកអំពីអាកាស ផ្កាយដុះកន្ទុយ អណ្តាតភ្លើងព្រមទាំងផ្សែង ក៏ប្រាកដឡើង ពួកម្រឹគស្រែកនូវសម្រែកករុណា ។ កាលនោះ យើងជាភិក្ខុ ៧ រូប ឃើញហេតុកាចអាក្រក់ ជាចម្រូងឲ្យវិនាសសាសនាកើតឡើង ក៏មានសេចក្តីសង្វេគគិតគ្នាថា ពួកយើងបើវៀរចាកសាសនាហើយ មិនគួររស់នៅឡើយ យើងទាំងឡាយគួរចូលទៅក្នុងព្រៃធំ ហើយប្រកបនូវសាសនារបស់ព្រះជិនស្រី ។ កាលនោះ ពួកខ្ញុំបានឃើញភ្នំខ្ពស់ក្នុងព្រៃ ទើបឡើងភ្នំនោះតាមបង្អោងហើយប្រានបង្អោងចោល ។ គ្រានោះ ព្រះថេរៈទូន្មានទូវពួកយើងថា ការកើតឡើងនៃព្រះពុទ្ធ ជាការកម្រណាស់ សទ្ធាសោត ក៏រកបានដោយកម្រដែរ ឯសាសនាដែលសេសសល់នៅ ក៏ស្តួចស្តើង ។ សត្វទាំងឡាយ តែមាន

ខណៈកន្លងហើយ រមែងធ្លាក់ចុះក្នុងសាគរគឺសេចក្តីទុក្ខ មិនមានទីបំផុតព្រោះហេតុនោះ សាសនាប្រតិស្ឋានទៅដរាបណា ពួកយើងគប្បីធ្វើព្យាយាមដរាបនោះ ។ ព្រះថេរៈនោះ ជាព្រះអរហន្ត អនុត្តរជាលំដាប់នឹងមហាថេរៈនោះជាអនាគាមី ភិក្ខុទាំងឡាយក្រៅអំពីនេះ មានសីលល្អប្រកបព្យាយាម បានទៅកើតក្នុងទេវលោក ។ ( ព្រះថេរៈ ១ រូប ) មានសង្ខារវដ្តក្ខន្ធហើយបរិនិព្វាន ព្រះថេរៈមួយរូបទៀត ទៅកើតក្នុងសុទ្ធាវាសព្រហ្មលោក ( ឯពួកយើង ) គឺខ្ញុំ ១ បុក្កុសាតិ ១ សភិយៈ ១ ពាហិយៈ ១ និងព្រះកុមារកស្សបៈ ១ ( នៅជាបុថុជ្ជន ) ដូចគ្នា ពួកយើងក៏ចូលទៅកើតហើយក្នុងភពនោះៗ បានព្រះសម្ពុទ្ធព្រះនាមគោតមអនុគ្រោះ ក៏រួចស្រឡះចាកចំណងសង្សារ ។ ខ្ញុំកើតក្នុងត្រកូលមល្លៈ ក្នុងក្រុងកុសិនារា កាលខ្ញុំនៅក្នុងគភ៌មាតារបស់ខ្ញុំស្លាប់ លុះគេលើកឡើងកាន់ជើងថ្ករ ខ្ញុំក៏របូតចាកគភ៌នោះ ធ្លាក់ទៅលើគំនរស្មៅជំណោកទន្សាយ ព្រោះហេតុនោះ ទើបខ្ញុំមានឈ្មោះប្រាកដជាទព្វៈ ខ្ញុំមានអាយុ ៧ ឆ្នាំ មានចិត្តផុតស្រឡះ ចាកកិលេស ដោយផលនៃព្រហ្មចរិយៈ ។ ខ្ញុំប្រកបដោយអវយវៈ ៥ ដោយផលនៃបាយ ដែលលាយទឹកដោះស្រស់ ត្រូវបាបដាស់តឿនហើយដោយច្រើន ដោយការតិះដៀលព្រះខីណាស្រព ។ ឥឡូវនេះ ខ្ញុំកន្លងបុណ្យនិងបាបទាំងពីរ បានដល់នូវសេចក្តីស្ងប់យ៉ាងក្រៃលែង ជាអ្នកមិនមានអាសវៈ ។ ខ្ញុំក្រាលសេនាសនៈញ៉ាំងពួកលោកអ្នកមានវត្តល្អឲ្យរីករាយ ព្រះជិនស្រីទ្រង់ត្រេកអរនឹងគុណនោះ ទើបតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំង

ពួនខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះទព្វមល្លបុត្តត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ទព្វមល្លបុត្តត្ថេរាបទាន ។

# អដ្ឋកថា

## ឧត្តមលុប្បុត្តត្ថេរាបទាន

[ ១២៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះថា អបទានរបស់ព្រះឧត្តមលុប្បុត្តត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតជាបុត្តសេដ្ឋីក្នុងនគរហង្សវតី ជាអ្នកសម្បូរដោយសម្បត្តិ ជ្រះថ្លាក្នុងព្រះសាស្ដា ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា ឃើញភិក្ខុមួយរូបដែលព្រះសាស្ដាទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈជាងភិក្ខុអ្នកចាត់ចែងសេនាសនៈ មានចិត្តជ្រះថ្លា និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានថ្វាយមហាទានអស់ ៧ ថ្ងៃ លុះកន្លងទៅ ៧ ថ្ងៃ បានក្រាបចុះទៀបបាទារបស់ព្រះមានព្រះភាគ ហើយប្រាថ្នាតំណែងនោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ការប្រាថ្នានឹងសម្រេច ទើបទ្រង់ព្យាករ ។

កុលបុត្តនោះ បំពេញកុសលកម្មដរាបដល់អស់ជីវិត ហើយចុតិចាកអត្តភាពនោះហើយ បានសោយទិព្វសម្បត្តិក្នុងពួកទេវតាជាន់តុសិតជាដើម ចុតិចាកអត្តភាពនោះហើយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាវិបស្សី កុលបុត្តនោះ បានកើតក្នុងត្រកូលមួយ ព្រោះបានគប់រកអសប្បុរស ទាំងដែលដឹងថា ភិក្ខុសាវករបស់ព្រះមានព្រះភាគអង្គនោះជាព្រះអរហន្ត ក៏នៅតែពោល

បន្តាច់ដោយពាក្យមិនពិត ។ កុលបុត្តនោះ បានថ្វាយសលាកកត្ត ដែលធ្វើអំពីទឹកដោះ ដល់សាវកទាំងឡាយរបស់ព្រះពុទ្ធអង្គនោះឯង ។ កុលបុត្តនោះបានធ្វើបុណ្យដរាបដល់អស់អាយុហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិទាំង ២ ហើយ ក្នុងកាលនៃព្រះកស្សបទសពលបានកើតក្នុងផ្ទះមានត្រកូល ចេញបួសក្នុងកាលសាសនាជិតវិនាស កាលព្រះមានព្រះភាគបរិនិព្វានហើយ សំឡេងប្រកាស ( ថាសាសនាវិនាស ) កើតឡើងក្នុងលោកទាំងមូល ភិក្ខុ ៧ អង្គ បួសហើយ ឡើងទៅលើភ្នំមួយដែលនៅកណ្តាលព្រៃ ក្នុងបច្ចន្តជនបទ ពោលថា អ្នកណាសោកស្តាយជីវិតសូមចុះទៅ អ្នកណាមិនអាល័យក្នុងជីវិតសូមអង្គុយ ហើយប្រានបង្អើងចោលព្រះថេរៈដែលជាប្រធាន ទូន្មានដល់ភិក្ខុទាំងនោះ បានជាព្រះអរហន្តខាងក្នុង ៧ ថ្ងៃ ។ ព្រះថេរៈ បន្ទាប់អំពីព្រះថេរៈនោះបានជាព្រះអនាគាមី ។ ព្រះថេរៈ ៥ រូបដ៏សេស ជាអ្នកមានសីលបរិសុទ្ធ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយទិព្វសុខក្នុងទេវលោកនោះអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាបុគ្គល ៤ នាក់ គឺបុក្កុសាតិ ១ សភិយៈ ១ ពាហិយៈ ១ កុមារកស្សបៈ ១ ចំណែកព្រះថេរៈនេះ កើតក្នុងអនុបិយនគរក្នុងដែនមល្លៈ ។ មាតាបានធ្វើកាលកិរិយា ក្នុងវេលាដែលទារកនោះមិនទាន់ចេញចាកឧទរ ។ តមក អ្នកពុកម្នាក់ លើកសរីរៈរបស់នាងដាក់លើជើងថ្ករ ដើម្បីធ្វើឈាបនកិច្ច នាំទារកដែលជ្រុះទៅត្រង់គំនរឧសយកទៅចិញ្ចឹម[១] ព្រោះហេតុនោះ ទើប

១-ក្នុងអដ្ឋកថាថេរគាថាថា យកទៅឲ្យជីដូនជីតាចិញ្ចឹម ។

ព្រះថេរៈនេះឈ្មោះថាទព្វមល្លបុត្ត ព្រោះធ្លាក់ត្រង់គំនរឧស ។ ក្នុងកាលតមក ដោយអំណាចបុញ្ញសម្ភារដែលបានធ្វើក្នុងកាលមុន ទើបលោកបួស ហើយប្រកបសេចក្តីព្យាយាម ចម្រើនកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ។

លំដាប់នោះ ព្រះសាស្តា ទ្រង់តាំងព្រះថេរៈទុកក្នុងតំណែងខាងរៀបចំសេនាសនៈ និងក្នុងតំណែងចាត់ចែងភត្តដល់ភិក្ខុទាំងឡាយ ព្រោះលោកដាក់ខ្លួនជាកណ្តាល និងព្រោះលោកមានអានុភាពបរិបូណ៌ ឯភិក្ខុសង្ឃទាំងអស់ក៏ព្រមទទួលលោក រឿងនេះមានក្នុងវិនយក្ខន្ធកៈហើយ ។ ក្នុងកាលតមក ព្រះថេរៈបានឧទ្ទិសសលាកភត្តរបស់អ្នកថ្វាយសលាកភត្តដែលល្អម្នាក់ ដល់ពួកភិក្ខុមេត្តិយនិងភុម្មជកៈ ។ ពួកភិក្ខុទាំងនោះ ត្រេកអរ កើតឧស្សាហៈថា ស្អែកនេះ ពួកយើងនឹងបរិភោគភត្តដែលលាយដោយសណ្តែកបាយ ទឹកដោះស្រស់ និងទឹកឃ្មុំរបស់យើង ។ ឯឧបាសកនោះដឹងថា ស្វាគដល់វារៈរបស់ភិក្ខុទាំងនោះ ទើបប្រាប់ទាសីថា នែនាង ស្អែកនេះ ភិក្ខុរូបណាមកក្នុងទីនេះ ចូរនាងអង្គាសភិក្ខុទាំងនោះ ដោយបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ។ ទាសីនោះក៏បាននិមន្តឲ្យភិក្ខុ ២ រូបនោះ ដែលមកដល់ ឲ្យអង្គុយត្រង់របៀងជង្រុក ប្រគេនឲ្យឆាន់តាមដែលម្ចាស់ប្រាប់ ។ ភិក្ខុទាំងនោះមិនពេញចិត្ត ធ្វើសំឡេង តជៈ តជៈ ដោយសេចក្តីក្រោធ ចងអាឃាតក្នុងព្រះថេរៈ អង្គុយអាក់អន់ចិត្តថា ព្រះថេរៈរូបនេះឯង ញុះញង់ឲ្យមធុរភត្តទាយកឲ្យឲ្យភត្តដែលមិនឆ្ងាញ់ដល់ពួកយើង ។ លំដាប់នោះ ទើបភិក្ខុនីឈ្មោះមេត្តិយា សួរភិក្ខុ

ទាំងនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់មានទុក្ខអ្វីឬ ភិក្ខុទាំងនោះពោលថា នែប្អូនស្រី កាលពួកយើងត្រូវទព្វមល្លបុត្តបៀតបៀន ហេតុអ្វី ទើបនាងព្រងើយកន្តើយ ។ ភិក្ខុនីក៏សួរថា បពិត្រលោកម្ចាស់ មានរឿងអ្វីដែលខ្ញុំអាចជួយធ្វើបាន ភិក្ខុទាំងនោះពោលថា ចូរនាងលើកទោសរបស់ព្រះទព្វមល្លបុត្តចុះ ។ ភិក្ខុនីនោះក៏ពោលទោសព្រះថេរៈដោយពាក្យមិនពិត ក្នុងទីផ្សេងៗ ។ ភិក្ខុទាំងឡាយ បានស្តាប់រឿងនោះហើយ ទើបក្រាបទូលឲ្យព្រះមានព្រះភាគបានជ្រាប ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ហៅព្រះទព្វមល្លបុត្តមកហើយត្រាស់សួរថា ម្នាលទព្វៈ បានឮថា អ្នកបានធ្វើប្រការចម្លែកដល់នាងមេត្តិយាភិក្ខុនីពិតឬ ។ ព្រះទព្វមល្លបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់រមែងជ្រាបថា ខ្ញុំព្រះអង្គដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ទព្វៈ ពួកទព្វមល្លបុត្តទាំងឡាយ មិនពោលបណ្តោះបណ្តោយយ៉ាងនេះឡើយ អ្នកចូរប្រាប់ថា អ្នកបានធ្វើ ឬមិនបានធ្វើ ។ ព្រះទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនបានធ្វើ ។ ព្រះមានព្រះភាគត្រាស់ថា ចូរញ៉ាំងមេត្តិយាភិក្ខុនីឲ្យវិនាស ហើយចូរសាកសួរភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយមានព្រះឧបាលិត្ថេរជាប្រធាន ក៏ឲ្យមេត្តិយាភិក្ខុនីនោះសឹក សាកសួរមេត្តិយនិងភុមជកភិក្ខុ កាលពួកភិក្ខុទាំងនោះប្រាប់ថា ពួកខ្ញុំបានប្រើភិក្ខុនីនោះឯងដូច្នេះហើយ ទើបនាំគ្នាក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តអាបត្តិសង្ឃាទិសេស ព្រោះពោលចោទមិនមានមូលរបស់ពួកភិក្ខុមេត្តិយនិងភុមជក ។

ក្នុងសម័យនោះឯង ព្រះទព្វត្ថេរ ចាត់ចែងសេនាសនៈសម្រាប់ពួកភិក្ខុ ចាត់ចែងឲ្យពួកភិក្ខុដែលស្នើទៅនៅក្នុងវិហារធំ ១៨ កន្លែង ជុំវិញវត្តវេឡុវ័ន មហាវិហារ ក្នុងពេលយប់ ប្រើម្រាមដៃឲ្យកើតជាពន្លឺក្នុងទីងងឹត ពួកភិក្ខុដែលមិនមានឫទ្ធិទៅដោយពន្លឺនោះឯង កាលកិច្ចចាត់ចែងសេនាសនៈ និងកិច្ចចាត់ចែងភត្តរបស់ព្រះថេរៈកើតប្រាកដហើយយ៉ាងនេះ ព្រះសាស្តា កាលទ្រង់តែងតាំងព្រះថេរៈក្នុងឋានន្តរ កណ្តាលពួកព្រះអរិយៈ ទើបស្ថាបនាទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកក្រាលសេនាសនៈដែលជាសាវ័ករបស់តថាគត ស្រេចនឹងទព្វមល្លបុត្តប្រសើរជាងគេ ដូច្នេះ ។

ព្រះថេរៈរឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យជាដើមថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះជាដើម ។

ពាក្យទាំងអស់មានអត្ថដូចខ្ញុំបានពោលមកហើយ ខាងដើមនោះឯង ភ្ជាប់សេចក្តីថា ក្នុងកប្បទី ៩១ បន្ទាប់ពីកប្បនេះ ព្រះលោកនាយក ព្រះនាមថាវិបស្សី ទ្រង់កើតឡើងហើយក្នុងលោក ។ បទថា **ទុដ្ឋចិត្តោ** សេចក្តីថា ជាអ្នកមានចិត្តប្រទូស្ត គឺជាអ្នកមានចិត្តមិនផូរផង់ ព្រោះសេពគប់នឹងបាបមិត្ត ។ បទថា **ឧបវទឹ សាវកំ តស្ស** សេចក្តីថា ខ្ញុំបានប្រទូស្តសាវ័កដែលជាព្រះខីណាស្រព របស់ព្រះមានព្រះភាគអង្គនោះ គឺខ្ញុំបានយកពាក្យដែលមិនពិតពោលសង្កត់សង្កិន បានដល់ ធ្វើនូវការពោលបង្កាច់ ។ បទថា **ទុន្ទុភិយោ** សេចក្តីថា ស្គរ លោកហៅថា **ទុន្ទុភិ** ព្រោះបន្លឺសំឡេងថា **ទុំ ទុំ** ដូច្នេះ ។

*បទថា* **ឆាទយីសុ** *ប្រែថា វាយឲ្យកើតសំឡេង ។ បទថា* **សមន្តតោ អសនិយោ** *ឈ្មោះថា* **អសនី** *ព្រោះនាំឲ្យកើតការលំបាក បានដល់ សេចក្តីវិនាសគ្រប់ទិស ។ ក្តាប់សេចក្តីថា ទេវទណ្ឌ ( រន្ទះ ) នាំភ័យមក និងនាំនូវការពុះប្រៀកចុះមក ។*

*បទថា* **ឧក្កា បតីសុ ឆភសា** *សេចក្តីថា គំនរភ្លើងបានធ្លាក់ចុះមកអំពីអាកាស ។ បទថា* **ធូមកេតុ ច ធិស្សតិ** *សេចក្តីថា គំនរភ្លើងដែលប្រកបដោយផ្សែងរមែងប្រាកដច្បាស់ ។ ពាក្យដ៏សេសមានអត្ថដឹងបានងាយហើយ ។*

*អដ្ឋកថាទព្វមល្លបុត្តត្ថេរាបទាន ចប់*

# កុមារកស្សបត្ថេរាបទានទី ៩

[ ១២៥ ] ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ជានាយក ទ្រង់ទំនុកបម្រុងសត្វលោកទាំងពួង ជាអ្នកប្រាជ្ញ ទ្រង់កើតឡើង ( ក្នុងលោក ) ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ មានល្បីល្បាញ ជាអ្នកដល់នូវត្រើយនៃត្រៃវេទ កាលដើរទៅដើម្បីសម្រាកក្នុងវេលាថ្ងៃ ក៏បានជួបប្រទះព្រះលោកនាយក ព្រះអង្គជាធម្មកថិកដ៏ត្រកាល ទ្រង់កំពុងប្រកាសសម្តែងនូវសច្ចៈ ៤ កំពុងញ៉ាំងមហាជនព្រមទាំងទេវតានិងសាវកឲ្យត្រាស់ដឹង ។ គ្រានោះ ខ្ញុំមានចិត្តរីករាយ បាននិមន្តព្រះតថាគត រួចតាក់តែងមណ្ឌបដោយសំពត់ មានពណ៌ក្រហមផ្សេងៗ ហើយនិមន្តព្រះពុទ្ធព្រមទាំងព្រះសង្ឃដែលមានរស្មីប្រាលរន្ទាលដូចរតនៈផ្សេងៗ ឲ្យឆាន់ក្នុងមណ្ឌបនោះ លុះឆាន់ចង្ហាន់មានរសដ៏ប្រសើរផ្សេងៗគ្រប់ ៧ ថ្ងៃហើយ ទើបខ្ញុំបូជាព្រះតថាគតព្រមទាំងសាវកដោយផ្កាដ៏វិចិត្រផ្សេងៗ ហើយក្រាបទៀបព្រះបាទា ប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះមុនីដ៏ប្រសើរ ព្រះអង្គមានករុណា មានករុណាជាលំនៅ ទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរមើលព្រាហ្មណ៍ដ៏ប្រសើរនុ៎ះ ដែលមានមុខនិងភ្នែកដូចផ្កាឈូក ជាអ្នកច្រើនដោយបីតិនិងបាមុជ្ជៈ មានរោមឆ្លើង ជាអ្នកនាំមកនូវសេចក្តីរីករាយ មានភ្នែកស្រឡះ មានសេចក្តីអាល័យក្នុងសាសនានៃតថាគត មានវត្តប្រតិបត្តិតែមួយ មានចិត្តល្អ បានក្រាបទៀបបាទានៃតថាគត ព្រាហ្មណ៍នុ៎ះ ប្រាថ្នានូវតំណែងនោះ គឺភាពជាអ្នកសម្តែងធម៌ដ៏វិចិត្រ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូល

ស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តាក្នុងលោក ព្រះនាមគោតម ។ ឯព្រាហ្មណ៍នុ៎ះ នឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌ របស់ព្រះសាស្តានោះហើយ នឹងបានជាសាវកនៃព្រះសាស្តាឈ្មោះថា កុមារកស្សបៈ ។ ដោយអានិសង្សនៃផ្កា និងសំពត់ដ៏វិចិត្រ និងរតនៈទាំងឡាយ កុមារកស្សបៈនោះ នឹងបានដល់នូវភាពនៃខ្លួនប្រសើរលើសលុប ជាងជម្មកថិកត្រកាលទាំងឡាយ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវសេចក្តីប្រាថ្នានោះផង ខ្ញុំលុះលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំវិលចុះវិលឡើងក្នុងភពតូចនិងភពធំ ហាក់ដូចជាអ្នករបាំ ( ដែលរាំវិលចុះឡើង ) ក្នុងកណ្តាលរឿណវគ្គ ខ្ញុំជាសត្វត្រូវកើតដោយសាខម្រឹគបានចូលទៅចាប់ផ្ទៃក្នុងមេម្រឹគ ។ កាលខ្ញុំកំពុងនៅក្នុងគភ៌ កាលនោះ វេនដែលគេសម្លាប់ក៏មកដល់ ឯមាតារបស់ខ្ញុំត្រូវសាខម្រឹគលះបង់ចោល គាត់ក៏ទៅយកនិគ្រោធម្រឹគជាទីពឹងវិញ ។ កាលនោះ មាតារបស់ខ្ញុំនោះ ត្រូវស្តេចម្រឹគនោះជួយដោះអំពីមរណៈ តែមាតាខ្ញុំស៊ូលះជីវិតរបស់ខ្លួន ក៏ទូន្មានខ្ញុំយ៉ាងនេះថា ( ហៃបា បើបាចង់បានសេចក្តីចម្រើន ) ត្រូវសេពគប់នឹងនិគ្រោធម្រឹគ កុំទៅសេពគប់នឹងសាខម្រឹគឡើយ ការស្លាប់ក្នុងសម្នាក់និគ្រោធម្រឹគទើបប្រសើរ ការរស់ក្នុងសម្នាក់សាខម្រឹគពុំប្រសើរឡើយ ។

ខ្ញុំ មាតា និងម្រឹគដទៃ ត្រូវស្តេចម្រឹគនោះប្រៀនប្រដៅហើយ ក៏ទទួលធ្វើតាមនូវឱវាទរបស់ស្តេចម្រឹគនោះ ហើយបានទៅកើតក្នុងពិមាននៅឋានតុសិត

ជាទីត្រេកអរ ហាក់ដូចជាបុគ្គលទៅកាន់ទីព្រាត់ប្រាស ហើយបានត្រឡប់មក ផ្ទះខ្លួនវិញ ។

កាលសាសនានៃព្រះពុទ្ធកស្សបៈ ជាអ្នកប្រាជ្ញសាបសូន្យទៅ ខ្ញុំបានឡើង ទៅលើកំពូលភ្នំ ហើយប្រកបតាមសាសនានៃព្រះជិនស្រីទៀត ។ ឥឡូវនេះ ខ្ញុំទៅចាប់ផ្ទៃក្នុងត្រកូលសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ឯមាតារបស់ខ្ញុំ បានចូលទៅ កាន់ផ្នួសទាំងមានគភ៌ ។ ពួកភិក្ខុនីលុះបានដឹងថាមាតាខ្ញុំនោះមានគភ៌ហើយ ក៏នាំគ្នាចូលទៅប្រាប់ទេវទត្ត ទេវទត្តនោះ បាននិយាយថា នាងទាំងឡាយចូរ ញុំាងភិក្ខុនីដ៏លាមកនេះឲ្យវិនាស ។ ឥឡូវនេះ មាតាជាព្រះជននីរបស់ខ្ញុំ មាន សេចក្តីសុខ ក្នុងសម្នាក់ភិក្ខុនី ដោយសារព្រះមុនិន្ទជិនស្រីទ្រង់អនុគ្រោះ ។ ព្រះបាទកោសលរក្សាផែនដី ទ្រង់ជ្រាបហេតុនោះហើយ ក៏បានចិញ្ចឹមខ្ញុំដោយ គ្រឿងរក្សាកុមារ ខ្ញុំមានឈ្មោះថាកស្សបៈ ។ ខ្ញុំពឹងពាក់អាស្រ័យនឹងព្រះមហា កស្សបៈ ទើបបានឈ្មោះថា កុមារកស្សបៈវិញ ខ្ញុំបានស្តាប់ធម៌ដែលព្រះពុទ្ធ ទ្រង់សម្តែងថា រាងកាយប្រាកដដូចជាដំបូក ។ លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួច ស្រឡះចាកអាសវៈ ព្រោះមិនមានការប្រកាន់សព្វគ្រប់ ខ្ញុំទូន្មាននូវខ្លួនឲ្យបាន បែបបទហើយ ក៏បានដល់នូវទីជាឯតទគ្គៈ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញ ហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបាន កាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះ ពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ

ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុមារកស្សបត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ កុមារកស្សបត្ថេរាបទាន ។

## ចប់ ភាណវារៈទី ២៤

# អដ្ឋកថា

# កុមារកស្សបត្ថេរាបទាន

[ ១២៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះថា អបទានរបស់ព្រះកុមារកស្សបត្ថេរ មានពាក្យផ្ដើមថា **ឥតោ សត-សហស្សម្ហិ** ដូច្នេះ ។

បានឮថា ព្រះថេរៈអង្គនេះ ក្នុងកាលព្រះមានព្រះភាគព្រះនាមថាបទុ-មុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយខណៈដែលស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ឃើញភិក្ខុមួយរូបដែលព្រះសាស្ដា ទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុអ្នកពោលធម្មកថាដ៏វិចិត្រ ខ្លួនឯងក៏ប្រាថ្នាតំណែងនោះដែរ ទើបតាំងបណិធានទុក ធ្វើបុណ្យទាំងឡាយដែលសមគួរដល់តំណែងនោះ តម្កល់ជីវិតដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំង ២ ក្នុងកាលព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតក្នុងផ្ទះមានត្រកូល បួសបំពេញសមណធម៌ក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះ អន្ទោលទៅតែក្នុងសុគតិប៉ុណ្ណោះ បានសោយទិព្វសុខ និងមនុស្សសុខហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទៃរបស់កូនស្រីសេដ្ឋីម្នាក់ ក្នុងក្រុងរាជគ្រឹះ បានឮថា កូនស្រីសេដ្ឋីនោះ មានបំណងនឹងបួស ក្នុងកាលនៅក្មេងនោះឯង ទើបសូមអនុញ្ញាតមាតាបិតា កាលមិនបានបួស ទើបទៅកាន់ត្រកូលស្វាមី មានគភ៌ តែមិនដឹងថាមានគភ៌ ទើបគិតថា អញនឹងធ្វើឲ្យស្វាមីត្រេកអរហើយ

សឹមសូមអនុញ្ញាតបួស ។ កាលនាងធ្វើឲ្យស្វាមីត្រេកអរ ដោយការចង្អុលបង្ហាញឲ្យឃើញទោសរបស់រូបកាយដោយន័យជាដើមថា

បពិត្រអយ្យបុត្ត បើខាងក្នុងសរីរកាយនេះ ពន្ធាត់ចេញមកខាងក្រៅ បុគ្គលនឹងត្រូវកាន់ដំបងចាំដេញពួកក្អែក និងពួកឆ្កែដោយពិត ។ ទើបធ្វើស្វាមីឲ្យត្រេកអរ ។

ស្រីនោះ បានទទួលអនុញ្ញាតអំពីស្វាមីហើយ មិនដឹងថាមានគភ៌ ក៏បួសក្នុងសម្នាក់ភិក្ខុនីរបស់ទេវទត្ត ។ ពួកភិក្ខុនីដឹងថានាងមានគភ៌ ទើបទៅសួរទេវទត្ត ទេវទត្តនោះប្រាប់ថា ភិក្ខុនីនេះមិនមែនជាសមណៈ ។ ភិក្ខុនីនោះក៏គិតថា ខ្ញុំមិនបានបួសឧទ្ទិសទេវទត្តភិក្ខុទេ ខ្ញុំបួសឧទ្ទិសព្រះមានព្រះភាគ ដូច្នេះ ទើបទៅគាល់ព្រះមានព្រះភាគ ទូលសួរព្រះទសពល ។ ព្រះសាស្តាទ្រង់ប្រគល់ឲ្យព្រះឧបាលិត្ថេរទទួលសាកសួរ ព្រះថេរៈអញ្ជើញត្រកូលអ្នកក្រុងសាវត្ថី និងនាងវិសាខាឧបាសិកាមកវិនិច្ឆ័យរឿងនោះ ចំពោះមុខបរិស័ទ មានព្រះរាជាផងដែរ ហើយប្រាប់ថា នាងមានគភ៌មុនបួស ទើបការបួសមិនជាអន្តរាយឡើយ ។ ព្រះសាស្តាបានស្តាប់រឿងនោះហើយ ត្រាស់ថា ឧបាលីវិនិច្ឆ័យអធិករណ៍ត្រឹមត្រូវល្អហើយ ទើបប្រទានសាធុការដល់ព្រះថេរៈ ។

ភិក្ខុនីរូបនេះ បានប្រសូតបុត្តដែលមានរូបល្អដូចមាស ព្រះបាទបសេនទិ-កោសល ទ្រង់ព្រះតម្រិះថា ការចិញ្ចឹមទារកជាកង្វល់របស់ភិក្ខុនី ទើបប្រទានឲ្យព្រះញាតិទទួលទៅចិញ្ចឹម ។ ពួកញាតិបានដាក់ឈ្មោះទារកនោះថាកស្សបៈ ។ ក្នុងកាលតមក ព្រះរាជាប្រដាប់តាក់តែងហើយ នាំទៅកាន់សម្នាក់ព្រះសាស្តា

ឲ្យបព្វជ្ជា ។ ព្រោះលោកបួសក្នុងកាលដែលនៅជាកុមារ កាលព្រះមានព្រះភាគត្រាស់ថា ពួកអ្នកចូរហៅកស្សបៈមក ពួកអ្នកចូរឲ្យផ្លែឈើ ឬរបស់គួរទំពានេះដល់កស្សបៈ ពួកភិក្ខុក៏ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កស្សបៈមួយណា ព្រះសាស្តាត្រាស់ថា កុមារកស្សបៈ ព្រោះមានឈ្មោះដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ប្រាប់បែបនេះ នឹងជាបុត្តដែលព្រះរាជាទ្រង់ចិញ្ចឹម ទោះបីចាស់ហើយ ក៏គេនៅតែហៅថា កុមារកស្សបៈនោះឯង ។

តាំងអំពីបួសហើយ លោកបំពេញវិបស្សនាកម្មដ្ឋាន និងសិក្សាព្រះពុទ្ធវចនៈ ។ លំដាប់នោះ មហាព្រហ្មដែលបំពេញសមណធម៌ត្រង់កំពូលភ្នំជាមួយព្រះថេរៈ ជាព្រះអនាគាមី ដែលបានទៅកើតក្នុងសុទ្ធាវាស គិតថា អញនឹងចង្អុលផ្លូវវិបស្សនា ហើយប្រាប់ឧបាយដើម្បីសម្រេចមគ្គផល ដូច្នេះហើយទើបចងបញ្ហា ១៥ ប្រការ ប្រាប់ដល់ព្រះថេរៈដែលនៅក្នុងព្រៃអន្ធវ័នថា លោកម្ចាស់គួរសួរបញ្ហាទាំងនេះនឹងព្រះសាស្តា ។ គ្រានោះ ទើបលោកទូលសួរបញ្ហាទាំងនោះនឹងព្រះមានព្រះភាគ ។ ព្រះមានព្រះភាគក៏ទ្រង់វិសជ្ជនាដល់ព្រះថេរៈ ។ ព្រះថេរៈរៀនបញ្ហាទាំងនោះ ដោយទំនងដែលព្រះមានព្រះភាគត្រាស់ហើយទាំងអស់ ញុំាងវិបស្សនាឲ្យតាំងគភ៌ បានសម្រេចអរហត្ត ។

កុមារកស្សបៈនោះ លុះបានសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមក ក្នុងកាលមុន ទើបពោលពាក្យថា **ឥតោ សតសហស្សម្ហិ** ដូច្នេះជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យណាដែលពោលអធិប្បាយទុកមុនហើយ និង

មានអត្ថមិនលំបាក ខ្ញុំមិនពណ៌នាពាក្យទាំងអស់នោះទេ នឹងពណ៌នាចំពោះបទដែលលំបាក ។

បទថា **អាបន្នសត្តា មេ មាតា** សេចក្តីថា មាតារបស់ខ្ញុំមានគភ៌គ្រប់ខែ គឺជាស្រីមានគភ៌ បានដល់ មានគភ៌ចាស់ជិតពេលប្រសូត ។ បទថា **វម្មិកសទិសំ កាយំ** សេចក្តីថា ឈ្មោះថា សរីរៈ រមែងដូចគ្នានឹងដំបូក ។ ដំបូកមានរន្ធតូចរន្ធធំខាងនោះខាងនេះ ជាទីនៅអាស្រ័យរបស់សត្វទាំងឡាយដូចជាជីងចក់ និងកណ្តៀរជាដើម យ៉ាងណា ព្រះពុទ្ធមានព្រះភាគទ្រង់សម្តែង គឺទ្រង់ប្រកាសទុកថា រាងកាយនេះមានរន្ធ ៩ មានវត្ថុមិនស្អាតហូរចេញជានិច្ច ក៏យ៉ាងនោះដូចគ្នា អធិប្បាយថា កាលបានស្តាប់ព្រះតម្រាស់នោះហើយ ចិត្តរបស់ខ្ញុំមិនប្រកាន់អាសវៈទាំងឡាយ ផុតចាកកិលេសដោយមិនមានពិសេសសល់ គឺតាំងនៅក្នុងអរហត្តផល ។ ក្នុងកាលតមក ព្រះសាស្តាទ្រង់ជ្រាបអំពីភិក្ខុទាំងឡាយក្នុងទីផ្សេងៗថា ព្រះថេរៈនោះ ជាអ្នកពោលធម្មកថាដ៏វិចិត្រ ទើបទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះសំដីដ៏វិចិត្រ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងកុមារកស្សបៈ ប្រសើរជាងគេ ដូច្នេះ ។

*អដ្ឋកថាកុមារកស្សបត្ថេរាបទាន ចប់*

# ពាហិយត្ថេរាបទានទី ៦

[ ១២៦ ] ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ព្រះអង្គមានរស្មីច្រើន ជាកំពូលនៃត្រៃលោក ស្តេចកើតឡើង ( ក្នុងលោក ) ។ ខ្ញុំបានឮព្រះមុនីទ្រង់សរសើរគុណនៃភិក្ខុអ្នកត្រាស់ដឹងឆាប់ ក៏មានចិត្តអណ្តែតឡើង ហើយបានធ្វើគ្រឿងសក្ការៈថ្វាយព្រះមហេសី ។ ក្នុងកាលនោះ ខ្ញុំបានថ្វាយទានដល់ព្រះមុនី ព្រមទាំងសិស្សអស់ ៧ ថ្ងៃ ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធទ្រង់ព្យាករខ្ញុំថា អ្នកទាំងឡាយចូរមើលព្រាហ្មណ៍នុ៎ះ ដែលក្រាបទៀបបាទមូលនៃតថាគត ជាអ្នកមានប្រាជ្ញាជាគ្រឿងពិចារណាពេញបរិបូណ៌ មានអវយវៈដូចជាគ្រឿងបូជាដែលគេទឹបមាស មានសម្បុរសមានស្បែកស្តើង មានបបូរមាត់ក្រហមដូចផ្លែបាសទុំដែលសំយុងចុះរយោង-រយាន ជាព្រាហ្មណ៍ស្មើដោយវត្ថុដ៏ត្រជាក់មុត ។ មានកម្លាំង គឺគុណដ៏ច្រើន មានរោមដ៏រៀវឡើងលើ មានអណ្តូងជាទីនៅនៃគុណកើតហើយ មានមុខរីកដោយបីតិ ។ ព្រាហ្មណ៍នេះ ប្រាថ្នាតំណែងនៃភិក្ខុអ្នកត្រាស់ដឹងឆាប់ ។ ព្រះពុទ្ធជាមហាវីរបុរសព្រះនាមគោតមនឹងមានក្នុងអនាគតកាល ។ ( ព្រាហ្មណ៍នេះ ) នឹងជាអ្នកទទួលនូវមត៌កក្នុងធម៌ព្រះគោតមនោះ ជាឱរសដែលធម៌និម្មិតហើយ នឹងបានជាសាវ័កនៃព្រះសាស្តា ឈ្មោះថាពាហិយៈ ។

គ្រានោះ ខ្ញុំត្រេកអរ បានក្រោកឡើងធ្វើសក្ការៈចំពោះព្រះមហាមុនីដរាបដល់អស់ជីវិត លុះច្យុត ( អំពីមនុស្ស ) បានទៅកើតក្នុងឋានសួគ៌ ត្រង់ទីលំនៅជារបស់ខ្លួន ។ ខ្ញុំអន្ទោលទៅ កើតជាទេវតា ឬជាមនុស្ស តែងដល់

នូវសេចក្ដីសុខ ហើយបានទទួលសម្បត្តិ ដោយអានិសង្សនៃកុសលកម្មនោះ ។ កាលសាសនាព្រះពុទ្ធកស្សបៈជាអ្នកប្រាជ្ញ ដល់នូវសេចក្ដីរៀវរោយ ខ្ញុំបានឡើងទៅលើកំពូលភ្នំ ហើយប្រកបព្យាយាមក្នុង សាសនានៃព្រះជិនស្រីទៀត ។ ខ្ញុំជាអ្នកមានសីលបរិសុទ្ធ ប្រកបដោយប្រាជ្ញា ជាអ្នកធ្វើតាមសាសនានៃព្រះជិនស្រី ពួកជន ៥ នាក់ ( ដែលប្រកបព្យាយាមជាមួយនឹងខ្ញុំ ) លុះច្យុតអំពីមនុស្សលោកទៅ បានទៅកើតក្នុងទេវលោក ។ បណ្ដាជនទាំង ៥ នាក់នោះ ខ្ញុំឈ្មោះពាហិយៈ កើតក្នុងក្រុងភារុកច្ឆៈ ជាបុរីខ្ពង់ខ្ពស់ លំដាប់នោះឯងខ្ញុំទៅកាន់សាគរឈ្មោះអប្បសិទ្ធិកៈដោយសំពៅ ។ ឯសំពៅនោះ បានបែកធ្លាយក្នុងសាគរ ខ្ញុំហែលទៅបានពីបីថ្ងៃ ក៏ធ្លាក់ទៅក្នុងលំនៅនៃសត្វមករ ជាទីគួរខ្លាចដ៏ពន្លឹក ។ គ្រានោះ ខ្ញុំប្រឹងប្រែងឆ្លងមហាសមុទ្ទ ក៏បានដល់កំពង់ផែដ៏ប្រសើរឈ្មោះសុប្បារកៈ ទាំងកំពុងមានសេចក្ដីញាប់ញ័រដ៏ចំប្រប់ ។ ខ្ញុំស្លៀកសម្បកឈើដើរចូលទៅក្នុងស្រុកដើម្បីដុំបាយ គ្រានោះ មានជនម្នាក់ត្រេកអរ ហើយនិយាយថា នេះជាព្រះអរហន្ត បាននិមន្តមកក្នុងទីនេះ ។ ពួកយើងនឹងធ្វើសក្ការៈចំពោះព្រះអរហន្តនេះ ដោយបាយ ទឹក សំពត់ ទីដេកនិងភេសជ្ជៈ ហើយនឹងបានសេចក្ដីសុខ ។ គ្រានោះ ខ្ញុំជាអ្នកបានបច្ច័យទាំង-ឡាយ ត្រូវជនទាំងនោះធ្វើសក្ការបូជា ក៏ញ៉ាំងសេចក្ដីត្រិះរិះឲ្យកើតឡើងដោយខុសឧបាយនៃប្រាជ្ញាថា អាត្មាអញជាព្រះអរហន្ត ។ លំដាប់នោះ បុព្វទេវតាមួយអង្គ ( ទេវតាជាមិត្តដែលធ្លាប់ធ្វើកុសលជាមួយគ្នាក្នុងជាតិមុន ) បានដឹងចិត្តខ្ញុំ ក៏មកជាស់តឿនខ្ញុំថា អ្នកមិនទាន់ដឹងផ្លូវជាឧបាយនៃព្រះនិព្វានទេ តើ

នឹងជាព្រះអរហន្តដូចម្តេចកើត ។ គ្រានោះ ខ្ញុំត្រូវទេវតានោះដាស់តឿនហើយ ក៏តក់ស្លុត បានសួរទេវតានោះថា បុគ្គលដូចម្តេច ដែលជាព្រះអរហន្តក្នុងលោក ជាអ្នកខ្ពង់ខ្ពស់ជាងពួកមនុស្ស ហើយអរហន្តទាំងនោះនៅទីណា ។

( ទេវតាតបថា ) ព្រះជិនស្រីព្រះអង្គមានប្រាជ្ញាច្រើន មានប្រាជ្ញាដូចផែនដីដ៏ប្រសើរ ស្តេចនៅក្នុងកោសលមន្ទីរ ទៀបក្រុងសាវត្ថី ព្រះអង្គជាសក្យបុត្ត ជាព្រះអរហន្ត មិនមានអាសវៈ ទ្រង់សម្តែងធម៌ដើម្បីដល់នូវព្រះអរហត្ត ។ ខ្ញុំគ្រាន់តែឮពាក្យទេវតានោះហើយ ក៏ឆ្អែតកាយឆ្អែតចិត្ត អស្ចារ្យក្នុងចិត្តមានចិត្តត្រេកអរ ដូចជាមនុស្សកំព្រាបានកំណប់ទ្រព្យ ( ដោយខ្ញុំគិតឃើញថា ) ការឃើញព្រះអហរន្តដ៏ខ្ពង់ខ្ពស់ មានអារម្មណ៍ជាទីបំផុត ជាការឃើញប្រពៃ ។ គ្រានោះ ខ្ញុំចេញពីស្រុកនោះ ដើរទៅកាន់សម្នាក់ព្រះសាស្តា ប្រាថ្នាឲ្យបានឃើញព្រះជិនស្រី ព្រះអង្គមានព្រះភក្ត្រប្រាសចាកមន្ទិលសព្វកាល ខ្ញុំចូលទៅក្នុងស្រុកឈ្មោះវីជិតៈ ជាទីត្រេកអរ បានសួរពួកព្រាហ្មណ៍ថា ព្រះពុទ្ធជាទីត្រេកអរនៃសត្វលោក គង់នៅក្នុងទីណា ។ លំដាប់នោះ ពួកព្រាហ្មណ៍ប្រាប់ថា ព្រះពុទ្ធដែលមនុស្សនិងទេវតាតែងថ្វាយបង្គំ ស្តេចចូលទៅក្នុងបុរី ដើម្បីស្វែងរកចង្ហាន់ បើអ្នកឯងជាអ្នកខ្វល់ខ្វាយចង់ជួបនឹងព្រះជិនស្រី ចូរទៅថ្វាយបង្គំនូវព្រះពុទ្ធ ជាអគ្គបុគ្គលក្នុងទីនោះឲ្យឆាប់ចុះ ។

លំដាប់នោះ ខ្ញុំបានទៅឯក្រុងសាវត្ថី ជាបុរីដ៏ឧត្តមយ៉ាងឆាប់ បានឃើញព្រះអង្គកំពុងស្តេចទៅដើម្បីបិណ្ឌបាត ព្រះអង្គឥតមានជាប់ព្រះហឫទ័យ ក្នុងអាហារ មានបាត្រនៅក្នុងព្រះហស្ត មានព្រះនេត្រមិនរលើមរលោម ទ្រង់សម្តែង

បំភ្លឺនូវអមតនិព្វានក្នុងទីនេះ ព្រះអង្គប្រាកដស្មើដោយលំនៅដ៏មានសិរី មាន ព្រះភក្ត្រភ្លឺដូចព្រះអាទិត្យដ៏រុងរឿង ។ លុះខ្ញុំបានជួបនឹងព្រះសាស្តានោះ ហើយ ក៏ក្រាបចុះហើយ ពោលពាក្យនេះថា បពិត្រព្រះគោតម សូមព្រះអង្គ ជាទីពឹងរបស់ខ្ញុំព្រះអង្គដែលជាអ្នកវង្វេងវិលវល់ក្នុងផ្លូវខុស ។ ព្រះមុនីទី ៧ ទ្រង់ត្រាស់ថា តថាគតកំពុងត្រាច់ទៅបិណ្ឌបាតដើម្បីបម្លងសត្វ កាលនេះជា កាលមិនគួរនឹងសម្តែងធម៌ដល់អ្នកទេ ។ គ្រានោះ ខ្ញុំជាអ្នកប្រាថ្នាក្នុងធម៌បាន អារាធនាព្រះពុទ្ធ ព្រះអង្គបានត្រាស់សម្តែងធម៌ជាបទជ្រាលជ្រៅ ជាធម៌សូន្យ ចាកកិលេសដល់ខ្ញុំ ។ ខ្ញុំលុះស្តាប់ធម៌របស់ព្រះអង្គហើយ ក៏បានដល់នូវកិរិ-យាអស់អាសវៈ ខ្ញុំមានអាយុអស់ហើយ ឱ ! ព្រះសាស្តាទ្រង់មានសេចក្តី អនុគ្រោះអ្វីម៉្លេះ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយភពទាំងពួងខ្ញុំដក ចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសាសនាព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបាន ដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះ ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។ ព្រះថេរៈឈ្មោះពាហិយទារុចិរិយៈ បានព្យាករ យ៉ាងនេះហើយ ក៏ដួលលើគំនរសំរាម ព្រោះមេគោដែលយក្ខិនីជំណែងមក ដល់ លុះព្រះពាហិយត្ថេរ ជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើននោះ ពោលសរ-សើរ បុព្វចរិតរបស់ខ្លួនរួចហើយ ក៏បរិនិព្វានក្នុងក្រុងសាវត្ថី ជាបុរីដ៏ឧត្តម ។ ព្រះពុទ្ធជាឥសីទី ៧ ចេញអំពីនគរ បានឃើញព្រះពាហិយៈជាអ្នកប្រាជ្ញនោះ

ស្មៀកសំពត់សម្បកឈើ មានការដុតកម្តៅកិលេសបន្សាត់បង់ហើយ ។ ដួល លើផែនដី ដូចជាកំណាត់ឈើ ឬដងទង់ដ៏ធំដែលគេផ្តួលចុះ មានអាយុអស់ ហើយ មានកិលេសស្ងួតហើយ ជាអ្នកធ្វើតាមសាសនាព្រះជិនស្រី ។ លំ ដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់ហៅពួកសាវក អ្នកត្រេកអរក្នុងសាសនាថា អ្នកទាំងឡាយចូរយកសពរបស់សព្រហ្មចារីទៅបូជាចុះ ។ ចូរធ្វើស្តូប ចូរ បូជា ត្បិតពាហិយៈជាអ្នកប្រាជ្ញធំនោះ ជាអ្នកធ្វើតាមពាក្យរបស់តថាគត ជា សាវកប្រសើរជាងសាវកដែលជាខិប្បាភិញ្ញា បរិនិព្វានហើយ ។ បើគាថា សូម្បីមួយពាន់ តែប្រកបដោយបទមិនជាប្រយោជន៍ មិនប្រសើរស្មើនឹងគាថា មួយបទដែលគេស្តាប់ហើយទេ ។ ទឹក ដី ភ្លើង ខ្យល់ មិនតាំងនៅក្នុងព្រះ និព្វានណា កុសលទាំងឡាយមិនរុងរឿងក្នុងព្រះនិព្វាននោះ ព្រះអាទិត្យ ក៏ មិនប្រាកដ ( ក្នុងព្រះនិព្វាននោះ ) ។ ព្រះចន្ទ ក៏មិនភ្លឺក្នុងព្រះនិព្វាននោះ ងងឹត ក៏មិនមានក្នុងព្រះនិព្វាននោះដែរ ខីណាសវព្រាហ្មណ៍ ជាមុនីដោយ ញាណ ត្រាស់ដឹងដោយខ្លួនឯងក្នុងកាលណា ក៏រួចចាករូបនិងអរូប សុខនិង ទុក្ខ ក្នុងកាលណោះ ។ ព្រះមុនីនាថជាទីពឹងនៃសត្វក្នុងត្រៃលោក បានសម្តែង យ៉ាងនេះឯង ។

បានឮថា ព្រះពាហិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយ ប្រការដូច្នេះ ។

**ចប់ ពាហិយត្ថេរាបទាន ។**

# អដ្ឋកថា

# ពាហិយត្ថេរាបទាន

[ ១២៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះថា អបទានរបស់ព្រះពាហិយទារុចិរិយត្ថេរ មានពាក្យផ្តើមថា **ឥតោ សត-សហស្សម្ហិ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវការសម្រេចក្នុងសិប្បៈ របស់ពួកព្រាហ្មណ៍ហើយ ជាអ្នកមានការដើរមិនដាច់ មិនខ្វះខាតក្នុងវេទង្គសាស្ត្រទាំងឡាយ ។ ថ្ងៃមួយ ទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ធម៌ មានចិត្តជ្រះថ្លា បានឃើញភិក្ខុមួយរូបដែលព្រះសាស្តាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈជាងពួកភិក្ខុខាងខិប្បាភិញ្ញា ជាអ្នកប្រាថ្នានូវតំណែងនោះ ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ លុះកន្លងទៅ ៧ ថ្ងៃហើយ ទើបក្រាបចុះទៀបបាទមូលរបស់ព្រះមានព្រះភាគ តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ព្រះមានព្រះភាគទ្រង់បានស្ថាបនាភិក្ខុណាទុកក្នុងតំណែងឯតទគ្គៈជាងពួកភិក្ខុខិប្បាភិញ្ញា ក្នុងអនាគតកាល សូម្បីខ្ញុំព្រះអង្គ ក៏គប្បីដូចភិក្ខុរូបនោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយផងចុះ ។ ព្រះមានព្រះភាគទ្រង់ប្រមើលដោយអនាគតំសញ្ញាណ ទ្រង់ជ្រាបថា សេចក្តីប្រាថ្នានឹងសម្រេចទើប

ទ្រង់ព្យាករថា ក្នុងអនាគតកាល កុលបុត្តនេះនឹងបួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាគោតម ជាបុគ្គលប្រសើរជាងពួកភិក្ខុដែលជាខិប្បាភិញ្ញា ។ កុលបុត្តនោះ បានធ្វើបុណ្យជាច្រើនដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក សោយសម្បត្តិក្នុងកាមាវចរ ៦ ជាន់ក្នុងទេវលោកនោះផង បានសោយសម្បត្តិ មានចក្កពត្តិសម្បត្តិជាដើម ក្នុងមនុស្សលោកច្រើនរយកោដិកប្បផង ក្នុងកាលព្រះមានព្រះភាគព្រះនាមថាកស្សបៈ កុលបុត្តនេះកើតក្នុងត្រកូលមួយកន្លែង កាលព្រះមានព្រះភាគបរិនិព្វានហើយ បានចេញបួស ។ កាលសាសនាសាបសូន្យភិក្ខុ ៧ រូបសម្លឹងឃើញការប្រព្រឹត្តខុសរបស់បរិស័ទ ៤ កើតនូវសេចក្ដីសង្វេគ នាំគ្នាចូលទៅកាន់ព្រៃគិតថា ពួកយើងនឹងធ្វើទីពឹងដល់ខ្លួនឯង អស់កាលដែលព្រះសាសនាមិនទាន់វិនាស ទើបនាំគ្នាថ្វាយបង្គំព្រះសុវណ្ណចេតិយ ហើយសម្លឹងឃើញភ្នំមួយក្នុងព្រៃនោះ ទើបពោលថា បុគ្គលមានការជាប់ចំពាក់ក្នុងជីវិតចូរត្រឡប់ទៅ បុគ្គលមិនជាប់ចំពាក់ក្នុងជីវិតចូរនាំគ្នាឡើងកាន់ភ្នំនេះ ហើយពាក់បង្អែងនាំគ្នាឡើងទៅកាន់ភ្នំនោះ ហើយច្រានបង្អែងឲ្យធ្លាក់ទៅ នាំគ្នាបំពេញសមណធម៌ ។ ក្នុងបណ្ដាភិក្ខុ ៧ រូបនោះ ព្រះសង្ឃត្ថេរបានសម្រេចអរហត្ត ដោយកន្លងទៅ ១ រាត្រីប៉ុណ្ណោះ ព្រះថេរៈទំពាឈើស្ទន់ឈ្មោះ នាគលតា ត្រង់អនោតត្តស្រះ លុបមុខហើយ នាំយកបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ហើយនិយាយនឹងភិក្ខុទាំងនោះថា អាវុសោ ចូរឆាន់បិណ្ឌបាតនេះចុះ ភិក្ខុទាំងនោះពោលថា បពិត្រលោកម្ចាស់ ពួកយើងបានធ្វើកតិកាយ៉ាងនេះឬថា ភិក្ខុរូប

ណាសម្រេចអរហត្តមុន ភិក្ខុរូបដ៏សេសចូរបរិភោគបិណ្ឌបាត ដែលភិក្ខុនោះនាំមកហើយឬ ។ ព្រះថេរៈពោលថា អាវុសោ សេចក្តីនោះមិនដូច្នោះឡើយ ។ ភិក្ខុទាំងនោះពោលថា បើយ៉ាងនោះ ពួកយើងនឹងធ្វើគុណវិសេសឲ្យកើតឡើងដូចលោកម្ចាស់សោត ខ្លួនឯងនឹងនាំមកបរិភោគឯង ដូច្នេះ ទើបមិនព្រមទទួល ។

ក្នុងថ្ងៃទី ២ ព្រះថេរៈទី ២ បានជាព្រះអនាគាមី បាននាំយកបិណ្ឌបាតមក និមន្តឲ្យភិក្ខុដ៏សេសឆាន់ដូចគ្នា ។ ភិក្ខុទាំងនោះពោលយ៉ាងនេះថា អាវុសោ ពួកយើងធ្វើកតិកាទុកឬថា ពួកយើងនឹងមិនឆាន់បិណ្ឌបាតដែលព្រះមហាថេរៈនាំមក ហើយនឹងឆាន់បិណ្ឌបាតដែលព្រះអនុថេរនាំមក ។ ព្រះថេរៈពោលថា អាវុសោ សេចក្តីនោះមិនមែនដូច្នោះឡើយ ភិក្ខុទាំងនោះពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងធ្វើគុណវិសេសឲ្យកើតឡើង ដូចពួកលោកម្ចាស់យ៉ាងនោះហើយ បើអាចរកឆាន់បានអំពីអាការរបស់បុរសរបស់ខ្លួនឯងទើបឆាន់ ។

បណ្តាភិក្ខុទាំងនោះ ព្រះថេរៈដែលបានសម្រេចអរហត្ត បានបរិនិព្វានហើយ ព្រះថេរៈអង្គទី ២ បានជាព្រះអនាគាមី ទៅកើតក្នុងព្រហ្មលោក ភិក្ខុ ៥ រូបក្រៅអំពីនេះ មិនអាចធ្វើគុណវិសេសឲ្យកើតឡើងបាន ស្គាំងស្គម ធ្វើមរណកាលក្នុងថ្ងៃទី ៧ ទៅកើតក្នុងទេវលោក សោយទិព្វសុខក្នុងទេវលោកនោះហើយ ក្នុងពុទ្ធុប្បាទកាលនេះ ចុតិចាកអត្តភាពនោះហើយ មកកើតក្នុងមនុស្សលោក ។ បណ្តាជន ៥ នោះ ជនម្នាក់បានជាព្រះរាជាព្រះនាមថា បុក្កុសាតិ ជនម្នាក់ជាកុមារកស្សបៈ នៅក្នុងនគរតក្កសិលា ដែនគន្ធារៈ[១] ជនម្នាក់ជាពាហិយទារុចីរិយៈ ជនម្នាក់ជាទព្វមល្លបុត្ត ជនម្នាក់ជាសភិយ-

បរិព្វាជក ។ បណ្ដាជន ៥ នោះ ពាហិយទារុចីរិយៈនេះ កើតក្នុងត្រកូលឈ្មួញត្រង់កំពង់សុប្បារកៈ ដល់នូវការសម្រេចក្នុងពាណិជកម្ម មានទ្រព្យច្រើន មានភោគៈច្រើន ។ កុលបុត្តនោះ បានឡើងសំពៅទៅប្រទេសដទៃមួយអន្លើដោយពួកឈ្មួញដែលកំពុងធ្វើដំណើរទៅកាន់សុវណ្ណភូមិ ចេញដំណើរទៅបានបន្តិច សំពៅក៏លិច មនុស្សដ៏សេសក៏ក្លាយជាចំណីត្រី និងអណ្ដើកសល់តែកុលបុត្តនេះម្នាក់ប៉ុណ្ណោះ តោងបន្ទះក្ដារមួយបន្ទះ ព្យាយាមហែលទឹក ក្នុងថ្ងៃទី ៧ ក៏ធ្លងដល់ត្រើយនៃកំពង់សុប្បារកៈ កុលបុត្តនោះមិនមានសំពត់ស្លៀក និងសំពត់ដណ្ដប់ មើលមិនឃើញវត្ថុដទៃ ទើបយកធ្មែចងនូវកំណាត់ឈើស្ងួតភ្ជាប់គ្នា យកមកស្លៀកដណ្ដប់ កាន់យកអំបែងអំពីទេវស្ថានទៅកាន់កំពង់សុប្បារកៈ ។ ពួកមនុស្សឃើញកុលបុត្តនោះហើយ នាំគ្នាឲ្យបបរនិងភត្តជាដើម លើកតម្កើងថា បុរសនេះជាព្រះអរហន្ត ។ កាលពួកអ្នកស្រុកនាំយកសំពត់ស្លៀកនិងសំពត់ដណ្ដប់មកឲ្យ គិតថា បើអញស្លៀកដណ្ដប់សំពត់សោត លាភនិងសក្ការៈរបស់អញនឹងអស់ទៅ ទើបមិនប្រើសំពត់ទាំងនោះ ប្រើប្រាស់សំពត់សម្បកឈើតែម្យ៉ាង ។

តមក កាលមហាជនលើកតម្កើងថា ជាព្រះអរហន្ត ជាព្រះអរហន្ត យ៉ាងនេះ ទើបកុលបុត្តនោះកើតគំនិតឡើងយ៉ាងនេះថា ព្រះអរហន្ត ឬអ្នកបដិបត្តិ-ដើម្បីសម្រេចអរហត្តមានក្នុងលោកនេះ អាត្មាអញ ក៏ជាបុគ្គលម្នាក់ បណ្ដាព្រះអរហន្តទាំងនោះ កុលបុត្តនោះ ចិញ្ចឹមជីវិតដោយការបោក បញ្ឆោតអ្នកដទៃបែបនេះ ។

ក្នុងចំនួនបុគ្គល ៧ នាក់ ដែលឡើងភ្នំបំពេញសមណធម៌ ក្នុងសាសនានៃព្រះកស្សបទសពល បុគ្គលម្នាក់ជាអនាគាមី បានទៅកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស សម្លឹងមើលព្រហ្មសម្បត្តិរបស់ខ្លួនថា មកអំពីណា ក៏ឃើញទីដែលឡើងភ្នំបំពេញសមណធម៌ ហើយពិចារណាដល់ទីដែលបុគ្គលដ៏សេសទៅកើត ដឹងថា ភិក្ខុមួយអង្គបរិនិព្វាន និងដឹងថាភិក្ខុ ៥ អង្គក្រៅអំពីនេះទៅកើតក្នុងទេវលោកជាន់កាមាវចរ បានពិចារណាដល់មនុស្សទាំង ៥ តាមកាលដ៏សមគួរ ។ កាលពិចារណាថា ក្នុងពេលនេះ ជនទាំង ៥ នោះទៅកើតក្នុងទីណាហ្ន៎ ក៏បានឃើញទារុចីរិយៈអាស្រ័យកំពង់សុប្បារកៈចិញ្ចឹមជីវិត ដោយការបោកបញ្ឆោត គិតថា បុគ្គលនេះជាបុគ្គលពាលវិនាសហើយហ្ន៎ ក្នុងកាលមុន បំពេញសមណធម៌ មិនបានឆាន់បិណ្ឌបាតដែលព្រះអរហន្តនាំមកហើយដោយឧក្រិដ្ឋក្រៃលែង ឥឡូវនេះ ព្រោះត្រឹមតែផ្ទៃ ទាំងដែលមិនមែនជាព្រះអរហន្ត ក៏នៅតែអះអាងថា ជាព្រះអរហន្ត ត្រាច់បោកបញ្ឆោតសត្វលោកមិនដឹងថា ព្រះទសពលកើតឡើងហើយ អញនឹងទៅធ្វើឲ្យគេកើតសង្វេគ និងឲ្យគេដឹងថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ដូច្នេះ ។ ក្នុងខណៈនោះឯង ទើបចុះចាកព្រហ្មលោក ប្រាកដក្នុងទីចំពោះមុខទារុចីរិយៈ ក្នុងចំណែកនៃរាត្រី ត្រង់កំពង់សុប្បារកៈ ។ ទារុចីរិយៈនោះ បានឃើញពន្លឺដែលជះមកក្នុងលំនៅរបស់ខ្លួន ទើបចេញមកខាងក្រៅ ឃើញមហាព្រហ្ម ទើបផ្គងអញ្ជលីសួរថា លោកជានរណាហ្ន៎ ។ មហាព្រហ្មឆ្លើយថា យើងជាសម្លាញ់ចាស់របស់អ្នក បានសម្រេចអនាគាមិផល ហើយទៅកើតក្នុងព្រហ្មលោក ព្រះថេរៈរបស់ពួក

យើងជាព្រះអរហន្តបរិនិព្វានហើយ ឯពួកលោក ៥ រូប កើតក្នុងទេវលោក ឥឡូវនេះ យើងបានឃើញអ្នកចិញ្ចឹមជីវិតដោយការបោកបញ្ឆោតក្នុងទីនេះទើបមកដើម្បីជាស់តឿន ហើយពោលដល់ហេតុនេះថា នែពាហិយៈ អ្នកមិនមែនព្រះអរហន្ត ទាំងមិនឈានចុះកាន់ផ្លូវព្រះអរហន្ត មិនមានការបដិបត្តិ ដើម្បីឈានចុះកាន់ផ្លូវព្រះអរហន្តឡើយ ។ លំដាប់នោះ មហាព្រហ្មបានប្រាប់ថា ព្រះសាស្តាទ្រង់កើតឡើងហើយ និងបានប្រាប់ថា ព្រះសាស្តា គង់នៅក្នុងនគរសាវត្ថី បានបញ្ជូនទៅដោយពាក្យថា ចូរទៅគាល់ព្រះសាស្តាចុះ ហើយក៏បានត្រឡប់ទៅកាន់ព្រហ្មលោកវិញ ។

ឯពាហិយៈ សម្លឹងមើលមហាព្រហ្ម ដែលកំពុងឈរពោលក្នុងអាកាស គិតថា ឱ ! អញធ្វើកម្មធ្ងន់ហ្ន៎ អញមិនមែនជាព្រះអរហន្ត តែគិតថាជាព្រះអរហន្ត មហាព្រហ្មពោលនឹងអញថា អ្នកមិនមែនជាព្រះអរហន្តទេ ទាំងអ្នកក៏មិនមែនបដិបត្តិតាមគន្លងព្រះអរហន្តដែរ ក្នុងលោកនេះ មានបុគ្គលដែលជាព្រះអរហន្តទៀតឬ ។ លំដាប់នោះ ទើបពាហិយៈសួរទេវតានោះថា កាលបើដូច្នោះ ក្នុងលោកនេះ ព្រមទាំងទេវលោក អ្នកណាដែលជាព្រះអរហន្ត ឬថា អ្នកណាជាអ្នកបដិបត្តិតាមផ្លូវរបស់អរហត្ត ។ លំដាប់នោះ ទេវតាក៏ប្រាប់ថា ពាហិយៈ ក្នុងជនបទទិសខាងជើង មាននគរមួយឈ្មោះសាវត្ថី ឥឡូវនេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ កំពុងគង់នៅក្នុងនគរនោះ នែពាហិយៈ ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ទ្រង់សម្តែងធម៌ដើម្បីឲ្យបុគ្គលបានជាព្រះអរហន្ត ។ ក្នុងចំណែករាត្រីនោះ ពាហិយៈបានស្តាប់

ពាក្យរបស់ទេវតាហើយ មានសេចក្តីសង្វេគ ទើបចេញអំពីកំពង់សុប្បារកៈ ក្នុងខណៈនោះឯង ហើយបានទៅកាន់ក្រុងសាវត្ថី ដោយរាត្រីមួយប៉ុណ្ណោះ កាលទៅ ក៏ដល់នគរសាវត្ថី មានរយៈផ្លូវ ១២០ យោជន៍ អាចារ្យខ្លះពោលថា ដោយទេវានុភាព អាចារ្យខ្លះពោលថា ដោយពុទ្ធានុភាព ។

ក្នុងខណៈនោះ ព្រះសាស្តាកំពុងទ្រង់យាងចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ចូលទៅកាន់វត្តជេតពនហើយ សួរភិក្ខុច្រើនរូប ដែលកំពុងដើរចង្ក្រមក្នុងទីវាលថា ឥឡូវនេះ ព្រះសាស្តាយាងទៅឯណា ពួកភិក្ខុតបថា ព្រះសាស្តាយាងទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយសួរថា ចុះអ្នកមកអំពីណា ក៏ឆ្លើយថា ខ្ញុំមកអំពីកំពង់សុប្បារកៈ ។ សួរថា អ្នកធ្វើដំណើរមកក្នុងពេលណា ក៏ឆ្លើយថា ខ្ញុំធ្វើដំណើរមកល្ងាចម្សិលមិញនេះ ។ ពួកភិក្ខុនិយាយរាក់ទាក់ថា អ្នកធ្វើដំណើរមកឆ្ងាយ អញ្ជើញអង្គុយ លាងជើង លាបប្រេងសិនសម្រាកបន្តិច ក្នុងពេលមិនយូរ នឹងបានឃើញព្រះសាស្តា ពាហិយៈពិតថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងអន្តរាយក្នុងជីវិតរបស់ព្រះសាស្តា ឬរបស់ខ្ញុំទេ ខ្ញុំមិនបានឈរសម្រាក មិនបានអង្គុយសម្រាកក្នុងទីណាឡើយ ដើរមក ១២០ យោជន៍ ដោយរាត្រីមួយប៉ុណ្ណោះ ខ្ញុំនឹងសូមចូលគាល់ព្រះសាស្តាជាមុនសិន ហើយសឹមសម្រាកឯក្រោយ កុលបុត្តនោះពោលយ៉ាងនោះហើយ ក៏ប្រញាប់ចូលទៅកាន់ក្រុងសាវត្ថី ឃើញព្រះមានព្រះភាគ កំពុងយាងចារិកទៅដោយព្រះពុទ្ធសិរីគ្មានអ្វីប្រៀប ទើបគិតថា អស់កាលយូរហើយ ដែលអញមិនបានជួបព្រះគោតមសម្មាសម្ពុទ្ធនេះ តាំងអំពីបានឃើញហើយ ក៏បង្អោនសរីរៈទៅ

ហើយក្រាបចុះត្រង់រវាងផ្លូវដោយបញ្ចង្គប្រតិស្ឋាន ចាប់កព្រះបាទាយ៉ាងណែន ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់សម្តែងធម៌ចុះ សូមព្រះសុគតទ្រង់សម្តែងធម៌ចុះ ដែលនឹងបានជាប្រយោជន៍ ជាសេចក្តីសុខ ដល់ខ្ញុំព្រះអង្គអស់កាលយូរ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលពាហិយៈ ពេលនេះមិនមែនជាកាល តថាគតនឹងចូលទៅកាន់ចន្លោះស្រុកដើម្បីបិណ្ឌបាត ។

ពាហិយៈបានស្តាប់ព្រះតម្រាស់នោះហើយ ទើបទូលអង្វរថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអន្ទោលទៅក្នុងសង្សារវដ្ត មិនធ្លាប់បានអាហារ គឺដុំបាយមិនមាន ខ្ញុំព្រះអង្គមិនដឹងអន្តរាយក្នុងជីវិតរបស់ព្រះអង្គ ឬរបស់ខ្ញុំព្រះអង្គទេ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់ខ្ញុំ ព្រះអង្គចុះ សូមព្រះសុគតទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាត្រាស់ឃាត់យ៉ាងនោះអស់វារៈ ២ ដង ។ បានឮថា ព្រះសាស្តាមានព្រះតម្រិះយ៉ាងនេះថា តាំងអំពីពេលដែលពាហិយៈនេះឃើញតថាគត សរីរៈទាំងមូលរបស់គេត្រូវបីតិជ្រួតជ្រាបមិនមានចន្លោះ បុគ្គលមានកម្លាំងនៃបីតិខ្លាំង ទោះបីស្តាប់ធម៌ ក៏មិនអាចត្រាស់ដឹងបាន តថាគតនឹងឲ្យកុលបុត្តនេះសម្រាកមួយស្របក់ដើម្បីធ្វើខ្លួនឲ្យជាកណ្តាលជាមុនសិន ( ម្យ៉ាងទៀត ) កុលបុត្តនេះ ធ្វើដំណើរមក អស់ចម្ងាយផ្លូវ ១២០ យោជន៍ ដោយរាត្រីមួយប៉ុណ្ណោះ មានការហត់នឿយពន់ពេក តថាគតនឹងឲ្យកុលបុត្តនេះ រម្ងាប់ការហត់នឿយនោះសិន ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ឃាត់អស់វារៈ ២ ដង កាល

កុលបុត្តនោះក្រាបទូលលើកទី ៣ ប្រថាប់ឈរក្នុងរវាងផ្លូវនោះឯង ទ្រង់បាន សម្ដែងធម៌ដោយអនេកបរិយាយ ដោយន័យ ( ក្នុងខុទ្ទកនិកាយ ឧទាន ) ថា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា រូបារម្មណ៍ ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ ដូច្នេះជាដើម ។ ខណៈពាហិយៈកំពុងស្ដាប់ធម៌របស់ព្រះសាស្ដានោះឯង បានធ្វើអាសវៈទាំង ពួងឲ្យអស់ទៅហើយ បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ។

ពាហិយៈនោះ ក្នុងខណៈដែលបានសម្រេចអរហត្តហើយនោះឯង រឭក ដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលធ្លាប់ ប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **តតោ សតសហស្សម្ហិ** ដូច្នេះ ជាដើម ។ អបទាននោះមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោល ហើយខាងដើមនោះឯង ។ ខ្ញុំនឹងធ្វើការពណ៌នាចំពោះបទដែលលំបាកប៉ុណ្ណោះ ។

បទថា **ហាសជំ បច្ចវេក្ខណំ** សេចក្ដីថា កើតនូវសោមនស្ស ផ្អែត និង ឃើញប្រចក្ស គឺមានពណ៌សម្បុរដូចបុគ្គលដែលមានវ័យក្មេងល្អិតសុខុមក្រៃ លែង ។

បទថា **ហេមយញ្ញោបចិតង្គំ** សេចក្ដីថា ជាអ្នកមានអវយវៈ គឺសរីរៈ បានដល់ រាងកាយពាក់ដោយសង្វារដែលធ្វើដោយមាស ។ បទថា **បលម្ព-ពិម្ពតម្ពោដ្ឋំ** សេចក្ដីថា មានបបូរមាត់ទាំង ២ ពណ៌ក្រហមដូចផ្លែបាស់ទុំ ។ បទថា **សេតតិណ្ហសមំ ឱជំ** សេចក្ដីថា មានធ្មេញស្មើ ដូចគ្នានឹងខាត់ឲ្យ ស្មើ ដោយគ្រឿងខាត់ដែកនិងលោហៈឲ្យមុតល្អ ។ បទថា **បីតិសម្ផុល្លិតា-**

**ឆនំ** សេចក្តីថា មានទឹកមុខរីកដោយល្អដោយបីតិ គឺមានមុខផូរផង់ ដូចគ្នានឹងកញ្ចក់ ។ បទថា **វិប្បាភិញ្ញស្ស ភិក្ខុនោ** សេចក្តីថា នៃភិក្ខុដែលអាចត្រាស់ដឹងបានដោយពិសេសក្រៃលែងដោយរួសរាន់ គឺក្នុងខណៈដែលលើកធម៌ឡើងសម្តែងប៉ុណ្ណោះ ។ បទថា **សគ្គំ អគំ សភវនំ យថា** សេចក្តីថា ខ្ញុំបានទៅកាន់ស្ថានសួគ៌ដែលដូចគ្នានឹងផ្ទះរបស់ខ្លួន ដូច្នោះ ។ បទថា **ឆ តុំ ឧបាយមគ្គញ្ញូ** សេចក្តីថា មិនមែនជាអ្នកដឹងផ្លូវ ដែលជាឧបាយឲ្យបានសម្រេចព្រះនិព្វាន ។ បទថា **សត្ថុនោ សធា ជិនំ** ប្រាកដសេចក្តីថា ខ្ញុំកាលឈ្នះ គឺបង្ក្រាបការកម្រើកបាន ក៏ឃើញ គឺនឹងទៅមើលព្រះភក្ត្រដែលល្អផូរផង់ដូចកញ្ចក់ របស់ព្រះសាស្តាសម្មាសម្ពុទ្ធសព្វកាល គឺគ្រប់វេលា ។ បទថា **ធិជេ អបុច្ឆឹ កុហឹ លោកនន្ទនោ** សេចក្តីថា ខ្ញុំបានសួរពួកអ្នកកើត ២ ដង គឺព្រាហ្មណ៍ បានដល់ ពួកភិក្ខុថា ព្រះសាស្តាទ្រង់ធ្វើឲ្យសត្វលោកជ្រះថ្លាគង់នៅក្នុងទីណា ។ បទថា **សសោវ វិប្បំ មុនិទស្សនុស្សុកោ** សេចក្តីថា ជាអ្នកខ្វល់ខ្វាយ គឺមានឧស្សាហៈក្នុងការឃើញព្រះមុនី គឺក្នុងការឃើញព្រះតថាគត ចូលទៅដោយរហ័សដូចទន្សាយ ។ បទថា **តុវជំ គន្ធា** សេចក្តីថា ទៅដោយឆាប់រួសរាន់ ។ បទថា **បិណ្ឌត្តំ អបិហាគិធំ** សេចក្តីថា មិនល្មោភ ប្រាសចាកការលោភ មិនមានលោភៈទាក់ទងដោយបិណ្ឌបាត ។ បទថា **អលោលក្ខុំ** ភ្លាប់សេចក្តីថា ខ្ញុំបានឃើញព្រះមានព្រះភាគដែលមិនក្រឡេកមើលខាងនោះខាងនេះ ទ្រង់យាងទៅដើម្បីបិណ្ឌបាតក្នុងនគរសាវត្ថីដ៏ឧត្តម ។ បទថា **សិរីធិលយសង្កាសំ** សេចក្តីថា ដូចគ្នានឹងលំនៅនៃសិរី

គឺល្អដោយលក្ខណៈនិងអនុព្យញ្ជនៈ ដូច គឺដូចគ្នានឹងសសរគោលដ៏រុងរឿង ។ បទថា **រវិឆិត្តិហារានធំ** សេចក្តីថា មណ្ឌលមុខដែលរុងរឿងដូចគ្នានឹងមណ្ឌលព្រះអាទិត្យដ៏រុងរឿង ។

បទថា **កុបថេ វិប្បនដ្ឋស្ស** សេចក្តីថា សូមព្រះអង្គជាទីពឹង គឺសូមជាទីពឹងរបស់ខ្ញុំព្រះអង្គ ដែលជាអ្នកវង្វេងក្នុងផ្លូវដែលបណ្ឌិតតិះដៀល គឺក្នុងផ្លូវដែលមានអន្តរាយ បានដល់ បដិបត្តិខុស ។ ពាហិយៈហៅព្រះមានព្រះភាគដោយគោត្តថា គោតម ។ បទថា **ន តត្ថ សុក្កា ជោតន្តិ** សេចក្តីថា ពួកផ្កាយ មានផ្កាយព្រឹកដែលមានពន្លឺជាដើម ទោះបីមានរស្មីភ្លឺត្រកាលក៏មិនភ្លឺដល់ គឺមិនបញ្ចេញពន្លឺ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ពាហិយៈនោះ កាលបានប្រកាសអបទានដែលខ្លួនប្រព្រឹត្តមក ក្នុងកាលមុនយ៉ាងនេះហើយ បានទូលសូមបព្វជ្ជានឹងព្រះមានព្រះភាគ ក្នុងខណៈនោះឯង ។ កុលបុត្តនោះ ត្រូវព្រះមានព្រះភាគត្រាស់សួរថា អ្នកមានបាត្រនិងចីវរគ្រប់គ្រាន់ហើយឬ ទើបក្រាបទូលថា មិនទាន់គ្រប់គ្រាន់ទេព្រះអង្គ លំដាប់នោះ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ចូរអ្នកស្វែងរកបាត្រនិងចីវរមក ហើយទ្រង់យាងចៀសចេញទៅ ។ បានឮថា កុលបុត្តនោះ បំពេញសមណធម៌អស់ ២ ម៉ឺនឆ្នាំ ពោលថា ធម្មតាភិក្ខុគួររកបច្ច័យឯង ប្រើប្រាស់ឯង មិនចាំបាច់ទាក់ទងដោយភិក្ខុដទៃ ទើបមិនសង្គ្រោះភិក្ខុសូម្បីតែមួយរូប ដោយបាត្រឬចីវរ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា បាត្រនិងចីវរដែលសម្រេចដោយឫទ្ធិនឹងមិនកើតឡើងដល់កុលបុត្តនេះ ទើបមិនប្រទានបព្វជ្ជាដោយឯហិភិក្ខុ ។

ខណៈដែលលោកស្វែងរកបាត្រនិងចីវរ កំពុងកាយយកសេសសំពត់អំពីគំនរសំរាមនោះឯង អមនុស្ស ( យក្ខិនី ) ដែលមានពៀរនឹងគ្នាក្នុងកាលមុនចូលសណ្ឋិតក្នុងសរីរៈមេគោកូនខ្ចីមួយ ប៉ុះកុលបុត្តនោះត្រង់គល់ភ្លៅខាងឆ្វេងធ្វើឲ្យអស់ជីវិត ។ ព្រះសាស្តា ចារិកទៅបិណ្ឌបាត ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ចេញអំពីនគរមកមួយអន្លើដោយភិក្ខុជាច្រើន ទតឃើញសរីរៈរបស់ពាហិយៈ ដែលដួលចុះត្រង់គំនរសំរាម ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយពួកអ្នកចូរសែងពាហិយទារុចីរិយៈនេះទៅ ហើយប្រថាប់ឈរត្រង់ទ្វារផ្ទះមួយកន្លែង ឲ្យនាំគ្រែមក ហើយទ្រង់ត្រាស់នឹងពួកភិក្ខុថា ចូរនាំសរីរៈនេះ ចេញទៅខាងក្រៅទ្វារនគរ ធ្វើឈាបនកិច្ចហើយនាំធាតុទៅសាងស្តូបបញ្ចុះទុក ។

ពួកភិក្ខុទាំងនោះ នាំគ្នាសាងព្រះស្តូបបញ្ចុះព្រះធាតុត្រង់ផ្លូវធំហើយចូលទៅគាល់ព្រះសាស្តា បានទូលឲ្យទ្រង់ជ្រាបដល់ការងារដែលខ្លួនធ្វើ បន្ទាប់ពីនោះមក ក្នុងកណ្តាលជំនុំសង្ឃ ក៏កើតអន្តរកថាឡើងថា ព្រះតថាគត ទ្រង់ឲ្យភិក្ខុសង្ឃធ្វើឈាបនកិច្ចសរីរៈ ឲ្យរើសយកធាតុដាក់ត្រង់ចេតិយ លោកសម្រេចមគ្គជាន់ណាហ្ន៎ ជាសាមណេរឬជាភិក្ខុ ព្រះសាស្តា ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយៈតាំងនៅក្នុងអរហត្ត ហើយទ្រង់សម្តែងព្រះធម្មទេសនាបន្ថែមទៀត ព្រះសាស្តាបានត្រាស់ថា ពាហិយៈនោះបរិនិព្វានហើយ ទើបទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកត្រាស់ដឹងរហ័សដែលជាសាវករបស់តថាគត ស្រេចនឹងពាហិយទារុចីរិយៈប្រសើរជាងគេ ដូច្នេះ ។

លំដាប់នោះ ទើបពួកភិក្ខុទូលសួរថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ថា ពាហិយទារុចីរិយៈសម្រេចអរហត្តហើយ តើបានសម្រេចអរហត្ត ក្នុងកាលណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងពេលដែលកុលបុត្តនេះ បានស្តាប់ធម៌របស់តថាគតហើយ ។ ពួកភិក្ខុទូលសួរថា បពិត្រព្រះអង្គ ទ្រង់ត្រាស់សម្តែងធម៌ដល់លោកក្នុងកាលណា ព្រះសាស្តាត្រាស់ថា កាលដែលតថាគតចារិកទៅដើម្បីភិក្ខា ឈរក្នុងរវាងផ្លូវ ។ ពួកភិក្ខុទូលសួរថា បពិត្រព្រះអង្គ ទ្រង់ប្រថាប់ឈរត្រង់រវាងផ្លូវ សម្តែងធម៌បន្តិចបន្តួច ញុំាងគុណវិសេសឲ្យកើតឡើងបានដោយព្រះធម៌ត្រឹមប៉ុណ្ណោះបានដូចម្តេច លំដាប់នោះ ព្រះសាស្តាត្រាស់នឹងពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំគិតថា ធម៌របស់តថាគតតិចឬច្រើន ដ្បិតថាគាថា ១០០០ តែប្រកបដោយបទមិនជាប្រយោជន៍ ទោះបីមានច្រើន ក៏មិនប្រសើរឡើយ ឯបទគាថាត្រឹមតែ ១ បទ ដែលប្រកបដោយប្រយោជន៍ រមែងប្រសើរពិត កាលទ្រង់សម្តែងធម៌បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថា ( ក្នុងធម្មបទ ) នេះថា

> បើគាថាសូម្បី ១ ពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍
> គាថានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណា
> ហើយរមែងស្ងប់រម្ងាប់បាន បទនៃគាថានោះសូម្បីតែមួយបទ
> ក៏ឈ្មោះថាប្រសើរជាង ដូច្នេះ ។

ក្នុងវេលាចប់ធម្មទេសនា សត្វ ៨៤០០០ បានសម្រេចធម្មាភិសម័យ ។

**អដ្ឋកថាពាហិយត្ថេរាបទាន ចប់**

# មហាកោដ្ឋិកត្ថេរាបទានទី ៧

[ ១២៧ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវលោកទាំងអស់ មានចក្ខុកើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ប្រទានឱវាទ ញុំាងសត្វឲ្យដឹងចម្លងសព្វសត្វ ញុំាងពួកជនច្រើនឲ្យឆ្លង ទ្រង់អនុគ្រោះ មានសេចក្តីករុណា ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង បានញុំាងពួកតិរ្ថិយទាំងអស់ដែលមកប្រជុំគ្នា ឲ្យតាំងនៅស៊ប់ក្នុងសីល ៥ ។ សាសនានេះឯង មិនរឹករវស្សូន្យចាកពួកតិរ្ថិយ វិចិត្រដោយព្រះអរហន្តទាំងឡាយ ជាបុគ្គលស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅ បានញុំាងពួកជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ក្នុងក្រុងហង្សវតី ជាអ្នកដល់នូវត្រើយនៃវេទ បានចូលទៅជិតព្រះពុទ្ធ ជាកំពូលនៃសត្វលោកទាំងពួង ហើយស្តាប់ធម្មទេសនា ។ គ្រានោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់តាំងសាវ័ក ( មួយអង្គ ) ដែលបែកធ្លាយបដិសម្ភិទា ជាអ្នកឈ្លាសវៃក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ក្នុងទីជាឯតទគ្គៈ កាលនោះ ខ្ញុំបានឮនូវតំណែងនោះហើយ ក៏មានចិត្តរីករាយ បានញុំាងព្រះជិនស្រីដ៏ប្រសើរ ព្រមទាំងសាវ័កឲ្យឆាន់អស់ ៧ ថ្ងៃ ។ ខ្ញុំញុំាងព្រះពុទ្ធដូចជាសាគរ ព្រមទាំងសិស្សឲ្យស្លៀកសំពត់ រួចខ្ញុំក្រាបទៀបបាទមូល ប្រាថ្នាតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធជាកំពូលលោក ទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរ

មើលព្រាហ្មណ៍ដ៏ខ្ពង់ខ្ពស់នុ៎ះ ក្រាបទៀបបាទមូល មានរស្មីពួដ៏ពោះ ដូចផ្កាឈូក ព្រាហ្មណ៍នេះ ( បរិបូណ៌ ) ដោយសទ្ធា ចាគៈ និងសទ្ធម្មស្សវនៈនោះ ប្រាថ្នានូវតំណែងនៃភិក្ខុរបស់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រាហ្មណ៍នេះ ជាអ្នកដល់នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅក្នុងភពតូចភពធំ រមែងបាននូវតំណែងនុ៎ះ ដូចបំណងក្នុងកាលជាអនាគត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តាក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះនឹងបានជាធម្មទាយាទ ជាឱរសជាធម្មនិម្មិតរបស់ព្រះគោតមនោះ នឹងបានជាសាវកនៃព្រះសាស្តា មាននាមថាកោដ្ឋិកៈ ។

កាលនោះ ខ្ញុំឮពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា មានប្រាជ្ញាខ្ជាប់ខ្ជួន បានបម្រើព្រះជិនស្រីដរាបដល់អស់ជីវិត ។ ដោយផលនៃកុសលកម្មនោះផង ដោយការតម្កល់ទុកនូវសេចក្តីប្រាថ្នានោះផង ខ្ញុំលុះលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយរាជ្យជាស្តេចទេវតាអស់ ៣០០ ដង បានជាស្តេចចក្កពត្តិអស់ ៥០០ ដង ។ បានសោយប្រទេសរាជ្យដ៏ទូលាយ រាប់ជាតិមិនអស់ ខ្ញុំបានសេចក្តីសុខក្នុងទីទាំងពួង ដោយអានិសង្សនៃកុសលកម្មនោះ ។ ខ្ញុំតែងអន្ទោលទៅក្នុងភព ២ គឺទេវតាឬមនុស្ស ខ្ញុំមិនដែលស្គាល់គតិដទៃ នេះជាផលនៃកុសលកម្មដែលខ្ញុំសន្សំល្អហើយ ។ ខ្ញុំតែងកើតក្នុងត្រកូល ២ គឺក្សត្រឬព្រាហ្មណ៍ មិនដែលកើតក្នុងត្រកូលទាបថោកទេ នេះ

ជាផលនៃកុសលកម្មដែលខ្ញុំសន្សំល្អហើយ លុះដល់បច្ឆិមភព ខ្ញុំជាអ្នកមានផៅពង្សប្រសើរ ខាងក្រោយមក ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ មានធនធានច្រើន ក្នុងក្រុងសាវត្ថី មាតារបស់ខ្ញុំឈ្មោះចន្ទវតី បិតារបស់ខ្ញុំឈ្មោះអស្សលាយនៈ ព្រះពុទ្ធទ្រង់ទូន្មានបិតារបស់ខ្ញុំដើម្បីសេចក្តីស្អាត គ្រប់យ៉ាងក្នុងកាលណា ។ កាលនោះ ខ្ញុំជ្រះថ្លាចំពោះព្រះសុគត ហើយចូលទៅកាន់ផ្នួស ព្រះមោគ្គល្លានជាអាចារ្យ ព្រះសារីបុត្តជាឧបជ្ឈាយ៍ ( របស់ខ្ញុំ ) កាលសក់ទាំងឡាយដាច់ចុះ ទិដ្ឋិព្រមទាំងឫស ក៏ដាច់ចុះដែរ ខ្ញុំកំពុងតែស្លៀកសំពត់កាសាវៈ ក៏បានសម្រេចអរហត្ត ។ ប្រាជ្ញារបស់ខ្ញុំបែកធ្លាយក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ហេតុនេះបានជាព្រះពុទ្ធជាកំពូលនៃលោក ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ខ្ញុំត្រូវឧបតិស្សៈសាកសួរក្នុងបដិសម្ភិទា ក៏បានដោះស្រាយនូវធម៌ដែលខ្ទួនមិនដែលបានឃើញ ហេតុនោះហើយ បានជាខ្ញុំជាអ្នកប្រសើរ ក្នុងសាសនានៃព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើររបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកោដ្ឋិកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ មហាកោដ្ឋិកត្ថេរាបទាន ។**

# អដ្ឋកថា
## មហាកោដ្ឋិកត្ថេរាបទាន

[ ១២៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា អបទានរបស់ព្រះមហាកោដ្ឋិកត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះ ។

មានរឿងកើតឡើងដូចម្តេច ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា បទុ-មុត្តរៈ កើតក្នុងត្រកូលមានភោគៈច្រើន ក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្តីហើយ លុះមាតាបិតាអនិច្ចកម្មទៅហើយ តាំងនៅក្នុងតំណែងកុដុម្ពិកៈនៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ ក្នុងកាលដែលព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈទ្រង់សម្តែងធម៌ កុលបុត្តនោះបានឃើញអ្នកហង្សវតីនគរកាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើម ដែលកំពុងបង្អោនកាយ ទៅក្នុងទីប្រជាប់របស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ទើបចូលទៅគាល់ព្រះមានព្រះភាគ មួយអន្លើដោយមនុស្សទាំងនោះ បានឃើញភិក្ខុមួយរូប ដែលព្រះសាស្តាទ្រង់ស្ថាបនាក្នុងតំណែងដ៏ប្រសើរជាងពួកភិក្ខុដែលសម្រេចបដិសម្ភិទា ទើបគិតថា ភិក្ខុរូបនេះជាកំពូលជាងពួកភិក្ខុដែលសម្រេចបដិសម្ភិទា ក្នុងសាសនានេះបើដូច្នោះ អាត្មាអញគប្បីជាកំពូលជាងពួកភិក្ខុ ដែលសម្រេចបដិសម្ភិទា ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយដូចភិក្ខុរូបនេះ ដូច្នេះ ក្នុងវេលាចប់ទេស-

សនារបស់ព្រះសាស្តា កាលបរិស័ទក្រោកទៅហើយ ទើបចូលទៅជិតព្រះមានព្រះភាគ ហើយទូលនិមន្តថា បពិត្រព្រះអង្គ ស្អែកនេះ សូមនិមន្តទទួលភិក្ខាត្រង់ផ្ទះរបស់ខ្ញុំព្រះអង្គផងចុះ ព្រះសាស្តាទ្រង់ទទួលនិមន្តន៍ហើយ កុលបុត្តនោះ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន យកគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ប្រដាប់ត្រង់ទីគង់របស់ព្រះពុទ្ធ និងទីគង់របស់ភិក្ខុសង្ឃអស់មួយយប់ទល់ភ្លឺ ឲ្យមនុស្សចាត់ចែងខាទនីយភោជនីយាហារ លុះអស់រាត្រីនោះទៅ បាននិមន្តព្រះសាស្តាដែលមានភិក្ខុមួយសែនរូបជាបរិវារ ឲ្យឆាន់បាយស្រូវសាលី ដែលមានក្លិនក្រអូប ព្រមទាំងស្លបៈនិងព្យញ្ជនៈ ដែលជារបស់បរិភោគរួមជាមួយយាគូ និងរបស់ទំពាច្រើនប្រភេទត្រង់លំនៅរបស់ខ្លួន ក្នុងពេលស្រេចភត្តកិច្ចគិតថា អញប្រាថ្នាតំណែងធំក្រៃលែង មិនគួរថ្វាយទានត្រឹមមួយថ្ងៃឡើយ អញប្រាថ្នាតំណែងនោះ គួរថ្វាយទានអស់ ៧ ថ្ងៃជាប់គ្នា ហើយប្រាថ្នាតំណែងនោះ ទើបប្រាថ្នា ។ កុលបុត្តនោះបានថ្វាយមហាទានអស់ ៧ ថ្ងៃ ដោយទំនងនោះឯង ក្នុងពេលស្រេចភត្តកិច្ច ឲ្យមនុស្សបើកឃ្លាំងសំពត់ ហើយដាក់សំពត់សាច់ម៉ដ្ឋដ៏ប្រសើរ ដែលល្មមធ្វើត្រៃចីវរបាន ត្រង់បាទមូលរបស់ព្រះសម្ពុទ្ធ និងបានប្រគេនត្រៃចីវរដល់ភិក្ខុមួយសែនរូប ហើយចូលទៅជិតព្រះតថាគត ក្រាបចុះទៀបបាទមូលរបស់ព្រះសាស្តា ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គភិក្ខុរូបណា ដែលទ្រង់ស្ថាបនាទុក ក្នុងតំណែងឯតទគ្គៈជាងភិក្ខុខាងបដិសម្ភិទា ក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ខ្ញុំព្រះអង្គគប្បីដូចភិក្ខុរូបនោះដែរ គឺសូម

ឲ្យបានបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលទ្រង់កើតឡើងក្នុងអនាគត គប្បីជាកំពូលជាងភិក្ខុដែលបានសម្រេចបដិសម្ភិទាផងចុះ ។ ព្រះសាស្តាទ្រង់ជ្រាបថា សេចក្តីប្រាថ្នានឹងសម្រេច ទើបទ្រង់ព្យាករថា ក្នុងអនាគតកាល គឺក្នុងទីបំផុតនៃមួយសែនកប្ប បន្ទាប់អំពីកប្បនេះ ព្រះពុទ្ធព្រះនាមថាគោតម ទ្រង់កើតឡើងក្នុងលោក សេចក្តីប្រាថ្នានៃកុលបុត្តនេះ នឹងសម្រេចក្នុងសាសនារបស់ព្រះអង្គ ។ កុលបុត្តនោះ ធ្វើបុណ្យក្នុងជាតិនោះ ដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ បានសោយទេវសម្បត្តិ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ។

កុលបុត្តនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយយ៉ាងនោះសន្សំបុណ្យនិងញាណទុកក្នុងភពនោះ ៗ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងក្រុងសាវត្ថី ។ មាតាបិតាបានតាំងឈ្មោះថាកោដ្ឋិកៈ បើមានពាក្យសួរថាហេតុអ្វីទើបដាក់ឈ្មោះបែបនោះ មិនដាក់ឈ្មោះតាមមាតាឬតាមញាតិ មានជីដូនជីតាជាដើម គប្បីជ្រាបថា មាតាបិតា បានដាក់ឈ្មោះកុលបុត្តនោះតាមសេចក្តីសម្គាល់ថា ជាអ្នកខោក ត្បក ចាក់ដោតបុគ្គលដែលឃើញដោយលំពែងគឺមាត់ ព្រោះជាអ្នកឆ្លាតវៃក្នុងវេទង្គសាស្ត្រ តក្កសាស្ត្ររបស់ខ្លួន និងរបស់អ្នកដទៃ ក្នុងនិឃណ្ឌុសាស្ត្រ កេដុភសាស្ត្រ ក្នុងអក្ខរសាស្ត្រច្រើនផ្នែក និងក្នុងការព្យាករគ្រប់ប្រការ ។ កុលបុត្តនោះចម្រើនវ័យហើយ រៀនត្រៃវេទរហូតដល់សេចក្តីសម្រេចក្នុងសិប្បៈរបស់ព្រាហ្មណ៍ ។ ថ្ងៃមួយ ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម៌ហើយ មានសទ្ធាបួស តាំងអំពី

បានឧបសម្បទាហើយ បំពេញវិបស្សនាកម្មដ្ឋាន បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ជាអ្នកជំនាញក្នុងបដិសម្ភិទា មិនកោតញញើតចូលទៅរកមហាថេរៈ សាកសួរបញ្ហាក្ដី ចូលទៅគាល់ព្រះទសពលក្ដី សួរបញ្ហាក្នុងបដិសម្ភិទា ៤ ប៉ុណ្ណោះ ។ ហេតុនោះ ទើបព្រះថេរៈរូបនេះក្លាយជាបុគ្គលប្រសើរជាងពួកភិក្ខុ ដែលសម្រេចបដិសម្ភិទា ព្រោះលោកបានសន្សំបុណ្យទុកក្នុងបដិសម្ភិទានោះ និងព្រោះលោកជំនាញក្នុងបដិសម្ភិទានោះ ។ តមកព្រះសាស្ដាទ្រង់ អាស្រ័យមហាវេទល្លសូត្រឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈជាងពួកភិក្ខុទាំងឡាយ ដែលសម្រេចបដិសម្ភិទាថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកបានបដិសម្ភិទា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងមហាកោដ្ឋិតៈប្រសើរជាងគេ ដូច្នេះ ។

សម័យតមក លោកសោយសុខដែលកើតអំពីវិមុត្តិ កើតនូវសោមនស្សកាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **បទុ-មុត្តរោ ណាម ជិនោ** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចខ្ញុំពោលហើយនោះឯង ។ បទថា **សុទំ** ក្នុងបទថា **ឥត្ថំ សុទមាយស្មា មហាកោដ្ឋិកោ** នេះ ជានិបាត ចុះក្នុងអត្ថប្រាប់ឲ្យដឹង ។ ពាក្យថា **អាយស្មា** ជាពាក្យហៅដោយគោរពយ៉ាងក្រៃលែង ដូចពាក្យថា **អាយស្មា មហាមោគ្គល្លានោ** ដូច្នេះឯង ។

**អដ្ឋកថាមហាកោដ្ឋិកត្ថេរាបទាន ចប់**

# ឧបាលិកស្សបត្ថេរាបទានទី ៨

[ ១២៨ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវលោកទាំងមូល មានបញ្ញាចក្ខុ ទ្រង់ឧប្បត្តិឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទានឱវាទ ញ៉ាំងសត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង ទ្រង់ឈ្លាសក្នុងទេសនា ស្តេចញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ ព្រះអង្គមានសេចក្តីអនុគ្រោះ មានសេចក្តីអាណិតអាសូរ ស្វែងរកនូវប្រយោជន៍ដល់សត្វទាំងពួង បានញ៉ាំងពួកតិរ្ថិយ ទាំងពួងដែលមកប្រជុំគ្នា ឲ្យតាំងនៅស៊ប់ក្នុងសីល ៥ ។ សាសនានេះមិនរឹករវរ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្ត ជាអ្នកស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅឡើយ បានញ៉ាំងពួកជនច្រើនឲ្យឆ្លង ( ចាកលោក ) កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ដែលលោកសន្មតជាជាសប្បុរស នៅក្នុងក្រុងហង្សវតី បានចូលទៅជិតព្រះពុទ្ធជាពន្លឺនៃលោក ហើយស្តាប់ធម្មទេសនា ។ ក្នុងកាលនោះ ខ្ញុំបានឃើញព្រះមានបុណ្យកំពុងតាំងមហាបុរសសាវកក្នុងទីជាឯតទគ្គៈក្នុងកណ្តាលមហាបរិស័ទ ខ្ញុំបានឮហើយក៏ត្រេកអរ ។ ខ្ញុំនិមន្តព្រះមហាជិនស្រី ព្រមទាំងបរិវារជាច្រើន បានថ្វាយទានជាមួយនឹងពួកព្រាហ្មណ៍មួយពាន់នាក់ ។ លុះថ្វាយមហាទានហើយ ក៏ក្រាបថ្វាយបង្គំព្រះនាយក ឋិតនៅក្នុងទីដ៏សមគួរ ត្រេកអរហើយ ក៏ពោលពាក្យនេះថា បពិត្រព្រះអង្គមានព្យាយាម ដោយសេចក្តីជឿចំពោះព្រះអង្គផង ដោយ

គុណដ៏ក្រៃលែងផង បរិស័ទច្រើនសូមសម្រេចដល់ខ្ញុំព្រះអង្គដែលកើតក្នុងទីនោះៗ ។

គ្រានោះ ព្រះសាស្តាមានសូរសេងក្បោះក្បាយ ដូចជាកម្ទរនៃដំរី ពីរោះដូចសត្វករវិក បានត្រាស់ចំពោះបរិស័ទថា អ្នកទាំងឡាយចូរមើលព្រាហ្មណ៍នុ៎ះ មានសម្បុរដូចមាស មានកំភួនដៃធំ មានមុខនិងភ្នែកដូចផ្កាឈូក មានរោមដ៏ខៀវឆ្វេង ជាអ្នកត្រេកអរ មានសេចក្តីជឿក្នុងគុណរបស់តថាគត ។ ព្រាហ្មណ៍នេះប្រាថ្នានូវតំណែងនៃភិក្ខុដែលមានសំឡេងដូចជាសីហៈនោះ នឹងបាននូវតំណែងនុ៎ះដូចបំណងក្នុងកាលជាអនាគត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានព្រះមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តាក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះជាឱរសដែលធម៌និម្មិតជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតមនោះនឹងបានជាសាវ័កនៃព្រះសាស្តាមាននាមថាកស្សបៈ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ នឹងមានព្រះសាស្តាព្រះនាមផុស្សៈ ព្រះអង្គប្រសើររកបុគ្គលប្រៀបផ្ទឹមមិនបាន ឥតមានបុគ្គលស្មើ ជានាយក ជាកំពូលនៃលោក ។ ព្រះអង្គកម្ចាត់បង់នូវងងឹតទាំងពួងទ្រង់ត្រដោះនូវបណ្តាញធំគឺតណ្ហា ស្តេចបង្អុរចុះនូវភ្លៀងគឺអមតៈ ហើយញុំាងមនុស្សលោកព្រមទាំងទេវលោកឲ្យឆ្អែតស្កប់ស្កល់ ( ដោយទឹកអម្រឹតនោះ ) ។ កាលនោះ យើងទាំងអស់គ្នា ៣ នាក់ជាបងប្អូន ជាអាមាត្យរបស់ស្តេចពារាណសី ជាទីទុកព្រះទ័យនៃព្រះរាជា ។ ជាអ្នកមានព្យាយាមអង់អាច មានកម្លាំងឈ្នះក្នុងសង្គ្រាម គ្រានោះ ស្រុកបច្ចន្តគ្រាមកើតបះបោរ ម្ចាស់ផែនដី

ក៏ត្រាស់បង្គាប់យើង ប្រៀនប្រដៅយើងថា អ្នកទាំងឡាយមកអាយ ចូរទៅកាន់បច្ចន្តគ្រាម បង្ក្រាបពលផែនដី ធ្វើដែនរបស់អញឲ្យបានក្សេមក្សាន្ត ហើយត្រឡប់មកវិញចុះ ។ លំដាប់នោះ ពួកយើងក្រាបទូលសូមពរថា បើព្រះអង្គប្រទាននូវព្រះពុទ្ធជានាយកដល់យើង ដើម្បីបានបម្រើ យើងទាំងឡាយនឹងបង្ក្រាបសត្រូវទាំងនោះ ក្នុងបច្ចន្តគ្រាមនោះ ឲ្យខាងតែបាន ។ គ្រានោះពួកយើង បានទទួលហើយ ទើបស្ដេចបញ្ជូនទៅ ដើម្បីរក្សាស្រុក ពួកយើងក៏ធ្វើបច្ចន្តគ្រាម ឲ្យមានគ្រឿងសាស្ត្រាដាក់ចុះ រួចហើយត្រឡប់មកកាន់ក្រុងពារាណសីនោះវិញ ។ បានសូមការបម្រើព្រះសាស្ដា ជាលោកនាយក នឹងព្រះរាជា លុះបានព្រះមុនីដ៏ប្រសើរមកហើយ ទើបនាំគ្នាបូជាព្រះអង្គនោះ ដរាបដល់អស់ជីវិត ។ ពួកយើងជាអ្នកមានសីល មានសេចក្ដីករុណា មានចិត្តប្រកបដោយការនា បានប្រគេននូវសំពត់មានតម្លៃផងនូវភោជនមានរសដ៏ថ្លៃថ្លាផង នូវសេនាសនៈជាទីត្រេកអរផង នូវភេសជ្ជៈជាប្រយោជន៍ផង ដែលកើតឡើងដោយធម៌ ដល់ព្រះមុនីព្រមទាំងព្រះសង្ឃ ហើយបម្រើព្រះនាយកដោយមេត្រីចិត្តសព្វកាល ។ កាលដែលព្រះអង្គជាកំពូលនៃលោក ទ្រង់បរិនិព្វានទៅ ពួកយើងក៏នាំគ្នាធ្វើការបូជា សមគួរតាមកម្លាំងធនធាន ។ ពួកយើងទាំងអស់គ្នា ច្យុតអំពីមនុស្សលោកនោះ បានទៅកើតក្នុងឋានតាវត្តិង្ស សោយមហាសុខក្នុងឋានតាវត្តិង្សនោះ នេះជាផលនៃពុទ្ធបូជា ។ ជាងក្រងផ្កាបាននូវផ្កា រមែងសម្ដែងនូវការធ្វើរំលេចផ្សេងៗច្រើនយ៉ាង យ៉ាងណាមិញចំណែកខាងខ្ញុំ កាលកើតក្នុងភព បានជាធំក្នុងដែនវិទេហៈ ក៏យ៉ាងនោះដែរ ។

ខ្ញុំមានអាសយធម៌ ត្រូវមិច្ឆាទិដ្ឋិកម្ចាត់បង់ ( ព្រោះជឿ ) តាមពាក្យអចេល ឈ្មោះគុណៈ ក៏ឡើងកាន់ផ្លូវនរក មិនបានកាន់យកឱវាទរបស់នាងរុចាជាធីតា នៃខ្ញុំ ។ លុះបាននារទព្រហ្មមកប្រៀនប្រដៅដោយវិធីច្រើនយ៉ាង ក៏បានស្ដាប់ រម្ងាប់ ហើយលះបង់ទិដ្ឋិអាក្រក់ចោលចេញ ។ ខ្ញុំបានបំពេញកម្មបថទាំង ១០ ដោយវិសេស លុះលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុង ឋានសួគ៌ ដូចជានៅក្នុងលំនៅរបស់ខ្លួន ។ លុះដល់បច្ឆិមភព ខ្ញុំជាអ្នកមាន ផៅពង្សដ៏ប្រសើរ គឺកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងពារាណសី ជាក្រុង ធំទូលាយ ។ ខ្ញុំត្រូវមច្ចុ ព្យាធិ និងជរាមកគ្របសង្កត់ហើយ បានចូលទៅក្នុង ព្រៃមហាវ័ន ស្វែងរកផ្លូវព្រះនិព្វាន ហើយក៏ចូលបួសក្នុងពួកជដិល ។ គ្រា នោះ ប្អូនរបស់ខ្ញុំទាំង ២ នាក់ ក៏បួសជាមួយនឹងខ្ញុំដែរ ខ្ញុំបានកសាងអាស្រម នៅក្នុងឧរុវេលប្រទេស ។ ខ្ញុំឈ្មោះកស្សបតាមគោត្ត នៅក្នុងឧរុវេលប្រទេស ព្រោះនៅក្នុងឧរុវេលប្រទេសនោះ បានជានាមបញ្ញត្តិរបស់ខ្ញុំថាឧរុវេលកស្សប ។ ប្អូនរបស់ខ្ញុំម្នាក់នៅក្បែរស្ទឹង មាននាមថានទីកស្សប ( ប្អូនម្នាក់ទៀត ) នៅ ក្នុងប្រទេសគយា ក៏មាននាមប្រាកដថាគយាកស្សប ។ ប្អូនពៅមានសិស្ស ២០០ ប្អូនកណ្ដាលមានសិស្ស ៣០០ ខ្ញុំឯងមានសិស្ស ៥០០ ឥតខ្វះ សិស្ស ទាំងអស់នោះប្រព្រឹត្តតាមខ្ញុំ ។ គ្រានោះ ព្រះពុទ្ធជាកំពូលនៃលោក ជានរ-សារថី ទ្រង់ចូលទៅរកខ្ញុំ បានធ្វើបាដិហារ្យផ្សេងៗទូន្មានខ្ញុំ ។ ខ្ញុំបានបួសជា ឯហិភិក្ខុ ព្រមដោយបរិវារមួយពាន់ ហើយបានសម្រេចអរហត្ត មួយអន្លើ ដោយជនទាំងនោះគ្រប់គ្នា ។ មិនមែនត្រឹមតែពួកជនទាំងនោះទេ មានទាំងពួក

ជនដទៃជាច្រើនចោមរោមខ្ញុំដោយយស ខ្ញុំក៏អាចប្រៀនប្រដៅ ( ជនទាំងនោះ ) បាន លំដាប់ពីនោះមក ព្រះពុទ្ធជាឥសីទី ៧ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈខាងឯមានបរិស័ទច្រើន ។ ឱហ្ន៎ ! ការបូជាដែលខ្ញុំបានធ្វើចំពោះព្រះពុទ្ធ កើតផលដល់ខ្ញុំវិញ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧរុវេលកស្សបត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ឧរុវេលកស្សបត្ថេរាបទាន ។

# អដ្ឋកថា

## ឧរុវេលកស្សបត្ថេរាបទាន

[ ១២៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះថា អបទានរបស់ព្រះឧរុវេលកស្សបត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ បានស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បានឃើញភិក្ខុមួយរូបដែលព្រះសាស្ដា ទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ជាងពួកភិក្ខុអ្នកមានបរិវារច្រើន ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបថ្វាយមហាទាន តាំងសេចក្ដីប្រាថ្នាទុក ។ ព្រះមានព្រះភាគទ្រង់ឃើញថា ការប្រាថ្នារបស់កុលបុត្តនោះមិនមានអន្តរាយ ទើបទ្រង់ព្យាករថា ក្នុងអនាគតកាល ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ កុលបុត្តនេះនឹងបានជាកំពូលជាងពួកភិក្ខុដែលមានបរិវារច្រើន ។

កុលបុត្តនោះ ធ្វើបុណ្យជាច្រើនទុកក្នុងភពនោះដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងទីបំផុត ៩២ កប្ប អំពីកប្បនេះ កើតជាព្រះកនិដ្ឋភាតាមាតាផ្សេងគ្នានៃព្រះមានព្រះភាគព្រះនាមថាផុស្សៈ ។ កុលបុត្តនោះ មានប្អូនប្រុស ២ អង្គ ក្សត្រទាំង ៣ នោះ និមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បូជាដោយគ្រឿងបូជា

ដ៏ប្រសើរ ធ្វើកុសលទុកដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្ស ទាំងឡាយ កើតជាបងប្អូន ៣ នាក់ ក្នុងត្រកូលព្រាហ្មណ៍នានគរពារាណសី មុនព្រះមានព្រះភាគនៃយើងទាំងឡាយកើតឡើង ។ ជនទាំង ៣ មានឈ្មោះ តាមគោត្តថា កស្សបៈ ជនទាំង ៣ ចម្រើនវ័យហើយ ក៏បានរៀនចប់ត្រៃ វេទ ។ បណ្តាជនទាំង ៣ បងប្រុសច្បង មានបរិវារ ៥០០ ប្អូនកណ្តាល មានបរិវារ ៣០០ ប្អូនពៅមានបរិវារ ២០០ ។ ជនទាំង ៣ នោះ ពិចារណា សារៈក្នុងគម្ពីររបស់ខ្លួនហើយ ឃើញថា មានត្រឹមតែប្រយោជន៍ក្នុងបច្ចុប្បន្ន ទើបពេញចិត្តក្នុងការបួស ។ បណ្តាបងប្អូន ៣ នាក់នោះ បងប្រុសច្បង មួយអន្ទើដោយបរិវាររបស់ខ្លួន ទៅកាន់តំបន់ឧរុវេលា បួសជាឥសី ប្រាកដ ឈ្មោះថា ឧរុវេលកស្សបៈ ប្អូនកណ្តាលបួសត្រង់ញោចស្ទឹងគង្គា ប្រាកដ ឈ្មោះថា នទីកស្សបៈ ប្អូនពៅ បួសត្រង់គយាសីសៈ បាកដឈ្មោះថា គយា កស្សបៈ ។

កាលបងប្អូន ៣ នាក់នោះ បួសជាឥសីយ៉ាងនោះ ស្នាក់នៅក្នុងទីដូច ពោលហើយ ឲ្យថ្ងៃជាច្រើនកន្លងទៅ ។ ព្រះពោធិសត្វនៃយើងយាងចេញ មហាភិនេស្រ្កមណ៍ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ទ្រង់ប្រកាសធម្មចក្កឲ្យ ប្រព្រឹត្តទៅដោយលំដាប់ ទ្រង់ឲ្យបញ្ចវគ្គិយតាំងនៅហើយក្នុងអរហត្ត ទ្រង់ ទូន្មានមនុស្ស ៥៥ នាក់ ដែលជាសម្លាញ់នឹងគ្នា មានយសកុលបុត្តជាប្រធាន ទ្រង់បញ្ជូនព្រះអរហន្ត ៦០ អង្គទៅ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅ ដើម្បីប្រយោជន៍ និងសេចក្តីសុខរបស់ជនច្រើន ដូច្នេះ

*ជាដើម ទ្រង់ទូន្មានពួកភទ្ទវគ្គិយភិក្ខុ ៣០ រូប ហើយយាងទៅកាន់លំនៅរបស់ឧរុវេលកស្សបៈ យាងចូលទៅកាន់រោងភ្លើងដើម្បីសូមអាស្រ័យនៅក្នុងទីនោះ ទ្រង់ទូន្មានឧរុវេលកស្សបៈ ព្រមទាំងបរិវារ ដោយបាដិហារ្យ ៣៥០០ មានការទូន្មាននាគដែលនៅក្នុងរោងភ្លើងនោះជាដើម ហើយឲ្យបួស ។ ឯការបួសរបស់ឧរុវេលកស្សបៈនោះ និងការសម្តែងឥទ្ធិប្បាដិហារ្យទាំងអស់ មានលម្អិតក្នុងអដ្ឋកថាអបទានរបស់ព្រះនទីកស្សបៈ ។ ចំណែកបងប្អូនដ៏សេស ២ នាក់ទៀត លុះដឹងថា ឧរុវេលកស្សបៈបួស មួយអន្លើដោយបរិវារ នាំគ្នាមកបួសក្នុងសម្នាក់របស់ព្រះសាស្តា ជនទាំងអស់នោះ ទទ្រង់នូវបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ បានជាឯហិភិក្ខុហើយ ។ ព្រះសាស្តា ទ្រង់នាំសមណៈ ១០០០ អង្គនោះយាងទៅកាន់គយាសីសៈ គង់លើផ្ទាំងថ្ម ទ្រង់ឲ្យសមណៈទាំងអស់នោះតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយទេសនា ។*

*ព្រះឧរុវេលកស្សបៈនោះ លុះបានសម្រេចអរហត្តយ៉ាងនោះហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុនទើបពោលពាក្យថា* **បទុមុត្តរោ ណាម ជិនោ** *ដូច្នេះជាដើម ។ ខ្ញុំនឹងពណ៌នាចំពោះបទដែលលំបាកប៉ុណ្ណោះ ។ បទថា* **សោ ច សព្វំ តមំ ហន្ត្វា** *សេចក្តីថា ព្រះមានព្រះភាគព្រះនាមថា ផុស្សៈអង្គនោះ ទ្រង់កម្ចាត់បានហើយនូវងងឹត គឺកិលេស បានដល់រាគៈ ទោសៈ មោហៈជាដើម ។ បទថា* **វិជដេត្វា មហាជដំ** *សេចក្តីថា ភ្ញារ គឺទម្លាយបំផ្លាញនូវគ្រឿងសាំញាំដ៏ធំ មានពួកនៃកិលេស ១៥០០ មានតណ្ហានិងមានៈជាដើម ។ មានវាចាប្រកបសេចក្តីថា ទ្រង់ធ្វើទេវ*

លោក គឺលោកសន្និវាសទាំងមូល ឲ្យស្ងប់ ឲ្យស្ងប់ដោយជុំវិញ ឲ្យឆ្អែត ញ៉ាំងភ្លៀងដែលជាអមតៈ គឺផ្គរភ្លៀងមហានិព្វាន ឲ្យធ្លាក់ចុះ គឺឲ្យហូរទៅ ។ បទថា **តទា ហិ ពារាណសិយំ** មានអត្ថវិគ្គហៈថា ពាក្យថា **ពារស** ប្រែថា ១២ ដូចក្នុងប្រយោគជាដើមថា **ពារស មនុស្សា** មនុស្ស ១២ នាក់ ។ នគរដែលមាន ១២ រាសី ( ក្រុម ) ឥសីចេញអំពីហិមវន្តប្បទេសក្តី ឥសី គឺព្រះបច្ចេកមុនី មកអំពីភ្នំគន្ធមាទន៍តាមអាកាសក្តី ទៅ ហោះចុះ ស្នាក់ អាស្រ័យក្នុងនគរនោះ ហេតុនោះ ទើបនគរនោះឈ្មោះថា **ពារាណសី** ម្យ៉ាង ទៀត លោកហៅនគរដែលជាទីកន្ទ្វែងរួម ( ចិត្ត ) ដើម្បីប្រកាសធម្មចក្ក របស់ព្រះសម្មាសម្ពុទ្ធច្រើនសែនអង្គ គេហៅថា **ពារាណសី** ដោយផ្លាស់ លិង្គ ។ ក្នុងនគរពាណសីនោះ ។ បទថា **និក្ខិត្តសត្ថំ បច្ចន្តំ** សេចក្តីថា ធ្វើ បច្ចន្តជនបទឲ្យដាក់ចុះនូវសស្ត្រា ឲ្យដាក់នូវអាវុធ ឲ្យអស់ព្យសន៍ ។ បទថា **កត្វា បុនរុបច្ចគំ** សេចក្តីថា ហើយត្រឡប់ចូលមកកាន់នគរនោះទៀត ។ ពាក្យដ៏សេសមានអត្ថដឹងបានងាយហើយ ។

## អដ្ឋកថាឧរុវេលកស្សបត្ថេរាបទាន ចប់

# រាជគ្គោបទានទី ៩

[ ១២៩ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ជាអ្នកប្រាជ្ញ ជ្រាបច្បាស់នូវលោកទាំងពួង ស្តេចកើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងការទេសនា ទ្រង់ប្រទានឱវាទ ញ៉ាំងសត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ ព្រះអង្គមានសេចក្តីអនុគ្រោះ មានសេចក្តីអាណិតអាសូរ ស្វែងរកប្រយោជន៍ដល់សព្វសត្វ ទ្រង់ញ៉ាំងពួកតិរ្ថិយទាំងពួងដែលមកប្រជុំគ្នា ឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាងនេះ សាសនានេះមិនវឹកវរ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្ត ជាបុគ្គលស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះមានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅឡើយ ស្តេចញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ គ្រានោះ ខ្ញុំកើតជាព្រាហ្មណ៍នៅក្រុងហង្សវតី ជាអ្នកដល់ត្រើយនៃមន្ត្រ បានចូលទៅគាល់ព្រះអង្គ ជានរៈដ៏ប្រសើរ ហើយស្តាប់ធម៌ទេសនា ។ ខ្ញុំបានឃើញនូវព្រះនាយកមានព្យាយាមធំ កំពុងតាំងភិក្ខុអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងទីជាឯតទគ្គៈ ក្នុងកណ្តាលបរិស័ទ ។ គ្រានោះ ខ្ញុំធ្វើសក្ការៈចំពោះព្រះលោកនាយក ព្រមទាំង ព្រះភិក្ខុសង្ឃ ហើយក្រាបទៀបព្រះបាទាដោយសិរ្សៈ ប្រាថ្នានូវតំណែងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ ព្រះអង្គមានរស្មីដូចជាមាសធ្លោ ទ្រង់ត្រាស់នឹងខ្ញុំដោយព្រះសូរសៀងគួរត្រេកអរ អាចកម្ចាត់បង់នូវកិលេស ជាមន្ទិលដូច្នេះថា

អ្នកចូរបានសេចក្ដីសុខ មានអាយុវែង សេចក្ដីប្រាថ្នាចូរសម្រេចដល់អ្នក ព្រោះគ្រឿងសក្ការៈអ្នកបានធ្វើដល់តថាគត ព្រមទាំងព្រះសង្ឃ ហៅពេញជាអធិកមហិមា ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូលស្ដេចឱក្កាកៈ នឹងបានជាសាស្ដាព្រះនាមគោតម ត្រាស់ឡើងក្នុងលោក ។ បុរសនេះនឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលនូវមត៌កក្នុងធម៌របស់ព្រះគោតមនោះ ជាសាវករបស់ព្រះសាស្ដា មានឈ្មោះថាកាចៈ ។ ព្រះនាយកនឹងតាំងបុរសនេះ ជាបុគ្គលប្រសើរជាងសាវកអ្នកមានប្រាជ្ញាទាំងឡាយ ។

គ្រានោះ ខ្ញុំឮព្រះពុទ្ធដីកានោះហើយ ក៏ត្រេកអរ មានចិត្តប្រកបដោយមេត្តា មានប្រាជ្ញាខ្ជាប់ខ្ជួន បានបម្រើព្រះជិនស្រីដរាបដល់អស់ជីវិត ។ ដោយអំពើដែលខ្ញុំធ្វើដោយល្អនោះផង ដោយការតម្កល់ទុកនូវសេចក្ដីប្រាថ្នា នោះផង ខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស បានសោយរាជ្យជាស្ដេចទេវតាអស់ ៣០០ ដង ។ បានជាស្ដេចចក្កពត្តិអស់ ៥០០ ដង បានសោយប្រទេសរាជ្យដ៏ទូលាយរាប់ជាតិមិនអស់ ។ ខ្ញុំជាអ្នកបានសេចក្ដីសុខក្នុងទីទាំងពួង ដោយអានិសង្សនៃកម្មនោះ លុះដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ ទ័លក្រ ខ្វះខាត គ្រឿងស្លៀកពាក់ និងគ្រឿងបរិភោគ នៅក្នុងក្រុងគិរិព្វជៈ ជាក្រុងខ្ពង់ខ្ពស់ បានប្រគេនចង្ហាន់មួយវែកដល់ព្រះសារីបុត្ត ជាតាទិបុគ្គល ។ កាលដែលខ្ញុំមានវ័យចាស់ចម្រើនឡើង បានចូលទៅក្នុងអារាម ក្នុងកាលនោះ ឥតមានកិក្ខុណាហ៊ានបំបួសខ្ញុំ ដែលចាស់

គ្រាំគ្រា មានកម្លាំងថមថយទេ ។ ព្រោះហេតុនោះ បានជាខ្ញុំកើតទុក្ខ មានសម្បុរខ្លួនអាប់អន់ មានសេចក្តីសោក កាលនោះព្រះមហាមុនី មានសេចក្តីករុណាធំ លុះឃើញហើយត្រាស់សួរខ្ញុំថា ម្នាលកូន អ្នកត្រូវសេចក្តីសោកគ្របសង្កត់ដូចម្តេច ចូរប្រាប់សេចក្តីឈឺចិត្តរបស់អ្នកមក ។ បពិត្រព្រះអង្គមានព្យាយាម ខ្ញុំព្រះអង្គមិនបានបព្វជាក្នុងសាសនាដែលព្រះអង្គសំដែងដោយល្អទេ ខ្ញុំព្រះអង្គកើតទុក្ខ ព្រោះសេចក្តីស្តាយនោះ បពិត្រព្រះនាយក សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ ។ គ្រានោះ ព្រះមុនីទី ៧ ប្រមូលភិក្ខុទាំងឡាយមកហើយត្រាស់សួរថា ពួកភិក្ខុណានឹកឃើញគុណរបស់ព្រាហ្មណ៍នេះ ពួកភិក្ខុនោះ ចូរពោលមក ។ គ្រានោះ ព្រះសារីបុត្តបានពោលថា ខ្ញុំព្រះករុណានឹកឃើញគុណរបស់ព្រាហ្មណ៍នេះ ដ្បិតព្រាហ្មណ៍នេះ បានប្រើគេឲ្យប្រគេនចង្ហាន់មួយវែក ដល់ខ្ញុំព្រះអង្គ កាលត្រាច់ទៅបិណ្ឌបាត ។ ម្នាលសារីបុត្តប្រពៃហើយៗ អ្នកជាមនុស្សកតញ្ញូនឹងព្រាហ្មណ៍នេះ អ្នកចូរបំបួសព្រាហ្មណ៍ចាស់នេះចុះ ព្រោះព្រាហ្មណ៍នេះ នឹងជាបុគ្គលគួរគេបូជា ។ លំដាប់នោះ ខ្ញុំក៏បានបព្វជា ព្រមទាំងឧបសម្បទា ដោយកម្មវាចា អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ តាំងពីខ្ញុំមានចិត្តរីករាយ ស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនី ដោយគោរព ក្នុងកាលណា ព្រះជិនស្រី ក៏តាំងខ្ញុំថាជាអ្នកប្រសើរខាងប្រាជ្ញា ជាងពួកសាវ័កអ្នកមានប្រាជ្ញា ក្នុងកាលនោះ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវ

ទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះរាជត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ រាជត្ថេរាបទាន ។

# អដ្ឋកថា

# រាជទត្តាបទាន

[ ១២៩ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះថា*

*អបទានរបស់ព្រះរាជទត្តៈ មានពាក្យផ្ដើមថា* **បទុមុត្តរោ ណាម ជិនោ** *ដូច្នេះ ៗ*

*ពាក្យទាំងអស់ វិញ្ញូជនទាំងឡាយ គប្បីកំណត់ដឹងបានដោយងាយ តាមគន្លងនៃព្រះបាលី ដោយពិចារណាតាមសេចក្ដីក្នុងអបទានដទៃ ផ្សេងគ្នាត្រឹមតែបុណ្យប៉ុណ្ណោះ*

***អដ្ឋកថារាជទត្តាបទាន ចប់***

# មោឃរាជត្ថេរាបទានទី ១០

[ ១៣០ ] ព្រះមុនីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ជាប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់កើតឡើង ក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ប្រទានឱវាទញុំាំងសត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង ទ្រង់ញុំាំងពួកជនច្រើនឲ្យឆ្លង ( ចាកលោក ) ទ្រង់មានសេចក្តីអនុគ្រោះ មានករុណា ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុំាំងពួកតិរ្ថិយទាំងពួងដែលមកប្រជុំគ្នា ឲ្យតាំងនៅក្នុងសីល ៥ ។ កាលយ៉ាងនេះ សាសនានេះឯង មិនរឹករវ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្ត ជាអ្នកស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈប្រសើរ ៣២ ប្រការ ។ មានព្រះជន្មាយុមួយសែនឆ្នាំ កាលព្រះអង្គទ្រង់គង់នៅឡើយ ទ្រង់ញុំាំងពួកជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលមួយ នៅក្នុងក្រុងហង្សវតី ជាអ្នកប្រកបការងាររបស់បុគ្គលដទៃ ខ្ញុំឥតមានវត្ថុតិចតួចជាទ្រព្យរបស់ខ្លួនឡើយ ។ កាលខ្ញុំនៅក្នុងបដិក្កមនសាលា ដែលគេធ្វើជាថ្នាក់ ក៏អុជភ្លើងក្នុងបដិក្កមនសាលានោះ ផែនដីដែលក្រាលដោយថ្ម ត្រូវភ្លើងឆេះខ្លោចខ្មៅ ។ កាលនោះ ព្រះលោកនាថកំពុងប្រកាសសច្ចៈ ៤ ក្នុងកណ្តាលបរិស័ទ ទ្រង់សរសើរសាវកដែលទ្រទ្រង់ចីវរសៅហ្មង ខ្ញុំត្រេកអរក្នុងគុណរបស់សាវកនោះ បានប្រតិបត្តិព្រះតថាគត ហើយប្រាថ្នាតំណែងដ៏ខ្ពង់ខ្ពស់ជាកំពូលនៃការទ្រទ្រង់ចីវរសៅហ្មង ។ គ្រានោះ ព្រះបទុមុត្តរៈមានជោគ ស្តេចទ្រង់ត្រាស់នឹងពួកសាវកថា អ្នកទាំង

ឡាយចូរមើលបុរសនុ៎ះ ដែលមានសំពត់កខ្វក់ មានខ្លួនស្គើង ។ មានមុខជ្រះថ្លាដោយបីតិ ទាំងមានទ្រព្យប្រសើរគឺសទ្ធា ជាប់តាមហើយ មានរោមដ៏រៀងឡើង រីករាយឥតកម្រើកដូចជាដុំឈើ ។ បុរសនុ៎ះ ប្រាថ្នានូវតំណែងនៃភិក្ខុអ្នកមានសច្ចៈជារបស់ខ្លួន ទ្រទ្រង់នូវចីវរសៅហ្មងនោះ មានអធ្យាស្រ័យតាំងនៅក្នុងគុណនៃភិក្ខុនោះ ។ លុះខ្ញុំស្តាប់ ព្រះពុទ្ធតម្រាស់នោះហើយ ក៏កើតសេចក្តីរីករាយ ក្រាបទៀបព្រះជិនស្រីដោយសិរ្សៈ ធ្វើនូវអំពើល្អក្នុងសាសនាព្រះជិនស្រី ដរាបដល់អស់ជីវិត ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវសេចក្តីប្រាថ្នានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដោយអំពើដែលខ្ញុំបានដុតថ្នាក់ក្នុងបដិក្កមនសាលា ខ្ញុំត្រូវវេទនាគ្របសង្កត់ឆេះនៅក្នុងនរកអស់មួយពាន់ឆ្នាំគត់ ។ ដោយសំណល់កម្មនោះ ខ្ញុំបានកើតក្នុងត្រកូលមនុស្ស មានលក្ខណៈគេស្គាល់បាន តាមលំដាប់អស់ ៥០០ ជាតិ ពេញប្រៀបដោយភោគយ្ឈ៍គ្រប់ ៥០០ ជាតិ រងសេចក្តីទុក្ខធំដោយផលនៃកម្មនោះ ។ ក្នុងកប្បនេះ ខ្ញុំមានចិត្តជ្រះថ្លាបានញុំាំងព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋៈ មានយស ឲ្យឆ្អែតស្កប់ស្កល់ដោយចង្ហាន់បិណ្ឌបាត ។ ដោយអំពើវិសេសនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះដល់បច្ឆិមភព ខ្ញុំបានកើតក្នុងត្រកូលក្សត្រ អំណើះឥតពីព្រះបិតាទៅ ខ្ញុំក៏បានឆ្អែតស្កប់ស្កល់ដោយរាជសម្បត្តិធំ ។ ខ្ញុំត្រូវភោគយ្ឈ៍គ្របសង្កត់ ឥតបានសុខក្នុងរាត្រីឡើយ សេចក្តីសុខក្នុង រាជសម្បត្តិជារបស់សោះ

សុន្យទេ ព្រោះហេតុណា ព្រោះហេតុនោះ បានជាខ្ញុំមានឈ្មោះថាមោឃរាជ ។ ខ្ញុំឃើញទោសរបស់កាយហើយ ក៏ចូលទៅកាន់ផ្នួស បានចូលទៅធ្វើជាសិស្ស របស់ពាវរីព្រាហ្មណ៍ ដែលជាកំពូលព្រាហ្មណ៍ ។ ខ្ញុំមានបរិវារច្រើន ចូលទៅគាល់ ព្រះពុទ្ធជានាយកនៃនរជន ហើយសួរនូវប្រស្នាដ៏ល្អិតល្អន់ ជាប្រស្នានៃបុគ្គលមានថ្វីមាត់ ជាទីហូរមកនៃវាទៈថា លោកនេះ បរលោក ព្រហ្មលោក ព្រមទាំងទេវលោក ( មានដែរឬទេ ) ខ្ញុំព្រះអង្គមិនដឹងទិដ្ឋិរបស់ព្រះអង្គជាគោតមដ៏មានយសទេ ។ ដែលខ្ញុំព្រះអង្គមកនេះ ដើម្បីសួរប្រស្នាចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ ចុះមច្ចុរាជមើលមិនឃើញនូវបុគ្គលដែលពិចារណាឃើញច្បាស់នូវលោក តើយ៉ាងណា ។ ព្រះពុទ្ធទ្រង់ព្យាបាលរោគគ្រប់មុខ បានត្រាស់ឆ្លើយនឹងខ្ញុំវិញថា ម្នាលមោឃរាជ អ្នកចូរមានស្មារតីសព្វកាល ពិចារណានូវលោកថាសូន្យចុះ បុគ្គលដែលបានដកនូវអត្តានុទិដ្ឋិចេញហើយ រមែងឆ្លងចាកមច្ចុរាជបាន ។ មច្ចុរាជរមែងមិនឃើញនូវបុគ្គលអ្នកពិចារណាឃើញច្បាស់នូវលោកយ៉ាងនេះ ។ គ្រាន់តែចប់គាថា ខ្ញុំវៀរស្រឡះចាកសក់និងពុកមាត់ ស្លៀកសំពត់កាសាវៈ បានក្លាយទៅជាអរហន្តភិក្ខុភ្លាម ។ ខ្ញុំត្រូវរោគបៀតបៀនហើយ មិនហ៊ាននៅក្នុងវិហាររបស់សង្ឃ ត្រូវគេរុកគួនដោយសម្តីថា អ្នកកុំប្រទូស្តវិហារ ។ លំដាប់នោះ ខ្ញុំបាននាំយកសំពត់អំពីគំនរសំរាមខ្លះ ព្រៃស្មសានខ្លះ ប្រកខ្លះមកធ្វើជាសង្ឃាដី ហើយប្រើប្រាស់ តែចីវរសៅហ្មង ។ ព្រះពុទ្ធជាមហាពេទ្យដឹកនាំសត្វ ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំនោះហើយ ក៏តាំងខ្ញុំក្នុងទីជាឯតទគ្គៈជាងពួកភិក្ខុ ទ្រទ្រង់

នូវចីវរសៅហ្មង ។ ខ្ញុំជាបុគ្គលអស់បុណ្យនិងបាប វៀរស្រឡះចាករោគគ្រប់យ៉ាង ឥតមានអាសវៈដូចជាភ្លើងឥតកំញម នឹងបរិនិព្វាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោឃរាជត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ មោឃរាជត្ថេរាបទាន ។

## ឧទ្ទាន

មហាកច្ចាយនត្ថេរាបទាន ១ វក្កលិត្ថេរាបទាន ១ មហាកប្បិនត្ថេរាបទាន ១ ទព្វមល្លបុត្តត្ថេរាបទាន ១ កុមារកស្សបត្ថេរាបទាន ១ ពាហិយត្ថេរាបទាន ១ មហាកោដ្ឋិកត្ថេរាបទាន ១ ឧរុវេលកស្សបត្ថេរាបទាន ១ រាធត្ថេរាបទាន ១ មោឃរាជបណ្ឌិតត្ថេរាបទាន ១ មានគាថា ៣៦២ ដែលព្រះសង្គីតិកាចារ្យ បានប្រមូលទុកហើយ ។

## ចប់ កច្ចាយនវគ្គទី ៥៤ ។

# អដ្ឋកថា

# មោឃរាជត្ថេរាបទាន

[ ១៣០ ] *អបទានរបស់ព្រះមោឃរាជត្ថេរដែលជាអបទានទី ១០ មាន អត្ថដ៏ងាយហើយ ។*

*អដ្ឋកថាមោឃរាជត្ថេរាបទាន ១០ ចប់*

*កច្ចាយនវគ្គទី ៥៤ ចប់*

# ភទ្ទិយវគ្គ ទី ៥៥

## លកុណ្ឌកភទ្ទិយត្ថេរាបទាន ទី ១

[ ១៣១ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងលោកក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្តក្នុងនគរហង្សវតី ជាអ្នកមានទ្រព្យច្រើន បានដើរទៅកាន់ទីសម្រាកស្មង ក៏ចៀងចូលទៅកាន់អារាមរបស់សង្ឃ ។ គ្រានោះ ព្រះអង្គជាប្រទីបនៃលោក ជានាយក កំពុងសម្តែងធម៌ ទ្រង់សរសើរសាវ័កដ៏ប្រសើរ ដែលមានសំឡេងពីរោះជាងពួកសាវ័ក ដែលមានសំឡេងពីរោះទាំងឡាយ ។ ខ្ញុំឮព្រះពុទ្ធដីកានោះហើយ ក៏ត្រេកអរ បានធ្វើគ្រឿងសក្ការៈចំពោះព្រះមហេសី ហើយថ្វាយបង្គំបាទានៃព្រះសាស្តា រួចប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះពុទ្ធជានាយក ទ្រង់ព្យាករក្នុងកណ្តាលជំនុំសង្ឃថា អ្នកនឹងបាននូវតំណែងនុ៎ះដូចចិត្តប៉ុនប៉ងក្នុងកាលអនាគត ។ ក្នុងកប្បទី មួយសែនអំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាសាស្តា ព្រះនាមគោតម ត្រាស់ក្នុងលោក ។ សេដ្ឋីបុត្តនេះ នឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតម ជាសាវ័កនៃព្រះសាស្តា មាននាមថាភទ្ទិយ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។

ព្រះជិនស្រីព្រះនាមផុស្សៈ ជានាយកដែលគេចូលទៅរកបានដោយកម្រ គេគ្របសង្កត់បានដោយក្រ ព្រះអង្គខ្ពង់ខ្ពស់ជាងលោកទាំងពួង ទ្រង់កើតឡើងក្នុងកប្បទី ៩២ អំពីកប្បនេះ ។ ទ្រង់បរិបូណ៌ដោយចរណៈ ជាបុគ្គលប្រសើរ មានព្រះទ័យត្រង់ មានតេជះ ស្វែងរកប្រយោជន៍ដល់សព្វសត្វ ទ្រង់ញុំាងសត្វជាច្រើនឲ្យរួចចាកចំណង ។ ខ្ញុំកើតជាសត្វតាវៅស នៅលើដើមស្វាយក្បែរគន្ធកុដិ ក្នុងឧទ្យានរបស់ព្រះសាស្តានោះ ។ គ្រានោះ ខ្ញុំបានឃើញព្រះជិនស្រីជាទក្ខិណេយ្យបុគ្គលដ៏ខ្ពង់ខ្ពស់ ស្តេចកំពុងទៅបិណ្ឌបាត ហើយញុំាងចិត្តឲ្យជ្រះថ្លា ក៏ស្រែករំពងដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានហើរទៅកាន់ឧទ្យានស្តេច ហើយពាំយកផ្លែស្វាយទុំ មានសម្បុរនៃសម្បកដូចមាសបង្អោនទៅជិតព្រះសម្ពុទ្ធ ។ ព្រះជិនស្រីទ្រង់ប្រកបដោយមហាករុណា ជានាយកទ្រង់ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំហើយ ក៏យកបាត្រអំពីដៃភិក្ខុជាឧបដ្ឋាក ( ហើយបង្អោនបាត្រទៅរកខ្ញុំជាសត្វតាវៅសនោះ ) ។ ខ្ញុំមានចិត្តរីករាយ បានដាក់ផ្លែស្វាយក្នុងបាត្រថ្វាយព្រះមហាមុនី រួចធ្វើអញ្ជលីដោយស្លាបទាំងពីរ ស្រែកដោយសំឡេងដ៏ពីរោះ កាលស្រែកដោយសំឡេងគួរត្រេកអរ គួរស្តាប់ដ៏ទន់ពីរោះ ដើម្បីពុទ្ធបូជា ហើយក៏ហើរទៅកាន់ទ្រនំ ហើយដេកលក់ ។ គ្រានោះ សត្វខ្លែង ជាសត្វចិត្តអាក្រក់ ហើរមកឆាបយកខ្ញុំដែលកំពុងមានចិត្តរីករាយ មានអព្យាស្រ័យស្រឡាញ់ចំពោះព្រះពុទ្ធ ។ ខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានទទួលមហាសុខក្នុងឋានតុសិត ( លុះច្យុតចាកឋានតុសិត ) ក៏បានមកកាន់កំណើតមនុស្ស ព្រោះអានិសង្សនៃកុសលកម្មនោះឯង ។ ក្នុងកប្បនេះ ព្រះ

*ពុទ្ធព្រះនាមកស្សបៈដោយគោត្ត មានផៅពង្សប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ស្តេចកើតឡើង ។ ព្រះអង្គបំភ្លឺសាសនា គ្របសង្កត់តិរ្ថិយអាក្រក់ ទ្រង់ទូន្មានពួកវេនេយ្យសត្វ រួចហើយព្រះអង្គព្រមទាំងពួកសាវក បរិនិព្វានទៅ ។ កាលព្រះអង្គជាបុគ្គលប្រសើរជាងសត្វលោកបរិនិព្វានហើយ ពួកជនច្រើនគ្នាកើតសេចក្តីជ្រះថ្លា នាំគ្នាធ្វើព្រះស្តូបដើម្បីជាពុទ្ធបូជាចំពោះព្រះសាស្តា ។ ពួកជនទាំងនោះប្រឹក្សាគ្នាយ៉ាងនេះថា យើងទាំងឡាយនឹងឲ្យពួកជាងធ្វើព្រះស្តូបកម្ពស់ ៧ យោជន៍ ស្អិតស្អាងដោយកែវ ៧ ប្រការ ថ្វាយព្រះពុទ្ធជាមហេសី ។ កាលនោះ ខ្ញុំជានាយកនៃសេនារបស់ព្រះបាទកិកិនៃដែនកាសី បានបង្គាប់ឲ្យគេធ្វើចេតិយដែលត្រូវមានទំហំធំ ឲ្យមកជាតូចវិញ ។ គ្រានោះ ពួកជនទាំងនោះ ក៏នាំគ្នាធ្វើចេតិយតាមពាក្យខ្ញុំកម្ពស់មួយយោជន៍ សឹងស្អិតស្អាងដោយកែវផ្សេង ៗ ថ្វាយព្រះពុទ្ធជាអ្នកប្រាជ្ញ ប្រសើរជាងជន ។ ដោយអំពើដែលខ្ញុំធ្វើដោយល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្រុងសាវត្ថី ជាក្រុងដ៏ប្រសើរ ស្តុកស្តម្ភ ទូលាយ មានទ្រព្យច្រើន ។ ខ្ញុំឃើញព្រះសុគតកំពុងចូលទៅក្នុងបុរី ក៏មានចិត្តស្ញប់ស្ញែង បានចូលទៅបួសមិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចព្រះអរហត្ត ។ ខ្ញុំបានធ្វើចេតិយឲ្យមានទំហំតូចណា ព្រោះអំពើនោះឯង បានជាខ្ញុំកើតមកមានសរីរៈតឿ គួរដល់ការមើលងាយ ( នៃអ្នកផង ) ។ ខ្ញុំបានដល់នូវភាពជាបុគ្គលប្រសើរ ( ខាង*

មានសំឡេងពីរោះ ) ជាផងពួកកិក្ខុដែលមានសំឡេងពីរោះ ព្រោះបានបូជាព្រះពុទ្ធជាឥសីទី ៧ ដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានសម្រេចនូវសាមញ្ញផលឥតមានអាសវៈ ព្រោះបានថ្វាយផ្លែស្វាយដល់ព្រះពុទ្ធ និងការទឹករឭកគុណនៃព្រះពុទ្ធ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលកុណ្តកភទ្ទិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ លកុណ្តកភទ្ទិយត្ថេរាបទាន ។

# អដ្ឋកថា

# លកុណ្ឌកភទ្ទិយត្ថេរាបទាន

[ ១៣១ ] *គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១ វគ្គទី ៥៥ ដូចតទៅនេះថា*

*អបទានរបស់ព្រះលកុណ្ឋកភទ្ទិយត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរោ ណាម ជិនោ** *ដូច្នេះ ។*

*ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលមានសម្បត្តិច្រើន ក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ខណៈអង្គុយស្ដាប់ធម៌របស់ព្រះសាស្ដា បានឃើញភិក្ខុមួយរូបដែលព្រះសាស្ដាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ជាឯកភិក្ខុអ្នកមានសំឡេងពីរោះ ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ បានថ្វាយមហាទានដែលផ្សំដោយរសផ្អែម ដូចជាសប្បិនិងស្ករក្រាមជាដើម ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយតាំងបណិធានទុកថា បពិត្រព្រះអង្គ ក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីដូចភិក្ខុរូបនេះ គឺគប្បីជាបុគ្គលដ៏ប្រសើរជាឯកភិក្ខុដែលមានសំឡេងពីរោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយផងចុះ ។ ព្រះមានព្រះភាគទ្រង់ឃើញថា សេចក្ដីប្រាថ្នារបស់កុលបុត្តនោះ មិនមានអន្តរាយ ទើបទ្រង់ព្យាករ ហើយយាងចៀសចេញទៅ ។*

*កុលបុត្តនោះ ធ្វើបុណ្យជាច្រើនដរាបដល់អស់អាយុ អន្ទោលទៅក្នុង*

ទេវតា និងមនុស្សទាំងឡាយ បានសោយសម្បត្តិ ក្នុងលោកទាំង ២ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមថាផុស្សៈ កុលបុត្តនេះ កើតជាសត្វតាវៅមានរូបស្អាត ពាំយកផ្លែស្វាយដែលមានរសឆ្ងាញ់ទៅអំពីព្រះរាជឧទ្យាន ខណៈហើរទៅ ឃើញព្រះសាស្តា មានចិត្តជ្រះថ្លា គិតថា អញនឹងថ្វាយដល់ព្រះពុទ្ធ ។ ព្រះសាស្តាទ្រង់ជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់តាវៅនោះ ទើបទ្រង់ទទួលបាត្រ ( អំពីភិក្ខុ ) ហើយប្រថាប់គង់ ។ តាវៅនោះ បានដាក់ផ្លែស្វាយក្នុងបាត្ររបស់ព្រះទសពល ។ ដើម្បីឲ្យតាវៅកើតសោមនស្ស ព្រះសាស្តាបានសោយផ្លែស្វាយទុំនោះ ក្នុងខណៈដែលតាវៅកំពុងមើលនោះឯង ។ លំដាប់នោះ តាវៅនោះមានចិត្តជ្រះថ្លា ញុំាងពេលវេលាឲ្យកន្លងទៅ ដោយសេចក្តីសុខដែលកើតអំពីបីតិនោះឯង អស់ ៧ ថ្ងៃ ដោយបុញ្ញកម្មនោះ គ្រប់ភពដែលកើត ទើបកុលបុត្តនោះ មានសំឡេងពីរោះ ។ ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមថាកស្សបៈ កុលបុត្តនោះ កើតក្នុងត្រកូលជាងឈើ បានជាមេជាងដែលមានកេរ្តិ៍ឈ្មោះ ។ កាលព្រះមានព្រះភាគបរិនិព្វានហើយ កាលមហាជនផ្តើមកសាងព្រះស្តូបប្រមាណ ៧ យោជន៍ ដើម្បីបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះពុទ្ធអង្គនោះ មេជាងនោះប្រាប់ថា យើងសូមឲ្យសាងព្រះស្តូបជារង្វង់មូល ១ យោជន៍ និងកម្ពស់ ១ យោជន៍ ។ មនុស្សទាំងអស់នោះ ធ្វើតាមវាចារបស់មេជាង ។ កុលបុត្តនោះ បានឲ្យសាងចេតិយទាបដល់ព្រះពុទ្ធដែលមានគុណប្រមាណមិនបានដោយប្រការដូច្នេះ ។ ដោយកម្មធ្វើចេតិយឲ្យទាបនោះ គ្រប់ភពដែលកុលបុត្តនោះកើត ក៏មានខ្លួនតឿជាងអ្នក

ដទៃ ។ ក្នុងកាលព្រះមានព្រះភាគនៃយើងទាំងឡាយ កើតក្នុងផ្ទះមានត្រកូល ប្រាកដឈ្មោះថាលកុណ្ឌកភទ្ទិយៈ ព្រោះមានរូបរាងទាប និងព្រោះមានសរីរៈស្អាតដូចគ្នានឹងមាសដូច្នោះ ។ ក្នុងកាលតមក បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មានទូវសទ្ធាបួសហើយ ជាពហុស្សូត ជាធម្មកថិកសម្តែងធម៌ដល់ជនដទៃ ដោយសំឡេងដ៏ពីរោះ ។

តមក ក្នុងថ្ងៃមានមហោស្រពមួយ ស្រីគណិកាម្នាក់ អង្គុយក្នុងរថ ទៅជាមួយព្រាហ្មណ៍ម្នាក់ ឃើញព្រះថេរៈ សើចរហូតមើលឃើញធ្មេញ ព្រះថេរៈកាន់យកឆ្អឹងធ្មេញរបស់ស្រីនោះមកជានិមិត្ត ធ្វើឈានឲ្យកើតឡើងហើយធ្វើនូវឈាននោះឲ្យជាបាទ ចម្រើនវិបស្សនា បានជាព្រះអនាគាមី ។ លោកនៅដោយសតិ ប្រព្រឹត្តទៅក្នុងកាយរឿយ ៗ ។ ថ្ងៃមួយ បានទទួលពាក្យប្រៀនប្រដៅអំពីព្រះធម្មសេនាបតី តាំងនៅក្នុងអរហត្ត ។ ភិក្ខុនិងសាមណេរពួកខ្លះ មិនដឹងថាលោកសម្រេចអរហត្ត ទាញត្រចៀកខ្លះ ចាប់ក្បាលខ្លះ ចាប់ដើមដៃខ្លះ ចាប់ដៃនិងជើងជាដើមខ្លះ លេងលេង ។

លោកបានជាព្រះអរហន្តហើយ កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុនទើបពោលពាក្យថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះជាដើម ។ បទថា **មញ្ជុស្សរាភិនិក្ខជយាំ** សេចក្តីថា ខ្ញុំស្រែកគឺបន្លឺសំឡេងដោយសំឡេងពីរោះគួរស្តាប់ ពាក្យដ៏សេសក្នុងអបទាននេះ ដឹងបានងាយហើយ ។

**អដ្ឋកថាលកុណ្ឌកភទ្ទិយត្ថេរាបទាន ចប់**

# កង្ខារេវតត្ថេរាបទានទី ២

[ ១៣២ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសម្ពុទ្ធទ្រង់មានចង្កាដូចចង្កាសីហៈ មានព្រះសូរសេងដូចសំឡេងព្រហ្ម មានសូរសព្ទដូចហង្សនិងស្គរ មានពុទ្ធដំណើរដូចដំរីដែលគៀវក្លា មានរស្មីដូចព្រះចន្ទនិងព្រះអាទិត្យជាដើម ។ មានប្រាជ្ញាច្រើន មានព្យាយាមធំ មានឈានធំ មានគតិធំ ប្រកបដោយមហាករុណា ជាទីពឹងនៃសត្វលោក ទ្រង់កម្ចាត់បង់នូវងងឹតធំ គឺមោហៈ ព្រះអង្គជាកំពូលនៃត្រៃលោក ទ្រង់ជ្រាបច្បាស់នូវចិត្តសត្វ ជាអ្នកប្រាជ្ញ កាលទូន្មាននូវវេនេយ្យសត្វ ហើយទ្រង់សម្តែងធម៌ច្រើន ។ ព្រះជិនស្រីទ្រង់សរសើរនូវបុគ្គលអ្នកមានឈាន ត្រេកអរក្នុងឈាន មានព្យាយាម មានចិត្តស្ងប់រម្ងាប់ មិនល្អក់ ទ្រង់ញុំាងពួកជនឲ្យត្រេកអរក្នុងកណ្តាលបរិស័ទ ។ កាលនោះ ខ្ញុំជាព្រាហ្មណ៍ដល់នូវត្រើយនៃវេទ នៅក្នុងក្រុងហង្សវតី លុះស្តាប់ធម៌ហើយ មានចិត្តរីករាយ ទើបប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះជិនស្រីជានាយក ទ្រង់ព្យាករក្នុងកណ្តាលនៃជំនុំសង្ឃថា ម្នាលព្រាហ្មណ៍ អ្នកចូរត្រេកអរចុះ អ្នកនឹងបាននូវតំណែងនុ៎ះ ដូចចិត្តប៉ុនប៉ងពុំខាន ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាសាស្តាក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះនឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតមនោះ ជាសាវ័ករបស់ព្រះសាស្តា មានឈ្មោះថា រេវតៈ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកចេតនានោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងត្រកូលក្សត្រ ជាត្រកូលសម្បូរស្តុកស្តម្ភ ទូលាយ មានទ្រព្យច្រើន នៅក្នុងក្រុងកោលិយៈ ។ កាលណា ព្រះពុទ្ធទ្រង់សំម្តែងធម៌ក្នុងក្រុងកបិលវត្ថុ កាលនោះ ខ្ញុំជ្រះថ្លាចំពោះព្រះសុគត ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំមានសេចក្តីសង្ស័យច្រើន ក្នុងវត្ថុគួរនិងមិនគួរនោះៗ ព្រះពុទ្ធទ្រង់សំម្តែងធម៌ដ៏ឧត្តម កម្ចាត់បង់នូវសេចក្តីសង្ស័យ ទាំងអស់នោះបាន ។ ហេតុនោះ ខ្ញុំឈ្មោះថាជាអ្នកមានសង្ស័យច្រើនជាងគេ (?) ... 

សេចក្តីសង្ស័យណាមួយក្នុងលោកនេះ ឬក្នុងលោកខាងមុខ ពួកបុគ្គលមានឈាន មានព្យាយាម ជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ តែងលះបង់នូវសេចក្តីសង្ស័យនោះបានដោយប្រាជ្ញានៃខ្លួន ឬដោយប្រាជ្ញានៃអ្នកដទៃ ។

អំពើដែលខ្ញុំបានធ្វើក្នុងកប្បទីមួយសែន ក៏បង្ហាញផលដល់ខ្ញុំក្នុងជាតិនេះ ខ្ញុំបានដុតបំផ្លាញកិលេសទាំងឡាយហើយ ដូចសន្ទុះសរដែលរបូតផុតចេញ ( ចាកធ្នូ ) ។ ព្រះមុនីទ្រង់ដល់នូវទីបំផុតនៃលោក មានប្រាជ្ញាច្រើន ទ្រង់ឃើញខ្ញុំជាអ្នកត្រេកអរក្នុងឈាន ដូច្នោះ ក៏តាំងខ្ញុំជាអ្នកប្រសើរជាងពួកភិក្ខុអ្នកមានឈាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចដំរីកាត់ផ្តាច់

នូវទុទ្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកង្ខារេវតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ កង្ខារេវតត្ថេរាបទាន ។

## អដ្ឋកថា

## កង្ខារេវតត្ថេរាបទាន

[ ១៣២ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ២ ដូចតទៅនេះថា អបទានរបស់ព្រះកង្ខារេវតត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ។ ពាក្យទាំងអស់ ដឹងបានងាយហើយ តាមគន្លងនៃព្រះបាលីនោះឯង ។

*អដ្ឋកថាកង្ខារេវតត្ថេរាបទាន ចប់*

# សីវលិត្ថេរាបទានទី ៣

[ ១៣៣ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ សីលរបស់ព្រះអង្គរាប់មិនបាន សមាធិឧបមាដូចកែវវជិរ ញាណដ៏ប្រសើរ ក៏រាប់មិនអស់ ទាំងវិមុត្តិក៏រកអ្វីប្រៀបផ្ទឹមគ្មាន ។ ព្រះនាយកទ្រង់សម្តែងធម៌ក្នុងទីប្រជុំដ៏កុះករដោយសមណៈនិងព្រាហ្មណ៍ដល់ពួកមនុស្ស ទេវតា នាគនិងព្រហ្ម ។ ព្រះពុទ្ធទ្រង់កៀវក្លាក្នុងពួកបរិស័ទ ស្តេចតាំងសាវ័ករបស់ព្រះអង្គ ដែលជាអ្នកសម្បូរលាភ មានបុណ្យ ទ្រទ្រង់នូវសេចក្តីរុងរឿងក្នុងទីជាឯតទគ្គៈ ។ កាលនោះ ខ្ញុំកើតជាក្សត្រក្នុងនគរឈ្មោះហំសសៈ បានឮព្រះពុទ្ធដីកានៃព្រះជិនស្រីផង ឮគុណនៃសាវ័កច្រើនផង ។ ខ្ញុំបាននិមន្តព្រះសាស្តា ព្រមទាំងសាវ័កឲ្យឆាន់ចង្ហាន់អស់ ៧ ថ្ងៃ លុះថ្វាយមហាទានរួចហើយ ទើបប្រាថ្នានូវតំណែងនោះ ។ គ្រានោះ ព្រះពុទ្ធជាបុរសប្រសើរ ជាអ្នកប្រាជ្ញ ទ្រង់ឃើញខ្ញុំក្រាបទៀបព្រះបាទា ក៏ទ្រង់ត្រាស់ពាក្យនេះដោយព្រះសូរសៀងដ៏ពីរោះ ។ លំដាប់នោះ ពួកមហាជន ទាំងពួកទេវតា គន្ធព្វ ពួកព្រហ្មមានឫទ្ធិច្រើន និងពួកសមណព្រាហ្មណ៍មានប្រាថ្នាដើម្បីស្តាប់នូវព្រះពុទ្ធដីកានៃព្រះជិនស្រី ហើយក៏នាំគ្នាធ្វើអញ្ជលីនមស្ការថា បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ។ បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គទាំងឡាយ ចង់ស្តាប់អានិសង្សនៃមហាទាន ដែលព្រះមហាក្សត្រ ទ្រង់បានថ្វាយអស់ ៧ ថ្ងៃ សូមព្រះអង្គទ្រង់ព្យាករនូវផលនៃមហាទាននោះ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរចាំស្តាប់ភាសិតតថាគតដូចតទៅនេះចុះ ទក្ខិណាទានដែលព្រះមហាក្សត្រ បានតម្កល់ទុកក្នុងព្រះពុទ្ធ ព្រមទាំងព្រះសង្ឃដែលជាអ្នកមានគុណសម្បត្តិប្រមាណមិនបាន ទក្ខិណាទាននោះ នឹងរកអ្នកណាពោលថា មានអានិសង្សប៉ុណ្ណេះ ឬប៉ុណ្ណោះបានឡើយ ដ្បិតទក្ខិណាទាននោះ មានផលប្រមាណមិនបានទេ មួយទៀត ព្រះមហាក្សត្រដែលមានភោគៈច្រើននេះ ប្រាថ្នានូវតំណែងដ៏ខ្ពង់ខ្ពស់ថា សុទស្សនភិក្ខុជាអ្នកបានលាភដ៏ទូលាយទាំងឡាយយ៉ាងណា អាត្មាអញសូមឲ្យបាននូវលាភយ៉ាងនោះ ព្រះមហាក្សត្រនេះ នឹងបាននូវតំណែងនេះ ក្នុងកាលអនាគតជាប្រាកដ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរសសម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាសាស្តាព្រះនាមគោតម នឹងត្រាស់ឡើងក្នុងលោក ។ ព្រះមហាក្សត្រនេះនឹងបានជាឱរសដែលព្រះធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌នៃព្រះគោតមនោះ ជាសាវ័កនៃព្រះសាស្តាមាននាមថា សីវលិ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះលោកនាយកព្រះនាមវិបស្សី មានព្រះនេត្រដូចមាសឃើញនូវធម៌ទាំងពួង ស្តេចកើតឡើងក្នុងកប្បទី ៩១ អំពីកប្បនេះ ។ កាលនោះ ខ្ញុំជាអ្នកចេះថែរក្សា វាំសរវៃ និងការឈើធ្នាលក្នុងការងាររបស់ត្រកូលមួយ នៅក្នុងនគរពន្ធុមតី ។ គ្រានោះ ពួកជនមួយក្រុមបានឲ្យជាងកសាងបរិវេណ ដែលប្រាកដថាជាបរិវេណធំ ថ្វាយព្រះពុទ្ធ ព្រះនាមវិបស្សី ទ្រង់

ស្វែងរកគុណដ៏ធំ ។ លុះធ្វើបរិវេណរួចស្រេច ពួកជនទាំងនោះ នាំគ្នាថ្វាយ
មហាទានប្រកបដោយបន្ថែម ខ្ញុំពិនិត្យមើល ( ក្នុងមហាទាននោះ ) មិន
ឃើញមានទឹកដោះជូរថ្មីនិងទឹកឃ្មុំសោះ ។ គ្រានោះ ខ្ញុំកំពុងតែកាន់ទឹកដោះ
ជូរថ្មី និងទឹកឃ្មុំដើរទៅផ្ទះនៃម្ចាស់ការងារ ស្រាប់តែពួកអ្នកស្វែងរកវត្ថុនោះ
បានជួបនឹងខ្ញុំ ។ គេបានឲ្យថ្លៃ ២០០ រហូតដល់ ១ ពាន់ ក៏នៅតែមិនបាន
លំដាប់នោះ ខ្ញុំគិតថា វត្ថុនោះមិនមែនជារបស់ថោកទាប ។ ពួកជនទាំងនេះ
គ្រប់គ្នាធ្វើសក្ការៈចំពោះព្រះតថាគតយ៉ាងណា អាត្មាអញនឹងធ្វើសក្ការៈចំពោះ
ព្រះលោកនាយក ព្រមទាំងព្រះសង្ឃយ៉ាងនោះដែរ ។ គ្រានោះ ខ្ញុំបាននាំ
យកទឹកដោះជូរនិងទឹកឃ្មុំ ចាក់លាយគ្នាហើយ ថ្វាយដល់ព្រះលោកនាថព្រម
ទាំងព្រះសង្ឃក្នុងកាលនោះ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការ
តម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បាន
ទៅកើតក្នុងឋានតាវត្តិង្ស ។ តពីនោះមក ខ្ញុំកើតជាស្តេចមានយសធំ ក្នុងក្រុង
ពារាណសី ជាអ្នកប្រទូស្តចំពោះសត្រូវ បានបិទទ្វារនគរ ។ គ្រានោះ ពួក
អ្នកនគរ ដែលត្រូវខ្ញុំបិទទ្វាររក្សាទុកអស់មួយថ្ងៃ កើតសេចក្តីក្តៅក្រហាយ
លំដាប់អំពីនោះមក ខ្ញុំទៅកើតក្នុងនរក ដ៏លាមកខ្លាំងក្លា ព្រោះផលនៃអំពើ
នោះឯង ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងកោលិយបុរី មាតារបស់ខ្ញុំ
ឈ្មោះសុប្បវាសា បិតាខ្ញុំឈ្មោះមហាលិច្ឆវី ។ ខ្ញុំនៅជាទុក្ខក្នុងផ្ទៃមាតាអស់
៧ ឆ្នាំ ខ្ញុំវង្វេងទ្វារយោនីអស់ ៧ ថ្ងៃ ពេញពោរដោយមហាទុក្ខ ព្រោះហេតុ
តែបិទទ្វារនគរ ដោយអានុភាពបុណ្យនៃខ្លួនជាក្សត្រ មាតារបស់ខ្ញុំកើតទុក្ខយ៉ាង

នោះដែរ ព្រោះឲ្យធនូះដល់ខ្ញុំ ។ ក្នុងថ្ងៃដែលប្រសូតចេញមក ខ្ញុំប្រសូតចេញមកដោយសុវត្ថិភាព ត្រូវព្រះពុទ្ធអនុគ្រោះ ក៏បានចូលទៅកាន់ផ្នួស ។ ព្រះសារីបុត្តជាឧបជ្ឈាយ៍របស់ខ្ញុំ ព្រះមោគ្គល្លានមានឫទ្ធិច្រើន មានប្រាជ្ញាច្រើន បានកោរសក់ ហើយប្រៀនប្រដៅខ្ញុំ ។ កាលដែលសក់ដាច់ចុះ ខ្ញុំក៏បានលុះអរហត្ត ពួកទេវតា នាគ និងពួកមនុស្សតែងបង្អោនបច្ច័យទាំងឡាយមកឲ្យខ្ញុំ ។ ខ្ញុំមានចិត្តរីករាយ បានបូជាព្រះពុទ្ធព្រះនាមបទុមុត្តរៈ និងព្រះនាយកព្រះនាមវិបស្សី ដោយបច្ច័យទាំងឡាយដ៏វិសេស ។ ព្រោះហេតុនោះ ទើបខ្ញុំបាននូវលាភដ៏ទូលាយខ្ពង់ខ្ពស់ក្នុងទីសព្វអន្លើ គឺព្រៃ ស្រុក ទីទឹក ទីគោក ដោយផលដ៏វិសេសនៃកម្មទាំងនោះ ។ កាលណាព្រះសម្ពុទ្ធជានាយកព្រះអគ្គជាកំពូលនៃលោក និងដឹកនាំសត្វ ស្តេចទៅជួបនឹងព្រះថេរៈឈ្មោះរេវតៈមួយអន្លើដោយភិក្ខុ ៣ ម៉ឺនរូប ។ កាលនោះ ព្រះពុទ្ធទ្រង់មានយោបល់ធំ មានព្យាយាមធំ ជានាយកនៃលោក ព្រមទាំងព្រះសង្ឃ ត្រូវខ្ញុំបម្រើដោយបច្ច័យទាំងឡាយ ដែលពួកទេវតាបង្អោនចូលមក ដើម្បីប្រយោជន៍ដល់ខ្ញុំ ហើយទ្រង់ជួបនឹងព្រះថេរៈឈ្មោះរេវតៈ លំដាប់នោះ ទ្រង់យាងទៅកាន់វត្តជេតពនវិញ ក៏តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ ព្រះសាស្តាទ្រង់ទំនុកបម្រុងសត្វលោកទាំងពួង ស្តេចសរសើរខ្ញុំក្នុងកណ្តាលពួកបរិស័ទថា ម្នាលភិក្ខុទាំងឡាយ បណ្តាសិស្សទាំងឡាយរបស់តថាគត មានតែភិក្ខុសីវលីមួយទេ ជាអ្នកប្រសើរជាងពួកភិក្ខុអ្នកស្វាក់លាភ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរី

កាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសីវលិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ សីវលិត្ថេរាបទាន ។

# អដ្ឋកថា
# សីវលិត្ថេរាបទាន

[ ១៣៣ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៣ ដូចតទៅនេះថា អបទានរបស់ព្រះសីវលិត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល បានទៅកាន់ព្រះវិហារ ដោយន័យដូចបានពោលហើយខាងដើម ឈរខាងចុងបរិ-ស័ទ ស្តាប់ធម៌ បានឃើញភិក្ខុមួយរូបដែលព្រះសាស្តា ទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈជាងពួកភិក្ខុអ្នកមានលាភ ទើបគិតថា ក្នុងអនាគតកាល អាត្មាអញគួរដូចជាភិក្ខុរូបនេះ ទើបនិមន្តព្រះទសពលថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយតាំងសេចក្តីប្រាថ្នាទុកថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកល្យាណកម្មដែលសន្សំនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នានូវសម្បត្តិដទៃណាឡើយ តែក្នុងអនាគតកាល ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាទីមួយ ខ្ញុំព្រះអង្គគប្បីជាកំពូលជាងពួកភិក្ខុអ្នកមានលាភដូចភិក្ខុដែលទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈនោះចុះ ។

ព្រះសាស្តា ទ្រង់ឃើញថា សេចក្តីប្រាថ្នារបស់កុលបុត្តនោះ មិនមានអន្តរាយ ទើបទ្រង់ព្យាករថា ការប្រាថ្នារបស់អ្នកនឹងសម្រេចក្នុងសម្នាក់របស់ព្រះគោតមសម្ពុទ្ធ ក្នុងអនាគតកាល ហើយយាងចៀសចេញទៅ ។ កុលបុត្ត

នោះ ធ្វើកុសលទុកដរាបដល់អស់ជីវិត សោយសម្បត្តិទាំង ២ ក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាវិបស្សី កុលបុត្តនេះកើតក្នុងស្រុកមួយ ដែលមិនឆ្ងាយអំពីពន្ធុមតីនគរ ។ ក្នុងសម័យនោះ អ្នកពន្ធុមតីនគរ បានយល់ព្រមជាមួយព្រះរាជា ហើយបានថ្វាយទានដល់ព្រះទសពល ។

ថ្ងៃមួយ ជនទាំងអស់បានរួមគ្នាថ្វាយទាន បានពិនិត្យមើលថា អ្វីដែលជាវត្ថុប្រសើរ ក្នុងទានដែលពួកយើងមិនទាន់មាន ក៏ឃើញថា ខ្វះទឹកឃ្មុំ និងទឹកដោះជូរ ។ ទើបជនទាំងនោះគិតថា ពួកយើងនឹងស្វែងរកគ្រប់ទីកន្លែង ទើបចាត់មនុស្សរង់ចាំមើលត្រង់ផ្លូវដែលមកអំពីជនបទ ចូលព្រះនគរ ។ គ្រានោះ កុលបុត្តនោះ កាន់យកឆ្នាំងទឹកដោះជូរមកអំពីផ្ទះរបស់ខ្លួន ដើរទៅកាន់នគរ ដោយគិតថា នឹងទៅរករបស់ឯណានីមួយ គិតថា អញនឹងលុបមុខ លាងដៃនិងជើងឲ្យស្អាតជាមុនសឹមចូលទៅ សម្លឹងរកទីងាយស្រួល ក៏ឃើញសម្បុកឃ្មុំឥតមេ មានទំហំប៉ុនយាមនង្គ័ល គិតថា វត្ថុនេះកើតឡើងហើយដោយបុណ្យរបស់អញ ទើបកាន់ចូលទៅក្នុងព្រះនគរ ។ បុរសដែលអ្នកនគរប្រគល់ឲ្យចាំមើលផ្លូវ ឃើញសម្បុកឃ្មុំ ទើបសួរថា នែសម្លាញ់ ឯងនាំវត្ថុនេះទៅឲ្យអ្នកណា កុលបុត្តនោះឆ្លើយថា ខ្ញុំមិនបាននាំយកទៅឲ្យអ្នកណាទេ ។ មនុស្សទាំងនោះ ក៏ពោលថា បើយ៉ាងនោះ ចូរទទួលយកកហាបណៈនេះ ហើយឲ្យទឹកឃ្មុំនិងទឹកដោះជូរនោះមក ។

កុលបុត្តនោះគិតថា ទឹកឃ្មុំជាដើមនេះ មិនមានតម្លៃច្រើនសម្រាប់អញ

ឡើយ តែបុរសនេះឲ្យតម្លៃច្រើនដោយមិនចាំបាច់កាត់ថ្លៃ អញនឹងសាកល្បង មើល បន្ទាប់អំពីនោះ ទើបកុលបុត្តនោះពោលនឹងបុរសនោះថា ខ្ញុំមិនព្រម ឲ្យដោយតម្លៃត្រឹមមួយកហាបណៈ ។ បុរសអ្នកស្រុកក៏ពោលថា បើយ៉ាងនោះ ចូរអ្នកទទួល ២ កហាបណៈ ហើយឲ្យទឹកឃ្មុំជាដើមមក កុលបុត្តនោះពោល ថា ទោះបី ២ កហាបណៈក៏ខ្ញុំមិនឲ្យ ។ បុរសអ្នកស្រុកបន្ថែមកហាបណៈ ឡើងដោយឧបាយនោះ រហូតដល់ ១០០០ កហាបណៈ ។ កុលបុត្តនោះ គិតថា អញមិនគួរបន្ថែមតម្លៃទៀត អញផ្អាកសិន អញនឹងសួរថា យកទឹក ឃ្មុំជាដើមនេះទៅធ្វើអ្វី ។ លំដាប់នោះ ទើបកុលបុត្តនោះពោលនឹងអ្នកស្រុក នោះថា ទឹកឃ្មុំជាដើមនេះ មិនមានតម្លៃច្រើនទេ តែអ្នកឲ្យតម្លៃច្រើន អ្នកនាំ ទឹកឃ្មុំជាដើមនេះទៅធ្វើអ្វី ។ បុរសអ្នកស្រុកប្រាប់ថា អ្នកដ៏ចម្រើន អ្នកស្រុក ក្នុងនគរនេះប្រណាំងប្រជែងជាមួយព្រះរាជា កំពុងថ្វាយទានដល់ព្រះវិបស្សី សម្មាសម្ពុទ្ធ មិនមានទឹកឃ្មុំនិងទឹកដោះជូរពីរយ៉ាងនេះ ក្នុងទានដ៏ប្រសើរ ទើប ប្រើឲ្យខ្ញុំមករក បើមិនបានរបស់ពីរយ៉ាងនេះ ពួកអ្នកនគរក៏នឹងចាញ់ពិត ព្រោះ ហេតុនោះ ខ្ញុំឲ្យទ្រព្យ ១០០០ កហាបណៈហើយ សូមទទួលទៅ ។ កុល បុត្តនោះពោលថា ទាននេះសមគួរដល់ពួកអ្នកស្រុកប៉ុណ្ណោះឬ ឬថា អ្នកដទៃ ក៏ឲ្យបាន អ្នកស្រុកឆ្លើយថា ការឲ្យមិនបានហាមសម្រាប់បុគ្គលណាឡើយ កុលបុត្តនោះ ពោលថា តើមាននរណាឲ្យទ្រព្យ ១០០០ ក្នុងមួយថ្ងៃក្នុងទាន របស់អ្នកស្រុក អ្នកស្រុកឆ្លើយថា មិនមានទេសម្លាញ់ ។ កុលបុត្តនោះពោល ថា វត្ថុដែល ខ្ញុំឲ្យដល់ពួកអ្នកស្រុកទាំងនោះ អ្នកចូរព្រមទទួលថា មានតម្លៃ

១០០០ ។ បុរសអ្នកស្រុកឆ្លើយថា យល់ព្រម ខ្ញុំព្រមទទួល កុលបុត្តនោះពោលថា បើយ៉ាងនោះ ចូរទៅប្រាប់ឲ្យពួកអ្នកស្រុកដឹងថា បុរសម្នាក់ មិនព្រមឲ្យរបស់ពីរយ៉ាងនេះ ដោយតម្លៃ គេបំណងនឹងរួមជាមួយពួកអ្នក ឲ្យដោយដៃរបស់ខ្លួនឯង ពួកអ្នកចូរអស់កង្វល់ជាមួយរបស់ពីរយ៉ាងនេះ ។ បុរសអ្នកស្រុកពោលថា អ្នកចូរសម្ដែងខ្លួនជាប្រធានក្នុងទាននេះ ហើយត្រឡប់ទៅ ។ ចំណែកកុលបុត្តនោះ បានយកកហាបណៈដែលខ្លួនកាន់យកជាស្បៀងធ្វើដំណើរអំពីផ្ទះ ទៅទិញគ្រឿងទេស ៥ យ៉ាងមកបុក នាំយកទឹកជូរអំពីទឹកដោះជូរ ច្របាច់សម្បុកឃ្មុំដាក់ក្នុងនោះ ផ្សំដោយគ្រឿងទេស ៥ យ៉ាងហើយ ដាក់ក្នុងស្លឹកឈូក កាលត្រៀមវត្ថុនោះស្រេចបាច់ហើយ កាន់យកទៅអង្គុយក្នុងទីមិនឆ្ងាយអំពីព្រះទសពល ។ កាលមហាជននាំសក្ការៈមកកុលបុត្តនោះរង់ចាំមើលវារៈ ដែលដល់លំដាប់ខ្លួន ដឹងថា បានឱកាសហើយក៏ចូលគាល់ព្រះសាស្ដា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នេះជាទុគ្គតសក្ការៈរបស់ខ្ញុំព្រះអង្គ សូមទ្រង់អនុគ្រោះខ្ញុំព្រះអង្គ ទទួលសក្ការៈនេះផងចុះ ។ ព្រះសាស្ដាទ្រង់អនុគ្រោះកុលបុត្តនោះ ទ្រង់ទទួលសក្ការៈនោះដោយបាត្រសិលាដែលទេវមហារាជទាំង ៤ ថ្វាយ ហើយទ្រង់អធិដ្ឋានឲ្យសក្ការៈដែលប្រគេនដល់ភិក្ខុ ៦៨ សែនរូប ក៏មិនអស់ទៅ ។

កុលបុត្តនោះថ្វាយបង្គំព្រះមានព្រះភាគដែលសោយស្រេចហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគហើយ ថ្ងៃនេះ ពួកអ្នកពន្ធមតីនគរនាំសក្ការៈមក

ថ្វាយទ្រង់ ដោយផលនៃការថ្វាយសក្ការៈនេះ ខ្ញុំព្រះអង្គគប្បីជាបុគ្គលប្រសើរដោយលាភ និងប្រសើរដោយយស ក្នុងភពដែលកើតហើយចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលកុលបុត្ត ចូរសម្រេចតាមប្រាថ្នាចុះ ហើយទ្រង់ធ្វើភត្តានុមោទនាដល់កុលបុត្តនោះ និងអ្នកនគរ ហើយក៏យាងចៀសចេញទៅ ។ កុលបុត្តនោះ ធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងសុប្បវាសារាជធីតា ។ ចាប់តាំងពីពេលដែលកុលបុត្តនោះបដិសន្ធិ មនុស្សទាំងឡាយរមែងនាំយកបណ្ណាការ ៥០០ សម្រាប់ មកថ្វាយដល់ព្រះនាងសុប្បវាសាទាំងពេលល្ងាចនិងពេលព្រឹក ។ លំដាប់នោះ ដើម្បីពិសោធបុណ្យរបស់ព្រះរាជឱរសនោះ ព្រះនាងទ្រង់ឈរយកព្រះហស្តខ្ទាងចាប់ល្អីពូជ ។ គ្រាប់ពូជមួយគ្រាប់សម្រេចជាដើមមួយរយ បែកខ្នែងចេញទៅទៀតជាមួយពាន់ដើម អំពីស្រែមួយករីសៈ បានស្រូវប្រមាណ ៥០ រទេះខ្លះ ៦០ រទេះខ្លះ កាលព្រះរាជធីតាយកព្រះហស្តចាប់ទ្វារជង្រុក ស្រូវដែលមនុស្សកើបហើយកើបទៀតក៏ពេញជាថ្មីដោយបុណ្យ ។ កាលមនុស្សឲ្យភត្តអំពីឆ្នាំងដែលមានភត្តពេញដល់បុគ្គលណាមួយ ដោយពោលថា នេះជាបុណ្យរបស់ព្រះរាជធីតា ដរាបណាមិនឈប់ដួស ភត្តក៏មិនអស់ដរាបនោះ ។ ខណៈដែលទារកនៅក្នុងផ្ទៃនោះឯង ពេលវេលាកន្លងទៅហើយ ៧ ឆ្នាំ ។

កាលព្រះគភ៌ចាស់ហើយ ព្រះនាងសោយទុក្ខវេទនាអស់ ៧ ថ្ងៃ ព្រះនាងឲ្យហៅព្រះរាជស្វាមីមកហើយមានព្រះសវនីយ៍ថា មុនពេលស្លាប់ ខ្ញុំសូម

ឲ្យទាន ទាន់មានជីវិតនៅឡើយ ដូច្នេះហើយ បញ្ជូនព្រះរាជស្វាមីទៅកាន់សម្នាក់ព្រះសាស្តាថា បពិត្រព្រះស្វាមី សូមទ្រង់ទៅក្រាបទូលរឿងនេះ ឲ្យព្រះសាស្តាទ្រង់ជ្រាប ហើយសូមនិមន្តព្រះសាស្តាមក ព្រះសាស្តាត្រាស់ព្រះតម្រាស់ណា សូមទ្រង់កំណត់ព្រះតម្រាស់នោះឲ្យល្អ ហើយត្រឡប់មកប្រាប់ដល់ខ្ញុំ ។ ព្រះស្វាមីនោះយាងទៅដល់ហើយ ក្រាបទូលដំណឹងរបស់ព្រះនាងឲ្យព្រះសាស្តាទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងកោលិយធីតាផ្តាំផ្ញើការថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។ ព្រះសាស្តាទ្រង់អាស្រ័យសេចក្តីអនុគ្រោះបានត្រាស់ថា ព្រះនាងសុប្បវាសាកោលិយធីតា ចូរជាអ្នកមានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តដែលមិនមានរោគចុះ ។ ព្រះស្វាមីនោះស្តាប់ព្រះតម្រាស់នោះហើយ ថ្វាយបង្គំព្រះមានព្រះភាគ បែរមុខទៅកាន់ដំណាក់របស់ខ្លួន ។ សត្វដែលកើតក្នុងផ្ទៃ បានប្រសូតចាកផ្ទៃរបស់ព្រះនាងសុប្បវាសា ងាយដូចចាក់ទឹកចេញអំពីធម្មក្រក ដូច្នោះ ស្រេចបាច់មុនព្រះស្វាមីមកដល់ មហាជនដែលមកអង្គុយចោមរោម មានមុខជោកដោយទឹកភ្នែក នាំគ្នាយំ បែរជាសើច ត្រេកអរ ទៅប្រាប់ដំណឹងដែលគួររីករាយដល់ស្វាមីរបស់ព្រះនាង ។ ព្រះស្វាមីនោះទ្រង់ឃើញអាកប្បកិរិយារបស់ជនទាំងនោះហើយ គិតថា ប្រហែលជាព្រះតម្រាស់ ដែលព្រះទសពលត្រាស់ទុកសម្រេចផលទៅហើយ ។ ព្រះស្វាមីនោះ លុះយាងមកដល់ ក៏ប្រាប់ព្រះតម្រាស់របស់ព្រះសាស្តាដល់ព្រះរាជធីតា ។ ព្រះរាជធីតាក៏ត្រាស់ថា ជីវភត្តដែលទ្រង់និមន្តព្រះសាស្តាហើយនោះឯងនឹងជាភត្តមង្គល សូមទ្រង់និមន្តព្រះ

ទសពល ( ដើម្បីសោយ ) អស់ ៧ ថ្ងៃ ព្រះរាជស្វាមីទ្រង់ធ្វើតាមនោះ ។ ជនទាំងឡាយបានញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានជាប់តគ្នាអស់ ៧ ថ្ងៃ ។ ទារកនោះជាអ្នកធ្វើចិត្តរបស់ពួកញាតិដែលកំពុងក្តៅឲ្យរលត់ គឺធ្វើឲ្យក្លាយជាត្រជាក់ ព្រោះហេតុនោះ ទើបពួកញាតិដាក់ឈ្មោះថា សីវលី ។ ទារកនោះ ធ្វើការងារគ្រប់យ៉ាងបានបន្ទាប់អំពីកើតព្រោះនៅក្នុងផ្ទៃដល់ទៅ ៧ ឆ្នាំ ។ ព្រះធម្មសេនាបតីសារីបុត្តត្ថេរ បានធ្វើការសន្ទនាជាមួយកុលបុត្តនោះ ក្នុងថ្ងៃទី ៧ ។ ព្រះសាស្តាក៏បានត្រាស់ព្រះគាថា ( ធម្មបទ ) នេះទុកថា

បុគ្គលណា កន្លងផ្លូវវាងគឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបានជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈានមិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ដូច្នេះ ។

លំដាប់នោះ ព្រះថេរៈបានពោលនឹងទារកនោះយ៉ាងនេះថា អ្នកបានទទួលនូវទុក្ខបែបនេះ ការបួសមិនសមគួរឬ ។ ទារកនោះឆ្លើយថា កាលបានទទួលនូវអនុញ្ញាតក៏នឹងបួស ។ ព្រះនាងសុប្បវាសាឃើញទារកនោះ កំពុងពោលនឹងព្រះថេរៈ ទើបគិតថា កូនរបស់អញកំពុងនិយាយរឿងអ្វីជាមួយព្រះធម្មសេនាបតីហ្ន៎ ទើបចូលទៅរកព្រះថេរៈសួរថា បពិត្រលោកម្ចាស់ កូនប្រុស

របស់ខ្ញុំនិយាយរឿងអ្វីជាមួយលោកម្ចាស់ ។ ព្រះថេរៈពោលថា កុមារនោះនិយាយដល់សេចក្ដីទុក្ខក្នុងការនៅក្នុងផ្ទៃដែលខ្លួនបានទទួល ក៏ពោលថា បើបានទទួលអនុញ្ញាតនឹងបួស ។ ព្រះនាងត្រាស់ថា សាធុ លោកម្ចាស់ សូមលោកម្ចាស់ឲ្យគេបួសចុះ ។ ព្រះថេរៈនាំទៅកាន់វិហារ ហើយឲ្យតចបញ្ចកកម្មដ្ឋាន ហើយក៏ឲ្យបួស ទូន្មានថា សីវលី ខ្ញុំមិនចាំបាច់ឲ្យឱវាទដទៃដល់អ្នក ចូរអ្នកពិចារណាដល់សេចក្ដីទុក្ខដែលអ្នកបានសោយមកហើយអស់ ៧ ឆ្នាំនោះចុះ ។ សីវលីឆ្លើយថា បពិត្រលោកម្ចាស់ ការឲ្យបួសជាភារៈរបស់លោកម្ចាស់ ខ្ញុំនឹងដឹងការៈដែលខ្ញុំធ្វើឯង ។ ព្រះសីវលីនោះ បានតាំងនៅក្នុងសោតាបត្តិផល ក្នុងខណៈកោរសក់ជុកទីមួយនោះឯង បានតាំងនៅក្នុងសកទាគាមិផល ក្នុងខណៈដែលកោរសក់ជុកទី ២ បានតាំងនៅក្នុងអនាគាមិផល ក្នុងខណៈកោរសក់ជុកទី ៣ លុះកោរសក់អស់ ការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល កើតឡើងក្នុងពេលមិនមុនមិនក្រោយ ។ តមក មានពាក្យកើតឡើងក្នុងពួកភិក្ខុថា ឱ ! ព្រះថេរៈ ទោះមានបុណ្យយ៉ាងនេះ ក៏គង់នៅក្នុងផ្ទៃអស់ ៧ ឆ្នាំ ៧ ខែ ហើយវង្វេងទ្វារយោនីអស់ ៧ ថ្ងៃទៀត ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកំពុងអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ មិនមែនធ្វើកម្មទុកក្នុងជាតិនេះ ហើយទ្រង់នាំអតីតនិទានមកត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល មុនពុទ្ធុប្បាទកាលនេះឯង កុល

បុត្តនេះកើតក្នុងរាជត្រកូល នាទនគរពារាណសី លុះព្រះរាជបិតាសោយទិវង្គត ហើយ ក៏បានតាំងនៅក្នុងរាជសម្បត្តិ ជាអ្នកសម្បូរដោយសម្បត្តិ មានកេរ្តិ៍ឈ្មោះ ។ ក្នុងគ្រានោះ ព្រះរាជាក្នុងបច្ចន្តជនបទមួយអង្គ ទ្រង់ព្រះតម្រិះថា អញនឹងដណ្តើមយករាជសម្បត្តិ ទើបយាងមក ឲ្យបោះបន្ទាយព័ទ្ធនគរទុក ។ លំដាប់នោះ ព្រះរាជាមានសមានធន្ទះដូចគ្នានឹងព្រះមាតា បញ្ជាឲ្យបិទទ្វារទាំង ៤ ទិស បោះបន្ទាយការពារអស់ ៧ ថ្ងៃ ។ មនុស្សទាំងឡាយ រកទ្វារចូលនឹងចេញមិនបាន គ្រានោះ ព្រះបច្ចេកពុទ្ធច្រើនអង្គ ក្នុងមិគទាយវិហារ ក៏ប្រកាសឡើង ។ ព្រះរាជាទ្រង់បានជ្រាប ទើបទ្រង់ត្រាស់ឲ្យបើកទ្វារនគរ[១] ។ ស្តេចបច្ចន្តជនបទក៏លើកទ័ពត្រឡប់ទៅវិញ ។ ដោយវិបាកនៃកម្មនោះ កុលបុត្តនោះ បានសោយសេចក្តីទុក្ខក្នុងអបាយ មាននរកជាដើម ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងរាជត្រកូល ក៏គង់សោយទុក្ខបែបនេះរួមជាមួយព្រះមាតា ។ តាំងអំពីពេលដែលលោកបួសហើយ បច្ច័យ ៤ តែងកើតឡើងដល់ភិក្ខុសង្ឃតាមប្រាថ្នា ។ រឿងក្នុងអតីតបានកើតឡើងយ៉ាងនេះ ។

ក្នុងកាលតមក ព្រះសាស្តាបានយាងទៅកាន់នគរសាវត្ថី ។ ព្រះថេរៈបានថ្វាយបង្គំព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងសាកល្បងកម្លាំងបុណ្យរបស់ខ្ញុំព្រះអង្គ សូមទ្រង់ប្រទានភិក្ខុ ៥០០ អង្គ ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលសីវលី ចូរអ្នកនាំទៅចុះ ព្រះសីវលីនោះបាននាំភិក្ខុ ៥០០ អង្គទៅ បែរមុខទៅកាន់ព្រៃហិមពាន្ត មកដល់

---

១-ក្នុងគម្ពីរឧទាន អដ្ឋកថាសុប្បវាសាសូត្រ មានសេចក្តីផ្សេងអំពីនេះបន្តិច ។

ផ្លូវចូលព្រៃជ្រៅ ។ ទេវតាដែលអាស្រ័យត្រង់ដើមជ្រៃដែលឃើញព្រះថេរៈដំបូង បានថ្វាយទានអស់ ៧ ថ្ងៃ ព្រោះហេតុនោះ ទើបមានពាក្យពោលថា

លោកឃើញដើមជ្រៃជាលើកទី ១ ឃើញភ្នំបណ្ឌវៈជាលើកទី ២ ឃើញស្ទឹងអចិរវតីជាលើកទី ៣ ឃើញស្ទឹងវរសាគរជាលើកទី ៤ ឃើញភ្នំហិមពាន្តជាលើកទី ៥ ដល់ស្រះឆទ្ទន្តជាលើកទី ៦ ដល់ភ្នំគន្ធមាទន៍ជាលើកទី ៧ និងជួបព្រះរេវតៈជាលើកទី ៨ ។

ទេវតានិងមនុស្សទាំងឡាយបានថ្វាយទានក្នុងទីគ្រប់កន្លែងអស់ ៧ ថ្ងៃនោះឯង ។ ក្នុង ៧ ថ្ងៃ ថ្ងៃមួយនាគទត្តទេវរាជ ត្រង់ភ្នំគន្ធមាទន៍ បានប្រគេនបិណ្ឌបាត គឺទឹកដោះមួយថ្ងៃ ថ្វាយបិណ្ឌបាត គឺសប្បិមួយថ្ងៃ លំដាប់នោះ ទើបភិក្ខុសង្ឃសួរលោកថា អាវុសោ ទេវរាជអង្គនេះ មិនឃើញមានមេគោទឹកដោះ ដែលរីតយកទឹកដោះមក ទេវរាជអង្គនេះ មិនឃើញមានទឹកដោះជូរ នៃទេវរាជ វត្ថុនេះកើតឡើងដល់អ្នកបានដូចម្តេច ។ ទេវរាជត្រាស់ថា បពិត្រលោកម្ចាស់ ផលនេះជាផលនៃការថ្វាយសលាកភត្តដែលផ្សំអំពីទឹកដោះក្នុងសាសនានៃព្រះកស្សបទសពល ។

ក្នុងកាលតមក ព្រះសាស្តាបានយាងទៅឲ្យព្រះខទិរវនិយរេវតត្ថេរធ្វើការទទួល ។ រឿងកើតឡើងដូចម្តេច គ្រានោះព្រះសារីបុត្តក្រាបទូល ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា រេវតៈប្អូនប្រុសរបស់ខ្ញុំព្រះអង្គបួសហើយ លោកត្រេកអរ ( ក្នុងព្រះសាសនា ) ឬមិនត្រេកអរ ខ្ញុំព្រះអង្គនឹងសួរសុខទុក្ខលោក ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រះរេវតៈផ្តើមធ្វើការ

ចម្រើនវិបស្សនា ទើបទ្រង់ឃាត់អស់វារៈ ២ ដង ក្នុងលើកទី ៣ កាល ព្រះសារីបុត្តសូមទៀត ទ្រង់ជ្រាបថា ព្រះរេវតៈសម្រេចអរហត្តហើយ ទើបត្រាស់ថា ម្នាលសារីបុត្ត តថាគតក៏នឹងទៅ ចូរអ្នកប្រាប់ឲ្យពួកភិក្ខុបានដឹង ។

ព្រះថេរៈប្រាប់ឲ្យភិក្ខុទាំងឡាយមកប្រជុំគ្នា ហើយប្រាប់ឲ្យភិក្ខុទាំងអស់ជ្រាបដោយពាក្យថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានបំណងនឹងយាងទៅកាន់ទីចារិក ពួកលោកមានបំណងនឹងទៅ ក៏ចូរមកចុះ ។ ក្នុងកាលដែលព្រះទសពលយាងទៅកាន់ទីចារិក ភិក្ខុដែលមិនទៅជាមួយ មានចំនួនតិច ចំណែកភិក្ខុដែលចង់ទៅតាម មានចំនួនច្រើន ព្រោះគិតថា ពួកយើងនឹងបានឃើញព្រះសរីរៈដែលមានពណ៌ដូចមាស របស់ព្រះសាស្តា ឬថា ពួកយើងនឹងបានស្តាប់ព្រះធម្មកថាដ៏ពីរោះ ព្រោះហេតុនោះ ព្រះសាស្តាមានមហាភិក្ខុសង្ឃជាបរិវារយាងចេញទៅ ដោយបំណងថា នឹងសួរសុខទុក្ខព្រះរេវតៈ ។

ក្នុងប្រទេសមួយកន្លែង ព្រះអានន្ទត្រេវដល់ផ្លូវបែកជា ២ ហើយ ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គ ត្រង់នេះមានផ្លូវបែកជា ២ ភិក្ខុសង្ឃនឹងទៅផ្លូវណា ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ ផ្លូវណាជាផ្លូវត្រង់ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គ ផ្លូវត្រង់មានចម្ងាយ ៣០ យោជន៍ ជាផ្លូវមិនមានមនុស្ស ចំណែកផ្លូវវាងមានចម្ងាយ ៦០ យោជន៍ ជាផ្លូវងាយស្រួល ផុតភ័យ មានភិក្ខារកបានងាយ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ សីវលីបានមកព្រមជាមួយពួកយើងដែរឬទេ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គ មក ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ សង្ឃចូរទៅតាមផ្លូវត្រង់

នោះឯង តថាគតនឹងល្បងបុណ្យរបស់សីវលី ។ ព្រះសាស្ដាមានភិក្ខុសង្ឃជាបរិវារ យាងទៅតាមផ្លូវ ៣០ យោជន៍ ដើម្បីល្បងបុណ្យរបស់ព្រះសីវលិត្ថេរ ។

តាំងអំពីឈានចុះកាន់ផ្លូវ ពួកទេវតាបាននិម្មិតនគរ ក្នុងទីគ្រប់យោជន៍ ត្រៀមវិហារជាទីសម្រាកសម្រាប់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ពួកទេវបុត្តធ្វើខ្លួនដូចអ្នកចាត់ចែងការដែលព្រះរាជាបញ្ជូនទៅ កាន់យកបបរ និងរបស់ទំពាជាដើម សួរថា លោកម្ចាស់សីវលីនៅឯណា ព្រះថេរៈឲ្យកាន់យកសក្ការៈនិងការរាប់អានហើយ ទៅគាល់ព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់បានសោយរួមជាមួយភិក្ខុសង្ឃ ។ ព្រះសាស្ដាទទួលសក្ការៈដោយទំនងនេះហើយ យាងទៅយ៉ាងច្រើនមួយថ្ងៃ ១ យោជន៍ រហូតចូលផ្លូវកន្តារ ៣០ យោជន៍ ទើបដល់លំនៅរបស់ព្រះខទិរវនិយរេវតត្ថេរ ។ ព្រះថេរៈដឹងថា ព្រះសាស្ដា យាងមក ទើបនិម្មិតវិហារមានចំនួនគ្រប់គ្រាន់ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន និងនិម្មិតព្រះគន្ធកុដិ គឺទីប្រថាប់ពេលយប់ និងទីប្រថាប់ពេលថ្ងៃដល់ព្រះទសពលដោយឫទ្ធិ ត្រង់លំនៅរបស់ខ្លួននោះឯង ហើយចេញទៅធ្វើការទទួលព្រះតថាគត ។ ព្រះសាស្ដាយាងចូលទៅកាន់ព្រះវិហារ តាមផ្លូវដែលប្រដាប់តាក់តែងទុក ។ កាលព្រះតថាគតយាងចូលទៅកាន់ព្រះគន្ធកុដិ ពួកភិក្ខុ ក៏ចូលទៅកាន់សេនាសនៈ ដែលដល់ហើយតាមលំដាប់វស្សា ។ ពួកទេវតាគិតថា កាលនេះមិនជាពេលអាហារ ទើបនាំយកទឹកបាន ៨ យ៉ាងមកប្រគេន ។ ព្រះសាស្ដាទ្រង់សោយទឹកបានរួមជាមួយព្រះភិក្ខុសង្ឃ ។ កាល

ព្រះតថាគតទ្រង់ទទួលសក្ការៈនិងការរាប់អានបែបនេះ ពេលវេលាកន្លងទៅហើយកន្លះខែ ។

លំដាប់នោះ ភិក្ខុដែលមិនពេញចិត្តពួកខ្លះ អង្គុយក្នុងទីមួយ នាំគ្នាលើករឿងឡើងសន្ទនាថា ព្រះទសពលត្រាស់ថា ប្អូនប្រុសនៃអគ្គសាវករបស់តថាគត ដូច្នេះហើយ យាងមកសួរសុខទុក្ខភិក្ខុដែលជាជាងកសាងបែបនេះ វត្តជេតពនមហាវិហារ ឬវេឡុវនវិហារជាដើម នឹងធ្វើអ្វីជាមួយវិហារនេះបាន ភិក្ខុរូបនេះ រវល់តែធ្វើការកសាងបែបនេះ នឹងបំពេញសមណធម៌បានដូចម្តេច ។ គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា កាលតថាគតនៅទីនេះយូរ ទីនេះនឹងក្លាយជាទីប្រឡូកប្រឡល់ ធម្មតាភិក្ខុទាំងឡាយដែលនៅក្នុងព្រៃ ត្រូវការភាពស្ងប់ស្ងាត់ រេវតៈនឹងនៅដោយមិនមានផាសុក ។ បន្ទាប់អំពីនោះ ក៏យាងទៅកាន់ទីសម្រាកពេលថ្ងៃរបស់ព្រះថេរៈ ។ ចំណែកព្រះថេរៈក៏នៅតែម្នាក់ឯង អង្គុយផ្អែកបង្អួចក្តារត្រង់ចុងទីចង្ក្រម លើផ្ទាំងថ្ម សម្លឹងឃើញព្រះសាស្តាយាងមកអំពីចម្ងាយ ទើបដើរទៅទទួល ហើយថ្វាយបង្គំ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរថា រេវតៈ ទីនេះមានម្រឹគកាច អ្នកបានស្តាប់សំឡេងដំរី សំឡេងសេះជាដើម ដែលកាចហើយ តើធ្វើដូចម្តេច ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គបានឮសំឡេងសត្វទាំងនោះហើយ កើតនូវការត្រេកអរថា ជាព្រៃ ។ ក្នុងទីនោះព្រះសាស្តាបានត្រាស់ព្រះពុទ្ធវចនៈឈ្មោះថា អានិសង្សក្នុងការនៅព្រៃ ដល់ព្រះរេវតៈដោយគាថា ៥០០ ស្អែកឡើង យាងទៅបិណ្ឌបាតក្នុងទីមិនឆ្ងាយ ត្រាស់ហៅ

ព្រះរេវតត្ថេរមកហើយ ទ្រង់បានអធិដ្ឋានឲ្យពួកភិក្ខុដែលពោលទោសព្រះថេរៈ ភ្លេចឈើច្រត់ ស្បែកជើង បំពង់ប្រេង និងឆត្រ ។ ពួកភិក្ខុទាំងនោះនាំគ្នាត្រឡប់មកយកបរិក្ខាររបស់ខ្លួន ទោះបីដើរទៅតាមផ្លូវ ដែលមកហើយក្តី ក៏មិនចាំទីនោះបាន ព្រោះកាលទៅគ្រាដំបូង ភិក្ខុទាំងនោះដើរទៅតាមផ្លូវដែលប្រដាប់តាក់តែងហើយ តែថ្ងៃនោះទៅតាមផ្លូវខ្ពស់ទាប អន្ទាយច្របោងវាទៅជារយៈៗ ។ ភិក្ខុទាំងនោះនាំគ្នាដើរជាន់ជន្ទត់ឈើ គុម្ពឈើ និងបន្លា ទៅដល់ទីដែលខ្លួនធ្លាប់នៅ ឃើញឆត្រ ស្បែកជើង ឈើច្រត់ និងបំពង់ប្រេងព្យួរលើដើមគគីរក្នុងទីច្រើនកន្លែង ។ ក្នុងពេលនោះ ភិក្ខុទាំងនោះក៏ដឹងថាភិក្ខុរូបនេះមានឫទ្ធិ ទើបកាន់យកបរិក្ខាររបស់ខ្លួន ហើយនាំគ្នាពោលថា សក្ការៈបែបនេះ ជាសក្ការៈដែលព្រះថេរៈចាត់ចែងដើម្បីព្រះទសពល ហើយធ្វើដំណើរទៅ ។

នាងវិសាខាឧបាសិកា សាកសួរភិក្ខុដែលមកដល់មុន ក្នុងពេលដែលលោកគង់ហើយក្នុងផ្ទះរបស់ខ្លួនថា បពិត្រលោកម្ចាស់ លំនៅរបស់ព្រះរេវតៈគួរពេញចិត្តដែរឬ ពួកភិក្ខុពោលថា ម្នាលឧបាសិកា គួរពេញចិត្ត សេនាសនៈនោះមានចំណែកប្រៀបដោយឧទ្យាននន្ទនវ័ន និងឧទ្យានចិត្តលតាវ័ននោះឯង ។ តមក នាងវិសាខាក៏សួរពួកភិក្ខុដែលមកឯក្រោយនោះថា បពិត្រលោកម្ចាស់ លំនៅរបស់ព្រះរេវតៈ គួរពេញចិត្តដែរឬទេ ភិក្ខុទាំងនោះឆ្លើយថា កុំសួរឡើយឧបាសិកា ទីនោះមិនសមគួរនឹងពោល ជាទីសោះកក្រោះ មានដុំក្រួស ដុំថ្ម ពុំពបស្មើ និងជាព្រៃគគីរទាំងអស់ ភិក្ខុរូបនោះ ( ចេះអត់ធន់ )

នៅក្នុងទីនោះបាន ។

នាងវិសាខាបានស្តាប់ពាក្យរបស់ភិក្ខុដែលមកមុន និងមកក្រោយហើយ គិតថា ពាក្យរបស់ភិក្ខុពួកណាហ្ន៎ ជាពាក្យពិត ក្រោយកត្ត ទើបកាន់យកគ្រឿងក្រអូបនិងកម្រងផ្កា ទៅកាន់ទីបម្រើរបស់ព្រះទសពល ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុពួកខ្លះសរសើរ ពួកខ្លះតិះដៀលលំនៅរបស់ព្រះរេវតត្ថេរ តើរឿងនោះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលវិសាខា លំនៅជាទីត្រេកអរ ឬមិនត្រេកអរចូរស្ទះទុក ចិត្តរបស់ព្រះអរិយៈទាំងឡាយ ត្រេកអរក្នុងទីណា ទីនោះឯងឈ្មោះថា ជាទីគួរពេញចិត្ត ដូច្នេះហើយទើបត្រាស់ព្រះគាថា ( ក្នុងធម្មបទ ) នេះថា

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី
ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ដូច្នេះ ។

ក្នុងកាលតមក ព្រះមានព្រះភាគគង់ក្នុងកណ្តាលពួកព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកមានលាភ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងសីវលី ប្រសើរជាងគេ ។

លំដាប់នោះ ព្រះសីវលិត្ថេរបានសម្រេចអរហត្ត បានទទួលឯតទគ្គៈហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះ

ជាដើម ។ ខ្ញុំនឹងធ្វើការពណ៌នាអត្ថចំពោះបទណា ដែលលំបាកប៉ុណ្ណោះ ។

បទថា **សីលំ តស្ស អសង្ខេយ្យំ** សេចក្តីថា សីលរបស់ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈអង្គនោះ កំណត់រាប់មិនបាន សិក្ខាបទទាំងឡាយដែលត្រាស់ហើយយ៉ាងនេះគឺ

សិក្ខាបទដែលជាសំវរវិន័យ មានចំនួនដូច្នេះគឺ ៩ ពាន់កោដិ និង ៨ ពាន់កោដិ ៥០ សែន និង ៣៦ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសទុកហើយ ក្នុងគម្ពីរវិន័យលោកនិទ្ទេសទុក ក្នុងមាតិកាបេយ្យាល ។

ជាសិក្ខាបទដែលត្រាស់ទុក ជាបញ្ញត្តិសម្រាប់សាវកដែលជាភិក្ខុ ។ អធិប្បាយថា សីលរបស់ព្រះមានព្រះភាគ បុគ្គលណាមួយមិនអាចគណនាបាន គឺបុគ្គលណាមួយ មិនអាចរាប់បាន ។ បទថា **សមាធិវជិរូបមោ** សេចក្តីថា ពេជ្ររមែងកាត់ គឺរមែងធ្វើការកាត់រតនៈ ដូចជាកែវឥន្ទនិល កែវពិទូរ្យ កែវផលិក និងកែវមរកតជាដើម ឲ្យជាចំណិតតូចចំណិតធំបាន យ៉ាងណា សមាធិក្នុងលោកុត្តរមគ្គរបស់ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ ក៏យ៉ាងនោះដូចគ្នា គឺរមែងចាក់ រមែងទម្លាយ រមែងកាត់ បានជាសមុច្ឆេទនូវធម៌ទាំងឡាយដែលជាបដិបក្ខនិងជាសត្រូវ ។

បទថា **អសង្ខេយ្យំ ញាណវរំ** សេចក្តីថា គំនរនៃព្រះញាណ ដូចជាព្រះសយម្ភូញាណ និងព្រះសព្វញ្ញុតញ្ញាណជាដើម របស់ព្រះពុទ្ធអង្គនោះដែលអាចដឹង និងចាក់ធ្លុះអរិយសច្ច ៤ ពោធិបក្ខិយធម៌ ៣៧ សន្ទិតធម៌

និងអសង្ខតធម៌ទាំងឡាយបាន ដែលបុគ្គលណាមួយគណនាមិនបាន គឺប្រាស ចាកការរាប់ ដោយចែកជាអតីត អនាគតនិងបច្ចុប្បន្នជាដើម ។ បទថា **វិមុត្តិ ច អនោបមា** សេចក្តីថា វិមុត្តិ ៤ មានសោតាបត្តិផលជាដើម មិនមាន ឧបមា ប្រាសចាកឧបមា ព្រោះផុតចាកកិលេសទាំងឡាយដែលបុគ្គលណា មួយមិនអាចឧបមាបានថា ដូចគ្នានឹងវត្ថុទាំងនេះ ។ ពាក្យដ៏សេស មានអត្ថ ងាយយល់ហើយ ។

## អដ្ឋកថាសីវលិត្ថេរាបទាន ចប់

# វង្គីសត្ថេរាបទានទី ៤

[ ១៣៤ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ព្រះអង្គមានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងហើយក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ រលកក្នុងសាគរ និងពួកផ្កាយឰដ៏អាកាស យ៉ាងណាមិញ សាសនារបស់ព្រះពុទ្ធអង្គនោះដ៏វិចិត្រហើយដោយពួកព្រះអរហន្ត ក៏យ៉ាងនោះដែរ ។ ព្រះជិនស្រីដ៏ឧត្តមនោះ មានពួកមនុស្សព្រមទាំងទេវតា អសុរ នាគ ចោមរោមក្នុងកណ្តាលប្រជុំជន កុះករដោយសមណៈនិងព្រាហ្មណ៍ ។ ព្រះជិនស្រីនោះ ព្រះអង្គដល់នូវទីបំផុតនៃលោក ក្នុងលោក ទ្រង់ញុំាងឈ្មួក គឺវេនេយ្យសត្វឲ្យពេញចិត្ត ដោយរស្មីទាំងឡាយ ឲ្យត្រាស់ដឹងដោយពាក្យ ( របស់ព្រះអង្គ ) ។ ព្រះអង្គបរិបូណ៌ដោយវេសារជ្ជធម៌ទាំង ៤ ជាបុរសដ៏ឧត្តម មានភ័យនិងសេចក្តីកោតញញើតលះបង់ហើយ ទ្រង់ដល់នូវទីដ៏ក្សេម ជាអ្នកក្លៀវក្លា ។ ព្រះអង្គជាបុគ្គលប្រសើរក្នុងលោក ទ្រង់ប្ដេជ្ញានូវពុទ្ធភូមិ ដែលជាទីដ៏ប្រសើរថ្លៃថ្លាទាំងអស់ ព្រះអង្គគ្មានបុគ្គលណាមួយជាស់តឿនឡើយ ។ កាលព្រះអង្គជាតាទិបុគ្គលបន្លឺនូវសីហនាទ ឥតមានញញើត មិនមានទេវតានិងនរជន ឬព្រហ្មពោលតបតបានឡើយ ។ ព្រះអង្គ កាលសម្តែងធម៌ដ៏ប្រសើរ ញុំាងមនុស្សព្រមទាំងទេវតាឲ្យឆ្លង ( នូវវដ្ដៈទាំង ៣ ) ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ទ្រង់ជាអ្នកក្លៀវក្លាក្នុងបរិស័ទ ។ ព្រះអង្គប្រកាសនូវគុណដ៏ច្រើននៃសាវកមួយរូបដ៏ប្រសើរជាងពួកលោកមានបដិភាណ ដែលគេសន្មតថាជាសប្បុរស ហើយតាំងសាវកនោះក្នុងទីជាឯតទគ្គៈ ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ឈ្មោះវង្គីសៈ នៅក្នុងនគរហង្សវតី ចេះចប់នូវវេទសព្វគ្រប់ គេសន្មត

ជាជាសប្បុរស ជាអ្នកបង្ហូរនូវពាក្យប្រៀនប្រដៅ ។ ខ្ញុំបានចូលទៅជិតព្រះអង្គមានព្យាយាមធំ ហើយស្តាប់ធម៌ទេសនា បាននូវបីតិដ៏ប្រសើរ ក៏ត្រេកអរក្នុងគុណនៃសាវ័ក ។ កាលនោះ ខ្ញុំនិមន្តព្រះសុគត ព្រមទាំងព្រះសង្ឃដែលជាអ្នកញ៉ាំងសត្វលោកឲ្យត្រេកអរ មកឆាន់អស់ ៧ ថ្ងៃ ហើយឲ្យគេបិទបាំងដោយសំពត់ទាំងឡាយ ។ ខ្ញុំបានក្រាបក្បាលទៀបព្រះបាទា ( នៃព្រះអង្គ ) លុះព្រះអង្គបើកឱកាសឲ្យខ្ញុំហើយ ខ្ញុំបានធ្វើនូវអញ្ជលី ឋិតនៅក្នុងទីដ៏សមគួរ មានចិត្តត្រេកអរសរសើរនូវព្រះជិនស្រីដ៏ឧត្តមថា បពិត្រព្រះអង្គ ទ្រង់បង្ហូរនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គជាឥសីទី ៧ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គជាបុគ្គលប្រសើរជាងសត្វលោកទាំងអស់ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវអភ័យ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ។ បពិត្រព្រះអង្គទ្រង់ញាំញីនូវមារ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់បង្ហូរនូវទិដ្ឋិ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ឲ្យនូវសន្តិសុខ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ បពិត្រព្រះ-អង្គ ទ្រង់ធ្វើនូវទីពឹង ខ្ញុំសូមក្រាបថ្វាយបង្គំព្រះអង្គ ។ ព្រះអង្គដ៏ចម្រើនជាទីពឹងនៃសត្វដែលពុំមានទីពឹង ទ្រង់ប្រទាននូវអភ័យដល់សត្វដែលមានភ័យ ទ្រង់ស្និទ្ធស្នាលរបស់សត្វទាំងឡាយដែលមានភូមិដ៏ស្ងប់ ជាទីពឹងរបស់ពួកជនអ្នកស្វែងរកនូវទីពឹង ។ លុះខ្ញុំសរសើរព្រះសម្ពុទ្ធមានគុណធំ ដោយពាក្យទាំងឡាយ មានយ៉ាងនេះជាដើម រួចបានពោលថា ខ្ញុំសូមដល់នូវគតិរបស់ភិក្ខុដែលជាអ្នកក្លៀវក្លាជាងភិក្ខុ អ្នកមានវាទៈក្លៀវក្លា ។

កាលនោះ ព្រះមានព្រះភាគព្រះអង្គមានបដិភាណគ្មានទីបំផុត បានត្រាស់ថា បុគ្គលណាបានញ៉ាំងព្រះពុទ្ធព្រមទាំងសាវ័កឲ្យឆាន់អស់ ៧ ថ្ងៃ ជ្រះថ្លា ( ប្រណម្យ ) ដោយដៃរបស់ខ្លួន សរសើរនូវគុណនៃតថាគត បុគ្គលនុ៎ះប្រាថ្នានូវតំណែងរបស់ភិក្ខុអ្នកក្លៀវក្លាក្នុងវាទៈ ។ បុគ្គលនុ៎ះ នឹងសោយសម្បត្តិទេវតានិងសម្បត្តិមនុស្សដ៏ច្រើន ហើយបាននូវតំណែងជាទីពេញចិត្តនោះ ក្នុងអនាគតកាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរសទ្រង់កើតក្នុងឱក្កាកៈត្រកូល នឹងបានជាព្រះសាស្តា ទ្រង់ព្រះនាមគោតម ត្រាស់ឡើងក្នុងលោក ។ បុរសនោះ ជាទាយាទក្នុងធម៌ទាំងឡាយរបស់ព្រះអង្គ ជាឱរស ជាធម្មនិម្មិត ជាសាវ័កនៃព្រះសាស្តាអង្គនោះ មានឈ្មោះថា វង្គីសៈ ។

កាលនោះ ខ្ញុំឮនូវពាក្យព្យាករណ៍នោះហើយ ក៏ជាបុគ្គលមានចិត្តទន់មានចិត្តមេត្តា បានបម្រើនូវព្រះតថាគតជិនស្រីដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានមកកើតក្នុងត្រកូលបរិព្វាជក មានអាយុ ៧ ឆ្នាំ រាប់អំពីកំណើត ក៏ចេះចប់នូវត្រៃវេទទាំងអស់ ក្លៀវក្លាដោយវាទសាស្ត្រ មានសំឡេងដ៏ពីរោះ មានសម្តីដ៏វិចិត្រ ជាអ្នកញាំញីនូវវាទៈនៃបុគ្គលដទៃ ។ ឯនាមដ៏ប្រសើររបស់ខ្ញុំ ដែលលោកសន្មតហើយថា វង្គីសៈ ព្រោះកើតក្នុងវង្គជនបទ ឬថាវង្គីសៈ ព្រោះជា

ឥស្សរៈក្នុងពាក្យ ។ កាលណាខ្ញុំបានដឹងក្តី ឋិតនៅក្នុងបឋមវ័យ កាលនោះ ខ្ញុំបានជួបនឹងព្រះសារីបុត្តក្នុងក្រុងរាជគ្រឹះ ដែលជាទីរីករាយ ។

## ចប់ ភាណវារៈទី ២៥ ។

ខ្ញុំឃើញព្រះសារីបុត្តនោះ កំពុងត្រាច់ទៅបិណ្ឌបាត មានបាត្រក្នុងដៃ លោកសង្រួមល្អ មានភ្នែកមិនរលើងរលោម និយាយល្មមកំណត់ ក្រឡេកមើលត្រឹមមួយជួរនឹម លុះឃើញលោកហើយ មានសេចក្តីអស្ចារ្យ បានពោលពាក្យគួរសម ជាបទគាថាវិចិត្រ ដូចផ្កាកណិការដែលគេវិចិត្រហើយ ។ លោកក៏ប្រាប់ខ្ញុំនូវព្រះសម្ពុទ្ធ ទ្រង់ជាសាស្តា ជាលោកនាយក កាលនោះលោកជាបណ្ឌិត មានប្រាជ្ញា បានប្រាប់ខ្ញុំតទៅទៀត ។ ខ្ញុំត្រូវលោកជាតាទិបុគ្គល ធ្វើពាក្យប្រកបដោយវិរាគៈដ៏ឧត្តម ដែលគេឃើញបានដោយកម្រ ឲ្យត្រេកអរដោយបដិភាណដ៏វិចិត្រទាំងឡាយ ។ ខ្ញុំក៏ឱនក្បាលទៀបព្រះបាទា ហើយពោលថា សូមលោកម្ចាស់បំបួសខ្ញុំ លំដាប់នោះ ព្រះសារីបុត្តមានប្រាជ្ញាច្រើននោះ នាំខ្ញុំចូលទៅរកព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំឱនក្បាលទៀបព្រះបាទាអង្គុយក្នុងសម្នាក់នៃព្រះសាស្តា ឯព្រះសាស្តាប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់មានព្រះពុទ្ធដីកានឹងខ្ញុំថា ម្នាលវង្គីសៈ សិប្បៈណាមួយរបស់អ្នកមានពិតឬ ។ ក្បាលមនុស្សដែលស្លាប់ហើយ បើអ្នកអាច ( ដឹងក្បាលមនុស្ស ) ដែលស្លាប់ទៅកាន់សុគតិ ឬទុគ្គតិ ដោយវិជ្ជាវិសេសរបស់អ្នក អ្នកចូរប្រាប់

មកចុះ ។ ខ្ញុំបានទទួលពាក្យប្តេជ្ញាថា ព្រះករុណាព្រះអង្គ ព្រះពុទ្ធទ្រង់បង្ហាញនូវក្បាល ៣ ខ្ញុំក៏ក្រាបទូលចំពោះក្បាល ( មនុស្ស ) ដែលទៅកើតក្នុងនរកនិងទេវតា ។

កាលនោះ ព្រះលោកនាយក បង្ហាញនូវក្បាលរបស់ព្រះខីណាស្រព លំដាប់នោះខ្ញុំទាល់គំនិត ក៏សូមបព្វជ្ជា ។ លុះខ្ញុំបព្វជ្ជាហើយ ក៏សរសើរព្រះសុគតតាមតែក្នុងទីណាៗក៏ដោយ លំដាប់នោះ ភិក្ខុទាំងឡាយលើកទោសថាជាអ្នករីករាយក្នុងកាព្យ ។ លំដាប់ព្រះពុទ្ធជានាយក ទ្រង់ត្រាស់ដើម្បីល្បងមើលចំពោះខ្ញុំថា លុះតែបុគ្គលទាំងឡាយជាអ្នកត្រិះរិះ ទើបពោលគាថាទាំងឡាយ តាមដំណើរបានមែនឬ ។ បពិត្រព្រះអង្គមានព្យាយាម ខ្ញុំព្រះអង្គ មិនមែនជាអ្នកយកចិត្តតិចតួចក្នុងកាព្យទេ តែខ្ញុំព្រះអង្គពោលនូវគាថាទាំងឡាយ តាមដំណើរបាន ។ ម្នាលវង្គីសៈ បើដូច្នោះ ឥឡូវនេះ អ្នកចូរសរសើរតថាគតតាមហេតុ ជាគាថាមកមើល ។ កាលនោះ ខ្ញុំសរសើរព្រះអង្គជាអ្នកប្រាជ្ញ ជាឥសីទី ៧ ដោយគាថាទាំងឡាយ ។ ព្រះជិនស្រីអង្គនោះមានព្រះហឫទ័យត្រេកអរមួយរំពេច ក៏តាំងខ្ញុំក្នុងទីឯតទគ្គៈ ។ ខ្ញុំកន្លងបង់នូវបុគ្គលដទៃដោយចិត្តដ៏ឈ្លាសវៃបាន ខ្ញុំជាបុគ្គលមានសីលជាទីស្រឡាញ់ មានសេចក្តីសង្វេគដោយបដិភាណចិត្ត ក៏បានដល់នូវអរហត្ត ។

ភិក្ខុដទៃណាមួយ ជាបុគ្គលប្រសើរជាងភិក្ខុអ្នកមានបដិភាណ ដូចជាវង្គីសភិក្ខុនេះ មិនមានទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចាំទុកយ៉ាងនេះចុះ ។

កម្មដែលខ្ញុំធ្វើហើយក្នុងកប្បទីមួយសែនអំពីកប្បនេះ ក៏ឲ្យផលដល់ខ្ញុំក្នុងលោកនេះ ខ្ញុំដកផុតចាកកិលេសហើយ ដូចជាសត្វទន្សាយរបូតផុតចាកបំពង់ព្រួញ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវង្គីសត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ វង្គីសត្ថេរាបទាន ។

# អដ្ឋកថា

# វង្គីសត្ថេរាបទាន

[ ១៣៤ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៤ ដូចតទៅនេះថា អបទានរបស់ព្រះវង្គីសត្ថេរ មានពាក្យផ្តើមថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កុលបុត្តនេះកើតក្នុងត្រកូលមានភោគៈច្រើន ក្នុងហង្សវតីនគរ ចម្រើនវ័យហើយ បានទៅកាន់ព្រះវិហារមួយអន្លើដោយអ្នកនគរ ដែលកំពុងដើរទៅស្តាប់ធម៌ ខណៈកំពុងស្តាប់ធម៌ បានឃើញភិក្ខុមួយរូបដែលព្រះសាស្តាទ្រង់ស្ថាបនា ទុកក្នុងតំណែងឯតទគ្គៈជាងពួកភិក្ខុដែលមានបដិភាណ ទើបបំពេញកម្មដែលជាអធិការ ដល់ព្រះសាស្តា ហើយតាំងនូវសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល ខ្ញុំព្រះអង្គសូមជាបុគ្គលប្រសើរជាងពួកភិក្ខុអ្នកមានបដិភាណចុះ ដូច្នេះ បានទទួលការព្យាករអំពីព្រះសាស្តា ហើយបំពេញតែកុសលកម្មដរាបដល់អស់ជីវិត សោយសម្បត្តិទាំង ២ ក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ព្រោះមាតាជាបរិព្វាជិកា ក្នុងកាលតមក ទើបបានឈ្មោះថា បរិព្វាជក និងមានឈ្មោះថា វង្គីសៈ ។ កុលបុត្តនោះរៀនត្រៃវេទហើយ បន្ទាប់អំពីនោះ ធ្វើអាចារ្យឲ្យត្រេកអរ សិក្សាមន្តដែលមានឈ្មោះថា ឆវសីស ជាមន្តយកក្រចកគោះលលាដ៍ក្បាលខ្មោច

ហើយ ដឹងថាសត្វនេះកើតក្នុងកំណើតនោះ ។

ពួកព្រាហ្មណ៍គិតថា មន្តនេះជាផ្លូវចិញ្ចឹមជីវិតរបស់ពួកយើង ទើបនាំវង្គីសៈនោះត្រាច់ទៅក្នុងស្រុក និគម និងរាជធានី ។ វង្គីសៈប្រកាសឲ្យបុគ្គលនាំយកសីសៈរបស់ពួកមនុស្សដែលស្លាប់ទៅហើយមិនលើស ៣ ឆ្នាំមក ហើយយកក្រចកគោះ ប្រាប់ថា សត្វនេះកើតក្នុងកំណើតនោះ ដើម្បីកាត់សេចក្តីសង្ស័យរបស់មហាជន ទើបរាយមន្តហៅបុគ្គលដែលស្លាប់ទាំងនោះមកឲ្យប្រាប់គតិរបស់ខ្លួន ដោយហេតុនោះ ទើបមហាជនជ្រះថ្លាយ៉ាងក្រៃលែងក្នុងកុលបុត្តនោះ ។ កុលបុត្តនោះអាស្រ័យមន្តនោះ បានប្រាក់ ១០០ កហាបណៈខ្លះ ១០០០ កហាបណៈខ្លះ អំពីដៃរបស់មហាជន ពួកព្រាហ្មណ៍នាំវង្គីសៈត្រាច់ទៅក្នុងទីសមគួរ ។ វង្គីសៈបានស្តាប់គុណទាំងឡាយរបស់ព្រះសាស្តាហើយ មានបំណងនឹងចូលគាល់ព្រះសាស្តា ។ ពួកព្រាហ្មណ៍នាំគ្នាឃាត់ថា ព្រះសមណគោតមនឹងយកមាយាធ្វើឲ្យចិត្តលោកត្រឡប់ ។

វង្គីសៈមិនជឿពាក្យរបស់ព្រាហ្មណ៍ទាំងនោះ ចូលទៅគាល់ព្រះសាស្តាធ្វើបដិសណ្ឋារៈ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្តាត្រាស់សួរថា ម្នាលវង្គីសៈ អ្នកចេះសិប្បៈអ្វីខ្លះឬ វង្គីសៈក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គចេះមន្តម្យ៉ាងឈ្មោះថា ឆវសីសជាននមន្ត ដោយយកក្រចកគោះលលាដ៍ក្បាលរបស់មនុស្សដែលស្លាប់ទៅខាងក្នុង ៣ ឆ្នាំ ក៏ដឹងទីដែលបុគ្គលនោះទៅកើត ។ លំដាប់នោះ ព្រះសាស្តាត្រាស់ឲ្យនាំយកសីសៈរបស់បុគ្គលដែលកើតក្នុងនរក ១ សីសៈរបស់បុគ្គលដែលកើតក្នុងមនុស្ស

១ សីសៈរបស់បុគ្គលដែលកើតក្នុងពួកទេវតា ១ សីសៈរបស់បុគ្គលដែលបរិនិព្វាន ១ មកឲ្យវង្គីសៈនោះ ។ វង្គីសៈគោះ សីសៈទី ១ ហើយក្រាបទូលថា បពិត្រព្រះគោតម សត្វនេះកើតក្នុងនរក ព្រះសាស្តាត្រាស់ថា សាធុ វង្គីសៈ អ្នកឃើញហើយដោយល្អ ហើយត្រាស់សួរទៀតថា សត្វនេះកើតក្នុងទីណា វង្គីសៈក្រាបទូលថា ក្នុងមនុស្សលោក ព្រះសាស្តាត្រាស់សួរទៀតថា សត្វនេះកើតក្នុងទីណា វង្គីសៈក្រាបទូលថា ក្នុងទេវលោក ។ វង្គីសៈបានក្រាបទូលទីកើតរបស់សត្វទាំង ៣ បានយ៉ាងត្រឹមត្រូវ តែការយកក្រចកគោះសីសៈនៃបុគ្គលដែលបរិនិព្វានហើយ ក៏មិនឃើញខាងដើមនិងខាងចុង ។ លំដាប់នោះ ទើបព្រះសាស្តាត្រាស់សួរថា ម្នាលវង្គីសៈ អ្នកមិនអាចឬ វង្គីសៈក្រាបទូលថា បពិត្រព្រះគោតម សូមទ្រង់បង្អង់សិន ខ្ញុំព្រះអង្គនឹងពិចារណាមើល ដូច្នេះហើយ សូម្បីព្យាយាមរាយមន្តត្រឡប់ទៅត្រឡប់មក ក៏មិនអាចដឹងនូវសីសៈរបស់ព្រះខីណាស្រព ដោយមន្តរបស់បុគ្គលខាងក្រៅ ( សាសនា ) ។ លំដាប់នោះ ញើសបានហូរចេញអំពីសីសៈរបស់វង្គីសៈ ។ វង្គីសៈខ្មាស បាននៅស្ងៀម ។ លំដាប់នោះ ព្រះសាស្តាបានត្រាស់សួរថា ម្នាលវង្គីសៈ អ្នកលំបាកណាស់ឬ វង្គីសៈក្រាបទូលថា បពិត្រព្រះគោតម ពិតហើយ ខ្ញុំព្រះអង្គមិនអាចដឹងទីកើតរបស់សីសៈនេះបាន បើទ្រង់ជ្រាប សូមត្រាស់ប្រាប់ ។ ព្រះសាស្តាត្រាស់ថា ម្នាលវង្គីសៈ តថាគតដឹងរឿងនេះផង ដឹងក្រៃលែងជាងនេះផង ហើយត្រាស់គាថា ២ ( ក្នុងធម្មបទ ) ថា

បុគ្គលណា ដឹងច្បាស់ចុតិនិងបដិសន្ធិរបស់ពួកសត្វ ដោយ

អាការៈទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់
នៅក្នុងកាម អ្នកមានដំណើរល្អដោយសេចក្តីប្រតិបត្តិ អ្នក
ត្រាស់ដឹងនូវសច្ច ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់
បុគ្គលណា តថាគតហៅបុគ្គលដែលជាអ្នកមានអាសវៈអស់
ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍ ដូច្នេះ ។

វង្គីសៈនោះទូលថា បពិត្រព្រះគោតម បើដូច្នោះ សូមទ្រង់ប្រទានវិជ្ជានោះដល់ខ្ញុំចុះ ហើយសម្តែងសេចក្តីគោរព អង្គុយគាល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា តថាគតនឹងឲ្យដល់បុគ្គលដែលមានភេទដូចតថាគត វង្គីសៈគិតថា អាត្មាអញធ្វើអ្វីក៏បាន សូមរៀនមន្តនេះឲ្យបាន ទើបចូលទៅរកពួកព្រាហ្មណ៍ពោលថា កាលខ្ញុំបួស ពួកអ្នកកុំគិតអ្វីឡើយ ខ្ញុំរៀនមន្តហើយ នឹងបានជាធំក្រៃលែងក្នុងជម្ពូទ្វីបទាំងមូល សូម្បីពួកអ្នក ក៏នឹងមានកេរ្តិ៍ឈ្មោះជាមួយខ្ញុំដែរ ។ វង្គីសៈនោះចូលទៅគាល់ព្រះសាស្តា ហើយទូលសូមបួសដើម្បីចង់បានមន្ត ។ ក្នុងកាលនោះ ព្រះនិគ្រោធកប្បត្ថេរ នៅក្នុងសម្នាក់របស់ព្រះមានព្រះភាគ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធកប្បៈ ចូរអ្នកឲ្យវង្គីសៈបួសផងចុះ ដូច្នេះហើយ ទ្រង់ប្រាប់កម្មដ្ឋាន គឺអាការៈ ៣២ និងវិបស្សនាកម្មដ្ឋាន ។ ព្រះវង្គីសៈនោះ កាលកំពុងស្វាធ្យាយកម្មដ្ឋាន គឺអាការៈ ៣២ ក៏ផ្តើមបំពេញវិបស្សនាកម្មដ្ឋាន ។ ពួកព្រាហ្មណ៍ចូលទៅរកវង្គីសៈនោះហើយ សួរថា បពិត្រលោកម្ចាស់វង្គីសៈ លោកម្ចាស់រៀនសិប្បៈក្នុងសម្នាក់របស់

ព្រះសមណគោតមចប់ហើយឬ ។ ព្រះវង្គីសៈឆ្លើយថា អាត្មារៀនចប់ហើយ ពួកព្រាហ្មណ៍ពោលថា បើដូច្នោះ សូមលោកម្ចាស់មក ពួកយើងនឹងទៅប្រយោជន៍អ្វី ដោយការសិក្សាសិប្បៈ ព្រះវង្គីសៈឆ្លើយថា ពួកលោកចូរទៅចុះ អាត្មាមិនមានកិច្ចដែលគប្បីធ្វើរួមជាមួយពួកលោកទេ ។ ពួកព្រាហ្មណ៍ពោលថា ឥឡូវនេះ លោកម្ចាស់ធ្លាក់ក្នុងអំណាចរបស់ព្រះគោតម ព្រះគោ-តមប្រើមាយាបំភាន់ចិត្តលោកម្ចាស់ហើយ ពួកយើងនឹងធ្វើអ្វីក្នុងសម្នាក់របស់លោកម្ចាស់បាន ទើបត្រឡប់ទៅតាមផ្លូវដែលមកនោះឯង ។ ព្រះវង្គីសៈចម្រើនវិបស្សនា ហើយធ្វើឲ្យច្បាស់នូវអរហត្ត ។

ព្រះថេរៈសម្រេចអរហត្តហើយយ៉ាងនេះ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមក ក្នុងកាលមុន ទើបពោលពាក្យថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះជាដើម ។ ខ្ញុំនឹងពណ៌នាចំពោះបទដែលមានអត្ថលំបាកប៉ុណ្ណោះ ។

បទថា **បភាសិ អនុរញ្ជន្តោ** សេចក្ដីថា ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈអង្គនោះ ទ្រង់រុងរឿង ស្អាត ល្អដោយព្រះរស្មី មានពន្លឺដោយឆព្វណ្ណរង្សី មានពណ៌ខៀវ និងពណ៌លឿងជាដើម ។ បទថា **វេនេយ្យ-បទុមានិ សោ** សេចក្ដីថា ព្រះអាទិត្យ គឺព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ ទ្រង់ញ៉ាំងផ្កាឈូក គឺវេនេយ្យជនឲ្យក្រាក់ ឲ្យរីកដោយវិសេសដោយរស្មីនៃព្រះអាទិត្យ ពោលគឺព្រះតម្រាស់របស់ព្រះអង្គ បានដល់ទ្រង់ធ្វើឲ្យរីកដោយការសម្រេចអរហត្តមគ្គ ។ បទថា **វេសារជ្ជេហិ សម្បន្នោ** សេចក្ដីថា សម្បូរ

គឺដល់ព្រម បានដល់ ប្រកបដោយចតុវេសារជ្ជញ្ញាណ សមដូចលោកពោលទុកយ៉ាងនេះថា

ព្រះពុទ្ធទ្រង់ក្លៀវក្លាយ៉ាងល្អ ក្នុងឋានៈ ៤ គឺក្នុងកាលមានអន្តរាយក្នុងធម៌ ជាគ្រឿងនាំចេញចាកវដ្តៈ ក្នុងភាពជាព្រះពុទ្ធ និងក្នុងការធ្វើអាសវៈឲ្យអស់ទៅ ដូច្នេះ ។

បទថា **វាគីសោ វាទិសូទនោ** សេចក្តីថា ជាធំ គឺជាប្រធានរបស់ពួកអ្នកពោល គឺពួកបណ្ឌិត ។ គប្បីជ្រាបថា គួរនឹងពោលថា **វាទីសោ** តែបែរជាពោលយ៉ាងនោះ ព្រោះធ្វើ **ទ** អក្ខរៈឲ្យជា **គ** អក្ខរៈ ។ ឈ្មោះថា **វាទិសូទន** ព្រោះបន្ទរ គឺឲ្យហូរចេញ បានដល់ ធ្វើឲ្យជាក់ច្បាស់នូវវាទៈក្នុងការសួរនិងការឆ្លើយ ។

បទថា **មារមសន** មានវិគ្គហៈថា ឈ្មោះថា **មារមសន** ព្រោះពាល់ត្រូវ ស្ទាបអង្អែល បានដល់ ទម្លាយមារ ៥ មានខន្ធមារជាដើម ។ បទថា **ទិដ្ឋិសូទន** មានវិគ្គហៈថា ឈ្មោះថា **ទិដ្ឋិសូទន** ព្រោះការឃើញ គឺទិដ្ឋិដែលរាប់ថាជាវោហារដែលពិតយ៉ាងក្រៃលែង រមែងហូរចេញ គឺសម្តែងដល់ការហូរចេញ ។ បទថា **វិស្សាមភូមិ សន្តានំ** បានដល់ ភូមិជាទីសម្រាកដែលជាទីស្នាក់នៅ បានដល់ ជាទីចូលទៅស្ងប់នៃសត្វដែលជាអ្នកត្រូវបន្តគឺជាអ្នកលំបាកក្នុងសង្សារសាគរទាំងមូល ដោយការសម្រេចមគ្គ មានសោតាបត្តិមគ្គជាដើម ។ បទថា **តតោហំ វិហាតារម្ភោ** សេចក្តីថា ព្រោះបានឃើញព្រះសរីរៈរបស់ព្រះបច្ចេកពុទ្ធអង្គនោះ ទើបខ្ញុំកម្ចាត់ភាពរឹងរូស ធ្វើការ

ប្រណាំងវាសនាឲ្យវិនាសទៅ កម្ចាត់មានះ មិនស្រវឹង ហើយទើបអង្វរសូម
បួសដោយល្អ ។ ពាក្យដ៏សេសមានអត្ថដឹងបានងាយហើយ ។

## អដ្ឋកថាវគ្គីសត្តេក្ខាបទាន ចប់

# ឆត្តករត្ថេរាបទានទី ៤

[ ១៣៥ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះអង្គជាបុរសអាជានេយ្យ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់ស្តេចទៅក្នុងមនុស្សលោក និងទេវលោក ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីសេចក្តីចម្រើនដល់សព្វសត្វទាំងឡាយ ។ ព្រះជិនស្រី ព្រះអង្គដល់នូវយសដ៏ប្រសើរ មានសិរី ពេញប្រៀបដោយកិត្តិគុណ ដែលសត្វលោកទាំងពួងបូជាហើយ ល្បីខ្ចរខ្ចាយសព្វទិស ។ ព្រះជិនស្រីនោះ មានវិចិកិច្ឆាឆ្លងផុតហើយ មានសេចក្តីសង្ស័យកន្លងហើយ មានសេចក្តីត្រិះរិះក្នុងព្រះចិន្តាពេញបរិបូណ៌ ទ្រង់ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះអង្គជានរៈដ៏ឧត្តម ទ្រង់ញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ទ្រង់ប្រាប់នូវពាក្យដែលគេមិនទាន់និយាយ ទ្រង់បង្កើតនូវធម្មជាតដែលមិនទាន់កើត ។ ព្រះអង្គជាអ្នកស្គាល់នូវផ្លូវ ជ្រាបច្បាស់នូវផ្លូវ ជាអ្នកប្រាប់នូវផ្លូវ ជាអ្នកអង់អាចជាងនរៈ ជាសាស្តាចារ្យដ៏ឈ្លាសវៃក្នុងផ្លូវ ជានរៈដ៏ឧត្តមជាងសារថីទាំងឡាយ ។ ក្នុងកាលនោះ ព្រះលោកនាយកទ្រង់ប្រកបដោយមហាករុណា ទ្រង់សម្តែងនូវធម៌ ហើយស្រង់ពួកសត្វដែលមុជចុះក្នុងភក់ គឺមោហៈ ។ ព្រះមហាមុនីទ្រង់សរសើរសាវកដែលកិក្ខុសង្ឃស្មនូតថា ជាច្បងក្នុងការទូន្មានពួកកិក្ខុនី បានតែងតាំងក្នុងឋានៈជាឯតទគ្គៈ ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយ និមន្តព្រះតថាគតព្រមទាំងព្រះសង្ឃឲ្យឆាន់ ហើយប្រាថ្នានូវតំណែងដ៏ឧត្តមនោះ ។

ក្នុងកាលនោះ ព្រះមហាឥសីជាទីពឹង ទ្រង់មានព្រះទ័យរីករាយ បាន ត្រាស់នឹងខ្ញុំថា អ្នកចូរបានសេចក្ដីសុខ មានអាយុវែង អ្នកនឹងបាននូវតំណែង ជាទីពេញចិត្តនុ៎ះ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្ដាទ្រង់ព្រះនាម គោតម ទ្រង់សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ បុរសនេះ នឹងបានជាទាយាទក្នុងធម៌របស់ព្រះសាស្ដា ជាឱរសដែលធម៌និម្មិត ឈ្មោះ នន្ទកៈ ជាសាវករបស់ព្រះសាស្ដានោះ ។ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អ នោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់ មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកក្នុង បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ជាបុរីប្រសើរស្តុកស្តម្ភ ទូលាយ មានទ្រព្យច្រើន ។ ខ្ញុំបានឃើញព្រះសុគតទៀបមាត់ទ្វារនៃបុរី ក៏ មានចិត្តរន្ធត់ កាលព្រះសុគតទទួលវត្តជេតពន ខ្ញុំចូលទៅកាន់ផ្នួស ។ លំដាប់ នោះ ខ្ញុំត្រូវព្រះសម្ពុទ្ធទ្រង់ឃើញសច្ច ប្រៀនប្រដៅហើយ មានសង្សារធ្វេង ហើយ ក៏បានដល់អរហត្តដោយកាលមិនយូរប៉ុន្មាន ។ ខ្ញុំបានធ្វើនូវធម្មកថា និងបរិបុច្ឆាចំពោះនាងភិក្ខុនីទាំងឡាយ ភិក្ខុនីទាំងអស់នោះ ចំនួន ៥០០ រូប ឥតខ្វះ ដែលខ្ញុំទូន្មានហើយ ក៏បានទៅជាភិក្ខុនីមិនមានអាសវៈ ។ កាលនោះ ព្រះមានព្រះភាគមានព្រះទ័យត្រេកអរ ទ្រង់ធ្វើប្រយោជន៍ដ៏ធំ ទ្រង់តាំងខ្ញុំក្នុង តំណែងដ៏ប្រសើរ ជាងពួកសាវកអ្នកទូន្មានពួកភិក្ខុនី ។ កុសលកម្មដែលខ្ញុំ ធ្វើហើយ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ក៏ឲ្យផលដល់ខ្ញុំ ក្នុងលោកនេះ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ដូចល្បឿននៃព្រួញ ដែលរបូតផុត

*ទៅ ។ កិលេសទាំងឡាយខ្ញុំដុតកម្ទេចហើយ ភពទាំងអស់ខ្ញុំដកចោលចេញហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះនន្ទកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

***ចប់ នន្ទកត្ថេរាបទាន ។***

# អដ្ឋកថា

## ឆន្នកត្ថេរាបទាន

[ ១៣៥ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៥ ដូចតទៅនេះថា អបទានរបស់ព្រះនន្ទកត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះ ។

លំនាំដើមមានពាក្យថា ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុក ហើយក្នុងព្រះពុទ្ធអង្គមុនៗ ជាដើម មានអត្ថដឹងបានងាយហើយ តាមគន្លង នៃព្រះបាលីនោះឯង ។

*អដ្ឋកថានន្ទកត្ថេរាបទាន ចប់*

# កាឡុទាយិត្ថេរាបទានទី ៦

[ ១៣៦ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ ក្នុងធម៌ទាំងពួង ព្រះអង្គជានាយកកើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះសាស្ដាទ្រង់ប្រសើរជាងពួកអ្នកទូន្មាន ទ្រង់ជ្រាបនូវគុណនិងទោស ព្រះអង្គឈ្នះមារ ជាកតញ្ញូកតវេទីបុគ្គល ទ្រង់ញុំាងពួកសត្វ ឲ្យប្រកបក្នុងកំពង់គឺធម្មវិន័យ ។ ព្រះអង្គជាសព្វញ្ញូមានសេចក្ដីអាណិតសត្វជាទីអាស្រ័យ ទ្រង់សន្សំនូវគុណរកទីបំផុតគ្មាន ទ្រង់ថ្លឹងមើលដោយញាណនោះ ហើយសម្ដែងនូវធម៌ដ៏ប្រសើរ ។ ក្នុងកាលណាៗក៏ដោយ ព្រះសាស្ដាមានព្យាយាមមាំមួន មានការបរិសុទ្ធស្អាត ជាងប្រជុំជនជាអនន្ត ទ្រង់សម្ដែងធម៌ដ៏ពីរោះប្រកបដោយសច្ចៈ ៤ ។ ពួកសត្វចំនួនមួយសែន បានត្រាស់ដឹងមគ្គផល ព្រោះបានស្ដាប់នូវធម៌ដ៏ប្រសើរ មានលម្អខាងដើម កណ្ដាល និងខាងចុង ។ ក្នុងកាលនោះ ផែនដីក៏លាន់ឮ មេឃក៏គ្រហឹម ពួកទេវតា ព្រហ្ម មនុស្ស អសុរ ក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ឱ ! ព្រះសាស្ដាទ្រង់ប្រកបដោយករុណា ឱ ! ព្រះសទ្ធម្មទេសនា ឱ ! ព្រះជិនស្រី ទ្រង់ស្រង់ទេវតា មនុស្ស សត្វ ដែលមុជចុះក្នុងសមុទ្ទ គឺភព ឡើងបាន ។ ( កាលបើសត្វទាំងឡាយ ) ព្រមទាំងមនុស្ស ទេវតា ព្រហ្មកើតសេចក្ដីសង្វេគយ៉ាងនេះហើយ ព្រះជិនស្រីទ្រង់សរសើរនូវសាវ័កដែលប្រសើរជាងបុគ្គលជ្រះថ្លាក្នុងត្រកូលទាំងឡាយ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលអាមាត្យ ក្នុងហង្សវតីនគរ ជាបុគ្គលប្រកបដោយសេចក្ដីជ្រះថ្លា គួរឲ្យរមិលមើល មានទ្រព្យនិងស្រូវច្រើន ។ ខ្ញុំចូលទៅក្នុងហង្សារាម ថ្វាយបង្គំព្រះតថាគតនោះ ស្ដាប់នូវធម៌ដ៏ពីរោះ ហើយធ្វើនូវ

គ្រឿងសក្ការៈដល់ព្រះតថាគតជាតាទិបុគ្គល ។ ខ្ញុំក្រាបទៀបព្រះបាទា ពោលពាក្យនេះថា បពិត្រព្រះមុនី បុគ្គលណាប្រសើជាង បុគ្គលអ្នកជ្រះថ្លាក្នុងត្រកូល ក្នុងសាសនានៃព្រះអង្គ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គសូមឲ្យបានជាបុគ្គលប្រាកដដូចបុគ្គលនោះក្នុងសាសនានៃព្រះពុទ្ធដ៏ប្រសើរ ។

កាលនោះ ព្រះពុទ្ធទ្រង់ប្រកបដោយមហាករុណា ក៏ស្រោចខ្ញុំដោយអម្រឹតធម៌ ។ ព្រះពុទ្ធទ្រង់ត្រាស់នឹងខ្ញុំថា ម្នាលបុត្ត ចូរអ្នកក្រោកឡើង អ្នកនឹងបាននូវតំណែងសមដូចបំណងនុ៎ះ បុគ្គលធ្វើនូវការបូជាចំពោះព្រះជិនស្រីនឹងប្រាសចាកផលដូចម្តេចកើត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្តា ទ្រង់ព្រះនាមគោតម ព្រះអង្គសម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ បុរសនេះនឹងបានជាទាយាទក្នុងធម៌ទាំងឡាយរបស់ព្រះសាស្តានោះ ជាឱរសដែលធម៌និម្មិតហើយ ឈ្មោះឧទាយី ជាសាវ័ករបស់ព្រះសាស្តានោះ ។ កាលនោះ ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយមានចិត្តប្រកបដោយមេត្តា បានបម្រើនូវព្រះជិនស្រីព្រះអង្គជាអ្នកដឹកនាំសត្វដោយការបរិច្ចាគបច្ច័យទាំងឡាយ រហូតដល់អស់ជីវិត ។ ដោយវិបាកនៃកុសលកម្មនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ឆិមភព ខ្ញុំបានកើតក្នុងត្រកូលអាមាត្យជាធំក្នុងកបិលវត្ថុបុរី ជាទីរីករាយមានព្រះបាទសុទ្ធោទនៈជាម្ចាស់ផែនដី ។ កាលនោះ ព្រះសិទ្ធត្ថកុមារ ជាអ្នកអង់អាច ជាឧនរជន បានកើតឡើងក្នុងព្រៃលុម្ពិនីជាទីរីករាយ ដើម្បី

ប្រយោជន៍ ដើម្បីសេចក្តីសុខដល់សព្វសត្វលោក ។ ខ្ញុំកើតក្នុងថ្ងៃនោះដែរ មានវ័យចម្រើនឡើងជាមួយនឹងព្រះសិទ្ធត្ថកុមារនោះ ជាសម្លាញ់ជាទីស្រឡាញ់ ប្រកបដោយសេចក្តីអាណិត ជាអ្នកស្និទ្ធស្នាល ឈ្លាសវៃក្នុងនីតិសាស្ត្រ ។ ព្រះសិទ្ធត្ថកុមារនោះ មានវ័យ ២៩ ឆ្នាំ ក៏ចេញទៅបួស ញុំាងកាលឲ្យកន្លងទៅអស់ ៦ វស្សា បានត្រាស់ជាព្រះពុទ្ធ ដឹកនាំ ( សត្វលោក ) ព្រះអង្គឈ្នះមារព្រមទាំងសេនា ហើយញុំាងអាសវៈឲ្យអស់ ទ្រង់ឆ្លងអន្លង់គឺភព បានជាព្រះពុទ្ធក្នុងមនុស្សលោក និងទេវលោក ។ ទ្រង់ស្តេចទៅកាន់ព្រៃឈ្មោះឥសិបតនៈ ទូន្មានបញ្ចវគ្គិយភិក្ខុ តពីនោះមក ព្រះមានព្រះភាគក៏ស្តេចទៅក្នុងទីនោះៗ ហើយទូន្មាន ( សត្វ ) ។ ព្រះមានព្រះភាគនោះ កាលទូន្មានពួកសត្វដែលគួរទូន្មាន សង្គ្រោះនូវមនុស្សនិងទេវតា រួចស្តេចចូលទៅឯភ្នំក្នុងដែនមគធៈ កាលនោះព្រះជិនស្រី ទ្រង់គង់ ( លើភ្នំនោះ ) ។ ពេលនោះ ខ្ញុំត្រូវព្រះបាទសុទ្ធោទនៈ ជាភូមិបាលបញ្ជូនទៅហើយ ខ្ញុំក៏ទៅ លុះខ្ញុំបានឃើញព្រះទសពលហើយក៏បួស បានជាអរហន្ត ។ ខ្ញុំបានអារាធនាព្រះពុទ្ធព្រះអង្គស្វែងរកនូវគុណដ៏ធំ ឲ្យចូលទៅកាន់ក្រុងកបិលពស្តុ លំដាប់នោះ ខ្ញុំទៅមុនទៀត បានញុំាងមហាត្រកូលឲ្យជ្រះថ្លា ។ ព្រះជិនស្រីត្រេកអរក្នុងគុណនោះ ព្រះអង្គជាបុរសប្រសើរ ជានាយកដ៏វិសេស បានតាំងខ្ញុំថាជាអ្នកប្រសើរជាងសាវ័កអ្នកញុំាងត្រកូលឲ្យជ្រះថ្លា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់

ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកាឡុទាយិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ កាឡុទាយិត្ថេរាបទាន ។

# អដ្ឋកថា

# កាឡុទាយិត្ថេរាបទាន

[ ១៣៦ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៦ ដូចតទៅនេះថា អបទានរបស់ព្រះកាឡុទាយិត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ ឆាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ខណៈស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ឃើញភិក្ខុមួយរូប ដែលព្រះសាស្ដាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ជាងពួកភិក្ខុដែលធ្វើត្រកូលឲ្យជ្រះថ្លា ទើបធ្វើកម្មដែលមានអំណាចដើម្បីឲ្យបានតំណែងនោះ ហើយប្រាថ្នាតំណែងនោះ ។ សូម្បីព្រះសាស្ដាក៏ទ្រង់បានព្យាករហើយ ។ កុលបុត្តនោះ បានបំពេញកុសលកម្មដរាបដល់អស់ជីវិត ហើយអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងថ្ងៃដែលព្រះពោធិសត្វនៃយើងបដិសន្ធិក្នុងព្រះឧទររបស់មាតា កុលបុត្តនេះក៏ចុតិចាកទេវលោក បដិសន្ធិក្នុងត្រកូលអាមាត្យក្នុងនគរកបិលពស្ដុនោះឯង ។ កុលបុត្តនេះបានកើតក្នុងថ្ងៃតែមួយជាមួយនឹងព្រះពោធិសត្វនោះឯង ក្នុងថ្ងៃនោះ មាតាបិតាឲ្យកុលបុត្តនោះដេកលើកែប ដែលធ្វើដោយសំពត់ទុកូលពស្ត្រយ៉ាងល្អនាំទៅកាន់ទីគាល់របស់ព្រះពោធិសត្វ ។ ពិតហើយ ដើមពោធិព្រឹក្ស រាហុល

មាតា កំណប់ទ្រព្យទាំង ៤ ដំរី[១]សេះកណ្ឋកៈ នាយឆន្ន និងកាឡុទាយី អាមាត្យ ៧ យ៉ាងនេះ ជាសហជាតនឹងព្រះពោធិសត្វ ព្រោះកើតក្នុងថ្ងៃតែមួយ ។ លុះដល់ថ្ងៃ ដាក់ឈ្មោះ មាតាបិតាបានដាក់ឈ្មោះថាឧទាយី ព្រោះកើតក្នុងថ្ងៃដែលអ្នកនគរទាំងមូលមានចិត្តត្រេកអរ ។ តែគេបែរជាមានឈ្មោះប្រាកដថាកាឡុទាយី ព្រោះមានសម្បុរខ្មៅបន្តិច ។ កុលបុត្តនោះ លេងតាមបែបក្មេងៗ ជាមួយព្រះពោធិសត្វ រហូតដល់ធំ ។

ក្នុងកាលតមក កាលព្រះលោកនាថយាងចេញមហាភិនេស្ក្រមណ៍ បានសម្រេចព្រះសព្វញ្ញុតញ្ញាណតាមលំដាប់ ហើយប្រកាសធម្មចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅហើយ ទ្រង់អាស្រ័យនគររាជគ្រឹះ ប្រថាប់នៅក្នុងវត្តវេឡុវន ។ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់បញ្ជូនអាមាត្យម្នាក់ដែលមានបរិវារ ១០០០ ទៅ ដោយព្រះតម្រាស់ថា ចូរអ្នកទៅនាំកូនរបស់យើងមកទីនេះចុះ ។ អាមាត្យនោះ ទៅដល់ក្នុងវិហារដែលព្រះសាស្តាសម្តែងព្រះធម្មទេសនាទើបឈរខាងចុងបរិស័ទ ស្តាប់ព្រះធម្មទេសនាហើយបានសម្រេចអរហត្ត មួយអន្លើដោយបរិវារ ។ លំដាប់នោះ ព្រះសាស្តាទ្រង់លាព្រះហស្ត ត្រាស់នឹងជនទាំងនោះថា ចូរមកជាភិក្ខុចុះ ។ ក្នុងរំពេចនោះឯង ជនទាំងអស់ទ្រទ្រង់នូវបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ ដូចគ្នានឹងព្រះថេរៈមានវស្សា ៦០ ។ តាំងអំពីបានសម្រេចអរហត្តហើយ ធម្មតាព្រះអរិយៈទាំងឡាយ រមែងជាបុគ្គលដាក់ខ្លួនជាកណ្តាល ព្រោះហេតុនោះ ទើប

១-ក្នុងអដ្ឋកថាទីខ្លះមិនរាប់ដំរីចូល តែរាប់ព្រះអានន្ទបញ្ចូលវិញ ។

មិនបានក្រាបទូលដំណឹង ដែលព្រះរាជាបញ្ជូនទៅឲ្យព្រះទសពលទ្រង់បានជ្រាប ។ ព្រះរាជាទ្រង់ត្រាស់ថា ជនទាំងនោះទៅហើយមិនត្រឡប់មក ដំណឹងក៏មិនដឹង ទើបទ្រង់បញ្ជូនអាមាត្យម្នាក់ទៀតទៅមួយអន្លើដោយបរិវារ ១០០០ ។ កាលអាមាត្យនោះធ្វើដូចគ្នាយ៉ាងនោះ ទើបទ្រង់បញ្ជូនអាមាត្យដទៃទៅទៀត ទ្រង់បញ្ជូនអាមាត្យទៅបែបនេះ រួមជាអាមាត្យ ៩ នាក់ បរិវាររបស់អាមាត្យ ៩០០០ នាក់ ។ ជនទាំងអស់ទៅដល់ហើយ សម្រេចអរហត្ត ក៏ស្ងៀមនៅ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ជនទាំងឡាយមានប្រមាណប៉ុណ្ណេះ មិនបានក្រាបទូលពាក្យណាមួយដើម្បីឲ្យព្រះទសពលយាងមក ក្នុងទីនេះ ព្រោះមានសេចក្តីស្រឡាញ់ក្នុងអញសោះ តែឧទាយីនេះ មានវ័យស្មើនឹងព្រះទសពល ធ្លាប់លេងដីជាមួយគ្នា និងមានសេចក្តីស្រឡាញ់ក្នុងអញ អញនឹងបញ្ជូនឧទាយីនេះទៅ ។ លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់ឲ្យហៅឧទាយីនោះមកថា នែបា ចូរបានាំបរិវារ ១០០០ ទៅនិមន្តព្រះទសពលមកក្នុងទីនេះចុះ ហើយទ្រង់បញ្ជូនទៅ ។ ឧទាយីនោះ កាលនឹងទៅ ទើបក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បើទូលព្រះបង្គំបានបួសសោត ទូលព្រះបង្គំនឹងនិមន្តព្រះមានព្រះភាគមកក្នុងទីនេះឲ្យបាន ។ ព្រះរាជាត្រាស់ថា សូម្បីអ្នកបួសហើយ ក៏ចូរឲ្យយើងបានឃើញបុត្តចុះ ។ ឧទាយីទៅដល់នគររាជគ្រឹះ ក្នុងកាលដែលព្រះសាស្តាទ្រង់សម្តែងព្រះធម្មទេសនា ទើបឈរខាងចុងបរិស័ទ ស្តាប់ធម៌ហើយ មួយអន្លើដោយបរិវារបានសម្រេចអរហត្ត តាំងនៅក្នុងភាពជាឯហិភិក្ខុ ។ លោកសម្រេចអរហត្តហើយគិតថា ពេលនេះមិន

មែនជាកាលដែលព្រះទសពលត្រូវយាងទៅកាន់នគរនៃត្រកូល តែកាលខាងចុងរដូវវស្សា កាលភូមិភាគដេរដាសទៅដោយតិណជាតិដែលខៀវស្រងាត់តាមភ្នំ តាមដងព្រៃ ជាកាលដែលគួរយាងទៅ ទើបរង់ចាំពេលវេលាយាងទៅ ។ កាលខាងចុងរដូវវស្សាមកដល់ ទើបពណ៌នាសរសើរផ្លូវដើម្បីទូលព្រះសាស្តាយាងទៅកាន់នគរនៃត្រកូល សមដូចពាក្យដែលលោកពោលទុកក្នុងថេរគាថាថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះរុងរឿងដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះជាកាលគួរបានចំណែកធម្មរសហើយ ។ ឈើទាំងឡាយជាទីរីករាយនៃចិត្ត មានផ្លែផ្សាយក្លិនសព្វទិសដោយជុំវិញ ជម្រុះស្លឹកចាស់ចោល ប្រុងនឹងចេញផ្លែថ្មីទៀត បពិត្រព្រះអង្គមានព្យាយាម កាលនេះ ជាកាលគួរដើម្បីចេញទៅអំពីទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈនិងពួកកោឡិយៈ សូមជួបព្រះអង្គ ដែលមានព្រះភក្ត្រ៍បែរត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។

អ្នកស្រែភ្ជួរស្រែ ដោយសេចក្តីប្រាថ្នាព្រោះពូជ ដោយសេចក្តីប្រាថ្នា ពួកឈ្មួញអ្នករកទ្រព្យឆ្លងសមុទ្រ ដោយសេចក្តី

ប្រាថ្នា ។ ខ្ញុំព្រះអង្គ ឋិតនៅដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គនោះ សូមឲ្យសម្រេច ។

( រដូវនេះមិនត្រជាក់ពេក មិនក្តៅពេក ក៏ក្លាយកបានងាយ មិនអត់ឃ្លាន ភូមិភាគមានស្មៅខ្ចាំងខៀវខ្ចី បពិត្រព្រះមហាមុនី នេះជាកាលសមគួរ )[១]។

អ្នកស្រែទាំងឡាយ ព្រោះពូជរឿយៗ ទេវរាជបង្អុរភ្លៀង ក៏រឿយៗ ពួកអ្នកស្រែភ្ជួរស្រែរឿយៗ ពួកអ្នកស្រែនោះនាំស្រូវចូលទៅកាន់ដែនក៏រឿយៗ ។ ពួកស្មូមត្រាច់សូមរឿយៗ អ្នកម្ចាស់ទានតែងឲ្យក៏រឿយៗ ពួកម្ចាស់ទានលុះឲ្យរឿយៗហើយ តែងទៅកាន់ឋានសួគ៌ក៏រឿយៗដែរ ។

អ្នកប្រាជ្ញមានបញ្ញាដូចផែនដី កើតក្នុងត្រកូលណា រមែងញុំាងគូនៃបុរស ៧ ជួរក្នុងត្រកូលនោះឲ្យស្អាត ខ្ញុំព្រះអង្គសម្គាល់ថា ( ព្រះមានព្រះភាគ ) ជាទេវតាប្រសើរជាងទេវតា អាច ( ធ្វើសត្វដទៃឲ្យស្អាតបាន ) ព្រោះអ្នកប្រាជ្ញមានព្រះនាមដ៏ពិត កើតហើយអំពីព្រះអង្គ ។ ព្រះបាទសុទ្ធោទនៈជាបិតារបស់ព្រះពុទ្ធព្រះអង្គស្វែងរកនូវគុណដ៏ធំ ឯព្រះមហេសីព្រះនាមមាយា ជាពុទ្ធមាតា ដែលរក្សាព្រះពោធិសត្វដោយផ្ទៃ លុះរំលាយខន្ធទៅ ត្រេកអរក្នុងតុសិតទេវលោក ។

---

១-គាថាក្នុងវង់ក្រចកនេះមិនប្រាកដក្នុងបាលីថេរគាថា ។

ព្រះនាងទេវីនោះ ជាគោតមគោត្ត លុះទិវង្គតច្យុតចាកលោក នេះទៅ បានស្កប់ស្កល់ដោយកាមជាទិព្វទាំងឡាយ ព្រះនាង ទ្រង់រីករាយដោយកាមគុណទាំង ៥ មានពពួកទេវតាទាំងនោះ ចោមរោមហើយ ។ អាត្មាជាបុត្តនៃព្រះពុទ្ធ ព្រះអង្គមិនមាន បុគ្គលដទៃគ្របសង្កត់បាន ព្រះនាមអង្គីរសៈ មិនមានបុគ្គល ដទៃប្រៀបបាន ប្រកបដោយតាទិគុណ បពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតារបស់អាត្មា បពិត្រព្រះគោតម ព្រះអង្គ ជាជីតារបស់អាត្មា ដោយធម៌ ។

ស្វាយ ខ្នុរ និងខ្វិត ប្រដាប់ដោយផ្កានិងស្លឹក មានផ្លែជា និច្ច មានផ្លែសំយុងចុះ ដូចសម្បុកឃ្មុំផ្អិត មានសងខាងផ្លូវ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់ យាង ។

ផ្លែព្រីងមានរសឆ្ងាញ់ផ្អែមត្រជាក់ ផ្លែឈើស្គួត គឺសម្បុក ឃ្មុំទាំងនោះ រុងរឿងល្អក្នុងសងខាងផ្លូវ បពិត្រព្រះអង្គមាន យសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ដើមទទ្លាប់ ដើមទ្រយឹង មានពណ៌ដូចមាស គួរជាទីត្រេក អរនៃចិត្ត ដើមដែលមានផ្លែតូចក៏មានជានិច្ច បពិត្រព្រះអង្គ មានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ដើមចេកនិងចេកដៃនាង ក៏មានផ្លែទុំសំយុងចុះសងខាងផ្លូវ

បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាន ។

ដើមឈើមានផ្លែមានរសផ្អែមជានិច្ច ដើមកន្ទុយក្ងោក គួរជាទីត្រេកអរនៃចិត្ត ដើមឈើដែលមានផ្លែតូច ក៏មាននៅជានិច្ច បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាន ។

ដើមទ្រាំងមានផ្លែទុំ មានដើមពណ៌ដូចប្រាក់រុងរឿង ដើមឈើតូចដែលដេរដាសដោយផ្លែទុំ មានរសធ្ងាញ់ ទ្រង់នឹងបានសោយផ្លែទាំងនោះ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាន ។

ដើមល្វាមានពណ៌ដូចអរុណមានផ្លែធ្ងាញ់សព្វកាល សំយុងចុះសងខាងផ្លូវ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាន ។

ដើមឈើជាច្រើនដែលពោលនោះ ចេញផ្លែសន្ទឹកសន្ធាប់ សំយុងចុះសងខាងផ្លូវ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាន ។

ផ្កាចម្ប៉ា ផ្កាស្រល់ ផ្កាខ្ទឹង មានក្លិនក្រអូប កាលខ្យល់រំភើយបក់មក ត្រួយចេញផ្ការីកស្គុសស្គាយ ល្អរុងរឿង យោនយានបូជាដោយក្លិនក្រអូប បពិត្រព្រះអង្គមានយសធំ ឥឡូវ

នេះ ជាកាលសមគួរទ្រង់យាង ។

ផ្កាបុសនាគ ផ្កាបុសនាគភ្នំ ដើមឈើមានផ្កាវីកស្រស់ត្រកាល ត្រួយចេញផ្កាវីកស្កុសស្កាយ រុងរឿង យោនយាន បូជាដោយក្លិនក្រអូប បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ផ្កាអសោកនិងផ្ការល្ងសផ្អុងដ៏ប្រសើរ នាំមកនូវសោមនស្ស ផ្កាកណិការមានក្លិនក្រអូបជ្រុះអំពីទង ធ្វើឲ្យផែនដីក្រាលដោយពណ៌ក្រហម យោនយានសំយុងចុះ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ដើមកណិការ ( មានផ្កា ) វីកជានិច្ច រុងរឿងដោយពន្លឺមាស ផ្សាយទៅដោយក្លិនទិព្វ ធ្វើទិសទាំងពួងឲ្យល្អ យោនយានសំយុងចុះ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ផ្កាកាកែស ផ្ការំចេក មានស្លឹកល្អ មានក្លិនក្រអូបឈ្ងុយឈ្ងប់ ក្លិនក្រអូបផ្សាយទៅតាមខ្យល់គ្រប់ទិស មានមែកយោនយាន សំយុងចុះដើម្បីបូជា បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ផ្កាម្លិះលា ម្លិះរួត ម្លិះមានផ្កាតូចៗមានក្លិនក្រអូប ជះក្លិនក្រអូបទៅគ្រប់ទិសធ្វើឲ្យសងខាងផ្លូវស្អាត យោនយាន បង្អោនចុះដើម្បីព្រះអង្គ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ

ជាកាលសមគួរទ្រង់យាង ។

ផ្កាឈើទាលខ្សាច់មានក្លិនក្រអូបត្រជាក់ មានក្លិនបក់មក ក្នុងកាលខ្យល់បក់ បូជាគ្រប់ទិស ធ្វើឲ្យសងខាងផ្លូវស្អាត យោនយាន មានមែកសំយុងចុះ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះជាកាលសមគួរទ្រង់យាង ។

សីហៈនិងកេសរសីហៈជាទីគប់រករបស់សត្វជើង ៤ មិនតក់ស្លុត ជាសត្វក្លៀវក្លា ជាស្តេចម្រឹគ ជាសត្វមានតបៈ ។

( សីហៈទាំងនោះ ) នាំគ្នាបូជាដោយការបន្លឺសីហនាទ មានសេចក្តីអើពើ គ្របសង្កត់នូវពួកម្រឹគដើម្បីព្រះអង្គ ដេញ ( សត្វកាចទាំងនោះ ) ឲ្យចេញអំពីសងខាងផ្លូវ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ខ្លាធំ សេះសិន្ធព សត្វស្ការ ដែលមានរូបស្អាត គួរខ្លាច ដូចលោតលេងក្នុងអាកាស មិនកោតញញើតបុគ្គលណាមួយ សត្វទាំងនោះមានការអើពើ នមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ដំរីត្រកូលឆទ្ទន្តចុះប្រេងក្នុងទី ៣ អន្លើ មានរូបល្អ មានសំឡេងពីរោះ ជាសត្វស្អាត មានទី ៧ ប្រតិស្ឋានទល់ ( ផែនដី )[១]បន្លឺសំឡេងសងខាងផ្លូវ មានការអើពើ ត្រេកអរ បពិត្រ

១-ជើង ៤ ប្រមោយ ១ ផ្ចិត ១ និងកន្ទុយ ១

ព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ម្រឹគ ជ្រូក ប្រើសមានខ្លួនវិចិត្រ ជាសត្វស្អាត បរិបូណ៌ ដោយកម្ពស់និងទំហំ មានរូបល្អសមសួន យាសយំសងខាង ផ្លូវ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរ ទ្រង់យាង ។

គោព្រៃ សរកម្រឹគនិងរុរុម្រឹគ ដែលមានជើងត្រង់និងជើង កោង មានរូបល្អគ្រប់ចំណែក រួមគ្នាឈប់សម្រាកក្នុងវេលា នោះ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរ ទ្រង់យាង ។

ខ្លាដំបង ខ្លាឃ្មុំ និងខ្លារខិន ដែលតែងតែចាប់ស៊ីសត្វទាំង ឡាយសព្វកាល ឥឡូវនេះ សត្វទាំងអស់នោះ បានសិក្សា ល្អហើយ មានសេចក្ដីមាំទាំចំពោះព្រះអង្គដោយមេត្តា ជាសត្វ ត្រូវការគប់រក ព្រះអង្គអស់កាលយូរមកហើយ បពិត្រព្រះ អង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ទន្សាយ ចចក ស្ការ កំប្រុក កង្ហែនជាច្រើន ជាសត្វ វាសវៃ មានចិត្តក្លាហាន មានប្រមុះវាងវៃ ( សត្វ ) ទាំង អស់នោះ កំពុងយំដើម្បីព្រះអង្គ បពិត្រព្រះអង្គមានយសធំ ឥឡូវនេះ ជាកាលសមគួរទ្រង់យាង ។

ក្ងោកមានផ្ចិតកពណ៌ខៀវ ក្ងោកទាំងនោះមានសិរល្អ មាន

ស្វាបល្អ មានសំណុំកន្ទុយល្អ ស្រែកយំពីរោះ ( មានរូប ) ល្អ ដូចកែវពិទូរ្យនិងកែវមណី នាំគ្នាបន្លឺសំឡេងបូជាដល់ព្រះអង្គ កាលនេះ ជាកាលសមគួរទ្រង់ឃើញព្រះបិតា ។

ពួកហង្សម្ចាសដ៏ល្អ ជាហង្សដែលហើរទៅក្នុងអាកាស ហង្សទាំងអស់នោះ បោះបង់ទីអាស្រ័យ ខ្វល់ខ្វាយក្នុងការឃើញព្រះជិនស្រី ទើបបន្លឺសំឡេងយំដ៏ពីរោះ កាលនេះ ជាកាលសមគួរទ្រង់ឃើញព្រះបិតា ។

ពួកហង្ស ពួកក្រៀលនាំគ្នាយំដោយសំឡេងដ៏ពីរោះ ពួកសត្វចាកប្រពាកជាសត្វទទឹចរ ពួកកុក ពួកត្រដក់ ជាសត្វគួរមើល ពួកក្អែកទឹក មាន់ទោរទាំងនោះ មានសេចក្តីអើពើ បន្លឺសំឡេងដ៏ពីរោះ កាលនេះ ជាកាលសមគួរទ្រង់ឃើញព្រះបិតា ។

ពួកសារិកា ពួកសេកមានរូបស្អាត មានសំឡេងពីរោះ មានរោម ស្អាត មានចំពុះល្អ បន្លឺសំឡេងលោតលើចុងឈើ យាសយំសងខាងផ្លូវ កាលនេះជាកាលសមគួរទ្រង់ឃើញព្រះបិតា ។

សត្វតាវ៉ៅដែលសុទ្ធតែល្អ មានសំឡេងពីរោះសព្វកាល ជាទីអស្ចារ្យដល់ជនទាំងពួង មានសេចក្តីក្តៅក្រហាក្នុងការរួមគ្នាជាមិត្តជាដើម កំពុងបូជាដោយសំឡេង កាលនេះជាកាលសមគួរទ្រង់ឃើញព្រះបិតា ។

ពួកកូនជីវ៍ លលក ត្រយង មាននៅពេញព្រៃសព្វកាល នាំគ្នាយំលេងលើយពេញព្រៃដោយសំឡេងដ៏ពីរោះ ឆ្លើយឆ្លងគ្នា កាលនេះជាកាលសមគួរទ្រង់យើញព្រះបិតា ។

ពួកសត្វទទា សត្វត្រយងមានសំឡេងពីរោះ មាន់ព្រៃមានសំឡេងល្អ ពីរោះ គួរត្រេកអរនៃចិត្ត កាលនេះជាកាលសមគួរទ្រង់យើញព្រះបិតា ។

ទឹកស្រះដេរដាសដោយខ្យាច់ពណ៌ស មានកំពង់រាបស្មើ គួរជាទីត្រេកអរនៃចិត្ត ពេញដោយទឹកមានរសឆ្ងាញ់ ថ្លាភ្លឺ-ផ្លេកសព្វកាល សត្វទាំងនោះ តែងនាំគ្នាងូតនិងផឹកក្នុងស្រះនោះ សម័យនេះជាសម័យសមគួរទ្រង់យើញពួកញាតិ ។

ស្រះទឹកដេរដាសដោយក្រពើនិងមករ មានត្រីរៀល ត្រីក្រពាត់ ត្រីឆ្ពិនក្រហម ត្រីនិងអណ្តើកហែលទៅមក មានទឹកត្រជាក់ល្អ ជាស្រះស្អាត សត្វទាំងនោះនាំគ្នាងូតនិងផឹក ក្នុងស្រះនោះ សម័យនេះជាសម័យសមគួរទ្រង់យើញពួកញាតិ ។

មានស្រះទឹកស្អាត ដេរដាសដោយផ្កាឧប្បលខៀវ ឧប្បលក្រហម ចម្រុះដោយផ្កាកុមុទនិងផ្កាឧប្បលច្រើនប្រភេទ មានទឹកត្រជាក់ល្អ សម័យនេះជាសម័យ សមគួរទ្រង់យើញពួកញាតិ ។

ស្រះទឹកនោះ ដេរដាសដោយផ្កាបុណ្ឌរីក ពេញទៅដោយ

ផ្កាឈូក ប្រជាប់នៅសងខាងផ្លូវក្នុងទីនោះៗ មានស្រះ បោក្ខរណីដទៃៗទៀត ជាទីដែលជនទាំងឡាយមកងូត សម័យ នេះ ជាសម័យសមគួរទ្រង់យើញពួកញាតិ ។

ស្ទឹងដេរដាសទៅដោយគ្រាប់ខ្សាច់ពណ៌ស មានកំពង់រាប ស្មើ គួរជាទីត្រេកអរនៃចិត្ត មានអន្លង់ប្រកបដោយទឹកត្រជាក់ ពេញដោយទឹក ជាស្ទឹងស្អាត ហូរទៅសងខាងផ្លូវ សម័យ នេះ ជាសម័យសមគួរទ្រង់យើញពួកញាតិ ។

ក្នុងសងខាងផ្លូវមានស្រុក និងនិគមរៀងៗគ្នា មហាជន ទាំងឡាយជាអ្នកមានសទ្ធាជ្រះថ្លា រាប់អានព្រះរតនត្រ័យ ជន ទាំងនោះពេញដោយតម្រិះត្រូវ សម័យនេះជាសម័យសមគួរ ទ្រង់យើញពួកញាតិ ។

ពួកទេវតានិងពួកមនុស្សទាំងពីរពួក នៅក្នុងប្រទេសនោះៗ នឹងបូជាព្រះអង្គដោយផ្កាកម្រងនិងគ្រឿងក្រអូប សម័យនេះជា សម័យសមគួរទ្រង់យើញពួកញាតិ ។

ព្រះថេរៈបានពណ៌នាដល់លម្អនៃផ្លូវយាងទៅ ថ្វាយព្រះសាស្តាដោយ គាថាប្រមាណ ៦០ យ៉ាងនេះ ។

លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា កាឡុទាយី ប្រាថ្នា នឹងឲ្យតថាគតទៅ តថាគតនឹងធ្វើនូវសេចក្តីត្រិះរិះរបស់ឧទាយី ឲ្យបរិបូណ៌ ដូច្នេះហើយ ទ្រង់យើញថា ក្នុងការទៅក្នុងទីនោះ មហាជនជាច្រើន នឹងបាន

សម្រេចគុណវិសេស ទ្រង់មានព្រះវីណាស្រេព ២ ម៉ឺន ហោមរោម យាង ចេញចាកក្រុងរាជគ្រឹះ ដោយយាងចារិកមិនប្រញាប់ប្រញាល់ ទ្រង់សោយ ផលាផល ។ ពួកសត្វជើង ២ និងជើង ៤ ជាដើម នាំគ្នាបូជាដោយការ មកគាល់ ទ្រង់បានទទួលក្លិនក្រអូបអំពីផ្កាឈើមានក្លិនក្រអូប ដូចបានពោល ហើយ ទ្រង់ធ្វើការសង្គ្រោះដល់អ្នកស្រុកនិងអ្នកនិគម យាងទៅតាមផ្លូវទៅ កាន់នគរកបិលពស្តុ ។ ព្រះថេរៈទៅកាន់នគរកបិលពស្តុដោយឫទ្ធិ ឈរ កណ្តាលអាកាសខាងមុខព្រះរាជា ព្រះរាជាបានឃើញភេទដែលមិនធ្លាប់ឃើញ ទើបត្រាស់សួរថា អ្នកជានរណា ព្រះថេរៈកាលពោលថា បើទ្រង់មិនស្គាល់ កូនអាមាត្យដែលទ្រង់បញ្ជូនទៅ សូមទ្រង់ជ្រាបដូចតទៅនេះ ហើយពោលគា ថាថា

> **អាត្មាជាបុត្តនៃព្រះពុទ្ធ** ព្រះអង្គ**មិនមានបុគ្គលដទៃគ្រប សង្កត់បានព្រះនាមអង្គីរសៈ មិនមានបុគ្គលដទៃប្រៀបបាន** ប្រកប ដោយតាទិគុណ បពិត្រព្រះអង្គជា**សក្យៈ ព្រះអង្គជាបិតានៃ បិតារបស់អាត្មា** បពិត្រ**ព្រះគោតម** ព្រះអង្គ**ជាជីតារបស់អា ត្មាដោយធម៌** ដូច្នេះ ។

បណ្តាបទទាំងនោះ ពាក្យថា **អាត្មាជាបុត្តនៃព្រះពុទ្ធ** សេចក្តីថា អាត្មា ជាបុត្តកើតអំពីទ្រូង ព្រោះកើតអំពីព្រះធម្មទេសនា ដែលព្រះអង្គព្យាយាមឲ្យ កើតក្នុងទ្រូងរបស់ព្រះសម្មាសម្ពុទ្ធ ។ ពាក្យថា **មិនមានបុគ្គលដទៃគ្រប សង្កត់បាន** សេចក្តីថា ឈ្មោះថា **មិនមានបុគ្គលដទៃគ្របសង្កត់បាន** ព្រោះ

នាំទៅនូវពោធិសម្ភារទាំងមូល និងជាប្រកពកើតនៃមហាករុណា ដែលឈ្មោះថា **គ្របសង្កត់មិនបាន** ព្រោះមិនមានបុគ្គលដទៃអាចគ្របសង្កត់ ព្រះមហាពោធិសត្វអំពីការត្រាស់ដឹង មុននឹងបានត្រាស់ដឹង បន្ទាប់អំពីនោះ ព្រោះញាំញី គឺគ្របសង្កត់នូវមារ ៥ ដែលឈ្មោះថាញាំញីមិនបាន ព្រោះអ្នកដទៃមិនអាចញាំញី គឺគ្របសង្កត់បាន ព្រោះទ្រង់អត់ធន់ចំពោះពុទ្ធកិច្ច ដែលអ្នកដទៃអត់ធន់មិនបាន ដែលបានដល់ការប្រៀនប្រដៅវេនេយ្យសត្វ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ តាមសមគួរ ដោយការឈមចុះដល់ការផ្សេងគ្នានៃសត្វ តាមអាសយានុសយៈ ចរិត និងអធិមុត្តិជាដើម ម្យ៉ាងទៀត ឈ្មោះថា **មិនមានបុគ្គលដទៃគ្របសង្កត់បាន** ក្នុងទីនេះ ព្រោះទ្រង់ធ្វើល្អ ។

ពាក្យថា **ព្រះនាមអង្គីរសៈ** បានដល់ ជាអ្នកសម្បូរដោយព្រះគុណ មានសីលជាដើម ដែលប្រកបឡើងជាព្រះអង្គ ។ អាចារ្យពួកដទៃពោលថា ទ្រង់មានព្រះរស្មីផ្សាយចេញអំពីព្រះវរកាយតូចធំ ដូច្នេះក៏មាន ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រះនាម ២ គឺព្រះអង្គីរសៈ ១ ព្រះសិទ្ធត្ថៈ ១ នេះពុទ្ធបិតាទ្រង់ដាក់ឲ្យ ។

ពាក្យថា **មិនមានបុគ្គលដទៃប្រៀបបាន** សេចក្តីថា មិនមានបុគ្គលប្រៀបបាន ជាបុគ្គលទឹងទីង ព្រោះសម្បូរដោយព្រះលក្ខណៈនៃភាពជាតាទិបុគ្គលក្នុងអារម្មណ៍ដែលគួរប្រាថ្នាជាដើម ។ ពាក្យថា **ព្រះអង្គជាបិតានៃបិតារបស់អាត្មា** សេចក្តីថា ដោយលោកវោហារ ព្រះអង្គជាព្រះបិតារបស់ព្រះសម្ពុទ្ធ

ដែលជាបិតានៃអាត្មាដោយអរិយជាតិ ។ ព្រះថេរៈហៅព្រះរាជាដោយវង្សថា **សក្យៈ** ។ ពាក្យថា **ដោយធម៌** បានដល់ ដោយសភាវៈ គឺដោយរួមសភាវៈ ២ ជាតិ ចូលជាមួយគ្នា គឺអរិយជាតិ និងលោកិយជាតិ ។ ព្រះថេរៈហៅព្រះរាជាដោយព្រះគោត្តថា **ព្រះគោតម** ។ ពាក្យថា **ជាជីតា** បានដល់ជាបិតារបស់បិតា កាលព្រះថេរៈពោលពាក្យជាដើមថា **អាត្មាជាបុត្តនៃព្រះពុទ្ធ** ក្នុងគាថានោះ ស្មើនឹងបានព្យាករអរហត្តផលហើយ ។

កាលព្រះថេរៈបានឲ្យព្រះរាជាស្គាល់ខ្លួនយ៉ាងនេះហើយ ព្រះរាជាទ្រង់រីករាយត្រេកអរ និមន្តឲ្យគង់លើបល្ល័ង្កដែលមានតម្លៃច្រើន ហើយទ្រង់ដាក់ភោជនដែលមានរសដ៏ថ្លៃថ្លាច្រើនប្រភេទ ដែលត្រៀមទុកដើម្បីព្រះអង្គ រហូតពេញបាត្រ កាលព្រះរាជាទ្រង់ប្រគេនបាត្រហើយ ព្រះថេរៈក៏សម្តែងអាការនឹងទៅ កាលព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ទើបបំណងនឹងទៅ និមន្តឆាន់សិនចុះ ។ ព្រះថេរៈទូលថា អាត្មានឹងទៅគាល់ព្រះសាស្តា ហើយទើបឆាន់ ។ ព្រះរាជាត្រាស់សួរថា ព្រះសាស្តានៅឯណា ព្រះថេរៈទូលថា ព្រះសាស្តាទ្រង់មានភិក្ខុ ២ ម៉ឺនជាបរិវារ កំពុងយាងមកតាមផ្លូវដើម្បីជួបព្រះអង្គហើយ ។ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ឆាន់បិណ្ឌបាតនេះចុះ សឹមនាំបិណ្ឌបាតដទៃទៅថ្វាយព្រះមានព្រះភាគ សូមលោកម្ចាស់នាំបិណ្ឌបាតអំពីទីនេះប៉ុណ្ណោះទៅថ្វាយព្រះអង្គ ទម្រាំកូនរបស់ខ្ញុំមកដល់នគរនេះ ។ ព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ ក៏សម្តែងធម៌ប្រោសព្រះរាជានិងបរិស័ទ ធ្វើរាជនិវេសន៍ ( អ្នករាជវាំង ) ឲ្យជ្រះថ្លាក្នុងគុណ ព្រះរតនត្រ័យ មុនព្រះសាស្តាយាងមកដល់

នោះឯង ។ កាលមនុស្សទាំងឡាយកំពុងសម្លឹងមើលនោះឯង បានបោះបាត្រដែលពេញដោយកក្កុ ដែលត្រូវនាំទៅដើម្បីព្រះសាស្តា ទៅក្នុងអាកាស ខ្លួនឯង ក៏ហោះឡើងកាន់វេហាស៍ បង្អោនយកបាត្រទៅដាក់ក្នុងព្រះហស្តព្រះសាស្តា ។ ព្រះសាស្តា ក៏សោយបិណ្ឌបាតនោះ ។

កាលព្រះមានព្រះភាគយាងទៅក្នុងចម្ងាយផ្លូវ ៦០ យោជន៍ មួយថ្ងៃ ១ យោជន៍យ៉ាងនេះ ព្រះថេរៈបាននាំយកកក្កុអំពីព្រះរាជវាំងទៅថ្វាយ ( រាល់ថ្ងៃ ) ។ ព្រះមានព្រះភាគយាងដល់នគរកបិលពស្តុហើយ ស្អែកឡើង យាងទៅបិណ្ឌបាតក្នុងផ្លូវធំ ។ ព្រះបាទសុទ្ធោទនមហារាជ បានដំណឹងនោះហើយ យាងទៅទីនោះត្រាស់ថា សូមទ្រង់កុំសម្គាល់ថា ការធ្វើបែបនេះ ជាវត្ថុដែលគួរធ្វើ វត្ថុនេះមិនមែនបវេណីរបស់រាជវង្សឡើយ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នេះជាវង្សរបស់ព្រះអង្គ តែពុទ្ធវង្សរបស់ពួកតថាគតបែបនេះ ហើយទ្រង់សម្តែងធម៌ ( ក្នុងធម្មបទ ) ថា

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល
គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រកតីរមែង
ដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យ
ទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ
ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដូច្នេះ ។

ព្រះរាជាទ្រង់តាំងនៅក្នុងសោតាបត្តិផល ។ បន្ទាប់អំពីនោះ ព្រះរាជា

ទ្រង់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យសោយ និងឆាន់ក្នុងព្រះរាជមន្ទីរ របស់ព្រះអង្គ ក្នុងទីបំផុតនៃការឆាន់កត្តាហារ ទ្រង់ស្តាប់ធម្មបាលជាតកហើយ មួយអន្ទើដោយបរិស័ទ បានតាំងនៅក្នុងអនាគាមិផល ។ ក្នុងកាលតមក ទ្រង់ផ្ទំខាងក្រោមស្វេតច្ឆត្រនោះឯង ទ្រង់បានសម្រេចអរហត្ត បរិនិព្វានហើយ ។

កាលនោះ ព្រះមានព្រះភាគ បានយាងទៅកាន់ប្រាសាទរបស់ព្រះនាងពិម្ពាទេវី ព្រះមាតារបស់ព្រះរាហុលកុមារ ទ្រង់សម្តែងធម៌ដល់ព្រះនាង ទ្រង់បន្ទោបង់សេចក្តីសោកហើយ ទ្រង់ឲ្យព្រះនាងកើតសេចក្តីជ្រះថ្លាដោយទេសនាគឺចន្ទកិន្នរីជាតក ហើយយាងទៅកាន់និគ្រោធារាម ។ កាលនោះ ព្រះនាងពិម្ពាទេវី បានត្រាស់នឹងរាហុលកុមារជាព្រះរាជឱរសថា ចូរកូនទៅសូមទ្រព្យដែលជាសម្បត្តិរបស់បិតាកូនចុះ ។ ព្រះរាជកុមារទូលថា បពិត្រសមណៈសូមទ្រង់ ព្រះរាជទានទ្រព្យដែលជាមរតកដល់ខ្ញុំចុះ ហើយដើរតាមព្រះមានព្រះភាគទៅបណ្តើរទូលបណ្តើរថា បពិត្រសមណៈ ស្រមោលរបស់ព្រះអង្គត្រជាក់ល្អណាស់ ។ ព្រះមានព្រះភាគទ្រង់នាំរាហុលកុមារនោះទៅកាន់និគ្រោ-ធារាម ហើយត្រាស់ថា ចូរអ្នកទទួលយកទ្រព្យ គឺលោកុត្តរធម៌ចុះ ហើយទ្រង់ឲ្យបព្វជ្ជា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងកណ្តាលពួកអរិយសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកញុំាងត្រកូលឲ្យជ្រះថ្លា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងកាឡុទាយិប្រសើរជាងគេ ដូច្នេះ ។

ព្រះថេរៈបានទទួលតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្ម

របស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានប្រព្រឹត្តដែលមក ក្នុងកាលមុន ទើបពោលគាថាថា **បទុមុត្តរោ នាម ជិនោ** ដូច្នេះជាដើម ។ ក្នុងគាថានោះ ខ្ញុំនឹងពណ៌នាចំពោះបទដែលលំបាកប៉ុណ្ណោះ ។

បទថា **គុណាគុណវិទូ** មានអត្ថថា គុណនិងមិនមែនគុណ ឈ្មោះថា **គុណាគុណា** គឺគុណនិងទោស ។ មយ៉ាងទៀត ឈ្មោះថា **គុណាគុណវិទូ** ព្រោះរមែងដឹងច្បាស់ថា វត្ថុនោះជាកុសលនិងអកុសល ។ បទថា **កតញ្ញូ** សេចក្តីថា ឈ្មោះថា **កតញ្ញូ** ព្រោះដឹងគុណដែលអ្នកដទៃធ្វើហើយ ឈ្មោះថា **កតញ្ញូ** ព្រោះអាចឲ្យសូម្បីរាជសម្បត្តិដល់បុគ្គលដែលធ្វើសក្ការៈ ដោយការឲ្យភត្តជាដើម សូម្បីត្រឹមមួយថ្ងៃបាន ។

បទថា **កតវេទី** សេចក្តីថា ឈ្មោះថា **កតវេទី** ព្រោះរមែងបាន រមែងសោយ គឺរមែងទទួលចំពោះនូវឧបការៈដែលគេធ្វើហើយ ។ បទថា **តិត្ថេ យោជេតិ បាណិនេ** សេចក្តីថា រមែងប្រកប គឺរមែងប្រកបព្រម បានដល់រមែងឲ្យសត្វទាំងពួងតាំងនៅក្នុងផ្លូវនៃកុសលធម៌ គឺមគ្គដែលជាឧបាយឲ្យចូលដល់ព្រះនិព្វានបានដោយការសម្តែងធម៌ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។ អត្ថនៃគាថាដែលពណ៌នាដល់ផ្លូវយានរបស់ព្រះមានព្រះភាគ ខ្ញុំបានពោលហើយក្នុងថេរគាថានោះឯង ។

## អដ្ឋកថាកាឡុទាយិត្ថេរាបទាន ចប់

# អភយត្ថេរាបទានទី ៧

[ ១៣៧ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះតថាគតទ្រង់ញ៉ាំងពួកសត្វខ្លះឲ្យតាំងនៅក្នុងសរណគមន៍ ញ៉ាំងពួកសត្វខ្លះឲ្យតាំងនៅក្នុងសីល និងកម្មបថ ១០ ដ៏ឧត្តម ។ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ប្រទាននូវសាមញ្ញផលដ៏ឧត្តមដល់ពួកសត្វខ្លះ ម្យ៉ាងទៀត ទ្រង់ញ៉ាំងសត្វខ្លះឲ្យត្រាស់ដឹង នូវសមាបត្តិ ៨ និងវិជ្ជា ៣ ។ ព្រះនរុត្តម ទ្រង់ញ៉ាំងសត្វពួកខ្លះឲ្យប្រកបក្នុងអភិញ្ញា ៦ ព្រះលោកនាថនោះ ទ្រង់ប្រទាននូវបដិសម្ភិទា ៤ ដល់ពួកសត្វខ្លះ ។ ព្រះនរសារថីទ្រង់ឃើញនូវពួកសត្វ ដែលគួរទូន្មានឲ្យត្រាស់ដឹងបាន សូម្បីនៅក្នុងទីចម្ងាយមួយអសង្ខេយ្យយោជន៍ ក៏ស្តេចទៅទូន្មានដោយមួយរំពេចបាន ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ក្នុងក្រុងហង្សវតី បានដល់នូវត្រើយនៃវេទទាំងពួង ចេះចប់នូវវេយ្យាករណ៍ ។ ជាអ្នកឈ្លាសក្នុងនិរុត្តិផង ក្បៀវក្លាក្នុងគម្ពីរឈ្មោះនិឃណ្ឌុផង រៀននូវបទផង ចេះនូវគម្ពីរឈ្មោះកេដុភៈផង ឈ្លាសវៃដ៏វិចិត្រក្នុងឆន្ទសាស្រ្តផង ។ ខ្ញុំកាលត្រាច់ទៅកាន់ទីសម្រាកស្ងួន ក៏ចូលទៅក្នុងហង្សារាម បានឃើញព្រះសម្ពុទ្ធប្រសើរថ្លៃថ្លា មានមហាជនចោមរោម ។ ខ្ញុំជាអ្នកដឹងនូវបច្ចនិកធម៌ បានចូលទៅគាល់ព្រះមានព្រះភាគ ព្រះអង្គកំពុងសម្តែងធម៌ដែលប្រាសចាកធូលី ខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ជាពាក្យមិនមានមន្ទិល ។ ខ្ញុំមិនឃើញនូវការភ្លាំងភ្លាត់ ដែលល្មមបៀតបៀនបាន ឬនូវហេតុមិនជាទីប្រាថ្នា ឬក៏នូវអំពើមិនមានប្រយោជន៍របស់ព្រះមុនីនោះសោះ លំដាប់នោះ ខ្ញុំក៏បួស ( ក្នុង

សម្នាក់នៃព្រះអង្គ ) ។ អស់កាលមិនយូរប៉ុន្មាន ខ្ញុំជាបុគ្គលក្លៀវក្លាក្នុងទីទាំងពួង គេសន្មតថាជាអ្នកមានគណៈក្នុងពុទ្ធវចនៈដ៏ល្អិតល្អន់ ។ កាលនោះ ខ្ញុំចងក្រងនូវគាថា ៤ មានព្យញ្ជនៈដ៏ល្អ ហើយសរសើរព្រះពុទ្ធ ជាកំពូលនៃត្រៃលោក ហើយសម្ដែងធម៌រាល់ៗថ្ងៃ ។ ព្រះមហាវីរៈព្រះអង្គនៅក្នុងសង្សារ ដែលប្រកបដោយភ័យ ទ្រង់មានព្រះទ័យនឿយណាយ តែទ្រង់មិនទាន់និព្វាន ព្រោះមានសេចក្ដីអាណិត ហេតុនោះ ព្រះមុនីឈ្មោះថាមានសេចក្ដីករុណា ។ សត្វណាដែលជាបុថុជ្ជន តែមិនលុះក្នុងអំណាចកិលេស ជាអ្នកមានការដឹងខ្លួន ប្រកបដោយសតិ ហេតុនោះ សត្វទាំងនុ៎ះ ព្រះអង្គមិនបាច់គិត ។ ពួកកិលេសរបស់ខ្ញុំណាដែលមានកម្លាំងខ្សោយ តាំងនៅខាងក្នុង ដែលភ្លើងគឺមគ្គញ្ញាណដុតកម្ដៅហើយ មិនទាន់អស់រលីងនៅឡើយ ( កិលេសទាំងឡាយ ) របស់ខ្ញុំនោះ មិនកើតឡើងទៀតទេ ។ បុគ្គលណាជាគ្រូនៃលោកទាំងពួងម្យ៉ាងទៀត គ្រូនៃបុគ្គលណាក្នុងលោក ឬជាអាចារ្យក្នុងលោក លោកប្រព្រឹត្តទៅតាមបុគ្គលនោះដោយពិត ។ ខ្ញុំសរសើរព្រះសម្ពុទ្ធនិងធម្មទេសនា ( នៃព្រះអង្គ ) ដោយពាក្យទាំងឡាយ មានយ៉ាងនេះជាដើម ហើយធ្វើ ( សេចក្ដីគោរព ) ដរាបដល់អស់ជីវិត លុះខ្ញុំច្យុតអំពីអត្តភាពនោះ ក៏បានទៅកើតក្នុងឋានសួគ៌ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ កាលនោះ ខ្ញុំសោយរាជ្យជាស្ដេចធំក្នុងទេវលោកដ៏ជាទិព្វ ហើយខ្ញុំសោយជាស្ដេចមហាចក្កពត្តិ ជាច្រើនជាតិ ។ ខ្ញុំកើតតែក្នុងភពពីរ គឺទេវតានិងមនុស្ស

ខ្ញុំមិនស្គាល់គតិដទៃទេ នេះជាផលនៃការសរសើរ ។ ខ្ញុំកើតតែក្នុងត្រកូលពីរ គឺត្រកូលក្សត្រនិងត្រកូលព្រាហ្មណ៍ ខ្ញុំមិនស្គាល់ត្រកូលទាបឡើយ នេះជាផលនៃការសរសើរ ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំមានឈ្មោះថា អភ័យ ជាបុត្ររបស់ព្រះបាទពិម្ពិសារ ក្នុងគិរិព្វជបុរីដ៏ឧត្តម ។ ខ្ញុំលុះអំណាចនៃបាបមិត្ត ត្រូវពួកនិគ្រន្ថបញ្ចុះបញ្ចូលហើយ ដែលគ្រូឈ្មោះនាដបុត្តប្រើទៅ ខ្ញុំក៏ចូលទៅគាល់ព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំសួរនូវប្រស្នាដ៏ល្អិត ស្តាប់នូវព្យាករណ៍ដ៏ឧត្តម ហើយក៏បព្វជ្ជា អស់កាលមិនយូរប៉ុន្មាន ក៏បានព្រះអរហត្ត ។ ខ្ញុំសរសើរព្រះជិនស្រីដ៏ប្រសើរ ត្រូវគេសរសើរសព្វកាល ជាបុគ្គលមានរាងកាយនិងមាត់មានក្លិនក្រអូបល្អ ឆ្អែតស្កប់ស្កល់ដោយសេចក្តីសុខ ។ ខ្ញុំជាបុគ្គល មានប្រាជ្ញាមុត មានប្រាជ្ញាដ៏រីករាយនិងរហ័ស មានប្រាជ្ញាច្រើន មានបដិភាណដ៏វិចិត្រ ព្រោះអានិសង្សនៃកុសលកម្មនោះ ។

> ខ្ញុំមានចិត្តជ្រះថ្លា បានសរសើរព្រះសយម្ភូព្រះនាមបទុមុត្តរៈ
> ឥតមានបុគ្គលស្មើ ខ្ញុំមិនទៅកាន់អបាយភូមិអស់មួយសែនកប្ប
> ដោយផលនៃកម្មនោះ ។

កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ

ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអភយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ អភយត្ថេរាបទាន ។

# អដ្ឋកថា

# អភយត្ថេរាបទាន

[ ១៣៧ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៧ ដូចតទៅនេះថា អបទានរបស់អភយត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរោ ណាម ជិនោ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះជិនស្រី ដ៏ប្រសើរអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងហង្សវតីនគរ ។ បានចម្រើនវ័យហើយ ជាអ្នករៀនចប់វេទង្គសាស្ត្រ ជាអ្នកឈ្លាសក្នុងលទ្ធិសម័យរបស់ខ្លួន និងរបស់អ្នកដទៃ ថ្ងៃមួយបានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា ពោលសរសើរព្រះមានព្រះភាគ ដោយគាថាទាំងឡាយ តាំងនៅក្នុងអត្តភាពនោះដរាបអស់អាយុ ធ្វើបុណ្យទាំងឡាយទុក ចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងទេវលោក អន្ទោលទៅមកតែក្នុងសុគតិភពប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារ ក្នុងនគររាជគ្រឹះ ជនទាំងឡាយថ្វាយព្រះនាមថា អភយកុមារ ។ ព្រះរាជកុមារនោះ លុះចម្រើនវ័យហើយ ជាអ្នកស្និទ្ធស្នាលជាមួយពួកនិគ្រន្ថ ថ្ងៃមួយ ត្រូវនិគណ្ឋនាដបុត្តបញ្ជូនទៅដើម្បីលើកវាទៈ ព្រះសាស្ដា បានទូលសួរបញ្ហាដ៏ល្អិតសុខុម ស្ដាប់ព្យាករដ៏ល្អិតហើយ មានសេចក្ដីជ្រះថ្លា បួសក្នុងសម្នាក់ព្រះសាស្ដា បញ្ជូនញាណទៅតាមលំដាប់កម្មដ្ឋានហើយ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។

*កាលបានសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **បទុមុត្តរោ ឆាម ជិនោ** *ដូច្នេះជាដើម ។ ពាក្យទាំងអស់មានអត្ថដឹងបានដោយងាយនោះឯង ។*

## *អដ្ឋកថាអកយត្ថោរាបទាន ចប់*

# លោមសតិយត្ថេរាបទានទី ៨

[ ១៣៨ ] ក្នុងកប្បនេះ ព្រះពុទ្ធទ្រង់ព្រះនាមកស្សប មានផៅពង្ស ដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ។ កាលនោះ ខ្ញុំនិងចន្ទនបុរសបានបួសក្នុងសាសនា បានបំពេញកុសលកម្ម ក្នុង សាសនា ក្នុងទីបំផុតនៃជីវិត យើងទាំងពីរនាក់ ច្យុតអំពីអត្តភាពនោះហើយ បានទៅកើតក្នុងឋានតុសិត បរិបូណ៌ដោយការរាំ ច្រៀង និងប្រគំជាទិព្វក្នុង ទីនោះ ។ គ្របសង្កត់ទេវតាដ៏សេសទាំងឡាយ ដោយអង្គទាំង ១០ មានរូប ជាដើម នៅទទួលសេចក្ដីសុខដរាបដល់អស់ជីវិត ។ លុះច្យុតអំពីនោះមក ចន្ទនបុរសទៅកើតក្នុងឋានត្រៃត្រិង្ស ចំណែកខ្ញុំបានកើតក្នុងក្រុងកបិលពស្តុ ជាកូននៃសក្យៈ ។ ព្រះលោកនាយកកាលឧទាយិត្ថេរអារាធនាហើយ ទ្រង់ អនុគ្រោះដល់ពួកសក្យៈ បានចូលទៅកាន់ក្រុងកបិលពស្តុ ។ កាលនោះ ពួក សក្យៈមានសេចក្ដីមើលងាយ មិនស្គាល់គុណរបស់ព្រះពុទ្ធ ជាអ្នករឹងត្អឹង ប្រកាន់ជាតិ មិនអើពើ មិនថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះជិនស្រីទ្រង់ជ្រាបនូវការ ត្រិះរិះរបស់សក្យៈទាំងនោះហើយ ក៏ចង្ក្រមព្ទដ៏អាកាស ឋិតនៅដូចជាមេឃ ភ្លីប្រាលដូចជាអណ្ដាតភ្លើង ។ ព្រះអង្គបង្ហាញនូវរូបឥតមានអ្វីប្រៀប ហើយ បាត់ទៅវិញ ធ្វើព្រះអង្គតែមួយអង្គ ឲ្យជាច្រើនអង្គ ធ្វើច្រើនអង្គឲ្យជាមួយ-អង្គវិញ ។ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់សម្ដែងនូវងងឹតផង ពន្លឺផង ដោយច្រើន ហើយធ្វើនូវបាដិហារ្យទូន្មានពួកញាតិ ។ ខណៈនោះ ទ្វីបទាំង ៤ មានភ្លៀង ធំបង្អុរចុះ កាលនោះ ព្រះពុទ្ធទ្រង់សម្ដែងវេស្សន្តរជាតក ។ ពួកក្សត្រទាំង អស់នោះ ក៏កម្ចាត់នូវសេចក្ដីស្រវឹងដែលកើតអំពីជាតិ យកព្រះពុទ្ធជាទីពឹង

ឯព្រះបាទសុទ្ធោទនៈទ្រង់ពោលថា

បពិត្រព្រះអង្គមានបញ្ញាដូចជាផែនដី មានចក្ខុជុំវិញ ខ្ញុំថ្វាយបង្គំព្រះបាទា របស់ព្រះអង្គជាគម្រប់ ៣ ដង នឹងនេះហើយ គឺកាលព្រះអង្គកើត ផែនដីញាប់ញ័រ ( ខ្ញុំថ្វាយបង្គំម្តង ) កាលម្លប់ព្រឹងមិនលះបង់ព្រះអង្គ ( ខ្ញុំថ្វាយបង្គំម្តង ឥឡូវនេះខ្ញុំថ្វាយបង្គំម្តងទៀត ) ។

កាលនោះ ខ្ញុំឃើញនូវអានុភាពរបស់ព្រះពុទ្ធនោះ ក៏មានចិត្តរន្ធត់ បានបួលបួស ជាអ្នកបូជាមាតានៅក្នុងសម្នាក់របស់ព្រះអង្គនោះ ។ កាលនោះ ចន្ទទេវបុត្តចូលទៅរកខ្ញុំសួរនូវន័យដ៏សង្ខេបនិងពិស្តារនៃភទ្ទេករត្តសូត្រ ។ ខ្ញុំត្រូវចន្ទទេវបុត្តនោះដាស់តឿនហើយ ក៏ចូលទៅគាល់ព្រះនរនាយក ស្តាប់នូវភទ្ទេករត្តសូត្រ មានចិត្តតក់ស្លុត ក៏ពេញចិត្តនឹងនៅក្នុងព្រៃ ។ កាលនោះ ខ្ញុំលាមាតាជាបុគ្គលម្នាក់ឯងនៅក្នុងព្រៃ មាតាខ្ញុំឃាត់ថា អ្នកជាបុគ្គលធ្លាប់ចម្រើនដោយសេចក្តីសុខ កាលនោះ ខ្ញុំបាននិយាយនឹងមាតាបិតាទាំងនោះ ។ ខ្ញុំបានពុះពារនូវស្បូវស្រែងថ្នាកាំ ស្បូវណ្តាស់ ស្មៅយាប្លង ស្មៅជំណេក ទន្សាយទាំងអស់ដោយទ្រូង ហើយចម្រើននូវវិវេក ។ កាលនោះ ខ្ញុំចូលទៅក្នុងព្រៃ រឭកនូវឱវាទ គឺភទ្ទេករត្តសូត្រ ដែលជាពាក្យប្រៀនប្រដៅព្រះជិនស្រី ហើយបានដល់អរហត្ត ។ បុគ្គលមិនត្រូវអាឡោះអាល័យនូវបញ្ចក្ខន្ធដែលកន្លងទៅហើយទេ មិនត្រូវប្រាថ្នាបញ្ចក្ខន្ធដែលជាអនាគតទេ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះកន្លងផុតទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះក៏មិនទាន់មកដល់ ។ បុគ្គលណាពិចារណាឃើញច្បាស់នូវធម៌

ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វានដែលមិនញាប់ញ័រ មិនបានកម្រើកនោះ គប្បីចម្រើនឲ្យរឿយៗ ។ ការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់ នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាយើងតទល់នឹងមច្ចុដែលមានសេនាច្រើននោះមិនបានសោះឡើយ ។ អ្នកប្រាជ្ញស្ងប់រម្ងាប់ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស មិនខ្ជិលច្រអូសអស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលោមសកិយត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ លោមសកិយត្ថេរាបទាន ។**

# អដ្ឋកថា

# លោមសកិយត្ថេរាបទាន

[ ១៣៨ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៨ ដូចតទៅនេះថា អបទានរបស់ព្រះលោមសកង្គិយត្ថេរ មានពាក្យផ្ដើមថា **ឥមម្ហិ ភទ្ទកេ កប្បេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតក្នុងត្រកូលព្រាហ្មណ៍ ជាបុគ្គលមានសទ្ធាជ្រះថ្លា ។ បុគ្គលម្នាក់ទៀតឈ្មោះថាចន្ទនៈ ជាសម្លាញ់នៃកុលបុត្តនោះ កុលបុត្តទាំង ២ នាក់ ស្ដាប់ព្រះធម្មទេសនាក្នុងសម្នាក់ព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា ទើបចេញបួស បានរក្សាសីលដរាបដល់អស់ជីវិត បានសោយទិព្វសុខរហូតមួយពុទ្ធន្តរ ។ ជនទាំង ២ នោះ ក្នុងពុទ្ធុប្បាទកាលនេះ ជនម្នាក់បានមកកើតក្នុងត្រកូលសក្យៈ ម្នាក់ទៀតដែលមានឈ្មោះថាចន្ទនៈ បានកើតជាទេវបុត្តក្នុងស្ថានតាវត្តិង្ស ។ លំដាប់នោះ ព្រះមានព្រះភាគដែលព្រះកាឡុទាយីធ្វើសក្យត្រកូលឲ្យជ្រះថ្លា ទូលអារាធនាហើយ ទ្រង់ធ្វើឥទ្ធិប្បាដិហារ្យឲ្យភ្លៀងបោក្ខរព័ស្សធ្លាក់ចុះ ក្នុងការសម្ដែងធម៌ គឺវេស្សន្តរជាតក ដើម្បីសង្កត់មានះរបស់ពួកសក្យៈ កុលបុត្តនោះឃើញហើយ មានចិត្តជ្រះថ្លាបួសហើយ បានស្ដាប់ព្រះធម្មទេសនាភទ្ទេករត្តសូត្រ ដែលត្រាស់ទុកក្នុងមជ្ឈិមនិកាយ នៅក្នុងព្រៃ រឭកដល់ទេសនា គឺឱវាទក្នុងភទ្ទេករត្តសូត្រ

បញ្ជូនញាណទៅតាមគន្លងនៃទេសនានោះ ដាក់ចិត្តក្នុងកម្មដ្ឋាន ហើយបាន សម្រេចអរហត្ត ។

កាលបានសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា **ឥមម្ហិ ភទ្ទកេ កប្បេ** ដូច្នេះជាដើម ។ បទថា **កប្បេ** ក្នុងអបទាននេះ មាន ៤ យ៉ាង គឺសារកប្ប ១ វរកប្ប ១ មណ្ឌកប្ប ១ ភទ្ទកប្ប ១ ។ បណ្ដាកប្បទាំង ៤ យ៉ាងនោះ កប្បដែលមានព្រះពុទ្ធ ១ អង្គកើតឡើង ឈ្មោះថា សារកប្ប កប្បដែលមានព្រះពុទ្ធ ២ ឬ ៣ អង្គ កើតឡើង ឈ្មោះថា វរកប្ប កប្បដែលមានព្រះពុទ្ធ ៤ អង្គ កើតឡើងឈ្មោះថា មណ្ឌ-កប្ប កប្បដែលមានព្រះពុទ្ធ ៥ អង្គ ទ្រង់កើតឡើង ឈ្មោះថា ភទ្ទកប្ប តែក្នុងទីដទៃ លោកពោលកប្បទុក ៥ យ៉ាងគឺ

> កប្បមាន ៥ យ៉ាង គឺសារកប្ប មណ្ឌកប្ប សារមណ្ឌកប្ប វរកប្ប និងភទ្ទកប្ប ។ ព្រះលោកនាយក ទ្រង់រមែងកើតឡើង បណ្ដាកប្បទាំង ៥ នេះតាមលំដាប់គឺ ព្រះពុទ្ធ ១ អង្គ ទ្រង់កើតឡើងក្នុងសារកប្ប ព្រះពុទ្ធ ២ អង្គ ទ្រង់កើតឡើងក្នុងមណ្ឌកប្ប ព្រះពុទ្ធ ៣ អង្គ ទ្រង់កើតឡើងក្នុងសារមណ្ឌកប្ប ព្រះពុទ្ធ ៤ អង្គ ទ្រង់កើតឡើងក្នុងវរកប្ប ព្រះពុទ្ធ ៥ អង្គ ទ្រង់កើតឡើងក្នុងភទ្ទកប្ប ។

បណ្ដាកប្បទាំងនោះ កប្បនេះបានឈ្មោះថា ភទ្ទកប្ប ព្រោះប្រកបដោយ

ព្រពុទ្ធ ៥ អង្គ គឺព្រះកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ព្រះគោតម ១ ព្រះមេត្តេយ្យ ១ ព្រោះហេតុនោះ ទើបមានពាក្យភ្ជាប់សេចក្តីថា ព្រះកស្សបសម្ពុទ្ធជាលោកនាយកទ្រង់កើតឡើងហើយក្នុងកទ្ទកប្បនេះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាលោមសតិយត្ថេរាបទាន ចប់

# វនវច្ឆត្ថេរាបទានទី ៩

[ ១៣៩ ] ក្នុងភទ្ទកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្ស ប្រសើរ មានយសធំ ទ្រង់ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ហើយ ។ កាលនោះ ខ្ញុំបួសក្នុងសាសនានៃព្រះពុទ្ធនោះ ប្រព្រឹត្តព្រហ្មចារ្យ ដរាបអស់ជីវិត ហើយច្យុតចាកអត្តភាពនោះ ។ ដោយកុសលកម្មដែលខ្ញុំធ្វើ ល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់ មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ មកកើតជាព្រាបនៅក្នុងព្រៃ មានភិក្ខុមួយរូបបរិបូណ៌ដោយគុណ ត្រេកអរក្នុង ឈាននៅក្នុងទីនោះសព្វកាល ។ ( ភិក្ខុនោះ ) មានមេត្តាចិត្ត មានសេចក្តី ករុណា មានមុខរីករាយសព្វកាល ប្រកបដោយឧបេក្ខា មានព្យាយាមធំ ឈ្លាសក្នុងអប្បមញ្ញាទាំងឡាយ ។ ខ្ញុំមានសេចក្តីត្រិះរិះ ប្រាសចាកនីវរណៈ មានអធ្យាស្រ័យជាប្រយោជន៍ដល់សព្វសត្វ មិនយូរប៉ុន្មាន ក៏ស្និទ្ធស្នាលចំពោះ សាវកនៃព្រះសុគតនោះ ។ កាលនោះ ខ្ញុំចូលទៅទៀបបាទានៃភិក្ខុនោះ ដែល គង់នៅក្នុងអាស្រម ចូនកាលលោកឲ្យអាមិសៈ ចូនកាលលោកសម្តែងធម៌ ឲ្យខ្ញុំស្តាប់ ។ កាលនោះ ខ្ញុំចូលទៅរកសាវកជាបុត្តនៃព្រះជិនស្រី ដោយ សេចក្តីស្រឡាញ់យ៉ាងខ្លាំង លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើត ក្នុងឋានសួគ៌ ដូចជាការនៅគ្រប់គ្រងផ្ទះរបស់ខ្លួន ។ ខ្ញុំច្យុតចាកឋានសួគ៌មក កើតក្នុងមនុស្សលោកដោយបុញ្ញកម្ម ហើយលះបង់ផ្ទះ ចេញទៅបួសច្រើន លើក ។ គឺខ្ញុំបួសជាសមណៈ ជាតាបស ជាព្រាហ្មណ៍ ជាបរិព្វាជក ដោយ ប្រការដូច្នោះ ព្រោះខ្ញុំនៅក្នុងព្រៃអស់រយនៃឆ្នាំដ៏ច្រើន ។ ឥឡូវនេះ មកដល់

ក្នុងបច្ឆិមភព ព្រាហ្មណីណាជាវច្ឆគោត្ត នៅក្នុងក្រុងកបិលពស្តុជាទីរីករាយ ខ្ញុំចុះចាប់បដិសន្ធិក្នុងផ្ទៃករិយារបស់ព្រាហ្មណ៍នោះ ។ កាលខ្ញុំនឹងប្រសូតចាកផ្ទៃមកខាងក្រៅ មាតារបស់ខ្ញុំមានសេចក្តីប្រាថ្នា គឺមានប្រាថ្នាដើម្បីនៅក្នុងព្រៃជិតទីដែលខ្ញុំនឹងកើត ។ លំដាប់នោះ មាតាបានបង្កើតខ្ញុំត្រង់ចន្លោះព្រៃគួរជាទីរីករាយ ជនទាំងឡាយបានទទួលខ្ញុំកាលចេញមកអំពីគភ៌ដោយសំពត់កាសាយៈ ។ លំដាប់នោះសិទ្ធត្ថកុមារទ្រង់កើតហើយ ជាទង់ជ័យនៃសក្យត្រកូល ខ្ញុំជាមិត្តរបស់សិទ្ធត្ថកុមារនោះ ជាទីស្រឡាញ់ស្និទ្ធស្នាលរាប់អានគ្នាបំផុត ។ កាលព្រះសិទ្ធត្ថៈជាខ្ទឹមរបស់សត្វ ទ្រង់ចេញបួស ខ្ញុំក៏លះបង់យសដ៏ធំ ហើយបួស ចូលទៅក្នុងព្រៃហិមពាន្តដែរ ។ ខ្ញុំឃើញព្រះកស្សបៈ ដែលមានព្រៃជាលំនៅ គួរសរសើរ មានវាទៈកម្ចាត់កិលេស ឮនូវការកើតឡើងនៃព្រះជិនស្រី ក៏ចូលទៅរកព្រះអង្គ ជាសារថីនៃនរៈ ។ ព្រះអង្គសម្តែងនូវធម៌ដល់ខ្ញុំប្រកាសនូវអត្ថទាំងពួង លំដាប់នោះ ខ្ញុំក៏បួសចូលទៅកាន់ព្រៃវិញទៀត ។ ខ្ញុំជាបុគ្គលមិនប្រមាទ នៅក្នុងទីនោះ ក៏បានឃើញអភិញ្ញា ៦ ឱ ! អញត្រូវមិត្តល្អអនុគ្រោះហើយ ក៏មានលាភបានដោយងាយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវនវច្ឆត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ វនវច្ឆត្ថេរាបទាន ។**

## អដ្ឋកថា

## វនវច្ឆត្ថេរាបទាន

[ ១៣៩ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ៩ ដូចតទៅនេះថា អបទានរបស់ព្រះវនវច្ឆត្ថេរ មានពាក្យផ្ដើមថា **ឥមម្ហិ ភទ្ទកេ កប្បេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ បានសន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមថាកស្សបៈ កើតក្នុងផ្ទះមានត្រកូលដល់នូវភាពជាអ្នកដឹងក្ដីហើយ បានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា កើតនូវសទ្ធា ទើបចេញបួស ប្រព្រឹត្តព្រហ្មចរិយៈយ៉ាងបរិសុទ្ធ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ចុតិចាកទេវលោកនោះ កើតក្នុងកំណើតព្រាបនៅក្បែរពួកភិក្ខុក្នុងព្រៃ ។ ព្រាបនោះមានមេត្តាចិត្តក្នុងពួកភិក្ខុទាំងនោះ បានស្ដាប់ធម៌ ចុតិចាកអត្តភាពនោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងនគរកបិលពស្ដុ ។ ក្នុង

*កាលដែលកុលបុត្តនេះនៅក្នុងផ្ទៃមាតានោះឯង មាតាបានចាញ់គភ៌ចង់ទៅនៅក្នុងព្រៃ និងចង់ប្រសូតក្នុងព្រៃ ។ តមក កាលមាតានៅក្នុងព្រៃ សមតាមសេចក្តីត្រូវការ បានប្រសូតបុត្តមក ។ ពួកញាតិបានយកកំណាត់សំពត់កាសាយៈទទួលទារកដែលប្រសូតចាកផ្ទៃ ។ ពេលនោះជាពេលដែលព្រះពោធិសត្វបានកើតឡើងហើយ ។ ព្រះរាជាទ្រង់មានបញ្ជាឲ្យមនុស្សនាំក្មេងនោះមកហើយចិញ្ចឹមរួមជាមួយព្រះពោធិសត្វ ។ តមក ព្រះពោធិសត្វយាងចេញមហាភិនេស្រ្កមណ៍ បួសហើយទ្រង់បំពេញទុក្ករកិរិយាអស់ ៦ ឆ្នាំ បានត្រាស់ជាព្រះពុទ្ធហើយ កុលបុត្តនោះទៅជួបព្រះមហាកស្សបៈ ជ្រះថ្លាក្នុងឱវាទរបស់ព្រះថេរៈ បានដឹងអំពីសម្នាក់នៃលោកថា ព្រះពុទ្ធកើតឡើងហើយ ទើបទៅគាល់ព្រះសាស្តា ស្តាប់ធម៌ហើយបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្តមួយអន្លើដោយអភិញ្ញា ៦ ។*

*លោកសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ទើបពោលពាក្យថា* **ឥមម្ហិ ភទ្ទកេ កប្បេ** *ដូច្នេះជាដើម ។*

*បណ្តាបទទាំងនោះ បទថា* **ពន្ធុ** *ក្នុងបទថា* **ព្រហ្មពន្ធុ មហាយសោ** *នេះបានដល់ ញាតិរបស់ព្រាហ្មណ៍ គប្បីជ្រាបថា ក្នុងកាលគួរពោលថា* **ព្រាហ្មណពន្ធុ** *តែលោកពោលថា* **ព្រហ្មពន្ធុ** *ដើម្បីងាយស្រួលក្នុងការចងគាថា ។ ឈ្មោះថា* **មហាយសោ** *ព្រោះមានយសគ្របដណ្តប់ទៅក្នុងលោកទាំង ៣ ។ ពាក្យដ៏សេស មានអត្ថដឹងបានងាយហើយ ។*

***អដ្ឋកថាវនវច្ឆត្ថេរាបទាន ចប់***

# ចូឡសុគន្ធត្ថេរាបទានទី ១០

[ ១៤០ ] ក្នុងកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ទ្រង់ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយ ។ ព្រះអង្គប្រកបដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានពន្លឺមួយព្យាមជុំវិញ ព្រោងព្រាតដោយបណ្ដាញគឺរស្មី ។ ព្រះអង្គញ៉ាំងលោកឲ្យត្រេកអរដូចជាព្រះចន្ទ ទ្រង់ធ្វើនូវពន្លឺដូចជាព្រះអាទិត្យ ទ្រង់រំលត់ទុក្ខដូចជាភ្លៀង ទ្រង់ជាអណ្ដូងនៃគុណដូចជាសាគរ ។ ព្រះអង្គមានសីលដូចជាធរណី មានសមាធិដូចជាភ្នំហិមពាន្ត មានបញ្ញាដូចជាអាកាស មិនមានអ្វីទើសដូចខ្យល់ ។ កាលនោះ ខ្ញុំកើតក្នុងមហាត្រកូល មានទ្រព្យនិងស្រូវច្រើន សន្សំរតនៈផ្សេងៗក្នុងក្រុងពារាណសី ។ ខ្ញុំចូលទៅរកព្រះលោកនាយកដែលគង់នៅដោយបរិវារច្រើន បានស្ដាប់អមតធម៌ដ៏គួរជល់ចិត្ត ។ ព្រះអង្គទ្រទ្រង់លក្ខណៈ ៣២ ប្រការ ដូចជាព្រះចន្ទមាននក្ខត្តឫក្សដ៏ល្អ ទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ដូចជាដើមសាលរាជ មានផ្ការីក ។ ទ្រង់មានបណ្ដាញ គឺរស្មីបិទបាំងដូចជាមាសមិនប្រែពណ៌ ដែលជាងមាសដុតហើយ មានពន្លឺមួយព្យាមផ្សាយជុំវិញ ដូចជាព្រះអាទិត្យមានរស្មីដ៏ច្រើន ។ ព្រះជិនស្រីប្រសើរ មានព្រះកត្រដូចមាស ឬដូចជាភ្នំ ជាទីរីករាយ មានព្រះហឫទ័យពេញដោយករុណា ( ប្រកប ) ដោយគុណដូចជាសាគរ ។ មានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងលោក ដូចជាភ្នំដ៏ឧត្តមឈ្មោះសិនេរុ ទ្រង់ជាអ្នកប្រាជ្ញផ្សាយចេញទៅដោយយស ជាមុនី ដូចជាអាកាស ។ ព្រះលោកនាយក មានព្រះហឫទ័យមិនជាប់ចំពាក់ក្នុងទីទាំងពួង ដូចជាខ្យល់ ជាមុនីទី ៧ ជាទីពឹងរបស់ពួកសត្វទាំងអស់

ដូចជាផែនដី ។ ព្រះអង្គមិនប្រឡាក់ដោយលោក ដូចជាផ្កាឈូកមិនទទឹកដោយទឹក ទ្រង់រុងរឿងដូចជាគំនរភ្លើងឆេះគុម្ពកុរាទៈ ។ ទ្រង់ញុំាងពិស គឺកិលេសឲ្យវិនាសក្នុងទីទាំងពួង ដូចជាឱសថ ទ្រង់ស្អិតស្អាងគ្រឿងក្រអូប គឺគុណ ដូចជាភ្នំគន្ធមាទនៈ ។ ព្រះអង្គជាអ្នកប្រាជ្ញ ជាអណ្តូងនៃគុណទាំងឡាយ ដូចជាសាគរ ជាទីកើតនៃរតនៈទាំងឡាយ ព្រះអង្គជាអាជានេយ្យនៃនរជន ទ្រង់នាំចេញនូវមន្ទិលគឺកិលេស ដូចជាស្ទឹងសិន្ធុ ។ ព្រះអង្គញុំាញីនូវមារនិងសេនានៃមារ ដូចជាមហាយោធាធំឈ្នះ ( នូវបច្ចាមិត្ត ) ជាឥស្សរៈដោយរតនៈ គឺពោជ្ឈង្គ ដូចជាស្តេចចក្កពត្តិ ។ ព្រះអង្គជាពេទ្យរក្សានូវព្យាធិ គឺទោសៈ ដូចជាគ្រូពេទ្យដ៏ធំ ព្រះអង្គវះនូវពកគឺទិដ្ឋិ ដូចជាពេទ្យវះដ៏ប្រសើរ ។ កាលនោះឯង ព្រះជិនស្រី ព្រះអង្គជាពន្លឺរបស់លោក ទេវតានិងមនុស្សធ្វើសក្ការៈហើយ ជាព្រះអាទិត្យរបស់នរៈ ទ្រង់សម្តែងធម៌ក្នុងពួកបរិស័ទ ។ ព្រះអង្គទ្រង់ទូន្មានប្រៀនប្រដៅថា បុគ្គលមានភោគៈច្រើនព្រោះឲ្យទាន ទៅកើតសុគតិព្រោះសីល បានព្រះនិព្វានព្រោះភាវនា ។ ពួកបរិស័ទទាំងអស់ ស្តាប់នូវទេសនានោះ ដែលមានអានិសង្សធំ មានលម្អខាងដើម កណ្តាល និងខាងចុង ដូចជាអមតធម៌មានរសដ៏ធំ ។ លុះខ្ញុំស្តាប់នូវធម៌ ដែលមានរសផ្អែមល្ហែមហើយ ក៏ជ្រះថ្លាក្នុងសាសនាព្រះជិនស្រី ដល់នូវព្រះសុគតជាទីពឹង នមស្ការដរាបដល់អស់ជីវិត ។ កាលនោះ ខ្ញុំលាបនូវគន្ធកុដិរបស់ព្រះមុនី ដោយក្លិនក្រអូបមានជាតិ ៤ អស់ ៨ ថ្ងៃ ក្នុងមួយខែ ហើយតម្កល់ទុកនូវគ្រឿងក្រអូបនោះ ដើម្បីសរីរៈដែលមិនមានក្លិនក្រអូប ។

កាលនោះ ព្រះជិនស្រីសម្ពុទ្ធ ទ្រង់ទំនាយនូវការបានខ្លួនមានក្លិនក្រអូប ថា បុគ្គលណា បានលាបនូវគន្ធកុដិដោយក្លិនក្រអូបអស់វារៈម្តង ព្រោះតែវិបាកនៃកុសលកម្មនោះ បុគ្គលនោះលុះកើតក្នុងទីណាក៏ដោយ នឹងមានរាងកាយមានក្លិនក្រអូបក្នុងទីទាំងពួង ជាអ្នកប្រកបដោយក្លិនគឺសីលគុណ មិនមានអាសវៈ នឹងបរិនិព្វាន ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ឆិមភព ខ្ញុំបានមកកើតក្នុងត្រកូលព្រាហ្មណ៍ កាលខ្ញុំនៅក្នុងផ្ទៃនៃមាតា មាតា ( របស់ខ្ញុំ ) ជាស្រីមានកាយក្លិនក្រអូប ។ កាលណាខ្ញុំចេញចាកផ្ទៃនៃមាតា កាលនោះ ក្រុងសាវត្ថីផ្សាយចេញដោយគ្រឿងក្រអូបទាំងពួង ហាក់ដូចជាគេអប់ ។ ភ្លៀងជាវិការៈនៃផ្កាក្រអូបមានក្លិនដូចជាក្លិនទិព្វ ជាទីរីករាយនៃចិត្តផង ធូបទាំង-ឡាយមានថ្លៃដ៏ច្រើនផង ក៏ផ្សាយចេញក្នុងខណៈនោះ ។ ខ្ញុំកើតក្នុងផ្ទះណា ទេវតាទាំងឡាយអប់នូវផ្ទះនោះដោយគ្រឿងក្រអូប ទាំងពួងផង ដោយធូបនិងផ្កាទាំងឡាយផង ដោយក្លិនទិព្វផង ។ កាលណាខ្ញុំនៅក្មេង កំពុងចម្រើនឋិតនៅក្នុងបឋមវ័យ កាលនោះព្រះនរសារថីទ្រង់ទូន្មាននូវជនដ៏សេស ព្រមទាំងបរិស័ទ ។ ព្រះអង្គប្រកបដោយបរិស័ទទាំងឡាយទាំងពួងនោះ ស្តេចមកកាន់ក្រុងសាវត្ថី កាលនោះ ខ្ញុំបានឃើញនូវអានុភាពនៃព្រះពុទ្ធនោះហើយ ក៏បួស ។ ខ្ញុំអប់រំធម៌ដ៏ប្រសើរទាំងបួន គឺសីល សមាធិ បញ្ញា និងវិមុត្តិ ហើយបានដល់នូវការអស់ទៅនៃអាសវៈ ។ ខ្ញុំបួសក្នុងកាលណាផង ខ្ញុំបានជាព្រះ

អរហន្តក្នុងកាលណាផង ខ្ញុំបរិនិព្វានក្នុងកាលណាផង ភ្លៀងមានក្លិនក្រអូបក៏បង្អុរចុះក្នុងកាលនោះៗ ។

ក្លិនរបស់សរីរៈខ្ញុំ ជាក្លិនដ៏ប្រសើរ គ្របសង្កត់នូវក្លិននៃខ្លឹមចន្ទន៍ ផ្កាចម្ប៉ានិងផ្កាឧប្បលមានថ្លៃច្រើន ម្យ៉ាងទៀត ខ្ញុំទៅក្នុងទីណា ក៏ដោយ តែងផ្សាយក្លិនក្រអូប គ្របសង្កត់នូវក្លិនដទៃដោយសព្វគ្រប់ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលចេញហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចូឡសុគន្ធត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ចូឡសុគន្ធត្ថេរាបទាន ។**

## ឧទ្ទាន

កទ្ទិយត្ថេរាបទាន ១ រេវតត្ថេរាបទាន ១ សីវលិត្ថេរាបទាន អ្នកមានលាភច្រើន ១ វង្គីសត្ថេរាបទាន ១ នន្ទកត្ថេរាបទាន ១ កាឡុទាយិត្ថេរាបទាន ១ អភយត្ថេរាបទាន ១ ។ លោមសតិយត្ថេរាបទាន ១ វនវច្ឆត្ថេរាបទាន ១ ចូឡសុគន្ធត្ថេរាបទាន ១ ជាគម្រប់ ១០ ក្នុងផ្ទៃនៃវគ្គនោះ មានគាថា ៣១៦ ។

## ចប់ កទ្ទិយវគ្គទី ៥៥ ។

## ម្យ៉ាងទៀត ឧទ្ទាននៃវគ្គ

កណិការវគ្គ ១ ផលទាយកវគ្គ ១ តិណទាយកវគ្គ ១ កច្ចាយនវគ្គ ១ កទ្ទិយវគ្គ ១ រាប់ជាគាថាមានចំនួន ២០ ។ អបទានទាំងឡាយលោកសម្តែងថា មានគាថា ៩០០ ផង ៨៤ ផង ៥៥៦ ផង ។ គាថាទាំងឡាយនេះ ព្រមទាំងឧទ្ទាន មានចំនួន ៦.២១៨ គាថា ។

## ចប់ ពុទ្ធាបទាន បច្ចេកពុទ្ធាបទាន និងថេរាបទាន ។

# អដ្ឋកថា

## ចូឡសុគន្ធត្ថេរាបទាន

[ ១៤០ ] គប្បីជ្រាបពាក្យអធិប្បាយក្នុងអបទានទី ១០ ដូចតទៅនេះថា អបទានរបស់ចូឡសុគន្ធត្ថេរ មានពាក្យផ្ដើមថា **ឥមម្ហិ ភទ្ទកេ កប្បេ** ដូច្នេះ ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមថាកស្សបៈកើតក្នុងត្រកូលដែលសម្បូរដោយសម្បត្តិក្នុងក្រុងពារាណសី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា នមស្ការ ថ្វាយមហាទានសព្វកាល នាំយកគន្ធជាតិ ៤ យ៉ាង ប្រោះព្រំព្រះគន្ធកុដិរបស់ព្រះមានព្រះភាគ មួយខែ ៧ ដង ។ កុលបុត្តនោះ បានធ្វើសេចក្ដីប្រាថ្នាទុកថា សូមឲ្យក្លិនក្រអូបក្រៃលែងកើតដល់សរីរៈរបស់ខ្ញុំ ក្នុងទីដែលកើតហើយចុះ ព្រះមានព្រះភាគ បានត្រាស់ព្យាករហើយ ដល់កុលបុត្តនោះ ។

កុលបុត្តនោះតាំងនៅដរាបដល់អាយុ បំពេញបុណ្យដ៏ច្រើន ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ធ្វើលោកគឺកាមាវចរ ( សួគ៌ ៦ ជាន់ ) ឲ្យក្រអូបដោយក្លិនកាយ ទើបគេស្គាល់ក្នុងឈ្មោះថា សុគន្ធទេវបុត្ត ។ ទេវបុត្តនោះ បានសោយសម្បត្តិក្នុងទេវលោកហើយ ចុតិចាកអត្តភាពនោះ ក្នុងពុទ្ធុប្បាទកាលនេះ បានកើតក្នុងត្រកូលមានភោគៈច្រើន ។ ដោយក្លិននៃសរីរៈរបស់មាតា ផ្ទះទាំងមូល និងព្រះនគរទាំងមូល មានក្លិនក្រអូបតែមួយ ។ ក្នុង

ខណៈដែលកុលបុត្តនោះកើតហើយ នគរសាវត្ថីទាំងមូល ដូចគ្នានឹងស្មុគ-គ្រឿងក្រអូប ។ ដោយហេតុនោះ ទើបមាតាបិតា ដាក់ឈ្មោះឲ្យកុលបុត្តនោះថាសុគន្ធៈ ។ កុលបុត្តនោះដល់នូវការចម្រើនវ័យហើយ ។ ក្នុងកាលនោះព្រះសាស្តាបានយាងដល់នគរសាវត្ថី ទ្រង់ទទួលវត្តជេតពនមហាវិហារ កុលបុត្តឈ្មោះសុគន្ធៈនោះ ឃើញព្រះសាស្តាអង្គនោះហើយ មានចិត្តជ្រះថ្លា ទើបបួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ។ តាំងអំពីថ្ងៃដែលលោកកើតហើយ រហូតដល់បរិនិព្វាន ក្នុងចន្លោះនេះ ក្លិនក្រអូបប៉ុណ្ណោះផ្សាយទៅក្នុងទីទាំងឡាយ ដូចជាទីដេក និងទីឈរជាដើម ។ ពួកទេវតាក៏នៅតែរោយលម្អិតទិព្វនិងផ្កាក្រអូបទិព្វថ្វាយ ។

ព្រះថេរៈនោះ កាលបានសម្រេចអរហត្តហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតនូវសោមនស្ស កាលប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុនទើបពោលពាក្យថា **តិស្សោ នាម ភគវា** ដូច្នេះជាដើម ។ ពាក្យទាំងនោះមានអត្ថដឹងបានងាយហើយ ព្រោះមានន័យដូចបានពោលមកហើយខាងដើម និងព្រោះមានអត្ថងាយយល់ហើយ ។ ផ្សេងគ្នាត្រឹមតែបុណ្យ និងឈ្មោះប៉ុណ្ណោះ ។

## អដ្ឋកថាចូឡសុគន្ធត្ថេរាបទាន ចប់

## កន្ទិយវគ្គទី ៥៥ ចប់

# សុត្តន្តបិដក

# ខុទ្ទកនិកាយ អបទាន

# បញ្ចមភាគ

# ថេរិយាបទាន

# សុមេធាវគ្គ ទី ១

## សុមេធាថេរិយាបទាន ទី ១

*លំដាប់តទៅនេះ ចូរចាំស្តាប់នូវថេរិកាបទានទាំងឡាយចុះ*

*[ ១ ] កាលព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ គង់នៅក្នុងសង្ឃារាម យើងជាស្រ្តី ៣ នាក់ ជាសម្លាញ់នឹងគ្នា បានថ្វាយនូវវិហារទាន ។ ពួកយើងបានទៅកើតក្នុងពួកទេវតាអស់ ១០ ជាតិផង ១០០ ជាតិផង ១ ម៉ឺនជាតិផង ចាំបាច់និយាយថ្វីក្នុងការកើតជារបស់មនុស្ស ។ ខ្ញុំជាស្រីមានឫទ្ធិច្រើន ក្នុងពួកទេវតាទាំងឡាយ ចាំបាច់និយាយថ្វីក្នុងការកើតជារបស់មនុស្ស ខ្ញុំកើតជាស្រីកែវ ធ្វើជាមហេសីរបស់ស្តេចមានរតនៈ ៧ ។ ជន ៣ នាក់នោះ គឺនាងធនញ្ជានី ១ នាងខេមា ១ និងខ្ញុំ ១ បានកើតក្នុងត្រកូលដែលសម្រេចល្អដោយកុសលដែលយើងបានសន្សំហើយក្នុងភពនោះ ។ ខ្ញុំបានកសាងអារាមល្អ ដ៏ប្រដាប់ដោយអវយវៈ ( គ្រឿងតាក់តែង ) គ្រប់យ៉ាងហើយមានចិត្តរីករាយ វេរថ្វាយដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។*

ដោយផលនៃកុសលកម្មនោះ ខ្ញុំចូលទៅកើតក្នុងភពណាៗ តែងដល់នូវភាពដ៏ប្រសើរ ក្នុងទេវលោក ក្នុងមនុស្សលោកក៏ដូចគ្នា ។ ក្នុងកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ។ កាលនោះ ស្តេចក្នុងដែនកាសី ទ្រង់ព្រះនាមកិកី ជាឥស្សរៈរបស់ជនក្នុងពារាណសីបុរីដ៏ឧត្តម ជាឧបដ្ឋាកនៃព្រះកស្សបៈព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ព្រះរាជាអង្គនោះ មានរាជកញ្ញាជាធីតា ៧ អង្គ ជាស្រីឋិតនៅក្នុងសេចក្តីសុខ ត្រេកអរក្នុងការបម្រើព្រះពុទ្ធ ធីតាទាំងនុ៎ះប្រព្រឹត្តព្រហ្មចរិយធម៌ ។ ខ្ញុំជាសម្លាញ់នៃធីតាទាំងនោះ មានចិត្តតម្កល់មាំក្នុងសីល ឲ្យនូវទានទាំងឡាយដោយគោរព ប្រព្រឹត្តនូវវត្តក្នុងផ្ទះ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវសេចក្តីប្រាថ្នានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំច្យុតអំពីឋាននោះមក ក៏បានទៅកើតក្នុងឋានយាមៈ លុះច្យុតអំពីឋានយាមៈនោះ បានទៅកើតក្នុងឋានតុសិត លុះច្យុតអំពីតុសិតនោះ បានទៅកើតក្នុងឋាននិម្មានរតី លុះច្យុតអំពីនិម្មានរតីនោះ បានទៅកើតក្នុងវសវត្តីបុរី ។ ខ្ញុំជាស្រីប្រកបដោយបុញ្ញកម្មនោះ ទៅកើតក្នុងឋានណា ៗ តែងបាននូវភាពជាមហេសីរបស់ស្តេចទាំងឡាយក្នុងឋាននោះ ៗ ។ លុះខ្ញុំច្យុតអំពីអត្តភាពនោះហើយ បានមកកើតជាមនុស្ស ក៏បាននូវភាពជាមហេសីនៃស្តេចចក្កពត្តិទាំងឡាយផង នៃស្តេចដែលមានមណ្ឌលទាំងឡាយផង ។ ខ្ញុំទទួលនូវសម្បត្តិក្នុងទេវតាទាំងឡាយផង ក្នុងមនុស្សទាំងឡាយផង ជាស្ត្រីមានសេចក្តីសុខ

ក្នុងទីទាំងពួង អន្ទោលទៅអស់ច្រើនជាតិ ។ ហេតុនោះក្តី ដើមកំណើតនោះក្តី ឫសគល់នោះក្តី សេចក្តីគាប់ចិត្តក្នុងសាសនានោះក្តី ការប្រជុំចុះជាដំបូងនោះក្តី ធម្មជាតទាំងនោះ បានរលត់ហើយដោយសេចក្តីត្រេកអរក្នុងធម៌ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមេធាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ សុមេធាថេរិយាបទាន ។

# មេខលទាយិកាថេរិយាបទានទី ២

[ ២ ] ខ្ញុំបានធ្វើព្រះស្តូបថ្វាយព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ហើយបានថ្វាយខ្សែក្រវាត់ចំពោះព្រះសាស្តាដើម្បីនវកម្ម ។ កាលមហាស្តូបសម្រេចហើយ ខ្ញុំមានចិត្តជ្រះថ្លា បានបូជាខ្សែក្រវាត់ចំពោះព្រះមុនិលោកនាថ ដោយដៃរបស់ខ្លួនទៀត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្សែក្រវាត់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើស្តូប ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្ត្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាច់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមេខលទាយិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ មេខលទាយិកាថេរិយាបទាន ។**

## មណ្ឌបទាយិកាថេរិយាបទានទី ៣

[ ៣ ] ខ្ញុំបានកសាងមណ្ឌបថ្វាយព្រះពុទ្ធ ព្រះនាមកោនាគមនៈ ហើយថ្វាយព្រះស្តូបដ៏ប្រសើរដល់ព្រះពុទ្ធ ជាផៅពង្សនៃលោកថែមទៀត ។ ខ្ញុំទៅកាន់ជនបទ និគម រាជធានីណាៗ ជាស្រីត្រូវគេបូជាក្នុងទីទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមណ្ឌបទាយិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ មណ្ឌបទាយិកាថេរិយាបទាន ។**

## សង្គមទាថេរិយាបទានទី ៤

[ ៤ ] កាលព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈ ជាធំជាងលោក ជាតាទិបុគ្គល ទ្រង់ស្ដេចទៅក្នុងប្រក ទ្រង់ញុំាងសត្វទាំងឡាយឲ្យឆ្លង ខ្ញុំចេញអំពីផ្ទះ ហើយឱនក្រាបចុះ កាលនោះ ព្រះពុទ្ធជាធំជាងលោក ព្រះអង្គជាអ្នកអនុគ្រោះ បានជាន់លើក្បាលខ្ញុំ ។ លុះព្រះលោកនាយក ទ្រង់ជាន់លើក្បាលខ្ញុំហើយស្ដេចហួសទៅ ខ្ញុំក៏បានទៅកើតក្នុងឋានតុសិត ដោយសេចក្ដីជ្រះថ្លាក្នុងចិត្តនោះ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសង្គមទាភិក្ខុនី មានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សង្គមទាថេរិយាបទាន ។**

# នឡមាលិកាថេរិយាបទានទី ៥

[ ៥ ] កាលនោះ ខ្ញុំជាកិន្នរញី នៅជិតច្រាំងស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេសហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ កើតសេចក្តីរីករាយ ធ្វើអញ្ជលីហើយយកកម្រងផ្កាបបុស បូជាព្រះសយម្ភូ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជាកិន្នរញីហើយក៏បានទៅកើតក្នុងឋានត្រៃត្រិង្ស ។ ខ្ញុំបាននូវភាពជាមហេសីនៃទេវរាជ ៣៦ ដង បាននូវភាពជាមហេសីនៃស្តេចចក្រពត្តិ ១០ ដង ។ ខ្ញុំទទួលរងកុសលបានចូលទៅកាន់ផ្នួស កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនឡមាលិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ នឡមាលិកាថេរិយាបទាន ។**

# ឯកបិណ្ឌទាតទាយិកាថេរិយាបទាន ទី ៦

[ ៦ ] ព្រះមហាក្សត្រព្រះនាមពន្ធុមៈក្នុងក្រុងពន្ធុមវតី ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានពោលនូវពាក្យខ្វះ ( នឹងស្តេចនោះ ) ។ កាលនោះខ្ញុំអង្គុយក្នុងទីស្ងាត់ ហើយគិតយ៉ាងនេះថា កុសលដែលអញគួរយកទៅបរលោក អញមិនបានធ្វើសោះ អញនឹងទៅកាន់នរកដែលជាឋានក្តៅខ្លាំងខ្លាចផ្សា មានសភាពគួរខ្លាច អាក្រក់ក្រៃលែងដោយពិត អញមិនមានសេចក្តីសង្ស័យក្នុងដំណើរនេះឡើយ ។ ខ្ញុំចូលទៅគាល់ព្រះរាជាហើយ ក្រាបទូលដូច្នេះថា បពិត្រព្រះមហាក្សត្រ សូមព្រះអង្គប្រទាននូវសមណៈ ១ អង្គ ដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងនិមន្តលោកឲ្យឆាន់ ។ ព្រះមហារាជទ្រង់ប្រទាននូវសមណៈ ១ អង្គ ដែលមានឥន្ទ្រិយអប់រំហើយដល់ខ្ញុំ ខ្ញុំទទួលនូវបាត្ររបស់លោកហើយបំពេញដោយបាយដ៏ប្រសើរ ។ លុះខ្ញុំបំពេញហើយ ធ្វើនូវបាយដ៏ប្រសើរ ឲ្យជាបាយលាយដោយវត្ថុមានក្លិនក្រអូប បិទដោយសំណាញ់គ្របដោយសំពត់លឿង ។ កុសលនុ៎ះ ជាអារម្មណ៍របស់ខ្ញុំ ខ្ញុំរឭកដរាបដល់អស់ជីវិត ខ្ញុំទៅកើតក្នុងឋានតាវត្តិង្ស ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងកុសលនោះ ។ ខ្ញុំបាននូវភាពនៃខ្លួនជាមហេសីនៃស្តេចទេវតាទាំងឡាយ ៣០ ជង សេចក្តីប្រាថ្នាដែលខ្ញុំប្រាថ្នាហើយក្នុងចិត្ត ក៏កើតឡើងដល់ខ្ញុំដូចសេចក្តីប្រាថ្នា ។ ខ្ញុំបាននូវភាពជាមហេសីនៃស្តេចចក្កពត្តិ ២០ ជង ខ្ញុំជាស្រីមានកុសលសន្សំហើយ តែងអន្ទោលទៅក្នុងភពតូចនិងភពធំ ។ ខ្ញុំរួចចាកចំណងទាំងអស់ហើយ ខ្ញុំជាអ្នកប្រាសចាកកំណើតហើយ អស់អាសវៈទាំងពួងរលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែល

ខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបិណ្ឌបាតទាន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបិណ្ឌបាតទាយិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ ឯកបិណ្ឌបាតទាយិកាថេរិយាបទាន ។

# កជង្គភិក្ខុនាយិកាបេរិយាបទានទី ៧

[ ៧ ] កាលព្រះសាស្តាព្រះនាមតិស្សៈ ទ្រង់ត្រាច់ទៅបិណ្ឌបាត ខ្ញុំបានយកចង្ហាន់មួយវែក ថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជាសាស្តា ជានាយកដ៏លើសលុបក្នុងលោកទ្រង់ទទួលហើយ ទ្រង់គង់នៅក្នុងផ្លូវ ទ្រង់ធ្វើអនុមោទនាដល់ខ្ញុំថា

នាងប្រគេនចង្ហាន់ ១ វែក នឹងបានទៅកើតក្នុងឋានតាវត្តិង្ស នឹងបានជាអគ្គមហេសីនៃស្តេចទេវតា ៣៦ ដង ។ នឹងបានជាមហេសីនៃស្តេចចក្កពត្តិ ៥០ ដង នឹងបាននូវសម្បត្តិទាំងពួងដែលនាងប្រាថ្នាហើយតាមចិត្តប្រាថ្នាក្នុងកាលទាំងពួង ។ នាងនឹងទទួលនូវសម្បត្តិ ជាស្ត្រីមិនមានសេចក្តីកង្វល់ នឹងបួសកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈនឹងបរិនិព្វាន ។ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជានាយកដ៏លើសលុបក្នុងលោក ព្រះអង្គជាអ្នកប្រាជ្ញ លុះត្រាស់នូវពាក្យនេះហើយ ក៏ហោះទៅឯអាកាស ដូចជាស្តេចហង្សហើរទៅឰដ៏អាកាស ។

ទានដែលខ្ញុំបានថ្វាយល្អហើយ យាគសម្បទាខ្ញុំបានបូជាល្អហើយ ខ្ញុំបានថ្វាយនូវចង្ហាន់ ១ វែក ហើយដល់នូវអចលបទ គឺព្រះនិព្វាន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយចង្ហាន់ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃពុទ្ធ

ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកដច្ឆុភិក្ខទាយិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ កដច្ឆុភិក្ខទាយិកាថេរិយាបទាន ។**

## សត្តឧប្បលមាលិកាថេរិយាបទានទី ៨

[ ៨ ] ក្នុងក្រុងអរុណវតី មានក្សត្រ ១ ព្រះអង្គទ្រង់ព្រះនាមអរុណៈ ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានចាត់ចែងនូវផ្កាដែលមិនទាន់ក្រងទុក ។ ខ្ញុំកាន់យកនូវផ្កាឧប្បល ៧ កម្រង មានក្លិនដូចជាក្លិនទិព្វ អង្គុយលើប្រាសាទដ៏ប្រសើរ គិតយ៉ាងនេះក្នុងខណៈនោះថា អញមានប្រយោជន៍អ្វីដោយកម្រងផ្កានេះ ដែលអញពាក់លើក្បាលរបស់អញ បើអញបូជាចំពោះញាណព្រះពុទ្ធដ៏ប្រសើរ ប្រសើរជាង ។ ជនទាំងឡាយតែងរាប់អាននូវព្រះសម្ពុទ្ធ អញអង្គុយនៅជិតទ្វារ កាលណាព្រះសម្ពុទ្ធទ្រង់ហៅថា នាងចូលមក អញនឹងបូជានឹងព្រះមហាមុនី ក្នុងកាលនោះ ។ ព្រះជិនស្រីប្រកបដោយភិក្ខុសង្ឃស្តេចមកតាមផ្លូវថ្នល់ ទ្រង់ល្វាសល្វន់ដូចជាដើមថ្វាន់ត្រូវខ្យល់ ឬដូចជាកេសររាជសីហ៍ ជាស្តេចម្រឹគ ។ ខ្ញុំជាអ្នកមានចិត្តរីករាយ លុះឃើញរស្មីព្រះពុទ្ធ

ក៏មានចិត្តសង្វេគមិនទាន់ដល់ទ្វារ ក៏បូជាចំពោះព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំធ្វើផ្កាឧប្បល ៧ កម្រង ត្រដាងពួដ៏អាកាស ផ្កាទាំងនោះ ក៏បាំងខាងលើព្រះសិរៈនៃព្រះពុទ្ធ ។ ខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តរីករាយ មានចិត្តត្រេកអរ ធ្វើអញ្ជលី ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធនោះ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ផ្កាទាំងឡាយបាំងធ្វើជាដំបូលនៃរោងធំខាងលើក្បាលខ្ញុំ ក្លិនជាទិព្វក៏ផ្សាយទៅ នេះជាផលនៃផ្កាឧប្បល ៧ កម្រង ។ កាលពួកញាតិនាំខ្ញុំទៅក្នុងកាលម្តងៗ បរិស័ទរបស់ខ្ញុំមានចំនួនត្រឹមណា ផ្កាទាំងឡាយក៏បាំងជារោងមានចំនួនត្រឹមនោះ ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៧០ ដង ខ្ញុំអន្ទោលទៅក្នុងភពតូចនិងភពធំ រមែងបានជាធំក្នុងទីទាំងពួង ។ ខ្ញុំបានជាមហេសីនៃស្តេចចក្កពត្តិ ៦៣ ដង ជនទាំងពួងតែងប្រព្រឹត្តតាមខ្ញុំ ខ្ញុំមានពាក្យគួរអ្នកផងជឿកាន់តាម ពណ៌និងក្លិនរបស់ខ្ញុំតែងផ្សាយទៅដូចក្លិននៃផ្កាឧប្បល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំជាស្រីឈ្លាសក្នុងឥទ្ធិបាទ ត្រេកអរក្នុងការចម្រើនពោជ្ឈង្គ ដល់នូវអភិញ្ញាបារមី នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំជាស្រីឈ្លាសក្នុងសតិប្បដ្ឋាន មានសមាធិជ្ឈានជាអារម្មណ៍ ប្រកបរឿយៗនូវសម្មប្បធាន នេះជាផលនៃពុទ្ធបូជា ។ សេចក្តីព្យាយាមរបស់ខ្ញុំជាគ្រឿងនាំទៅនូវធុរៈ នាំមកនូវធម៌ដ៏ក្សេមចាកយោគ ខ្ញុំមានអាសវៈអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោល

ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។ បានឮថា ព្រះសត្តឧប្បលមាលិកាភិក្ខុនី មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សត្តឧប្បលមាលិកាថេរិយាបទាន ។

# បញ្ចទីបិកាថេរិយាបទានទី ៩

[ ៩ ] ក្នុងកាលនោះ ខ្ញុំជាអ្នកដំណើរ នៅអាស្រ័យក្នុងនគរហង្សវតី ជាស្រីពេញចិត្តក្នុងកុសល តែងទៅអំពីអារាម ទៅកាន់អារាម ។ ខ្ញុំបានឃើញនូវពោធិព្រឹក្សដ៏ឧត្តម ក្នុងថ្ងៃកាឡបក្ខ ញុំាងចិត្តឲ្យជ្រះថ្លា ចំពោះពោធិព្រឹក្សនោះ ហើយអង្គុយនៅក្បែរគល់នៃពោធិព្រឹក្ស ។ ខ្ញុំតាំងចិត្តគោរព ធ្វើអញ្ជលីលើក្បាល ហើយទទួលនូវសោមនស្ស ក៏គិតយ៉ាងនេះក្នុងខណៈនោះថា បើព្រះពុទ្ធមានគុណរាប់មិនបាន មិនមានបុគ្គលប្រៀបផ្ទឹមស្មើបានមែន សូមឲ្យពោធិព្រឹក្សនេះ សម្ដែងនូវបាដិហារ្យដល់អាត្មាអញ គឺសូមឲ្យភ្លឺស្វាងចុះ ។ ក្នុងខណៈនោះ ពោធិព្រឹក្សប្រែជាមាសទាំងអស់ ភ្លឺស្វាងឡើងដំណាលគ្នានឹងខ្ញុំកំពុងពិចារណា ឯទិសទាំងពួងក៏ភ្លឺរុងរឿងឡើង ។ ខ្ញុំអង្គុយនៅក្បែរគល់

ពោធិព្រឹក្សនោះអស់ ៧ យប់ ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ខ្ញុំបានបូជាប្រទីប ។ ប្រទីបទាំង ៥ ក៏ភ្លឺរុងរឿងព័ទ្ធអាសនៈ កាលនោះប្រទីបទាំងឡាយរបស់ខ្ញុំ ក៏ភ្លឺរុងរឿងដរាបដល់ព្រះអាទិត្យរះឡើង ។ ខ្ញុំលះបង់នូវរាងកាយជារបស់មនុស្ស បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ។ ប្រាសាទរបស់ខ្ញុំ ដែលបុញ្ញកម្មធ្វើល្អ ហើយក្នុងឋានតាវត្តិង្សនោះហៅថាបញ្ចទីបប្រាសាទមានកម្ពស់ ១០០ យោជន៍ មានទំហំ ៦០ យោជន៍ ។ ប្រទីបទាំងឡាយរបស់ខ្ញុំរាប់មិនអស់ តែងភ្លឺរុងរឿងជុំវិញខ្ញុំ ទាំងកពទេវតាក៏ភ្លឺដោយ ពន្លឺប្រទីបនោះដែរ ។ ខ្ញុំអង្គុយបែរមុខទៅរកទិសខាងកើត បើខ្ញុំប្រាថ្នាដើម្បីមើលខាងលើ ខាងក្រោម និងទីទទឹង ខ្ញុំនឹងឃើញនូវវត្ថុទាំងពួងដោយចក្ខុ ។ ខ្ញុំប្រាថ្នាដើម្បីឃើញនូវកម្មដែលខ្ញុំធ្វើល្អនិងអាក្រក់ ដរាបណា គ្រឿងបិទបាំងក្នុងវត្ថុទាំងនោះ ទោះជាឈើឬភ្នំក៏មិនមាន ដរាបនោះ ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង បានជាមហេសីនៃស្តេចចក្កពត្តិ ១០០ ដង ។ ខ្ញុំដែលទៅកាន់កំណើតណាៗ ទោះជាទេវតាឬជាមនុស្ស ប្រទីប ១ សែន តែងបំភ្លឺជុំវិញខ្លួនខ្ញុំ ។ ខ្ញុំច្យុតបាកទេវលោក មកកើតក្នុងផ្ទៃនៃមាតា ភ្នែករបស់ខ្ញុំដែលនៅក្នុងផ្ទៃនៃមាតានោះមិនដែលធ្មេចឡើយ ។ ប្រទីប ១ សែន ប្រកបដោយបុញ្ញកម្ម រមែងរុងរឿងក្នុងផ្ទះជាទីប្រសូតិ នេះជាផលនៃប្រទីប ៥ ។ កាលកពជាទីបំផុតដល់ព្រមហើយ ខ្ញុំញុំាងចិត្តឲ្យប្រព្រឹត្តទៅ ខ្ញុំឃើញនូវព្រះនិព្វានដែលមិនមានជរានិងមរណៈ មានសេចក្តីត្រជាក់ ។ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត បានដល់

នូវព្រះអរហត្ត ព្រះពុទ្ធព្រះនាមគោតមទ្រង់ជ្រាបនូវគុណហើយឲ្យខ្ញុំបានឧបសម្បទា ។ ប្រទីបទាំង ៥ របស់ខ្ញុំរមែងឆេះឡើងក្នុងមណ្ឌប ជិតគល់ឈើ ក្នុងប្រាសាទ ក្នុងគុហា ក្នុងផ្ទះស្ងាត់ ។ ទិព្វចក្ខុរបស់ខ្ញុំស្អាតពិសេស ខ្ញុំជាស្រីឈ្លាសក្នុងសមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃប្រទីប ៥ ។ បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គមានការប្រព្រឹត្តធម៌ទាំងពួងចប់អស់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ មានប្រទីប ៥ ខ្ញុំសូមថ្វាយបង្គំព្រះបាទា ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយប្រទីបក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រទីប ៥ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចទីបិកាភិក្ខុនីមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បញ្ចទីបិកាថេរិយាបទាន ។**

## ឧទកទាយិកាថេរិយាបទានទី ១០

[ ១០ ] ខ្ញុំជាស្រីដងទឹក ក្នុងនគរពន្ធុមតី រស់នៅដោយការដងទឹក ចិញ្ចឹមទារកដោយការដងទឹកនោះ ។ ឯទេយ្យធម៌របស់ខ្ញុំមិនមាន ខ្ញុំចូលទៅក្នុងបន្ទប់ បានតម្កល់ទុកនូវទឹកចំពោះបុគ្គលជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ខ្ញុំបានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះ ខ្ញុំមានវិមានខ្ញុំដ៏ល្អដែលជាផលនៃការដងទឹកបាននិម្មិតឲ្យក្នុងឋានតាវត្តិង្សនោះ ក្នុងកាលនោះ ខ្ញុំប្រសើរជាងពួកស្រីអប្សរ ១០០០ នាក់ កាលនោះ ខ្ញុំគ្របសង្កត់នូវស្រីអប្សរទាំងនោះដោយហេតុ ១០ យ៉ាង ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៥០ ដង បានជាមហេសីនៃស្តេចចក្កពត្តិ ២០ ដង ។ ខ្ញុំអន្ទោលទៅក្នុងភពទាំងពីរ គឺទេវតានិងមនុស្ស ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃទានទឹក ។ កាលណាខ្ញុំចង់បានទឹកលើកំពូលភ្នំក្តី លើចុងឈើក្តី ឰដ៏អាកាសក្តី លើផែនដីក្តី ខ្ញុំក៏បាននូវទឹកយ៉ាងឆាប់ក្នុងកាលនោះ ទិសទាំងឡាយមិនធ្លាប់ភ្លៀងធ្លាក់សោះ ក៏ក្តៅសព្វ ខ្ញុំស្រេកទឹក មហាមេឃបានដឹងនូវតម្រិះរបស់ខ្ញុំ ក៏បង្អុរភ្លៀងចុះមក ។ ចួនណា កាលពួកញាតិកំពុងនាំខ្ញុំទៅ ខ្ញុំចង់បានទឹកក្នុងកាលណា មហាមេឃ ក៏ញុំាងភ្លៀងឲ្យកើតក្នុងកាលនោះ ។ កម្តៅក្តី សេចក្តីក្រហល់ក្រហាយក្តី មិនមានក្នុងសរីរៈរបស់ខ្ញុំឡើយ ធូលីក៏មិនមានក្នុងកាយរបស់ខ្ញុំ នេះជាផលនៃទានទឹក ។ ក្នុងថ្ងៃនេះ ខ្ញុំមានចិត្តស្អាតបរិសុទ្ធ ប្រាសចាកចិត្តលាមក មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានទឹក ។

កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយិកាភិក្ខុនីមានអាយុ បានសំដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឧទកាទាយិកាថេរិយាបទាន ។**

**ឧទ្ទាន**

សុមេធាថេរិយាបទាន ១ មេខលទាយិកាថេរិយាបទាន ១ មណ្ឌបទាយិកាថេរិយាបទា ១ សង្កមនទាថេរិយាបទាន ១ នឡមាលិកាថេរិយាបទាន ១ ឯកបិណ្ឌបាតទាយិកាថេរិយាបទាន ១ កដច្ឆុភិក្ខទាយិកាថេរិយាបទាន ១ សត្តឧប្បលមាលិកាថេរិយាបទាន ១ បញ្ចទីបិកាថេរិយាបទាន ១ ឧទកទាយិកាថេរិយាបទាន ១ ក្នុងវគ្គនេះ មានគាថា ១១៨ ដែលអ្នកប្រាជ្ញទាំងឡាយរាប់ឃើញហើយ ។

**ចប់ សុមេធាវគ្គទី ១ ។**

# ឧក្កុចោសថវគ្គ ទី ២

## ឧក្កុចោសថវិមានបាយទានទី ១

[ ១១ ] មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមពន្ធុមៈ សោយរាជ្យក្នុងនគរពន្ធុមវតី ព្រះអង្គរក្សាឧបោសថក្នុងថ្ងៃពេញបូរមី ។ សម័យនោះខ្ញុំជាកុម្ភទាសី នៅក្នុងទីនោះ ខ្ញុំបានឃើញសេនាព្រមទាំងព្រះរាជា ហើយក៏គិតយ៉ាងនេះថា សូម្បីស្តេចក៏ទ្រង់លះបង់រាជសម្បត្តិ ហើយរក្សាឧបោសថកម្មនោះពិតជាប្រកបដោយផល បានជាពួកជនរីករាយហើយ ។ ខ្ញុំពិចារណានូវទុគ្គតិផង នូវសេចក្តីក្រីក្រផងដោយឧបាយនៃប្រាជ្ញា ក៏ញុំាងចិត្តឲ្យរីករាយហើយរក្សាឧបោសថ ។ លុះខ្ញុំរក្សាឧបោសថក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធខ្ញុំក៏បានទៅកើតក្នុងឋានតាវត្តិង្សដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះ ។ វិមានរបស់ខ្ញុំដែលកុសលធ្វើល្អហើយក្នុងទីនោះ មានកម្ពស់ទៅខាងលើ ១ យោជន៍ប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈធំ ស្អិតស្អាងល្អហើយ ។ ស្រីអប្សរ ១ សែន តែងបម្រើខ្ញុំសព្វៗកាល ខ្ញុំរុងរឿងកន្លងលើសទេវតាទាំង-ឡាយដទៃសព្វៗកាល ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៦៤ ដង បានជាមហេសីនៃស្តេចចក្កពត្តិ ៣៦ ដង ។ ខ្ញុំមានពណ៌ដូចជាមាស តែងអន្ទោលទៅក្នុងកពទាំងឡាយ ខ្ញុំជាស្រីប្រសើរក្នុងទីទាំងពួង នេះជាផលនៃឧបោសថ ។ ខ្ញុំតែងបាននូវវត្ថុទាំងពួងនេះ គឺយានដំរី យានសេះ យានរថទាំងអស់ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួង ជាវិការៈនៃមាស ជាវិការៈនៃប្រាក់ជាវិការៈនៃកែវផលិក ជាវិការៈនៃកែវមានពណ៌ក្រហម ។ ខ្ញុំបាននូវវត្ថុទាំង

ពួង គឺសំពត់កោសេយ្យពស្រ្តនិងសំពត់កម្ពលផង សំពត់សម្បកឈើ និងសំពត់អម្បោះផង សំពត់មានថ្លៃដ៏ច្រើនផង ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះគឺ បាយ ទឹក ខាទនីយៈ សំពត់ និងសេនាសនៈ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺគ្រឿងប្រអប់ដ៏ប្រសើរនិងកម្រងផ្កា លម្អិតសម្រាប់លាប នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងនេះ គឺផ្ទះមានកំពូល ប្រាសាទមណ្ឌប ប្រាសាទមានជំបូលរលីង និងគុហា នេះជាផលនៃឧបោសថ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត បានចូលទៅកាន់ផ្នួស មិនទាន់បានកន្លះខែ ក៏បានសម្រេចព្រះអរហត្ត ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧបោ-សថ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកុបោសថិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឯកុបោសថិកាថេរិយាបទាន ។**

# សលឡបុប្ផិកាថេរិយាបទានទី ២

[ ១២ ] ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរញី នៅក្បែរឆ្នេរស្ទឹងចន្ទភាគា គ្រានោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ជាទេវតាប្រសើរជាងទេវតា ព្រះអង្គប្រសើរជាងនរជន ទ្រង់កំពុងចង្រ្កម ។ ខ្ញុំបានបេះផ្កាស្រល់ យកទៅថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ឯព្រះមហាវីរៈ ទ្រង់ហិតនូវផ្កាស្រល់ ដែលមានក្លិនដូចជាទិព្វ ។ ព្រះសម្ពុទ្ធព្រះនាមវិបស្សី ជាលោកនាយក មានព្យាយាមធំ ទ្រង់បានទទួលយកហើយ កាលដែលខ្ញុំកំពុងតែសម្លឹងមើល ទ្រង់ក៏ហិតក្នុងកាលនោះ ។ ខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងសត្វជើងពីរ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ឡើងទៅកាន់ភ្នំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡបុប្ផិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ សលឡបុប្ផិកាថេរិយាបទាន ។**

# មោទកទាយិកាថេរិយាបទានទី ៣

[ ១៣ ] ខ្ញុំជាកុម្ភទាសី នៅក្នុងនគរពន្ធុមតី បានកាន់យកនូវចំណែក ( នំអន្សម ) របស់ខ្ញុំ ហើយទៅកាន់កំពង់ទឹក ។ ខ្ញុំបានឃើញសមណៈ ១ រូបក្នុងទីពាក់កណ្ដាលផ្លូវ លោកមានចិត្តស្ងប់ស្ងាត់ មានចិត្តតម្កល់មាំមួន ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានប្រគេននំអន្សម ៣ ។ ខ្ញុំមិនដែលទៅកាន់វិនិបាតអស់ ២៩ កប្ប ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ខ្ញុំធ្វើនូវកុសលហើយ ខ្ញុំបានទទួលសម្បត្តិទាំងអស់ព្រោះបានធ្វើកុសលឲ្យជាសម្បត្តិ ខ្ញុំបានដល់នូវអចលបទគឺព្រះនិព្វាន ព្រោះប្រគេននំអន្សម ៣ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោទកទាយិកាភិក្ខុនីមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ មោទកទាយិកាថេរិយាបទាន ។**

# ឧក្កាសនទាយិកាថេរិយាបទានទី ៤

[ ១៤ ] ក្នុងកាលនោះ ខ្ញុំជាស្រីក្រមផ្កា នៅក្នុងនគរហង្សវតី មាតាបិតារបស់ខ្ញុំទាំងនោះ បានទៅធ្វើការងារ ។ កាលព្រះអាទិត្យកំពុងត្រង់ជាក់ ខ្ញុំឃើញព្រះសម្ពុទ្ធ ជាសមណៈកំពុងនិមន្តទៅតាមថ្នល់ ខ្ញុំក៏ក្រាលអាសនៈ ។ ខ្ញុំក្រាលអាសនៈដោយកម្រាល មានព្រំដែលមានរោមវែង ៤ ធ្នាប់ និងកម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវជាដើម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានពោលពាក្យនេះថា ផែនដីក្តៅណាស់ ឈរនៅពុំបាន ព្រះអាទិត្យកំពុងត្រង់ជាក់ ខ្យល់ក៏មិនបក់ ទាំងកត្តកាល ក៏ជិតអស់ ។ បពិត្រព្រះមហាមុនី អាសនៈនេះ ខ្ញុំក្រាលហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ សូមព្រះអង្គអាស្រ័យនូវសេចក្តីអនុគ្រោះ គង់លើអាសនៈរបស់ខ្ញុំ ។ ព្រះសមណៈ មានព្រះទ័យទូន្មានហើយ មានព្រះទ័យបរិសុទ្ធ គង់លើអាសនៈនោះ ខ្ញុំទទួលយកបាត្រនៃព្រះអង្គ បានប្រគេនចង្ហាន់ សមគួរដល់ការចម្អិន ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ វិមានរបស់ខ្ញុំល្អ ត្រូវផលនៃអាសនៈនិម្មិតហើយក្នុងឋានតាវត្តិង្សនោះ មានកំពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ បល្ល័ង្កផ្សេងៗរបស់ខ្ញុំជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវផលិក ជាវិការៈនៃមាសមានពណ៌ក្រហម ។ កម្រាលធ្វើដោយរោមសត្វ មានរោមប្រាងទាំងពីរខាង បល្ល័ង្ករបស់ខ្ញុំ តាំងនៅល្អហើយ ដោយកម្រាលដែលញាត់ដោយគរ និងកម្រាលដែលធ្វើដោយរោមសត្វដ៏វិចិត្រដោយរូបសត្វ មានសីហៈ និង

ខ្វាធំជាដើមផង ដោយកម្រាលដែលធ្វើដោយឱនមាសនិងសូត្រហើយ ចាក់ស្រេះដោយរតនៈ និងកម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរោមសត្វសាហាវផង ។ ខ្ញុំស្កប់ស្កល់ដោយការសើចនិងការលេង កាលណាខ្ញុំចង់ទៅ ខ្ញុំក៏ទៅកាន់ទីដែលខ្ញុំប្រាថ្នា មួយអន្ទើដោយបល្ល័ង្កដ៏ប្រសើរ ( ក្នុងកាលនោះ ) ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ជង បានជាមហេសី នៃស្តេចចក្កពត្តិ ៧០ ជង ។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ តែងបាននូវភោគៈដ៏ច្រើន ខ្ញុំមិនដែលខ្វះខាតភោគៈឡើយ នេះជាផលនៃអាសនៈឯក ។ ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ខ្ញុំមិនដែលស្គាល់ភពដទៃឡើយ នេះជាផលនៃអាសនៈឯក ។ ខ្ញុំតែងកើតក្នុងត្រកូល ២ គឺក្សត្រនិងព្រាហ្មណ៍ ប្រកបដោយត្រកូលខ្ពស់ក្នុងទីទាំងពួង នេះជាផលនៃអាសនៈឯក ។ ខ្ញុំមិនស្គាល់ទោមនស្សដែលញុំាងចិត្តរបស់ខ្ញុំឲ្យក្តៅ ខ្ញុំមិនស្គាល់នូវភេទផ្សេងៗ នេះជាផលនៃអាសនៈឯក ។ មេនំ ស្រីគម ស្រីកំពុងពេញល្បែងច្រើននាក់ តែងបម្រើខ្ញុំ ខ្ញុំទៅពីចង្កេះមួយទៅចង្កេះមួយ គឺគេពផ្លាស់ប្តូរគ្នា មិនដែលដើរដី នេះជាផលនៃអាសនៈឯក ។ ពួកស្រីដទៃផ្លូតទឹកឲ្យខ្ញុំ ពួកស្រីដទៃឲ្យខ្ញុំបរិភោគភោជន ពួកស្រីដទៃប្រដាប់តាក់តែងឲ្យខ្ញុំ ពួកស្រីដទៃឲ្យខ្ញុំត្រេកអរសព្វៗកាល ។ ពួកស្រីដទៃ លាបគ្រឿងក្រអូបឲ្យខ្ញុំ នេះជាផលនៃអាសនៈឯក ។ កាលខ្ញុំនៅក្នុងមណ្ឌបក្តី នៅជិតគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី បល្ល័ង្កតែងកើតឡើង ព្រោះដឹងនូវតម្រិះរបស់ខ្ញុំ នេះភពទីបំផុតរបស់ខ្ញុំ ភពជាទីបំផុតនេះកំពុងប្រព្រឹត្តទៅ ថ្ងៃនេះ ខ្ញុំទម្លាក់ចោលនូវរាជ ហើយចូលទៅកាន់ផ្នួស ។ ក្នុងកប្បទី ១ សែន អំពី

កទុកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអាសនៈឯក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនទាយិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ឯកាសនទាយិកាថេរិយាបទាន ។**

# បញ្ចទីបទាយិកាថេរិយាបទានទី ៥

[ ១៥ ] ក្នុងកាលនោះ ខ្ញុំជាស្រីអ្នកដំណើរ នៅក្នុងនគរហង្សវតី ខ្ញុំជាស្រីត្រូវការដោយកុសល តែងដើរទៅរកអារាម ទៅរកវិហារ ។ ខ្ញុំបានឃើញដើមពោធិព្រឹក្សដ៏ឧត្តមក្នុងថ្ងៃកាឡបក្ខ ហើយញុំាងចិត្តឲ្យជ្រះថ្លាចំពោះពោធិព្រឹក្សនោះ ក៏អង្គុយនៅក្បែរគល់នៃពោធិព្រឹក្ស ។ ខ្ញុំតម្កល់ចិត្តគោរពធ្វើនូវអញ្ជលីលើសិរ្សៈ ហើយរងនូវសោមនស្ស ក៏គិតយ៉ាងនេះ ក្នុងខណៈនោះថា បើព្រះពុទ្ធមានគុណរាប់មិនបាន មិនមានបុគ្គលផ្ទឹមស្មើមែន សូមឲ្យ

ពោធិព្រឹក្សនេះ សម្តែងនូវបាដិហារ្យដល់អាត្មាអញ គឺសូមឲ្យពោធិព្រឹក្សភ្លឺស្វាង ។ ដំណាលគ្នានឹងខ្ញុំកំពុងពិចារណា ពោធិព្រឹក្សក៏ភ្លឺស្វាង ក្លាយទៅជាពណ៌មាសទាំងអស់ ទិសទាំងពួងក៏រុងរឿង ក្នុងខណៈនោះ ។ ខ្ញុំអង្គុយក្បែរគល់ពោធិព្រឹក្សនោះ អស់ ៧ ថ្ងៃ ៧ យប់ ដល់ថ្ងៃទី ៧ ខ្ញុំបានបូជាប្រទីប ។ ប្រទីបទាំង ៥ នោះ ក៏ភ្លឺរុងរឿងឡើងព័ទ្ធអាសនៈ កាលនោះ ប្រទីបទាំងឡាយរបស់ខ្ញុំ ភ្លឺរុងរឿងដរាបដល់ព្រះអាទិត្យរះឡើង ។ លុះខ្ញុំលះបង់រាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ប្រាសាទរបស់ខ្ញុំដែលបុញ្ញកម្មធ្វើល្អហើយក្នុងឋានតាវត្តិង្សនោះ លោកហៅថា បញ្ចទីបប្រាសាទ មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ប្រទីបទាំងឡាយរបស់ខ្ញុំមានចំនួនរាប់មិនអស់ តែងភ្លឺរុងរឿងជុំវិញ ភពទេវតា ក៏ភ្លឺដោយពន្លឺប្រទីបនោះដែរ ។ ខ្ញុំអង្គុយបែរមុខទៅកាន់ទិសខាងកើត បើខ្ញុំប្រាថ្នាដើម្បីមើលខាងលើ ខាងក្រោម និងទិសទទឹង ខ្ញុំក៏ឃើញនូវវត្ថុទាំងអស់ដោយចក្ខុ ។ ខ្ញុំប្រាថ្នាដើម្បីឃើញនូវកម្មដែលខ្ញុំធ្វើល្អធ្វើអាក្រក់ដរាបណា គ្រឿងបិទបាំងក្នុងវត្ថុទាំងនោះ ទោះជាឈើឬភ្នំ ក៏មិនមានដរាបនោះ ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង បានជាមហេសីនៃស្តេចចក្កពត្តិ ១០០ ដង ។ ខ្ញុំទៅកាន់កំណើតណាៗ ជាទេវតាឬមនុស្ស ប្រទីបមានចំនួន ១ សែន ភ្លឺជុំវិញខ្ញុំ ។ លុះខ្ញុំច្យុតចាកទេវលោកមកកើតក្នុងផ្ទៃមាតា កាលខ្ញុំនៅក្នុងផ្ទៃនៃមាតា ភ្នែករបស់ខ្ញុំមិនដែលធ្មេចឡើយ ។ ប្រទីបចំនួន ១ សែន ដែលប្រកបដោយបុញ្ញកម្មរមែងភ្លឺក្នុង

ផ្ទះជាទីប្រសូតិ នេះជាផលនៃប្រទីប ៥ ។ កាលភពជាទីបំផុតដល់ព្រមហើយ ខ្ញុំញុំាងចិត្តឲ្យប្រព្រឹត្តទៅ ខ្ញុំឃើញព្រះនិព្វានមិនមានជរា និងមរណៈ មានសេចក្ដីត្រជាក់ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ក៏បានសម្រេចព្រះអរហត្ត ព្រះពុទ្ធទ្រង់ឲ្យឧបសម្បទាដល់ខ្ញុំ នេះជាផលនៃប្រទីប ៥ កាលខ្ញុំនៅក្នុងមណ្ឌបក្ដី ជិតគល់ឈើក្ដី ក្នុងផ្ទះស្ងាត់ក្ដី ប្រទីបតែងភ្លឺរុងរឿងសព្វៗកាល នេះជាផលនៃប្រទីប ៥ ។ ទិព្វចក្ខុរបស់ខ្ញុំស្អាតវិសេស ខ្ញុំជាស្រីឈ្លាសក្នុងសមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃប្រទីប ៥ ។ បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់មានចក្ខុ ខ្ញុំមានការប្រព្រឹត្តធម៌ចប់ស្រេចហើយ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ជាស្រីមានប្រទីប ៥ សូមថ្វាយបង្គំនូវព្រះបាទទាំងគូ ។ ក្នុងកប្បទី ១ សែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រទីប ៥ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចទាយិកាភិក្ខុនីមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ បញ្ចទីបទាយិកាថេរិយាបទាន ។**

# នឡមាលិកាថេរិយាបទានទី ៦

[ ១៦ ] កាលនោះឯង ខ្ញុំកើតជាកិន្នរញី នៅទៀបឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានឃើញព្រះពុទ្ធជាព្រះសយម្ភូ ទ្រង់ប្រាសចាកធូលី ទ្រង់ឈ្នះកិលេស ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយខ្លាំង មានចិត្តត្រេកអរធ្វើនូវអញ្ជលី ហើយកាន់យកនូវកម្រងផ្កាបបុស ទៅបូជាចំពោះព្រះសយម្ភូ ។ ខ្ញុំលះបង់រាងកាយជាកិន្នរញី បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៣៦ ជង សេចក្តីប្រាថ្នាដោយចិត្តរបស់ខ្ញុំរមែងកើតឡើងតាមសមគួរដល់សេចក្តីប្រាថ្នា ។ ខ្ញុំបានជាអគ្គមហេសីនៃស្តេចចក្កពត្តិ ១០ ជង ព្រោះបានសន្សំកងកុសល ខ្ញុំតែងអន្ទោលទៅក្នុងភពទាំងឡាយ ។ កុសលរបស់ខ្ញុំរមែងមាន ខ្ញុំបានចូលទៅកាន់ផ្នួស ថ្ងៃនេះ ខ្ញុំជាស្រីគួរដល់ការបូជាក្នុងសាសនានៃព្រះសក្យបុត្ត ។ ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រងផ្កាបបុស ។ ថ្ងៃនេះ ខ្ញុំមានចិត្តស្អាត ប្រាសចាកចិត្តលាមក មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនទ្បមាលិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ នទ្បមាលិកាថេរិយាបទាន ។**

# មហាបជាបតិគោតមីថេរិយាបទានទី ៧

[ ១៧ ] ក្នុងសម័យមួយ ព្រះសម្ពុទ្ធជាប្រទីបនៃលោក ព្រះអង្គជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់គង់នៅក្នុងកូដាគារសាលាក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ កាលនោះ ភិក្ខុនីឈ្មោះមហាបជាបតិគោតមី ជាព្រះមាតុច្ឆានៃព្រះជិនស្រី នៅក្នុងសម្នាក់ភិក្ខុនី ជិតបុរីជាទីរីករាយនោះឯង ។ ព្រះនាងមហាបជាបតិគោតមីភិក្ខុនី នៅក្នុងទីស្ងាត់ជាមួយនឹងពួកភិក្ខុនី ដែលមានចិត្តរួចស្រឡះចាកកិលេសចំនួន ៥០០ រូប ព្រះនាងមានចិត្តត្រិះរិះយ៉ាងនេះថា អញ ( បើរស់នៅ ) មិនបានទាន់ការបរិនិព្វាននៃព្រះសម្ពុទ្ធ នៃគូសាវ័ក នៃរាហុល អានន្ទ និងនន្ទទេ នឹងសុំអនុញ្ញាតព្រះលោកនាថ ជាមហេសី លះបង់នូវអាយុសង្ខារ ទៅកាន់ព្រះនិព្វានភ្លាមៗ ។ សេចក្តីត្រិះរិះរបស់នាងភិក្ខុនី ៥០០ រូបក្តី សេចក្តីត្រិះរិះរបស់នាងភិក្ខុនីទាំងឡាយ មាននាងភិក្ខុនីឈ្មោះខេមាជាដើមនេះក្តី ក៏ដូចព្រះនាងគោតមីដែរ ។ គ្រានោះមានការកក្រើកផែនដី ទាំងផ្គរក៏លាន់ឮឡើង ទេវតាទាំងឡាយដែលអាស្រ័យនៅក្នុងសម្នាក់ភិក្ខុនី ក៏ត្រូវសេចក្តីសោកបៀតបៀន ។ ( ទេវតាទាំងនោះ ) យំ

ទូញញាំងទឹកភ្នែក និងសេចក្ដីករុណាឲ្យប្រព្រឹត្តទៅក្នុងទីនោះ ភិក្ខុនីទាំងអស់ចូលទៅជិតនាងគោតមីភិក្ខុនី ជាមួយនឹងទេវតាទាំងនោះ ហើយក្រាបចុះដោយសិរ្សៈទៀបបាទា ពោលនូវពាក្យនេះថា បពិត្រព្រះនាងជាម្ចាស់ យើងទាំងឡាយនៅក្នុងទីស្ងាត់ត្រូវតំណក់ទឹកស្រោចស្រពហើយ ក្នុងទីនោះ ។ បពិត្រព្រះនាងគោតមីជាម្ចាស់ ផែនដីនោះ កក្រើកញាប់ញ័រ ទាំងផ្គរក៏លាន់ឮឡើង ទាំងសេចក្ដីខ្សឹកខ្សួល ពួកយើងក៏បានឮដែរ តើមានហេតុដូចម្ដេច ។ គ្រានោះ ព្រះនាងក៏ប្រាប់នូវហេតុ ទាំងអស់ដែលនាងត្រិះរិះ ។ លំដាប់នោះ ភិក្ខុនីទាំងអស់ បានប្រាប់នូវហេតុដែលខ្លួនត្រិះរិះហើយដែរថា បពិត្រព្រះនាងជាម្ចាស់ ព្រះនិព្វានជាទីក្សេមយ៉ាងក្រៃលែង បើព្រះនាងពេញចិត្តហើយ បពិត្រព្រះនាងដែលបានព្រះពុទ្ធអនុញ្ញាតហើយ យើងទាំងអស់គ្នានឹងនិព្វានដែរ ។ យើងទាំងឡាយនឹងចេញចាកផ្ទះចាកភពជាមួយនឹងព្រះនាងដែរ យើងនឹងទៅកាន់ព្រះនិព្វានជាបុរីដ៏ឧត្តមជាមួយនឹងព្រះនាងទៀត ។ កាលភិក្ខុនីទាំងឡាយពោលដើម្បីនិព្វាន គ្រានោះ ព្រះនាងក៏ពោលថា ខ្ញុំនឹងថាអ្វី ហើយក៏ចេញទៅចាកលំនៅភិក្ខុនី ជាមួយនឹងភិក្ខុនីទាំងអស់ រួចពោលថា ទេវតាណាដែលអាស្រ័យនៅក្នុងសម្នាក់ភិក្ខុនី ទេវតាទាំងនោះ សូមអត់ទោសដល់ខ្ញុំ ការឃើញលំនៅនាងភិក្ខុនីនេះ ជាការឃើញទីបំផុតរបស់ខ្ញុំ ។ ជរាក្ដី មច្ចុក្ដី មិនមានក្នុងទីណា ការជួបប្រទះដោយសត្វនិងសង្ខារមិនជាទីស្រឡាញ់ក្ដី ការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ក្ដី មិនមានក្នុងទីណា ទីនោះហៅថាអសង្ខតៈ ។ ពួកភិក្ខុនីជាឱរសរបស់ព្រះសុគតដែល មិនទាន់ប្រាស

ចាកភាគ: បានស្តាប់នូវពាក្យនោះហើយ ត្រូវសេចក្តីសោកគ្របសង្កត់ ក៏ខ្សឹកខ្សួលថា ឱហ្ន៎ ! យើងទាំងឡាយជាបុគ្គលឥតបុណ្យ ។ ទីលំនៅភិក្ខុនីនេះ បើវៀរចាកពួកភិក្ខុនីទាំងនោះហើយ ក៏នឹងសូន្យឈឹង ពួកនាងភិក្ខុនី ជាឱរសរបស់ព្រះជិនស្រី ក៏លែងប្រាកដដូចជាផ្កាយដែលមិនប្រាកដក្នុងពេលភ្លឺច្បាស់ ។ ព្រះនាងគោតមីនឹងទៅកាន់និព្វានជាមួយភិក្ខុនី ៥០០ រូប ដូចទន្លេគង្គាហូរទៅកាន់សាគរជាមួយស្ទឹង ៥០០ ដូច្នោះ ។ ពួកឧបាសិកាដែលមានសទ្ធាចេញអំពីផ្ទះដើរទៅតាមប្រក បានឃើញព្រះនាងគោតមីនោះ ក៏ក្រាបទៀបបាទាហើយពោលនូវពាក្យនេះថា ព្រះនាងម្ចាស់ ចូរជ្រះថ្លាក្នុងភោគៈដ៏ច្រើនចុះ ព្រះនាងមិនគួរលះបង់នូវយើងខ្ញុំទាំងឡាយ ឲ្យនៅឥតទីពឹង ហើយនិព្វានទេ ឧបា-សិកាទាំងនោះ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ក៏យំរៀបរាប់ ( យ៉ាងនេះ ) ។ ព្រះនាងគោតមី បានពោលវាចាដ៏ពីរោះ ដើម្បីបន្ទោបង់នូវសេចក្តីសោក របស់ស្រីទាំងនោះថា ម្នាលកូនទាំងឡាយ នាងទាំងឡាយមិនគួរយំស្រែកទេ ថ្ងៃនេះជាកាលគួរនាងទាំងឡាយសើចសប្បាយទេតើ ។ ព្រោះសេចក្តីទុក្ខខ្ញុំបានកំណត់ដឹងហើយ ហេតុនាំឲ្យកើតទុក្ខខ្ញុំវៀរស្រឡះហើយ ព្រះនិព្វានជាទីរលត់ទុក្ខ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងមគ្គទៀត ខ្ញុំក៏បានអប់រំល្អហើយ ។

## ចប់ ភាណវារៈទី ១ ។

ព្រះសាស្តាខ្ញុំបម្រើហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាធម្មជាតនាំសត្វទៅក្នុងភព ខ្ញុំក៏បានដកចោលហើយ ស្រីទាំងឡាយចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ណា ប្រយោជន៍ជាទីអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំក៏បានដល់ហើយ ។ ព្រះពុទ្ធក្តី ព្រះសទ្ធម្មរបស់ព្រះពុទ្ធនោះក្តី ឋិតនៅមិនខ្វះខាត ដរាបណា កាលនេះ ជាកាលគួរដើម្បីខ្ញុំនឹងនិព្វានដរាបនោះ ម្នាលកូនស្រីទាំងឡាយ នាងទាំងឡាយកុំសោកស្តាយខ្ញុំហើយ ។ ព្រះកោណ្ឌញ្ញៈ ព្រះអានន្ទ ព្រះនន្ទ ព្រះរាហុល ព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ចូរឋិតនៅជាសុខចុះ ទាំងពួកតិរ្ថិយដែលមានសេចក្តីល្ងង់ខ្លៅសាបសូន្យហើយក៏ឋិតនៅជាសុខចុះ ។ យសនៃវង្សរបស់ស្តេចឱក្កាកៈចម្រើនឡើងហើយ ញាំញីនូវមារ ម្នាលកូនស្រីទាំងឡាយ ក្រែង ( កាលនេះ ) ជាសម្បត្តិកាលដើម្បីឲ្យខ្ញុំនិព្វានហើយឬ ។ ចាប់តាំងអំពីយូរយារមកហើយ សេចក្តីប្រាថ្នាណាដែលខ្ញុំតម្កល់ទុក ( សេចក្តីប្រាថ្នានោះ ) នឹងសម្រេចក្នុងថ្ងៃនេះ កាលនេះ ជាកាលគួរទូងគេរី គឺសេចក្តីត្រេកអរក្នុងធម៌ ម្នាលកូនស្រីទាំងឡាយ នាងទាំងឡាយ មានប្រយោជន៍អ្វីនឹងសម្រក់ទឹកភ្នែក ។ បើនាងទាំងឡាយ មានសេចក្តីអាណិតខ្ញុំ ឬក៏ជាអ្នកកតញ្ញូនឹងខ្ញុំ នាងទាំងអស់គ្នា ចូរធ្វើព្យាយាមឲ្យមាំ ដើម្បីញុំាងព្រះសទ្ធម្មឲ្យតាំងនៅមាំចុះ ។ ព្រះសម្ពុទ្ធដែលខ្ញុំអង្វរសូមហើយ ព្រះអង្គក៏ទ្រង់ប្រទាននូវផ្នួស ដល់ស្រីទាំងឡាយ ព្រោះហេតុនោះ ខ្ញុំនឹងត្រេកអរយ៉ាងណា នាងទាំងឡាយ ចូរប្រព្រឹត្តតាមដំណើរនោះ យ៉ាងនោះចុះ ។ ព្រះនាងគោតមី

បានប្រៀនប្រដៅនូវពួកឧបាសិកាទាំងនោះយ៉ាងនេះហើយ ពួកភិក្ខុនីក៏ហែហម ហើយចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធ បានពោលនូវពាក្យនេះថា បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ជាព្រះមាតារបស់ព្រះអង្គ បពិត្រព្រះអង្គទ្រង់មានប្រាជ្ញា តែព្រះអង្គជាព្រះបិតានៃខ្ញុំព្រះអង្គ បពិត្រព្រះលោកនាថ ព្រោះព្រះអង្គទ្រង់ប្រទាននូវព្រះសទ្ធម្មនិងសេចក្ដីសុខ បពិត្រព្រះគោតម ខ្ញុំព្រះអង្គឈ្មោះថាកើតអំពីព្រះអង្គ ។ បពិត្រព្រះសុគត រូបកាយនៃព្រះអង្គនេះខ្ញុំឲ្យចម្រើនហើយ ធម្មកាយជាទីត្រេកអររបស់ខ្ញុំ ព្រះអង្គឲ្យចម្រើនហើយ ។ ខ្ញុំម្ចាស់ឲ្យព្រះអង្គបៅទឹកក្សីរ ដែលរម្ងាប់នូវសេចក្ដីស្រេកឃ្លានមួយរំពេច ព្រះអង្គឲ្យខ្ញុំបៅទឹកក្សីរគឺធម៌ មានសេចក្ដីស្ងប់រម្ងាប់ជាទីបំផុត បពិត្រព្រះមហាមុនី ព្រះអង្គមិនមានបំណុលដល់ខ្ញុំ ក្នុងការរក្សានូវចំណងទេ ស្រីទាំងឡាយចង់បានកូន កាលបន់ស្រន់ រមែងបានកូនប្រាកដដូចព្រះអង្គ ។ បពិត្រព្រះអង្គជាឱរស មាតាណារបស់ស្ដេចជាធំជាងនរៈ មានស្ដេចមន្ធាតុជាដើម មាតានោះ គឺខ្ញុំព្រះអង្គដែលលិចចុះក្នុងសមុទ្ទគឺភព បានព្រះអង្គចម្លងហើយចាកសមុទ្ទ គឺភព ។ ព្រះនាមជាព្រះមាតា ជាព្រះមហេសីរបស់ស្ដេច គឺស្រីទាំងឡាយតែងបានដោយងាយទេ ឯព្រះនាមថា ព្រះពុទ្ធមាតានេះ គឺស្រីទាំងឡាយសឹងបានដោយកម្រក្រៃពេក ។ បពិត្រព្រះមហាវីរៈ ឯសេចក្ដីប្រាថ្នាជាដំបូងនោះ ខ្ញុំព្រះអង្គបានហើយដោយសារព្រះអង្គ សេចក្ដីប្រាថ្នាទាំងអស់នោះ ទោះតូចក្ដី ធំក្ដី ព្រះអង្គបានបំពេញឲ្យហើយ ។ ខ្ញុំម្ចាស់សូមលះបង់នូវសាកសពនេះ ប្រាថ្នានឹងបរិនិព្វាន បពិត្រព្រះអង្គមានព្យាយាមជានាយក ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ សូម

ព្រះអង្គអនុញ្ញាតដល់ខ្ញុំព្រះអង្គ ។ សូមព្រះអង្គសណ្ដូកនូវព្រះបាទទាំងគូ ដ៏ទន់ល្មន់ដូចផ្កាឈូក ដេរដាសដោយស្នាមចក្រ កន្ទេវនិងទង់ ខ្ញុំព្រះអង្គមានសេចក្ដីស្រឡាញ់ចំពោះព្រះឱរស នឹងថ្វាយបង្គំព្រះបាទទាំងគូនោះ សរីរៈរបស់ព្រះអង្គ ប្រាកដស្មើដោយគំនរមាសដែលប្រាកដក្នុងដែនក្បុរ សូមព្រះអង្គធ្វើឲ្យជារាងកាយ គឺខ្ញុំព្រះអង្គឃើញបានដោយងាយ បពិត្រព្រះនាយក ខ្ញុំព្រះអង្គនឹងទៅកាន់ព្រះនិព្វាន ជាទីស្ងប់រម្ងាប់ ។ ព្រះជិនស្រី ទ្រង់សម្ដែងនូវរាងកាយប្រកបដោយលក្ខណៈ ៣២ ប្រដាប់ដោយពន្លឺដ៏ល្អដូចព្រះអាទិត្យដ៏ស្រទន់នាអាកាសក្នុងវេលាល្ងាច ។ លំដាប់នោះ ព្រះនាងគោតមីនោះ ក្រាបចុះដោយសិរ្សៈ ទៀបព្រះបាទាប្រាកដស្មើដោយផ្កាឈូករីក មានរស្មីដូចព្រះអាទិត្យទើបនឹងរះ ប្រដាប់ដោយចក្រ ហើយទូលថា ខ្ញុំសូមថ្វាយបង្គំព្រះអង្គជាព្រះអាទិត្យរបស់នរជន ជាទង់ក្នុងអាទិច្ចត្រកូល ព្រះអង្គជាពឹងរបស់ខ្ញុំក្នុងកាលជាទីបំផុត ខ្ញុំមិនបានឃើញព្រះអង្គទៀតទេ ។ បពិត្រព្រះអង្គជាកំពូលនៃលោក ធម្មតាស្ត្រីទាំងឡាយ ធ្វើនូវទោសទាំងពួងហើយស្លាប់ទៅ បើទោសរបស់ខ្ញុំមានបន្តិចបន្តួច បពិត្រព្រះអង្គទ្រង់ធ្វើសេចក្ដីករុណា សូមព្រះអង្គអត់ទោសនោះដល់ខ្ញុំ ។ ម្យ៉ាងទៀត ខ្ញុំសូមផ្ទួសរឿយៗ ដើម្បីស្រីទាំងឡាយ បើខ្ញុំមានទោសក្នុងហេតុនោះ បពិត្រព្រះអង្គដ៏ប្រសើរជាងនរជន សូមព្រះអង្គអត់នូវទោសនោះ ។ បពិត្រព្រះអង្គមានព្យាយាម ភិក្ខុនីទាំងឡាយ ដែលខ្ញុំប្រៀនប្រដៅហើយ តាមសេចក្ដីអនុញ្ញាតរបស់ព្រះអង្គ បើខ្ញុំទូន្មានមិនល្អក្នុងរឿងនោះទេ បពិត្រព្រះអង្គទ្រង់មានសេចក្ដីអត់ធន់នឹងមានព្យាយាម សូមព្រះ

អង្គអត់នូវទោសនោះដល់ខ្ញុំ ។

( ព្រះសម្ពុទ្ធត្រាស់តបថា ) តថាគតអត់ទោសក្នុងហេតុដែលតថាគតមិនទាន់អត់ ប្រយោជន៍អ្វីក្នុងភពដែលប្រដាប់ដោយគុណ តថាគតនឹងពោលនូវអ្វីដ៏លើសលុបជាងនាងដែលពោលដើម្បីនិព្វាន ។ កាលភិក្ខុសង្ឃរបស់តថាគតស្អាតគ្រប់គ្រាន់ ភិក្ខុសង្ឃក៏គួរដើម្បីវៀនចេញចាកលោកនេះ ដូចកាលព្រះចន្ទនិងផ្កាយទាំងឡាយ ដល់នូវសេចក្តីវិនាសក្នុងកាលព្រះអាទិត្យរះឡើង ស្នាមព្រះចន្ទដែលគេឃើញច្បាស់ ក៏រលុបបាត់ទៅ ។

ភិក្ខុនីដទៃ ក្រៅអំពីព្រះនាងមហាបជាបតិគោតមីនោះ ធ្វើប្រទក្សិណព្រះជិនស្រីដ៏ប្រសើរ ដូចជាផ្កាយប្រព្រឹត្តទៅតាមព្រះចន្ទ ដើរប្រទក្សិណភ្នំសិនេរុ ហើយក្រាបចុះទៀបព្រះបាទា រួចឈររមិលមើលនូវព្រះភក្ត្រនៃព្រះសាស្តានោះ ។ ព្រះនាងបជាបតិគោតមីក្រាបទូលថា ភ្នែករបស់ខ្ញុំមិនធ្លាប់ឆ្អែតដោយការឃើញនូវព្រះអង្គ ត្រចៀករបស់ខ្ញុំមិនធ្លាប់ឆ្អែតដោយភាសិតរបស់ព្រះអង្គ ។ ចិត្តរបស់ខ្ញុំតែមួយប៉ុណ្ណោះ ដល់នូវសេចក្តីឆ្អែតដោយរសនៃធម៌ដ៏ពេញលេញ ។

កាលព្រះមានព្រះភាគទ្រង់បន្លឺឡើងក្នុងកណ្តាលបរិស័ទ ទ្រង់ប្រហារនូវសេចក្តីរឹងត្អឹងរបស់ជនអ្នកមានវាទៈ ពួកជនណាបានឃើញព្រះឱស្ឋ បពិត្រព្រះអង្គជាធំជាងនរៈ ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ។ ជនទាំងឡាយណាថ្វាយបង្គំនូវព្រះបាទាមានព្រះអង្គុលីវែង មានព្រះនខាក្រហម មានព្រះបញ្ហិវែងល្អ បពិត្រព្រះអង្គ ទ្រង់ដល់នូវទីបំផុតនៃសេចក្តីសៅហ្មង ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ជនទាំងឡាយណា ស្តាប់នូវពាក្យទាំង-

ឡាយដ៏ពីរោះ ជាទីរីករាយចិត្ត ជាគ្រឿងជុតបោលនូវទោស ជាទីនាំមកនូវប្រយោជន៍ បពិត្រព្រះអង្គប្រសើរជាងនរៈ ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ។ បពិត្រព្រះមហាវីរៈ ខ្ញុំជាស្រីមានបុណ្យ ជាអ្នកយកចិត្តទុកដាក់ក្នុងការបូជានូវព្រះបាទារបស់ព្រះអង្គ ជាស្រីឆ្លងចាកផ្លូវលំបាកគឺសង្សារតាមព្រះពុទ្ធដីការបស់ព្រះអង្គ មានសិរី ។ លំដាប់នោះ ព្រះនាងគោតមី បានក្រាបទូលព្រះមានព្រះភាគ ជាស្រីមានវត្តល្អចំពោះភិក្ខុសង្ឃ រួចថ្វាយបង្គំព្រះរាហុល ព្រះអានន្ទ និងព្រះនន្ទ ហើយពោលនូវពាក្យនេះថា ខ្ញុំមានសេចក្តីនឿយណាយក្នុងសាកសព ជាលំនៅរបស់រោគ ស្មើដោយលំនៅនៃសត្វមានពិស ជាគ្រឿងកំណត់នៃទុក្ខ ជាទីគោចរនៃជរានិងមរណៈ ។ ជារូបជេរជាសដោយមន្ទិលគឺសាកសពផ្សេងៗ ជាអាយត្ត[១]នៃបុគ្គលដទៃ ជារូបប្រាសចាកអំណាច ព្រោះហេតុនោះ ខ្ញុំប្រាថ្នាដើម្បីព្រះនិព្វាន បពិត្រកូនទាំងឡាយ លោកទាំងឡាយចូរសម្គាល់ចុះ ។

ព្រះនន្ទនិងព្រះរាហុលដ៏ចម្រើន ជាអ្នកមិនមានសេចក្តីសោក មិនមានអាសវៈ មានចិត្តនឹងធឹង មិនមានកម្រើក មានប្រាជ្ញា មានព្យាយាម គិតរំពឹងនូវធម៌ថា ថ្វីយ! សង្ខតធម៌ជារបស់វិនាស របស់មិនមានខ្លឹម មានឧបមាដូចដើមចេក ប្រាកដស្មើដោយកលមាយា និងថ្ងៃបណ្តើរកូន ជារបស់តិចតួចមិនបានតាំងនៅយឺនយូរឡើយ ។ ព្រះនាងគោតមីនេះ ជាព្រះមាតុច្ឆានៃព្រះជិនស្រី បានចិញ្ចឹមព្រះសម្ពុទ្ធ ដើរទៅកាន់សេចក្តីស្លាប់ក្នុងទីណា ( ទីនោះ )

---

១-ដែលពឹងផ្អែកអ្នកដទៃដែលឥតអំណាចលើខ្លួន ។

មិនទៀត ត្រូវមានបច្ច័យតាក់តែងទាំងអស់ ។ ចំណែកឯព្រះអានន្ទ នៅជាសេក្ខបុគ្គល ជាប្អូនជាទីស្រឡាញ់នៃព្រះជិនស្រី ព្រះអានន្ទនោះបង្ហូរទឹកភ្នែកក្នុងទីនោះ ធ្វើនូវសេចក្តីករុណា ទួញយំ ខ្សឹកខ្សួលថា ព្រះនាងគោតមីពោលលាទៅកាន់ព្រះនិព្វានហើយ មិនយូរប៉ុន្មានទេ ព្រះសម្ពុទ្ធក៏គង់ទៅកាន់ព្រះនិព្វានពុំខានដែរ ដូចភ្លើងមិនមានកំញម ។ ព្រះនាងគោតមី បានមានព្រះសវនីយ៍ទៅកាន់ព្រះអានន្ទដែលកំពុងតែយំរៀបរាប់យ៉ាងនេះ ជាអ្នកមានវេទដ៏ជ្រៅ ដូចសាគរ ជាអ្នកយកចិត្តទុកដាក់ក្នុងការបម្រើព្រះសម្ពុទ្ធថា បពិត្រលោកកូន កាលបើកាលជាទីរីករាយប្រាកដហើយ លោកកូនមិនគួរសោយសោកទេ បពិត្រលោកកូន សេចក្តីស្លាប់របស់ខ្ញុំនោះ ជាកិច្ចចូលទៅកាន់ព្រះនិព្វានជាទីបំផុតវិញតើ ។ បពិត្រលោកកូន ព្រះសាស្តាដែលលោកកូនបានទូលសូមហើយ ទ្រង់ក៏អនុញ្ញាតនូវផ្នួសដល់យើង បពិត្រលោកកូន ចូរលោកកូនកុំតូចចិត្តឡើយ ព្រោះសេចក្តីខ្វល់ខ្វាយរបស់លោកកូន ជាការមួយប្រកបដោយផល ។ បទណាដែលពួកតិត្ថិកាចារ្យជាន់ចាស់មិនបានយល់ បទនោះសូម្បីពួកកុមារីដែលមានអាយុ ៧ ឆ្នាំ ក៏យល់ច្បាស់ហើយ ។ លោកកូនចូររក្សាព្រះពុទ្ធសាសនាចុះ ការឃើញលោកកូន ( គ្រានេះ ) ជាកិច្ចទីបំផុត ( របស់ខ្ញុំ ) បពិត្រលោកកូន បុគ្គលទៅហើយមិនប្រាកដក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ។ ព្រះនាយក ជាកំពូលនៃលោក ទ្រង់សម្តែងធម៌ផ្សាយទៅក្នុងកាលណា កាលនោះ ខ្ញុំជាស្រីអនុគ្រោះ ខ្ញុំបានពោលនូវវាចាឲ្យពរថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ បពិត្រ

ព្រះមហាមុនី សូមព្រះអង្គគង់នៅអស់ ១ កប្បចុះ សូមព្រះអង្គកុំមានជរានិង មរណៈ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងអស់ ។ ព្រះពុទ្ធនោះ ទ្រង់ត្រាស់នឹងខ្ញុំដែលជាអ្នកក្រាបទូលដូច្នោះនូវពាក្យនេះថា បពិត្រព្រះនាងគោតមី ព្រះនាងថ្វាយបង្គំយ៉ាងណា ព្រះពុទ្ធទាំងឡាយ គេមិនដែលថ្វាយបង្គំយ៉ាងនោះទេ ។

ព្រះតថាគតទាំងឡាយជាសព្វញ្ញូ បុគ្គលគប្បីថ្វាយបង្គំដោយប្រការដូចម្ដេច ព្រះពុទ្ធទាំងឡាយ បុគ្គលមិនគប្បីថ្វាយបង្គំ តើដោយប្រការដូចម្ដេច ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់នូវហេតុនោះឲ្យទាន ។

នាងចូរមើលនូវសាវកទាំងឡាយដែលមានព្យាយាមតឹងតែង មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានសេចក្ដីប្រឹងប្រែងដ៏មាំជានិច្ច ជាអ្នកព្រមព្រៀងគ្នា នេះឈ្មោះថា ការថ្វាយបង្គំនូវព្រះពុទ្ធទាំងឡាយ ។

លំដាប់នោះ ខ្ញុំទៅកាន់លំនៅភិក្ខុនីតែម្នាក់ឯង ក៏គិតយ៉ាងនេះថា ព្រះលោកនាថ ទ្រង់ដល់នូវទីបំផុតនៃត្រៃភព ទ្រង់ពេញព្រះហឫទ័យនឹងបរិស័ទដែលព្រមព្រៀងគ្នា ។ ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន កុំឲ្យឃើញនូវវិបត្តិនោះ ខ្ញុំគិតយ៉ាងនេះហើយ ក៏ឃើញនូវព្រះពុទ្ធជាឥសីទី ៧ ។ ខ្ញុំក្រាបទូលនូវកាលបរិនិព្វានរបស់ខ្ញុំចំពោះព្រះនាយក លំដាប់នោះ ព្រះអង្គទ្រង់អនុញ្ញាតថា បពិត្រព្រះនាងគោតមី ព្រះនាងចូរដឹងនូវកាលជាទីបរិនិព្វានចុះ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈព្រោះបានកាត់ចំណងដូចមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ

ក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ពួកជនពាលណា ដល់នូវសេចក្តីសង្ស័យ ក្នុងការត្រាស់ដឹងនូវធម៌នៃស្ត្រីទាំងឡាយ បពិត្រព្រះនាងគោតមី ព្រះនាងចូរសម្តែងនូវឫទ្ធិដើម្បីកម្ចាត់បង់នូវទិដ្ឋិនៃពួកជនពាលនោះ ។

គ្រានោះ ព្រះនាងគោតមី ក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ហើយហោះឡើងទៅឯអាកាស សម្តែងនូវឫទ្ធិដ៏ច្រើនជាអនេក តាមពុទ្ធានុញ្ញាត គឺស្ត្រីតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ស្ត្រីច្រើននាក់ ធ្វើឲ្យទៅជាម្នាក់ក៏បាន ទៅកាន់ទីវាលជាទីខាងក្រៅ ខាងក្រៅជញ្ជាំង ខាងក្រៅភ្នំក៏បាន ដើរទៅមិនទើសទាក់ មុជចុះក្នុងផែនដីក៏បាន ដើរលើទឹកមិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ។ ទៅទាំងភ្នែនលើអាកាស ដូចជាសត្វស្លាបក៏បាន ញុំាងអំណាចកាយឲ្យអណ្តែតទៅដរាបដល់លំនៅនៃព្រហ្មក៏បាន ។ យកភ្នំសិនេរុធ្វើជាដងឆត្រ យកផែនដីធំធ្វើជាឆត្រ បង្វិលដងឆត្រ បាំងដើរលើផ្ទៃអាកាស ។ ធ្វើនូវលោកឲ្យរុងរឿងដូចជាព្រះអាទិត្យ ៦ រះឡើងផង ធ្វើនូវលោកនោះឲ្យជាកម្រងសំណាញ់ ដូចជានៅលើភ្នំយុគន្ធផង ។ កាន់យកនូវវត្ថុទាំងពួងគឺ ដើមមុចលិន្ទ ថ្មធំ ភ្នំសិនេរុ ដើមមន្ទារៈ និងដើមទទ្ទុរៈទាំងឡាយ ដោយក្តាប់ដៃ ១ ដូចជាកាន់គ្រាប់ស្ពៃ ។ បិទបាំងព្រះអាទិត្យ ព្រះចន្ទ ដោយចុងម្រាម ទ្រនូវព្រះចន្ទ ព្រះអាទិត្យ ១ ពាន់ ដូចជាទ្រនូវគ្រឿងប្រដាប់ក្បាល ទ្រនូវទឹកក្នុងសមុទ្ទទាំង ៤ ដោយដៃម្ខាង

ញុំាងភ្លៀងធំមានអាការដូចជាទឹកហូរអំពីភ្នំយុគន្ធរឲ្យបង្អុរចុះ ។ ព្រះនាងគោតមីនោះ បាននិម្មិតជាស្តេចចក្កពត្តិ ព្រមទាំងបរិស័ទ សម្តែងនូវអត្តភាពជាគ្រុឌផង ដំរីផង សីហៈផង បន្លឺនូវសម្រែកលើផ្ទៃនៃអាកាស ។ ព្រះនាងតែម្នាក់ឯងនិម្មិតនូវពួកភិក្ខុនីដ៏ច្រើនប្រមាណមិនបាន ហើយឲ្យបាត់ទៅវិញ នៅតែម្នាក់ឯង ទើបពោលនឹងព្រះមុនីថា បពិត្រព្រះមហាវីរៈ ខ្ញុំជាមាតុច្ឆារបស់ព្រះអង្គ ជាស្ត្រីអ្នកធ្វើតាមនូវសាសនារបស់ព្រះអង្គ បានសម្រេចប្រយោជន៍របស់ខ្លួនហើយ បពិត្រព្រះអង្គមានចក្ខុ ខ្ញុំសូមថ្វាយបង្គំព្រះបាទាទាំងគូ ។ ព្រះនាងគោតមីនោះ លុះសម្តែងឫទ្ធិផ្សេងៗហើយ ក៏ចុះចាកផ្ទៃនៃអាកាស មកថ្វាយបង្គំព្រះសម្ពុទ្ធជាពន្លឺនៃលោក ហើយអង្គុយក្នុងទីដ៏សមគួរ រួចក្រាបទូលថា បពិត្រព្រះមហាមុនី ខ្ញុំកើតមកបានអាយុ ១២០ ហើយ បពិត្រព្រះមហាវីរៈ ខ្ញុំល្មមប៉ុណ្ណេះហើយ បពិត្រព្រះនាយក ខ្ញុំនឹងបរិនិព្វាន ។ គ្រានោះបរិស័ទទាំងពួងនោះ មានសេចក្តីអស្ចារ្យក្រៃពេក ផ្គងអញ្ជលីហើយពោលថា បពិត្រព្រះនាងមានឫទ្ធិប្រឹងពុំបាន មានព្យាយាម កិច្ចទាំងពួងព្រះនាងបានធ្វើហើយ ។

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ជានាយក ទ្រង់ត្រាស់ឡើងក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ ក្នុងកាលនោះខ្ញុំកើតក្នុងត្រកូលនៃអាមាត្យ ក្នុងនគរហង្សវតី ជាត្រកូលបរិបូណ៌ដោយឧបការៈទាំងពួង ដ៏ស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន ។ ក្នុងកាលមួយ ខ្ញុំទៅជាមួយនឹងបិតា មានពពួកខ្ញុំស្រីចោមរោម មានបរិវារច្រើន ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គប្រសើរជាងនរៈ ។ ខ្ញុំបានឃើញព្រះជិនស្រី មិនមានអាសវៈ ប្រាកដស្មើដោយ

ព្រះអាទិត្យ ក្នុងសរទកាល ដ៏ដេរដាសដោយកម្រងគឺរស្មី ទ្រង់បន្ទរបុះនូវភ្លៀង គឺធម៌ដូចជាព្រះឥន្ទ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា បានស្តាប់សុភាសិតនៃព្រះពុទ្ធនោះ ព្រះអង្គជានាយកនៃនរៈ ទ្រង់តាំងនូវនាងភិក្ខុនី ជាព្រះមាតុច្ឆា ក្នុងទីដ៏ប្រសើរ លើស ។ លុះខ្ញុំស្តាប់ហើយ ក៏បានថ្វាយនូវមហាទានផង នូវបច្ច័យដ៏ច្រើនផង ដល់ព្រះសម្ពុទ្ធដ៏ប្រសើរជាងនរជនអង្គនោះ ទ្រង់ជាតាទិបុគ្គល ព្រមទាំងព្រះសង្ឃ អស់ ៧ ថ្ងៃ រួចខ្ញុំក្រាបចុះទៀបព្រះបាទា ហើយប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធជាឥសីទី ៧ បានពោលក្នុងបរិស័ទច្រើនថា ស្ត្រីណា បានញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់អស់ ៧ ថ្ងៃ តថាគតនឹងសរសើរនូវស្ត្រីនោះ អ្នកទាំងឡាយចូរស្តាប់នូវពាក្យដែលតថាគត នឹងសម្តែងដូចតទៅនេះ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ ស្ត្រីនោះនឹងបានជាឱរស ជាអ្នកទទួលមរតកក្នុងធម៌នៃព្រះពុទ្ធនោះ ជាធម្មនិម្មិត ឈ្មោះនាងគោតមី នឹងបានជាសាវិកានៃព្រះសាស្តាអង្គនោះ ។ នាងគោតមីនេះ ជាព្រះមាតុច្ឆា ជាអ្នករក្សានូវជីវិតនៃព្រះពុទ្ធនោះ នឹងបាននូវទីដ៏ប្រសើរលើស ជាងភិក្ខុនីទាំងឡាយជាអ្នកដឹងនូវរាត្រីដ៏វែង ( មានអាយុវែង ) ។ គ្រានោះ ខ្ញុំស្តាប់នូវព្រះពុទ្ធដីកានោះ ក៏មានចិត្តរីករាយ បានបម្រើនូវព្រះជិនស្រី ដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត តមក ខ្ញុំក៏ធ្វើមរណកាល ។ ខ្ញុំទៅកើតក្នុងពួកទេវតាជាន់តាវត្តិង្ស សម្រេចនូវសេចក្តីប្រាថ្នាទាំងពួង បានគ្របសង្កត់នូវទេវតាទាំងឡាយដទៃដោយអង្គ ១០ យ៉ាង គឺដោយរូប សំឡេង ក្លិន រស

សម្ពស្ស អាយុ វណ្ណៈ សុខៈ យស ។ មួយទៀត ខ្ញុំឈ្នះឈ្នានុងរឿងដោយអធិបតេយ្យ ( ជាគម្រប់ ១០ ) ខ្ញុំបានជាមហេសីរបស់ព្រះឥន្ទក្នុងឋាននោះ ។ ខ្ញុំត្រូវខ្យល់គឺកម្មបក់ផាត់ទៅអន្ទោលទៅក្នុងសង្សារ បានទៅកើតក្នុងស្រុកទាស-គ្រាម ក្នុងដែននៃស្តេចឈ្មោះកាសិកៈ ។ គ្រានោះ ខ្ញុំប្រុស ៥០០ នាក់ ឥតខ្វះខាត នៅក្នុងស្រុកនោះ ជនណាជាធំជាងជនទាំងពួងក្នុងស្រុកនោះ ខ្ញុំបានជាប្រពន្ធរបស់ជននោះ ។ ភិក្ខុ ៥០០ អង្គ របស់ព្រះសយម្ភូ បានចូលទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាត ខ្ញុំព្រមទាំងញាតិទាំងអស់ ឃើញភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ ខ្ញុំព្រមទាំងប្តីមានចិត្តជ្រះថ្លាបានធ្វើកុដិ ៥០០ ខ្នង ( ប្រគេន ) ចូលទៅបម្រើអស់ ៤ ខែ ហើយប្រគេននូវត្រៃចីវរ ។ ខ្ញុំព្រមទាំងប្តី លុះច្យុតចាកអត្តភាពនោះ បានទៅកើតក្នុងឋានតាវត្តិង្ស ឥឡូវនេះ ខ្ញុំកើតក្នុងបុរីឈ្មោះទេវទហៈក្នុងភពជាទីបំផុត ។ ព្រះបិតារបស់ខ្ញុំជាសក្យព្រះនាម អញ្ជនៈ ព្រះមាតារបស់ខ្ញុំព្រះនាម សុលក្ខណា លំដាប់នោះ ខ្ញុំបានទៅកាន់សម្នាក់ ( អគ្គទេពី ) នៃព្រះរាជាព្រះនាមសុទ្ធោទនៈ ក្នុងក្រុងកបិលពស្តុ ។ ស្ត្រីទាំងអស់កើតក្នុងសក្យត្រកូល បានទៅកាន់សម្នាក់ ( ស្រីស្នំ ) របស់ព្រះបាទសុទ្ធោទនៈនោះ ខ្ញុំប្រសើរជាងស្ត្រីទាំងអស់ បានជាអ្នករក្សានូវព្រះជិនស្រី ។ ព្រះសម្ពុទ្ធនោះ ជានាយក ជាបុត្ររបស់ខ្ញុំ ទ្រង់ចេញទៅបព្វជ្ជា លុះកាលជាខាងក្រោយ ខ្ញុំក៏ចេញទៅបួសជាមួយនឹងស្ត្រី ៥០០ នាក់ ។ ខ្ញុំបានពាល់ត្រូវនូវសន្តិសុខជាមួយនឹងពួកនាងសាកិយានីទាំងឡាយ ជាស្ត្រីមានព្យាយាមក្នុងកាលនោះ ជនទាំងឡាយណាជាស្វាមីរបស់យើងក្នុងជាតិមុន ។ ជនទាំងនោះ ជាអ្នក

ធ្វើបុណ្យ អ្នកធ្វើលទ្ធិដ៏ធំដែលព្រះសុគតអនុគ្រោះហើយក៏បាននូវព្រះអរហត្ត ។

ភិក្ខុទាំងឡាយដទៃ ក្រៅអំពីព្រះនាងមហាបជាបតិគោតមីនោះ ហោះទៅកាន់ផ្ទៃអាកាស មានឫទ្ធិច្រើន រុងរឿងដូចជាផ្កាយប្រជុំគ្នា សម្តែងឫទ្ធិជាអនេក ជាស្ត្រីសិក្សាក្នុងបុញ្ញកម្មទាំងឡាយ ដូចជាជាងមាសធ្វើនូវគ្រឿងប្រដាប់ដ៏ប្លែកៗ ។ គ្រានោះ ភិក្ខុនីទាំងឡាយ សម្តែងនូវបាដិហារ្យផ្សេងៗជាច្រើន ញុំាងព្រះមុនីដ៏ប្រសើរដូចជាព្រះអាទិត្យ ព្រមទាំងបរិស័ទឲ្យត្រេកអរ ។ ចុះអំពីផ្ទៃអាកាសមកថ្វាយបង្គំព្រះពុទ្ធជាឥសីទី ៧ លុះព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់អនុញ្ញាតហើយក៏គង់ក្នុងទីដដែលវិញ រួចទូលថា បពិត្រព្រះមហាវីរៈ ព្រះនាងគោតមី បានអនុគ្រោះខ្ញុំព្រះអង្គទាំងអស់គ្នា ពួកខ្ញុំព្រះអង្គបាន ព្រះនាងគោតមីនោះ អប់រំដោយបុណ្យទាំងឡាយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ កិលេសទាំងឡាយពួកខ្ញុំម្ចាស់ដុតបំផ្លាញហើយ ភពទាំងពួង ពួកខ្ញុំម្ចាស់ដកចោលហើយ ពួកខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ពួកខ្ញុំម្ចាស់មកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ពួកខ្ញុំម្ចាស់បានដល់ហើយ សាសនារបស់ព្រះពុទ្ធ ពួកខ្ញុំម្ចាស់បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ពួកខ្ញុំម្ចាស់បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ពួកខ្ញុំព្រះអង្គក៏បានប្រតិបត្តិហើយ ។ បពិត្រព្រះមហាមុនី ពួកខ្ញុំម្ចាស់ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ស្ទាត់ក្នុងទិព្វសោតធាតុនិងចេតោ-បរិយញ្ញាណផង ។ ពួកខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាសៈ ជម្រះនូវទិព្វចក្ខុ អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។

បពិត្រព្រះមហាវីរៈ ញាណរបស់ខ្ញុំម្ចាស់កើតឡើងក្នុងសម្នាក់នៃព្រះអង្គ រមែងមានក្នុងអត្ថផង ក្នុងធម៌ផង ក្នុងនិរុត្តិផង ក្នុងបដិភាណផង ។ បពិត្រព្រះនាយក ពួកខ្ញុំព្រះអង្គមានមេត្តាចិត្ត បានបម្រើព្រះអង្គហើយ បពិត្រព្រះមហាមុនី សូមព្រះអង្គអនុញ្ញាតពួកខ្ញុំព្រះអង្គទាំងអស់ដើម្បីបរិនិព្វាន ។ ព្រះជិនស្រីទ្រង់ត្រាស់ថា តថាគតនឹងពោលដូចម្តេច ចំពោះនាងទាំងឡាយ ដែលចេះតែទទូចនិយាយយ៉ាងនេះថា យើងទាំងឡាយសូមបរិនិព្វានឥឡូវនេះ ( កាលបើយ៉ាងនេះ ) នាងទាំងឡាយ ចូរសម្គាល់នូវកាលគួរដើម្បីនិព្វានចុះ ។ កាលនោះ ភិក្ខុនីទាំងឡាយនោះ មានព្រះនាងគោតមីជាដើម ថ្វាយបង្គំព្រះជិនស្រីក្រោកចាកអាសនៈ ហើយដើរទៅ ។ ព្រះលោកនាយក ជាកំពូលនៃលោកជាអ្នកប្រាជ្ញ មួយអន្ទើដោយពួកជនដ៏ច្រើន បានស្តេចទៅតាមព្រះមាតុច្ឆាដរាបដល់បន្ទប់ ។ គ្រានោះឯង ព្រះនាងគោតមី ក្រាបចុះទៀបព្រះបាទាទាំងគូនៃព្រះលោកពន្ធុ ជាមួយនឹងពួកភិក្ខុនីទាំងអស់នុ៎ះ នេះឈ្មោះថា ការថ្វាយបង្គំនូវព្រះ-បាទជាទីបំផុត ។

ការឃើញព្រះលោកនាថនៃខ្ញុំនេះ ជាការឃើញទីបំផុត ខ្ញុំនឹងមិនបានឃើញនូវព្រះភក្ត្ររបស់ព្រះអង្គ ដែលមានអាការមិនស្លាប់ទៀតឡើយ ។ បពិត្រព្រះអង្គមានព្យាយាម ការថ្វាយបង្គំរបស់ខ្ញុំ ចំពោះព្រះបាទារបស់ព្រះអង្គដ៏ទន់ល្វន់នឹងមិនមានទៀតឡើយ បពិត្រព្រះអង្គជាកំពូលនៃលោក ខ្ញុំនឹងទៅកាន់ព្រះនិព្វានក្នុងថ្ងៃនេះ ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់តបថា ) ព្រះនាងនឹងមានប្រយោជន៍អ្វីដោយរូបក្នុងបច្ចុប្បន្ននេះ ព្រោះរូបទាំងអស់នុ៎ះ សុទ្ធតែមានបច្ច័យតាក់តែង ជា

របស់មិនមាំមួន ជារបស់ស្អុចស្តើង ។ ព្រះនាងគោតមីនោះ ទៅកាន់សម្នាក់ភិក្ខុនីមួយអន្លើដោយភិក្ខុនីទាំងនោះ អង្គុយបត់ជើងលើអាសនៈប្រសើរ ។ គ្រានោះឧបាសិកាទាំងឡាយក្នុងទីនោះ ជាអ្នកស្រឡាញ់ព្រះពុទ្ធសាសនា បានឮដំណឹងព្រះនាងគោតមី ក៏ទៅថ្វាយបង្គំព្រះបាទា ។ យកដៃគក់ទ្រូង យំស្រែក គួរអាណិត សោយសោក ផ្តួលខ្លួនលើផែនដី ដូចជាវល្លិដែលគេកាត់ឫសគល់ពោលដូច្នេះថា បពិត្រព្រះនាងជាទីពឹងទីរឮក ព្រះនាងកុំលះបង់នូវយើងទាំងឡាយទៅកាន់ព្រះនិព្វានឡើយ យើងទាំងអស់គ្នាក្រាបចុះដោយសិរ្ស: សូមអង្វរឃាត់ ។ ឧបាសិកាណាមានសទ្ធាមានបញ្ញា ជាប្រធាននៃស្រីទាំងនោះ ព្រះនាងគោតមីបានពោលនូវពាក្យនេះនឹងឧបាសិកានោះ ដែលកំពុងប្រចាប់ព្រះសិរៈរបស់ព្រះនាងថា នែកូនស្រី កុំពិលាបឡើយ ព្រោះការយំសោក ជាហេតុនាំឲ្យប្រព្រឹត្តទៅតាមនូវអន្ទាក់នៃមារទេ រូបទាំងអស់ដែលមានបច្ច័យប្រជុំតាក់តែងហើយ សុទ្ធតែមិនទៀង មានការព្រាត់ប្រាសជាទីបំផុត ជារបស់នាំឲ្យចលាចល ។ លំ-ដាប់នោះ ព្រះនាងលះបង់នូវពួកឧបាសិកាទាំងនោះ ចូលកាន់បឋមជ្ឈានដ៏ឧត្តមទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ចូលកាន់អាកាសានញ្ចាយតនជ្ឈានវិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញាយតនជ្ឈានតាមលំដាប់ ។ ព្រះនាងគោតមី ចូលកាន់ឈានទាំងឡាយជាបដិលោម តាំងពីចតុត្ថជ្ឈានមកដល់បឋមជ្ឈាន ។ ព្រះនាងគោតមី មិនមានអាសវៈ ចេញពីចតុត្ថជ្ឈាននោះហើយ ក៏និព្វានដូចជាប្រទីបអស់ប្រេង: ការកម្រើកផែនដីដ៏ធំ ក៏កើតមានឡើង ផ្លេកបន្ទោរក៏ធ្លៀលធ្លាត់ធ្លាក់ចុះពីអាកាស ។ ទាំងផ្គរក៏លាន់ឮ

គគ្រឹកគគ្រេង ទេវតាទាំងឡាយក៏យំខ្សឹកខ្សួល ភ្លៀងផ្កា ក៏ធ្លាក់ចុះអំពីអាកាស មកកាន់ផែនដី ។ ស្តេចភ្នំឈ្មោះសិនេរុ ក៏កក្រើកញាប់ញ័រ ដូចអ្នករបាំក្នុងកណ្តាលរឿណរង្គ ទាំងសាគរ ក៏ស្រែកហាក់ដូចជា មានសេចក្តីសោកគ្រប សង្កត់ ។ ទេវតា នាគ អសុរ ព្រហ្ម មានសេចក្តីសង្វេគ បានពោលក្នុងខណៈនោះថា ឱហ្ន៎ សង្ខារទាំងឡាយមិនទៀងទេ ដូចយ៉ាងព្រះនាងគោតមីនេះ គង់ដល់នូវការរលាយបាត់ទៅ ។ ស្រីទាំងឡាយណា ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ចោមរោមព្រះនាងគោតមីនេះ ស្រីទាំងនោះ មិនមានឧបាទាននិព្វានហើយ ដូចជាអណ្តាតប្រទីបដែលរលត់ ។ ហឺ ! ការប្រកបមានសេចក្តីព្រាត់ប្រាសជាទីបំផុត ហឺ! រូបទាំងពួងដែលបច្ច័យតាក់តែងហើយ សុទ្ធតែមិនទៀង ហឺ! ជីវិតមានសេចក្តីវិនាសជាទីបំផុត មានសេចក្តីខ្សឹកខ្សួលដូច្នេះឯង ។ លំដាប់នោះ ទេវតា ព្រហ្ម ចូលទៅគាល់ព្រះពុទ្ធជាឥសីទី ៧ ធ្វើនូវការប្រព្រឹត្តទៅតាមធម្មតាលោក ដ៏សមគួរតាមកាល គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់ហៅព្រះអានន្ទដែលមានវេទដ៏ជ្រៅដូចសាគរថា ម្នាលអានន្ទ អ្នកចូរទៅប្រាប់នូវបរិនិព្វានរបស់ព្រះមាតាដល់ភិក្ខុទាំងឡាយចុះ ។ គ្រានោះ ព្រះអានន្ទមានសេចក្តីទុក្ខ មានភ្នែកពេញដោយទឹកភ្នែក មានសំឡេងរអាក់រអួលពោលថា ភិក្ខុទាំងឡាយណានៅក្នុងទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ភិក្ខុទាំងឡាយនោះចូលប្រជុំគ្នា ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនីនោះ ជាព្រះមាតារបស់ខ្ញុំ ជាឱរសរបស់ព្រះសុគត ។ ព្រះនាងគោតមីណា ថ្វាយបង្គំព្រះសរីរៈរបស់ព្រះមុនី ជាទីបំផុតដោយការផ្ចិតផ្ចង់ ព្រះនាងគោតមីនោះ ទៅហើយកាន់

ទីស្ងប់រម្ងាប់គឺព្រះនិព្វាន ដូចជាផ្កាយបាត់ទៅក្នុងកាលជាទីរះឡើងនៃព្រះអាទិត្យ ។ ព្រះលោកនាយក សូម្បីមានព្រះនេត្រ ៥ មិនឃើញ ( នូវគតិរបស់ព្រះនាងបជាបតិគោតមី ) ទីស្ងប់រម្ងាប់ណា ព្រះនាងបជាបតិគោតមីភិក្ខុនី តម្កល់ទុកនូវឈ្មោះថាពុទ្ធមាតា ទៅហើយកាន់ទីស្ងប់រម្ងាប់នោះ ។ បុគ្គលណា មានជំនឿចំពោះព្រះសុគត ម្យ៉ាងទៀត សិស្សណា របស់ព្រះមហាមុនី សិស្សនោះ ជាឱរសរបស់ព្រះសុគត ចូរធ្វើសក្ការៈដល់ព្រះពុទ្ធមាតាចុះ ។ ភិក្ខុទាំងឡាយសូម្បីនៅក្នុងទីឆ្ងាយក្រៃពេក លុះឮដំណឹងនោះ ក៏មកដោយរហ័ស ភិក្ខុពួកខ្លះមកដោយពុទ្ធានុភាព ភិក្ខុពួកខ្លះជាអ្នកឈ្លាសក្នុងឫទ្ធិទាំងឡាយ ក៏មកដោយឫទ្ធិ ។ ព្រះនាងគោតមី ផ្ទុំលើគ្រែណា ជនទាំងឡាយលើកនូវគ្រែនោះ ដាក់ក្នុងផ្ទះកំពូលដ៏ប្រសើរ ជាទីរីករាយ ដ៏ស្អាត ជាវិការៈនៃមាសទាំងអស់ លោកបាលទាំង ៤ ក៏សែងដោយស្មាទាំងឡាយ ទេវតាដ៏សេស មានព្រះឥន្ទជាដើម ក៏បានចាប់កាន់ផ្ទះកំពូល ។ ផ្ទះកំពូលទាំងអស់មានចំនួន ៥០០ ខ្នង ដែលព្រះវិស្សុកម្មទេវបុត្តនិម្មិតហើយ មានពណ៌ដូចជាព្រះអាទិត្យ ក្នុងសរទកាល ។ ភិក្ខុនីទាំងអស់ សឹងនៅលើគ្រែក្នុងទីនោះ ទេវតាទាំងឡាយ សែងគ្រែលើស្មានាំចេញទៅតាមលំដាប់ ។ ផ្ទៃអាកាសបិទបាំងដោយពិតានទាំងអស់ ព្រះចន្ទ ព្រះអាទិត្យ និងផ្កាយ សឹងមានស្នាមសុទ្ធតែមាសទាំងអស់ ។ ទង់ទាំងឡាយជាអនេក ដ៏វិចិត្រ ដូចជាអាវផ្កា ដែលគេលើកឡើងហើយ មានផ្កាឈូកធ្លាក់ចុះអំពីអាកាស ផ្កាផុសឡើងអំពីផែនដី ។ ព្រះចន្ទនិងព្រអាទិត្យក៏ប្រាកដ ទាំងផ្កាយក៏រុងរឿង ព្រះអាទិត្យត្រង់ជាក់តែមិនក្តៅដូចព្រះចន្ទ ។ ទេវតាទាំងឡាយ ក៏បូជាដោយ

គ្រឿងក្រអូប កម្រងផ្កាជាទិព្វមានក្លិនឈ្ងុយឈ្ងប់ផង ដោយគ្រឿងប្រគំផង ដោយការរាំច្រៀងផង ។ នាគ អសុរ ព្រហ្ម ក៏បូជាដ៏សមគួរតាមសេចក្តីអន់អាចសមគួរតាមកម្លាំង នាំចេញទៅនូវពុទ្ធមាតាដែលនិព្វានហើយ ។ ភិក្ខុនីទាំងអស់ជាឱរសព្រះសុគតដែលនិព្វានហើយ ជនទាំងឡាយនាំទៅខាងមុខ ឯព្រះនាងគោតមីដែលចិញ្ចឹមព្រះពុទ្ធ ទេវតាធ្វើនូវសក្ការៈហើយនាំចេញទៅខាងក្រោយ ។ ទេវតា មនុស្ស ព្រមទាំងនាគ អសុរ ព្រហ្ម ដើរខាងមុខ ឯព្រះពុទ្ធព្រមទាំងសាវកយាងទៅខាងក្រោយដើម្បីបូជាព្រះមាតា ។ បរិនិព្វានរបស់ព្រះនាងគោ-តមី ជាការណ៍អស្ចារ្យក្រៃពេក យ៉ាងណា បរិនិព្វានរបស់ព្រះពុទ្ធ មិនដូច្នោះទេ ។ ( ព្រោះថា ) ក្នុងពុទ្ធបរិនិព្វាន មិនមានព្រះពុទ្ធនិងពួកភិក្ខុ មានព្រះសារីបុត្តជាដើម ( ជាអធិបតីទេ ) ក្នុងគោតមីបរិនិព្វាន មានព្រះពុទ្ធនិងពួកភិក្ខុ មានព្រះសារីបុត្តជាដើម ( ជាអធិបតី ) ទេវតាទាំងឡាយ ធ្វើជើងថ្ករទាំងឡាយជាវិការៈនៃគ្រឿងក្រអូបទាំងអស់ ដេរដាសដោយលម្អិតមានក្លិនក្រអូបហើយបូជាសពភិក្ខុនីទាំងឡាយក្នុងទីនោះ ។ ចំណែកនៃសរីរាវយវៈសេសសល់និងឆ្អឹងដែលសេសសល់ ក៏ឆេះសុសអស់ គ្រានោះព្រះអានន្ទ បានពោលនូវវាចាដែលញុំាងសេចក្តីសង្វេគឲ្យកើតថា ព្រះនាងគោតមី ទៅកាន់សេចក្តីស្លាប់ទាំងសរីរៈរបស់ព្រះនាងក៏ឆេះសុសអស់ មិនយូរប៉ុន្មាន ព្រះពុទ្ធនឹងបរិនិព្វានជាប្រាកដដែរ ។ លំដាប់នោះ ព្រះអានន្ទនោះដែលព្រះពុទ្ធទ្រង់ដាស់តឿន ក៏បង្អោននូវព្រះធាតុរបស់ព្រះនាងគោតមី ដែលតម្កល់ទុកក្នុងបាត្ររបស់ព្រះនាងមកថ្វាយព្រះលោកនាថ ។ ព្រះពុទ្ធជាឥសីទី ៧ ទ្រង់ទទួលនូវព្រះធាតុទាំងឡាយ

នោះដោយព្រះហស្ត ហើយទ្រង់ត្រាស់ដូច្នេះថា ដើមឈើធំមានខ្លឹម កាលនៅរស់ ទាំងទំហំដើមក៏ធំ គប្បីបាក់ទៅ ព្រោះសភាវៈមិនទៀង យ៉ាងណា ព្រះនាងគោតមី ជាប្រធាននៃភិក្ខុនីសង្ឃ បរិនិព្វានហើយ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ អ្នកចូរមើលចុះ ព្រះពុទ្ធមាតាដែលបរិនិព្វានហើយ សល់តែសរីរៈទេ អ្នកកុំសោកខ្សឹកខ្សួលឡើយ ។ ព្រះនាងគោតមីនោះ ឆ្លងចាកសាគរ គឺសង្សារហើយ វៀរចាកសេចក្ដីក្ដៅក្រហាយ មានសេចក្ដីត្រជាក់ មានទុក្ខរលត់ហើយមិនមែន ព្រោះតែសេចក្ដីសោក របស់ពួកជនដទៃឡើយ ។ ព្រះនាងគោតមីភិក្ខុនីនោះជាបណ្ឌិត មានបញ្ញាច្រើន មានប្រាជ្ញាក្រាស់ មួយទៀត ព្រះនាងជាអ្នកដឹងនូវរាត្រីវែង គឺអាយុវែង ជាងភិក្ខុនីទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរដឹងយ៉ាងនេះចុះ ។ ព្រះនាងគោតមីស្ទាត់ក្នុងឫទ្ធិផង ស្ទាត់ក្នុងទិព្វសោតធាតុ និងចេតោបរិយញ្ញាណផង ដឹងបុព្វេនិវាសៈ ជម្រះទិព្វចក្ខុ មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ញាណក្នុងអត្ថផង ក្នុងធម៌ផង ក្នុងនិរុត្តិផង ក្នុងបដិភាណផង ដ៏បរិសុទ្ធិ ព្រោះហេតុនោះ អ្នកមិនគួរសោកស្ដាយ ព្រះនាងគោតមីនោះឡើយ ។ គតិរបស់បុគ្គលដែលមានចិត្តស្ងប់រម្ងាប់ តាមលំដាប់ រមែងមិនប្រាកដ ដូចដុំដែកដែលបុគ្គលដំហើយ ក៏ភ្លឺរុងរឿងដោយសារភ្លើង យ៉ាងណា គតិរបស់បុគ្គលមានចិត្តផុតចាកកិលេសហើយដោយប្រពៃ ឆ្លងចាកចំណងគឺកាមនិងឱឃៈ ដល់នូវអចលបទ គឺព្រះនិព្វានហើយ ក៏មិនប្រាកដយ៉ាងនោះដែរ ។ អ្នកទាំងឡាយ ចូរមានខ្លួនជាទីពឹងចុះ មានសតិប្បដ្ឋានជាអារម្មណ៍ចុះ ចូរចម្រើននូវសត្តពោជ្ឈង្គចុះ ចូរ

ធ្វើនូវទីបំផុតនៃកងទុក្ខចុះ ។

បានឮថា ព្រះមហាបជាបតិគោតមីភិក្ខុនីមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ មហាបជាបតិគោតមីថេរិយាបទាន ។

# ខេមាថេរិយាបទាន ទី ៨

[ ១៨ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុចំពោះធម៌ទាំងពួង ជាលោកនាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្នុងនគរហង្សវតី ដែលរុងរឿងដោយរតនៈផ្សេងៗ ខ្ញុំឆ្អែតស្កប់ស្កល់ហើយ ដោយសេចក្តីសុខច្រើន ។ ខ្ញុំចូលទៅគាល់ព្រះមហាវីរបុរស ហើយបានស្តាប់ធម្មទេសនា លំដាប់នោះ ខ្ញុំមានសេចក្តីជ្រះថ្លាកើតឡើង ហើយដល់នូវព្រះជិនស្រីជាទីពឹង ។ ខ្ញុំសូមអង្វរមាតាបិតា ហើយនិមន្តព្រះពុទ្ធជានាយក ព្រមទាំងព្រះសាវកមកឆាន់អស់ ៧ ថ្ងៃ ។ លុះកន្លង ៧ ថ្ងៃផុតទៅ ព្រះពុទ្ធជានរសារថី ទ្រង់តាំងភិក្ខុនីដែលឧត្តមជាងពួកភិក្ខុនី មានបញ្ញាច្រើន ក្នុងទីជាឯតទគ្គៈ ។ ខ្ញុំឮព្រះពុទ្ធវាចានោះហើយក៏រីករាយ បានធ្វើសក្ការៈចំពោះព្រះពុទ្ធ ជាមហេសីនោះទៀត ក្រាបចុះហើយប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះជិនស្រីទ្រង់ត្រាស់ចំពោះខ្ញុំថា សេចក្តីប្រាថ្នារបស់នាងសម្រេចហើយ សក្ការៈដែលនាងធ្វើហើយចំពោះតថាគត ព្រមទាំងព្រះសង្ឃជាសក្ការៈមានផលរាប់មិនបាន ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាកៈ នឹងឧប្បត្តិឡើងក្នុងលោក ។ នាងនឹងបានជាភិក្ខុនីឈ្មោះខេមា ជាធម្មទាយាទ ជាឱរស ជាធម្មនិម្មិតនៃព្រះសាស្តានោះ ដល់នូវទីជាឯតទគ្គៈ ។

ខ្ញុំលះបង់រាងកាយជារបស់មនុស្ស ហើយចូលទៅកើតក្នុងឋានតាវត្តិង្សដោយបុញ្ញកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនាផង ។ លុះខ្ញុំ

ច្យុតចាកឋានតាវត្តិង្សនោះហើយ ទើបទៅកើតក្នុងឋានយាមៈ លុះច្យុតចាកឋានយាមៈនោះហើយ ក៏ទៅកើតក្នុងតុសិត លុះច្យុតចាកឋានតុសិតនោះហើយ ក៏ទៅកើតក្នុងឋាននិម្មានរតី ទៅកើតក្នុងឋានបរនិម្មិតវសវត្តីបុរី ។ ខ្ញុំកើតក្នុងត្រកូលណាៗ ខ្ញុំបានធ្វើភាពជាមហេសីនៃពួកស្តេចក្នុងត្រកូលនោះៗ ព្រោះអានិសង្សនៃបុញ្ញកម្មនោះ ។ លុះច្យុតចាកអត្តភាពនោះហើយ បានធ្វើជាមហេសីនៃពួកស្តេចចក្កពត្តិផង នៃពួកស្តេចមានមណ្ឌលផង ក្នុងអត្តភាពជារបស់មនុស្ស ។ ខ្ញុំបានទទួលសម្បត្តិក្នុងទេវលោកទាំងឡាយផង ក្នុងមនុស្សលោកទាំងឡាយផង ដល់នូវសេចក្តីសុខក្នុងទីទាំងពួង ហើយអន្ទោលទៅក្នុងកប្បទាំងឡាយដ៏ច្រើន ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធវិបស្សីជាលោកនាយក មានព្រះនេត្រដ៏រុងរឿង ឃើញនូវពួកធម៌ទាំងអស់ទ្រង់កើតឡើងហើយ ។ ខ្ញុំចូលទៅគាល់ព្រះលោកនាយកនោះ ព្រះអង្គជានរសារថី បានស្តាប់ធម៌ដ៏ប្រសើរ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសាសនានៃព្រះពុទ្ធជាវីរបុរសនោះ ប្រកបព្យាយាមជាពហុស្សូតអស់ ១ ម៉ឺនឆ្នាំ ។ ខ្ញុំជាអ្នកឈ្លាសវៃក្នុងធម៌ជាបច្ចយាការ ក្លៀវក្លាក្នុងចតុរារិយសច្ច មានបញ្ញាដ៏ល្អិត ជាធម្មកថិកាដ៏វិចិត្រ ជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា ។ លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងឋានតុសិត ជាទេវតាមានយស គ្របសង្កត់ពួកទេវតាដទៃ ក្នុងឋានតុសិតនោះ ដោយផលនៃព្រហ្មចរិយធម៌ ។ ខ្ញុំទៅកើតក្នុងទីណាៗ ជាស្រីមានភោគច្រើន មានទ្រព្យច្រើន មានប្រាជ្ញា មានរូបល្អ ទាំងបរិស័ទក៏មាន

សណ្ដាប់ធ្នាប់ ។ ខ្ញុំតែងកើតទាន់សាសនានៃព្រះជិនស្រី ដោយបុញ្ញកម្ម និង សេចក្ដីព្យាយាមនោះ សម្បត្តិទាំងអស់ ខ្ញុំរកបានដោយងាយ ទាំងជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំ សូម្បីបុរសណាជាកស្តាររបស់ខ្ញុំ ដែលខ្ញុំដើរទៅក្នុងទីណាៗ កស្តានោះៗ មិនដែលមើលងាយខ្ញុំឡើយ ព្រោះផលនៃការប្រតិបត្តិរបស់ខ្ញុំ ។ ក្នុងកទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកោនាគមនៈ ទ្រង់មានផៅពង្សប្រសើរ មានយសច្រើន ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើង ។ កាលនោះ ជន ៣ នាក់ គឺនាងធនញ្ជនី ១ សុមេធា ១ ខ្ញុំ ១ កើតក្នុងត្រកូលដ៏ស្តុកស្តម្ភក្នុងនគរពារាណសី ។ យើងទាំងឡាយជាអ្នកកសាងវិហារ ហើយឧទ្ទិសថ្វាយចំពោះព្រះពុទ្ធព្រមទាំងព្រះសង្ឃ បានវេរថ្វាយសង្ឃារាមនិងទាន រាប់ដោយពាន់ដ៏ច្រើន ចំពោះព្រះមុនី ។ លុះយើងទាំងឡាយគ្រប់គ្នា ច្យុតចាកអត្តភាពនេះហើយ បានទៅកើតឯឋានតាវត្តិង្ស ដល់នូវភាពជាបុគ្គលប្រសើរដោយយស ទាំងក្នុងមនុស្សលោកក៏ដូចគ្នា ។ ក្នុងកប្បនេះដដែល ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សប្រសើរ មានយសធំ ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើង ។ គ្រានោះ ព្រះរាជាក្នុងដែនកាសី ព្រះនាមកិកី ជាធំលើប្រជា-ជនក្នុងនគរពារាណសី ជាបុរីដ៏ឧត្តម ជាឧបដ្ឋាករបស់ព្រះពុទ្ធជាមហេសី ។ ខ្ញុំត្រូវជាធីតាច្បងរបស់ព្រះរាជាអង្គនោះ ដែលគេឮប្រាកដថា ឈ្មោះសមណី ខ្ញុំបានស្ដាប់ព្រះធម៌របស់ព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ ព្រះវររាជបិតា ទ្រង់ពុំអនុញ្ញាតដល់យើង គ្រានោះ យើងជាអ្នកមិនខ្ជិលប្រអូសទេ ប្រព្រឹត្តព្រហ្មចរិយសម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំ ក្នុងផ្ទះ ជាព្រះរាជកញ្ញា

ឋិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ប្រាំពីរ ។ ( ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះ ធីតាទាំង ៧ នោះ ) គឺខ្ញុំ ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ប្រាំពីរ ។ ក្នុងកាលមួយ ព្រះអង្គជាអាទិច្ចវង្សរបស់ជន កំពុងសម្តែងធម៌ ខ្ញុំបានស្តាប់មហានិទានសូត្រ ដែលជាសូត្រមិនទាន់ដែលកើតមាន ហើយក៏រៀនយកនូវសូត្រនោះ ។ ខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ ក៏ទៅកើតក្នុងឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ។ លុះដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានជាធីតាជាទីពេញចិត្ត ជាទីស្រឡាញ់ ជាទីប្រោសប្រាណរបស់ស្តេចព្រះនាមមទ្ទះ ក្នុងបុរីដ៏ឧត្តមឈ្មោះសាគលា ។ ការក្សេមក្សាន្តកើតមានឡើងក្នុងបុរីនោះ ដំណាលគ្នានឹងការដែលខ្ញុំកើតឡើង ព្រោះហេតុនោះ ពាក្យថានាងខេមា ជាឈ្មោះរបស់ខ្ញុំ កើតឡើងដោយគុណ ។ កាលណា ខ្ញុំដល់នូវវ័យដ៏ចម្រើន ស្អិតស្អាងរូបនិងពណ៌ ក្នុងកាលនោះ ព្រះវររាជបិតា បានប្រទានខ្ញុំទៅព្រះបាទពិម្ពិសារ ។ ខ្ញុំជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ព្រះរាជាអង្គនោះ ជាស្រីត្រេកអរក្នុងការប្រកាន់រូប ខ្ញុំមិនដែលបានចូលទៅគាល់ព្រះពុទ្ធ ព្រះអង្គមានសេចក្តីអាណិតធំ ដោយខ្ញុំគិតឃើញថា ព្រះពុទ្ធជាអ្នកពោលទោសចំពោះរូប ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ញុំាងអ្នកច្រៀង ឲ្យច្រៀងសរសើរវត្ត

វេឡុវ័នឲ្យខ្ញុំស្តាប់ ដោយឧបាយក្នុងការអនុគ្រោះចំពោះខ្លួនខ្ញុំ ដូច្នេះថា ពួកយើងសម្គាល់ថា បុគ្គលណាមិនឃើញនូវវត្តវេឡុវ័នជាទីរីករាយ ជាលំនៅនៃព្រះសុគតទេ នន្ទនឧទ្យាន ក៏ឈ្មោះថាបុគ្គលនោះមិនឃើញដែរ ។ វត្តវេឡុវ័ន ជាទីរីករាយដ៏ក្រៃលែងរបស់ប្រជាជន បុគ្គលណាបានឃើញហើយ ឧទ្យានឈ្មោះនន្ទនៈ ជាទីរីករាយដ៏ក្រៃលែងរបស់សម្តេចអមរិន្ទ្រាធិរាជ ក៏ឈ្មោះថាបុគ្គលនោះឃើញហើយដែរ ។ ពួកទេវតាលះបង់នន្ទនឧទ្យាន ចុះមកលើផ្ទៃផែនដី បានឃើញវត្តវេឡុវ័នជាទីរីករាយហើយ ក៏អស្ចារ្យចំឡែកមិនឆ្អែតក្នុងការមើល ។ វត្តវេឡុវ័ននេះ កើតឡើងដោយបុណ្យព្រះរាជាដែលស្អិតស្អាងហើយ ដោយបុណ្យរបស់ព្រះពុទ្ធ នរណាឡើយអាចពោលនូវការសន្សំគុណរបស់វត្តវេឡុវ័នដោយសព្វគ្រប់បាន ។

គ្រានោះ ខ្ញុំឮនូវសមិទ្ធិនៃវត្តវេឡុវ័ន ជារឿងនាំមកដល់ត្រចៀកនិងចិត្តរបស់ខ្ញុំ ខ្ញុំមានប្រាថ្នាចង់ទៅមើលឧទ្យាននោះ ទើបក្រាបទូលព្រះរាជា ។ គ្រានោះ ព្រះរាជាម្ចាស់ផែនដី អង្គនោះ ទ្រង់បញ្ជូនខ្ញុំដែលកំពុងខ្វល់ខ្វាយ ដើម្បីទៅមើលឧទ្យានដោយបរិវារច្រើន ដោយព្រះបន្ទូលថា ម្នាលនាងមានភោគច្រើន ព្រៃណាដែលគេត្រេកអរហើយ ដោយពន្លឺព្រះសុគត រមែងភ្លឺដោយសិរីគ្រប់កាលទាំងពួង ចូរនាងទៅចុះ ចូរនាងមើលព្រៃនោះដែលជាទីត្រេកអរនៃភ្នែក។ ព្រះមុនីសម្ពុទ្ធ ស្តេចទៅកាន់បុរីដ៏ឧត្តម ឈ្មោះគិរិព្វជៈ ដើម្បីបិណ្ឌបាតក្នុងកាលណា ខ្ញុំក៏ចូលទៅមើលវត្តវេឡុវ័នក្នុងកាលនោះ ។ គ្រានោះ វត្តវេឡុវ័ននោះ មានដើមឈើរីកផ្កាស្គុះស្គាយដែលទ្រហឹងដោយកមរជាតិផ្សេងៗប្រកប

ដោយចម្រៀងនៃសត្វតាវៅ ដែលពួកក្ងោកកំពុងពង់ពេន ។ វត្តវេឡុវ័ន ជាវត្តមានសំឡេងតិច មិនកុះករដោយមនុស្ស ស្អិតស្អាងដោយ ទីចង្រ្កមផ្សេងៗ មានកុដិ និងមណ្ឌបរៀបជាជួររៀងរាយ ដែលយោគីវីរបុរសគួរត្រេកអរដ៏វិសេស ។ កាលខ្ញុំដើរទៅ បានសម្គាល់ឃើញថា ភ្នែករបស់ខ្ញុំប្រកបដោយផល ក្នុងគ្រានោះ ខ្ញុំបានឃើញភិក្ខុកំលោះមួយរូបជាអ្នកព្យាយាម ខ្ញុំគិតថាភិក្ខុនេះឋិតនៅក្នុងព្រៃ គួរីករាយបែបនេះ ប្រកបដោយរូបជាទីត្រេកអរ ហាក់ដូចជារូបកាលនៅក្នុងវ័យក្មេង ។ ឃើ ! ភិក្ខុត្រងោលនេះ ឃុំសង្ឃាដី អង្គុយពិនិត្យទៀបគល់ឈើ លះបង់នូវតម្រេកដែលកើតអំពីអារម្មណ៍ ។ ធម៌នេះជាធម៌ដ៏ល្អក្រៃងគ្រហស្ថចាស់ទុំ បរិភោគកាមសុខតាមសប្បាយ គប្បីប្រព្រឹត្តក្នុងកាលខាងក្រោយទេឬ ។ ខ្ញុំដឹងច្បាស់ថា ព្រៃនេះស្ងាត់ ហើយចូលទៅកាន់គន្ធកុដិ ជាលំនៅព្រះជិនស្រី បានឃើញព្រះជិនស្រី ដូចជាព្រះអាទិត្យកំពុងរះឡើង ។ ខ្ញុំបានឃើញព្រះអង្គគង់ជាសុខ តែមួយព្រះអង្គ ដែលស្រីដ៏ប្រសើរកំពុងបក់ថ្វាយ ហើយគិតយ៉ាងនេះថា ព្រះជិនស្រីនេះ ជាបុគ្គលប្រសើរជាងជន មិនសៅហ្មងទេ ។ នាងកញ្ញានោះ មានវណ្ណៈដូចមាស មានមាត់នឹងភ្នែកដូចត្របកផ្កាឈូក មានបបូរមាត់ក្រហម មានមុខស្រស់បស់ ជាទីត្រេកអរនៃចិត្តនិងភ្នែក មានដងខ្លួនល្អ មានសម្បុរដូចមាស មានមាត់ល្អ មានស្តនល្អ មានអាការដូចផ្កាឈូក មានពាក់កណ្តាលដងខ្លួនមូលក្លំ មានត្រគាកល្អ មានភ្លៅគួរជាទីត្រេកអរ មានគ្រឿងស្អិតស្អាងល្អ ។ មានសំពត់បង់លើស្នាពណ៌ក្រហម មានសំពត់សម្លៀកសាច់ម៉ដ្ឋ ទាំងមានពណ៌ខៀវ ជាកញ្ញាប្រដាប់ដោយអាភរណៈគ្រប់បែប ដោយ

សភាពគួរមើល មិនចេះឆ្អែត ។ លុះខ្ញុំឃើញយ៉ាងនេះហើយ ទើបគិតថា ឱហ្ន៎ ស្រីនេះ មានរូបល្អណាស់ តាំងពីកាលណាមក អញមិនដែលឃើញដោយភ្នែកនេះទេ ។ លំដាប់នោះ ស្រីនោះ ត្រូវជរាគ្របសង្កត់ ទៅជាមានសម្បុរប្រែក មានមាត់វៀច មានធ្មេញបាក់ មានក្បាលស្កូវព្រោង មានមាត់កខ្វក់ ប្រកបដោយទឹកមាត់ហៀរកក្អាក់ ។ មានស្លឹកត្រចៀកខ្ទូរ មានភ្នែកសល្អក់ មានស្តនមិនល្អ ស្វិតយុរយារ មានអវយវៈទាំងអស់ជ្រួញជ្រីវ មានសាច់ទុះ មានរាងកាយរវាមដោយសរសៃ ។ មានខ្នងកោង មានឈើច្រត់ជាគម្រប់ពីរ មានសម្បុរលឿង ស្ងេកស្ងាំង ស្គាំងស្គម ញាប់ញ័រចំប្រប់ ដួលដេកស្រេតឹក ដកដង្ហើមផ្អិតៗ ។ លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគដ៏ចំឡែក ជាគ្រឿងព្រឺព្រួចរោមថា ប៉ឺយ ពួកជនពាលតែងរីករាយចំពោះរូបណា រូបនោះជារបស់មិនស្អាត ។ ក្នុងកាលនោះឯង ព្រះបរមសាស្តា ប្រកបដោយមហាករុណា ឃើញខ្ញុំមានចិត្តសង្វេគ ព្រះអង្គក៏មានព្រះហឫទ័យរីករាយត្រេកអរ បានសម្តែងនូវគាថាទាំងនេះថា ម្នាលនាងខេមា ចូរនាងមើលគ្រោងកាយ ជារបស់ក្តៅ ជារបស់មិនស្អាត ជារបស់ស្អុយរលួយ ដែលហូរខ្ទុរចុះខ្ទុរចេញ ដែលមានតែពួកជនពាលទេត្រេកត្រអាល ។ នាងចូរអប់រំចិត្តដោយអសុភសញ្ញា ឲ្យជាចិត្តមានអារម្មណ៍មូលតែមួយ ឲ្យជាសមាធិចិត្តដ៏ល្អ ចូរនាងមានកាយគតាសតិចុះ ចូរនាងច្រើនដោយនិព្វិទានុបស្សនាចុះ ។ រូបនេះយ៉ាងណា សរីរៈនៃនាងនុ៎ះក៏យ៉ាងនោះ សរីរៈនៃនាងនុ៎ះយ៉ាងណា រូបនេះក៏យ៉ាងនោះដែរ នាងចូរបន្សាត់នូវសេចក្តីប្រាថ្នាក្នុងកាយទាំងខាងក្នុងនិងខាងក្រៅចេញ ។ មួយទៀត ចូរនាងអប់រំនូវអនិមិត្តសមាធិ លះ

បង់បោលនូវមានានុស័យ តពីនោះ នាងនឹងបានជាបុគ្គលស្ងប់ ព្រោះយល់ច្បាស់នូវមានានុស័យ ។

ពួកជនណា ដែលត្រេកអរដោយរាគៈ រមែងធ្លាក់ទៅកាន់ខ្សែ
គឺតណ្ហាដូចជាសត្វពីងពាងដែលជាប់នឹងបណ្ដាញ ដែលខ្លួនឯង
ធ្វើ លុះតែពួកជនទាំងនោះ ជាអ្នកមិនមានអាល័យ កាត់នូវខ្សែ
គឺតណ្ហានុ៎ះ លះបង់នូវកាមសុខហើយ ទើបចេញបួសបាន ។

លំដាប់នោះ ព្រះមានព្រះភាគ ជានរសារថី ជ្រាបច្បាស់នូវខ្ញុំថា ជាអ្នកមានចិត្តស្រួល ក៏ទ្រង់សម្ដែងនូវមហានិទានសូត្រ ដើម្បីបន្ទោរបង់ ( នូវកិលេស ) របស់ខ្ញុំ ។ លុះខ្ញុំបានស្ដាប់នូវព្រះសូត្រដ៏ប្រសើរនោះហើយ ក៏រឭកឃើញនូវសញ្ញាក្នុងកាលមុន ខ្ញុំឋិតនៅក្នុងទីនោះ បានជម្រះនូវធម្មចក្ខុគឺសោតាបត្តិផល ជាគុណដ៏ស្ងប់ ។ ខ្ញុំក្រាបចុះទៀបបាទមូលនៃព្រះសម្ពុទ្ធជាមហេសីក្នុងខណៈនោះភ្លាម បានពោលពាក្យនេះ ដើម្បីសម្ដែងទោសថា បពិត្រព្រះអង្គទ្រង់ឃើញនូវហេតុទាំងពួង ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់មានករុណាជាលំនៅ ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់មានសង្សារឆ្លងហើយ ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គ ទ្រង់ឲ្យនូវអមតធម៌ ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះព្រះអង្គ ។ ពួកជនដែលស្ទុះទៅកាន់ព្រៃស្បាត គឺទិដ្ឋិ ដែលវង្វេងឈ្ងប់ក្នុងកាមរាគ ព្រះអង្គបានទូន្មាន ឲ្យត្រេកអរក្នុងវិន័យដោយឧបាយដ៏ប្រពៃ ។ ពួកសត្វ ដែលឃ្លាងចាកប្រយោជន៍ ព្រោះមិនបានជួបប្រទះនូវព្រះមហេសី ដែលប្រាកដដូចជាព្រះ

អង្គទេ រមែងរងសេចក្តីទុក្ខធំក្នុងសាគរគឺសង្សារ ។ ក្នុងកាលណា ខ្ញុំមិនបាន ឃើញព្រះពុទ្ធជាទីពឹងរបស់សត្វលោក ព្រះអង្គមិនមានកងកិលេស ដល់នូវទី បំផុតនៃមរណៈ ខ្ញុំនឹងសម្តែងទោសនោះ មានអត្ថដ៏ពីរោះ ក្នុងកាលនោះ ។ ខ្ញុំព្រះអង្គឥតមានវង្វៀសចំពោះព្រះពុទ្ធ ព្រះអង្គមានប្រយោជន៍ធំ ឲ្យនូវគុណដ៏ ប្រសើរថា ព្រះអង្គឥតប្រយោជន៍ ដូច្នេះឡើយ ខ្ញុំជាអ្នកត្រេកអរក្នុងរូប ទើប មិនបានចូលមកគាល់ព្រះអង្គ ខ្ញុំនឹងសូមសម្តែងនូវទោសនោះ ។ កាលនោះ ព្រះ ពុទ្ធជិនស្រី មានសំឡេងពីរោះ ប្រកបដោយមហាករុណា ស្រោចខ្ញុំដោយទឹក គឺអម្រឹត ហើយបានត្រាស់ថា ម្នាលនាងខេមា ចូរនាងឈប់សិន ។ ក្នុងកាល នោះ ខ្ញុំឱនប្រណម្យដោយត្បូង ធ្វើប្រទក្សិណចំពោះព្រះអង្គហើយ ទើបដើរចេញ ទៅ លុះខ្ញុំឃើញព្រះនរបតីហើយ ខ្ញុំពោលពាក្យនេះថា បពិត្រព្រះអង្គទូន្មាន នូវសត្រូវ ឱហ្ន៎ ! ឧបាយនេះ ព្រះអង្គទ្រង់ព្រះចិន្តាហើយដោយប្រពៃ បពិត្រ ព្រះអង្គជាអ្នកប្រាជ្ញ ការរលត់ ( កិលេស ) ដែលខ្ញុំម្ចាស់ប្រាថ្នាដើម្បីមើលនូវ វត្តវេឡុវ័ន ក៏បានឃើញហើយ ។ បពិត្រព្រះរាជា បើព្រះអង្គទ្រង់សព្វព្រះរាជ ហឫទ័យចំពោះសាសនារបស់ព្រះពុទ្ធ ជាបុគ្គលនឹងដឹងនោះ បពិត្រព្រះអង្គជា អ្នកប្រាជ្ញ ខ្ញុំម្ចាស់ជាអ្នកនឿយណាយក្នុងរូប ដោយព្រះវាចា នឹងសូមបួសក្នុង កាលឥឡូវនេះ ។

## ចប់ ភាណវារៈទី ២ ។

កាលនោះព្រះរាជាជាម្ចាស់លើផែនដី ផ្គងអញ្ជលីត្រាស់ថា ម្នាលនាងដ៏ចម្រើន ខ្ញុំអនុញ្ញាតឲ្យនាង សូមបព្វជ្ជារបស់នាងសម្រេចចុះ ។ ក្នុងកាលនោះ ខ្ញុំបួសរួចហើយ លុះដល់ខែ ៧ ប្រាកដហើយ ខ្ញុំបានឃើញនូវការកើតឡើងនិងការបែកធ្លាយនៃប្រទីប ហើយក៏មានចិត្តតក់ស្លុតរន្ធត់ ។ ខ្ញុំជាអ្នកនឿយណាយក្នុងសង្ខារទាំងពួង ឆ្លៀវឆ្លាសក្នុងបច្ចយាការ កន្លងផុតនូវឱឃៈទាំង ៤ ហើយបាននូវភាពនៃខ្លួនជាព្រះអរហន្ត ។ ខ្ញុំជាស្រីស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុ ក៏ខ្ញុំបានជម្រះហើយ អាសវៈទាំងអស់របស់ខ្ញុំអស់រលីងហើយ ឥឡូវនេះភពថ្មីទៀតមិនមានទេ ញាណរបស់ខ្ញុំដ៏បរិសុទ្ធក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណកើតឡើងហើយក្នុងពុទ្ធសាសនា ។ ខ្ញុំជាស្រីវាងវៃក្នុងវិសុទ្ធិទាំងឡាយផង ឆ្លៀវ-ឆ្លាក្នុងកថាវត្ថុទាំងឡាយផង ស្គាល់ន័យក្នុងអភិធម្មផង ដល់នូវការស្ទាត់ក្នុងសាសនាផង ។ លំដាប់នោះ ខ្ញុំដែលព្រះរាជាម្ចាស់ដែនកោសល ទ្រង់សាកសួរទៀបទីក្លោងទ្វារ ក៏ដោះនូវប្រស្នាទាំងឡាយដ៏ល្អិតតាមសេចក្តីពិត ។ គ្រានោះព្រះរាជានោះ ទ្រង់ចូលទៅគាល់ព្រះសុគតហើយទូលសួរ ឯព្រះពុទ្ធ ក៏ទ្រង់ដោះស្រាយ ដូចខ្ញុំបានដោះស្រាយប្រស្នាទាំងនោះដែរ ។ ព្រះជិនស្រី ព្រះអង្គជាបុគ្គលឧត្តមជាងជន ត្រេកអរចំពោះគុណនោះ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈថា ខេមាភិក្ខុនីនេះ ប្រសើរផុតជាងភិក្ខុនីទាំងឡាយដែលមានប្រាជ្ញាច្រើន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។

ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខេមាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ខេមាថេរិយាបទាន ។

# ឧប្បលវណ្ណាថេរិយាបទានទី ៩

[ ១៩ ] ឧប្បលវណ្ណាភិក្ខុនី ដល់នូវត្រើយនៃឫទ្ធិ បានថ្វាយបង្គំព្រះបាទាព្រះសាស្តា ហើយពោលនូវពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ឆ្លងផុតនូវជាតិសង្សារហើយ ដល់នូវព្រះនិព្វាន ជាទីមិនកម្រើក ខ្ញុំម្ចាស់សូមក្រាបទូលនូវទុក្ខទាំងពួងរបស់ខ្ញុំម្ចាស់ដែលអស់ហើយ ។ ពួកបរិស័ទទាំងប៉ុន្មាន ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី កំហុសរបស់ខ្ញុំម្ចាស់ មានចំពោះពួកជនណា សូមពួកជននោះ អត់ទោសក្នុងទីចំពោះព្រះភក្ត្រនៃព្រះជិនស្រីឲ្យទាន ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់កំពុងអន្ទោលទៅក្នុងសង្សារ បើខ្ញុំម្ចាស់មានសេចក្តីភ្ជាត់ភ្លាំង ខ្ញុំម្ចាស់សូមអង្វរ សូមព្រះអង្គអត់ទោសចំពោះកំហុសនៃខ្ញុំម្ចាស់នោះ ។ ម្នាលនាងអ្នកធ្វើតាមសាសនារបស់តថាគត បើដូច្នោះ ចូរនាងសម្តែងនូវឫទ្ធិចុះ ចូរនាងញុំាងបរិស័ទទាំង ៤ ឲ្យកាត់នូវសេចក្តីសង្ស័យទាំងប៉ុន្មានក្នុងថ្ងៃនេះចុះ ។ បពិត្រព្រះអង្គជាមហាវីរបុរសទ្រង់មានបញ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿង ខ្ញុំម្ចាស់ជាធីតារបស់ព្រះអង្គ ចំណែកខាងអំពើដ៏ច្រើន ដែលគេកម្រធ្វើបាន ខ្ញុំព្រះអង្គបានធ្វើឲ្យជាអំពើរឹតតែកម្រក្រៃលែង ។ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញាចក្ខុ សម្បុររបស់ខ្ញុំម្ចាស់ដូចជាសម្បុរនៃផ្កាឧប្បល ខ្ញុំម្ចាស់មានឈ្មោះថា ឧប្បលវណ្ណា ជាធីតារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទា ។ ព្រះរាហុលត្ថេរនិងខ្ញុំម្ចាស់ ធ្លាប់កើតក្នុងភពតែមួយអស់រយនៃជាតិជាច្រើន ជាអ្នកមានចិត្តនិងឆន្ទៈស្មើគ្នា ។ ការកើតឡើងក្នុងទីជាមួយគ្នាក៏មាន ក្នុងជាតិជាមួយគ្នាក៏មាន លុះដល់បច្ឆិមភពជនទាំងពីរនាក់កើតដោយឈ្មោះ ( ផ្សេងគ្នា ) ។ ព្រះរាជបុត្ត បានមកជា

កុមារឈ្មោះរាហុល ខ្ញុំម្ចាស់បានមកជាធីតាឈ្មោះឧប្បលវណ្ណា បពិត្រព្រះអង្គជាវីរបុរស សូមព្រះអង្គទតឫទ្ធិនៃខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់នឹងសម្តែងកម្លាំងថ្វាយព្រះសាស្តា ។ នាងឧប្បលវណ្ណា ដាក់មហាសមុទ្ទទាំង ៤ លើផ្ទៃបាតដៃហាក់ដូចកូនក្មេងលេងប្រេងដែលតាំងនៅលើបាតដៃ ។ នាងឧប្បលវណ្ណា ធ្វើផែនដីដាក់លើផ្ទៃបាតដៃ ដូចជាក្មេងជំទង់ដកនូវស្មៅយាប្លង់ដ៏វិចិត្រ ។ នាងឧប្បលវណ្ណា បាំងនូវបាតដៃស្មើចក្កវាឡលើក្បាល ហើយញុំាងគ្រាប់ភ្លៀងមានពណ៌ផ្សេងៗឲ្យធ្លាក់ចុះ ។ នាងធ្វើផែនដីជាត្បាល់ ធ្វើគ្រួសជាស្រូវ ធ្វើភ្នំសិនេរុជាអង្រែ ដូចក្មេងស្រីបុកស្រូវ ។ ខ្ញុំម្ចាស់ឈ្មោះឧប្បលវណ្ណា ជាធីតារបស់ព្រះពុទ្ធដ៏ប្រសើរ ជាអ្នកស្ទាត់ក្នុងអភិញ្ញាទាំងឡាយ ជាអ្នកធ្វើតាមសាសនារបស់ព្រះពុទ្ធអង្គ ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំម្ចាស់សូមធ្វើនូវវិកុព្វនឫទ្ធិផ្សេងៗសម្តែងថ្វាយព្រះលោកនាយក ហើយប្រកាសនូវនាមនិងគោត្ត ទើបថ្វាយបង្គំព្រះបាទាព្រះអង្គ បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុឫទ្ធិផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុក៏ខ្ញុំម្ចាស់ជម្រះហើយ អាសវៈទាំងអស់ ក៏អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានទៀតទេ ។ ញាណរបស់ខ្ញុំម្ចាស់ដ៏ទូលាយស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ តាមសភាពរបស់ព្រះពុទ្ធជាមហេសី ។ បពិត្រព្រះមហាមុនី ព្រះអង្គធ្លាប់សម្តែងនូវសង្គ្រាមចំពោះព្រះជិនស្រីដ៏ប្រសើរទាំងឡាយក្នុងកាលមុន កិច្ចការដ៏ក្រៃលែងច្រើនយ៉ាងរបស់ខ្ញុំម្ចាស់ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី អំពើ

ណាមានក្នុងកាលមុនដែលខ្ញុំម្ចាស់ធ្វើហើយ សូមព្រះអង្គរឭកនូវអំពើជាកុសល របស់ខ្ញុំម្ចាស់នោះ បពិត្រព្រះមហាវីរបុរស បុណ្យដែលខ្ញុំម្ចាស់សន្សំទុកហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់វៀរ ( នូវអំពើ ) ក្នុងទីមិនគួរ ហើយបានទាត់ចោលនូវអនាចារៈ ជីវិតដ៏ឧត្តម ដែលខ្ញុំម្ចាស់លះបង់ហើយដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានជីវិតដល់ខ្ញុំម្ចាស់អស់ ១០ ពាន់កោដិ ទាំងខ្លួនខ្ញុំម្ចាស់ ដែលខ្ញុំម្ចាស់បានលះបង់ហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ គ្រានោះ បរិស័ទទាំងអស់ស្ងប់ស្ងែងក្រៃលែង ធ្វើអញ្ជលីដោយត្បូងពោលថា បពិត្រនាងម្ចាស់ សេចក្តីព្យាយាមមានឫទ្ធិថ្លឹងមិនបានដែលនាងធ្វើហើយ តើដូចម្តេច ។

ក្នុងកប្បទី ១ សែន អំពីកប្បនេះ កាលនោះខ្ញុំកើតជាកញ្ញានៃនាគឈ្មោះនាងវិមលា ដែលគេសន្មតហៅថាស្រីល្អជាងនាគកញ្ញាទាំងឡាយ ។ ពស់ធំឈ្មោះមហានាគ ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី បាននិមន្តព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានតេជះច្រើន ព្រមទាំងសាវ័ក ។ មហានាគនោះ បានរៀបចំនូវមណ្ឌបជាវិការៈនៃកែវផង នូវបល្ល័ង្កជាវិការៈនៃកែវផង នូវគ្រឿងឧបភោគជាវិការៈនៃកែវដែលលាយដោយខ្សាច់ជាវិការៈនៃកែវផង នូវផ្លូវដែលស្អិតស្អាងដោយទង់ជ័យជាវិការៈនៃកែវផង ហើយប្រគំដោយតូរ្យតន្ត្រីទទួលព្រះសម្ពុទ្ធ ។ ចំណែកខាងព្រះលោកនាយក ដែលបរិស័ទទាំង ៤ បានហែហមហើយ ទ្រង់គង់លើអាសនៈដ៏ប្រសើរ ក្នុងលំនៅនៃមហានាគ ។ ស្តេចនាគបានថ្វាយនូវបាយទឹកផង នូវភោជនដែលគួរបរិភោគមានថ្លៃច្រើនផង នូវ

ពរដ៏ប្រសើរផង ចំពោះព្រះពុទ្ធទ្រង់មានយសធំ ។ លុះព្រះសម្ពុទ្ធនោះទ្រង់សោយហើយ ទ្រង់លាងបាត្រ ហើយធ្វើអនុមោទនាដោយ ឧបាយនៃប្រាជ្ញាថា បូរនាងនាគកញ្ញាមានឫទ្ធិច្រើនចុះ ។ នាងនាគកញ្ញាបានឃើញព្រះសព្វញ្ញុពុទ្ធដែលទ្រង់ស្រស់បស់ មានយសច្រើន ចិត្តក៏ជ្រះថ្លាចំពោះព្រះសាស្តាផង ចិត្តក៏ប្រតិព័ទ្ធចំពោះព្រះសាស្តាផង ក្នុងខណៈនោះ ព្រះសម្ពុទ្ធជាមហាវីរបុរស ព្រះនាមបទុមុត្តរៈជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំ ទ្រង់បង្ហាញនូវភិក្ខុនីដោយឫទ្ធិ ។ ភិក្ខុនីនោះក្លៀវក្លា សម្តែងនូវឫទ្ធិច្រើនប្រការ ខ្ញុំក៏រីករាយ ត្រេកអរ បានពោលពាក្យនេះចំពោះព្រះសាស្តាថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ខ្ញុំម្ចាស់បានឃើញឫទ្ធិទាំងនេះ ដែលរាប់ថាក្រៃលែងជាងឫទ្ធិឯទៀត ភិក្ខុនីនោះ ក្លៀវក្លាដោយឫទ្ធិខាំងម៉្លេះ តើដោយប្រការដូចម្តេច ។

ភិក្ខុនីនេះ ជាធីតា ជាឱរស កើតអំពីមាត់របស់តថាគត ទើបជាភិក្ខុនីមានឫទ្ធិច្រើន ជាអ្នកធ្វើតាមអនុសាសនីរបស់តថាគត បានជាមានសេចក្តីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ។

លុះខ្ញុំស្តាប់ព្រះវាចានៃព្រះពុទ្ធហើយ ក៏ត្រេកអរពោលនូវពាក្យយ៉ាងនេះថា សូមឲ្យខ្ញុំម្ចាស់ជាស្ត្រីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ប្រាកដដូចជាភិក្ខុនីនោះ ។ បពិត្រព្រះអង្គជានាយក ខ្ញុំម្ចាស់មានចិត្តអរសប្បាយរីករាយ មានចិត្តខ្ពង់ខ្ពស់ សូមឲ្យបានដូចភិក្ខុនីនេះក្នុងកាលអនាគតពុំខាន ។ ( ខ្ញុំបានថ្វាយ ) នូវបល្ល័ង្កជាវិការៈនៃកែវមណីផង នូវមណ្ឌបដ៏ក្លីផ្ទកផង ហើយញ៉ាំងព្រះពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់ឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ។ ខ្ញុំបូ

ជាផ្កាឧប្បលឈ្មោះអរុណ ជាផ្កាដ៏ប្រសើររបស់ពួកនាគ ចំពោះព្រះពុទ្ធជាលោកនាយក ហើយសូមឲ្យពណ៌សម្បុររបស់ខ្ញុំដូចផ្កានេះ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងឋានមនុស្ស បានថ្វាយបិណ្ឌបាតដែលបិទបាំងដោយផ្កាឧប្បលទាំងឡាយចំពោះព្រះពុទ្ធជាសយម្ភូ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយកព្រះនាមវិបស្សី មានព្រះនេត្រដ៏ភ្លឺថ្លា មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ទ្រង់កើតឡើង ។ ក្នុងកាលនោះ ខ្ញុំបានកើតជាសេដ្ឋីធីតាក្នុងបុរីដ៏ឧត្តមឈ្មោះពារាណសី បាននិមន្តព្រះសម្ពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃ ខ្ញុំថ្វាយមហាទាន បូជាព្រះពុទ្ធជានាយកដោយផ្កាឧប្បលទាំងឡាយ ហើយប្រាថ្នាឲ្យមានពណ៌សម្បុរល្អដូចផ្កាឧប្បលទាំងនោះ ។ ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសច្រើន ប្រសើរជាងពួកជនអ្នកពោល ទ្រង់កើតឡើង ។ គ្រានោះព្រះរាជាដែនកាសីព្រះនាមកិកី ជាឥស្សរៈលើប្រជាជនក្នុងពារាណសីបុរីដ៏ប្រសើរ បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។ ខ្ញុំជាធីតាទី ២ របស់ព្រះរាជាអង្គនោះ ឈ្មោះនាងសមណីគុត្តា បានស្តាប់ធម៌របស់ព្រះពុទ្ធជិនស្រី ជាបុគ្គលប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ ក្នុងគ្រានោះព្រះវររាជបិតារបស់យើងទ្រង់មិនអនុញ្ញាត យើងក៏មិនខ្ជិលច្រអូស ប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំនៅក្នុងផ្ទះ ជាព្រះរាជកញ្ញាឋិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការ

បម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ប្រាំពីរ ។ ( ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះ ធីតាទាំងនោះបានមកជា ) ខ្ជុនខ្ញុំ ១ នាងខេមាមានប្រាជ្ញា ១ បដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ប្រាំពីរ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងមនុស្សត្រកូលធំ បានថ្វាយនូវសំពត់សាច់ម៉ដ្ឋមានពណ៌លឿងដល់ព្រះអរហន្ត។ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងអរិដ្ឋបុរីក្នុងត្រកូលព្រាហ្មណ៍ ជាធីតានៃតិរិដិវច្ឆសេដ្ឋី ឈ្មោះនាងឧម្មាទន្តី ជាទីពេញចិត្ត ( របស់ជន ) លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងជនបទក្នុងត្រកូល ១ ជាអ្នកខ្វល់ខ្វាយមិនជាអ្នកស្តុកស្តម្ភណាស់ណាទេ ។ គ្រានោះ ខ្ញុំថែរក្សានូវស្រូវសាលី ខ្ញុំបានឃើញព្រះបច្ចេកសម្ពុទ្ធ ហើយថ្វាយលាជ ៥០០ កន្ទោង ដែលគ្របដោយផ្កាឈូក ហើយប្រាថ្នានូវកូន ៥០០ រូប ខ្ញុំថ្វាយទឹកឃ្មុំដល់ព្រះពុទ្ធជាសយម្ភូ ព្រោះតែកូនទាំងនោះ លុះច្យុតចាកអត្តភាពនោះហើយ បានមកកើតក្នុងត្របកផ្កាឈូកនៅក្នុងព្រៃ ។ ខ្ញុំបានជាមហេសីរបស់ស្តេចដែនកាសីដែលគេធ្វើសក្ការៈបូជា បានបង្កើតព្រះរាជបុត្តចំនួន ៥០០ ឥតខ្វះ ។ កាលណាព្រះរាជបុត្តទាំងនោះ ដល់នូវវ័យចម្រើនឡើង កំពុងលេងល្បែងក្នុងទឹក បានឃើញស្លឹកនិងផ្កាឈូកសំយុងចុះ ( មានចិត្តនឿយណាយក្នុងសង្ខារក៏ចេញ

បួស ) បានជាព្រះបច្ចេកពុទ្ធ ជានាយកក្នុងកាលនោះ ។ ខ្ញុំនោះជាអ្នកព្រាត់ប្រាសចាករាជបុត្តដ៏ប្រសើរទាំងនោះ ក៏មានសេចក្តីសោកស្តាយ លុះច្យុត ( ចាកអត្តភាពនោះហើយ ) បានមកកើតក្នុងស្រុកតូចមួយ ទៀបភ្នំឥសិគិលិ ។ កាលណាខ្ញុំមានចិត្តភ្ញាក់ទឹកដល់កូនដែលជាព្រះបច្ចេកពុទ្ធ ក៏នាំយកបបរដើរទៅដើម្បីកូនទាំងឡាយផង ដើម្បីខ្លួនផង ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធជានាយក ៨ ព្រះអង្គ ដែលកំពុងដើរទៅកាន់ស្រុកដើម្បីភិក្ខា ក៏នឹករឮកកូនទាំងឡាយ កាលនោះ ទវនៃទឹកដោះរបស់ខ្ញុំក៏ខ្ចរចេញ ព្រោះសេចក្តីស្រឡាញ់ចំពោះកូន ។ លំដាប់នោះ ខ្ញុំជ្រះថ្លាបានប្រគេនបបរដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដោយដៃរបស់ខ្លួន លុះច្យុតចាកអត្តភាពនោះ ក៏បានទៅកើតឯឧទ្យានឈ្មោះនន្ទនៈ ក្នុងឋានត្រៃត្រិង្ស ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់បានទទួលសុខទុក្ខ អន្ទោលទៅក្នុងភពតូចភពធំ ទាំងជីវិតក៏ខ្ញុំលះបង់ដើម្បីប្រយោជន៍នៃព្រះអង្គ ។ សេចក្តីទុក្ខផ្សេងៗជាច្រើនយ៉ាងក្តី សម្បត្តិផ្សេងៗជាច្រើនក្តី ( របស់ខ្ញុំ ) រមែងមានយ៉ាងនេះឯង លុះដល់បច្ឆិមភព ខ្ញុំមកកើតក្នុងសាវត្ថីបុរី ។ ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋីមានទ្រព្យច្រើន ដល់នូវសេចក្តីសុខ ជាត្រកូលចាត់ចែងល្អហើយ រុងរឿងដោយរតនវត្ថុផ្សេងៗ សម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ ខ្ញុំត្រូវគេធ្វើសក្ការៈបូជាផង រាប់អានកោតក្រែងដូច្នោះផង ដល់នូវរូបសិរី ត្រូវគេធ្វើសក្ការៈក្រៃលែងក្នុងត្រកូលទាំងឡាយ ។ ខ្ញុំជាស្ត្រីដែលពួកជនអ្នកមានសិរី ដោយរូប និងភោគៈប្រាថ្នាលើសលុបផង ដែលពួកកូនសេដ្ឋីជាច្រើនរយនាក់ប្រាថ្នាហើយផង ។ ខ្ញុំលះបង់នូវផ្ទះហើយ

ចូលទៅកាន់ផ្ទះ កាលមិនទាន់ដល់កន្ទះខែនៅឡើយក៏បានលុះនូវសច្ច ៤ ។ ខ្ញុំនិម្មិតនូវរថមានជ្រង ៤ ដោយឫទ្ធិហើយថ្វាយបង្គំនូវព្រះបាទានៃព្រះពុទ្ធ ព្រះអង្គជាទីពឹងដ៏មានសិរីរបស់សត្វលោក ។

( មារពោលថា ) នាងអាស្រ័យនៅដើមឈើ ដែលមានចុងរីកផ្កាស្គុសស្គាយ ឋិតនៅទៀបគល់រាំងតែម្នាក់ឯង ទាំងអ្នកណាមួយជាគម្រប់ពីរនឹងនាង ក៏មិនមាន តើនាងមិនខ្លាចពួកជនពាល ឬពួកអ្នកលេងទេឬ ។

( ខ្ញុំឆ្លើយថា ) ពួកជនអ្នកលេងចំនួន ១០០ ក្តី ១០០០ ក្តី ដែលប្រាកដដូច្នោះ មកក្នុងទីនេះ យើងក៏ឥតព្រឺរោម ឥតញាប់ញ័រ ម្នាលមារ អ្នកជាបុគ្គលម្នាក់ឯង តើនឹងធ្វើម្តេចដល់យើង ។

យើងនុ៎ះ អាចបំបាត់ខ្លួនក៏បាន ចូលទៅក្នុងពោះអ្នកឯងក៏បាន កាលយើងឋិតនៅត្រង់ប្រជុំចិញ្ចើម ក៏អ្នកមើលមិនឃើញ ។ យើងជាស្រីស្ទាត់ក្នុងផ្លូវចិត្ត ទាំងឥទ្ធិបាទទាំងឡាយ យើងក៏បានចម្រើនល្អហើយ យើងជាស្រីរួចចាកចំណងទាំងអស់ហើយ នែអាវុសោ យើងមិនខ្លាចអ្នកទេ ។ អ្នកពោលនូវសេចក្តីត្រេកអរក្នុងកាមចំពោះគំនរកាមណា គំនរកាមនោះ ឧបមាដូចមុខលំពែងដ៏មុតក្រៃលែង ឥឡូវនេះ យើងមិនមានសេចក្តីត្រេកអរក្នុងកាមនោះទៀតទេ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងអស់ យើងបានកម្ចាត់បង់ហើយ ទាំងគំនរនៃសេចក្តីងងឹត យើងក៏ទម្លាយចេញហើយ ម្នាលមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ ខ្លួនអ្នកត្រូវយើងកម្ចាត់បានហើយ ។ ព្រះជិនស្រីជានាយកត្រេកអរចំពោះគុណនោះ តាំងខ្ញុំក្នុងទីជាឯតទគ្គៈក្នុងបរិស័ទទាំងឡាយថា នាង

ឧប្បលវណ្ណា ជាស្រីប្រសើរបំផុតជាងភិក្ខុនីដែលមានឫទ្ធិទាំងឡាយ ។ ព្រះសាស្តាខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំក៏ទម្លាក់ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ដល់គុណវិសេសណា ប្រយោជន៍គឺគុណវិសេសនោះឯង ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងអស់ ខ្ញុំក៏បានដល់ជាលំដាប់ហើយ ។ ចំនួនពាន់នៃពួកជនដោយជុំវិញរមែងបង្អោនមកនូវបច្ច័យ គឺចីវរ បិណ្ឌបាត សេនាសនៈ ដោយកាលភ្លាមៗ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧប្បលវណ្ណាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ ឧប្បលវណ្ណាថេរិយាបទាន ។

# បដាចារាចរិយាបទានទី ១០

[ ២០ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ ក្នុងគ្រានោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្នុងនគរហង្សវតី រុងរឿងដោយរតនៈផ្សេងៗ ។ ជាស្រីឆ្អែតស្កប់ស្កល់ដោយសេចក្ដីសុខច្រើនយ៉ាង ។ ខ្ញុំបានចូលទៅគាល់ព្រះអង្គជាមហាវីរបុរសនោះ បានស្ដាប់ធម្មទេសនា លំដាប់នោះ ខ្ញុំកើតសេចក្ដីជ្រះថ្លា ហើយដល់នូវព្រះជិនស្រីជាទីពឹង ។ លំដាប់នោះ ព្រះពុទ្ធជានាយកទ្រង់សរសើរភិក្ខុនីជាអ្នកអៀនខ្មាស មានចិត្តនឹងធឹង ក្លៀវក្លាក្នុងហេតុគួរ និងមិនគួរ ជាភិក្ខុនីខ្ពង់ខ្ពស់ជាងភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់នូវវិន័យ ។ ក្នុងកាលនោះ ខ្ញុំមានចិត្តរីករាយ ប៉ុនប៉ងចំពោះតំណែងនោះ ហើយនិមន្តព្រះទសពលជាលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆាន់អស់ ៧ ថ្ងៃ ហើយបានថ្វាយបាត្រនិងចីវរ ក្រាបទៀបព្រះបាទាដោយត្បូង ហើយពោលពាក្យនេះថា បពិត្រព្រះមុនីជាធីរបុរស ភិក្ខុនីណាដែលព្រះអង្គសរសើរហើយ បពិត្រព្រះអង្គជានាយក ខ្ញុំម្ចាស់សូមឲ្យបានដូចភិក្ខុនីនោះ ក្នុងកប្បទី ៨ អំពីកប្បនេះ បើសេចក្ដីប្រាថ្នានឹងសម្រេច ។ ក្នុងកាលនោះ ព្រះសាស្ដាបានត្រាស់នឹងខ្ញុំថា ម្នាលនាងដ៏ចម្រើន នាងកុំខ្លាច ចូរនាងត្រេកអរចុះ ក្នុងកាលអនាគត នាងនឹងបានតំណែងនុ៎ះ ដូចចិត្តប្រាថ្នា ។ ព្រះសាស្ដាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាកៈនឹងមានក្នុងលោក ក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ នាងនឹងបានជាផៅពង្សក្នុងធម៌ទាំងឡាយនៃព្រះសាស្ដាអង្គនោះ ជាឱរស ជាធម្មនិម្មិត មានឈ្មោះថានាងបដាចារា ជាសាវិការបស់ព្រះសាស្ដា ។

ក្នុងគ្រានោះ ខ្ញុំមានចិត្តរីករាយ មានមេត្តាចិត្តបម្រើព្រះជិនស្រី ជាលោក-នាយក ព្រមទាំងព្រះសង្ឃដរាបអស់ជីវិត ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធព្រះនាមកស្សប មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងពួកជនអ្នកពោល ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ក្នុងកាលនោះ ព្រះរាជាក្នុងដែនកាសីព្រះនាមកិកី ជាឧបដ្ឋាករបស់ព្រះពុទ្ធជាមហេសី ជាឥស្សរៈលើប្រជាជនក្នុងក្រុងពារាណសីបុរីដ៏ឧត្តម ។ ខ្ញុំបានជាធីតាទី ៣ នៃព្រះបាទកិកីនោះ ដែលប្រាកដជាភិក្ខុនី បានស្តាប់ធម៌របស់ព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ តែក្នុងកាលនោះព្រះបិតារបស់យើងទ្រង់ពុំអនុញ្ញាត យើងក៏ជាស្ត្រីមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយ សម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំនៅក្នុងផ្ទះ ជាព្រះរាជកញ្ញាឋិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាធីតា ៧ អង្គ គឺ នាងសមណី ១ សមគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ប្រាំពីរ ។ ( រាជកញ្ញាទាំងនោះលុះចេរវិលវិញមកក្នុងពុទ្ធុប្បាទនេះ ) បានមកជាខ្ញុំ ១ ឧប្បលវណ្ណា ១ ខេមា ១ ភទ្ទាភិក្ខុនី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ប្រាំពីរ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនាផង លុះខ្ញុំបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរមាំមួន ស្តុក

ស្តម្ភ មានធនធានច្រើន ។ ខ្ញុំកំពុងប្រកបដោយវ័យដ៏ចម្រើន លុះក្នុងអំណាចនៃវិតក្កៈ ខ្ញុំបានឃើញនូវបុរសអ្នកនៅក្នុងជនបទ ហើយក៏បានទៅនៅជាមួយនឹងបុរសនោះ ។ ខ្ញុំមានបុត្តប្រុស ១ នាក់ ប្រសូតហើយ បុត្តទី ២ នៅក្នុងផ្ទៃរបស់ខ្ញុំ ក្នុងកាលនោះ ខ្ញុំកាត់ចិត្តថា អញត្រូវទៅរកចួបមាតាបិតាវិញ ។ គ្រានោះ ខ្ញុំមិនបានប្រាប់ស្វាមីរបស់ខ្ញុំទេ លុះស្វាមីនោះឃ្លាតចេញទៅ ខ្ញុំជាស្ត្រីតែម្នាក់ឯង រត់ចេញចាកផ្ទះ ដើរទៅកាន់ក្រុងសាវត្ថីដ៏ឧត្តម ។ លំដាប់នោះ ប្តីរបស់ខ្ញុំ មកតាមទាន់ក្នុងផ្លូវ បបួលខ្ញុំទៅវិញ ក្នុងគ្រានោះ ខ្យល់-កម្មជវាទ ( ខ្យល់កើតអំពីកម្ម ) ដ៏អាក្រក់ពន់ពេកកើតឡើងដល់ខ្ញុំ ។ ស្រាប់តែភ្លៀងធំតាំងឡើងក្នុងសម័យជាទីប្រសូតិនូវកូននៃខ្ញុំ គ្រានោះ ប្តី ( របស់ខ្ញុំ ) ទៅដើម្បីប្រយោជន៍ដល់ឧស ត្រូវពស់ចឹកស្លាប់ទៅ ។ គ្រានោះ ខ្ញុំជាស្រីកំព្រា មិនមានទីពឹង ដោយសេចក្តីទុក្ខ ព្រោះសម្រាលកូន ខ្ញុំដើរទៅកាន់លំនៅនៃត្រកូលរបស់ខ្លួន ឃើញនូវស្ទឹងតូច មានទឹកពេញព្រៀប ។ ខ្ញុំជាស្រីម្នាក់ឯង នាំយកកូនតូច ឆ្លងទៅដាក់ឯច្រាំងត្រើយនាយ ហើយញ៉ាំងកូនតូចឲ្យដេក រួចត្រឡប់មកចម្លងកូនបង ។ មានសត្វខ្លែងមួយឆាបយកកូនតូចដែលកំពុងយំ ទាំងខ្សែទឹកក៏ក្ងួចយកកូនបងទៅទៀត ខ្ញុំជាស្រីចុកណែនដោយសេចក្តីសោក ។ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី បានឮថា ពួកជនរបស់ខ្លួន គឺមាតាបិតា ត្រូវស្លាប់អស់ហើយ គ្រានោះ ខ្ញុំមានសេចក្តីសោកគ្របសង្កត់ចុកណែនដោយសេចក្តីសោកដ៏ធំ ហើយបានពោលថា កូនទាំងពីរធ្វើមរណកាលហើយ ទាំងប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងព្រៃ មាតាបិតានិងបងប្រុស ក៏ត្រូវគេ

ដុតលើជើងថ្ករជាមួយគ្នា កាលនោះ ខ្ញុំជាស្រីស្គាំងស្គមផង កើតរោគលឿងផង ឥតមានទីពឹង មានចិត្តប្រកបដោយសេចក្ដីទុក្ខ លំដាប់នោះ ខ្ញុំដើរចេញទៅអំពីទីនេះ បានឃើញព្រះពុទ្ធ ព្រះអង្គជាសារថីរបស់ប្រជាជន ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ត្រាស់ចំពោះខ្ញុំថា នាងចូរកុំសោកស្ដាយចំពោះកូនទាំងឡាយឡើយ ចូរនាងស្រស់ស្រាយឡើង ចូរនាងស្វែងរកខ្លួនរបស់នាងវិញ នាងព្រួយឥតប្រយោជន៍សោះទេ ។ កូនទាំងឡាយពឹងពុំបាន ញាតិក៏ពឹងពុំបាន ទាំងផៅពង្សក៏ពឹងពុំបាន បុគ្គលដែលត្រូវសេចក្ដីស្លាប់គ្របសង្កត់ ទីពឹងចំពោះញាតិពុំបានឡើយ ។ លុះខ្ញុំបានស្ដាប់ព្រះវាចានោះរបស់ព្រះមុនីក៏បាននូវផលទី ១ ខ្ញុំ បួសមិនយូរប៉ុន្មាន ក៏បានសម្រេចនូវព្រះអរហត្ត ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងសោតធាតុជាទិព្វផង ខ្ញុំជាអ្នកធ្វើតាមសាសនានៃព្រះសាស្ដា រមែងដឹងនូវចិត្តនៃបុគ្គលដទៃផង ។ ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុ ខ្ញុំបានជម្រះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធឥតមានមន្ទិល ព្រោះបានញ៉ាំងអាសវៈទាំងពួងឲ្យអស់ហើយ ។ លំដាប់នោះ ខ្ញុំបានរៀនវិន័យទាំងអស់ក្នុងសម្នាក់របស់ព្រះពុទ្ធ ព្រះអង្គឃើញហេតុទាំងអស់ផង ខ្ញុំឆ្លើយដោះស្រាយនូវសេចក្ដីពិស្ដារគ្រប់យ៉ាងតាមពិតផង ។ ព្រះជិនស្រីត្រេកអរចំពោះគុណានោះ ហើយតាំងខ្ញុំក្នុងទីឯតទគ្គៈថា នាងបដាចារាជាភិក្ខុនីឯក ប្រសើរជាងពួកភិក្ខុនីអ្នកទ្រទ្រង់វិន័យ ។ ព្រះសាស្ដា ខ្ញុំបានប្រព្រឹត្តតាមហើយ សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះ ចូល

ទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណធម៌ណា ប្រយោជន៍គឺគុណធម៌នោះ របស់ខ្ញុំ ជាទីអស់ទៅនៃសញ្ញោជនៈទាំងពួង ខ្ញុំក៏បានសម្រេចហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបដាចារាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ បដាចារាថេរិយាបទាន ។

## ឧទ្ទាន

ឯកុបោសថិកាថេរិយាបទាន ១ សឡលបុប្ផិកាថេរិយាបទាន ១ មោទកទាយិកាថេរិយាបទាន ១ ឯកាសនទាយិកាថេរិយាបទាន ១ បញ្ចទីបទាយិកាថេរិយាបទាន ១ នឡមាលិកាថេរិយាបទាន ១ បជាបតិគោតមីថេរិយាបទាន ១ ខេមាថេរិយាបទាន ១ ឧប្បលវណ្ណាថេរិយាបទាន ១ បដាចារាថេរិយាបទាន ១ មានគាថា ៥០៩ គាថា ។

## ចប់ ឯកុបោសថវគ្គទី ២ ។

# កុណ្ឌលកេសវគ្គ ទី ៣

## កុណ្ឌលកេសីថេរិយាបទានទី ១

[ ២១ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋីក្នុងក្រុងហង្សវតី ជាត្រកូលរុងរឿងដោយរតនវត្ថុផ្សេងៗ ខ្ញុំជាស្រីស្កប់ស្កល់ដោយសេចក្តីសុខច្រើនប្រការ ។ ខ្ញុំចូលទៅរកព្រះពុទ្ធ ជាមហាវីរបុរសអង្គនោះ ហើយបានស្តាប់ធម៌ដ៏ឧត្តម លំដាប់នោះ ខ្ញុំមានសេចក្តីជ្រះថ្លាកើតឡើងហើយ បានដល់ព្រះជិនស្រីជាទីពឹង ។ ក្នុងកាលនោះឯង ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ប្រកបដោយមហាករុណា ទ្រង់តាំងសុភាភិក្ខុនី ថាជាភិក្ខុនីប្រសើរជាងពួកភិក្ខុនី ដែលត្រាស់ដឹងឆាប់រហ័ស ។ លុះខ្ញុំបានស្តាប់ព្រះពុទ្ធវាចានោះហើយ ខ្ញុំមានសេចក្តីរីករាយ បានថ្វាយទានដល់ព្រះពុទ្ធជាមហេសី ហើយក្រាបចុះទៀបព្រះបាទាដោយត្បូង ប្រាថ្នានូវតំណែងនោះ ។

ព្រះពុទ្ធជាមហាវីរបុរស ទ្រង់អនុមោទនាថា ម្នាលនាងដ៏ចម្រើន តំណែងណា ដែលនាងប្រាថ្នាហើយ តំណែងទាំងអស់នោះ នឹងសម្រេចពុំខាន ចូរនាងបានសេចក្តីសុខ រំលត់ទុក្ខចុះ ។ ក្នុងកប្បទី ១ សែនអំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឈ្មោះឱក្កាកៈ នឹងកើតឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្តា ឈ្មោះនាងកុណ្ឌលកេសីដ៏

ចម្រើន ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ ទៅកើតក្នុងឋានយាមៈ ច្យុតចាកឋានយាមៈនោះ បានទៅកើតឋានតុសិត ច្យុតចាកឋានតុសិតនោះ ក៏បានទៅកើតក្នុងឋាននិម្មានរតី រួចទៅកើតក្នុងបរនិម្មិតវសវត្តីបុរី ។ ខ្ញុំកើតក្នុងទីណាៗ ខ្ញុំបាននូវភាពជាមហេសីរបស់ស្តេចទាំងឡាយក្នុងទីនោះ ៗ ព្រោះអានិសង្សនៃបុញ្ញ-កម្មនោះឯង ។ ខ្ញុំច្យុតចាកអត្តភាពនោះ ហើយបានមកកើតក្នុងមនុស្សលោក បាននូវភាពជាមហេសីរបស់ស្តេចចក្កពត្តិទាំងឡាយផង របស់ស្តេចក្នុងមណ្ឌលទាំងឡាយផង ។ ខ្ញុំបាននូវសម្បត្តិក្នុងទេវលោកផង ក្នុងមនុស្សលោកផង ហើយជាស្រីដល់នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅក្នុងកប្បដ៏ច្រើន ។ ព្រះពុទ្ធព្រះនាម កស្សបៈ ព្រះអង្គមានផៅពង្សដ៏ប្រសើរ មានយសច្រើន ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ។ គ្រានោះ ព្រះរាជាក្នុងដែនកាសី ព្រះនាមកិកី ក្នុងពារាណសីបុរីដ៏ឧត្តម ជាឥស្សរៈលើប្រជាជន បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។ ខ្ញុំជាធីតាទី ៤ របស់ព្រះរាជាអង្គនោះ ដែលប្រាកដជាភិក្ខុទាសី បានស្តាប់ធម៌របស់ព្រះជិនស្រីដ៏ប្រសើរ ហើយក៏ពេញចិត្តចំពោះបព្វជ្ជា ។ ព្រះបិតាយើង ទ្រង់មិនអនុញ្ញាតឲ្យបួសទេ កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារីអស់ ២ ម៉ឺនឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញាឋិតនៅ

ក្នុងសេចក្ដីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ នាងសង្ឃទាសិកាជាគម្រប់ប្រាំពីរ ។ កាលនោះ ( ព្រះរាជធីតាទាំង ៧ នាក់នេះ ចេរវិលវិឹងមក ) បានជានាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ ខ្ញុំ ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ១ ជាគម្រប់ប្រាំពីរ ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ឆិមកព ខ្ញុំកើតក្នុងត្រកូលសេដ្ឋីដ៏ស្ដុកស្ដម្ភក្នុងបុរីដ៏ឧត្តមឈ្មោះគិរិព្វជៈ បិតនៅក្នុងវ័យដ៏ចម្រើន ។ ខ្ញុំឃើញនូវចោរដែលគេកំពុងបណ្ដើរយកទៅដើម្បីសម្លាប់ ហើយស្រឡាញ់ចំពោះចោរនោះ លំដាប់នោះ បិតារបស់ខ្ញុំ ដោះចោរនោះចេញអំពីទោសដែលត្រូវសម្លាប់ ដោយកហាបណៈ ១០០០ ។ បិតាបានឲ្យខ្ញុំទៅចោរនោះ ព្រោះដឹងច្បាស់នូវចិត្តខ្ញុំ ខ្លួនខ្ញុំជាស្រីឥតវង្វៀស ជាអ្នកអាណិតអនុគ្រោះក្រៃពេកចំពោះចោរនោះ ។ ឯចោរនោះនាំមកនូវគ្រឿងបូជា ហើយនាំខ្ញុំទៅកាន់ជ្រោះសម្រាប់ទម្លាក់ចោរ ហើយគិតសម្លាប់ខ្ញុំលើភ្នំ ដោយសេចក្ដីចង់បាននូវគ្រឿងប្រដាប់របស់ខ្ញុំ ។ គ្រានោះ ខ្ញុំធ្វើអញ្ជលីដ៏ល្អ ប្រណម្យចំពោះចោរឈ្មោះសត្តុកៈ រក្សានូវជីវិតរបស់ខ្លួនទុកសិន ហើយពោលពាក្យនេះថា បពិត្រអ្នកដ៏ចម្រើន អ្នកចូរនាំយកនូវសង្វារជាវិការៈនៃមាស ព្រមទាំងកែវមុក្តា កែវពៃទូរ្យដ៏ច្រើន ទាំងអស់នេះទៅចុះ រួចសូមឲ្យអ្នកប្រាប់គេឲ្យដឹងថា ខ្ញុំជាទាសីចុះ ។ ម្នាលនាងកល្យាណី នាង

ចូរដាក់នូវគ្រឿងប្រដាប់មកឲ្យអញចុះ នាងកុំខ្សឹកខ្សួលខ្លាំងឡើយ អញមិនដែលថាមិនសម្លាប់នូវមនុស្សដែលមកក្នុងព្រៃសោះទេ ។ ខ្ញុំនឹករកមើលនូវខ្លួនខ្ញុំ ចាប់តាំងពីខ្ញុំដល់នូវភាពជាអ្នកដឹងក្តីមក ខ្ញុំមិនដែលស្គាល់អ្នកដទៃឲ្យជាទីស្រឡាញ់ជាងអ្នកឡើយ ។ អ្នកចូរមកនេះ ខ្ញុំនឹងបានកៀកកើយអ្នកសិនហើយសូមធ្វើប្រទក្សិណអ្នក ថ្វាយបង្គំអ្នក ព្រោះថា ការរួបរួមគ្នារវាងខ្ញុំនិងអ្នកមិនមានទៀតទេ ។ ( ទេវតាពោលថា ) ប្រុសមិនមែនឈ្មោះថាបណ្ឌិតក្នុងហេតុទាំងអស់ទេ សូម្បីស្រីសោះ តែជាអ្នកមានឧបាយវាងវៃ ក្នុងហេតុនោះ ៗ ក៏ឈ្មោះថាបណ្ឌិតបាន ។ ប្រុសមិនមែនឈ្មោះថាបណ្ឌិតក្នុងហេតុទាំងអស់ទេ សូម្បីស្រីសោះតែជាអ្នកគិតឃើញនូវប្រយោជន៍រហ័ស ក៏ឈ្មោះថាបណ្ឌិតដែរ ។ បុគ្គលណា ត្រិះរិះឃើញនូវប្រយោជន៍ច្រើនដ៏រហ័សផងឆាប់ផង ដូចជាបុគ្គលកាលឃើញតាមហេតុនៃសំបុត្រឬតម្រាដ៏វិចិត្រ បុគ្គលនោះឈ្មោះថាបណ្ឌិត គ្រានោះ ខ្ញុំបានសម្លាប់នូវចោរឈ្មោះសត្តុកៈ ។ បុគ្គលណា មិនយល់ឆាប់នូវប្រយោជន៍ដែលកើតឡើងហើយ បុគ្គលនោះឈ្មោះថាមានគំនិតទន់ រមែងទុក្ខព្រួយ ដូចជាចោរដែលធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ។ បុគ្គលណា យល់ច្បាស់ឆាប់នូវប្រយោជន៍ដែលកើតឡើងហើយ បុគ្គលនោះ រមែងរួចអំពីការចង្អៀតដោយសត្រូវ ដូចជាខ្លួនខ្ញុំរួចចាកបុរស ឈ្មោះសត្តុកៈ ក្នុងកាលនោះឯង ។ ខ្ញុំប្រានបុរសឈ្មោះសត្តុកៈទៅក្នុងជ្រោះភ្នំ រួចហើយចូលទៅកាន់សម្នាក់ពួកតាបស អ្នកស្លៀកពាក់សំពត់សហើយបួស ។ ក្នុងកាលនោះ ខ្ញុំទុកសក់របស់ខ្ញុំដោយចន្លាស ដោយប្រការទាំងពួងហើយ ទើបបួស

ពួកតាបសក៏ប្រាប់នូវលទ្ធិឥតមានចន្លោះឡើយ ។ លំដាប់នោះ ខ្ញុំរៀននូវលទ្ធិនោះហើយអង្គុយតែម្នាក់ឯង គិតនូវលទ្ធិនោះ ( គាប់ចួន ) ឆ្កែក៏ពាំយកដៃរបស់មនុស្ស ។ ឆ្កែពាំដៃរបស់មនុស្សដែលដាច់មកទម្លាក់ចោលក្នុងទីជិតខ្ញុំ ហើយចៀសចេញទៅ ខ្ញុំបានឃើញហើយ ក៏បាននូវនិមិត្តចំពោះត្រកូលនៃដង្កូវដែលឋិតនៅ ( ក្នុងសាកសពនោះ ) ។ លំដាប់នោះ ខ្ញុំតក់ស្លុតហើយក្រោកទៅសួរពួកសហធម្មិកៈ ឯពួកសហធម្មិកៈទាំងនោះប្រាប់ថា ពួកភិក្ខុជាសក្យបុត្ត ទើបដឹងច្បាស់នូវសេចក្តីនោះបាន ។ ខ្ញុំនោះបានចូលទៅរកពួកសាវ័ករបស់ព្រះពុទ្ធ ហើយសួរសេចក្តីនោះ ពួកសាវ័កទាំងនោះ ក៏នាំខ្ញុំទៅក្នុងសម្នាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ ។ ព្រះពុទ្ធជានាយកនោះ ទ្រង់សម្តែងនូវព្រះធម៌ចំពោះខ្ញុំថា ខន្ធ អាយតនៈ ធាតុ ជាធម្មជាតិមិនស្អាតផង មិនទៀងផង ជាទុក្ខផង ជាអនត្តាផង ។ លុះខ្ញុំបានស្តាប់នូវធម៌របស់ព្រះអង្គហើយ បានជម្រះធម្មចក្ខុ គឺសោតាបត្តិផល លំដាប់នោះ ខ្ញុំបានដឹងច្បាស់នូវព្រះសទ្ធម្មហើយក៏សូមនូវបព្វជ្ជានិងឧបសម្បទា ។ កាលនោះ ព្រះពុទ្ធជានាយក ដែលខ្ញុំសូមហើយ ទើបទ្រង់ត្រាស់ថា ម្នាលនាងដ៏ចម្រើន នាងចូរមកចុះ កាលនោះ ខ្ញុំក៏បានឧបសម្បទា ហើយបានឃើញទឹកបន្តិច ។ ខ្ញុំដឹងនូវរូប ប្រកបដោយការកើតឡើងនិងការសូន្យទៅ ដោយគ្រាន់តែលាងជើងហើយគិតក្នុងកាលនោះថា សង្ខារទាំងឡាយទាំងពួង មានសភាពដូចគ្នា ។ លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់ដោយប្រការទាំងពួង គ្រានោះព្រះជិនស្រី ទ្រង់តាំងខ្ញុំថា ប្រសើរលើសជាងពួកភិក្ខុ

នីដែលត្រាស់ដឹងធាប់របស់ ខ្ញុំជាស្រីស្ទាត់ក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុជាទិព្វផង ខ្ញុំជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា ដឹងនូវចិត្តនៃបុគ្គលដទៃផង ។ ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធ មិនមានមន្ទិល ព្រោះញុំាំងអាសវៈទាំងពួងឲ្យអស់ហើយ ។ ព្រះសាស្តាខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំដាក់ចេញហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភពថ្មី ខ្ញុំគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ដល់គុណធម៌ណា ប្រយោជន៍គឺគុណធម៌នោះរបស់ខ្ញុំ ជាទីអស់ទៅនៃសញ្ញោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ ។ ញាណរបស់ខ្ញុំដ៏ទូលាយស្អាត ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ក៏ដូចគ្នា ព្រោះហេតុនៃព្រះពុទ្ធជាបុគ្គលប្រសើរ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចេញហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចមេដំរីកាត់ផ្តាច់នូវទន្វីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុណ្ឌលកេសីភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ កុណ្ឌលកេសីថេរិយាបទាន ។**

## កិសាគោតមីថេរីបទានទី ២

[ ២២ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកទ្ទកប្បនេះទៅ ។ ក្នុងកាលនោះ ខ្ញុំកើតក្នុងត្រកូល ១ នៅក្នុងក្រុងហង្សវតី បានចូលទៅគាល់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ប្រសើរជាងនរជននោះ ហើយយកព្រះអង្គជាទីពឹង ។ ខ្ញុំបានស្ដាប់ធម៌ដ៏ពីរោះរបស់ព្រះអង្គ ជាធម៌ប្រកបដោយសច្ច ៤ មានអានិសង្សដ៏ក្រៃលែង នាំមកនូវសេចក្ដីស្ងប់ និងសេចក្ដីសុខក្នុងចិត្ត ។ កាលនោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់សរសើរតាំងភិក្ខុនីអ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ក្នុងទីជាឯតទគ្គៈ ។ ខ្ញុំញុំាងបីតិមានប្រមាណច្រើនឲ្យកើត ស្ដាប់នូវគុណនៃភិក្ខុនី ខ្ញុំធ្វើនូវគ្រឿងសក្ការៈដល់ព្រះពុទ្ធ តាមគួរដល់សេចក្ដីអង់អាច តាមគួរដល់កម្លាំង ។ ខ្ញុំបានក្រាបចុះជិតព្រះអង្គជាអ្នកប្រាជ្ញមានប្រាជ្ញាខ្ជាប់ខ្ជួននោះ ហើយប្រាថ្នានូវតំណែងនោះ កាលនោះ ព្រះសម្ពុទ្ធជានាយក ទ្រង់អនុមោទនាចំពោះការបាននូវតំណែងនោះថា ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាកត្រកូលនឹងត្រាស់ឡើងក្នុងលោក ។ នាងនេះនឹងបានព្រះញាតិ ក្នុងធម៌ទាំងឡាយនៃព្រះគោតមនោះ ជាឱរស ជាធម្មនិម្មិត បានជាសាវិកានៃព្រះសាស្ដា មានឈ្មោះថាកិសាគោតមី ។ កាលនោះ ខ្ញុំស្ដាប់នូវពុទ្ធព្យាករណ៍នោះ ក៏រីករាយ មានចិត្តប្រកបដោយមេត្តា បានបម្រើព្រះជិនស្រីជានាយក ដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើត

ក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយក្នុងភទ្ទកប្បនេះ ។ កាលនោះ ព្រះរាជាក្នុងដែនកាសី ទ្រង់ព្រះនាមកិកី ព្រះអង្គជាធំជាងនរជន ក្នុងក្រុងពារាណសីដ៏ឧត្តម ទ្រង់ជាឧបដ្ឋាកនៃព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ខ្ញុំជាធីតាទី ៥ នៃព្រះរាជានោះ មានឈ្មោះប្រាកដជាធម្មា បានស្តាប់ធម៌ព្រះពុទ្ធជិនស្រីដ៏ប្រសើរហើយពេញចិត្តនឹងផ្នួស ។ ព្រះបិតានៃយើង មិនទ្រង់អនុញ្ញាតឲ្យបួសទេ កាលនោះ យើងជាអ្នកមិនខ្ជិលប្រអូស បានប្រព្រឹត្តព្រហ្មចរិយធម៌សម្រាប់កុមារីអស់ ២ ម៉ឺនឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញានៃស្តេច ឋិតនៅក្នុងសេចក្តីសុខត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ប្រាំពីរ ។ ( ព្រះរាជធីតា ៧ អង្គនោះ ចេរវិលវិញមកបានជា ) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលា ១ ខ្ញុំ ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ ៧ ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផងលុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដែលជាអ្នកធ្លាក់ខ្លួនកម្សត់ ឥតទ្រព្យ ជាត្រកូលទន់ទាបវិញ តែខ្ញុំបានមានប្តីត្រកូលសម្បូណ៌ដោយទ្រព្យសម្បត្តិ ។ ជនទាំងឡាយដ៏សេស វៀរលែងតែប្តីរបស់ខ្ញុំចេញសុទ្ធតែ ជាអ្នកឥតទ្រព្យ ខ្ញុំប្រសូតកូនក្នុងកាលណា ជនទាំងពួងក៏អាណិតខ្ញុំ

ក្នុងកាលនោះ ។ កាលណាកូនខ្ចីរបស់ខ្ញុំនោះជាកុមារតូច ឋិតនៅក្នុងសេចក្ដីសុខ ជាទីស្រឡាញ់របស់ខ្ញុំ ដូចជាជីវិតរបស់ខ្លួន កាលនោះ កូននោះ ក៏លុះអំណាចនៃសេចក្ដីស្លាប់ទៅ ។ ខ្ញុំមានសេចក្ដីសោកគ្របសង្កត់ មានមុខប្រកបដោយសេចក្ដីទុក្ខ មានភ្នែកពេញដោយទឹកភ្នែក មានមាត់យំ ពរសាកសពដែលស្លាប់នោះ ដើរយំត្អូញត្អែរ ។ កាលនោះ ខ្ញុំបានជួបបុរសម្នាក់ ក៏ចូលទៅរកព្រះពុទ្ធជាគ្រូពេទ្យដ៏ប្រសើរ ហើយពោលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គឲ្យថ្នាំប្រោសកូនឲ្យរស់ ។ ព្រះជិនស្រី ព្រះអង្គជាអ្នកឈ្លាសវៃក្នុងឧបាយនៃការទូន្មាន ទ្រង់ត្រាស់ថា ជនទាំងឡាយដែលស្លាប់ហើយ មិនមានក្នុងផ្ទះណា ចូរនាងយកគ្រាប់ស្ពៃអំពីផ្ទះនោះមក ( ឲ្យតថាគត ) ។ កាលនោះ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី រកមិនបានផ្ទះប្រាកដដូច្នោះ ព្រោះហេតុនោះ នឹងរកគ្រាប់ស្ពៃអំពីផ្ទះណាបាន លំដាប់នោះ ខ្ញុំក៏បាននូវស្មារតីឡើង ។ ខ្ញុំចោលនូវសាកសព ហើយចូលទៅគាល់ព្រះពុទ្ធ ជាលោកនាយក ចំណែកខាងព្រះអង្គមានសំឡេងពីរោះ ទ្រង់ទតឃើញខ្ញុំអំពីចម្ងាយ ហើយត្រាស់ថា បុគ្គលណា កាលមិនបានឃើញនូវការកើតនិងការសូន្យទៅ ( នៃបញ្ចក្ខន្ធ ) ទេ ហើយរស់នៅ ១០០ ឆ្នាំក៏ដោយ ជីវិតរបស់បុគ្គលអ្នកឃើញនូវការកើតឡើងនិងការសូន្យទៅ ( នៃបញ្ចក្ខន្ធ ) សូម្បីរស់នៅតែ ១ ថ្ងៃ ក៏ប្រសើរជាង ។

អនិច្ចតាធម៌នេះ នឹងថាជាធម៌សម្រាប់ស្រុក ១ ក៏ទេ ជាធម៌សម្រាប់និគម ១ ក៏ទេ ជាធម៌សម្រាប់ត្រកូល ១ ក៏ទេ ធម៌នុ៎ះឯង សម្រាប់លោក

ព្រមទាំងទេវលោកទាំងអស់ ។

ខ្ញុំនោះ បានស្តាប់នូវគាថាទាំងឡាយនេះហើយ ជម្រះនូវធម្មចក្ខុ គឺសោតាបត្តិមគ្គ លំដាប់នោះ ខ្ញុំក៏ដឹងច្បាស់នូវព្រះសទ្ធម្ម ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសរួចហើយ ក៏មានចិត្តស្ងប់ ប្រកបក្នុងសាសនាព្រះជិនស្រី អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចនូវព្រះអរហត្ត ។ ខ្ញុំជាអ្នកធ្វើនូវសាសនានៃព្រះសាស្តា ស្ទាត់ក្នុងឫទ្ធិទាំងឡាយ ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំក៏បានជម្រះហើយ ខ្ញុំបានញុំាងអាសវៈទាំងពួងឲ្យអស់ទៅ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលសោះឡើយ ។ ព្រះសាស្តា ខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាដែលជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំគាស់រំលើងចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺកិរិយាអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានសម្រេចហើយ ។ ញាណរបស់ខ្ញុំ ដ៏ធំទូលាយស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ព្រោះអំណាចនៃព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំនាំសំពត់អំពីគំនរសំរាមផង អំពីព្រៃស្មសានផង អំពីប្រកផង ហើយធ្វើជាសង្ឃាដី ទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ព្រះជិនស្រីជានាយក ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំ គឺការទ្រទ្រង់នូវចីវរដ៏សៅហ្មងនោះ បានតាំងខ្ញុំក្នុងទីជាឯតទគ្គៈក្នុងពួកបរិស័ទ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីដ៏ប្រសើរ កាត់ផ្តាច់នូវ

ទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកិសាគោតមីភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ កិសាគោតមីថេរិយាបទាន ។

# ធម្មទិន្នាថេរិយាបទានទី ៣

[ ២៣ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ជាអ្នកដឹកនាំសត្វលោក ទ្រង់កើតឡើងក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូល ១ ក្នុងក្រុងហង្សវតី ជាអ្នកធ្វើនូវការងារនៃជនដទៃ ខ្ញុំមានប្រាជ្ញាចាស់ សង្រួមក្នុងសីល ។ ព្រះថេរៈឈ្មោះសុជាត ជាអគ្គសាវកនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ចេញអំពីវត្តទៅដើម្បីបិណ្ឌបាត ។ កាលនោះ ខ្ញុំចេញទៅដងទឹក កាន់ក្អមដើរទៅ បានឃើញព្រះថេរៈនោះ ក៏មានសេចក្តីជ្រះថ្លា បានប្រគេននំដោយដៃរបស់ខ្លួន ។ ព្រះថេរៈនោះ ទទួលនំហើយ ក៏គង់ឆាន់ក្នុងទីនោះ លំដាប់នោះ ម្ចាស់របស់ខ្ញុំមានចិត្តត្រេកអរនឹងខ្ញុំ បានយកខ្ញុំធ្វើជាកូនប្រសាររបស់ខ្លួន ខ្ញុំទៅជាមួយនឹងម្តាយក្មេក ថ្វាយបង្គំព្រះសម្ពុទ្ធ ។ គ្រានោះ ព្រះអង្គទ្រង់តាំងភិក្ខុនី ១ រូប ជាធម្មកថិកា អ្នកសម្តែងធម៌ដល់បរិស័ទ ក្នុងទីជាឯតទគ្គៈ ខ្ញុំបានស្តាប់ពុទ្ធតម្រាស់នោះហើយ ក៏មានចិត្តរីករាយខ្លាំង ។ ខ្ញុំនិមន្តព្រះសុគត ជាលោកនាយក ព្រមទាំងភិក្ខុសង្ឃ ថ្វាយមហាទាន ហើយប្រាថ្នានូវតំណែងនោះ ។ លំដាប់នោះ ព្រះសុគតព្រះអង្គមានសំឡេងណែនរំពងពីរោះ ត្រាស់នឹងខ្ញុំថា នាងជាស្រីត្រេកអរក្នុងការបម្រើតថាគត ជាអ្នកអង្គាសតថាគត ព្រមទាំងភិក្ខុសង្ឃ ។ នាងជាអ្នកប្រកបក្នុងការស្តាប់នូវព្រះសទ្ធម្ម មានចិត្តចម្រើនដោយគុណ ម្នាលនាងដ៏ចម្រើន នាងចូររីករាយចុះ នាងនឹងបានផលដែលនាងតាំងប្រាថ្នាទុំ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុង

ធម៌នៃព្រះពុទ្ធអង្គនោះ ជាឱរស ជាធម្មនិម្មិត បានជាសាវិកានៃព្រះសាស្តា មានឈ្មោះថាធម្មទិន្នា ។ ខ្ញុំបានស្តាប់ព្យាករណ៍នោះ ក៏រីករាយ មានចិត្ត ប្រកបដោយមេត្តា បម្រើព្រះមហាមុនី ជានាយក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការ តម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បាន ទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធមានផៅពង្សដ៏ប្រសើរ មានយសធំ ព្រះ អង្គប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ព្រះនាមកស្សបៈ កើតឡើងហើយក្នុងភទ្ទ-កប្បនេះ ។ កាលនោះ ព្រះរាជាក្នុងដែនកាសីព្រះនាមកិកី ជាឥស្សរៈនៃនរៈ ក្នុងក្រុងពារាណសីដ៏ឧត្តម ជាឧបដ្ឋាកនៃព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ ។ ខ្ញុំជា ធីតាទី ៦ នៃព្រះរាជាអង្គនោះ មានឈ្មោះប្រាកដថា នាងសុធម្មា បានស្តាប់ ធម៌នៃព្រះជិនស្រីដ៏ប្រសើរហើយ ពេញចិត្តនឹងផ្នួស ។ ព្រះបិតារបស់យើង ទ្រង់មិនអនុញ្ញាត កាលនោះយើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្ម ចរិយធម៌សម្រាប់កុមារី អស់ ២ ម៉ឺនឆ្នាំក្នុងផ្ទះ ។

## ចប់ ភាណវារៈទី ៣ ។

ធីតា ៧ អង្គ ជាកញ្ញានៃស្តេចតាំងនៅក្នុងសេចក្តីសុខ ត្រេកអររីករាយ ក្នុងការបម្រើព្រះពុទ្ធគឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុ ទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ ៧ ។ ( ធីតា ៧ អង្គ នោះ ចេរវិលវិញមកបានជា ) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលា ១ គោតមី ១ ខ្ញុំ ១ វិសាខា ១ ជាគម្រប់ ៧ ។ ដោយ

កុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋីដ៏ស្តុកស្តម្ភ ក្នុងក្រុងបរិព្វជៈដ៏ឧត្តម អាចសម្រេចសេចក្តីប្រាថ្នាទាំងពួងបាន ។ កាលណា ខ្ញុំប្រកបដោយគុណគឺរូបសម្បត្តិ តាំងនៅក្នុងបឋមវ័យហើយ កាលនោះឯង ខ្ញុំបានទៅកាន់ត្រកូលនៃបុរសដទៃ ( មានប្តី ) ហើយនៅស្កប់ស្កល់ដោយសេចក្តីសុខ ។ ឯស្វាមីរបស់ខ្ញុំនោះ មានប្រាជ្ញាល្អ បានចូលទៅគាល់ព្រះពុទ្ធជាទីពឹងនៃសត្វលោក ស្តាប់ធម៌ទេសនាហើយ ក៏បានដល់នូវអនាគាមិផល ។ កាលនោះ ខ្ញុំបានញ៉ាំងស្វាមីនោះ ឲ្យអនុញ្ញាតហើយ ចូលទៅកាន់ផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានដល់ព្រះអរហត្ត ។ កាលនោះ ឧបាសកនោះ ចូលមករកខ្ញុំហើយសួរនូវប្រស្នាទាំងឡាយដ៏ជ្រាលជ្រៅ ខ្ញុំក៏បានព្យាករប្រស្នាទាំងអស់នោះ ។ ព្រះជិនស្រីត្រេកអរក្នុងគុណនោះហើយ បានតាំងខ្ញុំក្នុងទីជាឯតទគ្គៈថា តថាគតមិនឃើញភិក្ខុនីជាធម្មកថិកាដទៃប្រាកដដូចភិក្ខុនីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះថា នាងធម្មទិន្នាជាអ្នកប្រាជ្ញ ។

ខ្ញុំឈ្មោះថាជាស្រីបណ្ឌិត ដែលព្រះលោកនាយកអនុគ្រោះដោយប្រការយ៉ាងនេះឯង ។ ព្រះសាស្តា ខ្ញុំបានបម្រើដោយគោរពហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់កព ខ្ញុំបានរំលើងចោលហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួង

ខ្ញុំបានសម្រេចហើយ ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមពុទ្ធសាសនា ដឹងនូវចិត្តនៃបុគ្គលដទៃដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកបរិសុទ្ធិស្អាតមិនមានមន្ទិលសោះឡើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងចោលអស់ហើយ ខ្ញុំជាអ្នកមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មទិន្នាភិក្ខុនីមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ ធម្មទិន្នាថេរិយាបទាន ។**

# សក្កុលាថេរិយាបទានទី ៤

[ ២៤ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ។ ជាបុរសអាជានេយ្យ ប្រតិបត្តិដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីសេចក្តីចម្រើនដល់សព្វសត្វ ក្នុងមនុស្សលោកព្រមទាំងទេវលោក ។ ព្រះជិនស្រីទ្រង់ដល់នូវយសដ៏ប្រសើរ មានសិរីពេញពោរដោយកេរ្តិ៍ឈ្មោះនិងសេចក្តីសរសើរ ដែលលោកទាំងពួងបូជាហើយ ប្រាកដក្នុងទិសទាំងពួង ។ ព្រះអង្គមានសេចក្តីសង្ស័យឆ្លងហើយ មានសេចក្តីងឿងឆ្ងល់កន្លងបង់ហើយ មានសេចក្តីត្រិះរិះក្នុងព្រះទ័យបរិបូណ៌ហើយ ទ្រង់ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះសម្ពុទ្ធប្រសើរជាងនរជន ទ្រង់ញុំាំងមគ្គដែលមិនទាន់កើតឲ្យកើតឡើងផង សំដែងនូវមគ្គដែលមិនទាន់សំដែងផង បណ្តុះនូវមគ្គដែលមិនទាន់បណ្តុះផង ។ ព្រះសម្ពុទ្ធ ជាអ្នកអង់អាចជាងនរជន ព្រះអង្គជ្រាបនូវមគ្គ ត្រាស់ដឹងនូវមគ្គ ប្រាប់នូវមគ្គ ជាគ្រូប្រៀនប្រដៅដ៏ឧត្តម ប្រសើរជាងសារថីទាំងឡាយ ។ ព្រះសម្ពុទ្ធ ព្រះអង្គប្រកបដោយព្រះទ័យករុណាដ៏ធំ ជាទីពឹងនៃសត្វលោក ជាអ្នកដឹកនាំសត្វលោក ទ្រង់សំដែងធម៌ ស្រោចស្រង់នូវសត្វទាំងឡាយដែលមុជចុះក្នុងភក់គឺកាម ។ កាលនោះ ខ្ញុំកើតក្នុងក្រុងហង្សវតី ឈ្មោះខត្តិយនន្ទា ជាស្រីមានរូបល្អ ប្រកបដោយទ្រព្យ មានចិត្តអាណិតអាសូរចំពោះអ្នកដទៃ ជាស្រីមានសិរី ។ ខ្ញុំជាធីតានៃមហារាជព្រះនាមអានន្ទ ជាស្រីមានលម្អដ៏ប្រសើរ ជាប្អូនស្រីមានមាតាផ្សេងគ្នានៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ខ្ញុំស្អិតស្អាងដោយគ្រឿងអាភរណៈ

ទាំងពួងជាមួយនឹងព្រះរាជកញ្ញាទាំងឡាយ ហើយចូលទៅគាល់ព្រះពុទ្ធ ទ្រង់មានព្យាយាមធំ ហើយស្តាប់ធម៌ទេសនា ។ គ្រានោះ ព្រះអង្គជ្រាបច្បាស់នូវលោក ទ្រង់តាំងភិក្ខុនីនោះដែលមានចក្ខុដូចជាទិព្វ ក្នុងឋានៈដ៏ប្រសើរ ក្នុងកណ្តាលនៃបរិស័ទ ៤ ។ ខ្ញុំបានស្តាប់ព្យាករណ៍នោះហើយ ក៏មានចិត្ត រីករាយ ថ្វាយទានដល់ព្រះសាស្តា បូជាព្រះសម្ពុទ្ធ ហើយប្រាថ្នានូវទិព្វចក្ខុ ។ លំដាប់នោះ ព្រះសាស្តាបានត្រាស់នឹងខ្ញុំថា ម្នាលនាងនន្ទា នាងនឹងបានតំណែងដែលនាងប្រាថ្នា ឋានៈដែលនាងប្រាថ្នាដោយប្រពៃនុ៎ះ ជាផលនៃធម្មទានដូចជាប្រទីប ។ ក្នុងកប្បទី ១ សែនអំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកៈត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនឹងបានជាព្រះញាតិក្នុងធម៌ទាំងឡាយនៃព្រះសាស្តានោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកាព្រះសាស្តា មានឈ្មោះថាសកុលា ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធព្រះនាមកស្សបៈ ព្រះអង្គមានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ។ កាលនោះខ្ញុំបួសជានាងបរិព្វាជិកា ប្រព្រឹត្តម្នាក់ឯង ត្រាច់ទៅដើម្បីភិក្ខា ហើយបាននូវវត្ថុត្រឹមតែប្រេងប៉ុណ្ណោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានអុជប្រទីបដោយប្រេងនោះ បម្រើព្រះចេតិយប្រសើរសមរម្យជាងចេតិយទាំងពួងនៃព្រះពុទ្ធប្រសើរជាងសត្វមានជើងពីរ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយ

ជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដោយផលនៃកម្ម នោះ ខ្ញុំកើតក្នុងទីណាៗ ប្រទីបដ៏ធំទាំងឡាយ បំភ្លឺដល់ខ្ញុំដែលនៅក្នុងទីនោះៗ ។ ខ្ញុំប្រាថ្នារបស់ណា ខ្ញុំឃើញ ( របស់នោះ ) ធ្លុះរហូតខាងក្រៅជញ្ជាំង ធ្លុះរហូតខាងក្រៅនៃភ្នំថ្ម នេះជាផលនៃការឲ្យប្រទីប ។ ខ្ញុំជាអ្នកមានភ្នែកស្អាត រុងរឿងដោយយស មានសទ្ធា មានប្រាជ្ញា នេះជាផលនៃការឲ្យប្រទីប ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ មានទ្រព្យនិងស្រូវច្រើន ជាត្រកូលរីករាយដែលស្តេចរាប់អានបូជាហើយ ។ ខ្ញុំបរិបូណ៌ដោយអវយវៈគ្រប់យ៉ាង ស្អិតស្អាងដោយអាភរណៈទាំងពួង ខ្ញុំឈរនៅត្រង់បង្អួច ឃើញព្រះសុគតត្រង់ប្រទេសជាទីចូលទៅកាន់បុរី ។ ខ្ញុំឃើញព្រះពុទ្ធរុងរឿងដោយយស ដែលទេវតានិងមនុស្សធ្វើសក្ការៈហើយ ទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ស្អិតស្អាងដោយលក្ខណៈទាំងឡាយ ។ ខ្ញុំមានចិត្តអណ្តែតឡើង មានចិត្តល្អ ពេញចិត្តនឹងផ្នួស អស់កាលមិនយូរប៉ុន្មានក៏បានដល់ព្រះអរហត្ត ។ ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ដឹងនូវចិត្តនៃបុគ្គលដទៃដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំបានញ៉ាំងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលឡើយ ។ ព្រះសាស្តាខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំង

ពួន ខ្ញុំបានសម្រេចហើយ ។ លំដាប់នោះ ព្រះពុទ្ធប្រសើរជាងនរជន ព្រះអង្គប្រកបដោយមហាករុណា ទ្រង់តាំងខ្ញុំជាឯតទគ្គៈដោយព្រះពុទ្ធដីកាថា នាងសកុលាថេរី ជាភិក្ខុនីប្រសើរផុត ជាងថេរីទាំងឡាយដែលមានទិព្វចក្ខុ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសកុលាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សកុលាថេរិយាបទាន ។**

# ឆត្តាថេរិយាបទានទី ៩

[ ២៥ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ទូន្មានសត្វលោក ញុំាងសត្វលោកឲ្យដឹងច្បាស់ ចម្លងសត្វទាំងពួង ឈ្លាសវៃក្នុងទេសនា ទ្រង់ញុំាងប្រជុំជនជាច្រើនឲ្យឆ្លងហើយ ។ ព្រះអង្គជាអ្នកអនុគ្រោះ ប្រកបដោយករុណា ស្វែងរកនូវប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុំាងតិរ្ថិយទាំងពួងដែលមកដល់ហើយឲ្យតាំងនៅក្នុងសីល ៥ ។ សីល ៥ ជារបស់មិនវឹកវរយ៉ាងនេះ ជារបស់សូន្យពួកតិរ្ថិយ ជារបស់ដែលព្រះអរហន្តទាំងឡាយ អ្នកមានសេចក្តីស្ងាត់ជំនាញ ប្រកបដោយគាទិគុណវិចិត្រហើយ ។ ព្រះពុទ្ធព្រះនាមបទុមុត្តរៈនោះ ជាអ្នកប្រាជ្ញធំ មានកម្ពស់ ៥៨ ហត្ថ មានទ្រង់ទ្រាយដូចចេតិយមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ។ ព្រះអង្គមានព្រះជន្ម ១ សែនឆ្នាំជាកំណត់ ទ្រង់ឋិតនៅអស់កាលប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជនជាច្រើនឲ្យឆ្លងហើយ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ជាត្រកូលរុងរឿងដោយកែវផ្សេង ៗ ជាអ្នកស្កប់ស្កល់ដោយសេចក្តីសុខដ៏ធំ នៅក្នុងក្រុងហង្សវតី ។ ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ព្រះអង្គមានព្យាយាមធំ ខ្ញុំបានស្តាប់នូវធម៌ទេសនា គឺអមតនិព្វាន ជាធម៌មានអានិសង្សក្រៃលែងមានប្រយោជន៍យ៉ាងល្អិតល្អន់ ជាធម៌ដែលព្រះអង្គសម្តែងហើយ ។ គ្រានោះ ខ្ញុំមានចិត្តជ្រះថ្លាខ្លាំង បាននិមន្តព្រះលោកនាយក ព្រមទាំងភិក្ខុសង្ឃ ហើយថ្វាយមហាទានដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ។ ខ្ញុំក្រាបជិតព្រះលោកនាយក ព្រះអង្គមានព្យាយាម ព្រមទាំងព្រះសង្ឃដោយត្បូង ហើយប្រាថ្នា

នូវតំណែងដ៏ប្រសើរ ជាងពួកភិក្ខុនីដែលមានឈាន ។ កាលនោះ ព្រះអង្គទូន្មានសត្វដែលមិនទាន់ទូន្មានហើយ ជាទីពឹងនៃលោកទាំង ៣ មានរស្មី ព្រះអង្គជានាយសារថីរបស់ពួកនរជន ទ្រង់ព្យាករថា នាងនឹងបាននូវតំណែងដែលនាងប្រាថ្នាហើយដោយប្រពៃនុ៎ះ ។ ក្នុង ១ សែនកប្ប អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌ទាំងឡាយរបស់ព្រះសាស្តាអង្គនោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្តា មានឈ្មោះថានាងនន្ទា ។ កាលនោះ ខ្ញុំបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះជិនស្រី ព្រះអង្គជានាយក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ បានទៅកើតឯឋានយាមៈ ច្យុតចាកឋានយាមៈនោះ បានទៅកាន់ឋានតុសិត ច្យុតចាកឋានតុសិតនោះ បានទៅកាន់និម្មានរតី ច្យុតចាកនិម្មានរតីនោះហើយ បានទៅកាន់បរនិម្មិតវសវត្តីបុរី ។ ដោយផលនៃកុសលនោះ ខ្ញុំកើតក្នុងទីណាៗ តែងបានជាមហេសីនៃស្តេចទាំងឡាយក្នុងទីនោះ ៗ ។ ខ្ញុំច្យុតចាកទីនោះហើយ កើតជាមនុស្ស បានជាមហេសីនៃស្តេចចក្កពត្តិទាំងឡាយផង នៃស្តេចមានមណ្ឌលទាំងឡាយផង ។ ខ្ញុំសោយនូវសម្បត្តិក្នុងទេវតានិងមនុស្ស ហើយដល់នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅអស់កប្បច្រើន ។ លុះដល់មកក្នុងបច្ឆិមភព ខ្ញុំ

កើតជាធីតានៃព្រះបាទសុទ្ធោទនៈ មិនមានអ្នកណាមួយតិះដៀលបាន ក្នុងបុរីឈ្មោះកបិលពស្តុ ។ ត្រកូលនោះ ក៏ដល់នូវសេចក្ដីត្រេកអរ ព្រោះបានឃើញខ្ញុំជាស្រីមានរស្មី ព្រោះហេតុនោះ ឈ្មោះរបស់ខ្ញុំថានាងនន្ទា ខ្ញុំជាស្រីល្អប្រសើរ ។ មួយទៀត ខ្ញុំប្រាកដជាស្រីមានលម្អជាងស្រីក្រមុំទាំងអស់ វៀរលែងតែងព្រះនាងយសោធរា ក្នុងនគរជាទីរីករាយនោះចេញ ។ បងប្រុសច្បង ( របស់ខ្ញុំ ) បានជាកំពូលនៃលោកទាំង ៣ បងប្រុសបន្ទាប់ខាងក្រោយជាព្រះអរហន្តដូចគ្នា ខ្ញុំនៅជាគ្រហស្ថតែម្នាក់ឯង ដែលមានមាតាតែងដាស់តឿនថា នាងជាព្រះអនុជា នៃព្រះពុទ្ធ កើតក្នុងត្រកូលសក្យបុត្ត នាងបើវៀរចាកសេចក្ដីត្រេកអរក្នុងធម៌ហើយ តើនឹងបាននូវអ្វីក្នុងផ្ទះ ។ សេចក្ដីចម្រើនមានជរាជាទីបំផុត រូបជារបស់ដែលសន្មតថាមិនស្អាត ការមិនមានរោគ មានរោគជាទីបំផុត ជីវិតមានសេចក្ដីស្លាប់ទីបំផុត ។ រូបរបស់នាងនេះល្អ គួររមិលមើល គួររីករាយ ជាគ្រឿងប្រដាប់របស់អ្នកស្ថិតស្ថាងទាំងឡាយ ដូចជាទីលំនៅដែលមានសិរី ។ ( រូបរបស់នាង ) ដែលគេបូជាហើយ ដូចជាវត្ថុមានខ្លឹមក្នុងលោក ជាទីនាំមកនូវរសដល់ភ្នែកទាំងឡាយ ជាទីញុំាងកិត្តិសព្ទឲ្យកើតដល់ជនអ្នកមានបុណ្យទាំងឡាយ ជាទីញុំាងឱក្កាកៈត្រកូល ឲ្យត្រេកអរ ។ អស់កាលមិនយូរប៉ុន្មាន ជរានឹងគ្រប់សង្កត់ ( នូវរូបរបស់នាង ) មិនខាន នាងគួរលះបង់ផ្ទះដែលអ្នកប្រាជ្ញគប្បីតិះដៀល ហើយប្រព្រឹត្តធម៌ដែលអ្នកប្រាជ្ញមិនតិះដៀលវិញ ។ ខ្ញុំបានស្ដាប់ពាក្យរបស់មាតា ជាអ្នកមានចិត្តមិនរលោរលាំដោយរាងកាយនិងរូបនិងវ័យ ហើយចូលទៅកាន់ផ្នួស ។

មាតារបស់ខ្ញុំ ពោលដើម្បីធ្វើនូវសេចក្តីរំពឹក ដោយការរៀនឈានដ៏ធំ ជាធម្មជាតស្អាត តែខ្ញុំមិនបានខ្វល់ខ្វាយក្នុងការរៀនឈាននោះទេ ។ លំដាប់នោះ ព្រះជិនស្រី ប្រកបដោយមហាករុណា ឃើញខ្ញុំមានមុខដូចផ្កាឈូក ទ្រង់និម្មិតស្រីល្អគួររមិលមើល រុងរឿងក្រៃពេក មានរូបល្អជាងខ្ញុំ ក្នុងវង្វង់ចក្ខុរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំនឿយណាយក្នុងរូប ដោយអានុភាពនៃព្រះអង្គ ។ ខ្ញុំឃើញស្រីនោះ មានរាងកាយអស្ចារ្យក្រៃពេក ក៏ស្ញើចគិតថា ភ្នែករបស់អញប្រកបដោយផល ព្រោះរូបជារបស់មនុស្សនេះជាលាភនៃភ្នែក ។ ខ្ញុំនិយាយនឹងស្រីនោះថា ម្នាលស្រីល្អល្អះ នាងចូរមក នាងមានសេចក្តីត្រូវការដោយវត្ថុណា នាងចូរប្រាប់វត្ថុនោះដល់ខ្ញុំ បើ ( ពាក្យរបស់ខ្ញុំ ) ជាទីស្រឡាញ់នៃនាង ចូរនាងប្រាប់ខ្ញុំនូវត្រកូល នាម និងគោត្តរបស់នាង ។ ម្នាលស្រីល្អ ( កាលនេះ ) មិនមែនជាកាលគួរដោះស្រាយប្រស្នាទេ នាងចូរឲ្យខ្ញុំឋិតនៅលើភ្លៅ អវយវៈទាំងឡាយរបស់ខ្ញុំស្រុតចុះ នាងចូរឲ្យខ្ញុំដេកមួយរំពេច ។ លំដាប់នោះ ស្រីដែលព្រះពុទ្ធនិម្មិតដ៏ល្អនោះ ដេកកើយក្បាលលើភ្លៅនៃខ្ញុំ ខ្ញុំជាស្រីអាក្រក់យ៉ាងក្រៃលែង ក៏ដួលទៅលើថ្ងាសស្រីនោះ ពកក៏កើតឡើងដល់ស្រីនោះ ដំណាលគ្នានឹងការដួលចុះ ខ្ទុះនិងឈាមទាំងឡាយ ហូរចេញចាកសាកសពដែលបែកធ្លាយហើយផង មាត់មានក្លិនស្អុយ ដូចសាកសពបែកធ្លាយហើយផង សរីរៈទាំងមូលហើមប៉ោងឡើង មានសម្បុរខៀវផង ។ ស្រីនោះមានអវយវៈទាំងពួងញ័ររន្ធត់ ដកដង្ហើមចេញម្ហប ៗ ទទួលវេទនារបស់ខ្លួនខ្សឹកខ្សួល ( ព្រោះអាស្រ័យ ) នូវសេចក្តីករុណាថា អាត្មាអញលំបាកដោយ

សេចក្តីទុក្ខ ប៉ះពាល់នូវវេទនា ជ្រមុជចុះក្នុងទុក្ខធំ អាត្មាអញមានសម្លាញ់ជាទីពឹងនៃអាត្មាអញ ។ ឱ ! លំអមុខរបស់នាងបាត់ទៅឯណាទៅ ច្រមុះកោងរបស់នាង បាត់ទៅឯណាទៅ បបូរមាត់ដ៏ប្រសើរដូចជាផ្លែបាសទុំរបស់នាងបាត់ទៅឯណាទៅ មាត់របស់នាង បាត់ទៅឯណាទៅ ។ សម្បុររបស់នាងប្រហែលដោយព្រះចន្ទ បាត់ទៅឯណាទៅ កដ៏ប្រដាប់ដោយមាសរបស់នាងបាត់ទៅឯណាទៅ ចង្កោមផ្កានិងកម្រងផ្កានិងត្រចៀករបស់នាង ប្រកបដោយសម្បុរខុសគ្នា ។ ដោះរបស់នាងក្បំមានអាការៈដូចផ្កាឈូកក្តោប សាកសពមានក្លិនស្អុយ បែកធ្លាយហើយ មានក្លិនអាក្រក់ក្រៃពេក ។ នាងមានចង្កេះវល មានត្រគាកធំ មានខ្លួនអាក្រក់ក្រៃលែងដូចជ្រញ់ ពេញដោយវត្ថុមិនស្អាត ឱ ! ហ្ន៎ រូបមិនទៀងទេតើ ។ ពួកពាលតែងត្រេកអរក្នុងរូបណា រូបទាំងអស់នោះ ដែលកើតហើយ ជាសរីរៈមានក្លិនស្អុយ គួរខ្ពើម ជាទីខ្ពើមរអើម ដូចជាព្រៃស្មសាន ។ កាលនោះ ព្រះសាស្តា ជាបងរបស់ខ្ញុំ ប្រកបដោយមហាករុណា ជានាយកនៃសត្វលោក ទ្រង់ឃើញខ្ញុំមានចិត្តតក់ស្លុត ទ្រង់បានត្រាស់នូវគាថាទាំងនេះថា ម្នាលនាង នន្ទា នាងចូរមើលនូវសាកសពដែលឈឺជានិច្ច មានក្លិនស្អុយ មានឆ្អឹង ៣០០ កំណាត់លើកឡើងហើយ នាងចូរចម្រើនចិត្ត ដោយអសុភកម្មដ្ឋាន ឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំដោយប្រពៃចុះ ។ រូបរបស់នាងនេះ យ៉ាងណា រូបរបស់ស្រីនុ៎ះ ក៏យ៉ាងនុ៎ះដែរ រូបរបស់ស្រីនុ៎ះ យ៉ាងណា រូបរបស់នាងនេះ ក៏យ៉ាងនោះដែរ រូបនេះ មានក្លិនអាក្រក់ ស្អុយ ផ្សាយទៅ តែពួកពាលប្រាថ្នាក្រៃពេក ។ ជន

ទាំងឡាយ ដែលមិនខ្ជិលទាំងយប់ទាំងថ្ងៃ រមែងពិចារណាឃើញរូបទ្រុំយ៉ាង នេះឯង នាងនឿយណាយចាករូបនោះ ហើយឃើញដោយប្រាជ្ញារបស់ខ្លួន ចុះ ។ លំដាប់នោះ ខ្ញុំបានស្តាប់នូវគាថាជាសុភាសិត ក៏មានចិត្តតក់ស្លុត ខ្ញុំ ឋិតនៅក្នុងទីនោះ មានចិត្តស្ងប់ បានដល់នូវព្រះអរហត្ត ។ កាលនោះ ខ្ញុំ អង្គុយក្នុងទីណាៗ ក៏មានឈាន ជាទីប្រព្រឹត្តទៅខាងមុខ ព្រះជិនស្រី ត្រេក អរក្នុងគុណនោះហើយ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ កិលេសទាំងឡាយខ្ញុំ ដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុង សម្នាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិ-បត្តិហើយ ។

បានឮថា ព្រះនន្ទាភិក្ខុនីជនបទកល្យាណីមានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ នន្ទាថេរិយាបទាន ។**

# សោណាថេរិយាបទានទី ៦

[ ២៦ ] ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងហើយក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដល់នូវសេចក្តីសុខ ជាស្រីមានគេជាប់ចិត្ត ជាទីស្រឡាញ់ ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ជាអ្នកប្រាជ្ញដ៏ប្រសើរ បានស្តាប់តម្រាស់ដ៏ពីរោះ ។ ព្រះជិនស្រីទ្រង់សរសើរ ភិក្ខុនីអ្នកមានព្យាយាមលើសលុប ជាឯកភិក្ខុនីទាំងឡាយអ្នកមានព្យាយាមប្រារព្ធ ខ្ញុំបានស្តាប់ព្រះពុទ្ធតម្រាស់នោះ ក៏មានចិត្តរីករាយ ហើយធ្វើនូវសក្ការៈចំពោះព្រះសាស្តា ។ កាលនោះ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធ ហើយប្រាថ្នានូវតំណែងនោះ ព្រះមហាវីរបុរស ទ្រង់អនុមោទនាថា សេចក្តីប្រាថ្នានៃនាងនឹងសម្រេច ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូលនឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនឹងបាន ជាញាតិក្នុងធម៌ទាំងឡាយនៃព្រះសាស្តានោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្តា មានឈ្មោះថា សោណា ។ កាលនោះ ខ្ញុំបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះជិនស្រី ជានាយកនៃសត្វលោក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋី ជាត្រកូលស្តុកស្តម្ភធំទូលាយ មានទ្រព្យច្រើនក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរ ។ កាលណា ខ្ញុំ

ដល់នូវវ័យទៅត្រកូលប្តី បានបង្កើតកូន ១០ នាក់ មានរូបល្អប្លែកៗគ្នា កូនទាំងអស់នោះ ឋិតនៅក្នុងសេចក្តីសុខ ជាទីគាប់ភ្នែកនិងចិត្តនៃជន សូម្បីសត្រូវទាំងឡាយក៏គង់គាប់ចិត្តដែរ នឹងបាច់និយាយទៅថ្វី ដល់កូនទាំងនោះដែលជាទីស្រឡាញ់នៃខ្ញុំ លំដាប់នោះ ប្តីរបស់ខ្ញុំនោះ មានកូន ១០ នាក់ ចោមរោមទៅបួសក្នុងសាសនាព្រះពុទ្ធ ជាទេវតាកន្លងទេវតា ដោយខុសបំណងរបស់ខ្ញុំ ។ គ្រានោះ ខ្ញុំតែម្នាក់ឯង បានគិតថា ជីវិតមិនគួរដល់អញ ដែលជាស្រីចាស់កំព្រា ព្រាត់ប្រាសចាកប្តី និងកូនទាំងឡាយឡើយ ដូច្នេះ ប្តីរបស់អញនៅក្នុងទីណា អញនឹងទៅក្នុងទីនោះ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ចូលទៅកាន់ផ្នួស ។ លំដាប់នោះ ភិក្ខុនីទាំងឡាយលះបង់ខ្ញុំម្នាក់ឯងក្នុងលំនៅនៃភិក្ខុនីហើយក៏ទៅឲ្យឱវាទថា នាងចូរដាំទឹក ។ គ្រានោះ ខ្ញុំនាំទឹកមកហើយចាក់អំពីក្អមតម្កល់ទុកក្នុងកាជន៍តូច ហើយអង្គុយតម្កល់ចិត្តមាំក្នុងខណៈនោះ ។ ខ្ញុំឃើញនូវខន្ធទាំងឡាយ ថាមិនទៀងផង ជាទុក្ខផង ជាអនត្តាផង បានញ៉ាំងអាសវៈទាំងពួងឲ្យអស់ ហើយដល់ព្រះអរហត្ត ។ គ្រានោះ នាងភិក្ខុនីទាំងឡាយមកសួររកទឹកក្តៅ ខ្ញុំក៏បានអធិដ្ឋានតេជោធាតុ ហើយញ៉ាំងទឹកឲ្យក្តៅយ៉ាងរហ័ស ។ ភិក្ខុនីទាំងនោះស្ងើច ហើយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះជិនស្រីដ៏ប្រសើរ ព្រះពុទ្ធជាទីពឹងនៃសត្វលោក ទ្រង់ព្រះសណ្តាប់សេចក្តីនោះហើយក៏រីករាយ ត្រាស់គាថានេះថា បុគ្គលណាមួយ ជាអ្នកខ្ជិលច្រអូស មានព្យាយាមថោកថយ គប្បីរស់នៅអស់ ១០០ ឆ្នាំ ជីវិតរបស់បុគ្គលដែលមានព្យាយាមប្រារព្ធមាំ រស់នៅតែមួយថ្ងៃ ប្រសើរជាង ។ ព្រះមហាមុនី មានព្យាយាម

ជំ ខ្ញុំបានធ្វើឲ្យរីករាយហើយដោយសេចក្តីប្រតិបត្តិដ៏ប្រពៃ ហើយទ្រង់ត្រាស់ថា ខ្ញុំជាស្រីប្រសើរផុតជាងភិក្ខុនីទាំងឡាយអ្នកមានព្យាយាមប្រារព្ធហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោណាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ សោណាថេរិយាបទាន ។

# ភទ្ទកាបិលានីថេរិយាបទានទី ៧

[ ២៧ ] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយកនៃសត្វលោក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ កាលនោះ សេដ្ឋីឈ្មោះវិទេហៈ មានកែវដ៏ប្រសើរនៅក្នុងក្រុងហង្សវតី ខ្ញុំជាប្រពន្ធនៃសេដ្ឋីនោះ ។ ក្នុងកាលមួយ សេដ្ឋីនោះ ព្រមទាំងជនជាបរិស័ទ ចូលទៅគាល់ព្រះពុទ្ធ ជាព្រះអាទិត្យរបស់នរជន ហើយស្តាប់ធម៌របស់ព្រះពុទ្ធ ជាទីនាំមកនូវការអស់ទៅនៃទុក្ខទាំងពួង ។ ព្រះពុទ្ធជានាយកទ្រង់សរសើរនូវសាវ័កថា ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ អ្នកពោលពាក្យជាគ្រឿងកម្ចាត់បង់នូវកិលេស ។ ខ្ញុំបានស្តាប់ហើយ ថ្វាយទានដល់ព្រះពុទ្ធជាតាទិបុគ្គលអស់ ៧ ថ្ងៃ ។ ខ្ញុំក្រាបទៀបព្រះបាទាដោយសិរ្សៈ ប្រាថ្នាតំណែងនោះ គ្រានោះ ព្រះអង្គជាអ្នកធ្មើមជាងនរៈ ទ្រង់ញុំាងបរិស័ទឲ្យរីករាយហើយ ទ្រង់ត្រាស់គាថាទាំងនេះដើម្បីអនុគ្រោះសេដ្ឋីថា ម្នាលកូន អ្នកនឹងបានតំណែងដែលអ្នកប្រាថ្នាហើយ អ្នកចូរបានរំលត់ទុក្ខចុះ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកៈត្រកូលនឹងត្រាស់ឡើងក្នុងលោក ។ សេដ្ឋីនោះនឹងបានជាញាតិក្នុងធម៌ទាំងឡាយនៃព្រះសាស្តានោះ ជាឱរស ជាធម្មនិម្មិត ជាសាវ័កនៃព្រះសាស្តា មានឈ្មោះកស្សបៈ ។ កាលនោះ ខ្ញុំបានស្តាប់ព្យាករណ៍នោះហើយ ក៏រីករាយ មានចិត្តប្រកបដោយមេត្តាបម្រើព្រះជិនស្រី ព្រះអង្គជានាយកនៃសត្វលោក ដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ព្រះពុទ្ធអង្គនោះ ញុំាងសាសនាឲ្យរុងរឿង ញុំាញីនូវតិរ្ថិយអាក្រក់ទាំងឡាយ ទូន្មាននូវវេនេយ្យសត្វ ព្រះអង្គព្រមទាំងសាវ័កបរិនិព្វាន

ហើយ ។ កាលព្រះមានព្រះភាគ ជាកំពូលនៃសត្វលោកនោះ និព្វានហើយ មហាជនបានប្រជុំញាតិនិងមិត្ត មួយអន្លើដោយសាវកទាំងឡាយនោះ បាន ញុំាងជនឲ្យធ្វើព្រះស្តូបជាវិការៈនៃកែវ កម្ពស់ ៧ យោជន៍ ដ៏រុងរឿងដូចព្រះ អាទិត្យ ឬដូចស្តេចឈើមានផ្ការីក ដើម្បីបូជាព្រះសាស្តា ។ ខ្ញុំបានឲ្យគេសាង កាជន៍ ៧ អស់ទ្រព្យ ៧ សែន កាជន៍ទាំងនោះ រុងរឿងដោយកែវ ៧ ដូច ភ្លើងឆេះបបុស ។ ខ្ញុំញុំាងប្រទីបទាំងនោះឲ្យពេញដោយប្រេងក្រអូប ហើយ អុជបំភ្លឺក្នុងទីនោះ ដើម្បីបូជាព្រះពុទ្ធទ្រង់ស្វែងរកគុណធំ ទ្រង់អនុគ្រោះដល់ សត្វទាំងពួង ។ ខ្ញុំសាងក្អមដ៏ពេញចំនួន ៧ សែន ដ៏ពេញដោយកែវ ៧ ដើម្បី បូជាដល់ព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ ។ គ្រឿងបូជា ជាវិការៈនៃមាសដែល បុគ្គលលើកឡើងហើយក្នុងកណ្តាលនៃក្អមប្រាំបីៗ ដ៏រុងរឿងដោយសម្បុរ ដូច ជាព្រះអាទិត្យក្នុងសរទសម័យ ។ ខ្លោងទ្វារជាវិការៈនៃកែវល្អ ក្នុងទ្វារទាំង ៤ ផែនក្តារជាវិការៈនៃកែវជាទីរីករាយ ដែលបុគ្គលលើកឡើងហើយក៏ល្អ ។ របងទាំងឡាយមានកំពូលដែល បុគ្គលតាក់តែងល្អរុងរឿង ទង់ទាំងឡាយជា វិការៈនៃកែវដែលបុគ្គលលើកឡើងហើយក៏រុងរឿង ។ ចេតិយនេះ ជាវិការៈ នៃកែវមានសម្បុរក្រហមល្អ ដែលបុគ្គលធ្វើហើយដោយប្រពៃ រុងរឿងដោយ សម្បុរដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃល្ងាច ។ ខ្ញុំបានញុំាងទិសទាំង ៣ នៃព្រះ ស្តូបរបស់ខ្ញុំឲ្យពេញ គឺទិស ១ ពេញដោយថ្មហរិតាល ទិស ១ ពេញដោយ ថ្មមនោសិលា ទិស ១ ពេញដោយថ្មមានពណ៌ខៀវ ។ ខ្ញុំបានញុំាងជនឲ្យធ្វើ នូវការបូជា ជាទីរីករាយប្រាជកដូចនុ៎ះ ។ ដល់ព្រះពុទ្ធមានវាទៈដ៏ប្រសើរហើយ

ឲ្យទានដល់ព្រះសង្ឃ តាមសមគួរដល់កម្លាំងដរាបដល់អស់ជីវិត ។ ខ្ញុំធ្វើបុណ្យទាំងនោះ ដោយសព្វគ្រប់ជាមួយនឹងសេដ្ឋីនោះ ដរាបដល់អស់ជីវិត ហើយក៏បានទៅកាន់សុគតិជាមួយគ្នា ។ ខ្ញុំបានសោយសម្បត្តិទាំងឡាយក្នុងអត្តភាពជាទេវតា និងមនុស្ស អន្ទោលទៅជាមួយនឹងសេដ្ឋីនោះ ដូចជាស្រមោលអន្ទោលទៅតាមសរីរៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយកទ្រង់ព្រះនាមវិបស្សី មានព្រះនេត្រដូចមាស ពិចារណាឃើញច្បាស់នូវធម៌ទាំងពួង ទ្រង់កើតឡើង ។ គ្រានោះ មានព្រាហ្មណ៍ម្នាក់ក្នុងក្រុងពន្ធុមតី គេសន្មតថាជាសប្បុរស ជាអ្នកមាំមួន ស្ងប់ស្ងាត់ដោយគុណ តែជាអ្នកខ្សត់ទ្រព្យក្រៃពេក ។ កាលនោះ ខ្ញុំជាព្រាហ្មណីរបស់ព្រាហ្មណ៍នោះ មានចិត្តស្មើគ្នា ជួនកាលព្រាហ្មណ៍ប្រសើរនោះ បានគប់រកព្រះមហាមុនី ដែលគង់សម្តែងអមតនិព្វានក្នុងពួកជន គាត់បានស្តាប់ធម៌ ក៏មានចិត្តរីករាយ បានថ្វាយសំពត់សាកដ ១ ហើយទៅកាន់ផ្ទះដោយសំពត់ ១ ហើយពោលពាក្យនេះនឹងខ្ញុំថា ម្នាលនាងមានបុណ្យធំ នាងចូររីករាយចំពោះសំពត់សាកដដែលបងបានថ្វាយដល់ព្រះពុទ្ធចុះ ។ កាលនោះ ខ្ញុំដឹងច្បាស់ បានធ្វើអញ្ជលីអនុមោទនាថា បពិត្រស្វាមី ខ្ញុំសូមអនុមោទនាសាកដដែលអ្នកថ្វាយហើយដោយប្រពៃដល់ព្រះពុទ្ធដ៏ប្រសើរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ប្តីនៃខ្ញុំនោះ ដល់ហើយនូវសេចក្តីសុខ ត្រូវបុញ្ញកម្មចាត់ចែង កាលអន្ទោលទៅក្នុងភពតូចនិងភពធំ បានកើតជាស្តេចម្ចាស់ផែនដី ក្នុងក្រុងពារាណសី ជាទីរីករាយ ។ កាលនោះ ខ្ញុំជាមហេសីនៃស្តេចនោះ ជាអ្នកខ្ពង់ខ្ពស់ជាងពួកស្រី

ហើយជាអគ្គមហេសី ដ៏ប្រសើរក្រៃលែងជាងសេចក្តីស្រឡាញ់នៃស្តេចនោះ ដែលមានក្នុងកពមុន ។ ស្តេចនោះ ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ និមន្តទៅដើម្បីបិណ្ឌបាត ក៏មានចិត្តរីករាយ ប្រគេនចង្ហាន់បិណ្ឌបាត មានថ្លៃច្រើន ។ ស្តេចនោះ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយ ហើយធ្វើបារាំកែវជាវិការៈនៃមាសមានប្រមាណ ១០០ ហត្ថ មានសណ្ឋានរលីង ដែលពួកជាងធ្វើហើយ ។ ព្រះរាជានោះ ទ្រង់រាប់អានព្រះបច្ចេកពុទ្ធទាំងអស់នោះ មានសេចក្តីជ្រះថ្លា ហើយបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដែលចូលទៅកាន់ទីសេនាសនៈដោយព្រហស្តនៃព្រះអង្គ ។ កាលនោះ ខ្ញុំបានឲ្យទាននោះ ជាមួយនឹងស្តេចក្នុងដែនកាសី ខ្ញុំកើតក្នុងកាសិកគ្រាម ជិតក្រុងពារាណសីម្តងទៀត ។ ស្តេចនោះ កើតក្នុងត្រកូលកុដុម្ពិកៈដ៏ធំទូលាយ ដល់នូវសេចក្តីសុខ ព្រមទាំងបងប្អូន ខ្ញុំជាប្រពន្ធនៃបងច្បង ជាស្រីមានវត្តដល់ប្តីដោយប្រពៃ ។ ប្អូនរបស់ប្តីខ្ញុំ បានឃើញព្រះបច្ចេកពុទ្ធហើយប្រគេនភត្តរបស់បងដល់ព្រះបច្ចេកពុទ្ធនោះ កាលបើបងនោះត្រឡប់មក ខ្ញុំបាននិយាយប្រាប់សព្វគ្រប់ ។ បងនោះមិនត្រេកអរចំពោះទាន លំដាប់នោះ ខ្ញុំបានឲ្យភត្តដល់ប្តីនោះ ប្តីនោះនាំបាយនោះ ហើយថ្វាយដល់ព្រះពុទ្ធនោះទៀត ។ កាលនោះ ខ្ញុំចោលនូវទាននោះហើយ ប្រទូស្តចំពោះព្រះពុទ្ធ ខ្ញុំបានឲ្យបាត្រដ៏ពេញដោយភក់ដល់ព្រះពុទ្ធនោះ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ កាលនោះ ខ្ញុំឃើញព្រះពុទ្ធ មានព្រះទ័យស្មើក្នុងការឲ្យទានផង ក្នុងការទទួលផង ក្នុងសេចក្តីកោតក្រែងផង ក្នុងសេចក្តីប្រទូស្តផង ហើយសង្វេគក្រៃលែង ។ ខ្ញុំកាន់យកបាត្រម្តងទៀត

ជម្រះដោយគ្រឿងក្រអូប មានចិត្តជ្រះថ្លាញ៉ាំងបាត្រឲ្យពេញ ហើយឲ្យស្គរព្រមទាំងទឹកដោះថ្លា ។ ខ្ញុំកើតក្នុងទីណាៗ ជាស្រីមានរូបល្អព្រោះទាននោះ ខ្ញុំជាស្រីមានក្លិនអាក្រក់ ព្រោះប្រទូស្តចំពោះព្រះពុទ្ធផង ព្រោះសេចក្តីស្រវឹងផង ។ កាលចេតិយនៃព្រះពុទ្ធ ព្រះនាមកស្សបៈ ជាអ្នកប្រាជ្ញ គេឲ្យសម្រេចហើយ ខ្ញុំមានចិត្តរីករាយ បានឲ្យឥដ្ឋជាវិការៈនៃមាសដ៏ប្រសើរទៀត ។ ខ្ញុំជ្រលក់ឥដ្ឋនោះឲ្យទទឹកដោយគ្រឿងក្រអូប មានជាតិ ៤ យ៉ាង ក៏បានរូបស្រឡះចាកទោសមានក្លិនអាក្រក់ ប្រកបដោយអវយវៈទាំងពួងដ៏ល្អ ។ ខ្ញុំឲ្យធ្វើភាជន៍ ៧០០០ ដោយកែវ ៧ ប្រការផង ប្រឆេះ ១០០០ ដ៏ពេញដោយខ្លាញ់ផង ។ ខ្ញុំមានចិត្តជ្រះថ្លាបានចាក់ប្រេងអុជបំភ្លឺតម្កល់ទុក ៧ ជួរ ដើម្បីបូជាព្រះលោកនាថ ។ គ្រានោះ ខ្ញុំជាស្រីមានចំណែកក្នុងបុណ្យនោះ ដោយវិសេស ( បុរសនោះ ) កើតក្នុងដែនកាសីទៀត ប្រាកដដោយឈ្មោះថាសមិត្តបុរស ។ កាលនោះ ខ្ញុំជាភរិយាបុរសនោះ ជាអ្នកដល់នូវសេចក្តីសុខមានគេជាប់ចិត្ត ជាទីស្រឡាញ់នៃជន ឯប្តីខ្ញុំបានប្រគេនឈ្នួតមានសាច់ក្រាស់ដល់ព្រះបច្ចេកមុនី ។ម្យ៉ាងទៀត ខ្ញុំជាស្រីមានចំណែកដោយបុណ្យ ត្រេកអរនូវទានដ៏ឧត្តមរបស់ប្តីនោះ ។ ឯបុរសនោះកើតក្នុងជាតិកោលិយជន ក្នុងដែនកាសីទៀត ។ កាលនោះ សមិត្តបុរសនោះ បម្រើព្រះបច្ចេកពុទ្ធ ៥០០ អង្គ មួយអន្លើដោយកោលិបុត្ត ៥០០ នាក់ ។ រួចហើយនិមន្តព្រះបច្ចេកពុទ្ធទាំងឡាយឲ្យគង់នៅអស់ ៣ ខែ ហើយប្រគេនត្រៃចីវរ កាលនោះ ខ្ញុំជាប្រពន្ធនៃសមិត្តបុរសនោះ ជាអ្នកប្រព្រឹត្តទៅតាមគន្លងនៃបុញ្ញកម្ម ។ សមិត្ត

បុរសនោះច្យុតចាកអត្តភាពនោះ បានកើតជាស្តេចព្រះនាមនន្ទៈ មានយសធំ ខ្ញុំជាមហេសីនៃស្តេចនោះ ជាអ្នកសម្រេចនូវសេចក្តីប្រាថ្នាទាំងពួង ។ លុះច្យុតអំពីអត្តភាពនោះហើយ បានកើតជាស្តេចព្រហ្មទត្ត ជាម្ចាស់ផែនដី កាលនោះខ្ញុំបម្រើព្រះបច្ចេកមុនីជាបុត្តនៃនាងបទុមាវតី ។ ខ្ញុំបម្រើព្រះបច្ចេកមុនី ៥០០ អង្គ ដរាបដល់អស់ជីវិត ហើយនិមន្តព្រះបច្ចេកមុនីទាំងឡាយ ឲ្យនៅក្នុងឧទ្យាននៃស្តេច ហើយបូជានូវព្រះបច្ចេកមុនីទាំងឡាយ ដែលនិព្វានហើយ ។ យើងទាំងពីរនាក់ បានឲ្យជាងធ្វើចេតិយទាំងឡាយ ហើយបួសចម្រើនអប្បមញ្ញាទាំងឡាយ ក៏បានទៅកើតក្នុងព្រហ្មលោក ។ លុះច្យុតចាកព្រហ្មលោកប្តីកើតក្នុងមហាតិត្ថ ជាកូនចៅនៃបិប្ផលគោត្ត ឯមាតាឈ្មោះសុមនទេវី បិតាជាព្រាហ្មណ៍កោសិគោត្ត ។ ខ្ញុំ ( កើត ) ក្នុងក្រុងសាកលា ជាបុរីដ៏ឧត្តមក្នុងជនបទឈ្មោះមទ្ទៈ ។ ខ្ញុំជាធីតានៃកបិលព្រាហ្មណ៍ មាតាឈ្មោះសុចិមតី បិតាស្អិតស្អាងខ្ញុំ ដោយរូបភាពជាវិការៈនៃមាសតាន់ បានឲ្យខ្ញុំដល់កស្សបបណ្ឌិតជាអ្នកវៀរចាកកាមទាំងឡាយ កាលដែលកស្សបបណ្ឌិតនោះនៅក្មេង បានទៅមើលការងារ ឃើញសត្វតូច ៗ ត្រូវពួកសត្វមានក្អែកជាដើមទំពាស៊ី ក៏សង្វេគ ។ ខ្ញុំឃើញគ្រាប់ល្ងទាំងឡាយដែលគេហាលក្នុងកម្តៅថ្ងៃជិតផ្ទះ ត្រូវពួកដង្កូវនិងក្អែកទំពាស៊ី បាននូវសេចក្តីសង្វេគក្នុងកាលនោះ ។ កាលនោះកស្សបបណ្ឌិតនោះបួសហើយ ខ្ញុំក៏បួសតាមកស្សបណ្ឌិតនោះដែរ ខ្ញុំនៅអាស្រ័យក្នុងគន្លងនៃបរិព្វាជកវត្តអស់ ៥ វស្សា ។ កាលណា នាងគោតមីជាអ្នកចិញ្ចឹមព្រះជិនស្រីបួសហើយ កាលនោះខ្ញុំក៏ចូលទៅរកនាងគោតមីនោះ

ដែលព្រះពុទ្ធប្រៀនប្រដៅហើយ ។ អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានដល់ព្រះអរហត្ត ឱហ្ន៎ ! ព្រះកស្សបមានសិរីជាមិត្តល្អ ។ ព្រះកស្សបជាកូន ជាញាតិនៃព្រះពុទ្ធ មានចិត្តតម្កល់ខ្ជាប់ហើយដោយប្រពៃ លោកដឹងនូវបុព្វេនិវាសផង ឃើញនូវឋានសួគ៌និងអបាយផង ។ ម្យ៉ាងទៀត ព្រះកស្សបនោះ ជាអ្នកប្រាជ្ញ មានអភិញ្ញានៅរួចហើយ បានដល់នូវការអស់ទៅនៃជាតិ ជាខីណាសវព្រាហ្មណ៍ មានវិជ្ជា ៣ ដោយវិជ្ជាទាំង ៣ នេះ ។ ភទ្ទកាបិលានីមានវិជ្ជា ៣ លះបង់មច្ចុ ទ្រទ្រង់រាងកាយមានក្នុងទីបំផុត ឈ្នះមារព្រមទាំងវាហនៈដូចគ្នាដែរ ។ យើងទាំងពីរនាក់ ឃើញទោសក្នុងលោក ហើយបួស យើងទាំងពីរនាក់នោះ មានអាសវៈអស់ហើយ មានខ្លួនទូន្មានហើយ មានសេចក្តីត្រជាក់កើតហើយ មានទុក្ខរំលត់ហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្ត្រីមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភទ្ទកាបិលានីភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

**ចប់ ភទ្ទកាបិលានីថេរិយាបទាន ។**

# យសោធរាថេរិយាបទានទី ៨

[ ២៨ ] ខ្ញុំជាអ្នកមានឫទ្ធិច្រើន មានប្រាជ្ញាច្រើន មាននាងភិក្ខុនី ទាំងឡាយ ១ សែនអង្គ ចោមរោមហើយ ចូលទៅគាល់ព្រះសម្ពុទ្ធ ។ ថ្វាយបង្គំព្រះសម្ពុទ្ធនិងលក្ខណៈគឺចក្កនៃព្រះសាស្តា អង្គុយក្នុងទីសមគួរ ហើយពោលពាក្យនេះថា ខ្ញុំមានវស្សា ៧៨ កន្លងបច្ឆិមវ័យ ខ្ញុំមកដល់ញកហើយក្រាបទូលព្រះមហាមុនីថា វ័យរបស់ខ្ញុំចាស់ណាស់ហើយ ជីវិតរបស់ខ្ញុំតិចណាស់ ខ្ញុំនឹងលះបង់ព្រះអង្គហើយទៅ ទីពឹងរបស់ខ្លួនខ្ញុំបានធ្វើហើយ ។ ក្នុងកាលជាបច្ឆិមវ័យ សេចក្តីស្លាប់កាន់តែរំកិលចូលមកជិត បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំម្ចាស់នឹងដល់នូវនិព្វានក្នុងវេលាយប់ថ្ងៃនេះ បពិត្រព្រះមហាមុនី ជាតិ ជរា ព្យាធិ និងមរណៈ មិនមាន ខ្ញុំនឹងដល់នូវបុរីដែលជាទីឥតមានជរាឥតមានមរណៈ ឥតមានភ័យ មិនមានបច្ច័យតាក់តែងឡើយ ។ បពិត្រព្រះមហាមុនី ធម្មតាបរិស័ទទាំងឡាយ តែងចូលទៅអង្គុយជិតព្រះសាស្តា ដឹងច្បាស់នូវកំហុស និងសេចក្តីគួរក្នុងទីចំពោះព្រះភក្ត្រ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គអន្ទោលទៅក្នុងសង្សារ សូមក្រាបទូលនូវការភ្លាំងភ្លាត់របស់ខ្ញុំចំពោះព្រះអង្គ សូមព្រះអង្គអត់នូវកំហុសនោះដល់ខ្ញុំព្រះអង្គ ។ នាងជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅនៃតថាគត ចូរនាងសម្តែងនូវឫទ្ធិ ចូរកាត់នូវសេចក្តីសង្ស័យនៃបរិស័ទទាំងពួងក្នុងសាសនា ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំឈ្មោះយសោធរា ជាករិយានៃព្រះអង្គ ( កាលនៅ ) ក្នុងផ្ទះ កើតក្នុងត្រកូលសក្យៈ តាំងនៅក្នុងអង្គជាស្ត្រី ។ បពិត្រព្រះអង្គមានព្យាយាម ខ្ញុំជាប្រធាននៃស្ត្រីទាំងឡាយ ១ សែន ៩៦ ជាធំជាងស្ត្រីទាំងពួងក្នុងផ្ទះនៃព្រះ

អង្គ ស្ត្រីទាំងពួង ប្រកបដោយគុណគឺរូបនិងមារយាទ តាំងនៅក្នុងបឋមវ័យសព្វៗកាល គោរពកោតក្រែងខ្ញុំ ដូចជាមនុស្សទាំងឡាយ គោរពកោតក្រែងទេវតា ។ ស្ត្រីទាំងនោះ មានពួកនាងកញ្ញា ១០០០ ជាប្រធាន មានសុខនិងទុក្ខស្មើគ្នា ក្នុងដំណាក់នៃសក្យបុត្ត ដូចជាពួកទេវតាក្នុងនន្ទនវ័ន ។ បណ្ឌិតទាំងឡាយ កន្លងនូវកាមធាតុ ប្រាកដស្មើដោយរូបក្នុងរូបធាតុ វៀរលែងតែព្រះលោកនាយកចេញមិនមានទេ ។ យសោធរាថេរី ថ្វាយបង្គំព្រះសម្ពុទ្ធហើយសម្តែងឫទ្ធិចំពោះព្រះសាស្តា ទាំងសម្តែងឫទ្ធិច្រើន មានអាការៈផ្សេងៗច្រើនយ៉ាង ។ គឺធ្វើកាយជាភ្នំចក្កវាឡ ក្បាលជាឧត្តរកុរុទ្វីប ទ្វីបទាំងពីរជាស្លាបទាំងពីរ ជម្ពូទ្វីបជាសរីរៈ ។ សមុទ្រខាងត្បូងជាសំណុំកន្ទុយ ស្លឹកជាលំពង់ស្លាប ព្រះចន្ទនិងព្រះអាទិត្យជាភ្នែក ភ្នំមេរុជាកំប៉ោយ ។ ភ្នំចក្កវាឡជាចំពុះ ដើមព្រីងជាទីប្រជុំ ហើយចូលទៅជិតថ្វាយបង្គំ អង្គុយបត់ព្រះលោកនាយក ។ សម្តែងនូវភេទនៃដំរី សេះ ភ្នំ ជលជាត ព្រះចន្ទ ព្រះអាទិត្យភ្នំមេរុ ភេទនៃព្រះឥន្ទ ក៏ដូចគ្នា ។ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ ខ្ញុំព្រះអង្គឈ្មោះយសោធរា សូមក្រាបថ្វាយបង្គំព្រះបាទា គ្របនូវលោកធាតុ ១ ពាន់ ដោយផ្កាវីក ។ ខ្ញុំនិម្មិតភេទជាព្រហ្ម ហើយសម្តែងធម៌ដ៏សូន្យ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ ខ្ញុំព្រះអង្គឈ្មោះយសោធរា សូមក្រាបថ្វាយបង្គំព្រះបាទា ។ បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយ ទាំងស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណ ដោយសោតធាតុជាទិព្វ ។ ខ្ញុំព្រះអង្គដឹងនូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំព្រះអង្គបានជម្រះហើយ អាសវៈទាំង

ពួងអស់រលើងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្ដីជឹងក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ កើតឡើងហើយដល់ខ្ញុំក្នុងសម្នាក់នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី ការគប់រកព្រះលោកនាថទាំងឡាយ ព្រះអង្គបានសម្ដែងហើយដោយប្រពៃ សេចក្ដីកសាងដ៏ច្រើនរបស់ខ្ញុំ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមុនី សូមព្រះអង្គរឭកកុសលកម្មរបស់ខ្ញុំដែលមានក្នុងកាលមុន បពិត្រព្រះអង្គមានព្យាយាមធំ បុណ្យខ្ញុំបានសន្សំហើយដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំបានលះបង់នូវអកុសលដ្ឋាន ហាមឃាត់នូវអនាចារៈ ហើយលះបង់ជីវិតដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់ប្រទានខ្ញុំម្ចាស់ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន ដើម្បីជាកិរិយា ( នៃជនដទៃវិញ ) ខ្ញុំមិនតូចចិត្តក្នុងរឿងនោះព្រោះជាប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានខ្ញុំម្ចាស់អស់ជាតិមានពាន់នៃកោដិដ៏ច្រើនដើម្បីជាឧបការៈ ( នៃជនដទៃ ) ខ្ញុំក៏មិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានខ្ញុំម្ចាស់អស់ជាតិមានពាន់នៃកោដិដ៏ច្រើន ដើម្បីការប្រើប្រាស់ ( នៃជនដទៃ ) ខ្ញុំមិនតូចចិត្តក្នុងរឿងនោះព្រោះជាប្រយោជន៍ដល់ព្រះអង្គ ។ ខ្ញុំបានលះបង់ជីវិត មានពាន់នៃកោដិដ៏ច្រើន ជនទាំងឡាយនឹងធ្វើការរួចចាកភ័យ ខ្ញុំឲ្យនូវជីវិតរបស់ខ្ញុំ ។ បពិត្រព្រះមហាមុនី ខ្ញុំមិនលាក់ទុកនូវគ្រឿងប្រដាប់សម្រាប់អវយវៈ គ្រឿងអលង្ការសំពត់ដ៏ច្រើន មានប្រការផ្សេងៗនិងកណ្ឌៈរបស់ស្រីប្រុសដើម្បីជាប្រយោជន៍

ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ការបរិច្ចាគទ្រព្យធននិងស្រូវ ទាំងស្រុក និគម ស្រែ បុត្តនិងធីតា ខ្ញុំក៏បានលះបង់ហើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ ដំរី សេះ គោ និងខ្ញុំស្រី អ្នកបម្រើ មានចំនួនរាប់មិនបាន ខ្ញុំក៏បានលះបង់ហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ ។ ព្រះអង្គព្រឹក្សានូវទានណានីង ខ្ញុំ ខ្ញុំឲ្យនូវទាននោះដល់ស្មូមទាំងឡាយ កាលព្រះអង្គឲ្យទានដ៏ឧត្តម ខ្ញុំមិនឃើញសេចក្តីតូចចិត្តរបស់ខ្ញុំទេ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំវេទនាដ៏ច្រើន មានប្រការផ្សេងៗ មានចំនួនរាប់មិនបាន ក្នុងសង្សារដ៏ច្រើន ដើម្បីប្រយោជន៍នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី កាលព្រះអង្គដល់នូវសេចក្តីសុខ ខ្ញុំក៏ត្រេកអរ មួយទៀត ខ្ញុំមិនតូចចិត្ត ព្រោះទុក្ខទាំងឡាយរបស់ខ្ញុំ ខ្ញុំជាអ្នកត្រេកអរក្នុងទីទាំងពួងដើម្បីជាប្រយោជន៍នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គសោយសុខនិងទុក្ខ ត្រាស់ដឹងតាមលំដាប់មគ្គ ហើយដល់នូវពោធិញ្ញាណ រួបនាំមកនូវធម៌ ។ ខ្ញុំមានការគប់រកព្រះលោកនាថដទៃច្រើនអង្គ ( ព្រោះអាស្រ័យ ) នូវព្រះសម្ពុទ្ធជាព្រះលោកនាយកព្រះនាមគោតមជាទេវតាប្រសើរ ។ បពិត្រព្រះមហាមុនី ការកសាងដ៏ច្រើនរបស់ខ្ញុំ ដើម្បីប្រយោជន៍នៃព្រះអង្គ ខ្ញុំជាអ្នកបម្រើព្រះអង្គដែលស្វែងរកនូវពុទ្ធធម៌ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្យាយាមធំ ជានាយកនៃសត្វលោកកើតហើយក្នុងកប្បទី ៤ អសង្ខេយ្យនិងមួយសែន ។ ជនទាំងឡាយនៅក្នុងបច្ចន្តប្រទេសមានចិត្តត្រេកអរ និមន្តព្រះតថាគត ហើយជម្រះផ្លូវជាទីស្តេចមកនៃព្រះទីបង្ករនោះ ។ កាលនោះព្រះអង្គជាព្រាហ្មណ៍ឈ្មោះសុមេធ: គាត់តែងផ្លូវសម្រាប់

ថ្វាយព្រះពុទ្ធទីបង្ករ ទ្រង់ឃើញធម៌ទាំងពួង កាលស្ដេចមកដល់ ខ្ញុំជាកញ្ញាកើតក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះនាងសុមិត្តា បានចូលទៅកាន់ទីប្រជុំ ។ ខ្ញុំយកផ្កាឧប្បល ៨ ក្ដាប់ ដើម្បីបូជាព្រះសាស្ដា បានឃើញឥសីដ៏ឧត្ដម ក្នុងកណ្ដាលនៃជន ។ កាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ខានយានមកអស់កាលយូរ ទ្រង់មានព្រះទ័យប្រកបដោយករុណា ក៏បណ្ដាលឲ្យចិត្តត្រេកអរក្រៃលែង ហើយសម្គាល់ថា ជីវិតរបស់អាត្មាអញ ប្រកបដោយផល ។ កាលនោះ ខ្ញុំបានឃើញសេចក្ដីព្យាយាម ប្រកបដោយផលរបស់ឥសីនោះ ទាំងចិត្តរបស់ខ្ញុំ ក៏ជ្រះថ្លាក្នុងព្រះពុទ្ធ ដោយកុសលកម្មមានក្នុងកាលមុន ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែងក្នុងឥសីមានចិត្តខ្ពង់ខ្ពស់ ហើយទូលថា បពិត្រឥសី ខ្ញុំមិនឃើញវត្ថុដទៃដែលគួរថ្វាយទេ ខ្ញុំសូមថ្វាយផ្កាទាំងឡាយដល់លោក ។ បពិត្រឥសី ផ្កា ៥ ក្ដាប់ ចូរមានដល់លោក ផ្កា ៣ ក្ដាប់ ចូរមានដល់ខ្ញុំ បពិត្រឥសី ផ្កាទាំងឡាយចូរជារបស់ស្មើគ្នាមួយអន្លើដោយឥសីនោះ ដើម្បីប្រយោជន៍ដល់ពោធិញ្ញាណរបស់ព្រះអង្គ ។

## ចប់ ភាណវារៈទី ៤ ។

ឥសីយកផ្កាទាំងឡាយបូជាព្រះពុទ្ធជាមហាឥសី មានយសធំ ដែលមកក្នុងកណ្ដាលនៃពួកជន ដើម្បីប្រយោជន៍ដល់ពោធិញ្ញាណ ។ ព្រះមហាមុនីព្រះនាមទីបង្ករ មានព្យាយាមធំ ឃើញឥសីមានចិត្តខ្ពង់ខ្ពស់ ទ្រង់ព្យាករក្នុងកណ្ដាលនៃជន ។

ព្រះមហាមុនី ព្រះនាមទីបង្ករ ជាអ្នកប្រាជ្ញ ទ្រង់ព្យាករនូវអំពើរបស់ខ្ញុំ ដែលជាស្រីមានភាពត្រង់ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះថា ម្នាល មហាឥសី ស្រីនេះ នឹងជាអ្នកមានចិត្តស្មើគ្នា មានការងារស្មើគ្នា ជាអ្នកធ្វើការស្មើគ្នា ជាទីស្រឡាញ់ដោយការងារស្មើគ្នានឹងអ្នក ដើម្បីប្រយោជន៍នៃអ្នក ។ មួយទៀត ស្រីនេះនឹងជាអ្នកមានរូបគួរឲ្យរមិលមើលក្រៃលែង គួរឲ្យស្រឡាញ់ពេញចិត្តក្រៃលែង ពោលពាក្យជាទីស្រឡាញ់ ជាអ្នកមានឫទ្ធិ នឹងបានជាញាតិក្នុងធម៌នៃព្រះពុទ្ធនោះ ។ ប្រៀបដូចជនជាម្ចាស់ទ្រព្យ រមែងរក្សាស្មុគសម្រាប់ដាក់នូវកណ្ឌៈយ៉ាងណា ស្រីនេះ នឹងរក្សាធម៌ជាកុសលទាំងឡាយក៏យ៉ាងនោះដែរ ។ ស្រីនេះ កាលអនុគ្រោះនូវកុសលធម៌នោះ របស់ព្រះពុទ្ធនោះ នឹងញុំាងបារមីទាំងឡាយឲ្យពេញ នឹងដល់នូវពោធិញ្ញាណ ដូចសត្វសីហៈលះបង់ទ្រុងដូច្នោះ ។

ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះពុទ្ធទ្រង់ព្យាករខ្ញុំដោយវាចាណា ខ្ញុំត្រេកអរចំពោះវាចានោះ ជាអ្នកធ្វើយ៉ាងនោះ កាលកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងកុសលនោះ ហើយបានកំណើតជារបស់នៃទេវតានិងមនុស្សរាប់មិនអស់ ។ លុះទទួលនូវសេចក្តីសុខនិងទុក្ខក្នុងទេវតានិងមនុស្សហើយ ដល់មកក្នុងបច្ឆិមភព បានកើតក្នុងត្រកូលសក្យៈ ។ លំដាប់នោះ ខ្ញុំជាអ្នកមានរូបល្អ មានភោគៈ មានយសនិងសីល បរិបូណ៌ដោយអវយវៈទាំងពួង ជាអ្នកគោរពចំពោះប្តីក្នុងត្រកូលទាំងឡាយ ។ ឯចិត្តរបស់ខ្ញុំដែលប្រជុំចុះក្នុងលោកធម៌មានលាភៈ សេចក្តីសរសើរ និងសក្ការៈ

ជាដើម ជាចិត្តមិនដល់នូវសេចក្តីទុក្ខទេ តើខ្ញុំនឹងមានភ័យអំពីណា ។ សម ដូចព្រះមានព្រះភាគបានត្រាស់ចំពោះព្រះរាជាខាងក្នុងបុរីដូច្នេះថា បពិត្រព្រះអង្គមានព្យាយាម ព្រះអង្គសម្តែងឧបការគុណរបស់នារីនៃពួកក្សត្រក្នុងបុរីនោះ គឺនារីធ្វើសេចក្តីទំនុកបម្រុង នារីដឹងសុខនិងទុក្ខ នារីប្រាប់ប្រយោជន៍ និងនារីជាអ្នកអនុគ្រោះ ។ ( ដោយសារនារីនោះ ) តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធ ប្រាំរយ កោដិនិង ប្រាំបួនរយ កោដិ ជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហារាជ សេចក្តីកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ព្រះពុទ្ធទាំងឡាយជានាយក ជាកំពូលនៃលោក ដល់ដប់មួយរយកោដិ ។ តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ។ ព្រះពុទ្ធទាំងឡាយ ពីរពាន់កោដិផង បីពាន់កោដិផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះដែលជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហារាជ សេចក្តីកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ព្រះពុទ្ធទាំងឡាយ បួនពាន់ កោដិ ផង ប្រាំរយកោដិ ផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងឡាយនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ។ ព្រះពុទ្ធទាំងឡាយ ប្រាំមួយពាន់កោដិផង ប្រាំពីរពាន់កោដិផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាង

ទេវតា ។ បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ព្រះពុទ្ធទាំងឡាយ ប្រាំបីពាន់កោដិផង ប្រាំបួនពាន់កោដិផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ។ ព្រះពុទ្ធទាំងឡាយ ជានាយកដ៏ប្រសើរក្នុងលោក ១ សែនកោដិ តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះដែលជាទេវតាក្រៃលែងជាទេវតា ។ បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ព្រះពុទ្ធទាំងឡាយ ជានាយកនៃសត្វលោកដទៃទៀត ប្រាំបួនពាន់កោដិ ។ តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ។ ព្រះពុទ្ធជាមហេសី ៨៥ សែនកោដិផង ១ សែនកោដិផង ៨៥ កោដិផង ២៧ កោដិផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ។ ព្រះបច្ចេកពុទ្ធទាំងឡាយដែលប្រាសចាករាគៈចំនួនប្រាំបីៗកោដិ បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត ( ចំពោះព្រះបច្ចេកពុទ្ធទាំងនុ៎ះ ) សូមព្រះអង្គស្ដាប់តថាគត ។ ព្រះខីណាស្រពទាំងឡាយ ជាសាវកនៃព្រះពុទ្ធ មានប្រមាណរាប់មិនបាន មានមន្ទិលអស់ហើយ បពិត្រព្រះមហារាជ ការកសាងដ៏ធំរបស់តថាគត ( ចំពោះព្រះខីណាស្រពទាំងនុ៎ះ ) សូម

ព្រះអង្គស្តាប់តថាគត ។ កាលបុគ្គលអ្នកសន្សំក្នុងធម៌ទាំងឡាយ កាលបុគ្គលអ្នកប្រព្រឹត្តនូវព្រះសទ្ធម្មទាំងឡាយសព្វ ៗ កាល បុគ្គលអ្នកប្រព្រឹត្តធម៌យ៉ាងនេះ តែងដេកជាសុខក្នុងលោកនេះនិងលោកខាងមុខ ។ បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យជាសុចរិត មិនគប្បីប្រព្រឹត្តធម៌នោះ ឲ្យជាទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌តែងដេកជាសុខក្នុងលោកនេះនិងលោកខាងមុខ ។ ខ្ញុំនៀយណាយក្នុងសង្សារ ហើយចូលទៅកាន់ផ្នួស ដោយបរិវារ ១០០០ លុះបួសហើយមិនមានសេចក្តីក្រវល់ក្រវាយ ។ ខ្ញុំលះបង់ផ្ទះហើយ ចូលទៅកាន់ផ្នួស មិនទាន់ដល់កន្លះខែផង ក៏បានដល់សច្ច ៤ ។ ជនទាំងឡាយជាច្រើន នាំចីវរបិណ្ឌបាតនិងទីដេកទីអង្គុយចូលមក ដូចជារលកក្នុងសាគរ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។ ខ្ញុំដល់នូវសេចក្តីទុក្ខច្រើនប្រការផង នូវសម្បត្តិច្រើនប្រការផង នូវការនាស្អាតផង ហើយបាននូវសម្បទាទាំងពួង ។ បុគ្គលណា ឲ្យខ្លួនរបស់ខ្លួនដល់ព្រះពុទ្ធមហេសី ដើម្បីប្រយោជន៍ដល់បុណ្យ សហាយសម្បទា និងចំណែកនៃព្រះនិព្វាន មិនមានបច្ច័យតាក់តែង រមែងមានដល់បុគ្គលនោះ ។ កិលេសជាតិជាអតីតៈក្តី ជាបច្ចុប្បន្នក្តី ជាអនាគតក្តី អស់រលីងហើយ កម្ម

ទាំងពួងរបស់ខ្ញុំអស់ហើយ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះបាទា ។

បានឮថា ព្រះយសោធរាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

## ចប់ យសោធរាថេរិយាបទាន ។

# ទសសហស្សថេរីអបទានទី ៩

[ ២៩ ] ក្នុងកប្បទី ៤ អសង្ខេយ្យ និង ១ សែនកប្ប ព្រះជិនស្រីព្រះនាមទីបង្ករ ជាលោកនាយកទ្រង់កើតឡើង ។ ព្រះពុទ្ធព្រះនាមទីបង្ករ ជាមហាវីរបុរស ទ្រង់ព្យាករនូវសុមេធតាបសផង នាងសុមិត្តាផង ដែលរួមសុខទុក្ខជាមួយគ្នា ។ ព្រះមហាមុនី ព្រះអង្គឃើញមនុស្សលោក ព្រមទាំងទេវលោក ទាំងទ្រង់ស្ដេចទៅកាន់មនុស្សលោក ព្រមទាំងទេវលោក ហើយចូលមកកាន់ទីប្រជុំនៃយើងខ្ញុំដែលកំពុងសសើរជនទាំងនោះ ។ ប្ដីទាំងអស់របស់យើងខ្ញុំមានក្នុងទីសមាគមជាអនាគត ប្រពន្ធទាំងអស់របស់ព្រះអង្គ ជាទីពេញព្រះទ័យនៃព្រះអង្គ ជាអ្នកពោលពាក្យជាទីស្រឡាញ់ ។ ទាន សីល ភាវនាទាំងអស់ យើងខ្ញុំបានអប់រំដោយល្អហើយ បពិត្រព្រះមហាមុនី វត្ថុទាំងអស់នេះ ខ្ញុំបានលះបង់ចោលអស់កាលជាយូរអង្វែងហើយ ។ វត្ថុណាមួយ គឺគ្រឿងក្រអូប កម្រងផ្កា គ្រឿងលាប និងប្រទីបជាវិការៈកែវដែលយើងខ្ញុំបានតម្កល់ទុកហើយ បពិត្រព្រះមហាមុនី វត្ថុទាំងអស់ ( នោះ ) យើងខ្ញុំបានលះបង់ចោលហើយ ។ ន័យមួយទៀត អំពើដទៃនិងគ្រឿងបរិភោគជារបស់មនុស្សដែលយើងបានធ្វើហើយ បពិត្រព្រះមហាមុនី របស់ទាំងអស់នុ៎ះ យើងខ្ញុំបានលះបង់ចោលអស់កាលយូរអង្វែងហើយ ។ បុណ្យមានប្រមាណច្រើនដែលយើងបានធ្វើហើយ បានសោយនូវភាពជាឥស្សរៈ ត្រាច់រង្គាត់ក្នុងភពតូចភពធំ អស់សង្សារវដ្ដ មានជាតិច្រើន ។ លុះដល់មកក្នុងបច្ឆិមភព យើងខ្ញុំបានកើតក្នុងត្រកូលផ្សេងៗគ្នា ក្នុងលំនៅនៃព្រះសក្យបុត្ត ជាស្រីមានពណ៌សម្បុរជាទីប្រាថ្នា បីដូចជាស្រីទេពអប្សរ ។ បានដល់នូវយសដែលជនទាំងពួងធ្វើ

សក្ការបូជាហើយ ដោយលាភដ៏ប្រសើរ បាននូវបាយនិងទឹក ដែលពួកជនរាប់អានសព្វ ៗ កាល ។ យើងខ្ញុំលះបង់នូវផ្ទះ ហើយចូលទៅកាន់ផ្នួស មិនទាន់បានដល់កន្លះខែ ក៏បានដល់សេចក្តីរលត់ទុក្ខទាំងអស់គ្នា ។ យើងខ្ញុំជាអ្នកបាននូវបាយនិងទឹកផង នូវសំពត់និងសេនាសនៈផង បច្ច័យទាំងពួង រមែងមានគ្រប់គ្រាន់ យើងខ្ញុំត្រូវគេធ្វើសក្ការបូជាសព្វកាល ។ កិលេសទាំងឡាយយើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់យើងខ្ញុំគាស់រំលើងហើយ យើងខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! យើងខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធយើងខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិក្ខុនី ១ ម៉ឺនរូប មានព្រះនាងយសោធរាភិក្ខុនីជាប្រធាន មានអាយុបានសម្តែងនូវគាថាទាំងនេះចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

**ចប់ ទសសហស្សថេរីនមបទាន ។**

# អដ្ឋារសបេរីសហស្សាធមបទានទី ១០

[ ៣០ ] ភិក្ខុនី ១៨ ពាន់ មាននាងយសោធរាជាប្រធាន ដែលកើតក្នុងត្រកូលសក្យៈ បាននាំគ្នាចូលទៅគាល់ព្រះសម្ពុទ្ធ ។ ភិក្ខុនីទាំង ១៨ ពាន់នោះ សុទ្ធតែមានឫទ្ធិច្រើន នាំគ្នាចូលទៅថ្វាយបង្គំព្រះបាទាព្រះមុនី ក្រាបទូលតាមសមគួរដល់កម្លាំងថា បពិតព្រះមហាមុនី ជាតិ ជរា ព្យាធិ និងមរណៈ ( នៃយើងខ្ញុំ ) អស់ហើយ បពិត្រព្រះអង្គជានាយក យើងខ្ញុំទាំងឡាយនឹងទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ដែលមិនមានអាសវៈ ជាផ្លូវដ៏ស្ងប់រម្ងាប់ ។ បពិត្រព្រះមហាមុនី កាលពីដើម ពួកភិក្ខុនីទាំងអស់ មានសេចក្តីភ្លាំងភ្លាត់ ពួកភិក្ខុនីដឹងច្បាស់នូវកំហុស បពិត្រព្រះអង្គជានាយក សូមព្រះអង្គអត់ទោសដល់យើងខ្ញុំ ។

នាងទាំងឡាយ ជាអ្នកធ្វើតាមសាសនារបស់តថាគត ចូរសម្តែងនូវឫទ្ធិឲ្យទាល់តែកាត់សេចក្តីសង្ស័យរបស់ពួកបរិស័ទទាំងអស់ ។

បពិត្រព្រះមហាវីរៈ ខ្ញុំម្ចាស់យសោធរា ជាទីពេញព្រះហឫទ័យ ជាទីស្រឡាញ់ គួររមិលមើល បពិត្រព្រះមហាវីរៈ ស្ត្រីទាំងពួងជាព្រះជាយាក្នុងដំណាក់របស់ព្រះអង្គ ។ បពិត្រព្រះអង្គមានព្យាយាម បណ្តាពួកស្រី ១ សែន ៩៦ រូប ខ្ញុំម្ចាស់ជាប្រធាន ជាឥស្សរៈលើស្រីទាំងពួងក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ។ ពួកស្រីទាំងអស់ ជាអ្នកបរិបូណ៌ដោយគុណ គឺរូបនិងអាចារៈឋិតនៅក្នុងបឋមវ័យ ពោលពាក្យជាទីស្រឡាញ់ តែងគោរពកោតក្រែងខ្ញុំម្ចាស់ដូចពួកមនុស្សគោរពកោតក្រែងពួកទេវតា ។ ពួកស្រីទាំង ១៨ ពាន់ កើតក្នុងត្រកូលសក្យៈ ក្នុងកាលនោះ ស្រី ១ ពាន់ទ្រទ្រង់យស ជាប្រធាន ជាធំ ។

បពិត្រព្រះមហាមុនី ស្រីទាំងឡាយ កន្លងនូវកាមធាតុ ឋិតនៅក្នុងរូបធាតុ ប្រាកដស្មើដោយរូបនៃស្រីទាំង ១ ពាន់គ្មានទេ ។ ថេរីទាំងឡាយ មានឫទ្ធិច្រើន លុះថ្វាយបង្គំព្រះសម្ពុទ្ធហើយ សម្តែងឫទ្ធិថ្វាយព្រះសាស្តា សម្តែងនូវមហិទ្ធិឫទ្ធិមានអាការផ្សេងៗដ៏ច្រើន ។ គឺសម្តែងកាយស្មើនឹងចក្កវាឡ ឧត្តរកុរុទ្វីបជាក្បាល ទ្វីបទាំងពីរជាស្លាបទាំងពីរខាង ជម្ពូទ្វីបជាសរីរៈ ។ ស្រះខាងត្បូងជាសំណុំកន្ទុយ ស្លឹកផ្សេងៗជាបំពង់ស្លាប ព្រះចន្ទនិងព្រះអាទិត្យជាភ្នែក ភ្នំមេរុជាសិរ ។ ភ្នំចក្កវាឡនិងដើមព្រឹងព្រមទាំងឫស ជាចំពុះ កាលបក់ហើយចូលមកថ្វាយបង្គំព្រះលោកនាយក ។ កាលនោះ បានសម្តែងភេទនៃដំរី សេះ ភ្នំ ជលជាត ព្រះចន្ទ ព្រះអាទិត្យ ភ្នំមេរុ និងភេទព្រះឥន្ទ ។ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ យើងខ្ញុំនិងនាងយសោធរា សូមថ្វាយបង្គំព្រះបាទា បពិត្រព្រះអង្គជានាយកនៃជន យើងខ្ញុំសម្រេចហើយ ដោយអានុភាពរបស់ព្រះអង្គ អស់កាលដ៏យូរ ។ បពិត្រព្រះមហាមុនី យើងខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ យើងខ្ញុំដឹងបុព្វេនិវាសៈ ទិព្វចក្ខុយើងខ្ញុំជម្រះស្អាតហើយ យើងខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃយើងខ្ញុំ កើតឡើងហើយក្នុងសម្នាក់ របស់ព្រះអង្គ ។ ការគប់រកនូវព្រះពុទ្ធទាំងឡាយដែលជាទីពឹងរបស់សត្វលោក យើងខ្ញុំបានសម្តែងហើយ បពិត្រព្រះ

មហាមុនី ការកសាងជាច្រើន យើងខ្ញុំបានធ្វើហើយដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមុនី កុសលកម្មណាដែលជាកម្មចាស់របស់ខ្ញុំ សូមព្រះអង្គនឹកនូវកុសលកម្មនោះ បពិត្រព្រះអង្គមានព្យាយាមធំ បុណ្យទាំងឡាយ យើងខ្ញុំសន្សំហើយ ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំបានវៀរក្នុងទីមិនគួរ ហើយហាមឃាត់នូវអនាចារៈ សូម្បីជីវិត យើងខ្ញុំក៏បានលះបង់ដើម្បីប្រយោជន៍ព្រះអង្គ ។ ព្រះអង្គទ្រង់ប្រទានយើងខ្ញុំ ដើម្បីប្រយោជន៍ជាកិរិយានៃបុគ្គលដទៃវិញ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំឥតមានតូចចិត្តក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ ។ ព្រះអង្គបានប្រទាននូវយើងខ្ញុំ ដើម្បីទំនុកបម្រុង ( ជនដទៃ ) អស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំឥតមានតូចចិត្តក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ ។ ព្រះអង្គទ្រង់ព្រះរាជទាននូវយើងខ្ញុំ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់នៃជនដទៃ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំទាំងឡាយ ឥតមានតូចចិត្តក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ ។ យើងខ្ញុំបានលះបង់ជីវិតទាំងឡាយ មានពាន់នៃកោដិដ៏ច្រើន គឺធ្វើឲ្យគេរួចចាកទុក្ខភ័យ ស៊ូលះបង់ជីវិតនៃខ្លួន ។ បពិត្រព្រះមហាមុនី យើងខ្ញុំមិនដែលលាក់ទុកនូវគ្រឿងប្រដាប់ដែលជាប់នឹងអង្គ ដូចយ៉ាងសំពត់ផ្សេងៗជាច្រើន កណ្ឌរបស់ស្រី ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមហាមុនី យើងខ្ញុំបានបរិច្ចាគទ្រព្យនិងស្រូវ បានបរិច្ចាគស្រុក និគម ស្រែ កូនប្រុស កូនស្រី ។ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំបានបរិច្ចាគដំរី

សេះ គោ ខ្ញុំស្រី អ្នកបម្រើរាប់មិនអស់ ដើម្បីប្រយោជន៍ព្រះអង្គ ។ ព្រះអង្គ បានប្រឹក្សានឹងយើងខ្ញុំដោយទានណា យើងខ្ញុំក៏បានឲ្យទាននោះដល់ស្វាមីទាំងឡាយ យើងខ្ញុំមិនបានឃើញនូវសេចក្តីតូចចិត្តចំពោះព្រះអង្គ កាលដែលឲ្យទានដ៏ឧត្តមនោះសោះឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំទាំងឡាយ បានទទួលនូវសេចក្តីទុក្ខ មានចំណែកច្រើនចំពូកណាស់ រាប់មិនអស់ក្នុងសង្សារមានចំណែកច្រើន ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមហាមុនី យើងខ្ញុំបានរីករាយ តាមចំណែកបុណ្យដែលនាំមកនូវសេចក្តីសុខ ទាំងមិនតូចចិត្តចំពោះទុក្ខទាំងឡាយ ជាអ្នកត្រេកអរក្នុងទីទាំងពួង ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះសម្ពុទ្ធទ្រង់សោយនូវសុខទុក្ខ ហើយដល់នូវការត្រាស់ដឹង នាំមកនូវធម៌ដោយលំដាប់មគ្គ ។ ការគប់រកព្រះសម្ពុទ្ធព្រះនាមគោតមជាលោកនាយកដែលជាទេវតាប្រសើរផង ព្រះលោកនាថទាំងឡាយដទៃផង យើងខ្ញុំ ( បានជួបហើយ ) ជាច្រើនដង ។ សេចក្តីកសាងដ៏ច្រើននៃយើងខ្ញុំ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ព្រះអង្គ បពិត្រព្រះមហាមុនី យើងខ្ញុំជាស្រីបម្រើរបស់ព្រះអង្គ កាលដែលទ្រង់ស្វែងរកនូវពុទ្ធធម៌ ។ ក្នុងកប្បទី ៤ អសង្ខេយ្យ និង ១ សែន ព្រះសម្ពុទ្ធព្រះនាមទីបង្ករ ជាមហាវីរបុរស ជាលោកនាយកទ្រង់កើតឡើង ។ ជនទាំងឡាយនៅបច្ចន្តប្រទេស និមន្តព្រះតថាគត មានចិត្តត្រេកអរ នាំគ្នាជម្រះផ្លូវសម្រាប់យាងមកនៃព្រះតថាគតនោះ ។ ក្នុងកាលនោះ ព្រះអង្គជាព្រាហ្មណ៍ ឈ្មោះសុមេធ: បានចាត់ចែងរៀបចំផ្លូវ ដើម្បីព្រះសម្ពុទ្ធទីបង្ករ ទ្រង់ឃើញហេតុទាំង

ពួន ទ្រង់យាងមក ។ ក្នុងកាលនោះ យើងខ្ញុំទាំងអស់គ្នា កើតក្នុងត្រកូលព្រាហ្មណ៍ បានទៅនាំយកផ្កាផលុកជាតិមកកាន់ទីប្រជុំ ។ ក្នុងសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករមានយសធំ មានព្យាយាមធំនោះ ទ្រង់បានព្យាករនូវសុមេធតាបសជាឥសី មានចិត្តរីករាយ ។ កាលព្រះពុទ្ធទីបង្ករទ្រង់ប្រកាសកម្មរបស់សុមេធតាបសនោះថា ជាឥសីមានចិត្តរីករាយផែនដីក៏កក្រើក រំភើបញាប់ញ័រ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ ពួកទេវកញ្ញា ពួកមនុស្ស ទាំងយើងខ្ញុំ ព្រមទាំងទេវតា សឹងនាំគ្នាបូជាគ្រឿងប្រដាប់ ដែលគួរបូជាផ្សេងៗ ហើយតាំងប្រាថ្នា ។ ព្រះពុទ្ធជាម្ចាស់ មានព្រះនាមទីបង្ករ ទ្រង់បានព្យាករដល់ពួកជនទាំងនោះថា ជនទាំងឡាយណា មានសេចក្តីប្រាថ្នាក្នុងថ្ងៃនេះ ជនទាំងនោះ ឈ្មោះថា មានក្នុងទីចំពោះមុខ ( នៃព្រះពុទ្ធ ) ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះពុទ្ធព្យាករនូវយើងខ្ញុំ ដោយព្រះពុទ្ធដីកាណា យើងខ្ញុំរមែងរីករាយ តាមព្រះពុទ្ធដីកានោះ ជាអ្នកធ្វើតាមយ៉ាងនោះ ។ ជនទាំងឡាយ បានចាប់កំណើត ជារបស់ទេវតានិងមនុស្សរាប់មិនអស់ ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធនោះ ដោយអំណាចនៃកម្មនោះដែលខ្ញុំធ្វើល្អហើយ ។ យើងខ្ញុំបានសោយសុខទុក្ខក្នុងទេវតាផង មនុស្សផង ដល់មកក្នុងបច្ឆិមភពនេះ បានមកកើតក្នុងត្រកូលសក្យៈ ។ យើងខ្ញុំជាអ្នកមានរូបល្អ មានភោគសម្បត្តិច្រើន មានយស និងសីលដ៏ល្អ បរិបូណ៌ដោយអវយវៈសព្វគ្រប់ ជាអ្នកអង់អាចលើសក្នុងត្រកូលទាំងឡាយ ។ ចិត្តនៃយើងខ្ញុំដែលប្រជុំចុះក្នុងលោកធម៌ មានលាភៈ សេចក្តីសរសើរនិងគ្រឿង

សក្ការៈ ជាចិត្តមិនដល់នូវសេចក្តីទុក្ខទេ តើយើងខ្ញុំនឹងមានភ័យអំពីណា ។ សមដូចព្រះមានព្រះភាគទ្រង់ត្រាស់នូវព្រះតម្រាស់នេះ ចំពោះស្តេចខាងក្នុងបុរី ក្នុងកាលនោះ ដូច្នេះថា មហារាជបានសម្តែងនូវឧបការគុណរបស់នារីនៃពួកក្សត្រក្នុងបុរីនោះ គឺនារីអ្នកមានឧបការៈ នារីរួមសុខទុក្ខ នារីដែលប្រាប់នូវប្រយោជន៍ និងនារីជាអ្នកមានសេចក្តីអនុគ្រោះ ។ បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យជាសុចរិត កុំគប្បីប្រព្រឹត្តធម៌នោះឲ្យជាទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។ យើងខ្ញុំបានលះបង់ផ្ទះហើយ ហើយចូលទៅកាន់ផ្នួស មិនទាន់បានដល់កន្លះខែ ស្រាប់តែយើងខ្ញុំបាននូវសច្ច ៤ ។ ពួកជនដ៏ច្រើនតែងបង្អោនមកនូវចីវរប្បច្ច័យ បិណ្ឌ-បាតប្បច្ច័យ និងសេនាសនប្បច្ច័យ ចំពោះយើងខ្ញុំ បីដូចរលកនៃសាគរ ។ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ យើងខ្ញុំដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! យើងខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ យើងខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។ យើងខ្ញុំដល់នូវភាពបរិសុទ្ធ បរិបូណ៌ដោយគុណទាំងពួង តែងបាននូវទុក្ខមានប្រការច្រើន និងសម្បត្តិមានប្រការច្រើនយ៉ាងនេះឯង ។ ស្រីទាំងឡាយណាឲ្យនូវខ្លួនជារបស់ខ្លួន ដល់បុគ្គលស្វែងរកនូវគុណដ៏ធំ ដើម្បីប្រយោជន៍ដល់

បុណ្យ ស្រីទាំងឡាយនោះ ឈ្មោះថាអ្នកបរិបូណ៌ដោយសម្ភាញ់ តែងបាននូវព្រះនិព្វាន មានចំណែកមិនមានបច្ច័យប្រជុំតាក់តែង ។ កម្មជាអតីត ជាបច្ចុប្បន្ន ជាអនាគតនៃយើងខ្ញុំអស់ហើយ កម្មទាំងពួងរបស់យើងខ្ញុំ អស់រលីងហើយ បពិត្រព្រះអង្គមានចក្ខុ យើងខ្ញុំសូមថ្វាយបង្គំនូវព្រះបាទា ។ បុគ្គលណា មានទោសគឺបច្ច័យប្រជុំតាក់តែងស្ងប់រម្ងាប់ហើយ ដល់នូវចំណែកព្រះនិព្វានឈ្មោះអមត យើងខ្ញុំនឹងក្រាបទូលដល់ព្រះអង្គនូវបុគ្គលនោះ ឱ្យក្រៃលែងជាងពួកស្រីដែលពោលពីព្រះនិព្វានដូចម្តេចកើត ។

បានឮថា ព្រះភិក្ខុនី ១៨.០០០ រូប មានព្រះនាងយសោធរាភិក្ខុនីជាប្រមុខ បានសម្តែងនូវគាថាទាំងនេះចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

## ចប់ អដ្ឋារសថេរីសហស្សាបទាន ។

## ឧទ្ទាន

កុណ្ឌលកេសីថេរិយាបទាន ១ កិសាគោតមីថេរិយាបទាន ១ ធម្មទិន្នាថេរិយាបទាន ១ សកុលាថេរិយាបទាន ១ នន្ទាថេរិយាបទាន ១ សោណាថេរិយាបទាន ១ ភទ្ទកាបិលានីថេរិយាបទាន ១ យសោធរាថេរិយាបទាន ១ ទសសហស្សថេរីនមបទាន ១ អដ្ឋារសថេរីសហស្សានមបទាន ១ មានគាថាចំនួន ៤៧៨ ។

## ចប់ កុណ្ឌលកេសវគ្គ ទី ៣ ។

# ខត្តិយកញ្ញាវគ្គ ទី ៤

## អដ្ឋារសសហស្សខត្តិយកញ្ញាថេរីឆមបទានទី ១

[ ៣១ ] បពិត្រព្រះមហាមុនី យើងខ្ញុំសូមក្រាបទូលថា ភពទាំងពួងនៃយើងខ្ញុំអស់ហើយ តំណនៃភពយើងខ្ញុំបានដោះចេញហើយ អាសវៈទាំងពួងរបស់យើងខ្ញុំមិនមានឡើយ ។ បពិត្រព្រះមហាមុនី កុសលណាមួយដែលយើងខ្ញុំបរិកម្មហើយ ទាំងប្រាថ្នាដោយប្រពៃហើយ គ្រឿងប្រើប្រាស់ យើងខ្ញុំបានឲ្យហើយ ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមហាមុនី គ្រឿងប្រើប្រាស់យើងខ្ញុំបានឲ្យហើយដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកទាំងឡាយបានប្រាថ្នាហើយដើម្បីប្រយោជន៍នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី កម្មខ្ពស់និងទាប យើងខ្ញុំបានតម្កល់ទុកដើម្បីពួកភិក្ខុដោយប្រពៃ ការបរិកម្មក្នុងត្រកូលដ៏ខ្ពស់យើងខ្ញុំបានធ្វើរួចហើយ ។ នាងខត្តិយកញ្ញាទាំងឡាយ ជាអ្នកបរិបូណ៌ដោយកម្ម ត្រូវកុសលមូលនោះឯងមកជាស់តឿនហើយ កន្លងនូវធម៌របស់មនុស្ស បានមកកើតក្នុងខត្តិយត្រកូល ។ កម្មដែលយើងខ្ញុំបានសន្សំ បានធ្វើហើយក្នុងជាតិជាមួយគ្នា ក្នុងបច្ឆិមជាតិ យើងខ្ញុំក៏កើតក្នុងខត្តិយត្រកូលជាមួយគ្នា ។ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំមានរូបល្អ ទាំងមានភោគសម្បត្តិច្រើន ទាំងមានលាភៈនិងគ្រឿងសក្ការៈ ត្រូវពួកជនបូជាហើយ នៅក្នុងព្រះរាជវាំង បីដូចជានៅក្នុងនន្ទនឧទ្យាននៃពួកទេវតា ។ យើងខ្ញុំទាំងអស់គ្នានឿយណាយហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស នៅអាស្រ័យត្រឹមតែ ២-៣ ថ្ងៃ ក៏បានដល់ព្រះនិព្វាន ។ ជនទាំងឡាយដ៏ច្រើន តែងបង្អោននូវ

ចីវរប្បច្ច័យផង បិណ្ឌបាតប្បច្ច័យផង សេនាសនប្បច្ច័យផង ដើម្បីយើងខ្ញុំ បូជានូវគ្រឿងសក្ការៈ ដល់យើងខ្ញុំសព្វៗកាល ។ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់យើងខ្ញុំដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! យើងខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខត្តិយកញ្ញាភិក្ខុនីចំនួន ១៨ ពាន់រូប មានព្រះនាងយសោធរាភិក្ខុនីជាប្រធាន បានសម្តែងនូវគាថាទាំងនេះចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

## ចប់ អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន ។

# ចតុរាសីតិសហស្សព្រាហ្មណកញ្ញាបេរីរឆមបទានទី ២

[ ៣២ ] បពិត្រព្រះមហាមុនី ភិក្ខុនី ៨៤ ពាន់ កើតក្នុងត្រកូលព្រាហ្មណ៍ មានជើងដៃទន់ល្វន់ ក្នុងបុរីនៃព្រះអង្គ បពិត្រព្រះមហាមុនី ពួកស្ត្រីកើតក្នុងវេស្សត្រកូល និងសុទ្រត្រកូល ពួកទេវតា ពួកនាគ ពួកកិន្នរ ពួកនាងកញ្ញាដ៏ច្រើន ទាំង ៤ ទិស ក្នុងបុរីរបស់ព្រះអង្គ ។ ពួកស្រីខ្លះ ក៏បានបួស ពួកទេវតាច្រើន ពួកកិន្នរ និងពួកនាគដែលជាអ្នកឃើញធម៌ទាំងពួងហើយ គង់នឹងបានត្រាស់ដឹងក្នុងអនាគតកាល ។ ជនទាំងឡាយនោះបានទទួលនូវយសទាំងពួង សម្រេចសម្បត្តិទាំងពួង ហើយបាននូវសេចក្តីជ្រះថ្លាក្នុងព្រះអង្គ មុខជានឹងបានត្រាស់ដឹងក្នុងអនាគតកាល ។ បពិត្រព្រះអង្គមានព្យាយាមធំ មានចក្ខុ យើងខ្ញុំជាធីតានៃព្រាហ្មណ៍ កើតក្នុងត្រកូលព្រាហ្មណ៍ ប្រកបដោយលក្ខណៈ សូមក្រាបថ្វាយបង្គំព្រះបាទា ( របស់ព្រះអង្គ ) ។ ភពទាំងឡាយយើងខ្ញុំលះបង់ចោលហើយ ឫសគល់នៃតណ្ហា យើងខ្ញុំបានដកចេញហើយ អនុស័យយើងខ្ញុំបានផ្តាច់ផ្តិលហើយ បុញ្ញាភិសង្ខារ យើងខ្ញុំបានទម្លាយចេញហើយ ។ យើងខ្ញុំទាំងអស់មានសមាធិជាអារម្មណ៍ ជាអ្នកស្ទាត់ជំនាញក្នុងសមាបត្តិ នឹងប្រព្រឹត្តនៅដោយការត្រេកអរក្នុងធម៌ ដោយឈានសព្វៗកាល ។ បពិត្រព្រះអង្គជានាយក តណ្ហាដែលនាំសត្វទៅកាន់ភព អវិជ្ជានិងសង្ខារទាំងឡាយ យើងខ្ញុំបានធ្វើឲ្យអស់ហើយ យើងខ្ញុំយល់ច្បាស់នូវធម៌ ព្រោះដល់នូវបទគឺព្រះនិព្វាន ដែលបុគ្គលឃើញបានដោយកម្រ ។

នាងទាំងឡាយ មានឧបការៈដល់តថាគត នាងទៅកាន់ផ្លូវឆ្ងាយអស់កាលមានរាត្រីវែង នាងទាំងអស់គ្នា ចូរកាត់នូវសេចក្តីសង្ស័យនៃបរិស័ទទាំង ៤ ហើយទៅកាន់ព្រះនិព្វានចុះ ។

ពួកភិក្ខុនីខ្លះ ថ្វាយបង្គំព្រះបាទានៃព្រះមុនីរួចហើយ ក៏ធ្វើនូវការប្លែងឫទ្ធិ សំដែងនូវពន្លឺ ហើយសំដែងនូវងងឹតដទៃទៀត ពួកភិក្ខុនីខ្លះសំដែងព្រះចន្ទ និងព្រះអាទិត្យ ខ្លះសំដែងសាគរប្រកបដោយត្រី ខ្លះសំដែងភ្នំសិនេរុ និងភ្នំបរិកណ្ឌ ខ្លះសំដែងដើមបារិច្ឆត្តកព្រឹក្ស ។ ខ្លះសំដែងភពតាវត្តិង្ស ខ្លះសំដែងភពឈ្មោះយាមៈដោយឫទ្ធិ ខ្លះនិម្មិតជាទេវតាមានឥស្សរៈធំនៅក្នុងជាន់តុសិត និងវសវត្តី ។ ពួកខ្លះនិម្មិតជាព្រហ្ម សំដែងទីចង្រ្កមមានតម្លៃច្រើន ខ្លះនិម្មិតភេទជាព្រហ្ម សំដែងនូវធម៌ដ៏សូន្យ ។ លុះពួកស្រីទាំងអស់បាន ប្លែងឫទ្ធិប្លែកៗ ហើយសំដែងឫទ្ធិ សំដែងកម្លាំងថ្វាយព្រះសាស្តា រួចហើយថ្វាយបង្គំព្រះបាទាព្រះសាស្តាទូលថា បពិត្រព្រះមហាមុនី យើងខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ យើងខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុយើងខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួងរបស់យើងខ្ញុំអស់ហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះគ្មានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទាផង ក្នុងធម្មប្បដិសម្ភិទាផង ក្នុងនិរុត្តិប្បដិសម្ភិទាផង ក្នុងបដិភាណប្បដិសម្ភិទាផង របស់យើងខ្ញុំកើតឡើងហើយក្នុងសម្នាក់ព្រះអង្គ។ បពិត្រព្រះមហាមុនី ការគប់រកព្រះពុទ្ធទាំងឡាយ ដែលជាទីពឹងនៃសត្វលោក យើង

ខ្ញុំបានចួបហើយ យើងខ្ញុំបានកសាងបុណ្យដ៏ច្រើន ដើម្បីប្រយោជន៍នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី កម្មណាដែលយើងខ្ញុំបានធ្វើហើយក្នុងកាលមុន សូមព្រះអង្គវព្រកនូវកម្មជាកុសលនោះចុះ បពិត្រព្រះមហាវីរៈ បុណ្យទាំងឡាយយើងខ្ញុំបានសាងសន្សំហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ ។ ក្នុងកប្បទី ១ សែនអំពីកប្បនេះ មានព្រះមហាមុនី ១ ព្រះអង្គ ព្រះនាមបទុមុត្តរៈ ឯបុរីឈ្មោះហង្សវតី ជាលំនៅនៃត្រកូលព្រះសម្ពុទ្ធ ។ ស្ទឹងគង្គាតែងហូរទៅក្នុងបុរីឈ្មោះហង្សវតីតាមទ្វារសព្វៗកាល ពួកភិក្ខុទាំងនោះ ត្រូវទឹកស្ទឹងបៀតបៀន ក៏ទៅមកមិនបាន ។ ភិក្ខុទាំងឡាយនោះ ទៅមិនបានអស់ ២ ថ្ងៃ អស់ ៣ ថ្ងៃ អស់ ៧ ថ្ងៃ អស់ ១ ខែ ដរាបទាល់តែពេញ ៤ ខែ ។ គ្រានោះ មានបុរសជាខ្ញុំមសាររបស់សត្វ ឈ្មោះជដ្ឋៈ ជាអ្នកនៅក្នុងដែន បានឃើញពួកភិក្ខុនៅត្រើយខាងអាយ ក៏ឲ្យគេសាងស្ពានត្រង់ស្ទឹងគង្គា ។ គ្រានោះ បុរសនោះបានសាងស្ពាននាស្ទឹងគង្គា ដោយតម្លៃ ១ សែនកហាបនៈផង បានសាងវិហារក្នុងត្រើយខាងនាយ និងត្រើយខាងអាយ ដើម្បីភិក្ខុសង្ឃផង ។ ពួកស្រី ពួកបុរស ពួកត្រកូលខ្ពស់និងទាប ជនទាំងនោះ បានធ្វើស្ពានផង វិហារផង មានភាគស្មើគ្នា ដើម្បីភិក្ខុសង្ឃនោះ ។ ពួកយើងខ្ញុំផង ពួកមនុស្សដទៃផង ក្នុងនគរ ក្នុងជនបទ មានចិត្តជ្រះថ្លា ជាអ្នកទទួលមត៌ក ក្នុងធម៌នៃព្រះសម្ពុទ្ធនោះ ។ ពួកស្រី ពួកប្រុស ពួកកុមារ ពួកកុមារិកាជាច្រើន ជនទាំងនោះ បាននាំគ្នាពោយកាយដីខ្សាច់ដល់ស្ពានផង ដល់វិហារផង ។ ជនទាំងនោះ នាំគ្នាដាំដើមចេក តម្កល់ក្អមពេញដោយទឹក លើកទង់ ប្រោស

សម្អាតផ្លូវថ្នល់ បូជាធូប គ្រឿងលម្អិត កម្រងផ្កា ជាគ្រឿងសក្ការៈ ថ្វាយព្រះសាស្តា ។ លុះជនទាំងនោះ បានធ្វើស្ពានទិនវិហាររួចហើយ និមន្តព្រះសាស្តាជានាយក ថ្វាយមហាទាន ហើយប្រាថ្នានូវសម្ពោធិញ្ញាណ ។

ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ជាមហាវីរៈ ជាទីគោរព របស់សព្វសត្វទាំងឡាយ ទ្រង់បានធ្វើអនុមោទនា ហើយព្យាករថា ក្នុងកប្បទី ១ សែនកន្លងទៅ មានកទ្ទកប្បកើតឡើង បុរសនោះ បាននូវសេចក្តីសុខក្នុងភពតូចភពធំ ហើយនឹងដល់ពោធិញ្ញាណ ។ ពួកនរៈ នារីណាមួយ ដែលបានធ្វើនូវហត្ថកម្ម លុះដល់កាលជាអនាគត ជនទាំងអស់នោះ នឹងមានក្នុងទីចំពោះព្រះភក្ត្រ ( នៃព្រះពុទ្ធនោះ ) ។

ពួកស្រីជាអ្នកបម្រើទាំងអស់នោះ របស់ព្រះអង្គ កើតហើយក្នុងភពនៃទេវតា ព្រោះផលនៃកុសលកម្មនោះផង ព្រោះការតម្កល់ទុកនូវចេតនានោះផង ។ ជនទាំងនោះ សោយទិព្វសុខរាប់មិនអស់ផង សោយសុខរបស់មនុស្សរាប់មិនអស់ផង ត្រាច់រង្គាត់ក្នុងភពតូចភពធំអស់កាលជាយូរអង្វែង ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ កម្មសម្បត្តិ យើងខ្ញុំធ្វើល្អហើយ ក្នុងពួកមនុស្សជាអ្នកល្អិតល្អ ទាំងក្នុងទេវបុរីដ៏ប្រសើរ ។ យើងខ្ញុំតែងបាននូវរូបល្អ នូវភោគសម្បត្តិនិងយស នូវសេចក្តីសរសើរសេចក្តីសុខ និងសេចក្តីស្រឡាញ់ ឯកម្មសម្បត្តិទាំងអស់ យើងខ្ញុំធ្វើល្អហើយ ដល់មកក្នុងបច្ឆិមភព យើងខ្ញុំបានមកកើតក្នុងត្រកូលព្រាហ្មណ៍ មានដៃជើងទន់ល្វន់ ក្នុងព្រះរាជនិវេសន៍នៃសក្យបុត្ត ។ បពិត្រព្រះមហាមុនី យើងខ្ញុំមិនដែលឃើញផែនដីដែលពួក

ជនមិនបានប្រដាប់រៀបចំសព្វកាលផង មិនដែលឃើញដំណើរទៅកាន់ទីមានកក់ផង ។ កាលយើងខ្ញុំនៅគ្រប់គ្រងផ្ទះ ពួកជនតែងនាំគ្រឿងសក្ការៈ ប្រកបដោយកាលទាំងពួង អស់កាលគ្រប់កាល ដោយផលនៃបុញ្ញកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានលះបង់ផ្ទះ ហើយចូលទៅកាន់ផ្នួស បានធ្វើផ្លូវគឺសង្សារវដ្តឥឡូវនេះ កពថ្មីទៀតមិនមានឡើយ ។ ជនទាំងឡាយ តែងនាំនូវចីវរប្បច្ច័យផង បិណ្ឌបាតប្បច្ច័យផង សេនាសនប្បច្ច័យផង ឲ្យដល់យើងខ្ញុំចំនួន ១ ពាន់កហាបណៈអំពីទីនោះៗ សព្វៗកាល ។ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ កពទាំងអស់យើងខ្ញុំដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! យើងខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធយើងខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះព្រាហ្មណកញ្ញាភិក្ខុនី ៨៤.០០០ រូប បានសម្តែងនូវ គាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

**ចប់ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន ។**

# ឧប្បលទាយិកាថេរិយាបទានទី ៣

[ ៣៣ ] ក្នុងនគរអរុណវតី មានក្សត្រមួយព្រះអង្គ ព្រះនាមអរុណៈ ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ ខ្ញុំបានញុំាងជនពួកខ្លះឲ្យបម្រើ ។ ក្នុងកាលនោះ ខ្ញុំអង្គុយក្នុងទីស្ងាត់ហើយ ត្រិះរិះយ៉ាងនេះថា បើអាត្មាអញមិនបានធ្វើកុសលដែលគប្បីកាន់យកទៅបានទេ អាត្មាអញនឹងទៅកាន់នរក មានសេចក្តីក្តៅក្រហាយធំ ខ្លោចផ្សា មានសភាពឃោរឃៅ អាក្រក់ក្រៃលែងដោយពិត សេចក្តីសង្ស័យរបស់អាត្មាអញក្នុងរឿងនេះគ្មានទេ ។ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តឲ្យរីករាយ ចូលទៅគាល់ព្រះរាជា ហើយក្រាប បង្គំទូលនូវពាក្យនេះថា បពិត្រព្រះសម្មតិទេព យើងខ្ញុំជាស្រី យើងខ្ញុំមិនមែនជាប្រុស បពិត្រព្រះមហាក្សត្រ សូមព្រះអង្គព្រះរាជទានសមណៈ ១ រូប ដល់ខ្ញុំម្ចាស់ ៗ នឹងញុំាងសមណៈនោះឲ្យឆាន់ ។ គ្រានោះឯង ព្រះរាជាបាន ទ្រង់ប្រទានសមណៈ មានឥន្ទ្រិយអប់រំហើយដល់ខ្ញុំ ទាំងខ្ញុំបានកាន់យកបាត្ររបស់សមណៈនោះ ហើយញុំាងបាត្រឲ្យពេញដោយបាយដ៏ឧត្តម ។ លុះដាក់បាយដ៏ឧត្តមព្រមទាំងគ្រឿងអប់និងគ្រឿងលាបហើយ ក៏មានចិត្តត្រេកអរ បានយកសំពត់ផ្ទាំងធំគ្របបាត្រហើយនាំយកទៅប្រគេន ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានធ្វើជាមហេសីនៃស្តេចទេវតា ១ ពាន់ដង បានធ្វើជាមហេសីនៃស្តេចចក្កពត្តិ ១ ពាន់ដង ។ ខ្ញុំបានធ្វើជាមហេសីនៃស្តេចប្រទេសរាជដ៏ធំទូលាយ រាប់ជាតិមិនអស់ ឯបុណ្យដទៃច្រើន មានប្រការផ្សេងៗ ផលនៃបុណ្យនោះ ច្រើនលើសនោះទៅទៀត ។

សម្បុររបស់ខ្ញុំដូចផ្កាឧប្បល ខ្ញុំជាស្រីមានរូបល្អល្អះ គួររមិលមើល បរិបូណ៌ដោយអវយវៈទាំងអស់ កើតក្នុងត្រកូលខ្ពស់ ទ្រទ្រង់សេចក្តីរុងរឿង ដល់មកក្នុងបច្ឆិមភព ខ្ញុំបានមកកើតក្នុងសក្យត្រកូល ជាប្រធាននៃស្រី ១ ពាន់នៃព្រះរាជបុត្តរបស់ព្រះបាទសុទ្ធោទនៈ ។ ខ្ញុំនឿយណាយក្នុងផ្ទះ ហើយចូលទៅកាន់ផ្នួស លុះគ្រប់ ៧ រាត្រី ក៏បានយល់ច្បាស់នូវសច្ច ៤ ។ ខ្ញុំមិនអាចនឹងរាប់នូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យបានទេ នេះឯងជាផលនៃបិណ្ឌបាត ។ បពិត្រព្រះមុនីមានព្យាយាមធំ កុសលកម្មណា ដែលខ្ញុំបានធ្វើហើយ ក្នុងកាលមុន សូមព្រះអង្គរឭកនូវកម្មជាកុសលនោះចុះ ឯអំពើល្អមានច្រើន ដែលខ្ញុំបានលះបង់ហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យបិណ្ឌបាតទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃបិណ្ឌបាត ។ ខ្ញុំស្គាល់តែគតិ ២ គឺទេវតានិងមនុស្ស ខ្ញុំមិនដែលស្គាល់គតិដទៃឡើយ នេះជាផលនៃបិណ្ឌបាត ។ ខ្ញុំស្គាល់តែត្រកូលខ្ពស់ជាមហាសាល មានទ្រព្យច្រើន មិនដែលស្គាល់ត្រកូលដទៃឡើយ នេះជាផលនៃបិណ្ឌបាត ។ ខ្ញុំត្រាច់រង្គាត់ទៅក្នុងភពតូច ភពធំ ត្រូវកុសលមូលជាស់តឿន មិនដែលបានជួបប្រទះនឹងវត្ថុមិនពេញចិត្តឡើយ នេះជាផលនៃសេចក្តីត្រេកអរ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀត

ឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃខ្ញុំព្រះអង្គ កើតឡើងក្នុងសម្នាក់របស់ព្រះអង្គ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧប្បលទាយិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

## ចប់ ឧប្បលទាយិកាថេរិយាបទាន ។

# សិង្គាលមាតាថេរិយាបទានទី ៤

[ ៣៤ ] ព្រះជិនស្រីព្រះនាមព្រះបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ ទាំងពួង ជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែនអំពីកទ្ទកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលអាមាត្យ ដែលរុងរឿងដោយកែវផ្សេងៗដ៏ស្តុកស្តម្ភទូលំទូលាយ មានទ្រព្យច្រើន នៅក្នុងនគរហង្សវតី ។ ខ្ញុំបានទៅជាមួយនឹងបិតា មានមហាជនចោមរោម បានស្តាប់ធម៌របស់ព្រះពុទ្ធជាម្ចាស់ហើយ ក៏ចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសរួចហើយ បានវៀរបាបកម្មដោយកាយ លះបង់វចីទុច្ចរិត ហើយជម្រះអាជីវៈ ។ ខ្ញុំជ្រះថ្លាចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានសេចក្តីគោរពដ៏ក្លៀវក្លា ប្រកបក្នុងការស្តាប់នូវព្រះសទ្ធម្ម ទាំងប្រកបដោយសេចក្តីអាល័យ ចង់ឃើញនូវព្រះពុទ្ធ ។ គ្រានោះ ខ្ញុំបានឮនូវភិក្ខុនីដ៏ប្រសើរលើសជាងពួកភិក្ខុនីដែលមានសទ្ធាស៊ប់សួន ខ្ញុំប្រាថ្នានូវតំណែងនោះ បានបំពេញនូវត្រៃសិក្ខា ។ លំដាប់នោះ ព្រះសុគតមានអធ្យាស្រ័យ ប្រព្រឹត្តទៅតាមសេចក្តីករុណា ទ្រង់ត្រាស់នឹងខ្ញុំថា បុគ្គលណា មានសទ្ធាមិនញាប់ញ័រតម្កល់មាំក្នុងតថាគត ។ បុគ្គលណាមានសីលល្អ ជាទីពេញចិត្តនៃព្រះអរិយៈដែលអ្នកប្រាជ្ញសរសើរហើយ បុគ្គលណាមានសេចក្តីជ្រះថ្លា មានការឃើញត្រង់ក្នុងព្រះសង្ឃ ។ តថាគតត្រាស់ហៅនូវបុគ្គលនោះថា ជាអ្នកមិនទ័លក្រទាំងជីវិតរបស់បុគ្គលនោះ ក៏មិនសោះសូន្យ ហេតុនោះ បុគ្គលមានប្រាជ្ញាជាគ្រឿងកម្ចាត់កិលេស កាលរឭកឃើញព្រះពុទ្ធសាសនា គប្បីប្រកបដោយរឿយៗនូវសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង ការឃើញធម៌ផង ។ លុះខ្ញុំបានស្តាប់ពុទ្ធភាសិតនោះហើយ ក៏រីករាយ ហើយបានទូលសួរនូវសេចក្តី

ប្រាថ្នារបស់ខ្ញុំ ។

វេលានោះ ព្រះនាយកមិនថោកទាប មានគុណរាប់មិនអស់ ទ្រង់ព្យាករថា នាងមានលំអ ជ្រះថ្លាក្នុងព្រះពុទ្ធ នឹងបានតំណែងនុ៎ះដែលនាងប្រាថ្នាល្អហើយ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះមហាបុរស សម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ នឹងបានជាសាស្តាព្រះនាមគោតមក្នុងលោក ។ នាងនឹងបានជាឱរសដែលព្រះធម៌និម្មិតហើយ ជាអ្នកទទួលមត៌កក្នុងធម៌នៃព្រះសម្ពុទ្ធនោះ ជាមាតានៃសង្គាលមាណព នឹងបានជាសាវិការបស់ព្រះសាស្តា ។ គ្រានោះ ខ្ញុំបានស្តាប់ពុទ្ធភាសិតនោះហើយ ក៏រីករាយ មានចិត្តមេត្តា ខំបម្រើព្រះជិនស្រី ជានាយក ដោយការប្រតិបត្តិ ដរាបអស់ជីវិត ។ ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ។ ដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានកើតក្នុងគិរិព្វជបុរីដ៏ឧត្តម ក្នុងត្រកូលសេដ្ឋី ស្តុកស្តម្ភទូលំទូលាយ ពាសពេញដោយកែវដ៏ច្រើន ។ កូនប្រុសរបស់ខ្ញុំឈ្មោះសិង្គាល ជាអ្នកត្រេកអរក្នុងផ្លូវខុស ស្ទុះទៅកាន់ទីសាំញ៉ាំគឺទិដ្ឋិ មានចិត្តជាប់ចំពាក់ក្នុងការបូជាទិស តែងមនស្ការទិសផ្សេងៗ ។ ព្រះពុទ្ធជានាយក ទ្រង់ស្តេចទៅបិណ្ឌបាត ក្នុងវេឡុវន ទ្រង់ឃើញសិង្គាលមាណពនោះ ទ្រង់គន់នៅ ប្រាប់ផ្លូវហើយឲ្យឱវាទ ។ កាលព្រះពុទ្ធជាម្ចាស់នោះទ្រង់សម្តែងធម៌ ក៏កើតមានសំឡេងគឹកកងអស្ចារ្យ ពួកនារី ២ កោដិក្នុងទីក្រុង ក៏បានសម្រេចមគ្គផល ។ កាលណោះ ខ្ញុំបានទៅកាន់បរិស័ទនោះ ស្តាប់ភាសិតរបស់ព្រះ

សុគត ហើយបានសម្រេចសោតាបត្តិផល ក៏ចូលទៅកាន់ផ្នួស ។ ខ្ញុំប្រកប ដោយសេចក្តីអាល័យ ក្នុងការឃើញនូវព្រះពុទ្ធ មិនយូរប៉ុន្មាន ក៏ចម្រើន អនុស្សតិនោះ ហើយបានដល់ព្រះអរហត្ត ។ ខ្ញុំទៅដើម្បីប្រយោជន៍ដល់ការ ចូលគាល់ព្រះពុទ្ធគ្រប់កាល ខ្ញុំមិនចេះឆ្អែតឆ្អន់ ( ក្នុងការមើលរូប ) តែង មើលរូបដែលជាទីត្រេកអរនៃភ្នែកនោះ ខ្ញុំនៅតែមិនឆ្អែតឆ្អន់នឹងរូបដទៃ ដែល កើតអំពីបារមីធម៌ទាំងអស់ ជាទីកើតនៃបុណ្យ កុះករដោយធម៌ដ៏ល្អទាំងអស់ ឡើយ ។ ព្រះជិនស្រី ទ្រង់ត្រេកអរក្នុងគុណនៃខ្ញុំនោះ ទ្រង់តាំងខ្ញុំក្នុងទីជា ឯតទគ្គៈ ជាមាតានៃសង្គាលមាណព ថាជាស្រីប្រសើរ មានសទ្ធាស៊ប់សួន ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណ ផង ។ ខ្ញុំដឹងនូវបុព្វេនិវាស ទាំងទិព្វចក្ខុខ្ញុំបានជម្រះស្អាតល្អហើយ ឥឡូវ នេះ ភពថ្មីទៀតមិនមានឡើយ ព្រោះកំណត់ដឹងនូវអាសវៈទាំងពួង ។ បពិត្រ ព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និ-រុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃខ្ញុំកើតឡើងក្នុងសម្នាក់របស់ ព្រះ អង្គ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញ ហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្តាច់ នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបាន សម្រេចហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះ

ពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសង្គាលមាតាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សង្គាលមាតាថេរិយាបទាន ។**

# សុក្កាថេរិយាបទានទី ៥

[ ៣៥ ] ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយកព្រះនាមវិបស្សី មានព្រះនេត្រដូចមាស ពិចារណាឃើញធម៌ទាំងអស់ កើតឡើងហើយ ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលមួយក្នុងនគរពន្ធុមតី បានស្តាប់ធម៌របស់ព្រះមុនីហើយ ចូលទៅកាន់ផ្នួស ។ ខ្ញុំជាអ្នកស្តាប់ច្រើន ចងចាំនូវធម៌ ជាអ្នកមានប្រាជ្ញាមួយទៀត ជាអ្នកពោលពាក្យវិចិត្រ ទាំងជាអ្នកធ្វើតាមសាសនានៃព្រះជិនស្រី ។ កាលនោះ ខ្ញុំបានធ្វើនូវធម្មកថា ដើម្បីប្រយោជន៍ដល់ប្រជុំជន គ្រប់កាលលុះខ្ញុំច្យុតចាកអត្តភាពនោះ ក៏ចូលទៅកើតក្នុងឋានតុសិត ជាស្រី មានយស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រះជិនស្រីព្រះនាមសិខី រុងរឿងដោយយសដូចជាភ្លើង ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ កើតឡើងក្នុងលោក ។ គ្រានោះ ខ្ញុំបានបួស ជាស្រីវាងវៃក្នុងព្រះពុទ្ធសាសនា ញុំាងព្រះពុទ្ធដីកាព្រះ ជិនស្រីឲ្យរុងរឿង លុះច្យុតចាកអត្តភាពនោះ ក៏បានទៅកាន់ឋានតាវត្តិង្ស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រះនាយកព្រះនាមវេស្សភូ ទ្រង់កើតឡើង ( ក្នុងលោក ) ឯខ្ញុំក៏កើតឡើងតំណាលនឹងព្រះនាយកនោះ ក្នុងកាលនោះដែរ ជា

អ្នកមានយានដ៏ធំ ។ ខ្ញុំបួសហើយ ជាអ្នកចងចាំនូវធម៌ ញ៉ាំងសាសនា ព្រះជិនស្រីឲ្យរុងរឿង ហើយទៅកើតក្នុងបុរីរបស់ទេវតាដែលជាទីរីករាយ ទទួលសេចក្ដីសុខដ៏ច្រើន ។ ក្នុងភទ្ទកប្បនេះ ព្រះជិនស្រីដ៏ឧត្ដមព្រះនាមកកុសន្ធៈ ជានរៈដ៏ខ្ពង់ខ្ពស់ កើតឡើងក្នុងលោក កាលនោះ ខ្ញុំក៏បានកើតឡើងដែរ ។ ខ្ញុំបានបួសរួចហើយ ញ៉ាំងសាសនានៃព្រះជិនស្រីឲ្យរុងរឿង តាមសប្បាយ ខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានទៅកើតក្នុងឋានត្រៃត្រិង្ស ដូចជាភពរបស់ខ្លួនដដែល ។ ក្នុងកប្បនេះដដែល ព្រះនាយកព្រះនាមកោនាគមនៈ ប្រសើរជាងអ្នកប្រាជ្ញ ឧត្ដមជាងពួកសត្វទាំងពួង ទ្រង់កើតឡើង ។ គ្រានោះ ខ្ញុំបានបួសក្នុងសាសនានៃព្រះកោនាគមនៈនោះ ព្រះអង្គប្រកបដោយតាទិគុណ ជាអ្នកបានស្ដាប់ច្រើន ចងចាំនូវធម៌ ញ៉ាំងសាសនានៃព្រះជិនស្រីឲ្យរុងរឿង ។ ក្នុងកប្បនេះឯង ព្រះមុនីទី ៧ ព្រះនាមកស្សប ជាទីពឹងនៃសត្វលោក មិនមានកិលេសដល់នូវព្រះនិព្វាន ជាទីបំផុតនៃមរណៈ កើតឡើង ។ ចំណែកខ្ញុំបានបួសក្នុងសាសនារបស់ព្រះពុទ្ធជាអ្នកប្រាជ្ញជាងពួកជននោះ មានព្រះសទ្ធម្មបែកសព្វគ្រប់ ដ៏ក្លៀវក្លាខាងការសោកស្ដារ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកមានសីលល្អ មានសេចក្ដីអៀនខ្មាស វាងវៃក្នុងត្រៃសិក្ខា ហើយធ្វើនូវធម្មកថា មានប្រមាណច្រើន ដរាបដល់អស់ជីវិត ។ ដោយកម្មវិបាកនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានកើតក្នុងត្រកូលនៃសេដ្ឋី ដ៏ធំទូលាយ ដេរដាសដោយរតនៈច្រើន ក្នុងគិរិព្វជបុរីដ៏

ឧត្តម ។ កាលព្រះលោកនាយក មានភិក្ខុចំនួន ១ ពាន់រូបចោមរោម ទ្រង់ស្តេចទៅកាន់ក្រុងរាជគ្រឹះ ព្រះឥន្ទក៏បានពោលសរសើរថា

ព្រះមានព្រះភាគ មានឥន្ទ្រិយទូន្មានហើយ មានព្រះហឫទ័យ
ផុតចាកកិលេសហើយ ព្រមដោយបុរាណជដិលទាំងឡាយ
ដែលមានឥន្ទ្រិយទូន្មាន មានចិត្តផុតស្រឡះហើយ ទ្រង់មាន
ពណ៌ិបី ដូចជាពណ៌ិនៃមាសឆ្តោឈ្មោះសិង្គី ស្តេចយាងចូល
ទៅកាន់ក្រុងរាជគ្រឹះ ។

ខ្ញុំបានឃើញអានុភាពនៃព្រះពុទ្ធនោះផង បានស្តាប់ការប្រជុំនូវគុណនោះផង ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងគុណរបស់ព្រះពុទ្ធ បានបូជាព្រះពុទ្ធនោះសមគួរតាមកម្លាំង ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួសក្នុងសម្នាក់នៃនាងធម្មទិន្នាថេរី ។ កាលសក់កំពុងជាប់ចុះ ខ្ញុំបានដុតបំផ្លាញពួកកិលេសហើយ ខ្ញុំបួសមិនយូរប៉ុន្មាន ក៏បានរៀននូវព្រះពុទ្ធសាសនា ចប់សព្វគ្រប់ ។ លំដាប់តពីនោះមក ខ្ញុំបានសម្តែងធម៌ក្នុងទីប្រជុំជនដ៏ច្រើនកាលដែលខ្ញុំកំពុងតែសម្តែងធម៌ ធម្មាភិសម័យ ក៏កើតមាន ( ដល់ជនទាំងឡាយ ) ។ បណ្តាពួកសត្វជាច្រើនពាន់ មានយក្សមួយដឹងច្បាស់នូវធម៌នោះហើយសង្វេគជ្រះថ្លានឹងខ្ញុំ ហើយបានទៅកាន់ក្រុងគិរិព្វជៈដោយគិតថា មនុស្សណាមិនចូលទៅអង្គុយជិតនាងសុក្កាថេរី ដែលកំពុងសម្តែងនូវអមតបទ គឺនិព្វាន អាត្មាអញធ្វើដូចម្តេចហ្ន៎ ឲ្យមនុស្សទាំងនោះ ដែលនៅក្នុងក្រុងរាជគហៈមូលគ្នាដូចពួកសត្វរោមផឹកនូវទឹកផ្អែម ។ ចំណែកខាងពួកបុគ្គលអ្នកប្រកបដោយ

បញ្ញា ទំនងជាផឹកទឹកអម្រឹតនោះ ដែលកិលេសមិនគប្បីតស៊ូបាន មានឱជា មិនបាច់ស្រោចថែម ដូចជាបុគ្គលដើរផ្លូវឆ្ងាយ ផឹកទឹកភ្លៀង ។

បពិត្រព្រះពុទ្ធជាមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោ-បរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំជម្រះស្អាតល្អហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្ប-ដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃខ្ញុំព្រះអង្គកើតឡើងក្នុង សម្នាក់នៃព្រះអង្គ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុក្កាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ សុក្កាថេរិយាបទាន ។**

**ចប់ភាណវារៈ ទី ៥ ។**

# អភិរូបនន្ទាថេរិយាបទានទី ៦

[ ៣៦ ] ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយក ព្រះនាមវិបស្សី មាន ព្រះនេត្រដូចជាមាស មានចក្ខុក្នុងធម៌ទាំងពួងកើតឡើង ។ គ្រានោះ ខ្ញុំកើត ក្នុងត្រកូលធំ ស្តុកស្តម្ភទូលំទូលាយក្នុងពន្ធុមតីនគរ ជាស្ត្រីមានរូបល្អ គួរ មហាជនបូជា ។ ខ្ញុំបានចូលទៅគាល់ព្រះលោកនាយក ព្រះនាមវិបស្សី ទ្រង់ មានព្យាយាមធំ បានស្តាប់ធម៌ហើយ ដល់នូវព្រះពុទ្ធជានាយកនៃពួក ជន ជាទីពឹង ។ ខ្ញុំជាអ្នកសង្រួមល្អក្នុងសីលទាំងឡាយ កាលដែលព្រះលោក នាយកដ៏ខ្ពង់ខ្ពស់ជាងពួកជន ទ្រង់បរិនិព្វានទៅហើយ ខ្ញុំបានបូជាឆត្រមាស តម្កល់ពីខាងលើនៃព្រះស្តូបដែលបញ្ចុះព្រះធាតុ ។ ខ្ញុំបានបរិច្ចាគទាន រួចផុត ហើយ ជាអ្នកមានសីលល្អ រស់នៅរហូតកំណត់អាយុ ក៏បានច្យុតចាកទីនោះ ។ លុះខ្ញុំលះបង់រាងកាយជារបស់នៃមនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ កាលនោះ ខ្ញុំគ្របសង្កត់នូវពួកទេវតាដទៃមិនសេសសល់ ដោយហេតុ ១០ យ៉ាងគឺ បានរុងរឿងគ្របសង្កត់ដោយ រូប ១ សំឡេង ១ ក្លិន ១ រស ១ សម្ផស្ស ១ អាយុ ១ ពណ៌ ១ សេចក្តីសុខ ១ យស ១ ភាពនៃខ្លួនជាធំ ១ ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំបានកើតជាធីតានៃខេមកសាក្យៈ ប្រាកដ នាមថា នន្ទា ក្នុងក្រុងកបិលពស្តុ ។ កាលណាខ្ញុំដល់នូវសេចក្តីចម្រើន ស្អិត ស្អាងដោយរូបនិងពណ៌ កាលនោះ ពួកជនបានពោលថា ខ្ញុំជាស្រីស្រួចមួយ មានរូបសម្បត្តិល្អ ។ សេចក្តីវិវាទដ៏ធំក្រៃលែងកើតមានដល់ពួកសក្យៈ ក្នុង នគរនេះ ព្រោះតែស្រឡាញ់ខ្ញុំ លំដាប់នោះ បិតាបានឲ្យខ្ញុំបួស ដោយគិតថា កុំឲ្យពួកសក្យៈវិនាសឡើយ ។ លុះខ្ញុំបួសរួចហើយ បានឮព្រះតថាគត ជា

បុគ្គលប្រសើរជាងពួកជន ទ្រង់គិះដៀលរូប ខ្ញុំជាស្រីប្រកាន់រូប មិនចូលទៅជិតព្រះអង្គ ។ ខ្ញុំជាអ្នកមានសេចក្ដីខ្លាចក្នុងការឃើញព្រះពុទ្ធ មិនហ៊ានចូលទៅស្ដាប់ឱវាទសោះ គ្រានោះ ព្រះជិនស្រីទ្រង់ដឹកនាំខ្ញុំទៅកាន់សម្នាក់របស់ព្រះអង្គ ដោយឧបាយ ។ ព្រះជិនស្រី ទ្រង់វាងវៃខាងផ្លូវឫទ្ធិ បាននិម្មិតនូវស្ត្រីភេទ ៣ នាក់ គឺស្ត្រីក្រមុំមានរូបល្អ ស្រដៀងនឹងស្ត្រីអប្សរ ១ ស្ត្រីចាស់ ១ ស្ត្រីស្លាប់ ១ ។ លុះខ្ញុំបានឃើញនូវស្ត្រីទាំង ៣ នោះហើយ ក៏មានសេចក្ដីសង្វេគធុញទ្រាន់ក្នុងរាងកាយ មានសេចក្ដីនឿយណាយក្នុងភព លំ-ដាប់នោះ ព្រះលោកនាយក ទ្រង់ត្រាស់នឹងខ្ញុំថា

ម្នាលនាងនន្ទា នាងចូររមិលមើលនូវរូបនេះ ដែលក្ដៅក្រហាយ មិនស្អាត ស្អុយ ហូរចេញហូរចូល ដែលជនពាលទាំងឡាយប្រាថ្នាក្រៃពេក ។ នាងចូរចម្រើននូវចិត្ត ដែលមានអារម្មណ៍តែមួយ ជាចិត្តតម្កល់មាំដោយអសុភភាវនាចុះ រូបនេះយ៉ាងណា រូបនៃនាងនុ៎ះ ក៏យ៉ាងនុ៎ះដែរ រូបនៃនាងនុ៎ះយ៉ាងណា រូបនេះក៏យ៉ាងនេះដែរ ។

កាលខ្ញុំពិចារណារូបនុ៎ះ យ៉ាងនេះហើយ ក៏មិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ លំដាប់នោះ ក៏នឿយណាយដោយបញ្ញារបស់ខ្លួន ខ្ញុំនោះមិនមានសេចក្ដីប្រមាទ ពិចារណាក្នុងទីនេះដោយឧបាយ ក៏ឃើញកាយនេះ ទាំងខាងក្នុង ទាំងខាងក្រៅ តាមសភាពពិត ។ កាលនោះ ខ្ញុំនឿយណាយក្នុងកាយផង ប្រាសចាកការត្រេកអរនឹងកាយប្រព្រឹត្តទៅខាងក្នុងផង ហើយជាអ្នកមិនមានសេចក្ដីប្រមាទ អស់កិលេសជាគ្រឿងផ្សំ ស្ងប់រម្ងាប់កិលេស មានទុក្ខ

រលត់ហើយ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយ ផងជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំជម្រះស្អាតល្អហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃខ្ញុំព្រះអង្គ កើតឡើងក្នុងសម្នាក់នៃព្រះអង្គ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអភិរូបនន្ទាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ អភិរូបនន្ទាថេរិយាបទាន ។

# អឌ្ឍកាសីថេរិយាបទានទី ៧

[ ៣៧ ] ព្រះជិនស្រីព្រះនាមកស្សប មានផៅពង្សប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ។ កាលនោះ ខ្ញុំបានបួសក្នុងសាសនា របស់ព្រះពុទ្ធអង្គនោះ បានសង្រួមក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ខ្ញុំជាអ្នកដឹងប្រមាណក្នុងអាសនៈដ៏ទាបផង ប្រកបក្នុងការភ្ញាក់រឭកផង មានសេចក្តីព្យាយាមប្រកបហើយផង កាលនោះ ខ្ញុំមានចិត្តប្រទូស្ត បានជេរភិក្ខុនី ដែលប្រាសចាកអាសវៈអស់វារៈម្តងថា នែ៎ ស្ត្រីផ្កាមាស ខ្ញុំក៏ទៅឆេះក្នុងនរក ព្រោះបាបកម្មនោះឯង ។ ដោយកម្មដ៏សេសនោះដល់មកក្នុងបច្ឆិមជាតិ ខ្ញុំកើតក្នុងត្រកូលនៃស្ត្រីផ្កាមាស ជាអ្នកអាស្រ័យចិញ្ចឹមជីវិត ដោយបុគ្គលដទៃទៀតជាច្រើន ។ ខ្ញុំបានកើតក្នុងត្រកូលសេដ្ឋី នៅក្នុងដែនកាសី ដោយផលដែលបានប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកបរិបូណ៌ដោយរូប បីដូចជាស្រីអប្សរក្នុងទេវលោក ។ ជនទាំងឡាយបានឃើញខ្ញុំ ដែលគួរមិលមើលក្នុងគិរិព្វជបុរីដ៏ឧត្តម ក៏ញ៉ាំងខ្ញុំឲ្យនៅក្នុងពួកនៃស្ត្រីផ្កាមាស ព្រោះផលនៃការជេររបស់ខ្ញុំនោះ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទានៃខ្ញុំកើតឡើងក្នុងសម្នាក់នៃព្រះអង្គ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ កពទាំងពួងខ្ញុំដកចោលអស់ហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់

ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអឌ្ឍកាសីភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ អឌ្ឍកាសីថេរិយាបទាន ។**

# បុណ្ណិកាថេរិយាបទាន ទី ៨

[ ៣៨ ] ខ្ញុំបានបួសក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមវិបស្សី ផង ព្រះនាមសិខីផង ព្រះនាមវេស្សភូផង ព្រះនាមកកុសន្ធៈផង ព្រះនាមកោនាគមនៈប្រកបដោយតាទិគុណផង ព្រះនាមកស្សបៈផង ខ្ញុំជាភិក្ខុនីបរិបូណ៌ដោយសីល មានប្រាជ្ញាចាស់ក្លា មានឥន្ទ្រិយសង្រួមល្អ ។ ជាពហុស្សូត ចងចាំនូវធម៌ ជាអ្នកសាកសួរនូវធម៌និងអត្ថ ហើយរៀនធម៌ស្តាប់ធម៌ ទាំងជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធជាម្ចាស់ ។ ខ្ញុំបានសម្តែងនូវសាសនារបស់ព្រះជិនស្រីក្នុងកណ្តាលនៃប្រជុំជន ខ្ញុំមានសីលជាទីស្រឡាញ់ បានមើលងាយគេ ដោយអាងខ្លួនជាពហុស្សូតនោះ ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំបានកើតក្នុងផ្ទៃនៃស្រីកុម្ភទាសី ក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋី ក្នុងបុរីដ៏ឧត្តមឈ្មោះសាវត្ថី ។ ខ្ញុំទៅកាន់កំពង់ទឹក បានឃើញសោត្ថិយព្រាហ្មណ៍ដែលជាអ្នកត្រូវត្រជាក់គ្របសង្កត់ ក្នុងកណ្តាលទឹក លុះខ្ញុំឃើញព្រាហ្មណ៍នោះហើយ បានពោលពាក្យនេះថា ខ្ញុំជាស្រីដងទឹក ចុះទឹកដ៏ត្រជាក់សព្វៗ

កាល ព្រោះភ័យកិតនិងអាជ្ញានៃម្ចាស់ ព្រោះភ័យនឹងពាក្យកំហឹងគ្របសង្កត់ ។ នៃព្រាហ្មណ៍ ចុះអ្នកខ្លាចនរណា បានជាមកចុះត្រាំទឹកសព្វៗកាល មានខ្លួនញាប់ញ័រ រងនូវត្រជាក់ដ៏ក្រៃលែង ។

ម្នាលនាងបុណ្ណិកាដ៏ចម្រើន យើអើ ! នាងស្គាល់យើងច្បាស់ បានជាហ៊ានសាកសួរយើង ដែលកំពុងធ្វើកុសលកម្ម បន្ទោរបង់នូវកម្មដ៏លាមក ។ បុគ្គលណាទោះបីចាស់ក្តី ក្មេងក្តី ធ្វើបាបកម្មហើយ បុគ្គលនោះឯង លុះតែជងទឹកមកស្រោចស្រពកាយ ទើបរួចចាកបាបកម្មបាន ។

កាលព្រាហ្មណ៍នោះ ឡើងមកអំពីទឹកវិញ ខ្ញុំក៏បានពោលនូវបទប្រកបដោយធម៌និងអត្ថ ឯព្រាហ្មណ៍បានឮភាសិតនោះហើយ ក៏តក់ស្លុតចេញទៅបួស បានសម្រេចជាព្រះអរហន្ត ខ្ញុំតាំងពីកើតក្នុងទាសីត្រកូល បានបំពេញជាទាសីមួយរយខ្វះមួយ ចាប់ដើមអំពីនោះមក នាមរបស់ខ្ញុំឈ្មោះថាបុណ្ណាជនទាំងនោះ បានធ្វើខ្ញុំឲ្យរួចជាអ្នកជា លំដាប់នោះ ខ្ញុំបានញុំាងសេដ្ឋីឲ្យរីករាយតាម ហើយចូលទៅកាន់ផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ។ បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំម្ចាស់ដឹងច្បាស់នូវបុព្វេនិវាស ទាំងទិព្វចក្ខុ ខ្ញុំម្ចាស់បានជម្រះស្អាតល្អហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ កពថ្មីទៀតមិនមានឡើយ ។ ខ្ញុំម្ចាស់មានសេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥត

មានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធប្រសើរ ។ ខ្ញុំមានប្រាជ្ញាច្រើន ព្រោះការអប់រំ ជាអ្នកចេះដឹង ព្រោះការស្តាប់ ជាអ្នកកើតក្នុងត្រកូលទាបព្រោះមានះ ព្រោះថា កម្មរបស់ខ្ញុំមិនបាននិនាសឡើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាងបុណ្ណិកាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ បុណ្ណិកាថេរិយាបទាន ។

# អម្ពបាលីថេរិយាបទានទី ៩

[ ៣៩ ] ព្រះមហាមុនី ព្រះនាមផុស្សៈណា មានជួរនៃរស្មីដ៏រុងរឿង ខ្ញុំបានកើតក្នុងខត្តិយត្រកូល ជាប្អូនស្រីនៃព្រះមហាមុនីនោះ ។ ខ្ញុំបានស្តាប់ព្រះធម៌នៃព្រះមហាមុនីនោះហើយ មានចិត្តជ្រះថ្លា បានថ្វាយមហាទាន ហើយប្រាថ្នានូវរូបសម្បត្តិ ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រះជិនស្រីព្រះនាមសិខី ជានាយកដ៏ប្រសើរក្នុងលោក ជាពន្លឺនៃលោក ជាទីពឹងនៃត្រៃភពកើតឡើង ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលនៃព្រាហ្មណ៍ ក្នុងអរុណាបុរី ជាទីក្រុងរីករាយ បានខឹងជេរផ្តាសាភិក្ខុនីដែលមានចិត្តរួចស្រឡះចាកកិលេសហើយ ។ មួយទៀត ខ្ញុំបានកើតជាស្រីផ្កាមាស ឥតមានអាចារៈ ជាអ្នកប្រទូស្តចំពោះសាសនានៃព្រះជិនស្រីសម្ពុទ្ធ បានជេរភិក្ខុនី តាមទំនងដូចគ្នា ព្រោះតែបាបកម្មនោះឯង ខ្ញុំបានទៅកើតក្នុងនរកដ៏អាក្រក់ ឆ្អែតឆ្អល់ដោយសេចក្តីទុក្ខយ៉ាងខ្លាំង លុះខ្ញុំរួចចាកនរកនោះ បានមកកើតក្នុងមនុស្ស ជាស្រីមានតបៈ ។ ខ្ញុំកើតជាស្រីផ្កាមាសអស់ ១០ ពាន់ជាតិ ខ្ញុំមិនរួចចាកបាបនោះទេ ដូចបុគ្គលបរិភោគថ្នាំពិស ដ៏កាចអាក្រក់ ។ ខ្ញុំបានសេពគប់នូវភេទដ៏ប្រសើរ កើតក្នុងសាសនានៃព្រះជិនស្រី ព្រះនាមកស្សបៈ ដោយអំណាចនៃផលកម្មនោះ ខ្ញុំបានទៅកើតក្នុងបុរីឋានត្រៃត្រិង្ស ។ លុះមកដល់បច្ឆិមភព ខ្ញុំជាឱបបាតិកៈកំណើត បានកើតក្នុងចន្លោះនៃមែកស្វាយ ព្រោះហេតុនោះ បានជាខ្ញុំឈ្មោះជាអម្ពបាលី ។ ខ្ញុំមានពួកសត្វ ១ កោដិចោមរោមហើយ បួសក្នុងសាសនាព្រះជិនស្រី បានជាធីតា ជាឱរសនៃព្រះពុទ្ធ ហើយបានដល់ឋានដ៏មិនកម្រើក បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់

ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ខ្ញុំមានសេចក្តីដឹងច្បាស់ក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធដ៏ប្រសើរ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញអស់ហើយ ភពទាំងពួងខ្ញុំដកចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពបាលីភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## ចប់ អម្ពបាលីថេរិយាបទាន ។

# សោណាថេរិយាបទានទី ១០

[ ៤០ ] ព្រះជិនស្រី ព្រះនាមកស្សបៈ មានផៅពង្សប្រសើរ ទ្រង់មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ។ ខ្ញុំកើតក្នុងត្រកូលនៃឧបាសកក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរ ជាអ្នកខ្វល់ខ្វាយ បានឃើញព្រះជិនស្រីដ៏ប្រសើរនោះផង បានស្តាប់នូវទេសនាផង ។ ខ្ញុំដល់នូវព្រះពុទ្ធ ទ្រង់មានសេចក្តីព្យាយាមនោះ ជាទីពឹងផង សមាទាននូវសីលទាំងឡាយផង ជួនកាល ព្រះពុទ្ធមានព្យាយាមធំនោះ ប្រសើរជាងពួកជន ទ្រង់ប្រកាសនូវអភិសម្ពោធិញ្ញាណរបស់ព្រះអង្គ ក្នុងទីប្រជុំមហាជន ក្នុងសច្ចទាំងឡាយ មានទុក្ខសច្ចជាដើម ជាធម៌ដែលព្រះអង្គមិនធ្លាប់ឮក្នុងកាលមុន ។ ចក្ខុក្តី ញាណក្តី បញ្ញាក្តី វិជ្ជាក្តី ពន្លឺក្តី កើតមានដល់ខ្ញុំ បពិត្រភិក្ខុទាំងឡាយ ខ្ញុំបានស្តាប់ បានរៀននូវរឿងនោះ ហើយសាកសួរ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់នៃមនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះដល់មកក្នុងបច្ឆិមភព ខ្ញុំកើតក្នុងត្រកូលមហាសេដ្ឋី បានចូលទៅជិតព្រះពុទ្ធ ហើយបានស្តាប់នូវព្រះសទ្ធម្មដែលប្រកបដោយមច្ចុ ។ ខ្ញុំបួសហើយមិនយូរប៉ុន្មាន ក៏បានត្រិះរិះនូវប្រយោជន៍ទាំងពួង បានញុំាងអាសវៈទាំងពួងឲ្យអស់ហើយបានសម្រេចព្រះអរហត្ត ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតល្អហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវ

នេះ ភពថ្មីទៀតមិនមានឡើយ ។ ខ្ញុំមានសេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធដ៏ប្រសើរ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោណាភិក្ខុនីមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## ចប់ សោណាថេរិយាបទាន ។

## ឧទ្ទាន

អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន ១ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន ១ ឧប្បលទាយិកាថេរិយាបទាន ១ សិង្គាលមាតាថេរិយាបទាន ១ សុក្កាថេរិយាបទាន ១ អភិរូបនន្ទាថេរិយាបទាន ១ អឌ្ឍកាសីថេរិយាបទាន ១ បុណ្ណិកាថេរិយាបទាន ១ អម្ពបាលីថេរិយាបទាន ១ សេលាថេរិយាបទាន ១ ។

### ចប់ ខត្តិយកញ្ញាវគ្គទី ៤ ។

### ចប់ អបទាន ។

# ក្បាលទី ៦១

# សុត្តន្តបិដក ទាលីប្រែ -៧៤

## អារក្ខទាយកវគ្គ ទី ៣២

មាតិកា ទំព័រ

អារក្ខទាយកត្ថេរាបទានទី ១ .......... .......... .......... .......... .......... ២
កោជនទាយកត្ថេរាបទានទី ២ .......... .......... .......... .......... .......... ៣
គតសញ្ញកត្ថេរាបទានទី ៣ .......... .......... .......... .......... .......... ៤
អដ្ឋកថាអារក្ខទាយកត្ថេរាបទានជាដើម .......... .......... .......... .......... .......... ៥
សត្តបទុមិយត្ថេរាបទានទី ៤ .......... .......... .......... .......... .......... ៦
អដ្ឋកថាសត្តបទុមិយត្ថេរាបទាន .......... .......... .......... .......... .......... ៧
បុប្ផាសនទាយកត្ថេរាបទានទី ៥ .......... .......... .......... .......... .......... ៨
អដ្ឋកថាបុប្ផាសនទាយកត្ថេរាបទាន .......... .......... .......... .......... .......... ៩
អាសនត្ថវិកត្ថេរាបទានទី ៦ .......... .......... .......... .......... .......... ១០
អដ្ឋកថាអាសនត្ថវិកត្ថេរាបទាន .......... .......... .......... .......... .......... ១១
សទ្ទសញ្ញកត្ថេរាបទានទី ៧ .......... .......... .......... .......... .......... ១២
អដ្ឋកថាសទ្ទសញ្ញកត្ថេរាបទាន .......... .......... .......... .......... .......... ១៣
តិរំសិយត្ថេរាបទានទី ៨ .......... .......... .......... .......... .......... ១៤
នាលិបុប្ផិយត្ថេរាបទានទី ៩ .......... .......... .......... .......... .......... ១៥
កុមុទមាលិយត្ថេរាបទានទី ១០ .......... .......... .......... .......... .......... ១៦
អដ្ឋកថាតិរំសិយត្ថេរាបទានជាដើម .......... .......... .......... .......... .......... ១៧

## ឧម្មាបុប្ផិយវគ្គ ទី ៣៣

ឧម្មាបុប្ផិយត្ថេរាបទានទី ១ .......... .......... .......... .......... .......... ១៨

បុឡិនបូជកត្ថេរាបទានទី ២ .......... .......... .......... .......... .... ១៩
ហាសជនកត្ថេរាបទានទី ៣ .......... .......... .......... .......... .... ២០
យញ្ញសាមិកត្ថេរាបទានទី ៤ .......... .......... .......... .......... .... ២១
និមិត្តសញ្ញកត្ថេរាបទានទី ៥ .......... .......... .......... .......... .... ២២
អន្នសំសាវកត្ថេរាបទានទី ៦ .......... .......... .......... .......... .... ២៣
អដ្ឋកថាឧម្មាបុប្ផិយត្ថេរាបទានជាដើម .......... .......... .......... .......... .... ២៤
និគ្គុណ្ឌិបុប្ផិយត្ថេរាបទានទី ៧ .......... .......... .......... .......... .... ២៥
អដ្ឋកថានិគ្គុណ្ឌិបុប្ផិយត្ថេរាបទាន .......... .......... .......... .......... .... ២៨
សុមនាវេឡិយត្ថេរាបទានទី ៨ .......... .......... .......... .......... .... ២៩
បុប្ផច្ឆត្តិយត្ថេរាបទានទី ៩ .......... .......... .......... .......... .... ៣០
សបរិវារច្ឆត្តទាយកត្ថេរាបទានទី ១០ .......... .......... .......... .......... .... ៣១
អដ្ឋកថាសុមនាវេឡិយត្ថេរាបទានជាដើម .......... .......... .......... .......... .... ៣៤

## គន្ធោទកវគ្គ ទី ៣៤

គន្ធធូបិយត្ថេរាបទានទី ១ .......... .......... .......... .......... .... ៣៥
ឧទកបូជកត្ថេរាបទានទី ២ .......... .......... .......... .......... .... ៣៦
បុន្នាគបុប្ផិយត្ថេរាបទានទី ៣ .......... .......... .......... .......... .... ៣៧
ឯកទុស្សទាយកត្ថេរាបទានទី ៤ .......... .......... .......... .......... .... ៣៧
ផុសិតកម្មិយត្ថេរាបទានទី ៥ .......... .......... .......... .......... .... ៤០
បភង្ករត្ថេរាបទានទី ៦ .......... .......... .......... .......... .... ៤១
តិណកុដិទាយកត្ថេរាបទានទី ៧ .......... .......... .......... .......... .... ៤៤
ឧត្តរេយ្យទាយកត្ថេរាបទានទី ៨ .......... .......... .......... .......... .... ៤៥
ធម្មស្សវនិយត្ថេរាបទានទី ៩ .......... .......... .......... .......... .... ៤៨

ឧក្ខិត្តបទុមិយត្ថេរាបទានទី ១០ .......... .......... .......... .......... ........ ៥០
អដ្ឋកថាគន្ធធូបិយត្ថេរាបទានជាដើម .......... ......... .......... .......... ........ ៥២

## ឯកបទុមវគ្គ ទី ៣៥

ឯកបទុមិយត្ថេរាបទានទី ១ .......... .......... .......... .......... ... ៥៣
តិណុប្បលមាលិយត្ថេរាបទានទី ២ .......... .......... .......... .......... ... ៥៤
ធជទាយកត្ថេរាបទានទី ៣ .......... .......... .......... .......... ... ៥៥
តីណិកិង្កណិបូជកត្ថេរាបទានទី ៤ .......... .......... .......... .......... ... ៥៦
នឡាគារិកត្ថេរាបទានទី ៥ .......... .......... .......... .......... ... ៥៧
ចម្បកបុប្ផិយត្ថេរាបទានទី ៦ .......... .......... .......... .......... ... ៥៨
បទុមបូជកត្ថេរាបទានទី ៧ .......... .......... .......... .......... ... ៥៨
តិណមុដ្ឋិទាយកត្ថេរាបទានទី ៨ .......... .......... .......... .......... ........ ៥៩
តិន្ទុកផលទាយកត្ថេរាបទានទី ៩ .......... .......... .......... .......... ... ៦១
ឯកញ្ជលិយត្ថេរាបទានទី ១០ .......... .......... .......... .......... ... ៦១
អដ្ឋកថាឯកបទុមិយត្ថេរាបទានជាដើម .......... .......... .......... .......... ... ៦៣

## សទ្ទសញ្ញិកវគ្គ ទី ៣៦

សទ្ទសញ្ញិកត្ថេរាបទានទី ១ .......... .......... .......... .......... ... ៦៤
យវកលាបិយត្ថេរាបទានទី ២ .......... .......... .......... .......... ... ៦៤
កឹសុកបូជកត្ថេរាបទានទី ៣ .......... .......... .......... .......... ... ៦៥
សកោដកកោរណ្ឌទាយកត្ថេរាបទានទី ៤ .......... .......... .......... .......... ... ៦៦
ទណ្ឌទាយកត្ថេរាបទានទី ៥ .......... .......... .......... .......... ... ៦៧
អម្ពយាគុទាយកត្ថេរាបទានទី ៦ .......... .......... .......... .......... ... ៦៧
បុដកបូជកត្ថេរាបទានទី ៧ .......... .......... .......... .......... ... ៦៨

វច្ចទាយកត្ថេរាបទានទី ៨ .......... .......... .......... .......... ........ ៦៩
សរណាគមនិយត្ថេរាបទានទី ៩ .......... .......... .......... .......... ........ ៧០
បិណ្ឌបាតិកត្ថេរាបទានទី ១០ .......... .......... .......... .......... ........ ៧០
អដ្ឋកថាសទ្ទសញ្ញិកត្ថេរាបទានជាដើម .......... .......... .......... .......... ........ ៧១

## មន្ទារវបុប្ផិយវគ្គ ទី ៣៧

មន្ទារវិយត្ថេរាបទានទី ១ .......... .......... .......... .......... ........ ៧២
កក្ការុបុប្ផិយត្ថេរាបទានទី ២ .......... .......... .......... .......... ........ ៧២
ភិសមុឡាលទាយកត្ថេរាបទានទី ៣ .......... .......... .......... .......... ........ ៧៣
កេសរបុប្ផិយត្ថេរាបទានទី ៤ .......... .......... .......... .......... ........ ៧៤
អង្កោលបុប្ផិយត្ថេរាបទានទី ៥ .......... .......... .......... .......... ........ ៧៥
កទម្ពបុប្ផិយត្ថេរាបទានទី ៦ .......... .......... .......... .......... ........ ៧៥
ឧទ្ទាលកបុប្ផិយត្ថេរាបទានទី ៧ .......... .......... .......... .......... ........ ៧៦
ឯកចម្បកបុប្ផិយត្ថេរាបទានទី ៨ .......... .......... .......... .......... ........ ៧៧
តិមិរបុប្ផិយត្ថេរាបទានទី ៩ .......... .......... .......... .......... ........ ៧៧
សលឡបុប្ផិយត្ថេរាបទានទី ១០ .......... .......... .......... .......... ........ ៧៨
អដ្ឋកថាមន្ទារវិយត្ថេរាបទានជាដើម .......... .......... .......... .......... ........ ៧៩

## ពោធិវន្ទនវគ្គ ទី ៣៨

ពោធិវន្ទកត្ថេរាបទានទី ១ .......... .......... .......... .......... ........ ៨០
បាដលិបុប្ផិយត្ថេរាបទានទី ២ .......... .......... .......... .......... ........ ៨១
តីណុប្បលមាលិយត្ថេរាបទានទី ៣ .......... .......... .......... .......... ........ ៨២
បត្តិបុប្ផិយត្ថេរាបទានទី ៤ .......... .......... .......... .......... ........ ៨៣
សត្តបណ្ណិយត្ថេរាបទានទី ៥ .......... .......... .......... .......... ........ ៨៤

គន្ធមុដ្ឋិយត្ថេរាបទានទី ៦ .......... .......... .......... ............ ៨៥
ចិតកបូជកត្ថេរាបទានទី ៧ .......... .......... .......... ............ ៨៥
សុមនតាលវណ្តិយត្ថេរាបទានទី ៨ .......... .......... .......... ............ ៨៦
សុមនទាមិយត្ថេរាបទានទី ៩ .......... .......... .......... ............ ៨៧
កាសុមារិផលទាយកត្ថេរាបទានទី ១០ .......... .......... .......... ............ ៨៨
អដ្ឋកថាពោធិវន្ទកត្ថេរាបទានជាដើម .......... .......... .......... ............ ៨៩

## អម្ពដផលវគ្គ ទី ៣៩

អម្ពដផលទាយកត្ថេរាបទានទី ១ .......... .......... .......... ............ ៩០
លពុជទាយកត្ថេរាបទានទី ២ .......... .......... .......... ............ ៩១
ឧទុម្ពរផលទាយកត្ថេរាបទានទី ៣ .......... .......... .......... ............ ៩២
មិលក្ខុផលទាយកត្ថេរាបទាន ទី ៤ .......... .......... .......... ............ ៩៣
ផារុសផលទាយកត្ថេរាបទានទី ៥ .......... .......... .......... ............ ៩៤
វល្លិផលទាយកត្ថេរាបទានទី ៦ .......... .......... .......... ............ ៩៥
កទលិផលទាយកត្ថេរាបទានទី ៧ .......... .......... .......... ............ ៩៦
បនសផលទាយកត្ថេរាបទានទី ៨ .......... .......... .......... ............ ៩៧
អដ្ឋកថាអម្ពដផលទាយកត្ថេរាបទានជាដើម .......... .......... .......... ............ ៩៨
សោណកោដិវីសត្ថេរាបទានទី ៩ .......... .......... .......... ............ ៩៩
អដ្ឋកថាសោណកោដិវីសត្ថេរាបទាន .......... .......... .......... ............ ១០១
បុព្វកម្មបិលោតិនាមពុទ្ធាបទានទី ១០ .......... .......... .......... ............ ១០៥
អដ្ឋកថាបុព្វកម្មបិលោតិនាមពុទ្ធាបទាន ...... .......... .......... ............ ១០៩

## បិលិន្ទវគ្គ ទី ៤០

បិលិន្ទវច្ឆត្ថេរាបទានទី ១ .......... .......... .......... ............ ១១១

អដ្ឋកថាបិលិន្ទវច្ឆត្ថេរាបទាន .......... .......... .......... ........ ១៣២
សេលត្ថេរាបទានទី ២ .......... .......... .......... ........ ១៣៤
សព្វកិត្តិកត្ថេរាបទានទី ៣ .......... .......... .......... ........ ១៤៥
មធុទាយកត្ថេរាបទានទី ៤ .......... .......... .......... ........ ១៤៩
បទុមកូដាគារិកត្ថេរាបទានទី ៥ .......... .......... .......... ........ ១៥២
អដ្ឋកថាសេលត្ថេរាបទានជាដើម .......... .......... .......... ........ ១៥៥
ពក្កុលត្ថេរាបទានទី ៦ .......... .......... .......... ........ ១៥៦
អដ្ឋកថាពក្កុលត្ថេរាបទាន .......... .......... .......... ........ ១៦០
គិរិមានន្ទត្ថេរាបទានទី ៧ .......... .......... .......... ........ ១៦៤
អដ្ឋកថាគិរិមានន្ទត្ថេរាបទាន .......... .......... .......... ........ ១៦៨
សលឡមណ្ឌបិយត្ថេរាបទានទី ៨ .......... .......... .......... ........ ១៧០
សព្វទាយកត្ថេរាបទានទី ៩ .......... .......... .......... ........ ១៧១
អជិតត្ថេរាបទានទី ១០ .......... .......... .......... ........ ១៧៤
អដ្ឋកថាសលឡមណ្ឌបិយត្ថេរាបទានជាដើម .......... .......... .......... ........ ១៧៩

## មេត្តេយ្យវគ្គទី ៤១

តិស្សមេត្តេយ្យត្ថេរាបទានទី១ .......... .......... .......... ........ ១៨០
អដ្ឋកថាតិស្សមេត្តេយ្យត្ថេរាបទាន .......... .......... .......... ........ ១៨៤
បុណ្ណកត្ថេរាបទានទី ២ .......... .......... .......... ........ ១៨៥
អដ្ឋកថាបុណ្ណកត្ថេរាបទាន .......... .......... .......... ........ ១៨៧
មេត្តគុត្ថេរាបទានទី ៣ .......... .......... .......... ........ ១៨៨
អដ្ឋកថាមេត្តគុត្ថេរាបទាន .......... .......... .......... ........ ១៩១
ធោតកត្ថេរាបទានទី ៤ .......... .......... .......... ........ ១៩២

អដ្ឋកថាជោតកត្ថេរាបទាន .......... .......... .......... .......... ...... ១៩៥
ឧបសីវត្ថេរាបទានទី ៥ .......... .......... .......... .......... ...... ១៩៦
អដ្ឋកថាឧបសីវត្ថេរាបទាន .......... .......... .......... .......... ...... ២០២
នន្ទកត្ថេរាបទានទី ៦ .......... .......... .......... .......... ...... ២០៣
អដ្ឋកថានន្ទកត្ថេរាបទាន .......... .......... .......... .......... ...... ២០៥
ហេមកត្ថេរាបទានទី ៧ .......... .......... .......... .......... ...... ២០៧
អដ្ឋកថាហេមកត្ថេរាបទាន .......... .......... .......... .......... ...... ២១២
តោទេយ្យត្ថេរាបទានទី ៨ .......... .......... .......... .......... ...... ២១៣
អដ្ឋកថាតោទេយ្យត្ថេរាបទាន .......... .......... .......... .......... ...... ២១៩
ជតុកណ្ណិកត្ថេរាបទានទី ៩ .......... .......... .......... .......... ...... ២២០
អដ្ឋកថាជតុកណ្ណិកត្ថេរាបទាន .......... .......... .......... .......... ...... ២២៥
ឧទេនត្ថេរាបទានទី១០ .......... .......... .......... .......... ...... ២២៦
អដ្ឋកថាឧទេនត្ថេរាបទាន .......... .......... .......... .......... ...... ២៣១

# សុត្តន្តបិដក បាលីប្រែ -៧៥

# ភទ្ទាលិវគ្គ ទី ៤២

ភទ្ទាលិត្ថេរាបទានទី ១ .......... .......... .......... .......... ...... ២៣២
ឯកច្ឆត្តិយត្ថេរាបទានទី ២ .......... .......... .......... .......... ...... ២៣៦
តិណសូលកឆាទនិយត្ថេរាបទានទី ៣ .......... .......... .......... .......... ...... ២៤១
អដ្ឋកថាភទ្ទាលិត្ថេរាបទានជាដើម .......... .......... .......... .......... ...... ២៤៤
មធុមំសទាយកត្ថេរាបទានទី ៤ .......... .......... .......... .......... ...... ២៤៥
អដ្ឋកថាមធុមំសទាយកត្ថេរាបទាន .......... .......... .......... .......... .... ២៤៧
នាគបល្លវកត្ថេរាបទានទី ៥ .......... .......... .......... .......... .... ២៤៨

ឯកទីបិយត្ថេរាបទានទី ៦ .......... .......... .......... .......... .... ២៤៩
ឧច្ឆុខណ្ឌិកត្ថេរាបទានទី ៧ .......... .......... .......... .......... .... ២៥១
យាគុទាយកត្ថេរាបទានទី ៨ .......... .......... .......... .......... .... ២៥២
បត្ថោទនទាយកត្ថេរាបទានទី ៩ .......... .......... .......... .......... .... ២៥៤
មញ្ចទាយកត្ថេរាបទានទី ១០ .......... .......... .......... .......... .... ២៥៦
អដ្ឋកថានាគបល្លវកត្ថេរាបទានជាដើម .......... .......... .......... .......... .... ២៥៩

# សកឹសម្មជ្ជកវគ្គទី ៤៣

សកឹសម្មជ្ជកត្ថេរាបទានទី ១ .......... .......... .......... .......... .... ២៦០
ឯកទុស្សទាយកត្ថេរាបទានទី ២ .......... .......... .......... .......... .... ២៦២
ឯកាសនទាយកត្ថេរាបទានទី ៣ .......... .......... .......... .......... .... ២៦៤
សត្តកទម្ពបុប្ផិយត្ថេរាបទានទី ៤ .......... .......... .......... .......... .... ២៦៧
កោរណ្ឌបុប្ផិយត្ថេរាបទានទី ៥ .......... .......... .......... .......... .... ២៦៨
ឃជមណ្ឌទាយកត្ថេរាបទានទី ៦ .......... .......... .......... .......... .... ២៦៩
ឯកធម្មស្សវនីយត្ថេរាបទានទី ៧ .......... .......... .......... .......... .... ២៧០
សុចិន្តិតត្ថេរាបទានទី ៨ .......... .......... .......... .......... .... ២៧៣
សោណ្ណកិង្កណិយត្ថេរាបទានទី ៩ .......... .......... .......... .......... .... ២៧៦
សោវណ្ណកោន្តរិកត្ថេរាបទានទី ១០ .......... .......... .......... .......... .... ២៧៨
អដ្ឋកថាសកឹសម្មជ្ជកត្ថេរាបទានជាដើម .......... .......... .......... .......... .... ២៨១

# ឯកវិហារិវគ្គទី ៤៤

ឯកវិហារិយត្ថេរាបទានទី ១ .......... .......... .......... .......... .... ២៨២
ឯកសង្ខិយត្ថេរាបទានទី ២ .......... .......... .......... .......... .... ២៨៣
បាដិហិរសញ្ញកត្ថេរាបទានទី ៣ .......... .......... .......... .......... .... ២៨៥

ញាណត្ថវិកត្ថេរាបទានទី ៤ .......... .......... .......... .......... .... ២៨៦
ឧច្ចង្កណ្ណិកត្ថេរាបទានទី ៥ .......... .......... .......... .......... .... ២៨៨
កលម្ពទាយកត្ថេរាបទានទី ៦ .......... .......... .......... .......... .... ២៨៩
អម្ពាដកទាយកត្ថេរាបទានទី ៧ .......... .......... .......... .......... .... ២៨៩
ហរីតកិទាយកត្ថេរាបទានទី ៨ .......... .......... .......... .......... .... ២៩០
អម្ពបិណ្ឌិយត្ថេរាបទានទី ៩ .......... .......... .......... .......... .... ២៩២
ជម្ពូផលិយត្ថេរាបទានទី ១០ .......... .......... .......... .......... .... ២៩៣
អដ្ឋកថាឯកវិហារិយត្ថេរាបទានជាដើម .......... .......... .......... .......... .... ២៩៥

## វិភេទកិវគ្គ ទី ៤៥

វិភេទកពីជិយត្ថេរាបទានទី ១ .......... .......... .......... .......... .... ២៩៦
អដ្ឋកថាវិភេទកពីជិយត្ថេរាបទាន .......... .......... .......... .......... .... ២៩៧
កោលទាយកត្ថេរាបទានទី ២ .......... .......... .......... .......... .... ២៩៨
វេលុវផលិយត្ថេរាបទានទី ៣ .......... .......... .......... .......... .... ២៩៩
កល្លាតកទាយកត្ថេរាបទានទី ៤ .......... .......... .......... .......... .... ៣០០
ឧម្មាបុប្ផិយត្ថេរាបទានទី ៥ .......... .......... .......... .......... .... ៣០១
អម្ពាដកិយត្ថេរាបទានទី ៦ .......... .......... .......... .......... .... ៣០១
សីហាសនិកត្ថេរាបទានទី ៧ .......... .......... .......... .......... .... ៣០២
បាទបីឋិយត្ថេរាបទានទី ៨ .......... .......... .......... .......... .... ៣០៤
វេទិយការកត្ថេរាបទានទី ៩ .......... .......... .......... .......... .... ៣០៥
ពោធិឃរការកត្ថេរាបទានទី ១០ .......... .......... .......... .......... .... ៣០៦
អដ្ឋកថាកោលទាយកត្ថេរាបទានជាដើម .......... .......... .......... .......... ... ៣០៩

## ជគតិវគ្គ ទី ៤៦

ជគតិទាយកត្ថេរាបទានទី ១ .......... .......... .......... .......... ... ៣១០

មោរហត្ថិយត្ថេរាបទានទី ២ .......... .......... .......... .......... ... ៣១១
សីហាសនពីជិយត្ថេរាបទានទី ៣ .......... .......... .......... .......... ... ៣១២
តិណុក្កធារិយត្ថេរាបទានទី ៤ .......... .......... .......... .......... ... ៣១៣
អក្កមនទាយកត្ថេរាបទានទី ៥ .......... .......... .......... .......... ... ៣១៤
វនកោរណ្ឌិយត្ថេរាបទានទី ៦ .......... .......... .......... .......... ... ៣១៥
ឯកច្ឆត្តិយត្ថេរាបទានទី ៧ .......... .......... .......... .......... ... ៣១៦
ជាតិបុប្ផិយត្ថេរាបទានទី ៨ .......... .......... .......... .......... ... ៣១៨
សត្តិបណ្ណិយត្ថេរាបទានទី ៩ .......... .......... .......... .......... ... ៣១៩
គន្ធបូជកត្ថេរាបទានទី ១០ .......... .......... .......... .......... ... ៣២០
អដ្ឋកថាជគតិទាយកត្ថេរាបទានជាដើម .......... .......... .......... .......... ... ៣២២

## សាលបុប្ផិវគ្គ ទី ៤៧

សាលកុសុមិយត្ថេរាបទានទី ១ .......... .......... .......... .......... ... ៣២៣
ចិតកបូជកត្ថេរាបទានទី ២ .......... .......... .......... .......... ... ៣២៤
ចិតកនិព្វាបកត្ថេរាបទានទី ៣ .......... .......... .......... .......... ... ៣២៥
សេតុទាយកត្ថេរាបទានទី ៤ .......... .......... .......... .......... ... ៣២៦
សុមនតាលវណ្តិយត្ថេរាបទានទី ៥ .......... .......... .......... .......... ... ៣២៧
អវដផលិយត្ថេរាបទានទី ៦ .......... .......... .......... .......... ... ៣២៨
លពុជផលទាយកត្ថេរាបទានទី ៧ .......... .......... .......... .......... ... ៣២៩
មិលក្ខុផលទាយកត្ថេរាបទានទី ៨ .......... .......... .......... .......... ... ៣៣០
សយម្បជិកាណិយត្ថេរាបទានទី ៩ .......... .......... .......... ............ ៣៣១
និមិត្តព្យាករណិយត្ថេរាបទានទី ១០ .......... .......... .......... ............ ៣៣៣
អដ្ឋកថាសាលកុសុមិយត្ថេរាបទានជាដើម .......... .......... .......... ............ ៣៣៥

## ឆន្នមាលិវគ្គ ទី ៤៨

នឡមាលិយត្ថេរាបទានទី ១ .......... .......... .......... ............ ៣៣៦

មណិបូជកត្ថេរាបទានទី ២ .......... .......... .......... ............ ៣៣៧

អដ្ឋកថានឡមាលិយត្ថេរាបទានជាដើម .......... .......... .......... ............ ៣៣៩

ឧក្កាសតិកត្ថេរាបទានទី ៣ .......... .......... .......... ............ ៣៤០

អដ្ឋកថាឧក្កាសតិកត្ថេរាបទាន .......... .......... .......... ............ ៣៤២

សុមនវីជនិយត្ថេរាបទានទី ៤ .......... .......... .......... ............ ៣៤៣

កុម្មាសទាយកត្ថេរាបទានទី ៥ .......... .......... .......... ............ ៣៤៤

អដ្ឋកថាសុមនវីជនិយត្ថេរាបទានជាដើម .......... .......... .......... ............ ៣៤៤

កុសដ្ឋកទាយកត្ថេរាបទានទី ៦ .......... .......... .......... ............ ៣៤៥

អដ្ឋកថាកុសដ្ឋកទាយកត្ថេរាបទាន .......... .......... .......... ............ ៣៤៦

គិរិបុន្នាគិយត្ថេរាបទានទី ៧ .......... .......... .......... ............ ៣៤៧

អដ្ឋកថាគិរិបុន្នាគិយត្ថេរាបទាន .......... .......... .......... ............ ៣៤៨

វល្លិការផលទាយកត្ថេរាបទានទី ៨ .......... .......... .......... ............ ៣៤៩

អដ្ឋកថាវល្លិការផលទាយកត្ថេរាបទាន ........ .......... .......... ............ ៣៥០

បានធិទាយកត្ថេរាបទានទី ៩ .......... .......... .......... ............ ៣៥១

អដ្ឋកថាបានធិទាយកត្ថេរាបទាន .......... .......... .......... ............ ៣៥៣

បុឡិនចង្កមិយត្ថេរាបទានទី ១០ .......... .......... .......... ............ ៣៥៤

អដ្ឋកថាបុឡិនចង្កមិយត្ថេរាបទាន .......... .......... .......... ............ ៣៥៥

## បង្សុកូលវគ្គ ទី ៤៩

បង្សុកូលសញ្ញកត្ថេរាបទានទី ១ .......... .......... .......... .......... ..... ៣៥៦

អដ្ឋកថាបង្សុកូលសញ្ញកត្ថេរាបទាន .......... .......... .......... .......... ..... ៣៥៧

ពុទ្ធសញ្ញកត្ថេរាបទានទី ២ .......... .......... .......... .......... ..... ៣៥៨

អដ្ឋកថាពុទ្ធសញ្ញកត្ថេរាបទាន .......... .......... .......... .......... ..... ៣៦១

កិសទាយកត្ថេរាបទានទី ៣ .......... .......... .......... .......... ..... ៣៦២
អដ្ឋកថាកិសទាយកត្ថេរាបទាន .......... .......... .......... .......... ..... ៣៦៤
ញាណត្ថវិកត្ថេរាបទានទី ៤ .......... .......... .......... .......... ..... ៣៦៥
ចន្ទនមាលិយត្ថេរាបទានទី ៥ .......... .......... .......... .......... ..... ៣៦៨
ធាតុបូជកត្ថេរាបទានទី ៦ .......... .......... .......... .......... ..... ៣៧២
អដ្ឋកថាញាណត្ថវិកត្ថេរាបទានជាដើម .......... .......... .......... .......... ..... ៣៧២
បុឡិនុប្បាទកត្ថេរាបទានទី ៧ .......... .......... .......... .......... ..... ៣៧៣
អដ្ឋកថាបុឡិនុប្បាទកត្ថេរាបទានទី ៧ .......... .......... .......... .......... ..... ៣៧៧
តរណិយត្ថេរាបទានទី ៨ .......... .......... .......... .......... ..... ៣៧៨
អដ្ឋកថាតរណិយត្ថេរាបទានទី ៨ .......... .......... .......... .......... ..... ៣៨០
ធម្មរុចិត្ថេរាបទានទី ៩ .......... .......... .......... .......... ..... ៣៨១
អដ្ឋកថាធម្មរុចិត្ថេរាបទាន .......... .......... .......... .......... ..... ៣៨៤
សាលមណ្ឌបិយត្ថេរាបទានទី ១០ .......... .......... .......... .......... ..... ៣៨៧
អដ្ឋកថាសាលមណ្ឌបិយត្ថេរាបទាន .......... .......... .......... .......... ..... ៣៩០

## កិំកណិបុប្ផវគ្គ ទី ៥០

តីណិកិំកណិបុប្ផិយត្ថេរាបទានទី ១ .......... .......... .......... .......... ..... ៣៩១
បង្សុកូលបូជកត្ថេរាបទានទី ២ .......... .......... .......... .......... ..... ៣៩២
កោរណ្ឌបុប្ផិយត្ថេរាបទានទី ៣ .......... .......... .......... .......... ..... ៣៩៣
កិំសុកបុប្ផិយត្ថេរាបទានទី ៤ .......... .......... .......... .......... ..... ៣៩៤
ឧបឌ្ឍទុស្សទាយកត្ថេរាបទានទី ៥ .......... .......... .......... .......... ..... ៣៩៥
ឃតមណ្ឌទាយកត្ថេរាបទានទី ៦ .......... .......... .......... .......... ..... ៣៩៦
ឧទកទាយកត្ថេរាបទានទី ៧ .......... .......... .......... .......... ..... ៣៩៧
បុឡិនថូបិយត្ថេរាបទានទី ៨ .......... .......... .......... .......... ..... ៣៩៨

នឡកុដិកទាយកត្ថេរាបទានទី ៩ .......... .......... .......... .......... ..... ៤០២
បិយាលផលទាយកត្ថេរាបទានទី ១០ .......... .......... .......... .......... ..... ៤០៣
អដ្ឋកថាកិង្កណិបុប្ផិយវគ្គទី ៥០ ........ .......... .......... .......... ..... ៤០៦

## កណិការវគ្គ ទី ៥១

តីណិកណិការបុប្ផិយត្ថេរាបទានទី ១ .......... .......... .......... .......... ..... ៤០៧
ឯកបត្តទាយកត្ថេរាបទានទី ២ .......... .......... .......... .......... ..... ៤១១
កាសុមារិកផលទាយកត្ថេរាបទានទី ៣ .......... .......... .......... .......... ..... ៤១២
អវដផលិយត្ថេរាបទានទី ៤ .......... .......... .......... .......... ..... ៤១៣
ចារផលិយត្ថេរាបទានទី ៥ .......... .......... .......... .......... ..... ៤១៤
មាតុលុង្គផលទាយកត្ថេរាបទានទី ៦ .......... .......... .......... .......... ..... ៤១៥
អជេ្ជលផលទាយកត្ថេរាបទានទី ៧ .......... .......... .......... .......... ..... ៤១៦
អមោរផលិយត្ថេរាបទានទី ៨ .......... .......... .......... .......... ..... ៤១៧
តាលផលិយត្ថេរាបទានទី ៩ .......... .......... .......... .......... ..... ៤១៨
នាលិកេរផលទាយកត្ថេរាបទានទី ១០ .......... .......... .......... .......... ..... ៤១៩
អដ្ឋកថាកណិការវគ្គទី ៥១ .......... .......... .......... .......... ..... ៤២០

## ផលទាយកវគ្គ ទី ៥២

កុរញ្ជិយផលទាយកត្ថេរាបទានទី ១ .......... .......... .......... .......... ..... ៤២១
កបិដ្ឋផលទាយកត្ថេរាបទានទី ២ .......... .......... .......... .......... ........ ៤២២
កោសុម្ពផលិយត្ថេរាបទានទី ៣ .......... .......... .......... .......... ........ ៤២២
កេតកបុប្ផិយត្ថេរាបទានទី ៤ .......... .......... .......... .......... ........ ៤២៣
នាគបុប្ផិយត្ថេរាបទានទី ៥ .......... .......... .......... .......... ........ ៤២៤
អជ្ជុនបុប្ផិយត្ថេរាបទានទី ៦ .......... .......... .......... .......... ........ ៤២៥
កុដជបុប្ផិយត្ថេរាបទានទី ៧ .......... .......... .......... .......... ........ ៤២៦

ឃោសសញ្ញកត្ថេរាបទានទី ៨ .......... .......... .......... .......... ........ ៤២៧
សព្វផលទាយកត្ថេរាបទានទី ៩ .......... .......... .......... .......... ........ ៤២៨
បទុមធារិយត្ថេរាបទានទី ១០ .......... .......... .......... .......... ........ ៤៣០
អដ្ឋកថាផលទាយកវគ្គទី ៥២ .......... .......... .......... .......... ........ ៤៣២

## តិណទាយកវគ្គ ទី ៥៣

តិណមុដ្ឋិទាយកត្ថេរាបទានទី ១ .......... .......... .......... .......... ........ ៤៣៣
វេច្ចកទាយកត្ថេរាបទានទី ២ .......... .......... .......... .......... ........ ៤៣៤
សរណគមនិយត្ថេរាបទានទី ៣ .......... .......... .......... .......... ........ ៤៣៦
អព្ភញ្ជនទាយកត្ថេរាបទានទី ៤ .......... .......... .......... .......... ........ ៤៣៧
សុបដទាយកត្ថេរាបទានទី ៥ .......... .......... .......... .......... ........ ៤៣៨
ទណ្ឌទាយកត្ថេរាបទានទី ៦ .......... .......... .......... .......... ........ ៤៣៩
គិរិនេលបូជកត្ថេរាបទានទី ៧ .......... .......... .......... .......... ........ ៤៤០
ពោធិសម្មជ្ជកត្ថេរាបទានទី ៨ .......... .......... .......... .......... ........ ៤៤១
អាមណ្ឌផលទាយកត្ថេរាបទានទី ៩ .......... .......... .......... .......... ........ ៤៤៣
សុគន្ធត្ថេរាបទានទី ១០ .......... .......... .......... .......... ........ ៤៤៤
អដ្ឋកថាតិណទាយកវគ្គទី ៥៣ .......... .......... .......... .......... ........ ៤៥០

## កច្ចាយនវគ្គ ទី ៥៤

មហាកច្ចាយនត្ថេរាបទានទី ១ .......... .......... .......... .......... ........ ៤៥១
អដ្ឋកថាកច្ចាយនត្ថេរាបទាន .......... .......... .......... .......... ........ ៤៥៤
វក្កលិត្ថេរាបទានទី ២ .......... .......... .......... .......... ........ ៤៥៧
អដ្ឋកថាវក្កលិត្ថេរាបទាន .......... .......... .......... .......... ........ ៤៦២
មហាកប្បិនត្ថេរាបទានទី ៣ .......... .......... .......... .......... ........ ៤៧០
អដ្ឋកថាមហាកប្បិនត្ថេរាបទាន .......... .......... .......... .......... ........ ៤៧៥

ទព្វមល្ហបុត្តត្ថេរាបទានទី ៤ .......... .......... .......... .......... .......... ៤៩៥
អដ្ឋកថាទព្វមល្ហបុត្តត្ថេរាបទាន .......... .......... .......... .......... .......... ៥០០
កុមារកស្សបត្ថេរាបទានទី ៥ .......... .......... .......... .......... .......... ៥០៦
អដ្ឋកថាកុមារកស្សបត្ថេរាបទាន .......... .......... .......... .......... .......... ៥១០
ពាហិយត្ថេរាបទានទី ៦ .......... .......... .......... .......... .......... ៥១៤
អដ្ឋកថាពាហិយត្ថេរាបទាន .......... .......... .......... .......... .......... ៥១៩
មហាកោដ្ឋិកត្ថេរាបទានទី ៧ .......... .......... .......... .......... .......... ៥៣២
អដ្ឋកថាមហាកោដ្ឋិកត្ថេរាបទាន .......... .......... .......... .......... .......... ៥៣៥
ឧរុវេលកស្សបត្ថេរាបទានទី ៨ .......... .......... .......... .......... .......... ៥៣៩
អដ្ឋកថាឧរុវេលកស្សបត្ថេរាបទាន .......... .......... .......... .......... .......... ៥៤៤
រាធត្ថេរាបទានទី ៩ .......... .......... .......... .......... .......... ៥៤៨
អដ្ឋកថារាធត្ថេរាបទាន .......... .......... .......... .......... .......... ៥៥២
មោឃរាជត្ថេរាបទានទី ១០ .......... .......... .......... .......... .......... ៥៥៣
អដ្ឋកថាមោឃរាជត្ថេរាបទាន .......... .......... .......... .......... .......... ៥៥៧

## កុណ្ឌិយវគ្គ ទី ៥៥

លកុណ្ឌកភទ្ទិយត្ថេរាបទានទី ១ .......... .......... .......... .......... .......... ៥៥៨
អដ្ឋកថាលកុណ្ឌកភទ្ទិយត្ថេរាបទាន .......... .......... .......... .......... .......... ៥៦២
កង្ខារេវតត្ថេរាបទានទី ២ .......... .......... .......... .......... .......... ៥៦៥
អដ្ឋកថាកង្ខារេវតត្ថេរាបទាន .......... .......... .......... .......... .......... ៥៦៨
សីវលិត្ថេរាបទានទី ៣ .......... .......... .......... .......... .......... ៥៦៩
អដ្ឋកថាសីវលិត្ថេរាបទាន .......... .......... .......... .......... .......... ៥៧៤
វង្គីសត្ថេរាបទានទី ៤ .......... .......... .......... .......... .......... ៥៩១
អដ្ឋកថាវង្គីសត្ថេរាបទាន .......... .......... .......... .......... .......... ៥៩៧

នទូកត្ថេរាបទានទី ៥ .......... .......... .......... .......... ......... ៦០៤
អដ្ឋកថានទូកត្ថេរាបទាន .......... .......... .......... .......... ......... ៦០៧
កាឡុទាយិត្ថេរាបទានទី ៦ .......... .......... .......... .......... ......... ៦០៨
អដ្ឋកថាកាឡុទាយិត្ថេរាបទាន .......... .......... .......... .......... ......... ៦១២
អភយត្ថេរាបទានទី ៧ .......... .......... .......... .......... ......... ៦៣១
អដ្ឋកថាអភយត្ថេរាបទាន .......... .......... .......... .......... ......... ៦៣៥
លោមសកិយត្ថេរាបទានទី ៨ .......... .......... .......... .......... ......... ៦៣៧
អដ្ឋកថាលោមសកិយត្ថេរាបទាន .......... .......... .......... .......... ......... ៦៤០
វនវច្ឆត្ថេរាបទានទី ៩ .......... .......... .......... .......... ......... ៦៤៣
អដ្ឋកថាវនវច្ឆត្ថេរាបទាន .......... .......... .......... .......... ......... ៦៤៥
ចូឡសុគន្ធត្ថេរាបទានទី ១០ .......... .......... .......... .......... ......... ៦៤៧
អដ្ឋកថាចូឡសុគន្ធត្ថេរាបទាន .......... .......... .......... .......... ......... ៦៥២

## សុត្តន្តបិដក ចាលីប្រែ -៧៦

## សុមេធាវគ្គ ទី ១

សុមេធាថេរិយាបទានទី ១ .......... .......... .......... .......... ......... ៦៥៤
មេខលទាយិកាថេរិយាបទានទី ២ .......... .......... .......... ............... ៦៥៧
មណ្ឌបទាយិកាថេរិយាបទានទី ៣ .......... .......... .......... ............... ៦៥៨
សង្កមនទាថេរិយាបទានទី ៤ .......... .......... .......... ............... ៦៥៩
នឡមាលិកាថេរិយាបទានទី ៥ .......... .......... .......... ............... ៦៦០
ឯកបិណ្ឌបាតទាយិកាថេរិយាបទានទី ៦ .......... .......... .......... ............... ៦៦១
កដច្ឆុភិក្ខទាយិកាថេរិយាបទានទី ៧ .......... .......... .......... ............... ៦៦៣
សត្តឧប្បលមាលិកាថេរិយាបទានទី ៨ .......... .......... .......... ............... ៦៦៤
បញ្ចទីបិកាថេរិយាបទានទី ៩ .......... .......... .......... ............... ៦៦៦

ឧទកទាយិកាថេរិយាបទានទី ១០ .......... .......... .......... ............... ៦៦៩

## ឯកុបោសថវគ្គ ទី ២

ឯកុបោសថិកាថេរិយាបទានទី ១ .......... .......... .......... ............... ៦៧១
សលឡបុប្ផិកាថេរិយាបទានទី ២ .......... .......... .......... ............... ៦៧៣
មោទកទាយិកាថេរិយាបទានទី ៣ .......... .......... .......... ............... ៦៧៤
ឯកាសនទាយិកាថេរិយាបទានទី ៤ .......... .......... .......... ............... ៦៧៥
បញ្ចទីបទាយិកាថេរិយាបទានទី ៥ .......... .......... .......... ............... ៦៧៧
នឡមាលិកាថេរិយាបទានទី ៦ .......... .......... .......... ............... ៦៨០
មហាបជាបតិគោតមីថេរិយាបទានទី ៧ .......... .......... .......... ............... ៦៨១
ខេមាថេរិយាបទានទី ៨ .......... .......... .......... ............... ៧០៣
ឧប្បលវណ្ណាថេរិយាបទានទី ៩ .......... .......... .......... ............... ៧១៤
បដាចារាថេរិយាបទានទី ១០ .......... .......... .......... ............... ៧២៣

## កុណ្ឌលកេសវគ្គ ទី ៣

កុណ្ឌលកេសីថេរិយាបទានទី ១ .......... .......... .......... ............... ៧២៨
កិសាគោតមីថេរិយាបទានទី ២ .......... .......... ....... ៧៣៤
ធម្មទិន្នាថេរិយាបទានទី ៣ .......... .......... ....... ៧៣៩
សកុលាថេរិយាបទានទី ៤ .......... .......... ....... ៧៤៣
នន្ទាថេរិយាបទានទី ៥ .......... .......... ....... ៧៤៧
សោណាថេរិយាបទានទី ៦ .......... .......... ....... ៧៥៣
កទ្ទកាបិលានីថេរិយាបទានទី ៧ .......... .......... ....... ៧៥៦
យសោធរាថេរិយាបទានទី ៨ .......... .......... ....... ៧៦៣
ទសសហស្សថេរីនមបទានទី ៩ .......... .......... ....... ៧៧៣
អដ្ឋារសថេរីសហស្សានមបទានទី ១០ .......... .......... ....... ៧៧៥

# ខត្តិយកញ្ញាវគ្គ ទី ៤

អង្គារសេសហស្សខត្តិយកញ្ញាថេរីនមថេរិយាបទាន ១ .......... .......... ....... ៧៨៣
ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទានទី ២ .......... .......... ....... ៧៨៥
ឧប្បលទាយិកាថេរិយាបទានទី ៣ .......... .......... ....... ៧៩០
សិង្គាលមាតាថេរិយាបទានទី ៤ .......... .......... ....... ៧៩៣
សុក្កាថេរិយាបទានទី ៥ .......... .......... ....... ៧៩៦
អភិរូបនន្ទាថេរិយាបទានទី ៦ .......... .......... ....... ៨០០
អឌ្ឍកាសីថេរិយាបទានទី ៧ .......... .......... ....... ៨០៣
បុណ្ណិកាថេរិយាបទានទី ៨ .......... .......... ....... ៨០៤
អម្ពបាលីថេរិយាបទានទី ៩ .......... .......... ....... ៨០៧
សេលាថេរិយាបទានទី ១០ .......... .......... ....... ៨០៩